# អដ្ឋកថា ព្រះសុត្តន្តបិដក

## ធម្មបទដ្ឋកថា
## ទុតិយភាគ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៨

# អដ្ឋកថា ព្រះសុត្តន្តបិដក

## ខុទ្ទកនិកាយ គាថាធម្មបទ

ឈ្មោះ

## ធម្មបទដ្ឋកថា

## ទុតិយភាគ

## ភាគ ៥២

ពុទ្ធសករាជ ២៥៥៨

អធិប្បាយ

គាថាធម្មបទ មាន ៥ វគ្គ

បុប្ផវគ្គ ពាលវគ្គ បណ្ឌិតវគ្គ អរហន្តវគ្គ សហស្សវគ្គ

# គាថាធម្មបទ

## ទុតិយភាគ រួមមាន ៥ វគ្គ

### ១-បុប្ផវគ្គ មាន ១២ រឿង

១.រឿងភិក្ខុ ៥០០ រូប
២.រឿងព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន
៣.រឿងព្រះបាទវិឌូឌភៈ
៤.រឿងនាងបតិបូជិកា
៥.រឿងកោសិយសេដ្ឋី
៦.រឿងបាជិកាជីវក
៧.រឿងឆត្តបាណិឧបាសក
៨.រឿងនាងវិសាខា
៩.រឿងបញ្ហាព្រះនន្ទត្ថេរៈ
១០.រឿងការថ្វាយបិណ្ឌបាតដល់ព្រះមហាកស្សបៈ
១១.រឿងការបរិនិព្វានរបស់ព្រះគោធិកៈ
១២.រឿងគរហទិន្នៈ

### ២-ពាលវគ្គ មាន ១៥ រឿង

១.រឿងបុរសម្នាក់
២.រឿងសិស្សរបស់ព្រះមហាកស្សបៈ
៣.រឿងអានន្ទសេដ្ឋី
៤.រឿងចោរទម្លាយបង្វេច
៥.រឿងព្រះឧទាយី
៦.រឿងភិក្ខុអ្នកក្រុងបាដ្ឋា
៧.រឿងសុប្បពុទ្ធកុដ្ឋិ
៨.រឿងអ្នកស្រែ
៩.រឿងនាយសុមនមាលាការ
១០.រឿងព្រះនាងឧប្បលវណ្ណា
១១.រឿងជម្ពុកាជីវក
១២.រឿងអហិប្រេត
១៣.រឿងសដ្ឋិកូដប្រេត
១៤.រឿងព្រះសុធម្មត្ថេរៈ
១៥.រឿងព្រះវនវាសីតិស្សៈ

### ៣-បណ្ឌិតវគ្គ មាន ១១ រឿង

១.រឿងព្រះរាធៈ
២.រឿងភិក្ខុអស្សជិ និងបុនព្វសុក
៣.រឿងព្រះឆន្នត្ថេរ
៤.រឿងព្រះមហាកប្បិន
៥.រឿងបណ្ឌិតសាមណេរ
៦.រឿងព្រះលកុណ្ឌកភទ្ទិយៈ
៧.រឿងមាតារបស់នាងកាណា
៨.រឿងភិក្ខុ ៥០០ រូប
៩.រឿងព្រះថេរៈតាំងនៅក្នុងធម៌
១០.រឿងការស្តាប់ធម៌
១១.រឿងភិក្ខុអាគន្តុកៈ

## ៤-អរហន្តវគ្គ មាន ១០ រឿង

១.រឿងពេទ្យជីវក

២.រឿងព្រះមហាកស្សបត្ថេរ

៣.រឿងព្រះពេឡដ្ឋសីសៈ

៤.រឿងព្រះអនុរុទ្ធ

៥.រឿងព្រះមហាកច្ចាយនៈ

៦.រឿងព្រះសារីបុត្រ

៧.រឿងព្រះតិស្សអ្នកក្រុងកោសម្ពី

៨.រឿងព្រះសារីបុត្រ

៩.រឿងព្រះខទិរវនិយរេវតៈ

១០.រឿងស្ត្រីម្នាក់

## ៥-សហស្សវគ្គ មាន ១៤ រឿង

១.រឿងបុរសពុកមាត់ក្រហម

២.រឿងព្រះទារុចីរិយៈ

៣.រឿងព្រះនាងកុណ្ឌលកេសី

៤.រឿងអនត្ថបុច្ឆកព្រាហ្មណ៍

៥.រឿងព្រាហ្មណ៍ជាឪពុកមាព្រះសារីបុត្រ

៦.រឿងព្រាហ្មណ៍ជាក្មួយព្រះសារីបុត្រ

៧.រឿងព្រាហ្មណ៍ជាសំឡាញ់ព្រះសារីបុត្រ

៨.រឿងអាយុវឌ្ឍនកុមារ

៩.រឿងសង្កិច្ចសាមណេរ

១០.រឿងព្រះខាណុកោណ្ឌញ្ញៈ

១១.រឿងសប្បទាសៈ

១២.រឿងព្រះនាងបដាចារា

១៣.រឿងព្រះនាងកិសាគោតមី

១៤.រឿងព្រះនាងពហុបុត្តិកាថេរី

# ស្រៈនិងសៀយ

# *Signes et accents.*



# ស្រះពេញតួ

# Voyelles.

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| រូម Romain | a | . ā | i | i | u | ū | e | o |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ព្យញ្ជនៈ
# *Consonnes:*

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ក | ខ | គ | ឃ | ង |
| អឺរ៉ុប Romain | *k* | *kh* | *g* | *gh* | *ṅ* |
| សៀម Siamois | ก | ข | ค | ฆ | ง |
| លាវ Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ច | ឆ | ជ | ឈ | ញ |
| រ៉ូម Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម Siamois | จ | ฉ | ช | ฌ | ญ |
| លាវ Laotien | ຈ | ຉ | ຊ | ຌ | ຎ |
| សង្ហ Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| ឡាតាំង Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សិង្ហ Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត្ត | ថ្ថ | ទ្ទ | ធ្ធ | ន្ន |
| រ៉ូម Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| ឡាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| លង្កា Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប្ប | ផ្ផ | ព្ព | ភ្ភ | ម្ម |
| រ៉ូម Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ບ | ຜ | ພ | ຠ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ | រ | ល | វ | ស | ហ | ឡ | ំ | ។ |
| រូម Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ·/. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| សិង្ហល Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | । |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | ။ |

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេងៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធៗ ដែលមិនមានឈ្មោះ ពោលដល់ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

***ឥតិវុត្តក*** *គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ ដែលមានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភុតធម្ម*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភុតធម្មទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដីរីករាយ និងសួរជាបន្តៗ ទៅ ។*

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម
ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត
មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល
បណ្ឌិតគប្បីដឹងបាន ។

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹង នូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេងៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣ ប្រការ គឺ ៖

១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

២ ទ្រង់សម្តែងធម៌មានហេតុផល ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ គឺ អ្នកប្រតិបត្តិតាម នឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេងៗ គ្នា មានសីល និងទិដ្ឋិផ្សេងៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងមានឧស្សាហៈដ៏ខ្លាំង-ក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដក នូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

១ **ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

២ **សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

៣ **អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេងៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង

បុព្វាចារ្យជំនាន់ក្រោយៗ ។

៤ **អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិទៅតាមមតិរបស់ខ្លួនឯងដោយច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនាដែលមានគោលសំខាន់ គឺ ព្រះត្រៃ-បិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសាបាលីដែលប្រែចេញមកហើយលំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។ ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះមានឱកាសដែលយល់ខុស និយាយខុស និងបដិបត្តិខុស ។

ព្រះត្រៃបិដកប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋ-ធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាស-និកជនដែលល្អប្រកាន់ថា ធ្វើមិនបានដូចគ្នា ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ

របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ

សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់

ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមាន-ព្រះភាគជាម្ចាស់ ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈក្រោមដើមបារិចត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្តាប់វត្ថុ ១០ ប្រការនោះហើយ បានកាន់យកព្រះចៅអសោករាជដែលជាព្រះឱរសរបស់ព្រះចៅសុសុនាគៈធ្វើជាសម្ពាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ (ដប់ពីរសែន) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសវីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ តិះដៀលហើយ ទើបស្វែងរកពួកគណៈ លុះបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់គ្រូកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីគ្រូកូលអាចារ្យសង្ឃិកៈនោះ ។ គ្រូកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀត ឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះៗ ឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ គ្រូកូលអាចារ្យទាំងប្រាំ បានកើតឡើងពីគ្រូកូលអាចារ្យមហាសង្ឃិកៈ ដោយប្រការដូច្នេះ ។

គ្រូកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជាប្រាំមួយ

ត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និង វជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធ-សករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈ កើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈ ផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយនោះ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្ដី ត្រកូលអាចារ្យ ១៨ ក្ដី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយនោះឯង ។ម្យ៉ាងទៀត បណ្ដានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

## តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




*ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្ត ជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបណ្ដេញចេញហើយ បានពួកដទៃ ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ*

*(ស្រង់ចេញពីអដ្ឋកថាបរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ)*

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បាន ប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ភិក្ខុមាន នាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងគម្ពីរនេះឡើង (គម្ពីរ អដ្ឋសាលិនី) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យ នោះ ក៏នៅមានព្រះពុទ្ធឃោសៈ អារាធនាឲ្យព្រះពុទ្ធឃោសៈតែងគម្ពីរនេះ ជា ដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការ កសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធឃោសាចារ្យជាអ្នកស្រុក ជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទី ត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍សាស្ត្រ ទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេងៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហា ជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នកមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍ កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែល សមណព្រាហ្មណ៍ និងបណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមាន ឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតអស់ទាំងសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្សំមកដល់វត្តមួយ ដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតៈដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមក ដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទ ដែលខ្លួននៅមានការសង្ស័យមិនយល់ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមក ព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះៗ ព្រាហ្មណ៍កំលោះឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជា ឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា **ព្រះពុទ្ធឃោសៈ** ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្តនាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីប មានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែនៅក្នុងលង្កាទ្វីបនៅមាន ព្រោះព្រះថេរៈទាំងឡាយ មានព្រះសារីបុត្ត (ឈ្មោះដូចអគ្គសាវ័ក) ជាដើមបានរចនាទុក និងតមក ព្រះមហិន្ទត្ថេរបានត្រួតពិនិត្យ ហើយរចនាទុកជា

ភាសាសីហឡ: សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរដែលបាននិមន្តជ្រួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះគឺ ជាកាលរបស់ក្សត្រិយ៍លង្កាទ្រង់ព្រះនាមថា **មហានាម** មាននាមដទៃទៀតថា (សិរិនិវាស) ខ្វះ (សិរិកុថៈ) ខ្វះ (សិរិកូដ្ឋៈ) ខ្វះ ក្នុងពុទ្ធសករាជ (៩៥២-៩៧៤) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡ: និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថាជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថា ឲ្យលោករចនាជាមុន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយ

ថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្ដាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្ដងទៀត ទេវតាក៏បណ្ដាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្ដងទៀត គម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀប គ្នាហើយ មិនមានការខុសគ្នា ទាំងដោយព្រះគម្ពីរឬអក្ខរៈ ឬដោយបទ ឬដោយ ព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុង ឬដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយក្នុងកន្លែងណាទីមួយឡើយទាំងបីច្បាប់ដូចគ្នា ដើម្បីសម្ដែងសេចក្ដីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយក៏បានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារ បានឃើញសេចក្ដីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរសោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះ ជាព្រះមេត្តេយ្យពោធិ-សត្វពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរពីភាសាសីហឡៈ មកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះមហានាមក្សត្រិយ៍នៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា ព្រះមហិន្ទត្ថេរនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈ ឈ្មោះ **មហា-អដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ (ផ្ទះទឹក) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុ-វិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋ-កថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចកវណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្ម ទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលបញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេងៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យដ៏សំខាន់ក្រៃលែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស
លោកគ្រូធម្មបណ្ឌិត រស់ សុជាត
លោកគ្រូវិនិយាចារ្យ គាំ អ៊ុវ

ឧបាសក ក្អាត ហ៊ិន
ឧបាសក ណាក់ ម៉ៅ
ឧបាសក ធុំ ធួន
ឧបាសក ហុក សីហ្វូត
ឧបាសក ជីម ជំនិត
ឧបាសក កើត និត្យ
ឧបាសក សន ម៉ារឌី
ឧបាសក ហាយ ចំរើន
ឧបាសក អ៊ឹម វ៉ៃយ៉ា
ឧបាសក សុក្រ ហ៊ិត
ឧបាសក សោម រតនៈ
ឧបាសក សំ ធាយ
ឧបាសក ម៉ៅ ឌុន
ឧបាសក ជា ស៊ីថាន
ឧបាសិកា ថាប់ លឿម
ឧបាសិកា ហាយ សារ៉ាត់
ឧបាសិកា ប៊ុត សុម៉ាលី
ឧបាសិកា យស សម្បត្តិ
ឧបាសិកា ពូ ហ៊ាង
ឧបាសិកា ប៊ុត សេដាឌួង
ឧបាសិកា ប៉ែន រមណី

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គធិន្នោ នូវ ប៉ូប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុធម្មប្បញ្ញោ ជុំ សារឿន ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ជុត តៅ ធម្មាចារ្យ

ព្រះភិក្ខុតេជធរោ ធាវ ធាន ធម្មាចារ្យ

សាមណេរ កោវិទោ ឡោះស្វៀត សមណសិស្សសាលាសតិប្បដ្ឋាន

ផ្នែកឧបាសក

ឧបាសក ហាយ ចំរើន

ឧបាសក ជឹម ជំនិត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បី

បូជាចំពោះព្រះរតនត្រៃ មួយវិញទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់៥.០០០ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះៈ-

ឧទ្ទិសថ្វាយ និងគោរពជូនៈ

-ព្រះមហាវរក្សត្រិយ៍ និងមហាវរក្សត្រិយានី

-ព្រះមហាក្សត្រិយ៍នៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុជាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះ

សូមអនុមោទនា ។.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

**ឈ្មោះធម៌** **ទំព័រ**

## បុប្ផវគ្គទី ៤


១–រឿងភិក្ខុ៥០០រូប ខំរៀនកម្មដ្ឋានបបរិកថា ១

–ការច្រាសព្រៃដែនដីខាងក្នុង ១

–អធិប្បាយគាថា ៣

២–រឿងព្រះថេរៈអ្នកចម្រើនមរីចិកម្មដ្ឋាន ៦

–ព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន ៦

–ទ្រង់ប្រៀបរូបដូចពពុះទឹកនិងថ្ងៃបណ្តើរកូន ៧

–អធិប្បាយគាថា ៧

៣–រឿងព្រះបាទវិឌូឌភៈ ៩

–ព្រះកុមារ ៣ អង្គ ទៅសិក្សាសិល្បៈ ៩

–ព្រះរាជាថ្វាយភត្តដល់ភិក្ខុសង្ឃ ១១

–បុគ្គលមានបុណ្យរមែងធ្វូន់ក្នុងហេតុ ១៣

–ត្រកូលដែលភិក្ខុគួរចូលទៅនិងមិនគួរ ១៤

–រឿងកេសវតាបស ១៦

–ព្រះរាជាបញ្ជូនដំណឹងទៅសូមធីតាសក្យរាជ ២០

–សក្យរាជឲ្យធីតានាងទាសីដល់ព្រះបាទបសេនទិ ២១

–ព្រះកុមារបានព្រះនាមថាវិឌូឌភៈ ២៣

–វិឌូឌភៈទៅសួរសុខទុក្ខសក្យត្រកូល ២៣

–ពួកសក្យៈទទួលវិឌូឌភៈ ២៤

–វិឌូឌភៈចងអាឃាតនឹងពួកសក្យៈ ២៥

–ពន្ធុលសេនាបតី ២៧

-ពន្ធុលសេនាបតីត្រូវសម្លាប់ជាមួយនឹងបុត្រ ៣២
-ព្រះនាងមល្លិកាទេវីមិនទោមនស្ស ៣៣
-ព្រះរាជាសោយទីវង្គត ៣៦
-ព្រះចាទវិឌូឌភៈទៅគាល់ព្រះសាស្តា ៣៧
-ព្រះចាទវិឌូឌភៈសម្លាប់ពួកសក្យៈ ៣៨
-មានះរបស់ក្សត្រ ៤១
-ព្រះចាទវិឌូឌភៈសោយទីវង្គតព្រោះទឹកជំនន់ ៤២
-សក្យត្រកូលស្លាប់សមគួរដល់បុព្វកម្ម ៤៣
-អធិប្បាយគាថា ៤៤
៤-រឿងនាងបតិបូជិកា ៤៧
-ទេពធីតាចុតិទៅកើតក្នុងក្រុងសាវត្ថី ៤៧
-ចុតិពីមនុស្សលោកទៅកើតក្នុងស្ថានសួគ៌ ៤៨
-អាយុរបស់មនុស្សប្រមាណ ១០០ ឆ្នាំ ៤៨
-១០០ ឆ្នាំ មនុស្ស ស្មើ ១ថ្ងៃស្ថានសួគ៌ ៥០
-អធិប្បាយគាថា ៥២
៥-រឿងកោសិយសេដ្ឋីកំណាញ់ ៥៤
-សម្បត្តិរបស់សេដ្ឋីមិនមានប្រយោជន៍ដល់... ៥៤
-សេដ្ឋីចង់បរិភោគនំអំបែងរហូតស្គម ៥៤
-ព្រះមហាមោគ្គល្លានទូន្មានសេដ្ឋី ៥៨
-ព្រះថេរៈនាំសេដ្ឋី និងភរិយាទៅគាល់ព្រះសាស្តា ៦១
-ពួកភិក្ខុសរសើរព្រះថេរៈ ៦៣
-អធិប្បាយគាថា ៦៤
៦-រឿងចាជិកាជីវក ៦៧
-អ្នកស្រុកសរសើរព្រះធម៌ទេសនារបស់ព្រះសាស្តា ៦៧
-ព្រះសាស្តាយាងទៅកាន់ផ្ទះឧចាសិកា ៦៩

-ឧបាសិកាស្តាប់ធម៌ត្រូវអាជីវកជេរ ៧០

-អធិប្បាយគាថា ៧១

៧-រឿងឆត្តបាណិឧបាសក ៧៤

-ឆត្តបាណិមិនក្រោកទទួលព្រះបាទបសេនទិ ៧៤

-ព្រះរាជាត្រាស់សួរការមិនក្រោកទទួល ៧៦

-ព្រះអានន្ទបង្រៀនព្រះទេវីទាំងពីរអង្គ ៧៨

-វាចាសុភាសិតរមែងមានផលដល់អ្នកបដិបត្តិ ៧៩

-អធិប្បាយគាថា ៨០

៧-រឿងនាងវិសាខា ៨២

-អ្នកមានបុណ្យទាំង ៥ នាក់ក្នុងភទ្ទិយនគរ ៨២

-អ្នកមានក្នុងដែនព្រះបាទពិម្ពិសារ ៥ នាក់ ៨២

-អ្នកមានសម្បត្តិស្តុកស្តម្ភ ៥ នាក់ ៨៣

-មេណ្ឌកសេដ្ឋីឱ្យនាងវិសាខាទៅទួលព្រះសាស្តា ៨៣

-ព្រះបាទបសេនទិចង់បានអ្នកមានបុណ្យ ៨៤

-ឱ្យធនញ្ជ័យសេដ្ឋីដល់ព្រះបាទកោសល ៨៥

-ការកសាងក្រុងសាកេត ៨៦

-លក្ខណៈបញ្ចកល្យាណី ៨៧

-សេដ្ឋីបញ្ជូនព្រាហ្មណ៍ឱ្យស្វែងរកស្ត្រីបញ្ច... ៨៨

-ព្រាហ្មណ៍ជួបនាងវិសាខា ៨៩

-ជន ៤ ជំពូករត់មិនល្អ ៩០

-ធនញ្ជ័យ និងពីតាចាត់ចែងទីទទួល ៩៤

-គ្រឿងប្រដាប់មហាលតាបសាធន៍ ៩៥

-ស្ត្រីថ្វាយចីវររមែងបានមហាលតាបសាធន៍ ៩៨

-សេដ្ឋីចាត់ចែងទេយ្យធម៌ឱ្យនាងវិសាខា ៩៨

-ឱវាទ ១០ ប្រការ របស់សេដ្ឋី ១០១

-នាងវិសាខាទៅដល់ក្រុងសាវត្ថី ១០៣

-នាវិសាខាថាឪពុកក្មេកបរិភោគរបស់ចាស់ ១០៦

-អធិប្បាយឱវាទ ១០ ប្រការ ១០៨

-មិគារសេដ្ឋីសូមទោសនាងវិសាខា ១១២

-មិគារសេដ្ឋីស្តាប់ធម៌ព្រះសាស្តា ១១៣

-នាងវិសាខាបាននាមថា មិគារមាតា ១១៤

-មិគារសេដ្ឋីធ្វើគ្រឿងប្រដាប់ឱ្យនាងវិសាខា ១១៦

-នាងវិសាខាមានកម្លាំងស្មើដំរី ៥ ១១៦

-នាងវិសាខាភ្លេចគ្រឿងប្រដាប់ឯវិហារ ១១៨

-នាងវិសាខាសាងវិហារថ្វាយសង្ឃ ១២១

-ការសាងវិហារ ៩ ខែ ទើបហើយ ១២៣

-នាងវិសាខាធ្វើបុណ្យឆ្លងវិហារ ១២៥

-នាងវិសាខាបន្លឺឧទានក្នុងថ្ងៃឆ្លងវិហារ ១២៧

-បុព្វប្រវត្តិរបស់នាងវិសាខា ១២៨

-សត្វកើតហើយ គប្បីធ្វើកុសលឱ្យច្រើន ១៣១

-អធិប្បាយគាថា ១៣២

៩-រឿងបញ្ហារបស់ព្រះអានន្ទ ១៣៤

-ព្រះអានន្ទទូលសួរបញ្ហា ១៣៤

-ព្រះសាស្តាត្រាស់ឆ្លើយបញ្ហា ១៣៥

-អធិប្បាយគាថា ១៣៧

១០-រឿងការថ្វាយបិណ្ឌបាតដល់ព្រះមហាកស្សបៈ ១៣៩

-ទេពធីតាប្រាថ្នាធ្វើបុណ្យ តែមិនសមដូចចិត្ត ១៣៩

-សក្កទេវរាជក្លែងខ្លួនធ្វើបុណ្យដល់ព្រះថេរៈ ១៤០

-សក្កទេវរាជប្រាប់សេចក្តីពិតដល់ព្រះថេរៈ ១៤២

-មហាកស្សបថេរទានសូត្រ ១៤៤

-អធិប្បាយគាថា ១៤៨
១១-រឿងការបរិនិព្វានរបស់ព្រះគោធិកត្ថេរ ១៥០
-ព្រះថេរៈគិតសម្លាប់ខ្លួនព្រោះវិនាសចាកឈាន ១៥០
-មារទូលដល់ព្រះសាស្ដាឱ្យទ្រង់ជ្រាប ១៥០
-មារស្វែងរកវិញ្ញាណរបស់ព្រះគោធិកៈ ១៥១
-អធិប្បាយគាថា ១៥៣
១២-រឿងគរហទិន្នៈ ១៥៥
-ជាសំឡាញ់គ្នាតែជ្រះថ្លាក្នុងវត្ថុមិនដូចគ្នា ១៥៥
-សិរិគុត្តត្រៀមទទួលពួកនិគ្រន្ថ ១៥៧
-ពួកនិគ្រន្ថធ្លាក់រណ្ដៅលាមក ១៦០
-គរហទិន្នៈប្ដឹងសិរីគុត្ត ១៦១
-គរហទិន្នៈសងសឹកនឹងសិរីគុត្ត ១៦២
-គរហទិន្នៈត្រៀមទទួលព្រះសាស្ដា ១៦៥
-គរហទិន្នៈជ្រះថ្លាក្នុងព្រះសាស្ដា ១៦៨
-សត្វមិនដឹងគុណព្រះសាស្ដាព្រោះគ្មានបញ្ញា ១៦៩
-អធិប្បាយគាថា ១៧០
-គរហទិន្នៈ និងសិរីគុត្តលុះព្រះសោតបន្ន ១៧១

## ពាលវគ្គទី ៥

១-រឿងបុរសម្នាក់ ១៧៤
-ព្រះរាជាប្រទក្សិណនគរ ១៧៤
-អំណាចសេចក្ដីស្រឡាញ់ ១៧៤
-សេចក្ដីលំបាកក្នុងរាជសំណាក់ ១៧៧
-ប្រេតដែលពោល ទុ ស: ន: សោ ១៨០
-ព្រាហ្មណ៍លួងឱ្យព្រះរាជាបូជាយញ្ញ ១៨១

-ព្រះនាងមល្លិកាដោះទុក្ខរបស់សត្វ ១៨៣

-ព្រះសាស្តាទ្រង់សម្តែងទោសបរទារិកកម្ម ១៨៥

-អធិប្បាយគាថា ១៩១

-ព្រះនាងមល្លិកាជួយដោះទុក្ខសត្វក្នុងជាតិមុន ១៩៣

-ទេវតាបូជាព្រះនាងធម្មទិន្នា ១៩៦

២-រឿងសទ្ធិវិហារិករបស់ព្រះមហាកស្សបៈ ២០១

-អ្នកខ្ជិលច្រអូសអាងសេចក្តីល្អរបស់អ្នកដទៃ ២០១

-កម្មតាមទាន់ ២០២

-ព្រះថេរៈចាប់សេចក្តីអាក្រក់របស់សិស្សបាន ២០៤

-ប្រទូសអ្នកមានគុណស្លាប់ទៅកើតក្នុងអវិចី ២០៤

-សត្វក្រលេងក្រលោង និងស្វាវិវាទគ្នា ២០៦

-ទ្រង់ប្រជុំជាតក ២០៧

-អធិប្បាយគាថា ២០៨

៣-រឿងអានន្ទសេដ្ឋី ២១១

-អានន្ទសេដ្ឋីទូន្មានបុត្រឱ្យកំណាញ់ ២១១

-អានន្ទសេដ្ឋីស្លាប់ទៅកើតក្នុងត្រកូលចណ្ឌាល ២១២

-មាតាឱ្យបុត្រសូមទានគេដោយខ្លួនឯង ២១៣

-ព្រះសាស្តាសម្តែងធម៌ដល់មូលសិរីសេដ្ឋី ២១៤

-អធិប្បាយគាថា ២១៥

៤-រឿងចោរទម្លាយបង្អួច ២១៨

-ចោរលាក់ទ្រព្យក្នុងថ្នក់សំពត់ ២១៨

-អ្នកដឹងខ្លួនថាជាពាលរមែងជាបណ្ឌិតបាន ២១៩

-អធិប្បាយគាថា ២១៩

៥-រឿងព្រះឧទាយី ២២១

-បុគ្គលល្ងង់ រមែងប្រកាន់ខ្លួន ២២១

-អធិប្បាយគាថា ២២២

៦-រឿងភិក្ខុអ្នកស្រុកចាដ្ឋា ២២៤

-ភិក្ខុសមាទានធុតង្គ ២២៤

-អធិប្បាយគាថា ២២៥

៧-រឿងសុប្បពុទ្ធកុដ្ឋិ ២២៧

-សុប្បពុទ្ធៈក្រាបទូលគុណវិសេសដល់ព្រះសាស្តា ២២៧

-អ្នកមានអរិយទ្រព្យ ៧ មិនមែនជាជនកំសត់ ២២៧

-បុព្វកម្មរបស់សុប្បពុទ្ធៈនិងមេគោ ២២៩

-អធិប្បាយគាថា ២៣១

៨-រឿងអ្នកស្រែ ២៣៣

-ចោរចូលលួចក្នុងត្រកូលស្តុកស្តម្ភ ២៣៣

-ព្រះសាស្តាទ្រង់ជ្រាបឧបនិស្ស័យអ្នកស្រែ ២៣៣

-អ្នកស្រែត្រូវចាប់ប្រហារជីវិត ២៣៥

-អ្នកស្រែរួចទោសព្រោះមានព្រះសាស្តាជាសាក្សី ២៣៦

-មិនគួរធ្វើកម្មដែលឱ្យផលក្តៅក្រហាយខាងក្រោយ ២៣៧

-អធិប្បាយគាថា ២៣៧

៩-រឿងនាយសុមនមាលាការ ២៣៩

-ព្រះសាស្តាស្តេចយាងបិណ្ឌបាត ២៣៩

-នាយមាលាការបូជាព្រះសាស្តាដោយផ្កា ២៤០

-សេចក្តីអស្ចារ្យនៃពុទ្ធបូជា ២៤១

-ភរិយាមិនជ្រះថ្លា ប្តឹងព្រះរាជា ២៤៣

-ព្រះរាជាទ្រង់ធ្វើជាក្រោធ ២៤៤

-ព្រះរាជាទ្រង់ប្រទានរបស់មួយមុខ ៨ យ៉ាង ២៤៥

-ព្រះសាស្តាត្រាស់សរសើរនាយមាលាការ ២៤៦

-មិនគួរធ្វើកម្មក្តៅក្រហាយជាខាងក្រោយ ២៤៧

-អធិប្បាយគាថា ២៨៨
១០-រឿងព្រះនាងឧប្បលវណ្ណាថេរី ២៩០
-ព្រះថេរីតាំងសេចក្ដីប្រាថ្នា ២៩០
-ព្រះនាងឧប្បលវណ្ណាសម្រេចព្រះអរហត្ត ២៩១
-នន្ទមាណពប្រទូសនឹងព្រះថេរី ២៩១
-អធិប្បាយគាថា ២៩៣
-ព្រះខីណាស្រពមិនត្រេកអរនឹងកាមសុខ ២៩៤
-ភិក្ខុនីគួរនៅក្នុងនគរ ២៩៥
១១-រឿងជម្ពុកាជីវក ២៩៦
-កុដុម្ពីក៏ទំនុកបម្រុងព្រះថេរៈ ២៩៦
-ជេរព្រះអរហន្តដោយអាការ ៤ យ៉ាង មានទោស ២៩៧
-ទោសនៃការជេរព្រះអរហន្ត ២៩៩
-ព្រះពុទ្ធស្ដេចយាងទ្រោសជម្ពុកាជីវក ២៦៣
-ជម្ពុការជីវកសម្រេចព្រះអរហន្ត ២៦៦
-ជម្ពុកាជិវកប្រាប់ការពិតដល់មហាជន ២៧០
-អធិប្បាយគាថា ២៧២
១២-រឿងអហិប្រេត ២៧៤
-ព្រះមហាមោគ្គល្លានធ្វើការញញឹម ២៧៤
-បុព្វកម្មរបស់កាកប្រេត ២៧៥
-បុព្វកម្មរបស់អហិប្រេត ២៧៧
-ព្រះសាស្ដាទ្រង់ប្រៀបធៀបផលកម្ម ២៧៩
-អធិប្បាយគាថា ២៧៩
១៣-រឿងសដ្ឋិកូដប្រេត ២៨២
-ព្រះមហាមោគ្គល្លានឃើញសដ្ឋិកូដប្រេត ២៨២
-ព្រះសាស្ដាទ្រង់ទទួលថាប្រេតមាន ២៨៣

-បុព្វកម្មរបស់សង្ឃិក្ខុដប្រេត ២៨៣
-ព្រះសាស្ដាត្រាស់ទូន្មានពួកភិក្ខុ ២៨៨
-អធិប្បាយគាថា ២៨៨
១៤-រឿងព្រះសុធម្មត្ថេរ ២៩០
-ចិត្តគហបតីថ្វាយឧទ្យានជាសង្ឃារាម ២៩០
-គហបតីសម្រេចព្រះអនាគាមិផល ២៩១
-ព្រះសុធម្មត្ថេរជេរគហបតី ២៩២
-ព្រះសុធម្មត្រូវសង្ឃដាក់បដិសារណិយកម្ម ២៩៣
-សមណៈមិនគួរមានះ និង៩ស្សា ២៩៣
-អធិប្បាយគាថា ២៩៥
-ព្រះសុធម្មសម្រេចព្រះអរហត្ត ២៩៨
-ចិត្តគហបតីទៅគាល់ព្រះសាស្ដា ២៩៨
-ការកើតមានបាដិហារិយ៍ ២៩៩
-ចិត្តគហបតីថ្វាយទាន ៣០១
-ចិត្តគហបតីត្រឡប់ពីការដើរផ្លូវ ៣០២
-បុព្វកម្មរបស់ចិត្តគហបតី ៣០៣
១៥-រឿងព្រះវនវាសីតិស្សត្ថេរ ៣០៦
-ព្រះសារីបុត្រអនុគ្រោះព្រាហ្មណ៍ក្រលំបាក៣០៦
-ព្រាហ្មណ៍អ្នកក្រស្លាប់ទៅកើតក្នុងក្រុងសាវត្ថី ៣០៨
-ទារកបរិច្ចាគទាន ៣០៩
-ការបួសធ្វើទានលំបាក ៣១១
-សាមណេរមានលាភច្រើនព្រោះផលទានក្នុង... ៣១៣
-លក្ខណៈបុគ្គលកំណាញ់ ៣១៥
-ឲ្យរបស់តិចតែបានផលច្រើន ៣១៦
-ឧបជ្ឈាយ៍ទៅសួរសុខទុក្ខសាមណេរ ៣២០

-ហេតុនៃសេចក្តីសុខ និងរួចផុតចាកទុក្ខ ៣២៣
-ពួកមនុស្សជ្រះថ្លាក្នុងព្រះសាមណេរ ៣២៥
-ទឹកភ្នែកមនុស្សច្រើនជាងទឹកក្នុងមហាសមុទ្រ ៣២៧
-ទីដែលសត្វធ្លាប់ស្លាប់ និងមិនធ្លាប់ស្លាប់ ៣២៨
-ការបរិនិព្វានរបស់ព្រះអានន្ទ ៣២៩
-ព្រះសាស្តាសន្ទនាជាមួយតិស្សសាមណេរ ៣៣១
-ពួកភិក្ខុសរសើរសាមណេរ ៣៣២
-វត្តបដិបត្តិ ២ យ៉ាង ៣៣៣
-អធិប្បាយគាថា ៣៣៤

## បណ្ឌិតវគ្គទី ៦

១-រឿងព្រះរាធ: ៣៣៧
-រាធព្រាហ្មណ៍ស្គមស្គាំងព្រោះមិនបានបួស៣៣៧
-រាធព្រាហ្មណ៍មានឧបនិស្ស័យព្រះអរហត្ត ៣៣៧
-ព្រះសារីបុត្រជាកតញ្ញូកតវេទី ៣៣៨
-ព្រាហ្មណ៍បួសហើយជាអ្នកប្រដៅងាយ ៣៣៩
-ព្រះសាស្តាទ្រង់សម្តែងអលីនចិត្តជាតក ៣៤០
-ភិក្ខុគួរជាអ្នកប្រដៅងាយដូចព្រះរាធ: ៣៤១
-អធិប្បាយគាថា ៣៤១
២-រឿងភិក្ខុអស្សជិ និងបុនព្វសុក ៣៤៥
-ភិក្ខុលាមកត្រូវបព្វាជនីយកម្ម ៣៤៥
-អធិប្បាយគាថា ៣៤៦
៣-រឿងព្រះឆន្នត្ថេរ ៣៤៨
-ព្រះឆន្ន:ជេរព្រះអគ្គសាវក ៣៤៨
-អធិប្បាយគាថា ៣៤៩
-ព្រះសាស្តាត្រាស់ឱ្យដាក់ព្រហ្មទណ្ឌព្រះឆន្ន: ៣៤៩

៤–រឿងព្រះមហាកប្បិន ៣៥១
–ព្រះបច្ចេកពុទ្ធសូមមហាត្ថកម្មធ្វើសេនាសនៈ ៣៥១
–ពួកជាងតម្បាញធ្វើបុណ្យ ៣៥២
–អានិសង្សទាននាំឱ្យកើតក្នុងតាវតិង្ស ៣៥៤
–កុដុម្ពីក៍ថ្វាយមហាទាន ៣៥៤
–កុដុម្ពីក៍ ភរិយា និងបរិវារកើតក្នុងរាជត្រកូល ៣៥៦
–ព្រះរាជាបានដំណឹងព្រះរតនត្រ័យអំពីឈ្មួញ ៣៥៨
–ព្រះរាជាចេញបួសជាមួយអាមាត្យ ៣៦០
–ព្រះរាជា និងអាមាត្យសម្រេចគុណវិសេស ៣៦៣
–ព្រះនាងអនោជាទេវីចេញបួស ៣៦៤
–អធិប្បាយគាថា ៣៧២
២–រឿងបណ្ឌិតសាមណេរ ៣៧៤
–ព្រះសាស្ដាត្រាស់អនុមោទនាកថា ៣៧៤
–អ្នកជ្រះថ្លាក្នុងអនុមោទនាកថា ៣៧៥
–បុរសក្រីក្រត្រេកអរទទួលអង្គាសភិក្ខុ ៣៧៦
–មហាទុគ្គតៈបានថ្វាយទានដល់ព្រះសាស្ដា ៣៨១
–មហាទុគ្គតៈនៅយាងព្រះសាស្ដា ៣៨៤
–ព្រះសាស្ដាប្រទានបាត្រដល់មហាទុគ្គតៈ ៣៨៥
–ព្រះសាស្ដាយាងទៅផ្ទះមហាទុគ្គតៈ ៣៨៧
–ផ្ទះរបស់មហាទុគ្គតៈពេញដោយរតនៈ ៧ ប្រការ ៣៨៨
–មហាទុគ្គតៈស្លាប់ទៅកើតក្នុងក្រុងសាវត្ថី ៣៩០
–ទារកចេញបួសជាសាមណេរ ៣៩១
–សាមណេរលាត្រឡប់ទៅធ្វើសមណធម៌ ៣៩៥
–អាសនៈស្ដេចសក្កៈក្ដៅព្រោះគុណធម៌សាមណេរ ៣៩៦
–ព្រះសាស្ដាទ្រង់រក្សាសាមណេរ ៣៩៨

-សាមណេរសម្រេចព្រះអរហត្ត ៤០០

-ធម្មតាបណ្ឌិតរមែងទូន្មានខ្លួន ៤០១

-អធិប្បាយគាថា ៤០២

៦-រឿងព្រះលកុណ្ឌកភទ្ទិយៈ ៤០៤

-ព្រះថេរៈត្រូវលេងព្រោះលោករាងតូច ៤០៤

-ព្រះខីណាស្រពប្រៀបដូចជាសិលា ៤០៤

-អធិប្បាយគាថា ៤០៥

៧-រឿងមាតានាងកាណា ៤០៧

-នាងកាណាជេរភិក្ខុ ៤០៧

-ព្រះរាជាតែងតាំងនាងកាណា ៤០៩

-អធិប្បាយគាថា ៤១៣

៨-រឿងភិក្ខុ៥០០រូប ៤១៥

-ព្រះសាស្តាយាងនៅក្រុងវេរញ្ជា ៤១៥

-ព្រះសាស្តាយាងនៅក្រុងសាវត្ថី ៤១៦

-ព្រះសាស្តាត្រាស់វាលោទកជាតក ៤១៧

-អធិប្បាយគាថា ៤១៨

៩-រឿងព្រះធម្មិកត្ថេរ ៤២១

-ឧបាសកគេចទៅបួសបានសម្រេចព្រះអរហត្ត ៤២១

-បុត្រ និងភរិយាទៅបួសសម្រេចព្រះអរហត្ត ៤២២

-អធិប្បាយគាថា ៤២៣

១០-រឿងការស្តាប់ធម៌ ៤២៥

-បុគ្គលអាស្រ័យភពជាប់ក្នុងភពមានច្រើន៤២៥

-អធិប្បាយគាថា ៤២៦

១១-រឿងភិក្ខុអាគន្តុកៈ ៤២៨

-ព្រះសាស្តាត្រាស់សមគួរដល់ការប្រព្រឹត្ត ៤២៨

-អធិប្បាយគាថា ៤២៩

## អរហន្តវគ្គទី ៧

១-រឿងពេទ្យជីវក ៤៣២
-ព្រះទេវទត្តធ្វើលោហិតុប្បាទកម្ម ៤៣២
-ពេទ្យជីវកធ្វើការព្យាបាលជំងឺ ៤៣២
-ព្រះអរហន្តមិនមានសេចក្តីក្តៅក្រហាយ ៤៣៤
-អធិប្បាយគាថា ៤៣៤
២-រឿងព្រះមហាកស្សបៈ ៤៣៧
-ធម្មធំនាមរបស់ព្រះពុទ្ធពេលទ្រង់ចារិក ៤៣៧
-ពួកភិក្ខុថាព្រះថេរៈលះបង់ញាតិ និងឧបដ្ឋាកមិនបាន ៤៣៧
-ទ្រង់ត្រាស់ហេតុដែលព្រះថេរៈត្រឡប់ ៤៣៩
-ព្រះសាស្តាត្រាស់បុព្វចរិយារបស់ព្រះថេរៈ ៤៤០
-អធិប្បាយគាថា ៤៤១
៣-រឿងព្រះពេឡដ្ឋសីសៈ ៤៤៣
-ទ្រង់បញ្ញត្តិសន្និធិការសិក្ខាបទ ៤៤៣
-អធិប្បាយគាថា ៤៤៤
៤-រឿងព្រះអនុរុទ្ធ ៤៤៧
-ទេពធីតាថ្វាយសំពត់ដល់ព្រះអនុរុទ្ធ ៤៤៧
-ព្រះចីណាស្រពមិននិយាយទាក់ទងនឹងបច្ច័យ ៤៤៨
-អធិប្បាយគាថា ៤៥០
៥-រឿងព្រះមហាកច្ចាយនៈ ៤៥១
-ព្រះថេរៈសរសើរការស្តាប់ធម៌ ៤៥១
-ទេវតាស្រឡាញ់ភិក្ខុអ្នកសង្រួមឥន្ទ្រិយ ៤៥២
-អធិប្បាយគាថា ៤៥៣

៦-រឿងព្រះសារីបុត្រ ៤៥៥
-ព្រះសារីបុត្រត្រូវភិក្ខុមួយរូបប្ដឹង ៤៥៥
-ព្រះថេរៈប្រៀបខ្លួនដោយឧបមា៩ប្រការ ៤៥៦
-ចិត្តរបស់ព្រះសារីបុត្រដូចជាផែនដី ៤៥៧
-អធិប្បាយគាថា ៤៥៩
៧-រឿងព្រះតិស្សៈអ្នកក្រុងកោសម្ពី ៤៦១
-សិស្សសម្រេចព្រះអរហត្តមុនអាចារ្យ ៤៦១
-ក្មេកសាមណេរបែកព្រះអាចារ្យ ៤៦៣
-អាចារ្យសូមទោសសិស្ស ៤៦៤
-ព្រះខីណាស្រពមិនក្រោធ មិនប្រទូស្ត ៤៦៦
-អធិប្បាយគាថា ៤៦៦
៨-រឿងព្រះសារីបុត្រ ៤៦៨
-សទ្ធិន្ទ្រិយជាដើមមានអមតៈជាទីបំផុត ៤៦៨
-អធិប្បាយគាថា ៤៧០
៩-រឿងព្រះខទិរវនិយរេវតៈ ៤៧២
-ព្រះសារីបុត្រដឹកនាំបងប្អូនបួស ៤៧២
-មាតាបិតាឱ្យរេវតៈរៀបការ ៤៧៣
-រេវតៈរកឧបាយចេញបួស ៤៧៤
-រេវតៈបានបួស ៤៧៤
-រេវតៈសាមណេរសម្រេចព្រះអរហត្ត ៤៧៦
-ពួកភិក្ខុអាស្រ័យបុណ្យព្រះសីវលី ៤៧៧
-ព្រះសាស្ដាអធិដ្ឋានឱ្យភិក្ខុភ្លេចបរិក្ខារ ៤៧៨
-នាងវិសាខាសួរដល់ទីនៅរបស់ព្រះរេវតៈ ៤៧៩
-អធិប្បាយគាថា ៤៨១
-ពួកភិក្ខុច្រាវពូដល់ការប្រព្រឹត្តរបស់ព្រះសីវលី ៤៨២

-បុព្វកម្មរបស់ព្រះសីវលី ៤៨២
-ពួកភិក្ខុសរសើរបុណ្យរបស់ព្រះសីវលី ៤៨៧
១០-រឿងស្ត្រីម្នាក់ ៤៨៩
-ស្ត្រីសោភិនីពន្យាក់ចិត្តព្រះថេរៈឱ្យវង្វេង ៤៨៩
-ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ព្រះថេរៈ ៤៨៩
-អធិប្បាយគាថា ៤៩០

## សហស្សវគ្គទី ៨

១-រឿងបុរសពុកមាត់ក្រហមអ្នកសម្លាប់ចោរ ៤៩២
-ពេជ្ឈឃាតពុកមាត់ក្រហម ៤៩២
-ពេជ្ឈឃាតឈប់ពីតំណែងព្រោះខ្លួនចាស់ ៤៩៣
-តម្ពទាឋិកៈធ្វើបុណ្យដល់ព្រះសារីបុត្រ ៤៩៥
-កល្យាណមិត្តជាហេតុឱ្យទៅកើតក្នុងតុសិត ៤៩៧
-អធិប្បាយគាថា ៤៩៩
២-រឿងព្រះទារុចីរិយៈ ៥០១
-ទារុចីរិយៈសម្គាល់ថាខ្លួនជាព្រះអរហន្ត ៥០១
-ប្រវត្តដើមរបស់ទារុចីរិយៈ ៥០២
-ព្រហ្មប្រាប់ការពិតដល់ទារុចីរិយៈ ៥០៤
-ទារុចីរិយៈទៅគាល់ព្រះសាស្តា ៥០៥
-ទារុចីរិយៈសម្រេចព្រះអរហន្តទាំងខ្លួនជាគ្រហស្ថ ៥០៦
-ទារុចីរិយៈជាកំពូលខាងខិប្បាភិញ្ញា ៥០៩
-អធិប្បាយគាថា ៥១០
៣-រឿងព្រះនាងកុណ្ឌលកេសីថេរី ៥១១
-ធីតាសេដ្ឋីបានចោរជាស្វាមី ៥១១
-ធីតាសេដ្ឋីរុញទម្លាក់ចោរ ៥១៥

-ធីតាសេដ្ឋីបួសជាបរិព្វាជិកា ៤១៧
-ឈ្នះកិលេសប្រសើរ ៤២០
-អធិប្បាយគាថា ៤២២
៤-រឿងអនត្ថបុច្ឆកព្រាហ្មណ៍ ៤២៤
-សេចក្តីវិនាសមានដល់អ្នកសេពកម្ម ៦ យ៉ាង ៤២៤
-ឈ្នះខ្លួនឯង ជាការឈ្នះដ៏ប្រសើរ ៤២៥
-អធិប្បាយគាថា ៤២៦
៥-រឿងព្រាហ្មណ៍ឪពុកមាព្រះសារីបុត្រ ៤២៨
-ព្រះថេរៈនាំឪពុកមាទៅគាល់ព្រះសាស្តា ៤២៨
-ព្រះសាស្តាសម្តែងធម៌ប្រោសព្រាហ្មណ៍ ៤២៩
-អធិប្បាយគាថា ៤៣០
៦-រឿងព្រាហ្មណ៍ជាក្មួយព្រះសារីបុត្រ ៤៣២
-ព្រះថេរៈនាំក្មួយទៅគាល់ព្រះសាស្តា ៤៣២
-ព្រះសាស្តាសម្តែងធម៌ប្រោសព្រាហ្មណ៍ ៤៣៣
-អធិប្បាយគាថា ៤៣៣
៧-រឿងព្រាហ្មណ៍ជាសំឡាញ់ព្រះសារីបុត្រ ៤៣៥
-ព្រះថេរៈនាំក្មួយទៅគាល់ព្រះសាស្តា ៤៣៥
-ព្រះសាស្តាសម្តែងធម៌ប្រោសព្រាហ្មណ៍ ៤៣៥
-អធិប្បាយគាថា ៤៣៦
៨-រឿងអាយុវឌ្ឍនកុមារ ៤៣៨
-ព្រាហ្មណ៍ជាសំឡាញ់ ២ នាក់ ចេញបួស ៤៣៨
-ព្រាហ្មណ៍សួរដល់ហេតុដែលសំឡាញ់មិនឱ្យពរ ៤៣៩
-ព្រះសាស្តាប្រាប់ឧបាយការពារ ៤៤០
-កុមាររួចពីអន្តរាយ ក៏មានអាយុវែង ៤៤១
-ការថ្វាយបង្គំអ្នកមានគុណមានអាយុវែង ៤៤២

-អធិប្បាយគាថា ៥៤៣
៩-រឿងសង្កិច្ចសាមណេរ ៥៤៥
-កុលបុត្រ ៣០ នាក់ចេញបួស ៥៤៥
-ប្រវត្តិរបស់សង្កិច្ចសាមណេរ ៥៤៦
-ត្រាស់ឱ្យភិក្ខុទៅលាព្រះសារីបុត្រ ៥៤៧
-ពួកភិក្ខុ ៣០ រូប នៅធ្វើសមណធម៌ ៥៤៩
-ពួកភិក្ខុតាំងកតិកានៅចាំវស្សា ៥៤៩
-ទុគ្គតបុរសមកនៅអាស្រ័យពួកនិងភិក្ខុ ៥៥០
-ទុគ្គតបុរសគេចពីពួកភិក្ខុនៅសួរសុខទុក្ខជីតា ៥៥១
-ពួកចោរនៅចាប់ភិក្ខុដើម្បីធ្វើពលីកម្ម ៥៥៣
-សង្កិច្ចសាមណេរប្រគល់ខ្លួនដល់ពួកចោរ ៥៥៤
-មេចោរសូមបព្វជ្ជាអំពីសាមណេរ ៥៥៧
-សាមណេរត្រឡប់នៅសួរសុខទុក្ខពួកភិក្ខុ ៥៥៨
-អ្នកមានសីល ប្រសើរជាងអ្នកទ្រុស្តសីល ៥៥៩
-អធិប្បាយគាថា ៥៥៩
-ប្រវត្តិអធិមុត្តកសាមណេរ ៥៦០
១០-រឿងព្រះខានុកោណ្ឌញ្ញៈ ៥៦២
-ព្រះថេរៈគង់ចូលឈាន ពួកចោរយកបង្វេច... ៥៦២
-អ្នកមានបញ្ញា ប្រសើរជាងអ្នកគ្មានបញ្ញា ៥៦៣
-អធិប្បាយគាថា ៥៦៤
១១-រឿងព្រះសប្បទាសៈ ៥៦៥
-ព្រះថេរៈឱ្យពស់ចាំខ្លួន ៥៦៥
-ព្រះថេរៈសម្រេចព្រះអរហត្ត មាននាមថា សប្បទាសៈ ៥៦៦
-បុព្វកម្មរបស់ព្រះសប្បទាសៈ ៥៦៨
-ជីវិតអ្នកព្យាយាមមួយថ្ងៃ ប្រសើរ ៥៦៩

-អធិប្បាយគាថា ៥៧០
១២-រឿងព្រះនាងបដាចារា ៥៧២
-នាងបដាចារារត់តាមអ្នកបម្រើ ៥៧២
-នាងជ្រាបដំណឹងថាមាតាបិតាស្លាប់ ៥៧៦
-នាងបានតាំងសេចក្ដីប្រាថ្នាទុកក្នុងជាតិមុន ៥៧៨
-នាងបដាចារាទូលសូមបួស ៥៨១
-អធិប្បាយគាថា ៥៨២
១៣-រឿងព្រះនាងកិសាគោតមីថេរី ៥៨៣
-ទ្រព្យរបស់សេដ្ឋីក្លាយជាធ្យូង ៥៨៣
-ធ្យូងក្លាយជាទ្រព្យដូចដើម ៥៨៤
-នាងបួសក្នុងព្រះពុទ្ធសាសនា ៥៨៨
-អធិប្បាយគាថា ៥៨៩
១៤-រឿងព្រះនាងពហុបុត្តិកាថេរី ៥៩០
-នាងមានកូនច្រើន ៥៩០
-អធិប្បាយគាថា ៥៩២

# បុប្ផវគ្គ ទី ៤

សូមនមស្ការព្រះមានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ

"ពោលដោយផ្កាឈើ"

## ១. រឿងភិក្ខុ ៥០០ រូប

[១៤] *ព្រះសាស្ដា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ដែលជាអ្នកខ្វល់ខ្វាយក្នុងបឋវីកថា ត្រាស់ធម្មទេសនា នេះថា* ***កោ ឥមំ បឋវឹ វិចេស្សតិ*** *(នរណាដឹងច្បាស់នូវផែនដីនេះ) ជាដើម ។*

### គួរប្រារព្ធផែនដីខាងក្នុង

*បានស្ដាប់មកថា ភិក្ខុទាំងនោះត្រាច់ទៅកាន់ជនបទជាមួយព្រះមានព្រះ-ភាគជាម្ចាស់ មកដល់វត្តជេតពនហើយ អង្គុយក្នុងឧបដ្ឋានសាលា ក្នុងពេលរសៀល ជំណាលរឿងផែនដីក្នុងស្ថានទីដែលខ្លួនទៅហើយថា ក្នុងស្រុកឯណោះមានផ្ទៃដីរាបស្មើ មិនរាបស្មើ មានភក់ល្បាប់ច្រើន មានគ្រួសច្រើន មានដីខ្មៅ មានដីក្រហម ។*

*ព្រះសាស្ដាស្ដេចយាងមក ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា*

“រឿងផែនដីក្នុងស្ថានទីដែលពួកខ្ញុំព្រះអង្គត្រាច់ទៅហើយ ព្រះអង្គ” ដូច្នេះ ទើបត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ នោះជាផែនដីខាងក្រៅ ការដែលពួកអ្នកធ្វើបរិកម្មក្នុងផែនដីខាងក្នុងទើបគួរ” លុះត្រាស់ដូច្នេះហើយ ក៏ទ្រង់បានភាសិត ២ គាថានេះថា ៖

កោ ឥមំ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
កោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។
សេក្ខោ បឋវឹ វិជេស្សតិ យមលោកញ្ច ឥមំ សទេវកំ
សេក្ខោ ធម្មបទំ សុទេសិតំ កុសលោ បុប្ផមិវ បចេស្សតិ ។

អ្នកណានឹងដឹងច្បាស់នូវផែនដី គឺអត្តភាពនេះ និងយមលោក គឺអបាយភូមិ ៤ និងមនុស្សលោកនេះព្រមទាំងទេវលោកបាន អ្នកណានឹងជ្រើសរើសនូវចំណែកនៃធម៌ ដែលព្រះមានព្រះភាគសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃ ជ្រើសរើសនូវផ្កាដូច្នោះឯង ។

ព្រះសេក្ខបុគ្គលនឹងដឹងច្បាស់នូវផែនដី គឺ អត្តភាពនេះ និងយមលោក គឺ អបាយភូមិ ៤ និងមនុស្សលោកនេះព្រមទាំងទេវលោកបាន ព្រះសេក្ខបុគ្គលនឹងជ្រើសរើសនូវចំណែកនៃធម៌ដែលព្រះតថាគតសម្តែងប្រពៃហើយ ដូចមាលាការដែលឈ្លាសវៃជ្រើសរើសនូវផ្កាដូច្នោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **កោ ឥមំ** (នរណា... នេះ) សេចក្ដីថា នរណា (នឹងដឹងច្បាស់) នូវផែនដីនេះ ពោលគឺ អត្តភាព ។ បទថា **វិជេស្សតិ (នឹងដឹងច្បាស់)** សេចក្ដីថា នឹងដឹងច្បាស់ គឺ ចាក់ធ្លុះ បានដល់ ធ្វើឲ្យជាក់ច្បាស់ដោយញាណរបស់ខ្លួន ។ បទថា **យមលោកញ្ច (និងយមលោក)** បានដល់ អបាយភូមិ ៤ ។

បទថា **ឥមំ សទេវកំ (និងមនុស្សលោកនេះ ព្រមទាំងទេវលោក)** សេចក្ដីថា នរណានឹងដឹងច្បាស់ គឺ នឹងជ្រាបច្បាស់ បានដល់ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវមនុស្សលោក និងទេវលោកផង ព្រះសាស្ដារមែងត្រាស់សួរដូច្នេះ ។ បទថា **កោ ធម្មបទំ សុទេសិតំ (នរណានឹងជ្រើសរើសបទធម៌ដែលតថាគតសម្ដែងល្អហើយ)** សេចក្ដីថា នរណានឹងជ្រើសរើស គឺ ស្រាវ-ជ្រាវ បានដល់ ពិចារណាឃើញ ចាក់ធ្លុះ ធ្វើឲ្យជាក់នូវបទធម៌ ពោលគឺ ពោធិបក្ខិយធម៌ ៣៧ ប្រការ មានសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ៍ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ មគ្គមានអង្គ ៨ ដែលតថាគតសម្ដែងល្អហើយ ព្រោះជាធម៌ដែលតថាគតសម្ដែងហើយតាមសេចក្ដីពិត ដូចជានាយមាលាការ ដែលឈ្លាសវៃជ្រើសរើសផ្កា ដូច្នោះ ។

បទថា **សេក្ខោ (ព្រះសេក្ខៈ)** ជាដើម សេចក្ដីថា ព្រះអរិយបុគ្គល ៧

ពួក តាំងអំពីលោកដែលតាំងនៅក្នុងសោតាបត្តិមគ្គ រហូតដល់លោកដែលតាំងនៅក្នុងអរហត្តមគ្គ ឈ្មោះថា ព្រះសេក្ខៈ ព្រោះនៅសិក្សាសិក្ខា ៣ គឺ អធិសីលសិក្ខា អធិចិត្តសិក្ខា អធិប្បញ្ញាសិក្ខា កាលបន្ទោបង់ឆន្ទរាគៈចេញពីអត្តភាពនោះ ដោយអរហត្តមគ្គ ឈ្មោះថា ដឹងច្បាស់ គឺ ជ្រាបច្បាស់ បានដល់ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវផែនដីនេះ ពោលគឺ អត្តភាព ។

បទថា **យមលោកញ្ច (និងយមលោក)** ជាដើម សេចក្តីថា ព្រះសេក្ខៈនោះឯងនឹងដឹងច្បាស់ គឺ នឹងជ្រាបច្បាស់ បានដល់ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់នូវយមលោក មានប្រការដូចពោលមកហើយនោះឯង និងមនុស្សលោកនេះនិងទេវលោកទាំងឡាយ ឈ្មោះថា ព្រមទាំងទេវលោក ។ លោកអ្នកដែលនៅសិក្សា ៧ ពួកនោះឯង ឈ្មោះថា សេក្ខៈ ។ អធិប្បាយថា នាយមាលាការដែលឈ្លាសវៃចូលទៅកាន់សួនផ្កាហើយ វៀរផ្កាដែលខ្ចី និងមិនទាន់រីក ដែលសត្វចោះ ដែលស្វិតស្រពោន និងដែលមានស្នាមអុជៗ ហើយរើសយកតែផ្កាដែលស្អាតល្អ មានឧបមា យ៉ាងណា ព្រះសេក្ខៈនឹងជ្រើសរើស គឺ ស្រាវជ្រាវ បានដល់ ពិចារណាឃើញ ចាក់ធ្លុះ ធ្វើឲ្យជាក់ច្បាស់សូម្បីនូវបទនៃពោធិបក្ខិយធម៌ ដែលតថាគតសម្តែងល្អហើយ ក៏ដូច្នោះឯង ។

ព្រះសាស្តា ទ្រង់ឆ្លើយបញ្ហាដោយព្រះអង្គឯង ដូច្នេះ ។ ក្នុងវេលាចប់ព្រះទេសនា ភិក្ខុ ៥០០ រូប បានសម្រេចជាព្រះអរហត្ត ព្រមទាំងបដិសម្ភិទា

ទាំងឡាយ ។ ព្រះទេសនាមានប្រយោជន៍សូម្បីដល់បរិស័ទដែលមកប្រជុំគ្នាក្នុងទីនោះឯង ។

ចប់រឿងភិក្ខុ ៥០០ រូប ដែលខ្វល់ខ្វាយក្នុងបឋវីកថា

# ២. រឿងព្រះថេរៈដែលចម្រើនមរីចិកម្មដ្ឋាន

*ព្រះសាស្តា កាលគង់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធភិក្ខុ ១ រូប ដែលចម្រើនមរីចិកម្មដ្ឋាន គឺ កម្មដ្ឋានដែលពិចារណាដល់ថ្ងៃបណ្តើរកូនជាអារម្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា* ***ផេណូបមំ (ប្រៀបដូចជាពពុះទឹក)*** *ជាដើម ។*

## ព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន

*បានស្តាប់មកថា ព្រះថេរៈនោះ រៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្តា ហើយ គិតថា "យើងនឹងធ្វើសមណធម៌" លុះគិតដូច្នេះហើយ ចូលទៅកាន់ព្រៃ បំពេញសេចក្តីព្យាយាមហើយព្យាយាមទៀត ក៏មិនបានសម្រេចអរហត្ត ទើបត្រឡប់មកកាន់សម្នាក់ព្រះសាស្តា ដោយតាំងចិត្តថា "នឹងទូលអារាធនាព្រះមានព្រះភាគដើម្បីទ្រង់ត្រាស់ប្រាប់ព្រះកម្មដ្ឋានឲ្យវិសេស" ឃើញថ្ងៃបណ្តើរកូនក្នុងវាលផ្លូវ ក៏ចម្រើនមរីចិកម្មដ្ឋានថា "ថ្ងៃបណ្តើរកូននេះតាំងឡើងហើយក្នុងរដូវក្តៅ រមែងប្រាកដដល់បុគ្គលទាំងឡាយដែលឈរនៅក្នុងទីឆ្ងាយ ដូចមានរូបរាង តែមិនប្រាកដដល់បុគ្គលដែលចូលទៅជិត យ៉ាងណា សូម្បីអត្តភាពនេះ ក៏ដូច្នោះដែរ ព្រោះអត្ថថា កើតឡើងហើយវិនាសទៅវិញ" ដើរមកអស់កម្លាំងតាមផ្លូវ ចុះងូតទឹកក្នុងស្ទឹងអចិរវតី អង្គុយក្រោមម្លប់ឈើក្បែរមាត់ច្រាំងស្ទឹងដែលមានក្រសែទឹកហូរត្របាញ់មួយកន្លែង ឃើញពពុះទឹកធំៗតាំងឡើងដោយកម្លាំងនៃទឹកប៉ះខ្ទប់គ្នា ហើយបែកទៅវិញ ក៏កាន់យកមកជា*

អារម្មណ៍ថា សូម្បីអត្តភាពនេះ ក៏មានឧបមាដូច្នោះដែរ ព្រោះអត្ថថា កើតឡើងហើយបែកធ្លាយទៅវិញ ។

## ទ្រង់ប្រៀបកាយនឹងពពុះទឹក និងថ្ងៃបណ្តើរក្អូន

ព្រះសាស្តាប្រថាប់នៅក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ទតឃើញព្រះថេរៈនោះ ក៏ត្រាស់ថា "ម្នាលភិក្ខុ យ៉ាងនោះឯង អត្តភាពនេះ មានសភាពយ៉ាងនោះឯង មានការកើតឡើង និងបែកធ្លាយទៅវិញជាធម្មតា ដូចពពុះទឹក និងថ្ងៃបណ្តើរក្អូន ដូច្នោះ" ហើយត្រាស់ព្រះគាថានេះថា ៖

ផេណូបមំ កាយមិមំ វិទិត្វា មរីចិធម្មំ អភិសម្ពុធានោ
ឆេត្វាន មារស្ស បបុប្ផកានិ អទស្សនំ មច្ចុរាជស្ស គច្ឆេ ។

ភិក្ខុ កាលដឹងច្បាស់នូវកាយនេះថា ដូចជាដុំពពុះទឹក
ដឹងច្បាស់នូវកាយនេះថា មានសភាពដូចព្រេញថ្ងៃ
គប្បីកាត់នូវកម្រងផ្ការបស់មារ គឺ វដ្តៈ ៣ ទៅកាន់
ស្ថានទីមិនឃើញនៃមច្ចុរាជ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ផេណូបមំ (ប្រៀបដូចដុំនៃពពុះទឹក) ព្រោះអត្ថថា ដឹងច្បាស់នូវកាយនេះ គឺ ដែលរាប់ថា ជាទីប្រជុំនៃចំណែកផ្សេងៗ មានសក់ជាដើមថា ដូចដុំពពុះទឹក ព្រោះអត្ថថា មិនមានកម្លាំង មានកម្លាំង

*តិច មិនតាំងនៅយូរ និងប្រព្រឹត្តទៅមួយជួរខណៈ ។ បទថា* ***មរីចិធម្មំ (មាន សភាពដូចព្រេញថ្ងៃ)*** *ជាដើម សេចក្តីថា ដឹងច្បាស់ គឺ ដឹង បានដល់ ជ្រាប ថា "សូម្បីកាយនេះ ឈ្មោះថា មានសភាពដូចថ្ងៃបណ្តើរកូន ព្រោះអត្ថថា ប្រព្រឹត្តទៅមួយជួរខណៈ និងប្រាកដជារបស់តិចតួច ដូចថ្ងៃបណ្តើរកូន ដូច ជាមានរូបរាង (និង) ប្រាកដដូចជារបស់ដែលគួរកាន់យក បានដល់ បុគ្គល ទាំងឡាយដែលឈរនៅក្នុងទីឆ្ងាយ (តែ) កាលបុគ្គលនោះចូលទៅជិត រមែង ប្រាកដជារបស់ទទេ ចូលដល់ភាពជារបស់កាន់យកមិនបាន ដូច្នោះ" ។ បទ ថា* ***មារស្ស បបុប្ផកានិ (កម្រងផ្ការបស់មារ)*** *ជាដើម សេចក្តីថា ភិក្ខុជាព្រះ ខីណាស្រព កាត់វដ្តៈដែលប្រព្រឹត្តទៅក្នុងត្រៃភូមិ ពោលគឺ កម្រងផ្ការបស់ មារបានដោយអរិយមគ្គហើយ គប្បីដល់ស្ថានទីដែលមិនឃើញ គឺ កន្លែងដែល មិនឃើញ គឺ កន្លែងដែលមិនមែនជាវិស័យរបស់មច្ចុរាជ បានដល់ អមត- មហានិព្វាន ។*

*ក្នុងកាលចប់ព្រះទេសនា ព្រះថេរៈបានសម្រេចអរហត្តព្រមទាំងបដិ- សម្ភិទាទាំងឡាយ រីករាយត្រេកអរនឹងភាសិតរបស់ព្រះអង្គ ថ្វាយបង្គំព្រះសរីរៈ របស់ព្រះសាស្តាដែលមានពណ៌ដូចមាស មកហើយ ដូច្នេះឯង ។*

ចប់ រឿងព្រះថេរៈចម្រើនមរីចិកម្មដ្ឋាន

# ៣. រឿងព្រះបាទវិឌូឌភៈ

ព្រះសាស្ដាកាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធព្រះបាទវិឌូឌភៈ ព្រមទាំងបរិស័ទ ដែលត្រូវទឹកជំនន់កួចពន្លិចឲ្យសោយទិវង្គត ទ្រង់ត្រាស់ព្រះធម្មទេសនានេះថា **បុប្ផានិ ហេវ បចិនន្តំ** (អ្នកជ្រើសរើសនូវផ្កា) ជាដើម ។

អនុបុព្វីកថាក្នុងរឿងនោះ មានដូចតទៅ ៖

## ព្រះរាជកុមារ ៣ អង្គទៅសិក្សាសិល្បៈក្នុងក្រុងតក្កសិលា

ព្រះកុមារ ៣ អង្គនោះ គឺ ព្រះរាជឱរសរបស់ព្រះបាទមហាកោសល ក្នុងនគរសាវត្ថី ព្រះនាមថា **បសេនទិកុមារ** , ព្រះកុមាររបស់ស្ដេចលិច្ឆវីក្នុងនគរវេសាលី ព្រះនាមថា **មហាលិ** , ឱរសរបស់មល្លក្សត្រក្នុងក្រុងកុសិនារា ព្រះនាមថា **ពន្ធុលៈ** ។ ស្ដេចទៅកាន់នគរតក្កសិលាដើម្បីសិក្សាសិល្បៈ ក្នុងសម្នាក់អាចារ្យទិសាបាមោក្ខ ព្រះកុមារទាំង ៣ អង្គនោះ បានមកជួបគ្នាត្រង់សាលាក្រៅនគរ មួយអង្គៗ ក៏សួរអំពីហេតុដែលទៅ សួរអំពីត្រកូល និងព្រះនាមនៃគ្នានឹងគ្នា ហើយរាប់អានគ្នាជាសម្លាញ់ រួមគ្នាចូលទៅរកអាចារ្យ មិនយូរប៉ុន្មានសិក្សាសិល្បៈចប់សព្វគ្រប់ ទើបលាអាចារ្យព្រមគ្នា ស្ដេចចេញពីក្រុងតក្កសិលាទៅកាន់នគររៀងៗ ខ្លួន ។

## ព្រះរាជកុមារទាំង ៣ បានទទួលតំណែងផ្សេងៗ គ្នា

បណ្ដាព្រះរាជកុមារទាំង ៣ ព្រះអង្គនោះ បសេនទិកុមារ ទ្រង់សម្ដែង

សិល្បៈថ្វាយព្រះរាជបិតា ធ្វើឲ្យព្រះរាជបិតាពេញព្រះទ័យ បានអភិសេកក្នុងរាជសម្បត្តិ ។

មហាលិកុមារ កាលទ្រង់សម្ដែងសិល្បៈថ្វាយស្ដេចលិច្ឆវីទាំងឡាយ ក៏ទ្រង់សម្ដែងដោយសេចក្ដីព្យាយាមយ៉ាងខ្លាំង ។ ធ្វើឲ្យព្រះនេត្រទាំងពីររបស់ព្រះអង្គបែក ពួកស្ដេចលិច្ឆវីប្រឹក្សាគ្នាថា “ពុទ្ធោអើយ អាចារ្យរបស់ពួកយើងវិនាសព្រះនេត្រហើយ ពួកយើងនឹងមិនលះបង់លោក នឹងទំនុកបម្រុងលោក” ដូច្នេះ ទើបថ្វាយស្រុកមួយ ដែលមានសួយមួយថ្ងៃបាន ១ សែន ដល់មហា-លិកុមារ ព្រះអង្គត្រូវអាស្រ័យស្រុកនោះ ឲ្យឱរសនៃស្ដេចលិច្ឆវី ៥០០ អង្គសិក្សាសិល្បៈ ។

ចំណែក ពន្ធុលកុមារ កាលពួកមល្លរាជពោលថា “ម្នាលពន្ធុលកុមារ ចូរកាប់ឫស្សីទាំងនេះ” ដូច្នេះ លោកបានលោតទៅលើអាកាសកម្ពស់ ៨០ ហត្ថ ដកដាវកាប់បាច់ឫស្សី ៦០ ដើម ដែលពួកមល្លក្សត្រ ស៊កដែកពីខាងក្នុងឲ្យដាច់អស់ ពន្ធុលកុមារបានឮសំឡេងលាន់ “ក្រឹក” នៃដែកក្នុងបាច់ចុងក្រោយ ទើបសួរថា “នេះជាសំឡេងអ្វី?” ទ្រង់ជ្រាបថា ជាសំឡេងដែក ដែលស៊កខាងក្នុងឫស្សីគ្រប់បាច់ ក៏បោះដាវចោល យំបណ្ដើរនិយាយបណ្ដើរថា “បណ្ដាញាតិ និងមិត្តរបស់យើង ប្រមាណប៉ុណ្ណេះសូម្បីតែម្នាក់ ដែលជាអ្នកមានសេចក្ដីស្រឡាញ់ (ក្នុងយើង) មិនបានប្រាប់ហេតុនេះ (ដល់យើង) ប្រសិនបើយើងបានដឹងជាមុននោះ យើងនឹងកាប់មិនឲ្យឮសំឡេងដែកលាន់ឮឡើង

ឡើយ" ហើយក្រាបទូលព្រះរាជមាតា និងរាជបិតាថា "បពិត្រ ព្រះមាតាបិតា ទូលបង្គំនឹងសម្លាប់មលក្ខត្រទាំងនេះឲ្យអស់ ហើយឡើងសោយរាជសម្បត្តិ" ព្រះមាតា និងបិតា ហាមដោយប្រការផ្សេងៗ ជាដើមថា "ម្នាលកូនសម្លាញ់ នេះជារាជប្រពៃណីទេ" កូនកុំធ្វើយ៉ាងនោះឡើយ ទើបទូលថា "បើដូច្នោះ ខ្ញុំនឹងទៅកាន់សម្នាក់មិត្ររបស់ខ្ញុំ" ដូច្នោះ ហើយក៏ស្តេចទៅកាន់ក្រុងសាវត្ថី ។

ព្រះបាទបសេនទិកោសល ទ្រង់ជ្រាបការយាងមកដល់របស់ពន្ធុល: ក៏ទ្រង់ស្វាគមន៍យាងឲ្យស្តេចចូលកាន់ព្រះនគរដោយសក្ការ:ដ៏ធំ ហើយទ្រង់តែងតាំងឲ្យធ្វើជាសេនាបតី ។ ពន្ធុលសេនាបតីនោះ បានយាងព្រះមាតាបិតាមកស្នាក់អាស្រ័យនៅក្នុងក្រុងសាវត្ថីដែរ ។

## ព្រះរាជាទ្រង់ថ្វាយភត្តាហារដល់ភិក្ខុសង្ឃខ្លួនឯង

ក្រោយមកថ្ងៃមួយ ព្រះរាជាទ្រង់ប្រថាប់នៅលើប្រាសាទជាន់លើ ទតទៅកាន់ថ្នល់ ឃើញភិក្ខុច្រើនពាន់រូបដែលត្រាច់ទៅដើម្បីភត្តកិច្ចក្នុងគេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋី ចូឡអនាថបិណ្ឌិកសេដ្ឋី នាងវិសាខា នាងសុប្បវាសា ក៏ត្រាស់សួរថា "លោកម្ចាស់ទាំងឡាយនោះនិមន្តទៅណា?" ពួករាជបុរសទូលថា "បពិត្រព្រះសម្មតិទេព ភិក្ខុពីរពាន់អង្គទៅដើម្បីប្រយោជន៍ដល់ភត្តទាំងឡាយ មាននិច្ចភត្ត សលាកភត្ត និងគិលានភត្តជាដើម ក្នុងគេហដ្ឋានរបស់អនាថបិណ្ឌិកសេដ្ឋីរាល់ៗ ថ្ងៃ ។ ភិក្ខុ ៥០០ អង្គ ទៅកាន់គេហដ្ឋានរបស់

ចូរឲ្យអនាថបិណ្ឌិកសេដ្ឋីជានិច្ច ។ ផ្ទះរបស់នាងវិសាខា (និង) នាងសុប្បវាសា ក៏ដូចគ្នា" ដូច្នេះ ទ្រង់បំណាននឹងផ្គត់ផ្គង់ភិក្ខុសង្ឃដោយព្រះអង្គឯងដែរ ទើបស្តេចទៅកាន់វិហារ ទ្រង់និមន្តព្រះសាស្តាព្រមទាំងភិក្ខុ ១.០០០ អង្គ ថ្វាយដោយផ្ទាល់ព្រះហស្តព្រះអង្គឯងអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តា ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ព្រមទាំងភិក្ខុសង្ឃចំនួន ៥០០ រូបអស់កាលជានិច្ចចុះ" ។

ព្រះសាស្តា. "មហាបពិត្រ ធម្មតាព្រះពុទ្ធទាំងឡាយ រមែងមិនទទួលភិក្ខាជានិច្ចក្នុងកន្លែងតែមួយទេ ព្រោះជនជាច្រើនរមែងសង្ឃឹមចំពោះការយាងមករបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។

ព្រះរាជា. បើដូច្នេះ សូមព្រះអង្គមេត្តាបញ្ជូនភិក្ខុមួយរូបទៅជាប្រចាំចុះ ។

ព្រះសាស្តាទ្រង់ធ្វើនូវភារៈនោះដល់ព្រះអានន្ទ ។

ព្រះរាជាទ្រង់មិនបានប្រគល់ (នាទី) ថា "បើភិក្ខុសង្ឃមកហើយ ជនឈ្មោះនេះ ទទួលបាត្រ ហើយចូរអង្គាស" ព្រះរាជាទ្រង់អង្គាសដោយព្រះអង្គឯងចំនួន ៧ ថ្ងៃប៉ុណ្ណោះ ក្នុងថ្ងៃទី ៨ ទ្រង់ក៏ភ្លេច ទើបបានទ្រង់ធ្វើឲ្យយឺតយូរ ។ ក៏ធម្មតាក្នុងរាជត្រកូល ជនទាំងឡាយដែលព្រះរាជាទ្រង់មិនបានបញ្ជាហើយ រមែងមិនក្រាលអាសនៈទាំងឡាយ មិននិមន្តពួកភិក្ខុសង្ឃឲ្យគង់ ហើយអង្គាសឡើយ ។ ពួកភិក្ខុក៏គិតគ្នាថា "យើងមិនអាចនៅក្នុងទីនេះបាន" លុះគិតដូច្នេះ

ហើយ ក៏នាំគ្នាចៀសចេញទៅអស់ជាច្រើនរូប ។ សូម្បីក្នុងថ្ងៃទី ២ ព្រះរាជាក៏ទ្រង់ក្អួចទៀត ភិក្ខុទាំងឡាយនាំគ្នាចៀសចេញទៅទៀត ។ សូម្បីក្នុងថ្ងៃទី ៣ ព្រះរាជាក៏ទ្រង់ក្អួចទៀត វៀរតែព្រះអានន្ទមួយអង្គប៉ុណ្ណោះ ភិក្ខុដ៏សេសនាំគ្នាចៀសចេញទៅអស់ ។

## អ្នកមានបុណ្យរមែងធ្វើតាមហេតុ

ធម្មតាអ្នកមានបុណ្យទាំងឡាយ រមែងប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ទើបរក្សាសេចក្តីជ្រះថ្លានៃត្រកូលទាំងឡាយទុកបាន ។ ក៏សាវករបស់ព្រះសាស្តាសូម្បីទាំងអស់ដែលមានឋានន្តរៈ ផ្តើមតាំងពីជនទាំង ៨ នេះ គឺ អគ្គសាវក ២ រូប គឺ ព្រះសារីបុត្តត្ថេរ ព្រះមហាមោគ្គល្លានត្ថេរ , អគ្គសាវិកា ២ រូប គឺ ព្រះនាងខេមា ព្រះនាងឧប្បលវណ្ណា , បណ្តាឧបាសកទាំងឡាយ ឧបាសកដែលជាអគ្គសាវក ២ រូប គឺ ចិត្តគហបតី និងហត្ថកឧបាសកអ្នកក្រុងអាឡវី , បណ្តាឧបាសិកាទាំងឡាយ ឧបាសិកាដែលជាអគ្គសាវិកា ២ រូប គឺ មាតារបស់នន្ទមាណព ឈ្មោះវេឡុកណ្ដកី និងនាងខុជ្ជុត្តរា (សុទ្ធ) តែមានបុណ្យច្រើនសម្បូណ៌ទៅដោយអភិនីហារ ព្រោះជាអ្នកបំពេញបារមី ១០ ដោយឯកទេស ។

សូម្បីព្រះអានន្ទត្ថេរ ក៏មានបារមីដែលបំពេញហើយអស់សែនកប្បសម្បូណ៌ដោយអភិនីហារ មានបុណ្យច្រើន កាលនឹងរក្សាសេចក្តីជ្រះថ្លារបស់ត្រកូល ទើបបាននៅ ព្រោះការដែលខ្លួនប្រព្រឹត្តទៅក្នុងអំណាចនៃហេតុ ពួក

រាជបុរសនិមន្តព្រះអានន្ទតែមួយអង្គប៉ុណ្ណោះឲ្យគង់ ហើយអង្គាស ។

ព្រះរាជាយាងមកក្នុងពេលដែលភិក្ខុនិមន្តទៅអស់ ទតឃើញខាទនីយៈ និងភោជនាហារនៅដដែល ក៏ត្រាស់សួរថា "លោកម្ចាស់ទាំងឡាយ មិនបាននិមន្តមកទេឬ?" ទ្រង់ស្តាប់ថា "ព្រះអានន្ទមួយរូបប៉ុណ្ណោះដែលមក ព្រះអង្គ" ក៏ទ្រង់ក្រោធនឹងភិក្ខុទាំងឡាយថា "លោកម្ចាស់ទាំងឡាយ បានធ្វើការកាត់ផ្តាច់ទំនាក់ទំនងចំពោះយើងត្រឹមនេះដោយពិត" ទើបស្តេចទៅកាន់សម្នាក់ព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គចម្រើន ខ្ញុំព្រះអង្គចាត់ចែងភិក្ខាទុក ដើម្បីភិក្ខុ ៥០០ រូប ជ្រាបថា ព្រះអានន្ទតែមួយអង្គប៉ុណ្ណោះ ដែលនិមន្តមក ភិក្ខាដែលខ្ញុំព្រះអង្គចាត់ចែងហើយនោះនៅដដែល ភិក្ខុ ៥០០ រូប មិនធ្វើនូវសេចក្តីសំខាន់ក្នុងព្រះរាជវាំងរបស់ខ្ញុំព្រះអង្គ (ឡើយ) តើព្រោះហេតុអ្វីហ្ន៎" ។

## ត្រកូលដែលភិក្ខុគួរចូលទៅ និងមិនគួរចូលទៅ

ព្រះសាស្តា ទ្រង់មិនបានត្រាស់ទោសរបស់ភិក្ខុទាំងឡាយ តែត្រាស់ថា "មហាបពិត្រ សាវកទាំងឡាយរបស់តថាគត មិនមានសេចក្តីស្និទ្ធស្នាលនឹងព្រះអង្គ ព្រោះហេតុនោះ ទើបបានមិននិមន្តទៅ" កាលនឹងប្រកាសហេតុនៃការមិនចូលទៅ និងហេតុនៃការចូលទៅកាន់ត្រកូលទាំងឡាយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ព្រះសូត្រនេះថា ៖

"ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ ភិក្ខុមិនទាន់

ចូលទៅ ក៏មិនគួរចូលទៅ លុះចូលទៅហើយ ក៏មិនគួរអង្គុយជិត ត្រកូលប្រកបដោយអង្គ ៩ នោះ ដូចម្ដេចខ្លះ? ត្រកូលប្រកបដោយអង្គ ៩ ទាំងនេះ គឺ គេមិនក្រោកទទួលដោយសេចក្ដីពេញចិត្ត ១ មិនអភិវាទដោយសេចក្ដីពេញចិត្ត ១ មិនឲ្យអាសនៈដោយសេចក្ដីពេញចិត្ត ១ លាក់របស់ដែលមាន ១ កាលរបស់មានច្រើនក៏ឲ្យតិច ១ កាលមានរបស់ប្រណីត ក៏ឲ្យនូវរបស់សៅហ្មង ១ ឲ្យដោយមិនគោរព មិនឲ្យដោយសេចក្ដីគោរព ១ មិនអង្គុយជិតដើម្បីស្ដាប់ធម៌ ១ កាលសម្ដែងធម៌គេមិនត្រេកអរ ១ ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ នេះឯង ភិក្ខុមិនទាន់ចូលទៅ ក៏មិនគួរចូលទៅ លុះចូលទៅហើយ ក៏មិនគួរអង្គុយជិត" ។

ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ ភិក្ខុមិនទាន់ចូលទៅក៏គួរចូលទៅ កាលចូលទៅហើយក៏គួរអង្គុយជិត ។

"ត្រកូលដែលប្រកបដោយអង្គ ៩ តើដូចម្ដេច? ត្រកូលដែលប្រកបដោយអង្គ ៩ គឺ គេក្រោកទទួលដោយសេចក្ដីគោរព ១ អភិវាទដោយសេចក្ដីគោរព ១ ឲ្យអាសនៈដោយសេចក្ដីពេញចិត្ត ១ មិនលាក់របស់ដែលមាន ១ កាលរបស់មានច្រើនក៏ឲ្យច្រើន ១ កាលមានរបស់ប្រណីតក៏ឲ្យរបស់ប្រណីត ១ ឲ្យដោយសេចក្ដីគោរព មិនឲ្យដោយមិនគោរព ១ ចូលទៅអង្គុយជិតដើម្បីស្ដាប់ធម៌ ១ កាលសម្ដែងធម៌គេរមែងត្រេកអរ ១ ។ ម្នាលភិក្ខុទាំងឡាយ ត្រកូលដែលប្រកបដោយអង្គ ៩ នេះឯង ភិក្ខុមិនទាន់ចូលទៅ ក៏គួរចូលទៅ

កាលចូលទៅហើយក៏គួរអង្គុយជិត" ដូច្នេះ ទើបត្រាស់ថា "មហាបពិត្រ សាវក របស់តថាគត កាលមិនបានសេចក្តីស្និទ្ធស្នាលអំពីសម្នាក់របស់ព្រះអង្គ ទើបមិននិមន្តទៅដោយប្រការដូច្នេះឯង" ។ ពិតណាស់ បុរាណបណ្ឌិតទាំងឡាយ សូម្បីគេទំនុកបម្រុងដោយសេចក្តីគោរពក្នុងទីដែលមិនធ្លាប់ស្និទ្ធស្នាល សូម្បីមានវេទនាជិតនឹងស្លាប់ ក៏បានទៅកាន់ទីនៃបុគ្គលអ្នកដែលស្និទ្ធស្នាលដែរ" ព្រះរាជាក៏ទូលសួរថា "ក្នុងកាលណាព្រះអង្គ?" ទើបទ្រង់នាំយកអតីតនិទាន (មកសាធក:) ដូចតទៅនេះ ៖

## រឿងកេសវតាបស

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះរាជាទ្រង់ព្រះនាមថា **កេសវ:** ទ្រង់លះបង់រាជសម្បត្តិ បួសជាឥសី ។ បុរស ៥០០ នាក់ ចេញបួសតាមព្រះរាជាអង្គនោះដែរ ។ ព្រះអង្គក៏បាននាមថា **កេសវតាបស** ម្យ៉ាងទៀត នាយកូសាមាលារបស់ព្រះអង្គ ក៏បួសតាមជាអន្តេវាសិកនាមថា **កប្បក:** ។ កេសវតាបស និងបរិស័ទអាស្រ័យនៅក្នុងហិមវន្តប្រទេសអស់ ៨ ខែ ក្នុងរដូវភ្លៀង ត្រូវការសេពរសប្រៃ និងរសជូរ ទើបទៅកាន់ក្រុងពារាណសី ហើយចូលទៅកាន់នគរដើម្បីភិក្ខា គ្រានោះ ព្រះរាជាទតឃើញតាបសទាំងនោះ ក៏ទ្រង់កើតសេចក្តីជ្រះថ្លា ទ្រង់ប្តេជ្ញាដើម្បីប្រយោជន៍ដល់ការនៅក្នុងសម្នាក់របស់ព្រះអង្គ រហូតអស់ ៤ ខែ ក៏និមន្ត

តាបសឲ្យគង់នៅក្នុងព្រះរាជឧទ្យាន ព្រះរាជាតែងតែយាងទៅកាន់ទីទំនុកបម្រុង តាបសនោះ ទាំងព្រឹកទាំងល្ងាច ។ ចំណែកពួកតាបសដទៃសម្រាកនៅ ២-៣ ខែ រំខានដោយសំឡេងផ្សេងៗ មានសំឡេងដំរីជាដើម ក៏ពោលថា "បពិត្រលោកអាចារ្យ ពួកខ្ញុំត្រូវសេចក្ដីរំខានបៀតបៀន ដូច្នេះ ពួកខ្ញុំនឹងត្រឡប់ទៅវិញហើយ" ។

កេសវ:. នឹងទៅទីណា បា! ទាំងឡាយ ។

អន្តេវា. ទៅកាន់ហិមវន្តប្រទេសវិញ លោកអាចារ្យ ។

កេសវ:. ក្នុងថ្ងៃដែលពួកយើងមកដល់ដំបូង ព្រះរាជាទ្រង់បានទទួលបេ្ដជ្ញាដើម្បីប្រយោជន៍ដល់ការនៅក្នុងទីនេះអស់ ៤ ខែ មិនមែនឬ ពួកអ្នកនឹងទៅដូចម្ដេច ។

អន្តេវាសិកពោលថា "លោកអាចារ្យមិនប្រាប់ពួកខ្ញុំជាមុនសិន ហើយចាំថ្វាយបេ្ដជ្ញា ពួកខ្ញុំមិនអាចនឹងនៅទីនេះបានទេ នឹងនៅក្នុងទីដែល (ល្មម) នឹងដឹងសុខទុក្ខរបស់លោកអាចារ្យបាន ដែលនៅមិនឆ្ងាយអំពីទីនេះ" ដូច្នេះ ហើយនាំគ្នាថ្វាយបង្គំអាចារ្យចៀសចេញទៅ ។ ចំណែកអាចារ្យគង់នៅជាមួយអន្តេវាសិកឈ្មោះកប្បក: (ប៉ុណ្ណោះ) ។

ព្រះរាជាស្ដេចយាងមកកាន់ទីទំនុកបម្រុង បានត្រាស់សួរថា "លោកម្ចាស់ទាំងឡាយទៅណា?" កេសវតាបសទូលថា "មហាបពិត្រ តាបសទាំងនោះប្រាប់ថា ពួកខ្ញុំមានការរំខាន ដូច្នេះ ក៏ទៅកាន់ហិមវន្តប្រទេសវិញ" ។

ក្រោយមកមិនយូរប៉ុន្មាន សូម្បីកប្បកតាបសក៏ធុញទៀត សូម្បីលោកអាចារ្យឃាត់យ៉ាងណាក៏ដោយ ក៏នៅតែពោលថា "មិនអាច" ហើយក៏ចៀសចេញទៅ ។

តែកប្បកតាបសនោះ មិនទៅកាន់សម្នាក់ពួកតាបសដែលទៅមុននោះទេ រង់ចាំស្តាប់ដំណឹងរបស់អាចារ្យ នៅក្នុងទីមិនឆ្ងាយ ។

ក្រោយមក កាលអាចារ្យគិតដល់ពួកអន្តេវាសិក រោគក្នុងពោះក៏កើតឡើង ។

ព្រះរាជាត្រាស់បង្គាប់ពេទ្យឲ្យមកព្យាបាល ។ រោគក៏មិនស្ងប់ ។ តាបសទើបទូលថា "មហាបពិត្រ ព្រះអង្គមានព្រះបំណងនឹងឲ្យរោគរបស់អាត្មាស្ងប់ឬ?" ។

ព្រះរាជា. បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើខ្ញុំព្រះករុណាអាចក៏នឹងធ្វើសេចក្តីសប្បាយឲ្យដល់លោកម្ចាស់ឥឡូវនេះឯង ។

តាបស. មហាបពិត្រ ប្រសិនបើព្រះអង្គប្រាថ្នាសេចក្តីសុខដល់អាត្មា ទ្រង់បញ្ជូនអាត្មាទៅកាន់សម្នាក់ពួកអន្តេវាសិកចុះ ។

ព្រះរាជាទ្រង់ទទួលថា "ប្រពៃហើយលោកម្ចាស់" ហើយឲ្យតាបសនោះដេកលើគ្រែតូចមួយ ទ្រង់ត្រាស់បង្គាប់អាមាត្យ ៤ នាក់ មាននារទអាមាត្យជាប្រធាន ដោយបង្គាប់ថា "ពួកអ្នកដឹងដំណឹងរបស់លោកម្ចាស់របស់ពួកយើងហើយ គប្បីបញ្ជូនដំណឹងមកឲ្យយើងផង" ។

កប្បក:អន្តេវាសិកដឹងថា អាចារ្យមក ក៏ធ្វើការក្រោកទទួល កាល អាចារ្យសួរថា "ពួកតាបសក្រៅពីនេះទៅទីណា" ក៏ប្រាប់ថា "ទៅទីឯណោះ" ។ អន្តេវាសិកទាំងនោះដឹងថា អាចារ្យរបស់ខ្លួនមក (ក៏មក) ប្រជុំគ្នាក្នុងទីនោះ ថ្វាយទឹកក្តៅ និងផលាផលដល់អាចារ្យ ពេគក៏ស្ងប់ក្នុងខណ:នោះឯង ។ ព្រះ តាបសនោះមានវណ្ណៈដូចមាសក្នុងកំឡុងពេល ២-៣ ថ្ងៃប៉ុណ្ណោះ ។ គ្រានោះ នារទអាមាត្យសួរថា ៖

បពិត្រកេសីតាបសដ៏មានជោគ ហេតុអ្វី លោកទើបលះបង់ ព្រះរាជា ដែលទ្រង់ជាធំជាងមនុស្ស ជាអ្នកញុាំងនូវសម្បត្តិ គួរប្រាថ្នាទាំងពួងឲ្យសម្រេចចេញ ហើយបានមកត្រេកអរក្នុង អាស្រមរបស់កប្បកតាបស ។

តាបសឆ្លើយថា

ពាក្យពីរោះនាំឲ្យរីករាយមានហើយ រុក្ខជាតិជាទីមនោរម្យនៃ ចិត្តក៏មាន នារទ: ពាក្យដែលកប្បក:ពោលល្អហើយ រមែង ធ្វើឲ្យអាត្មាត្រេកអរបាន ។

នារទ:សួរថា

លោកម្ចាស់បរិភោគបាយនៃស្រូវសាលី ដែលផ្សំដោយរស សាច់ល្អៗ ហើយ ស្រងែ និងស្នោកែលលក ដែលរសប្រៃ មិនបាន នឹងធ្វើឲ្យលោកម្ចាស់ត្រេកអរបានយ៉ាងណា ។

តាបសឆ្លើយថា

បុគ្គលក្តីស្និទ្ធស្នាលគ្នា បរិភោគអាហារទោះបីឆ្ងាញ់ក្តី មិនឆ្ងាញ់ក្តី តិចក្តី ច្រើនក្តី ក្នុងទីណា (អាហារដែលបរិភោគក្នុងទីនោះ ក៏ឲ្យសម្រេចប្រយោជន៍បាន) ព្រោះថា សេចក្តីស្និទ្ធ-ស្នាលជារសយ៉ាងក្រៃលែង ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រជុំជាតកទើបត្រាស់ថា "ព្រះរាជាក្នុងគ្រានោះ បានមកជាមោគ្គល្លាន នារទអាមាត្យបានមកជាសារីបុត្រ អន្តេវាសិកឈ្មោះកប្បកៈ បានមកជាអានន្ទ កេសវ-តាបស គឺ តថាគតនេះឯង ដូច្នេះហើយត្រាស់ថា "យ៉ាងនោះឯង មហាបពិត្របណ្ឌិតក្នុងកាលមុន សូម្បីមានវេទនាជិតនឹងស្លាប់ក៏ដោយ ក៏នៅតែទៅកាន់សម្នាក់អ្នកដែលស្និទ្ធស្នាលនឹងខ្លួនដែរ សាវកទាំងឡាយរបស់តថាគត ប្រហែលជាមិនបាននូវសេចក្តីស្និទ្ធស្នាលអំពីសម្នាក់របស់ព្រះអង្គហើយ ។

## ព្រះរាជាទ្រង់បញ្ជូនសារទៅសូមធីតាពីសក្យរាជ

ព្រះរាជាទ្រង់តម្រិះថា "យើងគួរធ្វើសេចក្តីស្និទ្ធស្នាលជាមួយភិក្ខុសង្ឃតើយើងនឹងធ្វើយ៉ាងណាហ្ន៎?" ដូច្នេះហើយ ទ្រង់ត្រិះរិះទៀតថា គួរធ្វើព្រះរាជ-ធីតានៃព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ ទុកក្នុងព្រះរាជដំណាក់ កាលបើដូច្នេះពួកភិក្ខុកំលោះ និងពួកសាមណេរ (ក៏នឹង) ស្និទ្ធស្នាល ហើយមកកាន់សម្នាក់

របស់យើងជានិច្ច ព្រោះគិតថា "ព្រះរាជាជាព្រះញាតិរបស់ព្រះសម្មាសម្ពុទ្ធ" លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏បញ្ជូនព្រះរាជសារទៅកាន់សម្នាក់សក្យរាជទាំងឡាយថា "សូមសក្យៈទាំងឡាយ ប្រទានព្រះរាជធីតាម្នាក់ដល់ទូលបង្គំ" ហើយផ្តាំទូតទាំងឡាយថា "ពួកអ្នកគប្បីសួរថា ជាព្រះរាជធីតានៃសក្យៈអង្គណា? ហើយ (សឹម) មក" ។

## ស្ដេចសក្យៈឱ្យធីតានាងទាសីដល់ព្រះបាទបសេនទិ

ពួកទូតទៅហើយ ទូលសូមស្ត្រី (ម្នាក់) អំពីស្ដេចសក្យៈទាំងឡាយ សក្យៈត្រកូលទាំងនោះក៏ប្រជុំគ្នា ទ្រង់ព្រះតម្រិះថា "ព្រះរាជាជាបក្សពួកដទៃ បើពួកយើងមិនឲ្យ ព្រះរាជានោះនឹងធ្វើឲ្យយើងវិនាស ក៏ (កាលពោល) ដោយត្រកូល ស្ដេចនោះក៏មិនស្មើនឹងយើងឡើយ ពួកយើងគួរធ្វើយ៉ាងណាទើបល្អ"

ស្ដេចមហានាមត្រាស់ថា "ធីតារបស់ខ្ញុំឈ្មោះ វាសភខត្តិយា កើតក្នុងផ្ទៃនៃនាងទាសី ជាអ្នកមានរូបរាងស្រស់ស្អាត ពួកយើងនឹងឲ្យនាងនោះ" លុះទ្រង់ប្រឹក្សាគ្នាដូច្នេះហើយ ក៏ប្រាប់ពួកទូតថា "ប្រពៃណាស់ ពួកយើងនឹងថ្វាយធីតាដល់ព្រះរាជាអ្នក"

ទូត. ជាព្រះធីតារបស់សក្យៈអង្គណា ។

ស្ដេចសក្យៈ. ជារាជធីតារបស់មហានាមសក្យរាជ ដែលជាព្រះឱរសរបស់ស្ដេចពូព្រះសម្មាសម្ពុទ្ធ ឈ្មោះ វាសភខត្តិយា ។

ទូតទាំងនោះទៅក្រាបទូលព្រះរាជារបស់ខ្លួន ។ ព្រះរាជាត្រាស់ថា "បើដូច្នោះប្រសើរហើយ ពួកអ្នកចូរប្រញាប់នាំមកចុះ ក៏ធម្មតាពួកក្សត្រ មានកលល្បិចច្រើន (ទើង) គប្បីបញ្ជូនកូននាងទាសីមក (ក៏អាចបាន) ពួកអ្នកចូរនាំធីតាដែលជាអ្នកសោយភោជនក្នុងភាជនៈមួយជាមួយព្រះបិតាមក" លុះទ្រង់មានព្រះតម្រាស់ដូច្នេះហើយ ទ្រង់បញ្ជូនទូតទាំងនោះទៅ ។ ពួកទូតទៅដល់ក្រាបទូលថា "បពិត្រមហារាជ ព្រះរាជារបស់ខ្ញុំទ្រង់ប្រាថ្នាព្រះរាជធីតាដែលសោយរួមទីងព្រះអង្គ" ស្ដេចមហានាមត្រាស់ថា "បាន" ទើបឲ្យតាក់តែងនាង ក្នុងវេលាសោយរបស់ព្រះអង្គ ក៏ត្រាស់បង្គាប់ឲ្យហៅនាងមក សម្ដែងអាការដូចជារួមសោយជាមួយនឹងនាង ហើយប្រគល់ឲ្យដល់ទូតទាំងឡាយ ។ ពួកទូតនាំនាងទៅកាន់ក្រុងសាវត្ថី ហើយក្រាបទូលរឿងនោះថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ពេញព្រះទ័យ តែងតាំងនាងជាធំជាងស្ត្រី ៥០០ នាក់ អភិសេកជាអគ្គមហេសី ។ ក្រោយមកមិនយូរប៉ុន្មាន នាងក៏ប្រសូតព្រះឱរស មានពណ៌ដូចមាស ។ ក្នុងថ្ងៃថ្វាយព្រះនាមឱរសនោះ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសាសន៍ទៅកាន់សម្នាក់ព្រះអយ្យកាថា "ព្រះនាងវាសភខត្តិយា ព្រះធីតានៃសក្យរាជ ប្រសូតព្រះឱរសហើយ ទ្រង់នឹងថ្វាយព្រះនាមព្រះកុមារនោះដូចម្ដេច" ចំណែកអាមាត្យដែលទទួលព្រះរាជសាសន៍នោះ ជាមនុស្សត្រចៀកធ្ងន់ គេទៅហើយ ក៏ក្រាបទូលព្រះអយ្យការបស់ព្រះរាជា ។

## ព្រះរាជកុមារមានឈ្មោះថាវិឌូឌភៈ

ព្រះអយ្យកានោះទ្រង់ព្រះសណ្ដាប់ពាក្យនោះហើយ ត្រាស់ថា "ព្រះនាងវាសភខត្តិយា សូម្បីមិនបានប្រសូតព្រះឱរស ក៏បានគ្រប់គ្រងទ្រព្យទាំងអស់ឥឡូវនេះ នាងនឹងជាទីប្រោសប្រាណយ៉ាងក្រៃលែងរបស់ព្រះរាជា" ។ អាមាត្យត្រចៀកធ្ងន់ស្ដាប់ពាក្យថា "វល្លភា" មិនច្បាស់ យល់ថា "វិឌូឌភៈ" លុះចូលគាល់ព្រះរាជាហើយ ក៏ក្រាបទូលថា "បពិត្រមហារាជ សូមព្រះអង្គថ្វាយព្រះនាមព្រះរាជកុមារថា **វិឌូឌភៈ** ចុះ" ។ ព្រះរាជាទ្រង់ព្រះតម្រិះថា "ពាក្យថា វិឌូឌភៈ ជាឈ្មោះប្រចាំត្រកូលចាស់របស់យើង" ទើបទ្រង់ថ្វាយព្រះនាមដល់ព្រះកុមារថា "វិឌូឌភៈ" ។

## វិឌូឌភៈយាងទៅសួរសុខទុក្ខសក្យត្រកូល

ក្រោយមក ព្រះរាជាបានព្រះរាជទានតំណែងជាសេនាបតីដល់វិឌូឌភកុមារនោះ ក្នុងវេលាដែលទ្រង់នៅក្មេងនោះឯង ដោយតាំងព្រះទ័យថា "នឹងធ្វើឲ្យជាទីប្រោសប្រាណរបស់ព្រះសាស្ដា" ។ វិឌូឌភៈនោះ ទ្រង់បរិបូរដោយគ្រឿងសម្រាប់កុមារ ក្នុងវេលាមានព្រះជន្ម ៧ ខួប ទ្រង់ឃើញរបស់លេងផ្សេងៗ មានរូបដំរី និងរូបសេះជាដើម របស់កុមារដទៃ ដែលបុគ្គលនាំមកអំពីត្រកូលយាយ ទើបសួរព្រះមាតាថា "ព្រះមាតា នរណាៗ គេក៏នាំបណ្ណាការមកអំពីត្រកូលយាយ ដើម្បីពួកកុមារដទៃ ឯព្រះញាតិណាៗ មិនដែលបញ្ជូន

បណ្ណាការអ្វីៗ មកដើម្បីបុត្រខ្លះសោះ ព្រះមាតាមិនមានព្រះជនកព្រះជននីទេ ឬ" ពេលនោះ ព្រះមាតាក៏លួងព្រះកុមារនោះថា "កូនសម្លាញ់ សក្យរាជជាយាយរបស់កូន ប៉ុន្តែនៅឆ្ងាយ ហេតុនោះ ទើបពួកលោកមិនបានបញ្ជូនគ្រឿងបណ្ណាការណាៗ មកដើម្បីកូន" ។ ក្នុងវេលាមានព្រះជន្ម ១៦ ឆ្នាំ ព្រះកុមារក៏ទូលព្រះមាតាទៀតថា "ព្រះមាតា បុត្រមានបំណងនឹងទៅសួរសុខទុក្ខម្ចាស់យាយ" សូម្បីត្រូវព្រះមាតាហាមថា "កុំឡើយកូន កូននឹងទៅធ្វើអ្វីនៅទីនោះ" ព្រះកុមារក៏នៅតែអង្វររឿយៗ ។ ពេលនោះ ព្រះមាតារបស់ព្រះកុមារក៏ទ្រង់អនុញ្ញាតថា "បើដូច្នោះ កូនទៅចុះ" ។

## ពួកសក្យៈស្វាគមន៍វិឌូឌភៈ

ព្រះកុមារក្រាបទូលព្រះរាជបិតាហើយ យាងចេញទៅជាមួយនឹងបរិវារជាច្រើន ។ ព្រះនាងវាសភខត្តិយា ទ្រង់បញ្ជូនសំបុត្រទៅមុនថា "ខ្ញុំម្ចាស់នៅទីនេះសុខសប្បាយទេ សូមព្រះញាតិទាំងឡាយកុំសម្តែងទោសណាៗ របស់ព្រះស្វាមីដល់ព្រះកុមារនោះឡើយ" ។ សក្យត្រកូលទ្រង់ជ្រាបថា វិឌូឌភៈយាងមក ក៏ទ្រង់ប្រឹក្សាគ្នាថា "ពួកយើងមិនអាចសំពះ (វិឌូឌភកុមារ) បានទេ" លុះទ្រង់ប្រឹក្សាគ្នាដូច្នេះហើយ បញ្ជូនព្រះរាជកុមារទាំងឡាយ ដែលនៅក្មេងៗ ជាងវិឌូឌភៈនោះទៅកាន់ជនបទអស់ កាលវិឌូឌភកុមារស្តេចយាងមកដល់កបិលពស្តុបុរី ក៏ប្រជុំគ្នានៅក្នុងព្រះរោង វិឌូឌភកុមារបានទៅប្រថាប់នៅ

ទីនោះ ។

គ្រានោះ ពួកសក្យៈបាននិយាយនឹងព្រះកុមារនោះថា "នែ៎បា! នេះជាស្តេចតារបស់បា នេះជាស្តេចអ៊ំរបស់បា" ។ វិឌូឌភកុមារនោះ ដើរសំពះសក្យៈទាំងអស់ មិនបានឃើញសក្យៈសូម្បីតែមួយអង្គមកសំពះខ្លួន ទើបទូលសួរថា "ហេតុអ្វីមិនមានសក្យៈទាំងឡាយ មកសំពះខ្ញុំព្រះអង្គខ្លះ" ។

ពួកសក្យៈត្រាស់ថា "នែ៎បា! កុមារជាប្អូនៗ របស់បា យាងទៅកាន់ជនបទអស់ហើយ ហើយទ្រង់ធ្វើសក្ការៈយ៉ាងធំថ្វាយព្រះកុមារនោះ វិឌូឌភៈប្រថាប់នៅទីនោះអស់ ២-៣ ថ្ងៃ ក៏យាងចេញពីព្រះនគរដោយបរិវារដ៏ច្រើន ។ គ្រានោះ នាងទាសីម្នាក់បានជេរថា "នេះជាបន្ទះក្តារដែលបុត្ររបស់នាងទាសីឈ្មោះវាសភខត្តិយាអង្គុយ" ដូច្នេះហើយ លាងបន្ទះក្តារដែលព្រះកុមារនោះទ្រង់គង់ក្នុងព្រះរោង ដោយទឹកលាយដោយទឹកដោះ ។ ពេលនោះ មានមហាតលិកម្នាក់ភ្លេចអាវុធរបស់ខ្លួន ក៏ត្រឡប់ទៅយកអាវុធនោះ បានឮសំឡេងជេរវិឌូឌភកុមារ ក៏សួរទោសនោះ ជ្រាបថា "នាងវាសភខត្តិយា កើតនៅក្នុងផ្ទៃរបស់នាងទាសីនៃមហានាមសក្យៈ" ទើបប្រាប់ដល់ពួកពល ។ បានឮតៗគ្នាដ៏ច្រើនថា "ព្រះនាងវាសភខត្តិយា ជាធីតារបស់នាងទាសី" ។

## វិឌូឌភៈទ្រង់ចងគំនុំនឹងពួកសក្យៈ

វិឌូឌភៈទ្រង់ព្រះសណ្តាប់ពាក្យនោះ ក៏តាំងព្រះទ័យទុកថា "ពួកសក្យៈ

ទាំងនោះ លាងបន្ទះក្ដារដែលយើងអង្គុយដោយទឹកលាយទឹកដោះមុនចុះ តែក្នុងកាលដែលយើងតាំងនៅក្នុងរាជសម្បត្តិហើយ យើងនឹងយកឈាមក្នុងបំពង់ករបស់ពួកសក្យៈទាំងនោះ លាងបន្ទះក្ដារដែលយើងអង្គុយវិញ” កាលព្រះអង្គស្ដេចយាងមកដល់ក្រុងសាវត្ថី ពួកអាមាត្យក៏ក្រាបទូលរឿងទាំងអស់នោះដល់ព្រះរាជា ។ ព្រះរាជាទ្រង់ពិរោធនឹងស្ដេចសក្យៈថា “បានឲ្យធីតានៃនាងទាសីដល់យើង” ទើបត្រាស់បង្គាប់ឲ្យដកហូតគ្រឿងប្រើប្រាស់ដែលព្រះរាជទានដល់ព្រះនាងវាសភខត្តិយា និងឱរស ឲ្យព្រះរាជទានត្រឹមតែវត្ថុដែលទាសៈ និងទាសីគួរបានប៉ុណ្ណោះ ។ តមក ដោយកាលកន្លងទៅ ២-៣ ថ្ងៃ ព្រះសាស្ដាយាងទៅកាន់ព្រះរាជនិវេសន៍ ប្រថាប់គង់ហើយ ។ ព្រះរាជាស្ដេចយាងមកថ្វាយបង្គំ ហើយទូលសួរថា “បពិត្រព្រះអង្គដ៏ចម្រើន មានដំណឹងថា ពួកព្រះញាតិរបស់ព្រះអង្គ បានប្រទានធីតានៃនាងទាសីដល់ខ្ញុំព្រះអង្គ ព្រោះដូច្នោះ ទើបខ្ញុំព្រះអង្គដកហូតគ្រឿងប្រើប្រាស់របស់នាងវាសភខត្តិយា ព្រមទាំងបុត្រ ឲ្យត្រឹមតែរបស់សម្រាប់បុគ្គលដែលជាទាសៈ និងទាសីគួរបានតែប៉ុណ្ណោះ” ។

ព្រះសាស្ដាត្រាស់ថា “មហាបពិត្រ ពួកសក្យៈធ្វើអំពើនេះមិនសមគួរទេ ធម្មតាកាលទឹងឲ្យ ក៏គួរឲ្យព្រះធីតាដែលមានជាតិស្មើគ្នា មហាបពិត្រ ក៏តថាគតទូលសួរព្រះអង្គថា ព្រះនាងវាសភខត្តិយា ជាធីតានៃខត្តិយរាជ បានអភិសេកក្នុងរាជដំណាក់នៃខត្តិយរាជ ចំណែកវិឌូឌភកុមារ ក៏ទ្រង់អាស្រ័យ

ខត្តិយរាជនោះឯងប្រសូតហើយ ធម្មតាថា វង្សត្រកូលខាងមាតានឹងធ្វើអ្វីបាន វង្សត្រកូលខាងបិតាប៉ុណ្ណោះជាសំខាន់" ដូច្នេះ ទើបត្រាស់ថា បុរាណបណ្ឌិតទាំងឡាយ បានព្រះរាជទានតំណែងអគ្គមហេសី ដល់ស្រីកំសត់អ្នករែកឧសម្នាក់ និងព្រះរាជកុមារដែលកើតក្នុងផ្ទៃរបស់នាងនោះ ក៏បានដល់នូវភាពជាព្រះរាជាក្នុងនគរពារាណសី (ដ៏ធំធេង) ដល់ ១២ យោជន៍ ទ្រង់ព្រះនាមថា "**កដ្ឋវាហនរាជា**" ហើយត្រាស់កដ្ឋហារិយជាតក ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់ព្រះធម្មកថានោះហើយ ទ្រង់ត្រេកអរថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជ្រាបហើយថា វង្សត្រកូលខាងបិតាប៉ុណ្ណោះជាសំខាន់" ទើបត្រាស់បង្គាប់ឲ្យព្រះរាជទានគ្រឿងប្រើប្រាស់ដូចសព្វដងនោះឯង ដល់នាងវាសភខត្តិយា និងវិឌូឌភៈវិញ ។

## ពន្ធុលសេនាបតី

កិរិយារបស់ពន្ធុលសេនាបតី ឈ្មោះមល្លិកា ដែលជាព្រះធីតារបស់មល្លក្សត្រ ក្នុងនគរកុសិនារា មិនមានបុត្រអស់កាលជាយូរ ។ តមក ពន្ធុលសេនាបតីបញ្ជូននាងទៅថា "នាងចូរទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួនវិញចុះ" ។ នាងគិតថា "យើងចូលគាល់ព្រះសាស្ដាសិនសឹមទៅ" ទើបចូលទៅកាន់ព្រះជេតពន ឈរថ្វាយបង្គំព្រះតថាគត ដែលព្រះតថាគតត្រាស់សួរថា "ម្នាល

នាងដ៏ចម្រើន នាងទៅណា?" ក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ស្វាមីរបស់ខ្ញុំព្រះអង្គបញ្ជូនខ្ញុំព្រះអង្គទៅកាន់ផ្ទះនៃត្រកូល" ។

ព្រះសាស្ដា. ព្រោះហេតុអ្វី ?

នាង. ព្រោះខ្ញុំព្រះអង្គជាស្ត្រីអារ មិនមានបុត្រ ។

ព្រះសាស្ដា. បើដូច្នោះ កិច្ចដែលត្រូវទៅមិនមាន ចូរនាងត្រឡប់ទៅវិញចុះ ។

នាងត្រេកអរណាស់ ថ្វាយបង្គំព្រះសាស្ដាត្រឡប់ទៅកាន់និវេសន៍វិញ កាលដែលស្វាមីសួរថា "នាងត្រឡប់មកធ្វើអ្វី?" ក៏ឆ្លើយថា "ព្រះទសពលឲ្យខ្ញុំត្រឡប់មក" ។ ពន្ធុលៈគិតថា "ព្រះទសពលឃើញហេតុឆ្ងាយ នឹងឃើញហេតុ (នេះ)" ទើបព្រម ។ តមកមិនយូរប៉ុន្មាន នាងក៏តាំងគភ៌ កើតអាការចាញ់ផ្ទៃ ក៏ប្រាប់ថា "អាការចាញ់ផ្ទៃ កើតដល់ខ្ញុំហើយ" ។

ពន្ធុលៈ. នាងចាញ់គភ៌ដូចម្ដេច ?

នាង. អ្នកស្វាមី ខ្ញុំប្រាថ្នាងូតទឹក ផឹកទឹកគួរផឹកក្នុងស្រះបោក្ខរណីដែលជាមង្គល ក្នុងពិធីអភិសេកនៃគណៈរាជត្រកូលក្នុងនគរវេសាលី ។

ពន្ធុលៈពោលថា "ប្រពៃហើយនាង" ហើយកាន់ធ្នូដែលបុគ្គលគប្បីលើករួចដោយកម្លាំងបុរសមួយពាន់នាក់ បីនាងឡើងរទេះ ចូលទៅកាន់ក្រុងវេសាលី តាមទ្វារដែលស្ដេចលិច្ឆវីឲ្យដល់មហាលិលិច្ឆវី ។ ក៏ទីអាស្រ័យនៅ

របស់ស្តេចលិច្ឆវី នាមថាមហាលិ មាននៅក្នុងទីជិតទ្វារនោះឯង ។ ពេលលោកបានឮសំឡេងរថប៉ះខ្ទប់ធរណីទ្វារ ក៏ដឹងថា “សំឡេងរថរបស់ពន្ធុលៈ” ទើបពោលថា “ថ្ងៃនេះភ័យនឹងកើតមានដល់ស្តេចលិច្ឆវី” ។ ការរក្សាស្រះបោក្ខរណី គឺងរឹងទាំងខាងក្នុង និងខាងក្រៅ ចំណែកខាងលើគេបាំងដោយសំណាញ់លោហៈ សូម្បីតែបក្សីក៏មិនមានឱកាស ។ ចំណែកពន្ធុលសេនាបតីចុះពីលើរថ វាយពួកមនុស្សដែលរក្សាស្រះបោក្ខរណីដោយរំពាត់ផ្តៅ ឲ្យចៀសចេញ ហើយកាត់សំណាញ់លោហៈ ឲ្យកិរិយាចុះងូត ។ សូម្បីខ្លួនឯងក៏ចុះងូតទឹកខាងក្នុងស្រះបោក្ខរណី ហើយបីនាងឡើងរទេះចេញចាកព្រះនគរ បរទៅតាមផ្លូវដែលមកនោះឯង ។

ពួកអ្នករក្សាស្រះបោក្ខរណី ទូលរឿងនោះថ្វាយស្តេចលិច្ឆវី ។ ពួកស្តេចលិច្ឆវីខ្ញាល់ ស្តេចយាងឡើងរទេះ ៥០០ បរចេញទៅដោយចេតនាថា “នឹងចាប់ស្តេចមល្លៈឈ្មោះពន្ធុលៈ” ។ បានប្រាប់រឿងនោះដល់មហាលិ ។ ស្តេចមហាលិត្រាស់ថា “ពួកព្រះអង្គកុំយាងទៅ ព្រោះពន្ធុលៈនោះនឹងសម្លាប់ពួកព្រះអង្គទាំងអស់មិនខាន” ស្តេចលិច្ឆវីទាំងនោះ បានត្រាស់ប្រាប់មហាលិថា “ពួកខ្ញុំនឹងទៅ” ។ ស្តេចមហាលិត្រាស់ថា “បើដូច្នោះ កាលពួកទ្រង់ឃើញត្រង់កង់រទេះស្រុតលិចចុះក្នុងផែនដីរហូតដល់ដុំហើយ គប្បីយាងត្រឡប់មកវិញ

បើមិនត្រឡប់ទេ នឹងបានឮសំឡេងដូចជារន្ទះខាងមុខ គប្បីត្រឡប់អំពីទីនោះ កាលមិនត្រឡប់អំពីទីនោះ ពេលឃើញប្រហោងក្នុងនិមរទេះរបស់ពួកលោក គប្បីត្រឡប់ពីទីនោះភ្លាម កុំយាងទៅមុខទៀត (ជាដាច់ខាត)” ។

ស្ដេចលិច្ឆវីទាំងនោះ មិនយាងត្រឡប់មកវិញតាមពាក្យរបស់មហាលិ គិតតែដេញតាមពន្ធុលៈ ។ នាងមល្លិកាឃើញស្ដេចលិច្ឆវីទាំងនោះដេញតាម ក៏និយាយប្រាប់ពន្ធុលៈថា “អ្នកស្វាមី រថទាំងឡាយសំដៅរមែងប្រាកដ” ។

ពន្ធុលៈពោលថា “បើដូច្នោះ វេលាដែលរថប្រាកដជាជួរតែមួយ នាងគប្បីប្រាប់ខ្ញុំ” ។

ពេលដែលរថប្រាកដជាជួរហើយ នាងប្រាប់ថា “អ្នកស្វាមី ចន្ទោលរថប្រាកដជាជួរតែមួយហើយ” ។

ពន្ធុលៈនិយាយថា “បើដូច្នោះ នាងចូរកាន់ខ្សែទាំងនេះ” ហើយឲ្យខ្សែទៅនាងមល្លិកា ឈរលើរទេះយឹតធ្នូឡើង កង់រទេះលិចចុះទៅក្នុងផែនដីដល់ដុំ ។ ស្ដេចលិច្ឆវីទ្រង់ឃើញដូច្នោះហើយ ក៏នៅតែមិនព្រមយាងត្រឡប់ ។ ពន្ធុលៈទៅបានបន្តិច ក៏ទាញខ្សែធ្នូ សំឡេងខ្សែធ្នូនោះប្រៀបដូចជាស្នូររន្ទះ ។ ពួកស្ដេចលិច្ឆវីទាំងនោះ ក៏នៅតែមិនយាងត្រឡប់សូម្បីអំពីទីនោះ ស្ដេចនៅតែដេញតាមទៅនោះឯង ។

ពន្ធុលៈឈរនៅលើរទេះនោះឯង បាញ់កូនសរទៅមួយគ្រាប់ ។ កូន

សរនោះ បានធ្វើឲ្យចន្ទោលរទេះ ៥០០ មានប្រហោងហើយ ចាក់ទម្លុះព្រះរាជា ៥០០ ចំត្រង់កន្ទែងចង្រ្កោះ ហើយលិចចុះទៅក្នុងផែនដី ។ ស្តេចលិច្ឆវីទាំងនោះមិនបានដឹងថា ខ្លួនត្រូវសរទេ ក៏ត្រាស់ថា "ឈប់សិន ឈប់សិន" នៅតែដេញតាមទៅទៀត ។ ពន្ធុលសេនាបតីបញ្ឈប់រទេះ ហើយពោលថា "ពួកលោកជាមនុស្សស្លាប់ ឈ្មោះថា ការច្បាំងរបស់ខ្ញុំជាមួយមនុស្សស្លាប់ទាំងឡាយ រមែងមិនមាន" ។

ស្តេចលិច្ឆវី. ដែលឈ្មោះថា មនុស្សស្លាប់ដូចយើងមិនមានទេ ។

ពន្ធុល:. បើដូច្នោះ ពួកលោកចូរដោះអាវក្រោះរបស់អ្នកដែលនៅខាងក្រោយបង្អស់មើល ។

ពួកស្តេចលិច្ឆវីទាំងនោះឲ្យដោះហើយ ។ ស្តេចលិច្ឆវីទាំងនោះ ក៏ដួលចុះ អស់ជីវិតក្នុងខណៈដោះអាវក្រោះចេញនោះឯង ។ ពេលនោះ ទើបពន្ធុល: និយាយនឹងស្តេចលិច្ឆវីទាំងនោះថា "សូម្បីពួកលោកទាំងអស់ក៏ដូចគ្នា យាងទៅដល់លំនៅរបស់រៀងៗ ខ្លួន ហើយចាត់ចែងវត្ថុដែលគួរចាត់ចែង ផ្តែផ្តាំកូនប្រពន្ធហើយ សឹមដោះអាវក្រោះចេញ" ។ ស្តេចលិច្ឆវីទាំងនោះ ធ្វើដូច្នោះគ្រប់ៗ អង្គ ទើបសោយទិវង្គត ។

ចំណែកពន្ធុល: និងនាងមល្លិកាមកកាន់ក្រុងសាវត្ថី ។ នាងប្រសូតបុត្រជាគូ ៗ ដល់ ១៦ ដង ។ សូម្បីបុត្ររបស់នាងទាំងអស់នោះ សុទ្ធតែជាអ្នកក្លៀវក្លា ដល់ព្រមដោយកម្លាំង បានសម្រេចសិល្បៈទាំងអស់ ។ ម្នាក់ៗ

មានបុរសជាបរិវារមួយពាន់ ។ ព្រះលានហ្លួងពេញទៅដោយបុត្រទាំងនោះឯង ដែលទៅកាន់រាជនិវេសន៍ជាមួយបិតា ។

## ពន្ធុលសេនាបតីត្រូវសម្លាប់ព្រមទាំងបុត្រ

តមកថ្ងៃមួយ ពួកមនុស្សដែលចាញ់ក្តី ដោយក្តីកោងក្នុងការវិនិច្ឆ័យ បានឃើញពន្ធុលៈកំពុងដើរមក ក៏ស្រែកទ្រហោយំ ប្រាប់ការវិនិច្ឆ័យក្តីកោង របស់ពួកអាមាត្យដល់ពន្ធុលៈនោះ ។ ពន្ធុលៈទៅកាន់រោងវិនិច្ឆ័យ ពិចារណាក្តីនោះហើយ បានធ្វើអ្នកដែលជាម្ចាស់របស់ ឲ្យជាម្ចាស់របស់ ។ មហាជនឲ្យពរសាធុការដោយសំឡេងដ៏ខ្លាំង ព្រះរាជាទ្រង់ព្រះសណ្តាប់នូវសំឡេងនោះ ទ្រង់ក៏ត្រាស់សួរថា “ម្នាលអ្នកដ៏ចម្រើនទាំងឡាយ សំឡេងអ្វីនោះ?” កាលទ្រង់ព្រះសណ្តាប់នូវរឿងនោះហើយ ទ្រង់សោមនស្ស ឲ្យដកពួកអាមាត្យទាំងនោះចេញអំពីការវិនិច្ឆ័យ ហើយប្រគល់ការវិនិច្ឆ័យឲ្យពន្ធុលៈតែម្នាក់តែប៉ុណ្ណោះ ។ តាំងពីពេលនោះមក ពន្ធុលៈក៏វិនិច្ឆ័យក្តីដោយត្រឹមត្រូវ ។ ចាប់ផ្តើមអំពីថ្ងៃនោះមក ពួកអាមាត្យដែលវិនិច្ឆ័យក្តីកាលពីមុនមិនបានសំណូក មានកម្រៃតិច ក៏ញុះញង់ក្នុងរាជត្រកូលថា “ពន្ធុលៈចង់ធ្វើជាព្រះរាជា” ។

ព្រះរាជាទ្រង់ជឿពាក្យរបស់ពួកអាមាត្យទាំងនោះ មិនអាចគ្របសង្កត់ព្រះហឫទ័យបាន ក៏ទ្រង់ព្រះតម្រិះទៀតថា “កាលបើពន្ធុលៈត្រូវសម្លាប់ក្នុងទីនេះ ការតិះដៀលនឹងមានដល់យើង” លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់

បញ្ជាឲ្យពួកបុរសរៀបចំធ្វើឲ្យបច្ចន្តជនបទចលាចល ហើយត្រាស់បង្គាប់ឲ្យហៅពន្ធុលៈមក ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា "បានឮថា នៅជនបទមានចោរកម្រើកឡើង អ្នក ព្រមទាំងបុត្ររបស់អ្នកចូរទៅចាប់ចោរនោះមក" ហើយទ្រង់បញ្ជូននាយទាហានធំដទៃ ទៅជាមួយនឹងពន្ធុលសេនាបតីនោះ ដោយព្រះតម្រាស់ថា "ពួកអ្នកចូរកាត់សីសៈពន្ធុលសេនាបតីព្រមទាំងបុត្រ ៣២ នាក់ក្នុងទីនោះ ហើយនាំមក" ។

កាលពន្ធុលៈទៅដល់ជនបទជាយដែនហើយ ពួកចោរ ដែលព្រះរាជាទ្រង់រៀបចំទុកនោះ និយាយគ្នាថា "ម្នាលអ្នកទាំងឡាយ បានឮថា សេនាបតីមកហើយ" ហើយក៏នាំគ្នារត់គេចទៅ ។

ពន្ធុលសេនាបតី ញ៉ាំងប្រទេសនោះឲ្យស្ងប់រម្ងាប់ហើយ ក៏ត្រឡប់មកវិញ ។ គ្រានោះ ទាហានទាំងនោះក៏កាត់សីសៈរបស់ពន្ធុលសេនាបតី ព្រមទាំងបុត្រទាំងអស់ក្នុងទីជិតព្រះនគរ ។

## នាងមល្លិកាទេវីមិនមានសេចក្តីខូចចិត្ត

ថ្ងៃនោះ នាងមល្លិកាទេវី បាននិមន្តព្រះអគ្គសាវកទាំងពីរព្រមទាំងភិក្ខុ ៥០០ អង្គ ។

លុះព្រឹកឡើង ពួកមនុស្សបាននាំសំបុត្រមកឲ្យនាង មានសេចក្តីថា "ចោរកាត់ក្បាលស្វាមី ព្រមទាំងបុត្ររបស់នាងអស់ហើយ" នាងដឹងរឿងនោះ

ហើយ មិនប្រាប់នរណាៗ បត់សំបុត្រដាក់ក្នុងថ្នក់សំពត់ អង្គាសភិក្ខុសង្ឃតទៅ ។

គ្រានោះ ស្រីបម្រើរបស់នាងថ្វាយកត្តដល់ភិក្ខុហើយ នាំថាសទឹកដោះថ្លាមក ធ្វើថាសឲ្យបែកត្រង់ទីចំពោះមុខព្រះថេរៈ ព្រះធម្មសេនាបតីពោលថា "វត្ថុដែលមានការបែកធ្លាយជាធម្មតា ក៏បែកទៅហើយ នរណាៗ មិនគួរគិត" ។

នាងមល្លិកានាំយកសំបុត្រចេញពីថ្នក់សំពត់ ប្រាប់លោកថា "គេនាំសំបុត្រនេះមកឲ្យដល់នាងខ្ញុំម្ចាស់ សេចក្តីថា ពួកចោរកាត់ក្បាលបិតាព្រមទាំងបុត្រ ៣២ នាក់ នាងខ្ញុំសូម្បីដឹងរឿងនេះហើយ ក៏មិនបានគិត និយាយទៅថ្វី (ត្រឹមតែ) ថាសទឹកដោះបែក នាងខ្ញុំនឹងគិតធ្វើអ្វី" ។

ព្រះធម្មសេនាបតីពោលពាក្យជាដើមថា ៖

**ជីវិតរបស់សត្វទាំងឡាយ ក្នុងលោកនេះ មិនមាននិមិត្ត**
**នរណាៗ ក៏ដឹងមិនបាន ទាំងមិនទៀង ទាំងតិចតួច និង**
**ជីវិតនោះ ប្រកបដោយសេចក្តីទុក្ខ" ។**

សម្តែងធម៌ចប់ ក៏ក្រោកចាកអាសនៈទៅកាន់វិហារ ។

ចំណែកនាងមល្លិកា ឲ្យគេទៅហៅកូនប្រសារស្រីទាំង ៣២ នាក់មកហើយទូន្មានថា "ស្វាមីរបស់ពួកនាងមិនមានកំហុស បានទទួលផលកម្មក្នុងជាតិមុនរបស់ខ្លួន នាងទាំងឡាយ កុំសោកសៅ កុំខ្សឹកខ្សួល កុំធ្វើការចងគំនុំនឹងព្រះរាជាឡើយ" ។ ចារបុរសរបស់ព្រះរាជាស្តាប់ពាក្យនោះហើយ ទៅក្រាប

ទូលនូវការដែលជនទាំងនោះ មិនមានទោសចំពោះព្រះរាជា ។ ព្រះរាជាទ្រង់ ដល់នូវការស្ពុតព្រះហឫទ័យ ស្ដេចយាងទៅកាន់និវេសន៍របស់នាងមល្លិកា ឲ្យ នាងមល្លិកា និងកូនប្រសាររបស់នាងអត់ទោសឲ្យ ហើយបានព្រះរាជទានពរ ដល់នាងមល្លិកា នាងក្រាបទូលថា "ពរ សូមជាពរដែលនាងខ្ញុំម្ចាស់ទទួលទុក ចុះ" កាលព្រះរាជាស្ដេចយាងទៅវិញ នាងថ្វាយកត្តដើម្បីមនុស្សស្លាប់ ងូត ទឹកហើយ ចូលទៅគាល់ព្រះរាជាទូលថា "បពិត្រមហាតេជៈ ព្រះអង្គព្រះរាជ-ទានពរឲ្យខ្ញុំម្ចាស់ហើយ ម្យ៉ាងទៀត ខ្ញុំម្ចាស់មិនមានសេចក្ដីត្រូវការដោយរបស់ ដទៃទេ សូមព្រះអង្គទ្រង់អនុញ្ញាតឲ្យកូនប្រសារទាំង ៣២ នាក់ របស់ខ្ញុំម្ចាស់ និងខ្លួនខ្ញុំម្ចាស់ត្រឡប់ទៅផ្ទះវិញចុះ" ។

ព្រះរាជាទ្រង់ទទួលហើយ ព្រះនាងមល្លិកាបញ្ជូនកូនប្រសារទាំង ៣២ នាក់ ទៅកាន់ត្រកូលរៀងៗ ខ្លួន ។ ចំណែកនាងទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន ក្នុងនគរកុសិនារា ។ ចំណែកព្រះរាជា ទ្រង់បានព្រះរាជទានតំណែងសេនាបតី ដល់ **ទីឃការាយនៈ** ដែលជាក្មួយរបស់ពន្ធុលសេនាបតី ។ ឯទីឃការាយនៈ នោះ ស្វែងរកកំហុសរបស់ព្រះរាជា ដោយគិតថា "អាំរបស់យើងត្រូវព្រះរាជា អង្គនេះ បញ្ជាឲ្យគេសម្លាប់ហើយ" បានឮថា ចាប់តាំងពីការដែលពន្ធុលៈ ដែលមិនមានកំហុសត្រូវសម្លាប់ហើយ ព្រះរាជាទ្រង់មានវិប្បដិសារៈ មិនបាន ទទួលការសប្បាយព្រះទ័យ មិនបានសោយនូវសេចក្ដីសុខក្នុងព្រះរាជសម្បត្តិ ឡើយ ។

## ព្រះរាជាសោយទិវង្គត

គ្រានោះ ព្រះសាស្ដា ទ្រង់ប្រថាប់នៅនិគមឈ្មោះមេទឡុបៈ នៃពួកសក្យរាជ ។ ព្រះរាជាស្ដេចយាងទៅកាន់ទីនោះហើយ ទ្រង់ឲ្យបោះជំរំក្នុងទីមិនឆ្ងាយពីអារាម ហើយស្ដេចយាងទៅកាន់វិហារដោយបរិវារជាច្រើន ដោយទ្រង់ព្រះតម្រិះថា "នឹងថ្វាយបង្គំព្រះសាស្ដា" ព្រះរាជទានគ្រឿងរាជកកុធភណ្ឌទាំង ៥[១] ដល់ទីឃការាយនៈ ហើយស្ដេចយាងចូលកាន់ព្រះគន្ធកុដិ តែមួយព្រះអង្គឯងប៉ុណ្ណោះ ។ គប្បីជ្រាបរឿងទាំងអស់នោះ តាមទំនងនៃធម្មចេតិយសូត្រចុះ ។ កាលព្រះរាជាស្ដេចចូលទៅកាន់ព្រះគន្ធកុដិហើយ ទីឃការាយនៈក៏កាន់យកគ្រឿងកកុធភណ្ឌទាំងនោះ ធ្វើវិឌូឌភៈឲ្យជាព្រះរាជា បន្សល់ទុកសេះមួយ និងស្ត្រីបម្រើម្នាក់ ហើយត្រឡប់ទៅក្រុងសាវត្ថីវិញ ។ ព្រះរាជាត្រាស់បិយកថាជាមួយព្រះសាស្ដារួចហើយ យាងចេញមកវិញ ទ្រង់មិនឃើញសេនាក៏ត្រាស់សួរស្រីនោះ ទ្រង់បានដឹងរឿងនោះហើយ ទ្រង់ព្រះតម្រិះថា "យើងនឹងនាំក្មួយរបស់យើងទៅចាប់វិឌូឌភៈ" ដូច្នេះ ហើយស្ដេចយាងទៅកាន់ក្រុងរាជគ្រឹះ លុះស្ដេចយាងទៅដល់ព្រះនគរ គេក៏បិទទ្វារព្រះនគរល្ងាច ព្រះរាជាក៏ផ្ទំក្នុងសាលាមួយក្បែរទ្វារនគរ ទ្រង់នឿយហត់ព្រោះខ្យល់ និងកម្ដៅថ្ងៃខ្លាំង

---

១ គ្រឿងប្រដាប់ព្រះកិត្តិយសរបស់ស្ដេចផែនដី មាន ៥ គឺ ខ្សែបាមរី ១ , មកុដ ១ , ព្រះខាន់ ១ , ធារព្រះកាណិ ១ , ស្បែកជើង ១ ។ កន្លែងខ្លះថា ព្រះខាន់ ១ , ស្វេតច្ឆត្រ ១ , មកុដ ១ , ស្បែកជើង ១ និងផ្លិតវាលវិជ្ជនី ១ ។

ពេក ក៏សោយទិវង្គតក្នុងទីនោះ នៅពេលពាក់កណ្ដាលយប់ ។ លុះភ្លឺឡើង ប្រជាជនបានឮសំឡេងស្ត្រីនោះយំរៀបរាប់ថា "បពិត្រព្រះសម្មតិទេព ព្រះអង្គជាស្ដេចនៃដែនកោសល ព្រះអង្គមិនមានទីពឹងឡើយ" ក៏ក្រាបទូលព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជាឲ្យធ្វើសរីរកិច្ចរបស់ម្ចាស់អ៊ំដោយសក្ការៈដ៏ធំ ។

## ព្រះចាងវិឌូឌភៈយាងទៅគាល់ព្រះសាស្ដា

ចំណែកព្រះបាទវិឌូឌភៈបានរាជសម្បត្តិហើយ ទ្រង់រឭកដល់ពៀរនោះ ទ្រង់ត្រិះរិះថា "យើងនឹងញ៉ាំងពួកសក្យៈទាំងនោះឲ្យស្លាប់" ដូច្នេះ ទើបស្ដេចយាងចេញទៅដោយសេនាដ៏ធំ ។ ក្នុងថ្ងៃនោះ ព្រះសាស្ដាទ្រង់ប្រមើលមើលសត្វលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញសេចក្ដីវិនាសនៃពួកញាតិហើយ ទ្រង់ព្រះតម្រិះថា "តថាគតគួរធ្វើញាតិសង្គហៈ" ក្នុងវេលាព្រឹក ទ្រង់យាងទៅដើម្បីបិណ្ឌបាត ត្រឡប់មកអំពីបិណ្ឌបាតវិញ ទ្រង់សម្រេចសីហសេយ្យាក្នុងព្រះគន្ធកុដិ ។ ក្នុងវេលាល្ងាច ស្ដេចយាងទៅតាមផ្លូវអាកាស ទ្រង់ប្រថាប់ក្រោមដើមឈើដែលមានម្លប់ស្ដើងៗ ជិតក្រុងកបិលពស្ដុ ។ នៅទីជិតនោះ មានដើមជ្រៃដែលមានម្លប់ត្រឈឹងត្រឈៃមួយដើម នៅក្នុងរាជសីមារបស់ព្រះបាទវិឌូឌភៈ ព្រះបាទវិឌូឌភៈទតឃើញព្រះសាស្ដា ក៏យាងចូលទៅគាល់ ថ្វាយបង្គំហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់ប្រថាប់ក្រោមដើមឈើដែលមានម្លប់តិចៗ ក្នុងវេលាក្ដៅបែបនេះ សូមព្រះអង្គមេត្តា

ប្រថាប់ក្រោមដើមជ្រៃ ដែលមានម្លប់ដ៏ក្រាស់នោះចុះ” ព្រះសាស្តាតបវិញថា “ណ្ហើយចុះមហាបពិត្រ ដែលឈ្មោះថា ម្លប់នៃពួកញាតិទើបជារបស់ត្រជាក់” ទើបទ្រង់ត្រិះរិះថា “ព្រះសាស្តាទ្រង់ស្តេចយាងមក ដើម្បីរក្សាពួកញាតិ” ទើបថ្វាយបង្គំព្រះសាស្តា ហើយយាងត្រឡប់ទៅកាន់ក្រុងសាវត្ថីវិញ ។ ចំណែកព្រះសាស្តាក៏ទ្រង់ហោះទៅកាន់វត្តជេតពនវិញដែរ ។ ព្រះរាជាទ្រង់រឭកដល់ទោសនៃពួកសក្យៈ ស្តេចចេញទៅលើកទី ២ ក៏ទតឃើញព្រះសាស្តាទ្រង់ប្រថាប់នៅទីនោះទៀត ក៏យាងត្រឡប់ទៅវិញ ។ ស្តេចយាងចេញទៅលើកទី ៣ ក៏ទ្រង់ឃើញព្រះសាស្តាក្នុងទីនោះ ស្តេចក៏យាងត្រឡប់ទៀត ។ ប៉ុន្តែកាលព្រះបាទវិឌូឌភៈ យាងចេញទៅលើកទី ៤ ព្រះសាស្តាទ្រង់ពិចារណាឃើញបុព្វកម្មរបស់ពួកសក្យៈទាំងឡាយ ទ្រង់ជ្រាបថា កម្មដ៏លាមក គឺ ការបាចថ្នាំពិសក្នុងស្ទឹងនៃពួកសក្យៈទាំងនោះ ជាកម្មដែលនរណាៗ ហាមឃាត់មិនបាន ទើបមិនយាងទៅលើកទី ៤ ។ ព្រះបាទវិឌូឌភៈយាងចេញទៅដោយពលសេនាដ៏ច្រើន ដោយទ្រង់ព្រះតម្រិះថា “យើងនឹងសម្លាប់ពួកសក្យៈ” ។

## ព្រះបាទវិឌូឌភៈសម្លាប់ពួកសក្យៈ

ក៏ព្រះញាតិទាំងឡាយរបស់ព្រះសម្មាសម្ពុទ្ធ ជាអ្នកវៀរចាកការសម្លាប់សត្វ សូម្បីស្លាប់ក៏មិនផ្តាច់ជីវិតរបស់សត្វដទៃដែរ ។ ពួកសក្យៈទាំងនោះគិតថា “ពួកយើងហ្វឹកហាត់ហើយ មានគ្រឿងចងដែលធ្វើល្អហើយ មានការហ្វឹក-

ហាត់មកច្រើនហើយ តែពួកយើងមិនអាចសម្លាប់សត្វដទៃឡើយ ពួកយើងនឹងសម្តែងកម្មរបស់ខ្លួនឲ្យអស់ទៅ” ។ ពួកសក្យៈទាំងនោះ ទ្រង់មានគ្រឿងចងដែលធ្វើហើយ ទើបស្តេចយាងចេញទៅផ្តើមការប្រយុទ្ធ ។ កូនសរដែលពួកសក្យៈទាំងនោះបាញ់ទៅ ទៅតាមចន្លោះៗ នៃពួកកងទ័ពរបស់ព្រះបាទវិឌូឌភៈចេញទៅតាមចន្លោះខែល និងចន្លោះត្រចៀកជាដើម ។ ព្រះបាទវិឌូឌភៈទតឃើញ ទើបត្រាស់ថា “នែពួកសក្យៈ ពួកលោករមែងត្រាស់ថា ពួកយើងជាអ្នកមិនសម្លាប់សត្វ មិនមែនឬ? បើដូច្នោះ ហេតុដូចម្តេចពួកសក្យៈទើបបាញ់ទ័ពរបស់យើងឲ្យវិនាស” គ្រានោះ បុរសម្នាក់ក្រាបទូលព្រះបាទវិឌូឌភៈថា “បពិត្រព្រះអង្គ ព្រះអង្គទ្រង់ពិនិត្យមើលហើយឬ” ។

ព្រះបាទវិឌូឌភៈ. ពួកសក្យៈញាំងបុរសរបស់យើងឲ្យវិនាស ។

បុរស. បុរសណាៗ របស់ព្រះអង្គ ឈ្មោះថា ស្លាប់ហើយ រមែងមិនមាន សូមព្រះអង្គបញ្ជាឲ្យរាប់បុរសទាំងនោះចុះ ។

ព្រះបាទវិឌូឌភៈកាលបញ្ជាឲ្យរាប់មើល ទ្រង់មិនឃើញអស់សូម្បីតែម្នាក់ ។ ព្រះអង្គយាងត្រឡប់អំពីទីនោះ ហើយត្រាស់ថា “នែ៎ បើនរណាៗប្រាប់ថា ពួកយើងជាសក្យៈ អ្នកទាំងឡាយចូរសម្លាប់អ្នកទាំងអស់នោះ ប៉ុន្តែឲ្យជីវិតដល់មនុស្សដែលឈរនៅក្នុងសម្នាក់របស់សក្យមហានាម ដែលជាស្តេចតារបស់យើង ។ ពួកសក្យៈទាំងឡាយ មិនឃើញវត្ថុណាដែលខ្លួនគប្បីកាន់

យក ពួកខ្លះឈរបៀមស្មៅ ពួកខ្លះឈរកាន់ដើមបបុស ត្រូវគេសួរថា "លោកជាសក្យៈឬ?" ព្រោះហេតុតែពួកសក្យៈទាំងនោះ សូម្បីទីងស្លាប់ក៏មិននិយាយកុហក ពួកដែលឈរបៀមស្មៅក៏ពោលថា "មិនមែនពួកសក្យៈ គឺស្មៅ" ។ ពួកដែលកាន់ដើមបបុស ក៏ពោលថា "មិនមែនពួកសក្យៈ គឺដើមបបុស" ។ ពួកសក្យៈទាំងនោះ និងពួកសក្យៈដទៃ ដែលឈរនៅក្នុងសម្នាក់នៃសក្យមហានាម ក៏បានរួចជីវិត ។ បណ្ដាពួកសក្យៈទាំងនោះ ពួកសក្យៈដែលឈរបៀមស្មៅ ឈ្មោះថា សក្យៈស្មៅ ពួកដែលឈរកាន់ដើមបបុស ឈ្មោះថាសក្យបបុស ។ ព្រះបាទវិឌូឌភៈ បញ្ជាឲ្យសម្លាប់ពួកសក្យៈដ៏សេសទាំងឡាយមិនវៀរសូម្បីតែទារកដែលនៅមិនទាន់ផ្ដាច់ដោះ ញុំាងស្ទឹង គឺ លោហិតឲ្យហូរទៅ ហើយបញ្ជាឲ្យលាងបន្ទះក្ដារដោយលោហិតក្នុងបំពង់កនៃពួកសក្យៈទាំងនោះ ។ សក្យវង្សត្រូវព្រះបាទវិឌូឌភៈ កាត់ផ្ដាច់ហើយដោយអាការយ៉ាងនេះ ។ ព្រះបាទវិឌូឌភៈ ត្រាស់បង្គាប់ឲ្យចាប់សក្យមហានាម ហើយស្ដេចយាងត្រឡប់ទៅវិញ លុះដល់វេលាសោយព្រះក្រយាហារពេលព្រឹក ទ្រង់ក៏ត្រិះរិះថា "យើងនឹងសោយអាហារព្រឹក" ដូច្នេះ ហើយទ្រង់ចៀងទៅកាន់ទីកន្លែងមួយ កាលភោជនដែលបុគ្គលនាំចូលទៅ ក៏បញ្ជាឲ្យហៅសម្ដេចតាមកដោយព្រះតម្រាស់ថា "យើងនឹងសោយរួមគ្នា" ។

## មានះរបស់ក្សត្រ

ប៉ុន្តែក្សត្រទាំងឡាយ សូម្បីអស់ជីវិតក៏មិនព្រមសោយរួមទីងបុត្រនាង ទាសីដែរ ព្រោះហេតុនោះ មហានាមទតឃើញស្រះមួយ ក៏ត្រាស់ថា "យើង មានរាងកាយកខ្វក់ណាស់ បា! យើងនឹងងូតទឹក" ។

ព្រះបាទវិឌូឌភៈត្រាស់ថា "ប្រពៃហើយ ព្រះអយ្យកោ យាងងូតចុះ" មហានាមទ្រង់ត្រិះរិះថា "ព្រះបាទវិឌូឌភៈនេះ នឹងសម្លាប់យើងដែលមិនបរិភោគ រួមជាមួយ ការស្លាប់ដោយខ្លួនឯងប៉ុណ្ណោះ ប្រសើរជាង" លុះទ្រង់ព្រះតម្រិះ ដូច្នេះហើយ ទ្រង់ក៏រំសាយសក់ ស៊កមេជើងទៅក្នុងសក់ មូរឲ្យជាកំនួចត្រង់ ចុង មុជចុះទៅក្នុងទឹក ។ ដោយតេជះនៃគុណមហានាមនោះ ពិភពនាគក៏ សម្តែងអាការក្តៅ ។ ស្តេចនាគពិចារណាថា "មានរឿងអ្វីទៅហ្ន៎" ឃើញ មហានាមហើយ ក៏មកកាន់សម្នាក់មហានាម ឲ្យមហានាមប្រថាប់លើពពារ ហើយយាងស្តេចចូលទៅកាន់ពិភពនាគ ។ មហានាមនៅក្នុងពិភពនាគអស់ ១២ ឆ្នាំ ។ ចំណែកព្រះបាទវិឌូឌភៈ គង់ចាំសក្យមហានាម ដោយព្រះតម្រិះ ថា "ព្រះអយ្យកោរបស់យើង នឹងមកក្នុងកាលឥឡូវនេះ" កាលមហានាមនោះ បាត់យូរ ក៏ត្រាស់បង្គាប់ឲ្យរាវរកក្នុងស្រះ ទោះខំប្រឹងរាវរកយ៉ាងណាក៏ដោយ ក៏មិនឃើញ កាលរកមិនឃើញ ស្តេចក៏យាងទៅ ដោយព្រះតម្រិះថា "តា របស់យើងប្រាកដជាយាងទៅហើយ" ។

## ព្រះបាទវិឌូឌភៈត្រូវទឹកជំនន់ក្បួចពង្រិចសោយទិវង្គត

*ព្រះបាទវិឌូឌភៈ ស្ដេចយាងទៅដល់ស្ទឹងអចិរវតីក្នុងវេលារាត្រី ត្រាស់បង្គាប់ឲ្យបោះជំរំនៅទីនោះ ។ មនុស្សពួកខ្លះដេកនៅលើឆ្នេរខ្សាច់ខាងក្នុងស្ទឹង ពួកខ្លះដេកនៅលើគោកខាងក្រៅ ។ បណ្ដាពួកជនដែលដេកនៅក្នុងខាងក្នុង ពួកដែលមានបាបកម្មមិនបានធ្វើក្នុងកាលមុនក៏មាន ។ បណ្ដាពួកជនដែលដេកនៅខាងក្រៅ ដែលមានបាបកម្មបានធ្វើទុកហើយក្នុងកាលមុនក៏មាន ស្រមោចក្រហមទាំងឡាយ ក៏បានកើតឡើងក្នុងទីដែលមនុស្សទាំងនោះដេក ។ ជនទាំងនោះនិយាយថា "ស្រមោចក្រហមកើតឡើងហើយក្នុងទីដែលពួកយើងដេក ស្រមោចក្រហមកើតឡើងហើយ ក្នុងទីដែលពួកយើងដេក" ក៏ក្រោកឡើង ពួកដែលមិនមានបាបកម្ម ក្រោកឡើងទៅដេកលើគោក ពួកដែលមានបាបកម្មចុះទៅដេកត្រង់ឆ្នេរខ្សាច់ ។ ខណៈនោះ មហាមេឃក៏តាំងឡើង ញុំាងគ្រាប់ភ្លៀងឲ្យធ្លាក់ចុះ អន្លង់ទឹកក៏ជន់ឡើងមក ញុំាងព្រះបាទវិឌូឌភៈព្រមទាំងបរិស័ទទៅកាន់សមុទ្រ ។ ជនទាំងអស់នោះ បានជាចំណីត្រី និងអណ្ដើកក្នុងសមុទ្រនោះឯង ។*

*មហាជនសន្ទនាគ្នាថា "ការស្លាប់របស់សក្យៈទាំងឡាយ មិនសមគួរឡើយ ការស្លាប់របស់ពួកសក្យៈដែលព្រះបាទវិឌូឌភៈប្រហារឲ្យស្លាប់យ៉ាងនេះគួរហើយ" ។*

## ពួកសក្យៈស្លាប់សមគួរដល់បុព្វកម្ម

ព្រះសាស្ដាទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការស្លាប់យ៉ាងនេះ មិនសមគួរដល់ពួកសក្យៈទាំងឡាយក្នុងអត្តភាពនេះក៏ពិតមែនហើយ ប៉ុន្តែការស្លាប់ដែលពួកសក្យៈទាំងនោះបានទទួលហើយសមគួរពិត ដោយអំណាចនៃកម្មដ៏លាមក ដែលខ្លួនធ្វើទុកហើយក្នុងកាលមុន" ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ក៏ពួកសក្យៈទាំងឡាយនោះ បានធ្វើកម្មអ្វីទុកក្នុងកាលមុន ?

ព្រះសាស្ដា. ក្នុងកាលមុន ពួកសក្យៈទាំងនោះ រួមគ្នាជាពួក បាចថ្នាំពិសទៅក្នុងស្ទឹង ។

ថ្ងៃស្អែកឡើង ពួកភិក្ខុទាំងឡាយ ញុំាងកថាឲ្យតាំងឡើងក្នុងរោងធម៌ថា "ព្រះបាទវិឌូឌភៈ បានញុំាងសក្យៈទាំងឡាយ ប្រមាណប៉ុណ្ណោះឲ្យស្លាប់ហើយស្ដេចយាងមក កាលមនោរថរបស់ខ្លួននៅមិនទាន់ដល់បំផុតនោះឯង ក៏នាំជនប្រមាណប៉ុណ្ណោះ (ទៅ) ជាអាហាររបស់ត្រី និងអណ្ដើកក្នុងសមុទ្រហើយ" ព្រះសាស្ដាយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ តើអ្នកទាំងឡាយសន្ទនាគ្នាដោយកថាអ្វី?" កាលភិក្ខុទាំងនោះទូលថា "ដោយកថាឈ្មោះនេះ" ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលមនោរថរបស់សត្វទាំងនេះ

នៅមិនទាន់ដល់ទីបំផុតនោះឯង មច្ចុរាជផ្តាច់ជីវិតិន្ទ្រិយ៍ ហើយឲ្យលិចចុះក្នុង សមុទ្រ គឺ អបាយភូមិ ៤ ដូចអន្លង់ទឹកដ៏ធំ ជន់ពន្លិចអ្នកស្រុកដែលដេកលក់ ដូច្នោះ" ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ
សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។

មច្ចុ គឺ សេចក្តីស្លាប់ តែងកៀរយកទៅនូវនរជនអ្នកមាន ចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេង ៗ កំពុងជ្រើសរើសនូវ ផ្កា គឺ កាមគុណ ៥ នុ៎ះឯង ដូចទឹកជំនន់ធំ ដែលកួចយក អ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះឯង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ព្យាសត្តមនសំ នរំ (នរៈដែលមានចិត្ត ជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ) សេចក្តីថា អ្នកមានចិត្តជាប់ជំពាក់ហើយក្នុង អារម្មណ៍ ដែលដល់ព្រមហើយ ឬដែលមិនទាន់ដល់ព្រមហើយ ។

ព្រះមានព្រះភាគ ត្រាស់អធិប្បាយពាក្យនេះទុកថា នាយមាលាការចូល ទៅកាន់សួនផ្កា គិតថា "នឹងបេះផ្កាឈើទាំងឡាយ" ហើយមិនបេះយកផ្កាឈើ អំពីសួននោះ ប្រាថ្នាគំនរផ្កាដទៃៗ ឈ្មោះថា បញ្ជូនចិត្តទៅក្នុងសួនផ្កាឈើ ទាំងអស់ ឬគិតថា "យើងនឹងបេះផ្កាឈើអំពីគំនរនេះ" ហើយមិនបេះយកផ្កា

អំពីគំនរនោះ រមែងបញ្ជូនចិត្តទៅកាន់ទីដទៃ ជ្រើសរើសនូវគំនរផ្កាឈើនោះឯង ឈ្មោះថា រមែងដល់នូវសេចក្ដីប្រមាទ យ៉ាងណា នរជនខ្លះក៏ដូច្នោះដែរ ញ៉ាំងចិត្តចុះកាន់កណ្ដាលកាមគុណ ៥ ដូចសួនផ្កា បានរូបដែលជាទីពេញចិត្តហើយ ប្រាថ្នាក្លិន រស ផោដ្ឋព្វៈ ដែលជាទីពេញចិត្តដទៃទៀត ឬបាននូវអារម្មណ៍ណាមួយ មានសំឡេងជាដើមហើយ ប្រាថ្នាអារម្មណ៍ដទៃទៀត ឬបានរូបនោះហើយ ប្រាថ្នាអារម្មណ៍ផ្សេងទៀត ឈ្មោះថា រមែងត្រេកអរនឹងអារម្មណ៍នោះឯង ឬបានអារម្មណ៍ទាំងឡាយមានសំឡេងជាដើម ហើយប្រាថ្នាអារម្មណ៍ដទៃទៀត (ឈ្មោះថា រមែងត្រេកអរជាមួយអារម្មណ៍ដែលខ្លួនបានហើយ) ។ បណ្ដាសវិញ្ញាណកទ្រព្យ និងអវិញ្ញាណកទ្រព្យ មានគោ ក្របី ទាសៈ ទាសី ស្រែ ចម្ការ ស្រុក និគម និងជនបទជាដើម ក៏ន័យនោះឯង ។ ចំណែកបរិវេណវិហារ និងបច្ច័យ មានបាត្រ និងចីវរជាដើមរបស់បព្វជិត ក៏មានន័យនោះដូចគ្នា ។ (មច្ចុរាជរមែងនាំ) នរជនដែលមានចិត្តជាប់ជំពាក់ក្នុងកាមគុណដែលដល់ព្រមហើយ ឬមិនទាន់ដល់ព្រម ដែលកំពុងជ្រើសរើសផ្កាឈើ ពោលគឺ កាមគុណ ៥ យ៉ាងនេះ ដោយប្រការដូច្នេះ (ទៅ) ។

បទថា **សុត្តំ គាមំ (អ្នកស្រុកដែលដេកលក់ហើយ)** សេចក្ដីថា ដែលឈ្មោះថា ការដេកលក់ ដោយអំណាចនៃការដេកលក់ព្រោះទព្វសម្ភារៈទាំងឡាយ មានជញ្ជាំងផ្ទះជាដើមនៃផ្ទះ រមែងមិនមាន ប៉ុន្តែផ្ទះឈ្មោះថា ដេកលក់ហើយ ក៏ព្រោះប្រៀបធៀបនឹងសត្វទាំងឡាយដែលប្រមាទហើយ ដូចការ

ដេកលក់ដូច្នោះ មច្ចុនាំ (នរជន) ទៅ ដូចអន្លង់ទឹកធំ និងជ្រៅ ២-៣ យោជន៍ (ក្ដួចនាំ) អ្នកស្រុកដែលកំពុងដេកលក់ហើយនោះឯងទៅដូច្នោះ គឺថា អន្លង់ទឹកធំនោះ ក្ដួចនាំអ្នកស្រុកទាំងអស់នោះទៅកាន់សមុទ្រ មិនឲ្យសត្វណា ៗ ក្នុងបណ្ដាបុរស ស្ត្រី គោ ក្របី និងមាន់ជាដើមសល់នៅ ធ្វើឲ្យជាចំណីរបស់ត្រី និងអណ្ដើក យ៉ាងណា មច្ចុរាជ គឺ សេចក្ដីស្លាប់ នាំនរជនដែលមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ គឺ ផ្ដាច់ឥន្ទ្រិយ៍ គឺ ជីវិតរបស់នរជននោះឲ្យលិចចុះក្នុងសមុទ្រ គឺ អបាយភូមិទាំង ៤ ក៏ដូច្នោះដែរ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ធម្មទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងព្រះចានវិគ្គឧភ:

# ៤. រឿងនាងបតិបូជិកា

ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធស្ត្រីម្នាក់ឈ្មោះ **បតិបូជិកា** ត្រាស់ព្រះធម្មទេសនានេះថា **បុប្ផានិ ហេវ** (ជ្រើសរើសផ្កាហើយ) ជាដើម ។

រឿងនេះកើតឡើងនៅក្នុងតាវត្តិង្សទេវលោក ។

## ទេពធីតាចុតិហើយកើតក្នុងក្រុងសាវត្ថី

បានឮថា ទេវបុត្រនាមថា មាលាការី នៅក្នុងតាវត្តិង្សទេវលោកនោះ មានទេពអប្សរ ១.០០០ ហែហមហើយ ចូលទៅកាន់សួន ។ ទេពធីតា ៥០០ ឡើងដើមឈើញាំងផ្កាឲ្យធ្លាក់ចុះ ។ ទេពធីតា ៥០០ ទៀតរើសយកផ្កាឈើដែលទេពធីតាទាំងនោះបេះទម្លាក់មក មកប្រដាប់ឲ្យទេវបុត្រ ។ បណ្តាទេពធីតាទាំងនោះ ទេពធីតា ១ អង្គចុតិនៅលើមែកឈើនោះឯង ។ សរីរៈរលត់ទៅ ដូចអណ្តាតប្រទីប នាងបដិសន្ធិក្នុងផ្ទៃនៃស្ត្រីម្នាក់ក្នុងក្រុងសាវត្ថី វេលាដែលនាងកើតហើយជាស្រីដែលរឭកជាតិបាន រឭកបានថា "យើងជាភរិយារបស់មាលាភារីទេវបុត្រ" លុះដល់ការចម្រើនវ័យហើយ ធ្វើការបូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម ប្រាថ្នាឲ្យបានទៅកើតក្នុងសម្នាក់ស្វាមី ។ នាងសូម្បីទៅកាន់ត្រកូលដទៃ ក្នុងវេលាមានអាយុ ១៦ ឆ្នាំ បានថ្វាយសលាកភត្ត បក្ខិកភត្ត និងវស្សាវាសិកភត្តជាដើម ហើយរមែងពោលថា "ចំណែក

នៃបុណ្យនេះ ចូរជាបច្ច័យដើម្បីប្រយោជន៍ដល់ការកើតក្នុងសម្នាក់ស្វាមីរបស់យើង" ។

## ចុតិពីមនុស្សលោកទៅកើតក្នុងសួគ៌

គ្រានោះ ភិក្ខុទាំងឡាយជ្រាបថា "នាងនេះក្រោកឡើងអំពីដំណេកកាលណា តែងតែប្រាថ្នាសូមឲ្យបានទៅកើតក្នុងសម្នាក់ស្វាមីប៉ុណ្ណោះ" ទើបដាក់នាមឲ្យនាងថា "**បតិបូជិកា**" ។ សូម្បីនាងបតិបូជិកានោះ តែងតែបដិបត្តិរោងឆាន់ ចូលទៅតម្កល់ទឹកឆាន់ ក្រាលអាសនៈជានិច្ច ។ មនុស្សពួកដទៃប្រាថ្នាថ្វាយសលាកភត្តជាដើម តែងតែនាំមកប្រគល់ឲ្យដោយពាក្យថា "នាងចូរចាត់ចែងភត្តនេះដល់ភិក្ខុសង្ឃ" ។ សូម្បីនាងដើរទៅដើរមកដោយទំនងនោះ បានកុសល ៥៦ គ្រប់ជំហាន ។ នាងតាំងគភ៌ហើយ ។ ដោយកាលដែលកន្លងទៅ ១០ ខែ ។ កាលដែលបុត្រនោះដើរបាន នាងបានបុត្រដទៃៗ រួម ៤ នាក់ ។ ថ្ងៃមួយ នាងថ្វាយទាន ធ្វើការបូជា ស្តាប់ធម៌ រក្សាសិក្ខាបទ ក្នុងវេលាជាទីបំផុតនៃថ្ងៃ ក៏ធ្វើកាលកិរិយាដោយរោគម្យ៉ាង ដែលកើតឡើងក្នុងខណៈនោះ ហើយទៅកើតក្នុងសម្នាក់នៃស្វាមីដើមរបស់នាង ។

## អាយុមនុស្សប្រមាណ ១០០ ឆ្នាំ

ចំណែកនាងទេពធីតាក្រៅពីនេះ កំពុងប្រដាប់តាក់តែងនោះឯង រហូតអស់កាលប៉ុណ្ណោះ ។ ទេវបុត្រឃើញនាងនោះហើយ ក៏សួរថា "នាងបាត់មុខ

ទៅណាតាំងពីព្រឹក នាងទើបមកពីណា?”

ទេពធីតា. បពិត្រអ្នកជាម្ចាស់ ខ្ញុំចុតិ ។

ទេវបុត្រ. ម្នាលនាង នាងនិយាយអ្វី ?

ទេពធីតា. សេចក្ដីនោះជាយ៉ាងហ្នឹងហើយ អ្នកជាម្ចាស់ ។

ទេវបុត្រ. នាងចុតិហើយទៅកើតនៅទីណា ?

ទេពធីតា. កើតក្នុងផ្ទះនៃត្រកូលក្នុងក្រុងសាវត្ថី ។

ទេវបុត្រ. នាងនៅក្នុងក្រុងសាវត្ថីនោះអស់កាលប៉ុន្មាន ?

ទេពធីតា. បពិត្រនាយ នាងខ្ញុំចេញចាកផ្ទៃមាតាដោយកាលកន្លងទៅ ១០ ខែ ក្នុងវេលាអាយុ ១៦ ឆ្នាំ ទៅកាន់ត្រកូលស្វាមី ប្រសូតបុត្រ ៤ នាក់ ធ្វើបុណ្យមានទានជាដើម ប្រាថ្នាឲ្យបានមកកើតក្នុងសម្នាក់អ្នកជាម្ចាស់ ក៏មកកើតក្នុងសម្នាក់របស់អ្នកជាម្ចាស់ដូចដើម ។

ទេវបុត្រ. អាយុរបស់មនុស្សមានប្រមាណប៉ុន្មាន ?

ទេពធីតា. បពិត្រនាយ ប្រមាណ ១០០ ឆ្នាំ ។

ទេវបុត្រ. ប៉ុណ្ណោះឯងឬ ?

ទេពធីតា. ចា៎ះ អ្នកជាម្ចាស់ ។

ទេវបុត្រ. ពួកមនុស្សមានអាយុប្រមាណប៉ុណ្ណោះ ជាអ្នកប្រមាទដូចដេកលក់ ញុំាងកាលឲ្យកន្លងទៅដោយសេចក្ដីប្រមាទ ឬក៏ធ្វើបុណ្យមានទានជាដើមដែរ ?

ទេពធីតា. កុំនិយាយឡើយអ្នកជាម្ចាស់ ពួកមនុស្សទាំងនោះប្រមាទជានិច្ច ដូចជាខ្លួនមានអាយុ ១ អសេង្ខ្យដូច្នោះ ឬដូចជាខ្លួនមិនចេះស្លាប់ ។

សេចក្តីសង្វេគ ក៏បានកើតឡើងដល់មាលាការីទេវបុត្រថា "បានឮថា ពួកមនុស្សមានអាយុប្រមាណ ១០០ ឆ្នាំប៉ុណ្ណោះ តែមានសេចក្តីប្រមាទដូចដេកលក់ កាលណាហ្ន៎ ទើបនឹងរួចផុតចាកទុក្ខបាន" ។

## ១០០ ឆ្នាំរបស់មនុស្សស្មើ ១យប់ ១ថ្ងៃ ក្នុងស្ថានសួគ៌

ក៏ ១០០ ឆ្នាំរបស់មនុស្ស បាន ១ យប់ ១ ថ្ងៃ របស់ពួកទេវតាជាន់តាវត្តិង្ស ៣០ រាត្រីដោយរាត្រីនោះជា ១ ខែ កំណត់ដោយ ១២ ខែនោះជា ១ ឆ្នាំ ១.០០០ ឆ្នាំទិព្វ ដោយឆ្នាំនោះ ជាប្រមាណអាយុរបស់ទេវតាជាន់តាវត្តិង្ស ១.០០០ ឆ្នាំទិព្វនោះ បើរាប់តាមឆ្នាំមនុស្ស ត្រូវជា ៣ កោដិ ៦ លានឆ្នាំ ។ ព្រោះដូច្នោះ ១ ថ្ងៃរបស់ទេវបុត្រនោះ ក៏មិនទាន់កន្លងទៅ ហាក់ដូចជាមួយស្របក់ប៉ុណ្ណោះ ។ ដែលឈ្មោះថា សេចក្តីប្រមាទរបស់សត្វដែលមានអាយុតិចយ៉ាងនេះ មិនគួរឡើយ ។

ថ្ងៃស្អែកឡើង ពួកភិក្ខុចូលទៅកាន់ស្រុក ឃើញរោងឆាន់មិនទាន់បានរៀបចំអាសនៈ មិនទាន់បានក្រាល ទឹកឆាន់មិនទាន់បានតម្កល់ទុក ទើបសួរថា "នាងបតិបូជិកាទៅណា?" ។

អ្នកស្រុក. បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយនឹង

ឃើញនាងក្នុងទីណាបាន? បើពីម្សិលមិញនេះ កាលលោកម្ចាស់ឆាន់រួចហើយ ត្រឡប់ទៅវិញ នាងស្លាប់នៅក្នុងពេលល្ងាច ។ ភិក្ខុបុថុជ្ជនស្តាប់ពាក្យនោះហើយ រឭកដល់ឧបការៈរបស់នាង មិនអាចទប់ទឹកភ្នែកបាន ធម្មសង្វេគបានកើតឡើងដល់ព្រះខីណាស្រព ភិក្ខុទាំងនោះធ្វើភត្តកិច្ចរួចហើយ ទៅវិហារវិញ ថ្វាយបង្គំព្រះសាស្តាទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ឧបាសិកា ឈ្មោះបតិបូជិកា ក្រោកពីដំណេកហើយ រមែងធ្វើបុណ្យ មានប្រការផ្សេងៗ ប្រាថ្នាតែស្វាមីប៉ុណ្ណោះ ឥឡូវនេះនាងស្លាប់ហើយ តើនាង (ទៅ) កើតទីណាដែរព្រះអង្គ?" ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ នាងកើតក្នុងសម្នាក់ស្វាមីរបស់នាងនុ៎ះឯង ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ក្នុងសម្នាក់ស្វាមីរបស់នាង មិនឃើញនាងនៅទីនោះទេ ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ នាងប្រាថ្នាស្វាមីនោះក៏ទេ មាលាភារីទេវបុត្រ ដែលនៅក្នុងតាវត្តិង្សពិភពជាស្វាមីរបស់នាង នាងចុតិចាកទីប្រជាប់តុបតែងផ្កាឈើរបស់ស្វាមីនោះហើយ បានទៅកើតក្នុងសម្នាក់ស្វាមីនោះឯងទៀត ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនេះពិតមែនឬ ?

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះពិតមែនហើយ ។

ភិក្ខុ. គួរឲ្យសង្វេគណាស់! ជីវិតរបស់សត្វទាំងឡាយតិច (ពិតមែន) បពិត្រព្រះអង្គដ៏ចម្រើន ពេលព្រឹកនាងអង្គាសពួកខ្ញុំព្រះអង្គ ពេលល្ងាចស្លាប់ដោយព្យាធិដែលកើតឡើង ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះហើយ ដែលឈ្មោះថាជីវិតរបស់សត្វទាំងឡាយតិច (ពិត) ហេតុនោះឯង មច្ចុដែលជាអ្នកធ្វើនូវទីបំផុត ញ៉ាំងសត្វទាំងឡាយដែលមិនចេះឆ្អែតឆ្អន់ដោយវត្ថុកាម និងកិលេស-កាម ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន ហើយរមែងនាំយកសត្វដែលកន្ទក់កន្ទេញ យំរៀបរាប់ទៅ លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ត្រាស់ព្រះគាថានេះថា

បុប្ផានិ ហេវ បចិនន្តំ ព្យាសត្តមនសំ នរំ
អតិត្តំយេវ កាមេសុ អន្តកោ កុរុតេ វសំ ។

អ្នកធ្វើទីបំផុត គឺ មរណៈ តែងក្រុងសត្វ ដែល
មានចិត្តជំពាក់ក្នុងអារម្មណ៍ផ្សេងៗ កំពុងជ្រើស
រើសនូវផ្កា គឺ កាមគុណ ៥ មិនឆ្អែតឆ្អន់ក្នុងកាម
ទាំងឡាយនុ៎ះឯង ឲ្យនៅក្នុងអំណាចរបស់ខ្លួន ។

## អធិប្បាយគាថា

បណ្តាបទទាំងនេះ បទថា បុប្ផានិ ហេវ បចិនន្តំ (កំពុងជ្រើសរើសនូវផ្កា) សេចក្តីថា អ្នករវល់តែជ្រើសរើសនូវផ្កា គឺ កាមគុណទាំងឡាយដែល

ជាប់ដោយអត្តភាព និងជាប់ដោយគ្រឿងឧបករណ៍ ដូចនាយមាលាការជ្រើសរើសយកផ្កាប្រភេទផ្សេងៗ នៅក្នុងសួនផ្កាដូច្នោះ ។ បទថា **ព្យាសត្តមនសំ នរំ (នរជនមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍)** សេចក្តីថា អ្នកមានចិត្តរាយ-មាយដោយអាការផ្សេងៗ ក្នុងអារម្មណ៍ដែលមិនទាន់មកដល់ ដោយអំណាចនៃសេចក្តីប្រាថ្នាក្នុងអារម្មណ៍ដែលមកដល់ហើយ ដោយអំណាចនៃសេចក្តីត្រេកអរ ។ បទថា **អតិត្តំយេវ កាមេសុ (នរជនដែលមិនឆ្អែតក្នុងកាមទាំងឡាយនោះឯង)** សេចក្តីថា ជនដែលមិនចេះឆ្អែតឆ្អន់ក្នុងវត្ថុកាម និងកិលេស-កាមទាំងឡាយ ដោយការស្វែងរកខ្លះ ដោយការបានដោយចំពោះខ្លះ ដោយការប្រើប្រាស់ខ្លះ ដោយការទុកដាក់ខ្លះ ។ បទថា **អន្តកោ កុរុតេ វសំ (មច្ចុអ្នកធ្វើនូវទីបំផុត... ឲ្យនៅក្នុងអំណាច)** សេចក្តីថា មច្ចុអ្នកធ្វើនូវទីបំផុតពោលគឺ មរណៈ នាំនរជនដែលកន្ទក់កន្ទេញ យំរៀបរាប់ ទៅហើយ ឲ្យដល់អំណាចរបស់ខ្លួន ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ទេសនាមានប្រយោជន៍ដល់មហាជនយ៉ាងដូច្នេះឯង ។

ចប់ រឿងនាងបតិបូជិកា

# ៥. រឿងកោសិយសេដ្ឋីអ្នកមានសេចក្តីកំណាញ់

ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធសេដ្ឋីឈ្មោះកោសិយៈអ្នកមានសេចក្តីកំណាញ់ ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ ភមរោ បុប្ផំ** (ដូចកមរជាតិ មិនញាំងផ្កា) ជាដើម ។ រឿងនេះកើតឡើងនៅក្នុងក្រុងរាជគ្រឹះ ។

## សម្បត្តិសេដ្ឋីមិនផ្តល់ប្រយោជន៍ដល់នរណា ៗ

បានស្តាប់មកថា ក្នុងទីមិនឆ្ងាយពីក្រុងរាជគ្រឹះ មាននិគមមួយឈ្មោះសក្ករៈ សេដ្ឋីម្នាក់ឈ្មោះ កោសិយៈ មានសេចក្តីកំណាញ់ មានទ្រព្យ ៨០ កោដិ ប្រចាំនៅក្នុងនិគមនោះ ។ គាត់មិនឲ្យសូម្បីតែតំណក់ប្រេង (មួយតំណក់) ដែលជាប់ចុងស្មៅ ដល់អ្នកដទៃឡើយ ។ ទាំងមិនហ៊ានបរិភោគខ្លួនឯងទៀត ។ សម្បត្តិរបស់គាត់នោះ មិនបានផ្តល់នូវប្រយោជន៍ដល់បិយជនទាំងឡាយ មានបុត្រ និងភរិយាជាដើម មិនបានជាប្រយោជន៍ដល់សមណៈនិងព្រាហ្មណ៍ទាំងឡាយ ស្ថិតនៅជារបស់ប្រើប្រាស់មិនកើត តាំងនៅដូចជាស្រះបោក្ខរណី ដែលមានខ្មោចទឹកហួងហែង ។

## សេដ្ឋីចង់ស៊ីនំអំបែងរហូតស្គម

ថ្ងៃមួយ វេលាជិតភ្លឺ ព្រះសាស្តាស្តេចចេញអំពីសមាបត្តិ ដែលប្រកប

ដោយមហាករុណា ទ្រង់ប្រមើលមើលពួកសត្វជាផៅពង្ស ដែលអាចណែនាំក្នុងការត្រាស់ដឹងបាន ក្នុងសកលលោកធាតុ ទ្រង់បានឃើញឧបនិស្ស័យនៃសោតាបត្តិផលរបស់សេដ្ឋី ព្រមទាំងភរិយា ដែលតាំងនៅក្នុងទីបំផុតផ្លូវ ៤៥ យោជន៍ ។ ក៏ក្នុងថ្ងៃមុនអំពីថ្ងៃនោះ សេដ្ឋីនោះបានទៅកាន់ព្រះរាជដំណាក់ដើម្បីបម្រើព្រះរាជា ធ្វើការបម្រើព្រះរាជាហើយត្រឡប់មកវិញ ឃើញអ្នកស្រុកក្រៅម្នាក់កំពុងបរិភោគនំកុម្មាស (នំអំបែង) ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ក៏កើតសេចក្តីស្រេកឃ្លានក្នុងនំនោះ ឡើងទៅកាន់ផ្ទះរបស់ខ្លួន គិតថា "បើយើងប្រាប់ថា យើងចង់ស៊ីនំអំបែងសោត មនុស្សជាច្រើនក៏នឹង (នាំគ្នា) ចង់ស៊ីជាមួយនឹងយើងដែរ បើដូច្នោះ វត្ថុជាច្រើនមានល្ង អង្ករ ទឹកដោះថ្លា ស្ករអំពៅជាដើម របស់យើងក៏នឹងអស់ទៅ យើងនឹងមិនប្រាប់នរណាៗ ឡើយ" លុះគិតដូច្នោះហើយ អត់ទ្រាំនឹងចំណង់នោះ មិនព្រមប្រាប់នរណាៗ ឡើយ ។ កាលក៏កន្លងទៅៗ គាត់ក៏កើតរោគស្លេកស្លាំងកាន់តែខ្លាំងឡើង មានខ្លួនរវើររវាមទៅដោយសរសៃ តអំពីនោះ គាត់មិនអាចអត់ទ្រាំនឹងចំណង់នោះបាន ក៏ចូលទៅកាន់បន្ទប់ហើយដេកឱបគ្រែ ។ គាត់សូម្បីដល់នូវសេចក្តីទុក្ខយ៉ាងនេះ ក៏នៅមិនប្រាប់នរណាៗ ទៀត ព្រោះខ្លាចអស់ទ្រព្យ ។

គ្រានោះ ភរិយារបស់គាត់ចូលទៅរកគាត់ ស្ទាបខ្នង ហើយសួរថា "លោកមិនសប្បាយឬ?" ។

សេដ្ឋី. ការមិនសប្បាយណាៗ របស់ខ្ញុំមិនមានទេ ។

កវិយា. ព្រះរាជាក្រោធនឹងលោកឬ ?

សេដ្ឋី. សូម្បីព្រះរាជាក៏មិនបានខឹងខ្ញុំ ។

កវិយា. បើដូច្នោះ ការមិនពេញចិត្តណាៗ ដែលពួកកូនប្រុសកូនស្រី ឬបរិជន មានទាសកម្មករជាដើមធ្វើដល់លោក មែនទេ ?

សេដ្ឋី. សូម្បីកម្មបែបនោះ ក៏មិនមាន ។

កវិយា. បើដូច្នោះ លោកមានចំណង់ក្នុងអ្វីឬ ?

សូម្បីកវិយាពោលយ៉ាងនោះ គាត់ក៏មិនពោលអ្វីទាំងអស់ នៅតែដេកស្ងៀម ព្រោះខ្លាចអស់ទ្រព្យ ។ គ្រានោះ កវិយារបស់គាត់ពោលនឹងគាត់ថា "បពិត្រអ្នកជាម្ចាស់ លោកចង់អ្វីប្រាប់មកចុះ?" គាត់ធ្វើដូចជាលេបពាក្យសម្ដីឆ្លើយថា "ខ្ញុំមានសេចក្ដីប្រាថ្នា" ។

កវិយា. បពិត្រអ្នកជាម្ចាស់ លោកចង់អ្វី ?

សេដ្ឋី. ខ្ញុំចង់ស៊ីនំអំបែង ។

កវិយា. បើដូច្នោះ ហេតុអ្វី លោកមិនប្រាប់ខ្ញុំ លោកជាមនុស្សក្រឬណ្ហើយចុះ ខ្ញុំនឹងចៀននំអំបែងឲ្យល្មមដល់មនុស្សដែលនៅក្នុងសក្ករនិគមនេះ ។

សេដ្ឋី. ប្រយោជន៍អ្វីដល់នាង ដោយមនុស្សទាំងនោះ ពួកគេធ្វើការងាររបស់គេ គេស៊ី (របស់គេទៅ) ។

កវិយា. បើដូច្នោះ ខ្ញុំចៀនឲ្យល្មមដល់មនុស្សដែលនៅក្នុងច្រកតែមួយជាមួយនឹងយើង ។

សេដ្ឋី. ខ្ញុំដឹងថា នាងជាមនុស្សមានទ្រព្យច្រើនហើយ ។

ករិយា. ខ្ញុំនឹងចៀនឲ្យល្មមដល់មនុស្សទាំងអស់ (ដែលនៅ) ក្នុងទីជិតផ្ទះនេះ ។

សេដ្ឋី. ខ្ញុំដឹងថា នាងជាមនុស្សមានអធ្យាស្រ័យធំទូលាយហើយ ។

ករិយា. បើដូច្នោះ ខ្ញុំនឹងចៀនឲ្យល្មមដល់ជនត្រឹមតែកូនប្រពន្ធ ហើយនឹងលោកប៉ុណ្ណោះឯង ។

សេដ្ឋី. ប្រយោជន៍អ្វីដល់នាង និងអ្នកទាំងអស់នោះ ។

ករិយា. ក៏ខ្ញុំនឹងចៀនឲ្យល្មមដល់លោក និងខ្ញុំឬ ?

សេដ្ឋី. នាងដែរ មិនបានទេ ។

ករិយា. បើដូច្នោះ ខ្ញុំនឹងចៀនឲ្យល្មមដល់លោកតែម្នាក់ប៉ុណ្ណោះ ។

សេដ្ឋី. កាលបើនាងចៀននំទីនេះ មនុស្សជាច្រើនក៏រមែងសង្ឃឹម (ថានឹងស៊ីដែរ) នាងចូររើអង្ករ (ដែលល្អ) ទាំងអស់ចេញ កាន់យកចុងអង្ករ និងជើងក្រាន ព្រមទាំងក្បឿង ទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅបន្តិច ឡើងទៅកាន់ប្រាសាទជាន់ទី ៧ ហើយចៀននៅទីនោះចុះ ខ្ញុំតែម្នាក់ប៉ុណ្ណោះនឹងអង្គុយស៊ីនៅទីនោះ ។

នាងទទួលថា "ប្រពៃហើយ" ហើយឲ្យទាសីកាន់វត្ថុដែលគួរកាន់ឡើងទៅកាន់ប្រាសាទ ហើយដេញទាសីឲ្យទៅហៅសេដ្ឋីមក ។ សេដ្ឋីនោះបិទទ្វារដាក់គន្លឹះគ្រប់ទ្វារ តាំងពីទ្វារដំបូងមក ហើយឡើងទៅកាន់ប្រាសាទជាន់ទី ៧

បិទទ្វារ ហើយអង្គុយនៅក្នុងទីនោះ ។ ចំណែកភរិយារបស់គាត់បង្កាត់ភ្លើង លើកក្បឿងឡើងដាក់លើជើងក្រាន ហើយចាប់ផ្តើមចៀននំ ។

ព្រះមហាមោគ្គល្លានទូន្មានសេដ្ឋី

គ្រានោះ ព្រះសាស្តា ត្រាស់ហៅព្រះមហាមោគ្គល្លានមកអំពីព្រលឹម ហើយត្រាស់ថា "ម្នាលមោគ្គល្លាន ក្នុងសក្ករនិគម (ដែលស្ថិតនៅមិនឆ្ងាយអំពីក្រុងរាជគ្រឹះ សេដ្ឋីអ្នកមានសេចក្តីកំណាញ់នោះ គិតថា យើងនឹងស៊ីនំអំបែង ទើបឲ្យភរិយាចៀននំនៅលើប្រាសាទជាន់ទី ៧ ព្រោះខ្លាចអ្នកដទៃឃើញ អ្នកចូរទៅកាន់ទីនោះ ហើយទូន្មានសេដ្ឋីឲ្យអស់យស ឲ្យប្តីប្រពន្ធទាំងពីរនាក់នោះកាន់នំ និងទឹកដោះថ្លា ទឹកឃ្មុំ និងស្ករអំពៅ នាំមកកាន់វត្តជេតពន ដោយកម្លាំងរបស់ខ្លួនចុះ ។ ថ្ងៃនេះ តថាគត និងភិក្ខុ ៥០០ រូបនឹងគង់ក្នុងវិហារនេះឯង ធ្វើភត្តកិច្ចដោយនំនោះ ។ ព្រះថេរៈ ក៏ទទួលព្រះតម្រាស់របស់ព្រះសាស្តាថា "ព្រះករុណា ព្រះអង្គ" ហើយទៅកាន់និគមនោះដោយឫទ្ធិ ស្លៀកដណ្តប់រៀបរយហើយ ឈរនៅហ្នឹងមាត់បង្អួចនៃប្រាសាទនោះ ដូចរូបកែវមណីអណ្តែតនៅកណ្តាលអាកាសដូច្នោះ ។ សេដ្ឋីនោះឃើញព្រះថេរៈភ្លាម ដួងហឫទ័យរបស់សេដ្ឋីក៏ញាប់ញ័រ គាត់គិតថា "យើងមកកាន់ទីនេះ ព្រោះខ្លាចបុគ្គលទាំងឡាយ មានសភាពយ៉ាងនេះឯង តែសមណៈនេះនៅមានមុខមកឈរនៅហ្នឹងមាត់បង្អួចទៀត" កាលមិនឃើញឧបករណ៍ ដែលខ្លួនគួរនឹងចាប់យក ព្រោះភាពក្តៅរបស់នំដែលធ្វើនូវសំឡេងប្រេះៗ ដូចអំបិល

ដែលដាក់ទៅក្នុងភ្លើង ទើបពោលយ៉ាងនេះថា "នែសមណៈ កុំថាលោកឈរ
នៅក្នុងអាកាស សូម្បីដើរចង្ក្រម សម្ដែងស្នាមជើងក្នុងអាកាសដែលរកស្នាម
ជើងមិនបាន លោកក៏មិនបានអ្វីពីយើងដែរ" ។ ព្រះថេរៈចង្ក្រមទៅមកក្នុងទី
នោះឯង ។ សេដ្ឋីពោលថា "កុំថាលោកដើរចង្ក្រមទៅមក នៅលើអាកាស
សូម្បីអង្គុយពែនភ្នែនក្នុងអាកាស ក៏មិនបានអ្វីអំពីយើងដែរ" ។ ព្រះថេរៈក៏គង់
ពែនភ្នែន ។ លំដាប់នោះ សេដ្ឋីពោលនឹងព្រះថេរៈថា "កុំថាលោកអង្គុយក្នុង
អាកាស សូម្បីមកឈរនឹងបង្អួច ក៏នឹងមិនបានអ្វីពីយើងដែរ" ព្រះថេរៈក៏មក
ឈរនៅនឹងបង្អួចភ្លាម ។ គ្រានោះ គាត់ពោលនឹងព្រះថេរៈថា "កុំថាលោក
ឈរនៅនឹងបង្អួច សូម្បីតែបង្កើតផ្សែង ក៏មិនបានអ្វីដែរ" ។ សូម្បីព្រះថេរៈ
ក៏ញុំាងផ្សែងឲ្យកើតឡើង ។ ប្រាសាទទាំងអស់ក៏មានផ្សែងហុយទ្រលោម ។
អាការនោះ ដូចជាវេលាជាទីចាក់ភ្នែកទាំងពីររបស់សេដ្ឋីដោយម្ជុល សេដ្ឋីមិន
ហ៊ានពោលនឹងព្រះថេរៈថា "សូម្បីលោកញុំាងភ្លើងឲ្យឆេះសន្ធោសន្ធៅ ក៏នឹង
មិនបានដូចគ្នា" ព្រោះខ្លាចភ្លើងឆេះផ្ទះ ទើបគិតថា "សមណៈនេះ ជាអ្នកជាប់
ជំពាក់យ៉ាងស្អិត កាលមិនបាននឹងមិនទៅ យើងនឹងថ្វាយនំដល់សមណៈមួយ
បន្ទះចុះ" លុះគិតដូច្នោះហើយ ក៏ពោលនឹងភរិយាថា "ម្នាលនាងដ៏ចម្រើន
នាងចូរចៀននំមួយបន្ទះតូចឲ្យដល់សមណៈ ហើយចូរឲ្យសមណៈនេះទៅ
វិញចុះ" ។ សេដ្ឋីនីបន្តក់ម្សៅទៅក្នុងថាសក្បៀងបន្តិច ។ (តែ) នំ (ក្លាយ)
ជាបន្ទះធំ រីកឡើងពេញថាស ។ សេដ្ឋីឃើញដូច្នោះ ក៏ពោលថា "ប្រហែល

ជា) នាងដាក់ម្សៅច្រើនពេកទេដឹង” ដូច្នេះ ហើយជួសម្សៅដោយចុងវែកបន្តិចបន្តួចដោយខ្លួនឯង ។ នំក៏ធំជាងនំមុន ។ សេដ្ឋីចៀននំបន្ទះណាៗ ដោយអាការនោះ នំបន្ទះនោះៗ ក៏ធំក្រៃលែងឡើងៗ ។ គាត់ហត់ស្បើយកម្លាំង ក៏ពោលនឹងភរិយាថា “ម្នាលនាងដ៏ចម្រើន នាងចូរឲ្យនំដល់សមណៈនេះ មួយបន្ទះចុះ” កាលនាងចាប់មួយបន្ទះអំពីថាស នំទាំងអស់ក៏ជាប់ជាមួយគ្នា ។ នាងក៏ពោលនឹងសេដ្ឋីថា “បពិត្រអ្នកជាម្ចាស់ នំទាំងអស់ជាប់គ្នាតែមួយ ខ្ញុំមិនអាចធ្វើឲ្យដាច់ពីគ្នាបានទេ” សេដ្ឋីពោលថា “ខ្ញុំនឹងធ្វើខ្លួនឯង” ។ ហើយក៏មិនអាចធ្វើនំឲ្យដាច់ចេញពីគ្នាបាន ។ ស្វាមីទាំងពីរនាក់ប្តីប្រពន្ធចាប់ត្រង់ជាយនំ (បន្ទះនំ) ហើយទាញចេញ ក៏មិនអាចឲ្យដាច់ចេញពីគ្នាបានដែរ ញើសក៏ហូរចេញអំពីសរីរៈ សេចក្តីស្រេកឃ្លានក៏បាត់ទៅ ។ គ្រានោះ គាត់ក៏ពោលនឹងភរិយាថា “ម្នាលនាងដ៏ចម្រើន ខ្ញុំមិនត្រូវការនំនេះទៀតទេ នាងចូរឲ្យដល់សមណៈចុះ” ភរិយារបស់គាត់ចាប់យកថាសនំ ហើយចូលទៅរកព្រះថេរៈ ។ ព្រះថេរៈសម្តែងធម៌ឲ្យសេដ្ឋីទាំងពីរនាក់ស្តាប់ ពោលអំពីគុណព្រះរតនត្រៃ សម្តែងអំពីផលទាន ដែលបុគ្គលឲ្យហើយជាដើម ឲ្យដូចជាព្រះច័ន្ទក្នុងផ្ទៃមេឃថា “ទាន ដែលបុគ្គលឲ្យហើយ រមែងមានផល យញ្ញដែលបុគ្គលបូជាហើយ រមែងមានផល” ។ សេដ្ឋីស្តាប់ហើយ មានចិត្តជ្រះថ្លា ពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មកគង់ឆាន់លើបល្ល័ង្កនេះចុះ” ។

## ព្រះថេរៈនាំសេដ្ឋី និងភរិយាទៅគាល់ព្រះសាស្ដា

ព្រះថេរៈពោលថា "មហាសេដ្ឋី ព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់នៅក្នុងវិហារជាមួយនឹងភិក្ខុ ៥០០ រូប ដោយតាំងព្រះទ័យថា "នឹងសោយនំនេះ បើលោកពេញចិត្ត ម្នាលសេដ្ឋី ចូរលោកឲ្យភរិយារបស់លោកកាន់យកនំ និងវត្ថុដទៃ មានទឹកដោះជាដើម ពួកយើងនឹងទៅកាន់សម្នាក់ព្រះសាស្ដា" ។

សេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏ឥឡូវនេះ ព្រះសាស្ដាទ្រង់ប្រថាប់នៅទីណា ?

ព្រះថេរៈ. ម្នាលសេដ្ឋី ព្រះសម្មាសម្ពុទ្ធទ្រង់ប្រថាប់នៅក្នុងវត្តជេតពនចម្ងាយប្រមាណ ៤៥ យោជន៍ អំពីទីនេះ ។

សេដ្ឋី. បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកយើងនឹងទៅអស់ផ្លូវឆ្ងាយមានប្រមាណប៉ុណ្ណេះ នឹងមិនហួសពេលទេឬ ?

ព្រះថេរៈ. មហាសេដ្ឋី ប្រសិនបើលោកមានការពេញចិត្ត អាត្មានឹងនាំអ្នកទាំងពីរទៅដោយកម្លាំងរបស់អាត្មា ។ ក្បាលជណ្ដើរប្រាសាទរបស់លោកនឹងនៅក្នុងទីរបស់ខ្លួននេះឯង តែជើងជណ្ដើរ នៅត្រង់ខ្លោងទ្វារវត្តជេតពន អាត្មានឹងនាំអ្នកទាំងពីរទៅកាន់វត្តជេតពន ដោយកាលត្រឹមតែចុះអំពីប្រាសាទជាន់លើ ទៅកាន់ប្រាសាទជាន់ក្រោមប៉ុណ្ណោះ ។

សេដ្ឋីទទួលថា "ប្រពៃហើយលោកម្ចាស់" ។ ព្រះថេរៈធ្វើក្បាលជណ្ដើរទុកក្នុងទីនោះ ហើយអធិដ្ឋានថា "សូមជើងជណ្ដើរ មាននៅត្រង់ខ្លោងទ្វារវត្ត

ជេតពន" ។ ជណ្ដើរក៏បានប្រាកដហើយយ៉ាងនោះ ។ ព្រះថេរៈនាំសេដ្ឋី និង ភរិយាឲ្យដល់វត្តជេតពន លឿនជាងកាលដែលចុះអំពីប្រាសាទជាន់លើ ទៅកាន់ប្រាសាទជាន់ក្រោមទៅទៀត ។

ស្វាមី និងភរិយាទាំងពីរនាក់នោះ ចូលទៅគាល់ព្រះសាស្ដា ហើយក្រាបទូលកាល ។ ព្រះសាស្ដា ស្ដេចយាងទៅកាន់រោងឆាន់ ប្រថាប់លើពុទ្ធាសនៈដែលគេក្រាលទុក ព្រមទាំងភិក្ខុសង្ឃ ។ មហាសេដ្ឋីបានថ្វាយទក្ខិណោទកចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ភរិយាដាក់នំក្នុងបាត្ររបស់ព្រះអង្គហើយ មហាសេដ្ឋី ព្រមទាំងភរិយាក៏បរិភោគនំល្មមដល់សេចក្ដីត្រូវការ ។ ការអស់ទៅនៃនំក៏មិនប្រាកដឡើយ ។ សូម្បីកាលគាត់ប្រគេននំដល់ភិក្ខុសង្ឃក្នុងវិហារទាំងអស់ និង (ឲ្យ) មនុស្សអ្នកស៊ីដែលទាំងឡាយទៀត ការអស់ទៅនៃនំក៏មិនប្រាកដ ។ ទាំងពីរនាក់ប្ដីប្រពន្ធ ក៏ក្រាបទូលព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន នៅសល់ច្រើនណាស់" ។

ព្រះមានព្រះភាគ ត្រាស់ថា "បើដូច្នោះ អ្នកទាំងពីរចូរចាក់ចោលត្រង់ខ្លោងទ្វារវត្តជេតពនចុះ" គាត់ក៏ចាក់ចោលត្រង់ញកដែលនៅមិនឆ្ងាយអំពីខ្លោងទ្វារ (វត្តជេតពន) ។ សូម្បីសព្វថ្ងៃនេះ ទីនោះក៏នៅប្រាកដថា "ញកនំអំបែង" ។ មហាសេដ្ឋី ព្រមទាំងភរិយាចូលទៅគាល់ព្រះមានព្រះភាគ ឈរក្នុងទីដ៏សមគួរ ។ ព្រះមានព្រះភាគ ទ្រង់អនុមោទនាទានរបស់ស្វាមី និងភរិយានោះ ។

ក្នុងវេលាចប់អនុមោទនា ស្វាមី និងភរិយា ក៏តាំងនៅក្នុងសោតាបត្តិផល ថ្វាយបង្គំព្រះសាស្តា ឡើងជណ្តើរត្រង់ខ្លោងទ្វារវត្តជេតពន ហើយស្ថិតនៅក្នុងប្រាសាទរបស់ខ្លួន ។ តាំងពីនោះមក សេដ្ឋីបានចំណាយទ្រព្យ ៨០ កោដិ ដើម្បីជាប្រយោជន៍ក្នុងព្រះពុទ្ធសាសនា ។

ពួកភិក្ខុសរសើរព្រះមហាមោគ្គល្លាន

ថ្ងៃស្អែកក្នុងវេលារសៀល ពួកភិក្ខុប្រជុំគ្នាក្នុងធម្មសភា អង្គុយពោលគុណរបស់ព្រះថេរៈថា "អ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយ ចូរមើលអានុភាពរបស់ព្រះមហាមោគ្គល្លានចុះ លោកឈ្មោះថា មិនធ្វើឲ្យខូចសទ្ធា មិនធ្វើឲ្យខូចភោគៈ ទូន្មានសេដ្ឋីដែលជាអ្នកមានសេចក្តីកំណាញ់មួយភ្លែត ធ្វើឲ្យអស់យស ហើយឲ្យសេដ្ឋីកាន់នំនាំមកកាន់វត្តជេតពន ធ្វើទុកចំពោះព្រះភក្ត្រព្រះសាស្តា ហើយឲ្យតាំងនៅក្នុងសោតាបត្តិផល ព្រះថេរៈមានអានុភាពច្រើន គួរឲ្យអស្ចារ្យណាស់" ។ ព្រះសាស្តា ទ្រង់ស្តាប់ពាក្យរបស់ពួកភិក្ខុ ដោយព្រះសោតធាតុជាទិព្វហើយ ស្តេចយាងមកត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយប្រជុំគ្នាអំពីរឿងអ្វី?" កាលភិក្ខុ ទាំងនោះក្រាបទូលថា "អំពីរឿងឈ្មោះនេះ" ទើបត្រាស់សរសើរព្រះថេរៈថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុអ្នកទូន្មាន មិនធ្វើឲ្យខូចសទ្ធា មិនធ្វើឲ្យខូចភោគៈ មិនធ្វើឲ្យខូចត្រកូល មិនបៀតបៀនត្រកូល ដូចជាកមរជាតិក្រេបយកលម្អងអំពីផ្កាឈើឯការចូលទៅរក (ត្រកូល) ហើយ ធ្វើឲ្យដឹងនូវពុទ្ធគុណ មោគ្គល្លានជាបុត្រ

របស់តថាគត ក៏ដូច្នោះ" លុះទ្រង់ត្រាស់ដូច្នេះហើយ ទើបត្រាស់ព្រះគាថា នេះថា ៖

យថាបិ ភមរោ បុប្ផំ វណ្ណគន្ធំ អហេឋយំ
បលេតិ រសមាទាយ ឯវំ គាមេ មុនី ចរេ ។

ភមរជាតិ មិនធ្វើផ្កាឈើដែលមានពណ៌ និងក្លិនឲ្យវិនាសទេ
ក្រេបយកតែរស ហើរទៅ យ៉ាងណាមិញ អ្នកប្រាជ្ញ គប្បីត្រាច់
ទៅក្នុងស្រុក ក៏យ៉ាងនោះឯង ។

## អធិប្បាយគាថា

ជាតិនៃសត្វអ្នកធ្វើទឹកឃ្មុំប្រភេទណាមួយ ឈ្មោះថា ភមរៈ ក្នុងព្រះគាថានេះ ។ បទថា បុប្ផំ (ផ្កា) ជាដើម សេចក្តីថា ភមរៈកាលហើរទៅយ៉ាងនោះហើយ ក្រេបយករសត្រឹមតែសេចក្តីត្រូវការ នាំយករសដទៃទៅដើម្បីប្រយោជន៍ដល់ការធ្វើទឹកឃ្មុំ ហើយហើរទៅ ។ ភមរជាតិនោះហើរចុះកាន់ព្រៃណាមួយហើយ ដាក់រស ដែលលាយដោយធូលីនោះទៅក្នុងប្រហោងឈើមួយកន្លែង ហើយធ្វើរសទឹកឃ្មុំឲ្យជាទឹកឃ្មុំ ដោយលំដាប់ ផ្កាឬពណ៌ និងក្លិននៃផ្កាឈើនោះមិនបានវិនាសទៅ ព្រោះការត្រាច់ទៅក្នុងសួនច្បារនៃភមរជាតិនោះជាបច្ច័យទេ ការពិតវត្ថុទាំងអស់នោះ តាំងនៅជាប្រក្រតីនោះឯង ។ បទថា ឯវំ គាមេ មុនិ ចរេ (មុនីគប្បីត្រាច់ទៅក្នុងស្រុក ដូច)

សេចក្តីថា ព្រះអនាគារិយមុនី មានព្រះសេក្ខៈ និងព្រះអសេក្ខៈក៏ដូច្នោះដែរ ត្រាច់ទទួលភិក្ខាក្នុងស្រុក តាមលំដាប់ត្រកូល ។ ពិតណាស់ ការខូចសទ្ធា ឬវិនាសភោគៈ រមែងមិនមានដល់ត្រកូលទាំងឡាយ ព្រោះការត្រាច់ទៅក្នុងស្រុករបស់មុនីនោះជាបច្ច័យទេ សទ្ធាក្តី ភោគៈក្តី ក៏រមែងតាំងនៅជាប្រក្រតី នោះឯង ព្រះសេក្ខមុនី និងព្រះអសេក្ខមុនី លុះត្រាច់ទៅយ៉ាងនោះ ចេញមកហើយ ព្រះសេក្ខមុនីក្រាលសង្ឃាដិ អង្គុយក្នុងទីដែលជាទីសប្បាយខាងស្រុក ហើយពិចារណា "អាហារបិណ្ឌបាត" ដោយការប្រៀបដូចប្រេងបន្តក់ភ្លៅរទេះ សំពត់បិទដំបៅ និងសាច់របស់បុត្រ ហើយឆាន់បិណ្ឌបាត គេចចូលទៅកាន់ព្រៃសណ្ឌៈបែបនោះ ពិចារណាកម្មដ្ឋាន ធ្វើមគ្គ ៤ និងផល ៤ ឲ្យនៅក្នុងកណ្តាប់ដៃរបស់ខ្លួន ចំណែកព្រះអសេក្ខមុនី ក៏នៅយ៉ាងសប្បាយក្នុងទិដ្ឋធម៌ រឿយៗ ។ បណ្ឌិតគប្បីជ្រាបការនៅរបស់មុនីនោះ ដូចជាភមរជាតិធ្វើនូវទឹកផ្អែមដូច្នោះ ។ តែក្នុងទីនេះ ទ្រង់សំដៅយកព្រះខីណាស្រព ។

ក្នុងកាលចប់ព្រះទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ព្រះសាស្តា លុះត្រាស់ព្រះធម្មទេសនានេះហើយ ដើម្បីនឹងប្រកាសគុណរបស់ព្រះថេរៈឲ្យក្រៃលែង ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានមិនមែនទូន្មានសេដ្ឋីដែលមានសេចក្តីកំណាញ់តែក្នុងកាលឥឡូវនេះ ប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនមោគ្គល្លាន ក៏ធ្លាប់ទូន្មានសេដ្ឋីឲ្យដឹងដល់ការទំនាក់ទំនង

គ្នានៃកម្ម និងផលរបស់កម្មដែរ" ដូច្នេះ កាលនឹងប្រកាសសេចក្ដីនេះ ទ្រង់នាំអតីតនិទានមក (សាធក:) ត្រាស់ឥល្លីសជាតកនេះថា ៖

ជនទាំងពីរនាក់ខ្វក ជនទាំងពីរនាក់ក្ងែង ជនទាំងពីរនាក់
មានភ្នែកស្រលៀង ជនទាំងពីរពកសីស: យើងមិនស្គាល់
សេដ្ឋី ឈ្មោះ ឥល្លីស: (ថា) ជាជនណា ដូច្នេះឯង ។

ចប់ រឿងកោសិយសេដ្ឋីកំណាញ់

# ៦. រឿងបាដិកាជីវក

ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអាជីវកឈ្មោះបាដិកាជីវក ត្រាស់ព្រះធម្មទេសនានេះថា **ន បរេសំ វិលោមានិ (ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ)** ជាដើម ។

អ្នកស្រុកសរសើរព្រះធម្មទេសនារបស់ព្រះសម្មាសម្ពុទ្ធ

បានស្តាប់មក មានស្ត្រីមេផ្ទះម្នាក់នៅក្នុងក្រុងសាវត្ថី បដិបត្តិអាជីវកឈ្មោះ បាដិកៈ ដូចជាកូនរបស់ខ្លួន ។ ពួកមនុស្សដែលនៅជិតខាងផ្ទះរបស់នាង បានទៅស្តាប់ព្រះធម៌ទេសនារបស់ព្រះសាស្តាហើយ មកពណ៌នាអំពីព្រះពុទ្ធគុណដោយប្រការផ្សេងៗ ជាដើមថា " ព្រះធម្មទេសនារបស់ព្រះពុទ្ធជាម្ចាស់ គួរអស្ចារ្យ (ណាស់)" ។

ស្ត្រីមេផ្ទះនោះ ស្តាប់ពាក្យសរសើររបស់ព្រះពុទ្ធជាម្ចាស់រួច ក៏មានបំណងចង់ទៅវិហារស្តាប់ធម៌ ក៏ប្រាប់សេចក្តីនោះដល់អាជីវក បាននិយាយថា "លោកម្ចាស់ ខ្ញុំនឹងទៅកាន់សម្នាក់ព្រះសាស្តា" ។

អាជីវកនោះហាមឃាត់ថា "កុំទៅអីញោម" សូម្បីនាងអង្វរហើយអង្វរទៀត អាជីវកនោះក៏ហាមឃាត់មិនឲ្យទៅ ។

នាងគិតថា "លោកម្ចាស់នេះមិនឲ្យយើងទៅវិហារស្តាប់ធម៌ យើងនឹងនិមន្តព្រះសាស្តាមក ហើយស្តាប់ធម៌ក្នុងទីនេះ" លុះគិតដូច្នេះហើយ ដល់វេលា

ល្ងាច ក៏ហៅកូនប្រុសមក បញ្ជូនទៅដោយពាក្យថា "ម្នាលកូនសម្លាញ់ កូនចូរទៅនិមន្តព្រះសាស្ដាមក ដើម្បីសោយភត្ដាហារក្នុងថ្ងៃស្អែក នៅផ្ទះរបស់យើង" ។

មុននឹងទៅ បុត្រនោះក៏ទៅកាន់សម្នាក់អាជីវកជាមុនសិន ថ្វាយបង្គំអាជីវកហើយអង្គុយចុះ ពេលនោះ អាជីវកសួរថា "ឯងទៅណា?" ។

បុត្រ. ខ្ញុំទៅនិមន្តព្រះសាស្ដាតាមពាក្យរបស់ម៉ែ ។

អាជីវក. ឯងកុំទៅសម្នាក់ព្រះអង្គឡើយ ។

បុត្រ. លោកម្ចាស់ដ៏ចម្រើន មិនបានទេ ខ្ញុំត្រូវតែទៅ ។

អាជីវក. ឯងកុំទៅអី យើងទាំងពីរនាក់នឹងបរិភោគគ្រឿងសក្ការៈដែលម្ដាយឯងធ្វើបម្រុងថ្វាយព្រះសាស្ដានោះ ។

បុត្រ. មិនបានទេ បើខ្ញុំមិនទៅនិមន្តព្រះអង្គមក ម៉ែនឹងស្តីបន្ទោសខ្ញុំ ។

អាជីវក. បើដូច្នោះ ឯងទៅក៏ទៅចុះ ប៉ុន្ដែលុះទៅដល់ហើយ ចូរត្រឹមតែនិមន្តបានហើយ "កុំប្រាប់ព្រះអង្គថា សូមស្ដេចយាងទៅកាន់ផ្ទះខ្ញុំនៅក្នុងទីឯណោះ តាមផ្លូវឯណោះ ឬតាមជងផ្លូវឯណោះឲ្យសោះ" ធ្វើហាក់ដូចជាឈរក្នុងទីជិត ដូចនឹងទៅតាមផ្លូវផ្សេងទៀត ហើយចូរគេចមក ។

គេស្ដាប់ពាក្យរបស់អាជីវកហើយ ទៅកាន់សម្នាក់ព្រះសាស្ដា និមន្តព្រះសម្មាសម្ពុទ្ធហើយ ធ្វើកិច្ចគ្រប់យ៉ាងតាមដែលអាជីវកប្រាប់ ហើយទៅកាន់សម្នាក់អាជីវកនោះ ត្រូវអាជីវកសួរថា "ឯងធ្វើដូចម្ដេចខ្លះ?" ក៏ឆ្លើយប្រាប់

អាជីវកថា "ខ្ញុំបានធ្វើតាមដែលលោកម្ចាស់ប្រាប់ហើយនោះឯង" ។ "ឯងធ្វើនេះ ល្អណាស់" យើងទាំងពីរនាក់នឹងបរិភោគគ្រឿងសក្ការៈដែលម៉ែរបស់ឯងធ្វើទុកដើម្បីព្រះសាស្ដានោះ ។

ថ្ងៃស្អែកឡើង អាជីវកនោះ ក៏ធ្វើដំណើរទៅកាន់ផ្ទះនោះតាំងអំពីព្រឹកព្រហាម មនុស្សក្នុងផ្ទះ ក៏អញ្ជើញអាជីវកទៅអង្គុយបន្ទប់ខាងក្រោយ រួចបោសប្រាស់ខាត់លាបផ្ទះដោយអាចម៍គោស្រស់ បាចដោយផ្កាភ្ញី មានលាជជាគម្រប់ ៥ ហើយក្រាលអាសនៈដ៏សមគួរដែលមានតម្លៃច្រើន ដើម្បីការប្រថាប់របស់ព្រះសាស្ដា ។ ពិតណាស់ តាមធម្មតាពួកមនុស្សដែលមិនធ្លាប់ស្និទ្ធស្នាលនឹងព្រះអង្គ រមែងមិនដឹងក្នុងការរៀបចំក្រាលអាសនៈ ។

## ព្រះពុទ្ធជាម្ចាស់ស្ដេចយាងទៅផ្ទះរបស់ឧបាសិកា

ដែលឈ្មោះថា កិច្ច (ទាក់ទង) ដោយអ្នកបង្ហាញផ្លូវ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយឡើយ ផ្លូវទាំងអស់តែងជាក់ច្បាស់ដល់ព្រះពុទ្ធគ្រប់ៗព្រះអង្គហើយថា "ផ្លូវនេះទៅនរក ផ្លូវនេះទៅកំណើតតិរច្ឆាន ផ្លូវនេះទៅបេត្តវិស័យ ផ្លូវនេះទៅមនុស្សលោក ផ្លូវនេះទៅទេវលោក ផ្លូវនេះទៅកាន់អមតនិព្វាន" ក្នុងថ្ងៃដែលទ្រង់ញ៉ាំងម៉ឺនលោកធាតុឲ្យញាប់ញ័រហើយ ទ្រង់សម្រេចនូវពោធិញ្ញាណ ត្រង់គល់ពោធិព្រឹក្សនោះឯង ទើបមិនមានពាក្យដែលគួរពោលអំពីផ្លូវនៃស្ថានទីផ្សេងៗ មានស្រុក និងនិគមជាដើមឡើយ ព្រោះដូច្នោះ ព្រះសាស្ដាទ្រង់ប្រដាប់បាត្រ និងចីវរ យាងទៅកាន់ទ្វារផ្ទះរបស់មហាឧបាសិកា

តាំងអំពីព្រឹក នាងចេញមកអំពីផ្ទះថ្វាយបង្គំព្រះសាស្តាដោយអង្គ ៥ (បញ្ចង្គ-ប្រតិស្ឋាន) ហើយនិមន្តឲ្យយាងគង់លើអាសនៈ បានថ្វាយនូវទឹកទក្ខិណោទកអង្គាសដោយខាទនីយៈ និងភោជនីយាហារដ៏ប្រណីត ឧបាសិកាប្រាថ្នានឹងឲ្យព្រះសាស្តាដែលទ្រង់ធ្វើភត្តកិច្ចរួចរាល់ហើយ ទ្រង់ធ្វើអនុមោទនា ទើបទទួលបាត្រអំពីព្រះសាស្តា ។

## ឧបាសិកាស្តាប់ធម៌ហើយត្រូវអាជីវកជេរ

ព្រះសាស្តា ទ្រង់ផ្តើមធម្មកថាអនុមោទនា ដោយព្រះសូរសៀងដ៏ពីរោះ ឧបាសិកាស្តាប់ធម៌បណ្តើរ សាធុការថា "សាធុ សាធុ" បណ្តើរ អាជីវកអង្គុយក្នុងបន្ទប់ខាងក្រោយនោះ បានឮសំឡេងនាងសាធុការ ហើយស្តាប់ធម៌ មិនអាចនឹងអត់ទ្រាំបាន ទើបចេញទៅដោយគិតថា "ចាប់ពីថ្ងៃនេះតទៅ នាងមិនមែនជារបស់យើងទៀតទេ" ដូច្នេះ ហើយបានជេរប្រទេចឧបាសិកា និងព្រះសាស្តាដោយប្រការផ្សេងៗ ថា "មេកាឡកណ្ណី នាងឯងជាមនុស្សវិនាស នាងចូរធ្វើសក្ការៈនេះដល់សមណៈនេះចុះ" ដូច្នេះជាដើម ក៏ចៀសចេញទៅ ។

ឧបាសិកាខ្មាសព្រះសាស្តា ព្រោះតែពាក្យរបស់អាជីវកនោះ មិនអាចបញ្ជូនចិត្តដែលរាយមាយ ឲ្យទៅតាមក្រសែនៃព្រះធម្មទេសនាបាន ។

គ្រានោះ ព្រះសាស្តាត្រាស់នឹងនាងថា "ម្នាលឧបាសិកា នាងមិនអាចញ៉ាំងចិត្តឲ្យប្រព្រឹត្តទៅតាមក្រសែព្រះធម្មទេសនាបានឬ?" ។

ឧបាសិកា. បពិត្រព្រះអង្គដ៏ចម្រើន ព្រោះពាក្យអាជីវកនេះឯង ធ្វើឲ្យ

ចិត្តរបស់ខ្ញុំព្រះអង្គដល់នូវការរាយមាយហើយ ។

ព្រះសាស្តាត្រាស់ថា “ម្នាលឧបាសិកា នាងមិនគួរពឹកដល់ពាក្យដែលជនវិសភាគគ្នាបែបនេះពោលឡើយ ការមិនរឭកដល់ពាក្យបែបនេះ ហើយចូរពិចារណានូវកិច្ចទាំងឡាយដែលធ្វើហើយ និងមិនទាន់បានធ្វើរបស់ខ្លួនប៉ុណ្ណោះទើបគួរ ។ លុះទ្រង់ត្រាស់ដូច្នេះហើយ ក៏ត្រាស់ព្រះគាថាដូច្នេះបន្ទថា ៖

*ន បរេសំ វិលោមានិ ន បរេសំ កតាកតំ*

*អត្តនោ វ អវេក្ខេយ្យ កតានិ អកតានិ ច ។*

ពាក្យចាក់ដោតទាំងឡាយរបស់ជនដទៃ បុគ្គលមិនគួរធ្វើទុកក្នុងចិត្តទេ កិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ជនដទៃ (ដែលមិនមែនជាមុខការរបស់ខ្លួន) បុគ្គលមិនគួរពិនិត្យមើលទេ បុគ្គលគួរពិនិត្យពិចារណា តែកិច្ចការទាំងឡាយ ដែលធ្វើហើយ និងមិនទាន់ធ្វើហើយរបស់ខ្លួនតែម្យ៉ាង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា *ន បរេសំ វិលោមានិ (មិនគួរធ្វើពាក្យចាក់ដោតរបស់ជនដទៃទុកក្នុងចិត្តទេ)* សេចក្តីថា មិនគួរធ្វើចាក់ដោត គឺ ពាក្យគ្រោតគ្រាត បានដល់ ពាក្យដែលកាត់នូវសេចក្តីស្រឡាញ់របស់ពពួកជនដទៃ

ទុកក្នុងចិត្តឡើយ ។

បទថា **ន បរេសំ កតាកតំ (មិនគួរពិនិត្យមើលកិច្ចដែលធ្វើហើយ និងមិនទាន់ធ្វើរបស់បុគ្គលដទៃទេ)** សេចក្តីថា មិនគួរសម្លឹងមើលអំពើដែលធ្វើហើយ និងមិនទាន់បានធ្វើហើយ របស់ពួកជនដទៃយ៉ាងនេះថា “ឧបាសកឯណោះមិនមានសទ្ធា មិនជ្រះថ្លា សូម្បីត្រឹមតែវត្ថុ មានបាយមួយវែកជាដើមក្នុងផ្ទះ គេក៏មិនអាចលះបង់ឲ្យទៅអ្នកដទៃបាន សលាកភត្តជាដើម គេក៏មិនធ្លាប់ឲ្យ ការឲ្យបច្ច័យមានចីវរជាដើម មិនមានដល់ឧបាសកនោះឡើយ ឧបាសិកាឯណោះក៏ដូចគ្នា មិនមានសទ្ធា មិនជ្រះថ្លា បាយត្រឹមតែមួយវែកជាដើមក្នុងផ្ទះ នាងក៏មិនឲ្យ សលាកភត្តជាដើម ក៏មិនធ្លាប់ឲ្យ ការឲ្យបច្ច័យមានចីវរជាដើម ក៏មិនមានដល់ឧបាសិកានោះ ភិក្ខុឯណោះក៏ដូចគ្នា មិនមានសទ្ធា មិនជ្រះថ្លា ថែមទាំងមិនបានធ្វើនូវឧបជ្ឈាយវត្ត មិនធ្វើអាចរិយវត្ត មិនធ្វើអាគន្តុកវត្ត មិនធ្វើវត្តដើម្បីភិក្ខុដែលត្រៀមនឹងទៅ មិនធ្វើវត្តត្រង់លានព្រះចេតិយ មិនធ្វើវត្តក្នុងរោងឧបោសថ មិនធ្វើវត្តក្នុងរោងឆាន់ មិនធ្វើវត្ត មានវត្តក្នុងរោងភ្លើងជាដើម ទាំងធុតង្គណាៗ ក៏មិនមានដល់ពួកភិក្ខុនោះ សូម្បីនូវហេតុត្រឹមតែឧស្សាហ៍ ដើម្បីភាពជាអ្នកមាននូវការវន្ទាជាទីត្រេកអរ ក៏មិនមាន” ។

បទថា **អត្តនោ វ អវេក្ខេយ្យ (គប្បីពិចារណា... របស់ខ្លួនប៉ុណ្ណោះ)** សេចក្តីថា កុលបុត្រដែលបួសដោយសទ្ធា កាលរឭកដល់ឱវាទនេះថា បព្វជិត

គប្បីពិចារណារឿយៗ ថា "ថ្ងៃ និងយប់ចេះតែកន្លងទៅៗ តើយើងបានធ្វើខ្វះ" ដូច្នេះ គប្បីពិចារណាមើលនូវកិច្ចទាំងឡាយដែលបានធ្វើហើយ និងមិនទាន់បានធ្វើរបស់ខ្លួនយ៉ាងនេះថា "យើងមិនអាចនឹងលើកខ្លួនឡើងកាន់ត្រៃលក្ខណ៍ គឺ អនិច្ចំ ទុក្ខំ អនត្តា ហើយធ្វើឲ្យក្សេមចាកយោគៈទេហ្ន៎" ។

ក្នុងកាលចប់ព្រះធម៌ទេសនា ឧបាសិកាក៏តាំងនៅក្នុងសោតាបត្តិផល ធម្មទេសនា មានប្រយោជន៍ដល់មហាជនទាំងឡាយ ដូច្នេះឯង ។

ចប់ រឿងធាដិកាជីវក

# ៧. រឿងឆត្តបាណិឧបាសក

ព្រះសាស្តា កាលប្រថាប់នៅក្រុងសាវត្ថី ទ្រង់ប្រារព្ធឆត្តបាណិឧបាសក ត្រាស់ព្រះធម្មទេសនានេះថា **យថាបិ រុចិរំ បុប្ផំ** (ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ល្អ តែគ្មានក្លិន "ក្រអូប") ជាដើម ។

ឆត្តបាណិមិនក្រោកទទួលព្រះបាទបសេនទិកោសល

សេចក្តីពិស្តារថា នៅក្នុងក្រុងសាវត្ថីមានឧបាសកម្នាក់ឈ្មោះ **ឆត្តបាណិ** ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ជាព្រះអនាគាមី ។ ឧបាសកនោះ ជាអ្នករក្សាឧបោសថ បានទៅកាន់ទីបម្រើរបស់ព្រះសាស្តាពីព្រលឹម ។ ពិតហើយ ដែលឈ្មោះថា ឧបោសថកម្ម រមែងមិនមានដល់អរិយសាវក ថ្នាក់អនាគាមីទាំងឡាយ ដោយអំណាចនៃការសមាទានទេ ព្រហ្មចរិយៈ និងការបរិភោគភត្តមួយពេលរបស់ព្រះអរិយសាវកថ្នាក់អនាគាមិបុគ្គលទាំងនោះ មកព្រមនឹងមគ្គនោះឯង ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា "មហាបពិត្រ នាយស្មូនឆ្នាំងឈ្មោះឃដិកានោះឯង ជាអ្នកបរិភោគភត្តតែម្តង មានប្រក្រតីប្រព្រឹត្តព្រហ្មចារ្យ មានសីល មានកល្យាណធម៌" ។ ដោយប្រក្រតី ព្រះអនាគាមិ-បុគ្គលទាំងឡាយ ជាអ្នកបរិភោគភត្តតែមួយពេល និងមានប្រក្រតីប្រព្រឹត្តព្រហ្មចារ្យយ៉ាងនោះ ។ សូម្បីឧបាសកនោះ ក៏ជាអ្នករក្សាឧបោសថយ៉ាងនោះដែរ លោកចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយស្តាប់ធម្មកថា ។

ក្នុងសម័យនោះ ព្រះបាទបសេនទិកោសល ស្តេចបានយាងទៅកាន់ទីទំនុកបម្រុងព្រះសាស្តា ឆត្តបាណិឧបាសក ឃើញព្រះបាទបសេនទិកោសលយាងមក ក៏គិតថា "អាត្មាអញគួរក្រោកទទួល ឬក៏មិនគួរក្រោក" លុះគិតដូច្នេះហើយ ក៏មិនក្រោកឡើង ដោយយល់ឃើញថា "អាត្មាអញអង្គុយក្នុងសម្នាក់របស់ព្រះរាជាដ៏កំពូល ការដែលយើងបានឃើញព្រះរាជា ដែលជាប្រទេស-រាជហើយ ក្រោកទទួល មិនគួរឡើយ ក៏កាលយើងមិនក្រោកទទួល ព្រះរាជាក៏នឹងក្រោធពុំខាន កាលព្រះរាជានោះក្រោធ យើងក៏នឹងមិនក្រោកទទួលទៀត ឬ ព្រោះថា យើងឃើញព្រះរាជាហើយ ក្រោកឡើង ក៏ឈ្មោះថា បានធ្វើសេចក្តីគោរពចំពោះព្រះរាជា មិនធ្វើសេចក្តីគោរពចំពោះព្រះសាស្តា យើងនឹងមិនក្រោកទទួលទេ" ។

ក៏ធម្មតាបុគ្គលជាបណ្ឌិត បានឃើញអ្នកដែលអង្គុយក្នុងសម្នាក់របស់បុគ្គលដែលគួរគោរពជាង (ខ្លួន) មិនក្រោកឡើង រមែងមិនក្រោធ ប៉ុន្តែព្រះរាជាបានឃើញឧបាសកនោះ មិនក្រោកឡើង (ទទួលខ្លួន) ក៏មានព្រះទ័យកករល្អក់ ថ្វាយបង្គំព្រះសាស្តាហើយ ទ្រង់គង់នៅក្នុងទីដ៏សមគួរមួយ ។

ព្រះសាស្តាទ្រង់ជ្រាបថា ព្រះរាជាក្រោធ ក៏ត្រាស់កថា ពណ៌នាអំពីគុណរបស់ឧបាសកថា "មហាបពិត្រ ឆត្តបាណិឧបាសកនេះជាបណ្ឌិត មានធម៌បានឃើញហើយ ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក ឈ្លាសក្នុងប្រយោជន៍ និងមិនមែនប្រយោជន៍" កាលព្រះរាជាទ្រង់ស្តាប់នូវគុណកថារបស់ឧបាសកនោះ

ហើយ ព្រះហឫទ័យក៏ទោរទន់ទៅវិញ ។

ព្រះរាជាត្រាស់សួរហេតុដែលឆត្តបាណិឧបាសកមិនក្រោកទទួល

ថ្ងៃក្រោយមក ព្រះរាជាប្រថាប់ឈរនៅលើប្រាសាទជាន់លើ ទតឃើញឆត្តបាណិឧបាសក ដែលធ្វើភត្តកិច្ចរួចហើយ បាំងឆត្រ ពាក់ស្បែកជើង ធ្វើដំណើរទៅតាមផ្លូវព្រះលានហ្លួង ក៏ឲ្យរាជបុរសហៅឧបាសកនោះមក ឧបាសកនោះបិទឆត្រ និងដោះស្បែកជើងចេញ ចូលទៅគាល់ព្រះរាជា ថ្វាយបង្គំហើយឈរនៅក្នុងទីដ៏សមគួរមួយ លំដាប់នោះ ព្រះរាជាត្រាស់សួរឧបាសកនោះថា "ម្នាលឧបាសកដ៏ចម្រើន ហេតុអ្វីបានជាលោកដោះឆត្រ និងដោះស្បែកជើងចេញ?" ។

ឧបាសក. ខ្ញុំព្រះអង្គបានស្តាប់ថា ព្រះរាជាត្រាស់ឲ្យហៅ ទើបខ្ញុំព្រះអង្គមក ។

ព្រះរាជា. កាលដែលយើងជាព្រះរាជា (ប្រហែល) លោកទើបនឹងដឹងក្នុងថ្ងៃនេះ (ទេឬ) ។

ឧបាសក. ខ្ញុំព្រះអង្គដឹងថា ព្រះអង្គជាព្រះរាជា សូម្បីគ្រប់កាលទាំងពួង ។

ព្រះរាជា. បើដូច្នោះ ហេតុអ្វីក្នុងថ្ងៃមុន លោកអង្គុយនៅក្នុងសម្នាក់ព្រះសាស្តា ពេលឃើញយើងហើយ មិនក្រោកឡើង (ទទួល) ។

ឧបាសក. បពិត្រមហារាជ ខ្ញុំព្រះអង្គអង្គុយក្នុងសំណាក់ព្រះរាជាដ៏

ប្រសើរលើសលប់ កាលឃើញព្រះរាជាជាប្រទេសរាជហើយ ក្រោក (ទទួល) រមែងជាអ្នកមិនគោរពក្នុងព្រះសាស្តា ព្រោះដូច្នោះ ទើបខ្ញុំព្រះអង្គមិនក្រោកឡើង (ទទួល) ។

ព្រះរាជា. ណ្ហើយចុះ អ្នកដ៏ចម្រើន រឿងនេះលើកទុកសិនចុះ យើងឮថា លោកជាអ្នកឈ្លាសក្នុងប្រយោជន៍ និងមិនមែនជាប្រយោជន៍ ដែលប្រព្រឹត្តទៅក្នុងទិដ្ឋធម៌ និងសម្បរាយិកភព ទ្រទ្រង់ព្រះត្រៃបិដក ចូរប្រាប់ធម៌ដល់យើងទាំងឡាយខាងក្នុងព្រះរាជវាំងចុះ ។

ឧបាសក. បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនអាចទេ ។

ព្រះរាជា. ព្រោះហេតុអ្វី ។

ឧបាសក. ព្រោះថា ដែលឈ្មោះថា ព្រះរាជវាំងរមែងជាស្ថានទីដែលមានទោសច្រើន បពិត្រព្រះសម្មតិទេព ក្នុងព្រះរាជដំណាក់នេះ កម្មដែលបុគ្គលប្រព្រឹត្តល្អក្តី អាក្រក់ក្តី រមែងជាកម្មធ្ងន់ ។

ព្រះរាជា. លោកកុំពោលដូច្នោះ កុំធ្វើសេចក្តីរង្កៀសថា "ថ្ងៃមុនឃើញយើងហើយ មិនបានក្រោកឡើង (ទទួល)" ។

ឧបាសក. បពិត្រព្រះសម្មតិទេព ដែលឈ្មោះថាស្ថានទីជាទីត្រាច់ទៅរបស់គ្រហស្ថ ជាទីដែលមានទោសច្រើន សូមព្រះអង្គត្រាស់ឲ្យនិមន្តបព្វជិតមួយរូបមក ហើយឲ្យប្រាប់ធម៌ចុះ ។

## ព្រះអានន្ទបង្រៀនព្រះធម៌ដល់ព្រះរាជទេវីទាំងពីរព្រះអង្គ

*ព្រះរាជា ទ្រង់បញ្ជូនឆត្តបាណិឧបាសកនោះទៅ ដោយព្រះតម្រាស់ថា "ប្រពៃហើយ អ្នកដ៏ចម្រើន សូមលោកអញ្ជើញទៅចុះ" ដូច្នេះ ហើយស្ដេចយាងទៅគាល់ព្រះសាស្ដា ទូលសូមព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមល្លិកាទេវី និងនាងវាសភខត្តិយា មានព្រះសវនីយ៍ថា "នឹងរៀនធម៌" សូមព្រះអង្គ និងព្រះភិក្ខុ ៥០០ រូប សូមស្ដេចយាងទៅកាន់ដំណាក់របស់ខ្ញុំព្រះអង្គជានិច្ច ដើម្បីសម្ដែងព្រះធម៌ដល់នាងទាំងពីរនោះចុះ" ។*

*ព្រះសាស្ដា. បពិត្រមហារាជ ធម្មតាព្រះពុទ្ធទាំងឡាយ មិននិមន្តទៅកាន់កន្លែងតែមួយអស់កាលជានិច្ចឡើយ ។*

*ព្រះរាជា. បើដូច្នោះ សូមព្រះអង្គប្រទានភិក្ខុអង្គដទៃ ដល់ខ្ញុំព្រះអង្គក៏បាន ។*

*ព្រះអង្គទ្រង់បានប្រគល់ភារៈនេះទៅឲ្យព្រះអានន្ទត្ថេរ ព្រះអានន្ទតែងនិមន្តទៅសម្ដែងព្រះបាលីថ្វាយព្រះនាងទាំងនោះអស់កាលជានិច្ច បណ្ដានាងទាំងពីរនោះ ព្រះនាងមល្លិកាទេវី បានរៀន បានទន្ទេញ (និង) ឲ្យព្រះថេរៈបង្រៀនព្រះបាលីដោយគោរព ចំណែកនាងវាសភខត្តិយាមិនរៀន មិនទន្ទេញដោយគោរព ថែមទាំងមិនអាចឲ្យព្រះថេរៈបង្រៀនព្រះបាលីដោយគោរពបាន ថ្ងៃមួយ ព្រះសាស្ដាត្រាស់សួរព្រះថេរៈថា "ម្នាលអានន្ទ ឧបាសិកាទាំងពីរនៅរៀនធម៌ទេឬ?" ។*

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន នៅរៀន ។

ព្រះសាស្តា. ឧបាសិការូបណារៀនធម៌ដោយគោរព ?

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមល្លិកាទេវី រៀនដោយគោរព ទន្ទេញដោយគោរព អាចឲ្យខ្ញុំព្រះអង្គបង្រៀនព្រះបាលីដោយគោរព ចំណែកធីតាដែលជាព្រះញាតិរបស់ព្រះអង្គ មិនរៀនដោយគោរព មិនទន្ទេញដោយគោរព មិនអាចឲ្យខ្ញុំព្រះអង្គបង្រៀនព្រះបាលីដោយសេចក្តីគោរពឡើយ ។

វាចាសុភាសិតរមែងមានផលដល់អ្នកបដិបត្តិ

ព្រះសាស្តាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រះថេរៈហើយ ត្រាស់ថា "អានន្ទ ធម្មតាធម៌ដែលតថាគតពោលហើយ សម្តែងហើយ រមែងមិនមានផលដល់អ្នកមិនស្តាប់ មិនរៀន មិនទន្ទេញ មិនសម្តែងដោយគោរព ប្រៀបដូចផ្កាឈើដែលបរិបូណ៌ដោយពណ៌ តែមិនមានក្លិនក្រអូបដូច្នោះ តែរមែងមានផលច្រើន មានអានិសង្សច្រើន ដល់អ្នកបដិបត្តិទាំងឡាយ មានការស្តាប់ដោយសេចក្តីគោរពជាដើម" លុះទ្រង់ត្រាស់ដូច្នោះហើយ បានត្រាស់ពីរព្រះគាថានេះថា ៖

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ អគន្ធកំ
ឯវំ សុភាសិតា វាចា អផលា ហោតិ អកុព្វតោ ។

---

១-ព្រះនាងវាសភខត្តិយា ជាធីតារបស់សក្យមហានាម ជាព្រះអនុជរបស់ព្រះសាស្តា , រាប់តាមលំដាប់ ព្រះនាងវាសភខត្តិយាជាព្រះភាគិនេយ្យរបស់ព្រះសាស្តា ។

យថាបិ រុចិរំ បុប្ផំ វណ្ណវន្តំ សគន្ធកំ
ឯវំ សុភាសិតា វាចា សផលា ហោតិ សុកុព្វតោ ។

ផ្កាឈើមានទ្រង់ទ្រាយល្អ មានពណ៌ (ល្អ) តែគ្មានក្លិន (ក្រអូប) (រមែងមិនក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងគ្មានផលដល់អ្នក ដែលមិនធ្វើតាម ដូច្នោះ ។ ផ្កាដែលមានទ្រង់ទ្រាយល្អ មានពណ៌មានក្លិន (រមែងក្រអូបដល់អ្នកដែលទ្រទ្រង់) ដូចម្ដេចមិញ វាចាជាសុភាសិត រមែងមានផលដល់អ្នកដែលធ្វើតាមដោយគោរព ដូច្នោះឯង ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា រុចិរំ គឺ ស្រស់ល្អ ។ បទថា វណ្ណវន្តំ (មានពណ៌ល្អ) គឺ បរិបូណ៌ដោយពណ៌ និងទ្រង់ទ្រាយ ។ បទថា អគន្ធកំ (មិនមានក្លិន) គឺ ឥតក្លិន មានផ្កាសិរមាន់ ផ្កាកណិការ និងផ្កាជយព្រឹក្សជាដើម ។ បទថា ឯវំ សុភាសិតា វាចា (វាចាសុភាសិតក៏ដូច្នោះ) សេចក្ដីថា ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដកទាំង ៣ ឈ្មោះថា វាចាសុភាសិត ។ ព្រះពុទ្ធវចនៈនោះ ប្រៀបដូចផ្កាឈើបរិបូណ៌ដោយពណ៌ និងទ្រង់ទ្រាយ (តែ) មិនមានក្លិន (ក្រអូប) ។ ឧបមាដូចផ្កាឥតក្លិនក្រអូប ក្លិននោះឯង រមែងមិនផ្សាយទៅ (គឺមិនផ្សាយទៅ) ក្នុងសរីរៈរបស់អ្នកប្រដាប់ផ្កា ដែលឥតក្លិននោះ

យ៉ាងណា សុភាសិតវាចា គឺព្រះពុទ្ធវចនៈនេះ ក៏ដូច្នោះ រមែងមិននាំក្លិន គឺ ការស្តាប់ ក្លិន គឺ ការបងចាំ និងក្លិន គឺ ការបដិបត្តិមកឲ្យ ឈ្មោះថា រមែងឥតផល ដល់អ្នកដែលមិនតាំងចិត្តប្រព្រឹត្តតាមព្រះពុទ្ធវចនៈនោះ ដោយសេចក្តីគោរព ដោយកិច្ចទាំងឡាយ មានការស្តាប់ជាដើម ឈ្មោះថា មិនបានធ្វើកិច្ចដែលគួរធ្វើក្នុងព្រះពុទ្ធវចនៈនោះ ព្រោះហេតុនោះ ទើបព្រះអង្គទ្រង់ត្រាស់ថា "វាចាជាសុភាសិត ក៏ដូច្នោះ រមែងមិនមានផលដល់អ្នកមិនធ្វើតាម" ។

បទថា ***សគន្ធកំ*** (ព្រមដោយក្លិន "ក្រអូប") បានដល់ ផ្កាចម្ប៉ា និងផ្កាឈូកខៀវជាដើម ។ បទថា ***ឯវំ*** ជាដើម សេចក្តីថា ក្លិនក្រអូប រមែងផ្សាយទៅក្នុងសរីរៈរបស់អ្នកប្រដាប់ផ្កានោះ យ៉ាងណា សុភាសិតវាចាជាសុភាសិត ពោលគឺ ព្រះពុទ្ធវចនៈ បិដកទាំង ៣ ក៏ដូច្នោះ រមែងមានផល គឺ ឈ្មោះថា រមែងមានផលច្រើន មានអានិសង្សច្រើន ព្រោះនាំក្លិន គឺ ការស្តាប់ ក្លិន គឺ ការទ្រទ្រង់ ក្លិន គឺ ការបដិបត្តិមកឲ្យបុគ្គលដែលធ្វើល្អ គឺ បុគ្គលដែលតាំងចិត្តធ្វើនូវកិច្ចដែលគួរធ្វើក្នុងព្រះពុទ្ធវចនៈនោះ ដោយកិច្ចទាំងឡាយ មានការស្តាប់ជាដើម ។

ក្នុងកាលចប់ព្រះធម៌ទេសនា ពពួកជនជាច្រើនបានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ព្រះធម៌ទេសនាបានជាប្រយោជន៍ដល់មហាជនច្រើន ដូច្នេះឯង ។

ចប់ រឿងឆត្តបាណិឧបាសក ទី ៧

# ៨. រឿងនាងវិសាខា

*ព្រះសាស្តា កាលទ្រង់ចូលទៅអាស្រ័យក្រុងសាវត្ថី ទ្រង់ប្រថាប់នៅក្នុងវត្តបុព្វារាម ទ្រង់ប្រារព្ធឧបាសិកាឈ្មោះ* ***វិសាខា*** *ទ្រង់ត្រាស់ព្រះធម្មទេសនានេះថា* ***យថាបិ បុប្ផរាសិម្ហា (មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា "ផ្សេងៗ គ្នា" ឲ្យបានច្រើន យ៉ាងណា)*** *ជាដើម ។*

## អ្នកមានបុណ្យច្រើនទាំង ៥ ក្នុងភទ្ទិយនគរ

*បានស្តាប់មក ឧបាសិកាវិសាខានោះ កើតក្នុងផ្ទៃនៃនាងសុមនាទេវី ជាភរិយារបស់ធនញ្ជយសេដ្ឋី ដែលជាបុត្ររបស់មេណ្ឌកសេដ្ឋី ក្នុងភទ្ទិយនគរ ដែនអង្គៈ ក្នុងវេលាដែលនាងមានអាយុ ៧ ឆ្នាំ ព្រះសាស្តាទ្រង់ឃើញឧបនិស្ស័យរបស់សត្វអ្នកមានផៅពង្ស ដែលគប្បីប្រោស ដើម្បីការត្រាស់ដឹង មានសេលព្រាហ្មណ៍ជាដើម មានពួកភិក្ខុសង្ឃពួកធំជាបរិវារ ស្តេចយាងទៅកាន់នគរនោះ ។*

## អ្នកអង្គុយក្នុងដែនរបស់ព្រះចាទពិម្ពិសារ ៥ នាក់

*ក៏ក្នុងសម័យនោះ មេណ្ឌកគហបតីជាប្រធាន នៃអ្នកដែលមានបុណ្យច្រើន ៥ នាក់ គ្រប់គ្រងតំណែងជាសេដ្ឋីនៅក្នុងនគរនោះ ។ ឈ្មោះអ្នកដែលមានបុណ្យច្រើន ៥ នាក់នោះ គឺ មេណ្ឌកសេដ្ឋី ១ ភរិយារបស់គាត់ ឈ្មោះចន្ទបទុមា ១ បុត្រប្រុសច្បងរបស់គាត់ ឈ្មោះធនញ្ជ័យ ១ ភរិយារបស់*

ធនញ្ជយសេដ្ឋី ឈ្មោះនាងសុមនាទេវី ១ អ្នកបម្រើរបស់មេណ្ឌកសេដ្ឋីឈ្មោះ បុណ្ណៈ ១ ។

## អ្នកមានសម្បត្តិស្តុកស្តម្ភក្នុងដែនរបស់ព្រះបាទពិម្ពិសារ ៥ នាក់

មិនមែនមានតែមេណ្ឌកសេដ្ឋីតែម្នាក់ប៉ុណ្ណោះទេ ក្នុងដែនរបស់ព្រះបាទពិម្ពិសារ មានអ្នកមានភោគៈរាប់មិនអស់ ៥ នាក់ គឺ ជោតិយសេដ្ឋី ១ ជដិល ១ មេណ្ឌកៈ ១ បុណ្ណកៈ ១ កាកវលិយៈ ១ ។

## មេណ្ឌកសេដ្ឋីឱ្យនាងវិសាខាទៅទទួលព្រះសាស្តា

ក្នុងសម័យនោះ មេណ្ឌកសេដ្ឋីបានជ្រាបដំណឹងថា ព្រះទសពលស្តេចយាងមកកាន់នគររបស់ខ្លួន ក៏ហៅក្មេងស្រីឈ្មោះវិសាខា ដែលជាបុត្រីរបស់ធនញ្ជយសេដ្ឋីមកប្រាប់ថា "នែ៎ចៅ ជាមង្គលដល់ចៅ ទាំងដល់តារបស់ចៅ និងពួកក្មេងស្រីជាបរិវាររបស់ចៅទាំង ៥០០ ចៅចូរឡើងរថ ៥០០ គ្រឿង ហែហមដោយទាសី ៥០០ នាក់ ទៅទទួលព្រះទសពលចុះ" នាងវិសាខាទទួលថា "សាធុលោកតា" ហើយក៏បានធ្វើតាមបង្គាប់ ប៉ុន្តែព្រោះនាងជាក្មេងស្រីឆ្លាតក្នុងហេតុដែលគួរ និងមិនគួរ ទើបនាងធ្វើដំណើរទៅដោយយានល្មមដែលអាច (ទៅបាន) ចុះពីយាន ក៏ដើរចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយឈរនៅក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះសាស្តាទ្រង់សម្តែងព្រះធម៌ដោយអំណាចនៃបុព្វចរិយារបស់នាង ។

ក្នុងវេលាចប់ព្រះធម៌ទេសនា នាងព្រមទាំងក្មេងស្រី ៥០០ នាក់ ក៏តាំង

នៅក្នុងសោតាបត្តិផល ។ ចំណែកមេណ្ឌកសេដ្ឋី ចូលទៅគាល់ព្រះសាស្តា ស្តាប់ធម្មកថា ក៏បានតាំងនៅក្នុងសោតាបត្តិផលដែរ ទើបនិមន្តព្រះសាស្តា ដើម្បីសោយអាហារថ្ងៃស្អែក អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយខាទនីយៈភោជនីយៈដ៏ប្រណីតក្នុងផ្ទះរបស់ខ្លួន បានថ្វាយមហាទានដោយឧបាយនេះឯង រហូតអស់កន្លះខែ ។ ព្រះសាស្តាទ្រង់គង់នៅក្នុងភទ្ទិយនគរ តាមសេចក្តីពេញព្រះហឫទ័យហើយ ក៏ចៀសចេញទៅកាន់ចារិក ។

## ព្រះបាទបសេនទិកោសលចង់បានអ្នកមានបុណ្យ

ក្នុងសម័យនោះឯង ព្រះបាទពិម្ពិសារ និងព្រះបាទបសេនទិកោសល មួយអង្គៗ ក៏ជាព្រះភស្តារបស់ប្អូនស្រី (ភគិនី) ដល់គ្នានិងគ្នា ។ ថ្ងៃមួយ ព្រះបាទបសេនទិកោសល ទ្រង់ព្រះតម្រិះថា "អ្នកដែលមានភោគៈរាប់មិនអស់ មានបុណ្យច្រើនទាំង ៥ នាក់ រមែងអាស្រ័យនៅក្នុងដែនព្រះបាទពិម្ពិសារ ចំណែកដែនរបស់យើង បុគ្គលដូច្នោះ សូម្បីត្រឹមតែម្នាក់ក៏គ្មាន បើដូច្នោះ គួរតែយើងទៅកាន់សម្នាក់របស់ព្រះបាទពិម្ពិសារ ដើម្បីសូមអ្នកមានបុណ្យច្រើនបានម្នាក់ ។ ព្រះអង្គស្តេចក៏យាងទៅកាន់នគរនោះ ព្រះបាទពិម្ពិសារ ទ្រង់ធ្វើបដិសណ្ឋារៈទូលសួរថា "ព្រះអង្គស្តេចមកព្រោះហេតុអ្វី?" ទើបត្រាស់ថា ខ្ញុំព្រះអង្គមកដោយបំណងថា "អ្នកដែលមានភោគៈច្រើន មានបុណ្យច្រើនទាំង ៥ នាក់ នៅក្នុងដែនរបស់ព្រះអង្គ ខ្ញុំព្រះអង្គនឹងនាំយកម្នាក់អំពី ៥ នាក់នោះទៅ សូមព្រះអង្គប្រទានម្នាក់ ក្នុងបណ្តាមនុស្សទាំង ៥ នាក់នោះ ដល់

ខ្ញុំព្រះអង្គផងចុះ” ។

ព្រះបាទពិម្ពិសារ. ខ្ញុំមិនអាចនឹងឲ្យត្រកូលធំៗ ផ្លាស់ប្តូរបានទេ ។

ព្រះបាទបសេនទិ. ខ្ញុំព្រះអង្គមិនបាន ក៏នឹងមិនទៅ ។

## ប្រគល់ធនញ្ជយសេដ្ឋីឱ្យទៅព្រះបាទកោសល

ព្រះបាទពិម្ពិសារ ទ្រង់ប្រឹក្សានឹងពួករាជអាមាត្យ ត្រាស់ថា “ដែលឈ្មោះថា ការផ្លាស់ប្តូរត្រកូលធំៗ មានជោតិយត្រកូលជាដើម ដូចផែនដីញ័រ បុត្ររបស់មេណ្ឌកសេដ្ឋី ឈ្មោះធនញ្ជយសេដ្ឋីក៏មានដែរ ខ្ញុំប្រឹក្សានឹងគេសិនសឹមថ្វាយដំណឹងដល់ទ្រង់” ដូច្នេះ ហើយត្រាស់ឲ្យហៅធនញ្ជយសេដ្ឋីមក មានព្រះឱង្ការថា “លោកសេដ្ឋី ព្រះបាទកោសលត្រាស់ថា នឹងនាំសេដ្ឋីអ្នកមានទ្រព្យម្នាក់ ទៅកាន់នគររបស់ព្រះអង្គ លោកចូរទៅជាមួយព្រះអង្គចុះ” ។

ធនញ្ជយ. កាលបើព្រះអង្គបញ្ជូនខ្ញុំព្រះអង្គទៅ ខ្ញុំព្រះអង្គនឹងទៅ ។

ពិម្ពិសារ. បើដូច្នោះ លោកចូរធ្វើការត្រៀមទៅចុះ ។

ធនញ្ជយសេដ្ឋី ក៏បានធ្វើកិច្ចដែលគួរធ្វើរបស់ខ្លួន ។ ឯព្រះរាជាទ្រង់បានធ្វើសក្ការៈដ៏ធំដល់សេដ្ឋី ទ្រង់ជូនព្រះរាជដំណើរព្រះបាទកោសលទៅ និងមានព្រះតម្រាស់ថា “សូមព្រះអង្គនាំយកលោកសេដ្ឋីនេះទៅចុះ” ។ ព្រះបាទកោសល នាំធនញ្ជយសេដ្ឋីទៅដោយការសម្រាកមួយរាត្រីៗ ក្នុងទីទាំងពួង រហូតដល់ទីកន្លែងមួយប្រកបដោយសុវត្ថិភាព ទ្រង់ក៏ឈប់សម្រាកនៅទីនោះ ។

ការសាងសង់នគរសាកេត

គ្រានោះ ធនញ្ជយសេដ្ឋីទូលសួរព្រះបាទបសេនទិកោសលថា "ទីនេះជាដែនរបស់នរណា?" ។

បសេនទិ. ម្នាលសេដ្ឋី ជាដែនដីរបស់យើង ។

ធនញ្ជ័យ. ពីទីនេះទៅក្រុងសាវត្ថីមានចម្ងាយប៉ុន្មាន?

បសេនទិ. ចម្ងាយ ៧ យោជន៍ ។

ធនញ្ជ័យ. ខាងក្នុងព្រះនគរចង្អៀត ជនជាបរិវាររបស់ខ្ញុំព្រះអង្គមានចំនួនច្រើន បើព្រះអង្គប្រោសដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងនៅទីនេះឯង ។

ព្រះរាជាទ្រង់ទទួលថា "ប្រពៃហើយ" ដូច្នេះ ទើបឲ្យសាងក្រុងនៅទីនោះ បានព្រះរាជទានដល់សេដ្ឋីនោះហើយ ស្ដេចក៏យាងទៅ ។ ក្រុងនោះមាននាមថា "**សាកេត**" ព្រោះលំនៅក្នុងប្រទេសនោះ ធនញ្ជយសេដ្ឋីចាប់ផ្ដើមកសាងក្នុងវេលាល្ងាច ។

សូម្បីនៅក្នុងក្រុងសាវត្ថីឯណោះវិញ មានបុត្ររបស់មិគារសេដ្ឋីឈ្មោះបុណ្ណវឌ្ឍនកុមារ បានចម្រើនវ័យហើយ ។ គ្រានោះ មាតាបិតាពោលនឹងគេថា "បា ឯងចូរជ្រើសរើសក្មេងស្រី ក្នុងទីជាទីពេញចិត្តរបស់ឯងចុះ" ។

បុណ្ណៈ. កិច្ចដោយភរិយារបស់ខ្ញុំ មិនមានទេ ។

មាតាបិតា. កូនកុំធ្វើយ៉ាងនេះឡើយ ធម្មតាត្រកូលដែលមិនមានបុត្រពុំអាចតាំងនៅបានទេ ។

## លក្ខណៈបញ្ចកល្យាណី

គេត្រូវមាតាបិតាអង្វរដដែលៗ ទើបពោលថា "បើដូច្នោះ បើខ្ញុំបាន ស្រីក្រមុំប្រកបដោយលម្អ ៥ យ៉ាង ក៏នឹងធ្វើតាមពាក្យរបស់លោកពុក អ្នកម៉ែ" ។

មាតាបិតា. ដែលឈ្មោះថា លម្អ ៥ យ៉ាងនោះ អ្វីខ្លះទៅកូន ?

បុណ្ណ:. គឺសក់ល្អ សាច់ល្អ ឆ្អឹងល្អ សម្បុរល្អ វ័យល្អ ។

ក៏សក់របស់ស្ត្រីអ្នកមានបុណ្យច្រើន ដូចកន្ទុយក្ងោកស្រោយ ព្រលែងធ្លាក់ទៅពាល់ជាយសំពត់ស្លៀក ហើយក៏ត្រឡប់មានចុង.ងឡើង នេះជា **លម្អសក់** ។ បបូរមាត់ដូចផ្លែបាស់ទុំ ដល់ព្រមដោយពណ៌ រាបជិតស្និទ្ធល្អ នេះឈ្មោះថា **លម្អសាច់** ។ ធ្មេញស រាបស្មើ មិនមានប្រហោង ឬមិនឃ្លាតអំពីគ្នា ស្រស់ស្អាតដូចកម្រងពេជ្រថ្មី ដែលគេលើកឡើងតាំងទុក និងដូចកម្រងស័ង្ខដែលគេខាត់ហើយ នេះហៅថា **លម្អឆ្អឹង** ។ ពណ៌សម្បុរដែលជាចំណែកខ្មៅ មិនលាបលនដោយគ្រឿងលម្អផ្សេងៗ ជាដើមឡើយ ក៏ខ្មៅស្និទ្ធដូចផ្កាឧប្បលខៀវ ចំណែក.ស ដូចផ្កាកណិការ នេះហៅថា **លម្អស្បែក** ។ ក៏ស្ត្រីណាប្រសូតបុត្រហើយ ១០ ដង ក៏ដូចប្រសូតម្តង នៅតែស្រស់ស្អាតគួរឲ្យគយគន់ ឈ្មោះថា **លម្អវ័យ** ដូច្នេះឯង ។

## សេដ្ឋីបញ្ជូនព្រាហ្មណ៍ឱ្យស្វែងរកស្ត្រីបញ្ចកល្យាណី

គ្រានោះ មាតាបិតារបស់បុណ្ណវឌ្ឍនកុមារនោះ អញ្ជើញព្រាហ្មណ៍ ១០៨ នាក់ ឲ្យមកបរិភោគ ហើយសួរថា "ស្ត្រីដែលឈ្មោះថា ប្រកបដោយលក្ខណៈបញ្ចកល្យាណី មានដែរឬទេ?" ព្រាហ្មណ៍ទាំងនោះឆ្លើយថា "បាទមាន" ។

សេដ្ឋីពោលថា "បើដូច្នោះ ជន (គឺព្រាហ្មណ៍) ៨ នាក់ ចូរទៅស្វែងរកក្មេងស្រីបែបនេះ" ដូច្នេះ ហើយឲ្យទ្រព្យជាច្រើន ប្រាប់ថា ក៏ក្នុងវេលាណាពួកលោកត្រឡប់មកវិញ យើងខ្ញុំទាំងឡាយនឹងដឹងវត្ថុដែលគួរធ្វើដល់ពួកលោក លោកទាំងឡាយទៅចុះ" ស្វែងរកស្រីបែបនោះ ក្នុងវេលាដែលបានជួប គប្បីបំពាក់កម្រងមាសនេះឲ្យនាងចុះ ហើយក៏ឲ្យកម្រងមាសមានតម្លៃ ១ សែន ។ ព្រាហ្មណ៍ទាំងនោះ បានទៅកាន់នគរធំៗ ស្វែងរកក្មេងស្រីដែលប្រកបដោយលក្ខណៈ ៥ យ៉ាង មិនជួបសោះ ក៏ត្រឡប់មកដល់នគរសាកេតជាលំដាប់ ក្នុងថ្ងៃនោះ មានពិធីរៀបចំធ្វើបុណ្យនក្ខត្តឫក្ស ទើបគិតគ្នាថា "ការងាររបស់ពួកយើងគង់សម្រេចថ្ងៃនេះ" ។

ក៏ក្នុងនគរនោះ តែងតែមានបុណ្យនក្ខត្តឫក្ស គឺ នក្ខត្តឫក្សបើក ១ ប្រចាំឆ្នាំ ។ ក្នុងកាលនោះ សូម្បីត្រកូលដែលមិនចេញទៅខាងក្រៅ ក៏ចេញអំពីផ្ទះព្រមជាមួយបរិវារ មានរាងកាយមិនបានបិទបាំង ទៅកាន់ច្រាំងនៃស្ទឹងដោយជើង ក្នុងថ្ងៃនោះ សូម្បីបុត្រទាំងឡាយរបស់ខត្តិយមហាសាលជាដើម

ក៏ឈរអែបតាមជង្ហួរនោះៗ ដោយតាំងចិត្តថា "ពួកយើងជួបក្មេងស្រីដែលមានត្រកូលជាទីពេញចិត្ត មានជាតិស្មើនឹងខ្លួន នឹងបំពាក់កម្រងផ្កាឲ្យ" ។

ព្រាហ្មណ៍ជួបនាងវិសាខា

ព្រាហ្មណ៍ទាំងនោះ ចូលទៅកាន់សាលា ១ ទៀបច្រាំងនៃស្ទឹងហើយឈរនៅទីនោះ ។ គ្រានោះ នាងវិសាខា មានអាយុឈានចូល ១៥-១៦ ឆ្នាំ ប្រដាប់ដោយគ្រឿងអាភរណៈគ្រប់យ៉ាង ដែលមានកុមារី ៥០០ ហែហម បានគិតថា "យើងនឹងទៅកាន់ស្ទឹង ហើយងូតទឹក" លុះគិតដូច្នោះហើយ ក៏ធ្វើដំណើរទៅកាន់ទីនោះ ។ លុះទៅដល់ទីនោះ ភ្លៀងក៏បង្អុរចុះមកយ៉ាងខ្លាំង ក្មេងស្រី ៥០០ ប្រញាប់រត់ចូលទៅកាន់សាលា ពួកព្រាហ្មណ៍ពិចារណាមើលក៏មិនឃើញក្មេងស្រីទាំងនោះ សូម្បីតែម្នាក់ ដែលប្រកបដោយបញ្ចកល្យាណី ចំណែកនាងវិសាខា ចូលទៅកាន់សាលាដោយការដើរតាមប្រក្រតីនោះឯង ។ សំពត់ និងគ្រឿងអាភរណៈទទឹកជោក ។ ពួកព្រាហ្មណ៍ឃើញលម្អ ៤ យ៉ាងរបស់នាងហើយ ក៏ចង់ឃើញធ្មេញនាងទៀត ទើបនាំគ្នានិយាយចំអកឲ្យនាងថា "ធីតារបស់ពួកយើងជាស្រីគ្មានមារយាទ ស្វាមីរបស់ស្ត្រីនេះប្រហែលជាមិនបានសូម្បីតែបាយចុងអង្ករបរិភោគផងមើលទៅ ពេលនោះ នាងវិសាខានិយាយនឹងពួកព្រាហ្មណ៍ទាំងនោះថា "ពួកលោកនិយាយចំអកឲ្យនរណា?" ។

ព្រាហ្មណ៍. ចំអកឲ្យនាងហ្នឹងឯង ។

បានឮថា សំឡេងដ៏ពីរោះរបស់នាងបន្លឺចេញមក ប្រៀបដូចជាសំឡេង

គេរាំង លំដាប់នោះ នាងសួរព្រាហ្មណ៍ទាំងនោះ ដោយសំឡេងដ៏ពីរោះជាថ្មីម្តងទៀតថា "ព្រោះហេតុអ្វី ទើបពួកលោកចំអកឲ្យខ្ញុំ?" ។

ព្រាហ្មណ៍. ស្រីជាបរិវាររបស់នាងមិនឲ្យសំពត់ និងគ្រឿងប្រដាប់សើម ក៏ប្រញាប់រត់ចូលកាន់សាលា កិច្ចសូម្បីត្រឹមតែការប្រញាប់មកកាន់ទីមានប្រមាណប៉ុណ្ណេះរបស់នាងក៏មិនមាន នាងបណ្តោយឲ្យសំពត់ និងគ្រឿងអាភរណៈទទឹកអស់ ព្រោះហេតុនោះ ទើបពួកយើងនាំគ្នាចំអកឲ្យនាង ។

វិសាខា. លោកទាំងឡាយ ពួកលោកកុំនិយាយយ៉ាងនេះឡើយ ខ្ញុំជាស្ត្រីរឹងមាំជាងក្មេងស្រីទាំងនោះ ប៉ុន្តែខ្ញុំកំណត់ហេតុការណ៍ហើយ ទើបមិនមកដោយប្រញាប់ ។

ព្រាហ្មណ៍. ម្នាលនាងដ៏ចម្រើន នាងកំណត់ហេតុដូចម្តេច?

## ជន ៤ ពួក រត់មិនល្អ

វិសាខា. លោកទាំងឡាយ ជន ៤ ពួក កាលរត់ រមែងមិនគួរឡើយ និងនៅមានហេតុដទៃទៀត ។

ព្រាហ្មណ៍. ជន ៤ ពួកនោះ បានដល់ ជនពួកណាខ្លះ កាលរត់មិនសមគួរ? ។

វិសាខា. លោកទាំងឡាយ ព្រះរាជាដែលបានអភិសេកហើយ ទ្រង់ប្រដាប់ដោយគ្រឿងអាភរណៈទាំងពួង កាលសង្ក្រឹញសំពត់រត់ក្នុងព្រះលានហ្លួងមិនគួរឡើយ រមែងទទួលពាក្យនិន្ទាដោយពិតថា "ហេតុអ្វី ព្រះរាជាអង្គនេះ

ទើបវត់ ដូចគហបតី ស្ដេចយានទៅសន្សឹមៗ ប៉ុណ្ណោះ ទើបគួរ , សូម្បីដំរីមង្គលរបស់ព្រះរាជាដែលប្រដាប់ហើយ វត់ក៏មិនគួរ ដើរទៅដោយដំណើរលីលានៃដំរី ទើបគួរ , បព្វជិតវត់ក៏មិនគួរ រមែងបានទូវការតិះដៀលតែម្យ៉ាងប៉ុណ្ណោះឯងថា "ហេតុអ្វី សមណៈអង្គនេះ វត់ដូចគ្រហស្ថ" ប៉ុន្តែរមែងគួរដោយការដើរដូចអាការរបស់អ្នកស្ងប់ , ស្ត្រីភេទវត់ក៏មិនគួរ រមែងត្រូវគេតិះដៀលតែម្យ៉ាងថា "ហេតុអ្វី ស្ត្រីនេះវត់ដូចប្រុសដូច្នោះ" ប៉ុន្តែដែលគួរនោះដោយការដើរធម្មតា បពិត្រលោកទាំងឡាយ ជន ៤ ពួកនេះ កាលវត់រមែងមិនល្អ ដូច្នេះ ។

ព្រាហ្មណ៍. ម្នាលនាងដ៏ចម្រើន ក៏ហេតុដទៃនៅមានទៀតឬ ។

វិសាខា. លោកទាំងឡាយ ធម្មតាមាតាបិតាថ្នាក់ថ្នមនូវអវយវៈតូចធំមើលថែរក្សាធីតា ព្រោះថា ពួកខ្ញុំជារបស់ដែលមាតាបិតាត្រូវលក់ មាតាបិតាចិញ្ចឹមនាងខ្ញុំមក ពួកគាត់ក៏រមែងត្រូវការបញ្ជូនទៅកាន់ត្រកូលដទៃ ប្រសិនបើវេលាដែលពួកនាងខ្ញុំវត់ទៅជាន់ជាយសំពត់ ឬរអិលដួលលើផែនដី បាក់ដៃឬជើងនោះ ពួកនាងខ្ញុំនឹងក្លាយទៅជាភារៈរបស់ត្រកូលទ៉ុះឯង ចំណែកគ្រឿងអលង្ការសើមហើយ នឹងស្ងួតវិញបាន នាងខ្ញុំដឹងនូវហេតុនេះហើយ ទើបមិនវត់ ។

ពួកព្រាហ្មណ៍ឃើញការដល់ព្រមនៃធ្មេញ ក្នុងវេលាដែលនាងនិយាយទើបឲ្យសាធុការដល់នាងថា "ការដល់ព្រមដូច្នេះ ពួកយើងមិនដែលឃើញ

ឡើយ" ទើបនិយាយថា "ម្នាលនាងដ៏ចម្រើន កម្រងផ្កានេះសមគួរដល់នាង ប៉ុណ្ណោះ" ដូច្នេះ ទើបបំពាក់កម្រងផ្កាមាសនោះឲ្យ ។ គ្រានោះ នាងវិសាខា សួរពួកព្រាហ្មណ៍ថា "ពួកលោកទាំងឡាយ មកអំពីទីណា?" ។

ព្រាហ្មណ៍. ម្នាលនាងដ៏ចម្រើន ពួកខ្ញុំមកពីក្រុងសាវត្ថី ។

វិសាខា. ត្រកូលសេដ្ឋីឈ្មោះអ្វី ?

ព្រាហ្មណ៍. ឈ្មោះមិគារសេដ្ឋី ។

វិសាខា. បុត្ររបស់សេដ្ឋីឈ្មោះអ្វី ?

ព្រាហ្មណ៍. ឈ្មោះបុណ្ណវឌ្ឍនកុមារ ។

នាងវិសាខាក៏ទទួលធានាថា "ត្រកូលរបស់យើងស្មើគ្នា" លុះពោល ដូច្នេះហើយ ក៏បញ្ជូនដំណឹងទៅបិតាថា "សូមលោកពុកអ្នកម្តាយ បញ្ជូនរថ មកឲ្យពួកខ្ញុំផង" ។ ក្នុងវេលាមក នាងដើរមកក៏ពិត តែតាំងពីពេលដែល នាងប្រដាប់ដោយកម្រងមាសហើយ រមែងមិនដើរទៅផ្ទះឡើយ ។ ក្មេងស្រី ទាំងឡាយដែលមានឥស្សរៈ រមែងទៅដោយយាន មានរថជាដើម ស្ត្រីក្រៅ ពីនេះ ឡើងយានធម្មតា (ទៅ) បាំងឆត្រ ឬស្លឹកត្នោតអំពីខាងលើ កាលឆត្រ ឬស្លឹកត្នោតនោះមិនមាន ក៏យកជាយស្បៃមកពាក់លើស្មា ។ ចំណែកបិតា របស់នាងវិសាខា បញ្ជូនរថទៅ ៥០០ គ្រឿង ។ នាងវិសាខា និងបរិវារ ឡើងរថទៅផ្ទះវិញ ចំណែកពួកព្រាហ្មណ៍ក៏ទៅជាមួយដែរ ។

ពេលនោះ ធនញ្ជយសេដ្ឋីសួរព្រាហ្មណ៍ទាំងនោះថា "ពួកលោកមក

អំពីទីណា?" ។

ព្រាហ្មណ៍. បពិត្រមហាសេដ្ឋី ពួកខ្ញុំមកអំពីក្រុងសាវត្ថី ។

សេដ្ឋី. សេដ្ឋីឈ្មោះអ្វី ?

ព្រាហ្មណ៍. ឈ្មោះមិគារសេដ្ឋី ។

សេដ្ឋី. បុត្ររបស់សេដ្ឋីឈ្មោះអ្វី ?

ព្រាហ្មណ៍. ឈ្មោះបុណ្ណវឌ្ឍនកុមារ ។

សេដ្ឋី. ទ្រព្យមានប៉ុន្មាន ?

ព្រាហ្មណ៍. បពិត្រមហាសេដ្ឋី មាន ៤០ កោដិ ។

សេដ្ឋីទទួលពាក្យដោយគិតថា "ទ្រព្យប៉ុណ្ណោះប្រៀបនឹងទ្រព្យរបស់យើង ក៏ស្មើនឹងមួយកាកណិក ប្រយោជន៍អ្វីដោយហេតុដទៃ ផ្ដើមពីកាលដែលនាងទារិការបស់យើងបានហេតុត្រឹមតែការរក្សា" ។ លោកសេដ្ឋីធ្វើសក្ការៈដល់ព្រាហ្មណ៍ទាំងនោះ ឲ្យស្នាក់នៅពីរថ្ងៃ ហើយក៏បញ្ជូនឲ្យត្រឡប់វិញ ។

ពួកគេទៅដល់ក្រុងសាវត្ថីហើយ ប្រាប់ (លោកសេដ្ឋី) ថា "ពួកខ្ញុំបាននាងទារិកាហើយ" ។

សេដ្ឋី. កូនស្រីរបស់អ្នកណា ?

ព្រាហ្មណ៍. របស់ធនញ្ជយសេដ្ឋី ។

សេដ្ឋីនោះគិតថា "នាងទារិកានៃត្រកូលធំ ដែលយើងបានហើយ គួរតែយើងនាំនាងមកដោយប្រញាប់" លុះគិតដូច្នេះហើយ ក៏ក្រាបទូលព្រះរាជា

ដើម្បីទៅកាន់ក្រុងនោះ ។

ព្រះរាជាទ្រង់ព្រះតម្រិះថា "ត្រកូលធំនោះ ដែលយើងនាំមកពីសម្នាក់របស់ព្រះបាទពិម្ពិសារ ហើយឲ្យអាស្រ័យនៅក្នុងក្រុងសាកេត យើងគួរតែលើកតម្កើងត្រកូលនោះ" លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់បញ្ជូនដំណឹងថា "លោកសេដ្ឋី សូម្បីយើង ក៏នឹងទៅ" ។

សេដ្ឋីទទួលថា "ព្រះករុណា ថ្លៃវិសេស" ដូច្នេះ ហើយបញ្ជូនដំណឹងទៅប្រាប់ធនញ្ជយសេដ្ឋីថា "កាលខ្ញុំមក ព្រះរាជាក៏ស្តេចយាងមកដែរ" ពលរបស់ព្រះរាជាច្រើន លោកអាចធ្វើកិច្ច ដែលគួរធ្វើដល់ជនប្រមាណប៉ុណ្ណោះបាន ឬក៏មិនបាន ?" ។

ចំណែកធនញ្ជយសេដ្ឋី បានបញ្ជូនដំណឹងទៅប្រាប់មិគារសេដ្ឋីថា "សូម្បីព្រះរាជា ១០ ព្រះអង្គ ស្តេចមានព្រះបំណងនឹងយាងមកកាន់ផ្ទះរបស់ខ្ញុំ សូមស្តេចយាងមកចុះ" ។ មិគារសេដ្ឋី ទុកតែអ្នកចាំផ្ទះ ក៏នាំយកមនុស្សដ៏សេសក្នុងនគរធំដល់ម៉្លោះទៅ បញ្ឈប់យានក្នុងផ្លូវកន្លះយោជន៍ហើយ បញ្ជូនដំណឹងទៅប្រាប់ថា "ពួកខ្ញុំមកដល់ហើយ" ។

## ធនញ្ជយសេដ្ឋី និងធីតាចាត់ចែងរៀបចំកន្លែងទទួល

ធនញ្ជយសេដ្ឋី បញ្ជូនគ្រឿងបណ្ណាការជាច្រើនទៅ ហើយប្រឹក្សានឹងធីតាថា "កូន បានឮថា ឪពុកក្មេករបស់កូនមកជាមួយព្រះបាទកោសល" យើងគួរចាត់ចែងផ្ទះមួយណា សម្រាប់ឪពុកក្មេករបស់កូន មួយណាសម្រាប់ព្រះរាជា

មួយណាសម្រាប់ឥស្សរជន មានឧបរាជជាដើម" ។ សេដ្ឋីធីតាដែលជាអ្នកឈ្លាស មានញាណមុតស្រួចដូចពេជ្រ តាំងសេចក្តីប្រាថ្នាទុកអស់មួយសែនកប្ប បរិបូរដោយអភិនីហារ ចាត់ចែងថា "អ្នកទាំងឡាយចូរចាត់ចែងផ្ទះឯណោះ សម្រាប់ឪពុកក្មេករបស់យើង មួយនោះសម្រាប់ព្រះរាជា មួយនោះសម្រាប់ឧបរាជជាដើម" លុះចាត់ចែងដូច្នេះហើយ ឲ្យហៅទាសៈ និងកម្មករមកចាត់ចែងការថា "ពួកអ្នកប៉ុណ្ណេះនាក់ ចូរធ្វើកិច្ចដែលគួរធ្វើចំពោះព្រះរាជា ប៉ុណ្ណេះនាក់ចូរធ្វើកិច្ចដែលគួរដល់ឧបរាជជាដើម ។ ពួកអ្នកចូរមើលថែសត្វពាហនៈ មានដំរីនិងសេះជាដើម សូម្បីអ្នកមើលសេះជាដើម មកដល់ហើយ នឹងបានឱកាសមើលមហោស្រពក្នុងពិធីមង្គល ។

សួរថា ព្រោះហេតុអ្វី (ទើបនាងចាត់ចែងយ៉ាងនោះ) ?

ឆ្លើយថា "(ព្រោះ) ការពារកុំឲ្យមានពាក្យនិន្ទាអំពីសម្នាក់មនុស្សខ្លះដែលតែងតែនិយាយថា យើងទៅកាន់ពិធីមង្គលរបស់នាងវិសាខា មិនបានអ្វីសោះ ធ្វើតែកិច្ចការ មានការមើលសេះជាដើម មិនបានដើរសប្បាយ" ។

គ្រឿងប្រដាប់មហាលតាបសាធន៍

ក្នុងថ្ងៃនោះឯង បិតារបស់នាងវិសាខាឲ្យហៅជាងមាសមក ៥០០ នាក់ ហើយពោលថា "ពួកលោកចូរធ្វើគ្រឿងប្រដាប់ឈ្មោះ មហាលតាបសាធន៍ឲ្យធីតារបស់យើង" ដូច្នេះ ហើយបញ្ជាគេឲ្យមាស និងប្រាក់ កែវមណី កែវមុក្តា កែវប្រវាឡ និងពេជ្រជាដើម ល្មមសមនឹងមាសនោះ ។

ព្រះរាជាទ្រង់ប្រថាប់នៅទីនោះពីរបីថ្ងៃ ទ្រង់ក៏បញ្ជូនដំណឹងទៅប្រាប់ធនញ្ជយសេដ្ឋីថា "លោកសេដ្ឋីមិនអាចធ្វើការទទួលពួកយើងបាន ចូរលោកសេដ្ឋីដឹងកាលទៅរបស់នាងទារិកាចុះ" ។

ចំណែកធនញ្ជយសេដ្ឋី បញ្ជូនដំណឹងទៅថ្វាយព្រះរាជាថា "ឥឡូវនេះរដូវភ្លៀងមកដល់ហើយ នរណាៗ ក៏មិនអាចត្រាច់ទៅរហូត ៤ ខែបាន កាលដែលពួកពលរបស់ព្រះអង្គបានវត្ថុណាៗ សមគួរ វត្ថុនោះៗ ទាំងអស់ជាភារៈរបស់ខ្ញុំព្រះអង្គ បពិត្រមហារាជ ស្ដេចនឹងយាងទៅបាន ក្នុងពេលដែលខ្ញុំព្រះអង្គបញ្ជូនស្ដេចឲ្យយាងទៅ" ។ ចាប់ពីពេលនោះ នគរសាកេត បានជានគរមាននក្ខត្តឫក្សជានិច្ច ។ វត្ថុមានកម្រងផ្កា គ្រឿងក្រអូប និងសំពត់ជាដើម ជារបស់ដែលសេដ្ឋីបានចាត់ចែងសម្រាប់ជនទាំងអស់ តាំងអំពីព្រះរាជាជាដើមទៅ ។ ជនទាំងនោះគិតគ្នាថា សេដ្ឋីចាត់ចែងវត្ថុទាំងឡាយសម្រាប់ពួកយើងអស់រយៈកាល ៣ ខែកន្លងទៅហើយ ចំណែកគ្រឿងអលង្ការសម្រាប់នាងវិសាខាមិនទាន់សម្រេច ។ អ្នកគ្រប់គ្រងការងារមកប្រាប់សេដ្ឋីថា "បពិត្រលោកសេដ្ឋី វត្ថុទាំងឡាយណាៗ មិនខ្វះទេ ខ្វះតែឧសសម្រាប់ចំអិនអាហារដើម្បីពួកពលប៉ុណ្ណោះ" ។ សេដ្ឋីពោលថា "បើដូច្នោះ ពួកអ្នកចូររុះរើយករោងដំរីចាស់ៗ និងផ្ទះចាស់ៗ ជាដើម ក្នុងនគរនេះធ្វើឧសចំអិនចុះ" ។

សូម្បីចំអិនយ៉ាងនោះ ក៏កន្លងទៅកន្លះខែ ។ លំដាប់នោះ អ្នកចាត់ចែងការងារ មកប្រាប់ដល់លោកសេដ្ឋីម្ដងទៀតថា "អស់ឧសហើយ" ។ លោកសេដ្ឋី

ពោលថា "ទរណាៗ ក៏មិនអាចស្វែងរកឧសក្នុងវេលានេះបាន បើដូច្នោះ ពួកអ្នកចូរបើកឃ្លាំងសំពត់ទាំងឡាយ ហើយយកសំពត់សាច់គ្រោតគ្រាត ធ្វើជាប្រទេះជ្រលក់ប្រេង ចំអិនអាហារចុះ" ។ ជនទាំងនោះបានធ្វើយ៉ាងនោះ រហូតអស់កន្លះខែ ។ ៤ ខែបានកន្លងផុតទៅ ដោយអាហារយ៉ាងនេះ ។ ចំណែកគ្រឿងប្រដាប់ក៏សម្រេចហើយដែរ ។

ក្នុងគ្រឿងប្រដាប់នោះប្រកបដោយ ពេជ្រ ៤ នាឡិ កែវមុក្តា ១១ នាឡិ កែវប្រវាឡ ២០ នាឡិ កែវមណី ៣៣ នាឡិ ។ គ្រឿងប្រដាប់នោះប្រដាប់ដោយរតនៈទាំងនេះ និងវត្ថុដទៃដោយប្រការដូច្នេះ ។ គ្រឿងប្រដាប់នោះ មិនសម្រេចដោយអំបោះ ការងារណាដែលត្រូវធ្វើដោយអំបោះ គេក៏ធ្វើដោយអំបោះប្រាក់ ។ គ្រឿងប្រដាប់នោះ ពាក់ត្រង់ក្បាលក៏ធ្លាក់ទៅទល់នឹងខ្នងជើង ឡេវធ្វើដោយមាស រង្វង់ឡេវធ្វើដោយប្រាក់ ឡេវនៅត្រង់ក្បាល ១ វង់ ត្រង់ត្រចៀកទាំងពីរ ២ វង់ ត្រង់ចង្កេះទាំងសងខាង ២ វង់ ត្រង់ក ១ វង់ ត្រង់ជង្គង់ទាំងពីរ ២ វង់ ។ ក៏ក្នុងគ្រឿងប្រដាប់នោះ គេតាក់តែងជារូបក្ងោក ១ ទុក ។ ធ្វើរោមស្លាបដោយមាស ៥០០ បន្ទះ នៅស្លាបខាងស្តាំ និង ៥០០ បន្ទះនៅស្លាបខាងឆ្វេង ចំពុះធ្វើអំពីកែវប្រវាឡ ភ្នែកធ្វើអំពីកែវមណី ក និងរង្វង់កន្ទុយក៏ដូចគ្នា ទងរោមធ្វើអំពីប្រាក់ ជើងក៏ដូចគ្នា ។ រូបក្ងោកនោះស្ថិតនៅកណ្តាលសីសៈនាងវិសាខា ប្រាកដដូចក្ងោកឈររាំនៅលើកំពូលភ្នំ ។ សំឡេងស្លាបមួយពាន់ប្រព្រឹត្តទៅដូចសង្គីតទិព្វ និងដូចសំឡេងរំពងនៃតន្ត្រី

ប្រកបដោយអង្គ ៥ ។ ជនទាំងឡាយដែលចូលទៅកាន់ទីជិត ទើបដឹងក្អែក នោះ មិនមែនក្អែក (ពិត) ។ គ្រឿងប្រដាប់មានតម្លៃ ៩ កោដិ ។ លោក សេដ្ឋីឲ្យថ្លៃឈ្នួលមួយសែន ។

## ស្ត្រីថ្វាយចីវរ រមែងបានមហាលតាបសាធន៍

សួរថា "ក៏គ្រឿងប្រដាប់ដែលនាងវិសាខាបាននោះ ព្រោះផលនៃកម្ម អ្វី ?" ។

ឆ្លើយថា "ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ នាងថ្វាយចីវរសាដក ដល់ភិក្ខុពីរម៉ឺនរូប ហើយបានថ្វាយសូត្រផង ម្ជុលផង គ្រឿងជ្រលក់ផង ដែល ជារបស់ខ្លួននោះឯង នាងបានទទួលនូវគ្រឿងប្រដាប់នេះ ព្រោះផលនៃចីវរ-ទាននោះ" ។ ក៏ចីវរទានរបស់ស្ត្រីទាំងឡាយ រមែងដល់ទីបំផុតដោយគ្រឿង ប្រដាប់ឈ្មោះ មហាលតាបសាធន៍ ចីវរទានរបស់បុរសទាំងឡាយ រមែងដល់ ទីបំផុតដោយបាត្រ និងចីវរដែលសម្រេចអំពីឫទ្ធិ ។

## សេដ្ឋីចាត់ចែងទេយ្យធម៌ឲ្យដល់នាងវិសាខា

មហាសេដ្ឋី ធ្វើការរៀបចំដើម្បីធីតាអស់ ៤ ខែ យ៉ាងនោះហើយ កាល នឹងឲ្យទេយ្យធម៌ដល់ធីតានោះ បានឲ្យរទេះពេញដោយកហាបណៈ ៥០០ រទេះ ពេញដោយភាជនៈមាស ៥០០ រទេះ ពេញដោយភាជនៈប្រាក់ ៥០០ រទេះ ពេញដោយភាជនៈមាសក្រហម (ទង់ដែង) ៥០០ រទេះ ពេញដោយភាជនៈ

សំរិទ្ធ ៥០០ រទេះ ពេញដោយសំពត់សូត្រ និងសំពត់សំបកឈើ ៥០០ រទេះ ពេញដោយទឹកដោះថ្លា ៥០០ រទេះ ពេញដោយប្រេង ៥០០ រទេះ ពេញដោយស្ករអំពៅ ៥០០ រទេះ ពេញដោយអង្ករស្រូវសាលី ៥០០ រទេះ ពេញដោយគ្រឿងឧបករណ៍ មាននង្គ័ល និងផាលជាដើម ៥០០ រទេះ ។ បានឮថា ការគិតយ៉ាងនេះ បានមានដល់មហាសេដ្ឋីនោះថា "ក្នុងទីដែលធីតារបស់យើងទៅហើយ នាងកុំបានឲ្យមនុស្សទៅកាន់ទ្វារផ្ទះនៃជនដទៃថា "យើងត្រូវការវត្ថុឈ្មោះឯណោះ" ព្រោះដូច្នោះ ទើបមហាសេដ្ឋីបានបង្គាប់ឲ្យផ្តល់គ្រឿងឧបករណ៍គ្រប់យ៉ាង (ដល់ធីតារបស់ខ្លួន) ។ មហាសេដ្ឋីបានឲ្យរថ ៥០០ ព្រមទាំងស្រីក្រមុំរូបស្អាត ដែលប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ទុកលើរថនីមួយៗ ៣ នាក់ បានឲ្យនាងបរិចារិកា ១.៥០០ នាក់ ដោយប្រាប់ថា "ពួកនាងប៉ុណ្ណេះនាក់ ចូរឲ្យធីតារបស់យើងងូតទឹក ប៉ុណ្ណេះនាក់ឲ្យបរិភោគ ប៉ុណ្ណេះនាក់តែងខ្លួនឲ្យកូនយើង" ។ គ្រានោះ មហាសេដ្ឋីបានគិតយ៉ាងនេះថា "យើងនឹងឲ្យគោដល់ធីតារបស់យើង" លុះគិតដូច្នេះហើយ ក៏បង្គាប់បុរសថា "នែនាយ ពួកអ្នកចូរទៅ ចូរបើកទ្វារក្រោលតូចហើយ ឈរកាន់ស្គរ ៣ នៅក្នុងទីប្រមាណ ៣ គាវុត ឈរនៅត្រង់ខាងទាំងពីរក្នុងទីប្រមាណ ១ ឧសភៈ ដោយចំណែកទទឹង ។ បន្ទាប់ពីនោះ ចូរកុំឲ្យមេគោទាំងឡាយទៅកាន់ទីដទៃ គប្បីវាយស្គរឲ្យសញ្ញាក្នុងវេលាមេគោឈប់ហើយយ៉ាងនេះ" ។ បុរសទាំងនោះក៏ធ្វើយ៉ាងនោះ ។ ពេលមេគោចេញពីក្រោលបាន ១ គាវុត ពួកគេក៏បានវាយ

ស្គរឲ្យសញ្ញាម្តង ពេលមេគោទៅបានកន្លះយោជន៍ ក៏បានវាយស្គរឲ្យសញ្ញាម្តងទៀត ប៉ុន្តែពេលមេគោទៅបាន ៣ គាវុត ពួកគេបានហាមការទៅដោយចំណែកទទឹងទៀត មេគោទាំងឡាយ បានឈរប្រជ្រៀតគ្នានិងគ្នាក្នុងទីប្រមាណ ៣ គាវុត ទទឹងប្រមាណ ១ ឧសភៈ ដោយប្រការយ៉ាងនេះ ។

មហាសេដ្ឋីបង្គាប់ឲ្យបិទទ្វារក្រោល ដោយពាក្យថា "គោប៉ុណ្ណេះ ល្មមដល់ធីតារបស់យើងហើយ ពួកអ្នកចូរបិទទ្វារក្រោលចុះ" កាលគេបិទទ្វារក្រោលហើយ ព្រោះផលបុណ្យរបស់នាងវិសាខា គោមានកម្លាំង និងមេគោទឹកដោះទាំងឡាយក៏លោតចេញទៅទៀត ។ កាលពួកមនុស្សកំពុងតែហាមនោះឯង គោដែលមានកម្លាំង ៦០.០០០ ក្បាល និងមេគោទឹកដោះ ៦០.០០០ ក្បាល លោតចេញទៅតាមគោដែលចេញមុននោះ (និង) កូនគោដែលមានកម្លាំង មានចំនួនប៉ុណ្ណេះ ក៏ចេញទៅហើយ ពួកគោឧសភៈរបស់មេគោទឹកដោះទាំងនោះ ក៏បានជាប់តាមទៅដែរ ។

សួរថា "ក៏គោទាំងឡាយទៅយ៉ាងនោះ ព្រោះផលនៃកម្មអ្វី ?" ។

ឆ្លើយថា "ព្រោះផលនៃទានដែលនាងវិសាខា ប្រគេនដល់ភិក្ខុកំលោះ និងសាមណេរដែលជាអ្នកហាមហើយ" ។

បានឮថា ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ នាងជាប្អូនគេបង្អស់នៃធីតាទាំង ៧ របស់ព្រះបាទកិកិ មានព្រះនាមថា **សង្ឃទាសី** កាលប្រគេនបញ្ចគោរសដល់ភិក្ខុ ២០.០០០ រូប សូម្បីភិក្ខុកំលោះ និងសាមណេរបិទបាត្រ

ហើយហាមថា "ល្មមហើយៗ" ក៏នៅតែប្រាប់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន នេះឆ្ងាញ់ នេះគួរឲ្យឆ្ងាញ់" ហើយប្រគេន (ទៀត) ។ ព្រោះផលនៃកម្មនោះ គោទាំងនោះ សូម្បីគេហាម ក៏នៅតែចេញទៅយ៉ាងនោះ ។ ក្នុងវេលាដែលសេដ្ឋីឲ្យទ្រព្យប៉ុណ្ណោះ (ដល់ធីតារបស់គាត់) ភរិយារបស់សេដ្ឋីបាននិយាយថា "វត្ថុគ្រប់យ៉ាង លោកបានចាត់ចែងឲ្យធីតារបស់យើង ប៉ុន្តែអ្នកបម្រើស្រីប្រុស អ្នកចាត់ចែងការ លោកមិនទាន់បានចាត់ចែង សេចក្តីនោះព្រោះហេតុអ្វី? សេដ្ឋីឆ្លើយថា (ដែលយើងមិនទាន់ចាត់ចែង) ព្រោះចង់ដឹងអ្នកដែលស្រឡាញ់ និងស្អប់ធីតារបស់យើង ព្រោះយើងមិនអាចចាត់ពួកអ្នកដែលមិនពេញចិត្តនឹងធីតារបស់យើង បញ្ជូនឲ្យទៅជាមួយនឹងធីតារបស់យើងទេ តែក្នុងវេលានឹងឡើងយានទៅនោះឯង យើងនឹងនិយាយថា "នរណាចង់ទៅជាមួយនាងវិសាខា ក៏ចូរទៅចុះ អ្នកមិនចង់ទៅ ក៏កុំទៅ" ។

## ឱវាទ ១០ ប្រការ របស់សេដ្ឋី

គ្រានោះ សេដ្ឋីគិតថា "ធីតារបស់យើងនឹងទៅថ្ងៃស្អែកនេះ" ក៏អង្គុយក្នុងបន្ទប់ក្នុងទីជិត ហើយឲ្យឱវាទថា "ម្នាលកូនស្រី ធម្មតាស្ត្រីដែលនៅក្នុងត្រកូលស្វាមី រក្សាមារយាទនេះ និងនេះ ទើបគួរ" ។ សូម្បីមិគារសេដ្ឋីអង្គុយក្នុងបន្ទប់ជិតនោះ ក៏បានឮឱវាទរបស់ធនញ្ជយសេដ្ឋីដែរ ។ ចំណែក (ធនញ្ជយសេដ្ឋី) ប្រៀនប្រដៅធីតារបស់ខ្លួនយ៉ាងនោះហើយ ឲ្យឱវាទ ១០ ប្រការថា "ម្នាលកូនស្រី ធម្មតាស្ត្រីដែលនៅក្នុងត្រកូលឪពុកម្តាយក្មេក មិនគួរនាំភ្លើង

ខាងក្នុងទៅខាងក្រៅ, មិនគួរនាំភ្លើងខាងក្រៅចូលមកខាងក្នុង, គប្បីឲ្យមនុស្ស ដែលគួរឲ្យប៉ុណ្ណោះ, មិនគប្បីឲ្យមនុស្សដែលមិនគួរឲ្យ, គប្បីឲ្យមនុស្សទាំង ដែលគួរឲ្យ ទាំងដែលមិនគួរឲ្យ, គប្បីអង្គុយជាសុខ, គប្បីបរិភោគជាសុខ, គប្បីដេកជាសុខ, គប្បីបម្រើភ្លើង, គប្បីនមស្ការទេវតាខាងក្នុង" ដូច្នេះ ។ លុះឲ្យឱវាទ ១០ ប្រការ ដូច្នេះហើយ ថ្ងៃស្អែកឡើង ហៅសេនាទាំងអស់ មកប្រជុំ ហើយក៏រើសយកកុដុម្ពិក៍ ៨ នាក់ ឲ្យជាអ្នកវិនិច្ឆ័យក្នុងកណ្ដាល រាជសេនា ហើយពោលថា "ប្រសិនបើទោសកើតឡើងដល់ធីតារបស់យើង ក្នុងទីដែលទៅហើយ ពួកអ្នកគប្បីជម្រះ" ដូច្នេះហើយ ប្រដាប់ធីតាដោយគ្រឿង ប្រដាប់ឈ្មោះមហាលតាបសាធន៍ មានតម្លៃ ៩ កោដិ ឲ្យទ្រព្យ ៥៤ កោដិ ជាតម្លៃលម្អិតសម្រាប់ងូតទឹក ឲ្យឡើងកាន់យានហើយ ឲ្យមនុស្សដើរវាយស្គរ ប្រកាសក្នុងស្រុកសួយ ១៤ តំបន់ ដែលជារបស់ខ្លួន ដែលស្មើនឹងអនុរាធបុរី ជុំវិញក្រុងសាកេតថា "ជនណាដែលចង់ទៅជាមួយនឹងធីតារបស់យើង ចូរទៅ ចុះ" ។ អ្នកស្រុកទាំង ១៤ តំបន់ លុះបានឮសំឡេងនោះឯង ក៏ចេញទៅមិន មានសល់នរណាៗ ឡើយ ដោយគិតថា "នឹងមានប្រយោជន៍អ្វីដល់ពួកយើង ដែលនៅទីនេះ ព្រោះនាងម្ចាស់ដ៏ចម្រើនរបស់យើង ទៅហើយ" ។ ចំណែក ធនញ្ជយសេដ្ឋី ធ្វើសក្ការៈចំពោះព្រះរាជា និងមិគារសេដ្ឋីហើយ ក៏តាមជូន ធីតា និងមនុស្សទាំងនោះទៅបន្តិច រួចក៏ត្រឡប់មកវិញ ។

មិគារសេដ្ឋីអង្គុយក្នុងយានតូច ទៅពីខាងក្រោយនៃយានទាំងនោះ ឃើញ

ពួកពលហើយ ទើបសួរថា "នុ៎ះ ជាពួកណា?" ។

ពួកអ្នកបម្រើ. ទាសាទាសី ជាអ្នកបម្រើរបស់ស្ត្រីដែលជាកូនប្រសាររបស់លោក ។

មិគារ. នរណានឹងចិញ្ចឹមមនុស្សចំនួនប៉ុណ្ណោះបាន, ពួកអ្នក ចូរដេញគ្រវែង គប់មនុស្សទាំងនោះ ហើយបណ្ដេញឲ្យចេញទៅ ចូរចាប់ទាញពួកអ្នកដែលមិនព្រមចេញអំពីទីនេះ ។

តែនាងវិសាខាបានពោលថា "ចៀសចេញ កុំហាម ពលនោះឯង យើងនឹងឲ្យកត្តដល់ពលទាំងនោះ ។

សូម្បីនាងវិសាខាពោលយ៉ាងនោះ សេដ្ឋីក៏នៅតែពោលថា "ម្នាលកូនស្រី យើងមិនត្រូវការជនទាំងអស់នោះទេ នរណានឹងចិញ្ចឹមមនុស្សទាំងនោះបាន" លុះពោលដូច្នេះហើយ ក៏ឲ្យគេគប់ដោយដុំដី និងកំណាត់ឈើជាដើម បណ្ដេញឲ្យចេញទៅ នាំពួកដ៏សេសទៅ ដោយគិតថា "មនុស្សប៉ុណ្ណេះគ្រប់គ្រាន់ហើយ" ។

នាងវិសាខានៅដល់ក្រុងសាវត្ថី

លុះដល់ខ្លោងទ្វារនគរសាវត្ថី នាងវិសាខាគិតថា "យើងនឹងអង្គុយក្នុងយានដែលបិទបាំងចូលទៅឬ ឬក៏ឈរលើរថចូលទៅ?" ពេលនោះ នាងបានសម្រេចចិត្តថា "កាលយើងចូលទៅដោយយានបិទបាំង សេចក្ដីវិសេសនៃគ្រឿងប្រដាប់ឈ្មោះ **មហាលតាបសាធន៍** នឹងមិនប្រាកដ" ។ លុះគិតដូច្នោះ

ហើយ នាងក៏ឈរលើរថ សម្ដែងខ្លួនដល់អ្នកនគរទាំងអស់ចូលទៅកាន់នគរ ។ អ្នកក្រុងសាវត្ថីឃើញសម្បត្តិរបស់នាងហើយ ក៏នាំគ្នានិយាយថា "បានឮថា ស្ត្រីនោះ ឈ្មោះនាងវិសាខា សម្បត្តិបែបនេះសមគួរដល់នាងដោយពិត" ។

នាងវិសាខា ចូលទៅកាន់ផ្ទះរបស់សេដ្ឋីដោយសម្បត្តិដ៏ច្រើន ដោយប្រការដូច្នេះ ។ ក៏ក្នុងថ្ងៃដែលនាងមកដល់ អ្នកនគរទាំងអស់ក៏បានបញ្ជូនបណ្ណាការទៅតាមកម្លាំងរបស់ខ្លួន ដោយគិតថា "ធនញ្ជយសេដ្ឋីបានធ្វើសក្ការៈយ៉ាងសន្ធឹកសន្ធាប់ដល់ពួកយើង ដែលជាអ្នកមកកាន់នគររបស់ខ្លួន" ។ នាងវិសាខាធ្វើបណ្ណាការដែលគេបញ្ជូនមកនោះ ឲ្យជាប្រយោជន៍គ្រប់យ៉ាងដល់ត្រកូលដទៃៗ ដែលនៅក្នុងនគរនោះឯង ។ នាងពោលពាក្យជាទីស្រឡាញ់សមគួរដល់វ័យនៃមនុស្សទាំងនោះៗ ថា "លោកចូរឲ្យវត្ថុនេះដល់ម្ដាយរបស់ខ្ញុំ លោកចូរឲ្យវត្ថុនេះដល់ពុករបស់ខ្ញុំ ចូរឲ្យវត្ថុនេះដល់បងប្រុស ប្អូនប្រុសរបស់ខ្ញុំ" ដូច្នេះ ហើយបញ្ជូនបណ្ណាការទៅ បានធ្វើអ្នកស្រុកទាំងអស់ឲ្យដូចជាពួកញាតិរបស់ខ្លួន ដោយប្រការដូច្នេះ ។

តមក ក្នុងវេលាពាក់កណ្ដាលយប់ លាមួយក្បាលជាមេសេះអាជានេយ្យរបស់នាងបានកើតកូន ។ នាងឲ្យពួកទាសីកាន់ប្រទីបទៅកាន់ទីនោះ ហើយញ៉ាំងមេលាឲ្យងូតដោយទឹកក្ដៅ ហើយលាបដោយប្រេង ទើបឲ្យបានទៅកាន់លំនៅរបស់ខ្លួនវិញ ។

មិគារសេដ្ឋី កាលធ្វើអាវាហមង្គលឲ្យបុត្រ មិនបាននឹកដល់ព្រះតថា-

គត សូម្បីព្រះអង្គគង់នៅក្នុងវិហារជិតផ្ទះរបស់ខ្លួន ដោយសេចក្តីស្រឡាញ់ពួកសមណៈអាក្រាត ដែលជក់ជាប់នៅក្នុងចិត្តរបស់គាត់អស់កាលដ៏យូរនោះ បានជាសោតឿនឲ្យគាត់គិតថា "យើងនឹងធ្វើសក្ការៈដល់លោកម្ចាស់ដ៏ចម្រើនរបស់យើង" ។ ថ្ងៃមួយ ឲ្យបម្រើជាំបាយាសដែលមានទឹកតិច ដាក់ក្នុងភាជន៍ថ្មី ច្រើនរយសម្រាប់ ហើយឲ្យគេនិមន្តដល់ពួកអចេលក៍ ៥០០ នាក់ ដែលចូលទៅកាន់ផ្ទះ ប្រើបម្រើឲ្យប្រាប់នាងវិសាខាថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរទៅហៅកូនប្រសាររបស់ខ្ញុំ មកថ្វាយបង្គំព្រះអរហន្តទាំងឡាយ" ។ នាងជាអរិយសាវិកាថ្នាក់សោតាបន្ន (លុះ) បានឮពាក្យថា "ព្រះអរហន្ត" ក៏រីករាយត្រេកអរមកកាន់កន្លែងបរិភោគរបស់អចេលក៍ទាំងនោះ កាលក្រឡេកឃើញអចេលក៍ទាំងនោះ ក៏គិតថា "អ្នកដែលប្រាសចាកហិរិឱត្តប្បៈបែបនេះ មិនមែនជាព្រះអរហន្តទេ ព្រោះហេតុអ្វី ទើបលោកឪពុកក្មេកឲ្យហៅយើងមក" តិះដៀលសេដ្ឋីហើយ ក៏ទៅទីនៅរបស់ខ្លួនវិញ ។ ពួកអចេលក៍ឃើញអាការរបស់នាងវិសាខាដូច្នោះ ក៏តិះដៀលសេដ្ឋី ដោយមានសំឡេងតែមួយទាំងអស់គ្នាថា "គហបតី លោកមិនមានស្ត្រីដទៃឬ ទើបបានឲ្យសាវិការបស់សមណ-គោតម ដែលជាស្រីកាឡកណ្ណីចូលមកក្នុងទីនេះ? ចូរបណ្តេញនាងចេញអំពីផ្ទះនេះដោយប្រញាប់" ។ សេដ្ឋីនោះគិតថា "យើងមិនអាចបណ្តេញនាងព្រោះហេតុត្រឹមតែពាក្យរបស់លោកម្ចាស់ទាំងឡាយនេះប៉ុណ្ណោះទេ នាងជាធីតានៃត្រកូលធំ" ដូច្នេះ ហើយក៏ពោលថា "លោកម្ចាស់ដ៏ចម្រើនទាំងឡាយ ធម្មតា

ក្មេងដីងខ្លះ មិនដឹងខ្លះ រមែងធ្វើ លោកម្ចាស់ទាំងឡាយនៅស្ងៀមចុះ” ហើយបញ្ជូនអចេលក៍ទាំងនោះទៅ អង្គុយលើអាសនៈដែលមានតម្លៃច្រើន បរិភោគមធុបាយាសដែលមានទឹកតិចដោយថាសមាស ។ ក្នុងសម័យនោះ ព្រះថេរៈអ្នកត្រាច់បិណ្ឌបាតជាវត្តមួយរូប កំពុងនិមន្តបិណ្ឌបាត បានចូលទៅទីនោះ ។ នាងវិសាខាឈរបក់ផ្លិតឲ្យឪពុកក្មេក ឃើញព្រះថេរៈរូបនោះក៏គិតថា “ការប្រាប់ឪពុកក្មេកមិនគួរឡើយ” ទើបបានឆាកចេញទៅឈរដោយអាការឲ្យឪពុកក្មេកនោះឃើញព្រះថេរៈបាន ។ ប៉ុន្តែសេដ្ឋីនោះជាបុគ្គលពាល សូម្បីឃើញព្រះថេរៈក៏ដោយ ក៏ក្លែងធ្វើដូចជាមិនឃើញ ឱនមុខហើយបរិភោគ ។

នាងវិសាខាតិះដៀលឪពុកក្មេកថា បរិភោគរបស់ចាស់

នាងវិសាខាដឹងថា “ឪពុកក្មេករបស់នាងឃើញព្រះថេរៈ ក៏មិនយកចិត្តទុកដាក់” ទើបពោលថា “និមន្តទៅខាងមុខទៀតចុះ លោកម្ចាស់ ឪពុកក្មេករបស់នាងខ្ញុំកំពុងបរិភោគរបស់ចាស់” ។ សេដ្ឋីនោះ សូម្បីអត់ទ្រាំបានក្នុងពេលដែលពួកនិគ្រន្ថប្រាប់ (តែ) ក្នុងខណៈដែលពួនាងវិសាខាពោលថា “បរិ-ភោគរបស់ចាស់” ភ្លាម ក៏ដាក់ដៃចុះ ហើយពោលថា “អ្នកទាំងឡាយចូរនាំបាយបាយាសចេញអំពីទីនេះ ចូរបណ្តេញនាងនេះ ចេញអំពីផ្ទះនេះ នាងម្នាក់នេះ ធ្វើឲ្យយើងជាអ្នកទំពាស៊ីរបស់មិនស្អាតក្នុងវេលាមង្គលដូច្នេះ” ។ ឯទាសៈនិងកម្មករទាំងអស់ក្នុងផ្ទះនោះ សុទ្ធតែជាមនុស្សរបស់នាងវិសាខា ទើបមិនមាននរណាហ៊ានចូលទៅជិត ចាប់ត្រង់ដៃ ឬជើងរបស់នាង ដោយហោចទៅ

សូម្បីតែពោលដោយមាត់ក៏មិនមាន ។

នាងវិសាខាស្តាប់ពាក្យរបស់ឪពុកក្មេកហើយ ពោលថា "នាងខ្ញុំនឹងមិនចេញទៅដោយហេតុត្រឹមតែប៉ុណ្ណោះទេ លោកពុកមិនបាននាំនាងខ្ញុំមក ដូចនាងកុម្ភទាសីមកអំពីកំពង់ទឹកទេ ធម្មតាធីតារបស់មាតាបិតាដែលជាអ្នកនៅមានជីវិតនឹងមិនចេញទៅដោយហេតុត្រឹមតែប៉ុណ្ណោះឡើយ ព្រោះហេតុនោះ ក្នុងវេលាខ្ញុំមកទីនេះ ឪពុករបស់ខ្ញុំបានហៅកុដុម្ពិក៍ ៨ នាក់មកប្រាប់ថា "ប្រសិនបើទោសកើតឡើងដល់ធីតារបស់យើង" ដូច្នេះ ហើយប្រគល់ខ្ញុំទុកក្នុងដៃរបស់កុដុម្ពិក៍ទាំងនោះ សូមលោកឪពុកឲ្យគេហៅលោកទាំងនោះមក ហើយឲ្យជម្រះទោសរបស់នាងខ្ញុំ" ។ សេដ្ឋីគិតថា "នាងវិសាខានេះនិយាយល្អ" ទើបឲ្យហៅកុដុម្ពិក៍ទាំង ៨ នាក់មក ហើយប្រាប់ថា "នាងទារិកានេះថាឲ្យខ្ញុំដែលជាអ្នកអង្គុយទទួលទានបាយាស ដែលមានទឹកតិចក្នុងថាស ក្នុងវេលាមង្គលថាអ្នកស៊ីរបស់មិនស្អាត ពួកលោកលើកទោសនាងវិសាខា ហើយបូរបណ្តេញនាងឲ្យចេញអំពីផ្ទះនេះ" ។

កុដុម្ពិក៍. នាងដ៏ចម្រើន យ៉ាងនោះពិតមែនឬ ?

វិសាខា. ខ្ញុំមិនបាននិយាយយ៉ាងនោះទេ ប៉ុន្តែកាលព្រះថេរៈដែលជាអ្នកត្រាច់បិណ្ឌបាតជាវត្តមួយរូប មកឈរនៅហ្នឹងមាត់ទ្វារផ្ទះ ឪពុកក្មេករបស់ខ្ញុំកំពុងទទួលទានបាយបាយាសដែលមានទឹកតិច មិនដាក់ចិត្តដល់ព្រះថេរៈរូបនោះ ខ្ញុំក៏គិតថា ឪពុកក្មេករបស់យើង មិនធ្វើបុណ្យក្នុងអត្តភាពនេះ បរិភោគ

តែបុណ្យចាស់ប៉ុណ្ណោះ ទើបខ្ញុំនិយាយថា "និមន្តទៅខាងមុខចុះលោកម្ចាស់ ឪពុកក្មេករបស់នាងខ្ញុំកំពុងបរិភោគរបស់ចាស់" តើនាងខ្ញុំមានទោសព្រោះហេតុដូច្នេះឬ ។

កុដុម្ពិក៍. លោកសេដ្ឋី ទោសព្រោះហេតុនេះមិនមានទេ ធីតារបស់ពួកខ្ញុំពោលត្រឹមត្រូវហើយ ហេតុអ្វីទើបលោកក្រោធ ។

សេដ្ឋី. អ្នកទាំងឡាយ ទោសនេះជាការដែលផុតទៅហើយ តែថ្ងៃមួយក្នុងមជ្ឈិមយាម នាងវិសាខានេះ ដែលមានអ្នកបម្រើប្រុសស្រីហែហមហើយ បានទៅខាងក្រោយផ្ទះ ។

កុដុម្ពិក៍. នាងដ៏ចម្រើន យ៉ាងនោះពិតមែនឬ ?

វិសាខា. លោកពុកទាំងឡាយ នាងខ្ញុំមិនបានទៅព្រោះហេតុដទៃទេ ក៏កាលលាដែលជាមេសេះអាជានេយ្យកើតកូននៅជិតផ្ទះនេះ នាងខ្ញុំគិតថា ការដែលយើងអង្គុយព្រងើយមិនយកចិត្តទុកដាក់ មិនគួរ ទើបឲ្យគេកាន់ប្រទីបទៅជាមួយនឹងពួកស្រីបម្រើ ឲ្យធ្វើការរក្សាមេលាដែលកើតកូន ព្រោះហេតុនេះ នាងខ្ញុំនឹងមានទោសអ្វី ។

កុដុម្ពិក៍. លោកសេដ្ឋី ធីតារបស់ពួកខ្ញុំធ្វើកម្ម សូម្បីតែពួកស្រីបម្រើមិនគប្បីធ្វើក្នុងផ្ទះរបស់លោក លោកនៅឃើញទោសអ្វីចំពោះហេតុនេះ ។

### អធិប្បាយឱវាទ ១០ ប្រការ

សេដ្ឋី. លោកទាំងឡាយ សូម្បីក្នុងរឿងនេះនឹងមិនមាន ក៏ណ្ហើយចុះ

តែថា បិតារបស់នាងវិសាខានេះ កាលពោលប្រៀនប្រដៅនាងវិសាខា មុនពេលមកទីនេះ បានឲ្យឱវាទ ១០ ប្រការ ដែលជារបស់អាថ៌កំបាំង យើងមិនជ្រាបសេចក្ដីនៃឱវាទនោះ នាងចូរប្រាប់សេចក្ដីនៃឱវាទនោះដល់យើង ក៏បិតារបស់នាងបានប្រាប់ថា "**ភ្លើងក្នុងមិនគួរនាំចេញទៅខាងក្រៅ**" ពួកយើងអាចមិនឲ្យភ្លើងដល់ផ្ទះអ្នកជិតខាង ហើយរស់នៅបានដែរឬ?" ។

កុដុម្ពិក៍. នាងដ៏ចម្រើន យ៉ាងនោះពិតមែនឬ ?

វិសាខា. បពិត្រលោកទាំងឡាយ ឪពុករបស់នាងខ្ញុំមិនបាននិយាយសំដៅយកសេចក្ដីដូច្នោះទេ ប៉ុន្តែបាននិយាយដូច្នេះថា "នែ៎កូនសម្លាញ់ បើកូនឃើញទោសរបស់ម្ដាយក្មេកឪពុកក្មេក និងស្វាមីរបស់កូនហើយ កុំនាំយកទៅពោលខាងក្រៅ ព្រោះថា ដែលឈ្មោះថាភ្លើង ដូចភ្លើងប្រភេទនេះមិនមាន ។

សេដ្ឋី. អ្នកទាំងឡាយ សេចក្ដីនោះចូរលើកទុកចុះ ក៏បិតារបស់នាងវិសាខានេះបានពោលថា "**ភ្លើងពីខាងក្រៅមិនគប្បីនាំចូលមកខាងក្នុង**" ពួកយើង អាចដើម្បីនឹងមិនទៅនាំភ្លើងអំពីខាងក្រៅបានដែរឬ? ក្នុងកាលភ្លើងខាងក្នុង (ផ្ទះ) រលត់ ។

កុដុម្ពិក៍. ដូច្នោះមែនឬ នាង? ។

វិសាខា. លោកទាំងឡាយ ឪពុករបស់ខ្ញុំមិនបាននិយាយសំដៅសេចក្ដីដូច្នោះទេ ប៉ុន្តែបាននិយាយសំដៅយកសេចក្ដីដូច្នេះថា បើបុរស ឬស្ត្រីទាំងឡាយ ក្នុងផ្ទះជិតខាងរបស់កូន ពោលទោសរបស់ម្ដាយក្មេក ឪពុកក្មេក និង

ស្វាមី កូនកុំនាំយកពាក្យដែលពួកជនទាំងនោះនិយាយហើយ មកនិយាយទៀតថា "ជនឈ្មោះឯណោះ ពោលទោសយ៉ាងនេះរបស់លោកទាំងឡាយ" ព្រោះដែលឈ្មោះថាភ្លើង ដូចជាភ្លើងនោះ រមែងមិនមាន ។

នាងវិសាខាបានរួចផុតអំពីទោស ព្រោះហេតុយ៉ាងនេះ ។ ក៏នាងរួចផុតអំពីទោសព្រោះហេតុនេះ យ៉ាងណា សូម្បីនៅក្នុងពាក្យដ៏សេស នាងក៏បានរួចផុតដូច្នោះដែរ ។

ក៏ក្នុងឱវាទទាំងនោះ គប្បីជ្រាបអធិប្បាយដូច្នេះ ៖

ក៏ពាក្យដែលបិតារបស់នាងវិសាខាប្រៀនប្រដៅថា "ម្នាលកូនស្រី កូនគួរឲ្យដល់មនុស្សទាំងឡាយដែលគួរឲ្យប៉ុណ្ណោះ" លោកសេដ្ឋីពោលសំដៅយក (សេចក្តីនេះ) ថា "គួរឲ្យដល់មនុស្សដែលកាន់យកគ្រឿងឧបករណ៍ដែលខ្ចីទៅហើយ សងវិញប៉ុណ្ណោះ" ។ សូម្បីពាក្យថា "មិនគួរឲ្យដល់មនុស្សដែលមិនគួរឲ្យ" នេះ លោកសេដ្ឋីពោលសំដៅយកសេចក្តីថា "មិនគួរឲ្យដល់អ្នកកាន់យកគ្រឿងឧបករណ៍ដែលខ្ចីទៅហើយ មិនសងវិញ" ក៏ឯពាក្យថា "គួរឲ្យដល់មនុស្សទាំងដែលគួរឲ្យទាំងដែលមិនគួរឲ្យ" នេះ លោកសេដ្ឋីពោលសំដៅយកសេចក្តីថា "កាលញាតិ និងមិត្រ ស្អូមយាចកមកដល់ហើយ ជនទាំងនោះសង ឬមិនសងក៏ដោយ ឲ្យដល់ញាតិមិត្រទាំងនោះឯង គួរ" ។ សូម្បីពាក្យថា "គប្បីអង្គុយជាសុខ" នេះ លោកសេដ្ឋីពោលសំដៅយកសេចក្តីថា "ការអង្គុយក្នុងឋានៈដែលនាងឃើញនូវម្តាយក្មេក ឪពុកក្មេក និងស្វាមីហើយ គប្បីក្រោក

ឡើង រមែងមិនសមគួរ" ។ ចំណែកពាក្យថា **"គប្បីបរិភោគឲ្យជាសុខ"** នេះ សេដ្ឋីពោលសំដៅ យកសេចក្តីថា "ការមិនបរិភោគមុនម្តាយក្មេក ឪពុកក្មេក និងស្វាមី ចាត់ចែងរៀបចំអាហារឲ្យដល់លោកទាំងនោះ ដឹងថា លោកទាំងនោះបានវត្ថុដែលគួរបានហើយ ឬក៏មិនទាន់បាន ខ្លួនឯងសឹមបរិភោគក្រោយទើបគួរ" ។ សូម្បីពាក្យថា **"គប្បីដេកឲ្យជាសុខ"** នេះ សេដ្ឋីពោលសំដៅ យកសេចក្តីថា "មិនគប្បីឡើងទីដេកមុន ម្តាយក្មេក ឪពុកក្មេក និងស្វាមីឡើយ គួរធ្វើវត្តបដិបត្តិដែលខ្លួនគួរធ្វើដល់លោកទាំងនោះជាមុនសិន សឹមដេកជាខាងក្រោយទើបគួរ" និងពាក្យថា **"គប្បីបម្រើភ្លើង"** នេះ សេដ្ឋីពោលសំដៅយកសេចក្តីថា "ការឃើញម្តាយក្មេកឪពុកក្មេក និងស្វាមី ឲ្យដូចជាគំនរភ្លើង និងដូចជាស្តេចនាគ ទើបគួរ" ។ សូម្បីពាក្យថា **"គប្បីនមស្ការទេវតាខាងក្នុង"** នេះ សេដ្ឋីពោលសំដៅយកសេចក្តីថា "គប្បីឃើញម្តាយក្មេកឪពុក-ក្មេក និងស្វាមីឲ្យដូចទេវតា" ។ សេដ្ឋីបានស្តាប់ឱវាទ ១០ ប្រការនេះហើយ មិនមានពាក្យឆ្លើយឆ្លង បានអង្គុយដាក់មុខសំយុងចុះ ។

គ្រានោះ កុដុម្ពិក៍ទាំងឡាយ សួរសេដ្ឋីនោះថា "លោកសេដ្ឋី ទោសដទៃនៃធីតារបស់ពួកខ្ញុំនៅមានទៀតដែរឬ?" ។

សេដ្ឋី. មិនមានទេ ។

កុដុម្ពិក៍. បើដូច្នោះ ហេតុអ្វីទើបលោកឲ្យគេបណ្តេញនាងដែលជាអ្នកមិនមានកំហុសចេញអំពីផ្ទះ ដោយមិនមានហេតុដូច្នេះ?

## មិគារសេដ្ឋីសូមទោសនាងវិសាខា

កាលកុដុម្ពិក៍ទាំងឡាយ និយាយយ៉ាងនោះហើយ នាងវិសាខាក៏បាន និយាយថា "លោកពុកទាំងឡាយ ការដែលនាងខ្ញុំទៅពីមុនតាមឪពុកក្មេកមិន សមគួរពិត ប៉ុន្តែមុនមកកាន់ទីនេះ ឪពុករបស់នាងខ្ញុំបានប្រគល់នាងខ្ញុំទុកក្នុង ដៃរបស់ពួកលោក ដើម្បីឲ្យជម្រះទោសរបស់នាងខ្ញុំ បើនាងខ្ញុំមិនមានទោស លោកទាំងឡាយបានជ្រាបហើយ ឥឡូវខ្ញុំគួរទៅបានហើយ" លុះពោលដូច្នេះ ហើយ "ក៏ប្រាប់អ្នកបម្រើស្រីប្រុសថា ពួកអ្នកទាំងឡាយចូរជួយគ្នាចាត់ចែង ពាហនៈមានយានជាដើម" ។ ពេលនោះ សេដ្ឋីចាប់ទាញកុដុម្ពិក៍ទាំងនោះទុក ហើយពោលនឹងនាងថា "កូនស្រី ឪពុកមិនដឹង បានជានិយាយទៅហើយ ចូរ អត់ទោសឲ្យឪពុកផងចុះ" ។ វិសាខា "លោកឪពុក នាងខ្ញុំអត់ទោសដែលគួរ អត់ ឲ្យដល់លោកឪពុកបាន តែនាងខ្ញុំជាធីតារបស់ត្រកូលអ្នកមានសេចក្តី ជ្រះថ្លា ដែលមិនញាប់ញ័រក្នុងព្រះពុទ្ធសាសនា ពួកនាងខ្ញុំវៀរភិក្ខុសង្ឃចេញ ហើយ មិនអាចរស់នៅបាន បើនាងខ្ញុំបានឱកាស ទំនុកបម្រុងភិក្ខុសង្ឃតាម សេចក្តីពេញចិត្តរបស់នាងខ្ញុំ ទើបនាងខ្ញុំរស់នៅទីនេះបាន ។

សេដ្ឋី. នែកូន កូនឯងចូរទំនុកបម្រុងពួកសមណៈរបស់កូន តាមការ ពេញចិត្តចុះ ។

## មិគារសេដ្ឋីស្តាប់ធម៌របស់ព្រះពុទ្ធជាម្ចាស់

នាងវិសាខា ឲ្យមនុស្សទៅនិមន្តព្រះទសពល ហើយនិមន្តស្តេចឲ្យចូលទៅកាន់និវេសន៍ក្នុងថ្ងៃស្អែក ។ ចំណែកពពួកសមណអចេលក៍ បានឮថា ព្រះសាស្តាស្តេចយាងទៅកាន់ផ្ទះរបស់មិគារសេដ្ឋី ក៏នាំគ្នាទៅអង្គុយជុំវិញផ្ទះនោះ ។ នាងវិសាខាថ្វាយទឹកទក្ខិណោទកហើយ បញ្ជូនដំណឹងទៅថា "នាងខ្ញុំចាត់ចែងគ្រឿងសក្ការៈទាំងពួងទុកហើយ សូមអញ្ជើញឪពុកក្មេករបស់នាងខ្ញុំមកអង្គាសព្រះទសពលចុះ" ។ គ្រានោះ ពួកអាជីវកហាមឃាត់មិគារសេដ្ឋីដែលជាអ្នកចង់មកថា "ម្នាលគហបតី ចូរលោកកុំទៅកាន់សម្នាក់ព្រះគោតមឡើយ" ។ សេដ្ឋីបញ្ជូនដំណឹងទៅថា "សូមកូនស្រី អង្គាសភិក្ខុសង្ឃដោយខ្លួនឯងចុះ" ។ នាងអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានដោយខ្លួនឯង កាលកត្តកិច្ចស្រេចហើយ បានបញ្ជូនដំណឹងទៅទៀតថា "សូមអញ្ជើញឪពុកក្មេករបស់ខ្ញុំមកស្តាប់ធម្មកថា" ។ ពេលនោះ អាជីវកទាំងនោះ ពោលនឹងសេដ្ឋីដែលកំពុងគិតថា "ឈ្មោះថា ការមិនទៅលើកនេះ មិនសមគួរ" ហើយក៏ទៅព្រោះខ្លួនប្រាថ្នានឹងស្តាប់ធម៌ អាជីវកទាំងនោះពោលថា "បើដូច្នោះ កាលលោកទៅស្តាប់ធម៌របស់ព្រះសមណគោតម ចូរអង្គុយខាងក្នុងវាំងននចុះ" លុះប្រាប់ដូច្នេះហើយ ក៏ដើរទៅមុនសេដ្ឋី ហើយបាំងវាំងននទុក សេដ្ឋីទៅអង្គុយខាងក្នុងវាំងនន ។ ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលសេដ្ឋី អ្នកអង្គុយក្នុងវាំងននក្តី ក្រៅជញ្ជាំងផ្ទះអ្នកក្តី ម្ខាងនៃភ្នំឯណោះក្តី ម្ខាងចក្រវាឡឯណោះក្តី

តថាគតដែលឈ្មោះថាព្រះពុទ្ធ រមែងនឹងឲ្យអ្នកបានឮនូវសំឡេងរបស់តថាគត បាន" ដូច្នេះ ទើបទ្រង់បានផ្តើមអនុបុព្វីកថាដើម្បីសម្តែងធម៌ ដូចចាប់ដើមព្រីង ធំអង្រួន និងដូចញ៉ាំងភ្លៀង គឺ អមតធម៌ឲ្យធ្លាក់ចុះដូច្នោះ ។ ក៏កាលព្រះ សម្មាសម្ពុទ្ធទ្រង់សម្តែងធម៌ ជនដែលឈរនៅខាងមុខក្តី ឈរនៅខាងក្រោយ ក្តី នៅឆ្ងាយមួយរយចក្រវាឡ មួយពាន់ចក្រវាឡក្តី នៅក្នុងអកនិដ្ឋភពក្តី រមែងពោលថា "ព្រះសាស្តាទ្រង់ទតមើលយើងតែម្នាក់ប៉ុណ្ណោះ ទ្រង់សម្តែង ធម៌ប្រោសយើងតែម្នាក់ប៉ុណ្ណោះ" ។ ពិតណាស់ ព្រះសាស្តាដូចជាទតមើល ជននោះៗ និងដូចជាត្រាស់ជាមួយជននោះៗ ។ ន័យថា ព្រះពុទ្ធទាំងឡាយ ឧបមាដូចព្រះច័ន្ទ ។ រមែងប្រាកដ ដូចជាប្រថាប់ឈរនៅចំពោះមុខនៃសត្វ ទាំងឡាយ ដូចជនដែលឈរនៅក្នុងទីណាមួយ ដែលមានព្រះច័ន្ទអណ្តែតនៅ កណ្តាលវេហាស៍ រមែងប្រាកដដល់សត្វទាំងពួងថា "ព្រះច័ន្ទនៅលើសីរសៈ របស់យើង ព្រះច័ន្ទនៅលើសីរសៈរបស់យើង" ដូច្នោះ ។ បានឮថា នេះជា ផលនៃទានដែលព្រះពុទ្ធទាំងឡាយ ទ្រង់បានកាត់ព្រះសីរសៈដែលប្រដាប់ហើយ ទ្រង់ឆ្កៀលព្រះនេត្រ ទ្រង់កាត់សាច់បេះដូង ហើយទ្រង់បរិច្ចាគឱរស ដូចជា ព្រះជាលី ធីតាដូចជានាងកណ្ហាជិនា បជាបតីដូចជាព្រះនាងមទ្រី ឲ្យទៅជា ទាសៈនៃអ្នកដទៃ ។

## ឆាផវិសាខាចាឆនាមថា មិគារមាតា

កាលព្រះតថាគត ទ្រង់ផ្លាស់ប្តូរនូវធម្មទេសនា មិគារសេដ្ឋីដែលកំពុង

អន្តុយស្តាប់នៅខាងក្នុងវាំងនននោះឯង ក៏បានសម្រេចសោតាបត្តិផល ដែលប្រដាប់ដោយន័យមួយពាន់ ប្រកបដោយអចលសទ្ធា ជាអ្នកអស់នូវសេចក្តីសង្ស័យក្នុងព្រះរតនៈ ៣ លើកដាយវាំងននឡើង ហើយយកមាត់ថៀដោះស្ត្រីដែលជាកូនប្រសារ តាំងនាងទុកនៅក្នុងតំណែងជាមាតា ដោយពាក្យថា "នាងចូរជាមាតារបស់ខ្ញុំ តាំងពីថ្ងៃនេះតទៅ" ។ ចាប់តាំងពីថ្ងៃនោះមក នាងវិសាខាមានឈ្មោះថា **មិគារមាតា** ក្រោយមកបានបុត្រប្រុសម្នាក់ បានដាក់ឈ្មោះបុត្រនោះថា "**មិគារៈ**" ។ មហាសេដ្ឋីព្រលែងដោះស្ត្រីជាកូនប្រសារហើយ ទៅក្រាបចុះទៀបព្រះបាទរបស់ព្រះមានព្រះភាគ ប្រេបាច់ព្រះបាទដោយដៃ និងជញ្ជក់ដោយមាត់ ហើយប្រកាសឈ្មោះ ៣ ដងថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គឈ្មោះមិគារសេដ្ឋី" ដូច្នេះជាដើម ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជ្រាបរហូតអស់កាលប៉ុណ្ណេះថា ទានដែលបុគ្គលឲ្យហើយក្នុងសាសនានេះ ជាទានមានផលច្រើន" ខ្ញុំព្រះអង្គជ្រាបផលនៃទានក្នុងកាលឥឡូវនេះ ក៏ព្រោះស្ត្រីដែលជាកូនប្រសាររបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាអ្នករួចផុតហើយអំពីអបាយទាំងពួង ស្ត្រីដែលជាកូនប្រសាររបស់ខ្ញុំព្រះអង្គ កាលមកកាន់ផ្ទះនេះ ក៏មកដើម្បីប្រយោជន៍ ដើម្បីអនុគ្រោះ ដើម្បីសេចក្តីសុខដល់ខ្ញុំព្រះអង្គ ដូច្នេះ ហើយបានពោលគាថានេះថា ៖

ខ្ញុំព្រះអង្គនេះ រមែងដឹងនូវទៅដល់ទានក្នុងខេត្តដែលបុគ្គល
ឲ្យហើយមានផលច្រើនក្នុងថ្ងៃនេះ ស្ត្រីដែលជាកូនប្រសារ

ដ៏ល្អរបស់ខ្ញុំព្រះអង្គមកកាន់ផ្ទះ ដើម្បីប្រយោជន៍ដល់ខ្ញុំព្រះអង្គ ។

នាងវិសាខាបាននិមន្តព្រះសាស្ដា សូម្បីសោយក្នុងថ្ងៃស្អែក ។ ថ្ងៃស្អែកឡើង ម្ដាយក្មេកក៏បានសម្រេចសោតាបត្តិផល ។ ចាប់ពីពេលនោះមកផ្ទះនោះ បានបើកទ្វារដើម្បីព្រះសាសនា ។

មិគារសេដ្ឋីធ្វើគ្រឿងប្រដាប់ឱ្យនាងវិសាខា

លំដាប់នោះ សេដ្ឋីគិតថា “កូនប្រសាររបស់យើងមានឧបការៈច្រើន យើងនឹងធ្វើបណ្ណាការឲ្យដល់នាង ព្រោះគ្រឿងប្រដាប់របស់នាងធ្ងន់ពេក មិនអាចប្រដាប់រហូតអស់កាលជានិច្ចបាន យើងនឹងឲ្យជាងធ្វើគ្រឿងប្រដាប់ដែលស្រាលៗ ដល់នាង គួរដល់ការប្រដាប់គ្រប់ឥរិយាបថ ទាំងក្នុងពេលថ្ងៃ និងពេលយប់” ដូច្នេះ ទើបឲ្យជាងធ្វើគ្រឿងប្រដាប់ឈ្មោះ **ឃនមដ្ឋកៈ** ដែលមានតម្លៃមួយសែន កាលគ្រឿងប្រដាប់នោះសម្រេចហើយ សេដ្ឋីបាននិមន្តព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឆាន់ដោយសេចក្ដីគោរព ឲ្យនាងវិសាខាងូតទឹកក្រអូប ១៦ ឆ្នាំង ហើយឲ្យឈរថ្វាយបង្គំព្រះសាស្ដាក្នុងទីចំពោះព្រះភក្ត្រព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់ធ្វើអនុមោទនាហើយ ស្ដេចក៏យាងទៅកាន់វិហារវិញ ។

នាងវិសាខាមានកម្លាំងស្មើដំរី ៥

ចាប់ពីពេលនោះមក ពេលដែលនាងវិសាខាធ្វើបុណ្យ មានទានជាដើម

ម្តងៗ តែងបានទទួលពរ ៨ ប្រការអំពីសម្នាក់ព្រះសាស្តាជានិច្ច ប្រាកដដូចចន្ទលេខា (ព្រះច័ន្ទពេញវង់) ក្នុងកណ្តាលវេហាស៍ ដូច្នោះ ធ្វើឲ្យនាងបានចម្រើនដោយបុត្រ និងធីតាយ៉ាងច្រើន ។ បានឮមកថា នាងមានបុត្រ ១០ នាក់ មានធីតា ១០ នាក់ ។ បណ្តាបុត្រ (ប្រុសស្រី) ទាំងនោះ ម្នាក់ៗ មានបុត្រ ១០ នាក់ មានធីតា ១០ នាក់ ។ បណ្តាចៅទាំងនោះ ម្នាក់ៗ មានបុត្រ ១០ នាក់ មានធីតា ១០ នាក់ ចំនួនមនុស្សទាំងអស់ ៨.៤២០ នាក់ ប្រព្រឹត្តទៅដោយអំណាចនៃការបន្តគ្នានៃបុត្រ ចៅ និងចៅទួតរបស់នាងវិសាខាយ៉ាងនេះដោយប្រការដូច្នេះ ។ នាងវិសាខាមានអាយុ ១២០ ឆ្នាំ ។ ដែលឈ្មោះថាសក់ស្កូវសូម្បីតែមួយសរសៃនៅលើសីសៈរបស់នាងក៏មិនមាន ។ នាងប្រៀបបីដូចជាក្មេងស្រីជំទង់ អាយុប្រហែល ១៦ ឆ្នាំជានិច្ច ។ ជនទាំងឡាយឃើញនាងមានបុត្រ និងចៅជាបរិវារដើរទៅកាន់វិហារ តែងតែសួរគ្នាថា "ក្នុងបណ្តាស្ត្រីទាំងនេះ ស្ត្រីណាមួយជានាងវិសាខា?" ។ ជនដែលឃើញនាងដើរទៅតែងគិតថា "ឥឡូវនេះ សូមឲ្យដើរទៅបន្តិចទៀតចុះ ម៉ែម្ចាស់របស់យើងដើរបានល្អណាស់" ។ ជនដែលឃើញនាងឈរ អង្គុយ ដេក ក៏តែងគិតថា "សូមឲ្យដេកបន្តិចទៀតចុះ ម៉ែម្ចាស់យើងដេកបានល្អណាស់" ។ នាងបានជាអ្នកដែលនរណាៗ និយាយមិនបានថា ក្នុងឥរិយាបថទាំង ៤ នាងមានឥរិយាបថមួយនោះមិនល្អ ដោយប្រការដូច្នេះឡើយ ។ ក៏នាងវិសាខា មានកម្លាំងស្មើដំរី ៥ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់ថា "នាងវិសាខាមានកម្លាំងស្មើនឹងដំរី ៥"

ក្នុងពេលដែលនាងទៅកាន់វិហារស្តាប់ធម៌ ហើយត្រឡប់មកវិញ មានព្រះបំណងចង់សាកល្បងកម្លាំងរបស់នាង ទើបត្រាស់ឲ្យព្រលែងដំរី ដំរីនោះក៏បានលើកប្រមោយបោលសម្រុកចូលទៅរកនាងវិសាខា ។ ស្ត្រីដែលជាបរិវាររបស់នាងទាំង ៥០០ នាក់ ពួកខ្លះក៏រត់គេចទៅ ពួកខ្លះក៏មិនលះបង់នាង កាលនាងវិសាខាសួរថា អ្វីនេះ? ក៏ប្រាប់ថា "ម៉ែម្ចាស់ បានឮថា ព្រះរាជាទ្រង់បំណងនឹងសាកល្បងកម្លាំងរបស់ម៉ែម្ចាស់ ទើបត្រាស់ឲ្យព្រលែងដំរី" ។ នាងវិសាខាគិតថា "ប្រយោជន៍អ្វីដោយការឃើញដំរីនេះ ហើយរត់គេចចេញ យើងនឹងចាប់ដំរីនោះវិធីណាហ្ន៎" ទើបគិតថា "បើយើងចាប់ដំរីនោះខ្លាំងពេក ដំរីនោះនឹងវិនាស" ដូច្នេះ ទើបយកម្រាមដៃពីរចាប់ត្រង់ប្រមោយ ហើយច្រានទៅ ។ ដំរីមិនអាចទប់ខ្លួនបាន ក៏ដួលចុះត្រង់ព្រះលានហ្លួងនោះឯង ។ ពួកមហាជន ក៏បានឲ្យសាធុការ ។ នាងព្រមទាំងបរិវារ បានត្រឡប់ទៅកាន់ផ្ទះដោយសុវត្ថិភាព ។

## នាងវិសាខាក្មេងគ្រឿងប្រដាប់ក្នុងវិហារ

ក៏ក្នុងសម័យនោះឯង នាងវិសាខាមិគារមាតា មានបុត្រច្រើន មានចៅច្រើន មានបុត្រមិនមានរោគ មានចៅមិនមានរោគ សន្មតថា ជាមង្គលដ៏ឧត្តមក្នុងក្រុងសាវត្ថី ។ បណ្តាបុត្រ និងចៅទាំងពាន់ មានចំនួនប៉ុណ្ណោះ សូម្បីតែម្នាក់ដែលឈ្មោះថា ដល់នូវសេចក្តីស្លាប់ក្នុងរវាងមិនមានឡើយ ។ ក្នុងពិធីបុណ្យដែលជាមង្គល អ្នកក្រុងសាវត្ថី តែងតែអញ្ជើញនាងឲ្យបរិភោគ

មុន ។ ថ្ងៃមួយ កាលមហាជនកំពុងប្រដាប់តុបតែងខ្លួន ដើម្បីទៅស្តាប់ធម៌ ពេលនោះ នាងវិសាខាបរិភោគក្នុងទីដែលគេអញ្ជើញហើយ ក៏ប្រដាប់គ្រឿងមហាលតាបសាធន៍ ទៅកាន់វិហារជាមួយមហាជនដែរ លុះទៅដល់ជេតពន-វិហារ បានដោះគ្រឿងអាភរណៈឲ្យទៅស្រីបម្រើទុក ដែលជម្ទសង្គាហកាចារ្យពោលសំដៅយកពាក្យនេះថា "ដោយសម័យនោះ នៅក្រុងសាវត្ថី មានពិធីបុណ្យមួយ មនុស្សទាំងឡាយតាក់តែងខ្លួនទៅកាន់វត្ត ។ ចំណែកនាងវិសា-ខាមិគារមាតា ក៏ប្រដាប់តាក់តែងខ្លួនទៅកាន់វិហារដែរ ។ គ្រានោះឯង នាងវិសាខាមិគារមាតាដោះគ្រឿងប្រដាប់ចងឲ្យជាបង្វេចនឹងសំពត់ដណ្តប់ ហើយ (ហុច) ឲ្យស្ត្រីបម្រើថា "នែះនែ៎នាង នាងចូរទទួលបង្វេចនេះទុក" ។ បានឮថា នាងវិសាខានោះ កាលកំពុងដើរទៅកាន់វិហារ គិតថា "កាលយើងប្រដាប់គ្រឿងមានតម្លៃច្រើនបែបនេះទុកលើសីសៈ និងប្រដាប់គ្រឿងអលង្ការរហូតដល់ជើង ចូលទៅកាន់វិហារមិនគួរ" ទើបដោះគ្រឿងប្រដាប់នោះចេញ វេចហើយហុចឲ្យស្ត្រីបម្រើ ដែលមានកម្លាំងស្មើនឹងដំរី ៥ ដែលកើតដោយបុណ្យរបស់ខ្លួនដូចគ្នា ។ ស្ត្រីបម្រើតែម្នាក់ប៉ុណ្ណោះ ដែលអាចទទួលគ្រឿងប្រដាប់មហាលតាបសាធន៍នោះបាន ព្រោះហេតុនោះ ទើបនាងវិសាខាពោលនឹងស្ត្រីបម្រើនោះថា "នែ៎នាង នាងចូរទទួលគ្រឿងប្រដាប់នេះទុកឲ្យខ្ញុំ ខ្ញុំនឹងពាក់វាក្នុងវេលាត្រឡប់អំពីសម្នាក់របស់ព្រះសាស្តាវិញ លុះឲ្យគ្រឿងប្រដាប់មហាលតាបសាធន៍នោះទៅទាសីហើយ ក៏ពាក់គ្រឿងប្រដាប់ឈ្មោះឃនមដ្ឋកៈ ចូល

ទៅគាល់ព្រះសាស្តាស្តាប់ធម៌ ។ ក្នុងទីបំផុតនៃការស្តាប់ធម៌ នាងថ្វាយបង្គំព្រះមានព្រះភាគ ក្រោកចាកអាសនៈចៀសចេញទៅ ។ ចំណែកស្ត្រីបម្រើរបស់នាងក៏ភ្លេចគ្រឿងប្រដាប់នោះដែរ ។ ក៏កាលបរិស័ទស្តាប់ធម៌ចៀសចេញទៅហើយ បើមានរបស់ណាភ្លេចរបស់របរអ្វីៗ ព្រះអានន្ទតែងរើសរបស់នោះទុក ។ ព្រោះហេតុដូច្នោះ ក្នុងថ្ងៃនោះ លោកឃើញគ្រឿងមហាលតាបសាធន៍នោះ ក៏ទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន នាងវិសាខាភ្លេចគ្រឿងប្រដាប់នៅទីនេះ" ព្រះមានព្រះភាគត្រាស់ថា "ម្នាលអានន្ទ អ្នកចូររើសទុកក្នុងទីម្ខាងចុះ" ព្រះថេរៈរើសគ្រឿងប្រដាប់នោះពាក់ទុកត្រង់ម្ខាងនៃជណ្តើរ ។ ចំណែកនាងវិសាខាដើរក្នុងវិហារជាមួយនាងសុប្បិយា ដោយតាំងចិត្តថា "នឹងដឹងវត្ថុដែលគួរធ្វើចំពោះភិក្ខុអាគន្តុកៈ ភិក្ខុដែលត្រៀមខ្លួននឹងចេញទៅ និងភិក្ខុអាពាធជាដើម" តាមប្រក្រតីនោះឯង ភិក្ខុកំលោះ និងសាមណេរដែលត្រូវការទឹកដោះថ្លា ទឹកឃ្មុំ និងប្រេងជាដើម ឃើញឧបាសិកាទាំងនោះនៅក្នុងវិហារហើយ តែងតែកាន់កាជន៍ មានថាសជាដើមដើរចូលទៅរក ។ សូម្បីក្នុងថ្ងៃនោះ ក៏ធ្វើដូច្នោះ ។ គ្រានោះ នាងសុប្បិយាឃើញភិក្ខុអាពាធមួយរូប ក៏សួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ត្រូវការអ្វី?" កាលភិក្ខុអាពាធនោះឆ្លើយថា "ត្រូវការរសនៃសាច់" ក៏ឆ្លើយថា បានលោកម្ចាស់ ខ្ញុំនឹងបញ្ជូនមកក្នុងថ្ងៃទី ២ កាលរកមិនបានសាច់ដែលជាកប្បិយៈ ក៏ធ្វើកិច្ចដែលគួរធ្វើដោយសាច់ភ្លៅរបស់ខ្លួន ព្រោះសេចក្តីជ្រះថ្លាក្នុងព្រះសាស្តា ក៏ត្រឡប់ជាអ្នកមានសរីរៈតាំង

នៅដូចប្រក្រតីនោះឯង ។ ចំណែកនាងវិសាខាត្រួតមើលភិក្ខុកំលោះ និង សាមណេរដែលអាពាធហើយ ក៏ចេញទៅតាមទ្វារដទៃ ឈរនៅត្រង់ឧបចារៈ វិហារ ហើយនិយាយថា "នែ៎នាង នាងចូរយកគ្រឿងប្រដាប់មក ខ្ញុំនឹងពាក់ គ្រានោះ ស្រីបម្រើនោះដឹងថា ខ្លួនភ្លេច ក៏ឆ្លើយថា "ម៉ែម្ចាស់ ខ្ញុំភ្លេចហើយ" ។ នាងវិសាខាពោលថា បើដូច្នោះ នាងចូរទៅយកមក តែបើលោកម្ចាស់អានន្ទ របស់យើងរើសទុកក្នុងទីដទៃ នាងកុំយកមក ខ្ញុំនឹងបរិច្ចាគគ្រឿងប្រដាប់នោះ ដល់លោកម្ចាស់" ។ បានឮថា នាងវិសាខានោះ រមែងដឹងថា "ព្រះថេរៈតែង រើសវត្ថុដែលពួកមនុស្សភ្លេចទុក" ព្រោះដូច្នោះ ទើបនិយាយយ៉ាងនោះ ។

## នាងវិសាខាទិញដីសាងវិហារថ្វាយសង្ឃ

ចំណែកព្រះថេរៈ លុះបានឃើញស្រីបម្រើនោះ ក៏សួរថា "ម្នាលនាង នាងមកធ្វើអ្វីវិញ?" កាលស្រីបម្រើនោះឆ្លើយថា "នាងខ្ញុំភ្លេចគ្រឿងប្រដាប់ របស់ម៉ែម្ចាស់នៃនាងខ្ញុំ ទើបបាននាងខ្ញុំមក" ទើបពោលថា "អាត្មាភាពរើស ទុកត្រង់ជណ្តើរនុ៎ះ នាងចូរយកទៅ" ។ ស្រីបម្រើនោះពោលថា "បពិត្រលោក ម្ចាស់ដ៏ចម្រើន បង្វេចភណ្ឌៈដែលលោកម្ចាស់យកដៃពាល់ហើយ ម៉ែម្ចាស់ របស់នាងខ្ញុំប្រាប់មិនឲ្យយកទេ ដូច្នេះហើយ ក៏មានដៃទទេត្រឡប់ទៅវិញ ត្រូវ នាងវិសាខាសួរថា "ដូចម្តេចហើយនាង?" ក៏ប្រាប់សេចក្តីនោះ ។ នាងវិសាខា ពោលថា "នាង ខ្ញុំមិនប្រដាប់គ្រឿងដែលលោកម្ចាស់របស់ខ្ញុំពាល់ត្រូវហើយ ទេ ខ្ញុំបរិច្ចាគហើយ ប៉ុន្តែលោកម្ចាស់រក្សាទុកជាការលំបាក ខ្ញុំចំណាយគ្រឿង

ប្រដាប់នោះ ហើយនាំយកវត្ថុដែលជាកប្បិយៈមកប្រគេនលោកម្ចាស់វិញ នាងចូរទៅយកគ្រឿងប្រដាប់នោះមក ។ ស្រីបម្រើនោះ ក៏ទៅកាន់យកមកឲ្យនាងវិសាខាវិញ ។ នាងវិសាខា មិនតាក់តែងគ្រឿងប្រដាប់នោះដោយខ្លួនឯងទេ ប្រាប់ឲ្យហៅពួកជាងមាសមកហើយ ឲ្យវាយតម្លៃ កាលពួកជាងមាសទាំងនោះឆ្លើយថា "មានតម្លៃ ៩ កោដិ ឯថ្លៃឈ្នួល ១ សែន" ទើបដាក់គ្រឿងប្រដាប់ទុកលើយាន ហើយពោលថា "បើដូច្នោះ ពួកលោកចូរលក់គ្រឿងប្រដាប់នេះចុះ" ។ មិនមាននរណាហ៊ានទិញ ព្រោះស្ត្រីដែលសមគួរប្រដាប់ គ្រឿងប្រដាប់នោះ រកបានលំបាក ។ ពិតណាស់ នៅក្នុងបឋវីមណ្ឌល ស្ត្រី ៣ នាក់ប៉ុណ្ណោះ ដែលជាអ្នកបានគ្រឿងប្រដាប់មហាលតាបសាធន៍ គឺ **នាងវិសាខាមហាឧបាសិកា ១ នាងមល្លិកាភរិយារបស់ពន្ធុលសេនាបតី ១ កូនស្រីសេដ្ឋីក្រុងពារាណសី ១** ព្រោះដូច្នោះ ទើបនាងវិសាខាឲ្យតម្លៃគ្រឿងប្រដាប់នោះដោយខ្លួនឯង ហើយបញ្ជូនទ្រព្យ ៩ កោដិ ១ សែន ឡើងកាន់រទេះ នាំទៅកាន់វិហារ ថ្វាយបង្គំព្រះសាស្តា ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអានន្ទជាម្ចាស់របស់ខ្ញុំព្រះអង្គ យកដៃពាល់នូវគ្រឿងប្រដាប់របស់ខ្ញុំព្រះអង្គហើយ ចាប់តាំងពីពេលលោកពាល់ត្រូវហើយ ខ្ញុំព្រះអង្គមិនប្រដាប់ទៀតទេ តែខ្ញុំព្រះអង្គឲ្យលក់គ្រឿងប្រដាប់នោះ ដោយគិតថា "នឹងចំណាយ ហើយនាំយកវត្ថុដែលជាកប្បិយៈមក" មិនមានអ្នកណាហ៊ានទិញ ទើបខ្ញុំព្រះអង្គឲ្យតម្លៃគ្រឿងប្រដាប់នោះដោយខ្លួនឯង ខ្ញុំព្រះអង្គនឹងបង្អោនចូលទៅក្នុងបច្ច័យណា

ក្នុងបណ្ដាបច្ច័យទាំង ៤ នោះ ព្រះអង្គ? ព្រះសាស្ដាត្រាស់ថា "ម្នាលនាងវិសាខា នាងគួរនឹងធ្វើលំនៅដើម្បីសង្ឃ ជិតខ្លោងទ្វារទិសខាងកើតចុះ" ។ នាងវិសាខាទទួលថា "ព្រះករុណា ព្រះអង្គ" នាងមានចិត្តរីករាយ យកទ្រព្យ ៩ កោដិនោះទៅទិញដី ។ នាងផ្ដើមកសាងវិហារដោយទ្រព្យ ៩ កោដិទៀត ។

ការកសាងវិហាររបស់នាងវិសាខា ៩ ខែ ហើយស្រេច

ថ្ងៃមួយ ព្រះសាស្ដាទ្រង់ត្រួតមើលសត្វលោកក្នុងវេលាជិតភ្លឺ បានទតឃើញឧបនិស្ស័យសម្បត្តិរបស់សេដ្ឋីបុត្រនាមថា **ភទ្ទិយៈ** ដែលចុតិចាកទេវលោកមកកើតក្នុងត្រកូលសេដ្ឋី ក្នុងភទ្ទិយនគរ ទ្រង់ធ្វើភត្តកិច្ចក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីហើយ ស្ដេចក៏បែរព្រះភក្ត្រទៅកាន់ទ្វារទិសឧត្តរ ។ តាមប្រក្រតី ប្រសិនបើព្រះសាស្ដាទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់នាងវិសាខាស្រេចហើយ ស្ដេចក៏យាងចេញតាមទ្វារទិសទក្សិណគង់នៅក្នុងវត្តជេតពន បើទ្រង់ទទួលភិក្ខាក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីរួចស្រេចហើយ ស្ដេចក៏យាងចេញតាមទិសបស្ចិម គង់នៅក្នុងបុព្វារាម ជនទាំងឡាយឃើញព្រះមានព្រះភាគស្ដេចយាងសំដៅត្រង់ទៅរកខ្លោងទ្វារទិសឧត្តរ ក៏ដឹងបានថា "ស្ដេចនឹងចៀសចេញទៅកាន់ទីចារិក" ។ ក្នុងថ្ងៃនោះ សូម្បីនាងវិសាខា លុះជ្រាបថា "ព្រះសាស្ដាស្ដេចយាងបែរព្រះភក្ត្រទៅកាន់ខ្លោងទ្វារទិសឧត្តរ" ។ ក៏ប្រញាប់ទៅថ្វាយបង្គំ ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គមានបំណងនឹងស្ដេចយាងទៅចារិកឬ?" ។

ព្រះសាស្តា. ម្នាលនាងវិសាខា យ៉ាងនោះពិតមែនហើយ ។

វិសាខា. បពិត្រព្រះអង្គដ៏ចម្រើន នាងខ្ញុំបរិច្ចាគទ្រព្យចំនួនប៉ុណ្ណោះ សាងវិហារថ្វាយព្រះសង្ឃ សូមមេត្តាស្តេចត្រឡប់វិញចុះ ។

ព្រះសាស្តា. ម្នាលនាងដ៏ចម្រើន នេះជាការទៅមិនទាន់ត្រឡប់ទេ ។

នាងវិសាខាគិតថា “ព្រះមានព្រះភាគនឹងទ្រង់ឃើញនរណាៗ ដែលជាអ្នកសម្បូណ៌ហេតុ ដោយពិត” ទើបក្រាបទូលថា បើដូច្នោះ សូមព្រះអង្គប្រោសបញ្ជូនភិក្ខុមួយរូបដែលជាអ្នកយល់ការ ដែលនាងខ្ញុំធ្វើហើយ ឬមិនទាន់បានធ្វើ ឲ្យត្រឡប់ ហើយសូមស្តេចយាងទៅចុះ ព្រះអង្គ ។

ព្រះសាស្តា. នាងពេញចិត្តភិក្ខុរូបណា ចូរទទួលបាត្រភិក្ខុរូបនោះចុះ ។

សូម្បីនាងពេញចិត្តព្រះអានន្ទក៏ពិត ប៉ុន្តែនាងគិតថា “ព្រះមហាមោគ្គ-ល្លានជាអ្នកមានឫទ្ធិ” ការងាររបស់យើង នឹងឆាប់បានសម្រេច ព្រោះអាស្រ័យព្រះថេរៈរូបនោះ” ព្រោះហេតុដូច្នេះ ទើបនាងទទួលបាត្ររបស់ព្រះថេរៈ ។ ព្រះថេរៈក្រឡេកមើលព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា “ម្នាលមោគ្គល្លាន អ្នកចូរនាំភិក្ខុដែលជាបរិវារ ៥០០ រូប របស់អ្នកត្រឡប់វិញចុះ” ។ ព្រះថេរៈក៏បានធ្វើតាមព្រះតម្រាស់របស់ព្រះសាស្តា ។ ដោយអានុភាពរបស់ព្រះថេរៈ ពួកមនុស្សដែលទៅដើម្បីត្រូវការឈើ និងថ្ម សូម្បីមានចម្ងាយផ្លូវ ៥០-៦០ យោជន៍ ក៏ជញ្ជូនឈើ និងថ្មច្រើនសន្ធឹកសន្ធាប់មកទាន់ក្នុងថ្ងៃនោះឯង សូម្បីលើកឈើ និងថ្មដាក់រទេះក៏មិនលំបាក ភ្លៅរទេះក៏មិនបាក់ មិនយូរប៉ុន្មានពួក

គេក៏កសាងប្រាសាទ ២ ជាន់ហើយស្រេច ។ ប្រាសាទនោះបានជាប្រាសាទប្រដាប់ដោយបន្ទប់ ១.០០០ គឺ ជាន់ក្រោម ៥០០ បន្ទប់ ជាន់លើ ៥០០ បន្ទប់ ។ ព្រះសាស្ដាស្ដេចយាងទៅកាន់ចារិកអស់ ៩ ខែ ស្ដេចក៏ (ត្រឡប់) មកកាន់ក្រុងសាវត្ថីវិញទៀត ។ សូម្បីការងារក្នុងប្រាសាទរបស់នាងវិសាខាក៏សម្រេចហើយអស់ពេល ៩ ខែដែរ ។ នាងឲ្យកសាងត្រង់កំពូលប្រាសាទដោយមាស ដែលអាចផ្ទុកទឹកបាន ៦០ ឆ្នាំង ។ នាងបានឮថា "ព្រះសាស្ដាស្ដេចយាងមកកាន់ជេតពនវិហារវិញ" ក៏ទៅទទួល រួចនាំព្រះសាស្ដាទៅកាន់វិហាររបស់ខ្លួន ហើយទូលអារាធនាថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តានាំភិក្ខុសង្ឃគង់នៅក្នុងវិហារនេះអស់ ៤ ខែនេះចុះ ខ្ញុំព្រះអង្គនឹងធ្វើការឆ្លងប្រាសាទ" ។ ព្រះសាស្ដាទ្រង់ទទួលហើយ ។

## នាងវិសាខាធ្វើបុណ្យឆ្លងវិហារ

ចាប់តាំងពីពេលនោះមក នាងវិសាខាតែងតែថ្វាយនូវទានចំពោះភិក្ខុ-សង្ឃមានព្រះពុទ្ធជាប្រធាន ក្នុងវិហារនោះឯង ។

គ្រានោះ ស្ដ្រីដែលជាសម្លាញ់របស់នាងវិសាខាម្នាក់ កាន់សំពត់ ១ ផ្ទាំង តម្លៃ ១ ពាន់មក ហើយពោលថា "សម្លាញ់ ខ្ញុំចង់ក្រាលសំពត់ ១ ផ្ទាំងនេះ ក្នុងប្រាសាទរបស់នាង សូមនាងជួយប្រាប់កន្លែងក្រាលដល់ខ្ញុំ" ។ នាងវិសាខាពោលថា "សម្លាញ់ បើខ្ញុំប្រាប់នាងថា ឱកាសមិនមាន នាងសម្គាល់ថា ខ្ញុំមិនឲ្យឱកាសដល់ នាង នាងចូររកមើលផ្ទៃនៃប្រាសាទពីរជាន់ និងបន្ទប់

១.០០០ ចុះ ហើយដឹងទីដែលក្រាលដោយខ្លួនឯងចុះ" ។ ស្ត្រីដែលជាសម្លាញ់របស់នាងវិសាខានោះ កាន់សំពត់តម្លៃ ១.០០០ (ដើររកមើល) ក្នុងទីនោះៗ មិនឃើញសំពត់ដែលមានតម្លៃតិចជាងសំពត់របស់ខ្លួននោះឡើយ ក៏ខូចចិត្តថា (យើងមិនបានចំណែកបុណ្យក្នុងប្រាសាទនេះទេ) ក៏បានឈរយំនៅត្រង់កន្លែងមួយ ។ គ្រានោះ ព្រះអានន្ទឃើញស្ត្រីនោះក៏សួរថា "ព្រោះហេតុអ្វីបានជានាងយំ?" នាងក៏ប្រាប់សេចក្តីនោះ ។ ព្រះថេរៈពោលថា "ម្នាលនាងដ៏ចម្រើន នាងកុំព្រួយឡើយ អាត្មានឹងប្រាប់ទីសម្រាប់ក្រាលដល់នាង" ហើយពោលថា "នាងចូរក្រាលត្រង់ជណ្តើរ ធ្វើជាសំពត់ជូតជើងចុះ ភិក្ខុទាំងឡាយលាងជើងហើយ ជូតជើងនឹងសំពត់នោះមុន ទើបចូលទៅខាងក្នុង បើដូច្នោះផលដ៏ចម្រើននឹងមានដល់នាង" ។ បានឮថា ទីនោះ ជាទីដែលនាងវិសាខាមិនបានយកចិត្តទុកដាក់ ។ នាងវិសាខាបានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ខាងក្នុងវិហារអស់ ៤ ខែ ។ ក្នុងថ្ងៃចុងក្រោយ បានប្រគេនសំពត់សាដក ដើម្បីធ្វើចីវរដល់ភិក្ខុសង្ឃ ។ សំពត់សាដកដើម្បីធ្វើចីវរដែលភិក្ខុថ្មីក្នុងសង្ឃបានហើយ មានតម្លៃ ១.០០០ ។ នាងបានប្រគេនភេសជ្ជៈពេញបាត្រដល់ភិក្ខុគ្រប់រូប ។ ព្រោះការបរិច្ចាគទាន ទ្រព្យបាន (អស់ទៅ) ៩ កោដិ ។ នាងវិសាខាបរិច្ចាគទ្រព្យក្នុងព្រះពុទ្ធសាសនាទាំងអស់ ២៧ កោដិ គឺ ក្នុងការទិញដីសម្រាប់កសាងវិហារ ៩ កោដិ ក្នុងការកសាងវិហារ ៩ កោដិ ក្នុងការឆ្លងវិហារ ៩ កោដិ ។

ដែលឈ្មោះថា ការបរិច្ចាគបែបនេះ រមែងមិនមានដល់ស្ត្រីដទៃដែល នៅក្នុងត្រកូលបុគ្គលមិច្ឆាទិដ្ឋិឡើយ ។

នាងវិសាខាបន្លឺឧទានក្នុងថ្ងៃធ្លងវិហារ

ក្នុងថ្ងៃធ្លងវិហារចុងក្រោយ វេលារសៀល នាងវិសាខាដែលមានបុត្រ និងចៅហែហម គិតថា "សេចក្តីប្រាថ្នាណាៗ ដែលយើងតាំងទុកហើយក្នុង កាលមុន សេចក្តីប្រាថ្នានោះៗ ដល់ទីបំផុតហើយ" ទើបដើរប្រទក្សិណប្រាសាទ បន្លឺឧទានដោយសំឡេងដ៏ពីរោះ ៥ គាថា ៖

-សេចក្តីត្រិះរិះរបស់យើងថា កាលណា យើងនឹងថ្វាយប្រាសាទ ថ្មី លាបដោយកំបោ និងដី ជាវិហារទានដូច្នេះ បរិបូណ៌ហើយ ។

-សេចក្តីត្រិះរិះរបស់យើងថា កាលណា យើងនឹងថ្វាយគ្រែ តាំង ពូក និងខ្នើយ ជាសេនាសនភ័ណ្ឌដូច្នេះ បរិបូណ៌ហើយ ។

-សេចក្តីត្រិះរិះរបស់យើងថា កាលណា យើងនឹងថ្វាយសាលា- កកត្ត ផ្សំដោយសាច់ដ៏ល្អ ជាភោជនទានដូច្នេះ បរិបូណ៌ហើយ ។

-សេចក្តីត្រិះរិះរបស់យើងថា កាលណា យើងនឹងថ្វាយសំពត់ កាសិកព័ស្ត្រ សំពត់សំបកឈើ និងសំពត់សំបកធ្មៃ ជាចីវរទាន ដូច្នេះ បរិបូណ៌ហើយ ។

-សេចក្តីត្រិះរិះរបស់យើងថា កាលណា យើងនឹងថ្វាយទឹកដោះ ថ្លា ទឹកដោះខាប់ ទឹកឃ្មុំ ប្រេង និងទឹកអំពៅ ជាភេសជ្ជទានដូច្នេះ

បរិបូណ៌ហើយ ។

ភិក្ខុទាំងឡាយ បានឮសំឡេងរបស់នាង ក៏ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ដែលឈ្មោះថា ការច្រៀងរបស់នាងវិសាខា ពួកខ្ញុំព្រះអង្គមិនធ្លាប់ឮ អស់កាលយូរប្រមាណប៉ុណ្ណោះ ថ្ងៃនេះ នាងដែលមានបុត្រ និងចៅហែហមហើយ ច្រៀងរណ្តើរ ដើរប្រទក្សិណជុំវិញប្រាសាទបណ្តើរ ប្រមាត់របស់នាងកម្រើកឬ? នាងខូចចរិកហើយឬ?" ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធីតារបស់តថាគតមិនច្រៀងទេ" ប៉ុន្តែអធ្យាស្រ័យរបស់នាងពេញប្រៀបហើយ នាងរីករាយថា "សេចក្តីប្រាថ្នា ដែលយើងប្រាថ្នាទុកនោះ ដល់ទីបំផុតហើយ ទើបដើរបន្លឺឧទាន" ។ កាលភិក្ខុទាំងឡាយក្រាបទូលសួរថា "ក៏នាងធ្វើសេចក្តីប្រាថ្នាទុក ក្នុងកាលណា?" ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចង់ស្តាប់ឬ?" កាលភិក្ខុទាំងនោះក្រាបទូលថា "ព្រះករុណា ព្រះអង្គ" ទើបទ្រង់នាំអតីតនិទានមក "ត្រាស់ដូចតទៅនេះ" ៖

## បុព្វប្រវត្តិរបស់នាងវិសាខា

ម្នាលភិក្ខុទាំងឡាយ ក្នុងទីបំផុតមួយសែនកប្បអំពីនេះទៅ ព្រះពុទ្ធព្រះនាមថា **បទុមុត្តរះ** ទ្រង់ឧប្បត្តិឡើងក្នុងលោក ។ ព្រះអង្គមានព្រះជន្មាយុមួយសែនឆ្នាំ មានភិក្ខុខីណាស្រពមួយសែនជាបរិវារ នគរឈ្មោះហង្សវតី ព្រះបិតាជាព្រះរាជានាមថា **សុនន្ទះ** ព្រះមាតាជាព្រះទេវីនាមថា **សុជាតា** ។ ឧបាសិកាដែលជាកំពូលឧបដ្ឋាយិការបស់ព្រះសាស្តាអង្គនោះ ទូលសូមពរ ៨ ប្រការ

ហើយតាំងនៅក្នុងឋានៈដូចមាតា ទំនុកបម្រុងព្រះសាស្តាដោយបច្ច័យ ៤ តែង ទៅកាន់ទីទំនុកបម្រុងទាំងល្ងាចទាំងព្រឹក ។ ស្រ្តីដែលជាសម្លាញ់របស់ឧបាសិកា នោះ តែងទៅកាន់វិហារជាមួយឧបាសិកានោះជានិច្ច ។ ស្រ្តីនោះឃើញឧបាសិកា នោះនិយាយជាមួយព្រះសាស្តាដោយសេចក្តីស្និទ្ធស្នាល និងឃើញភាពជាអ្នក ស្និទ្ធស្នាលនឹងព្រះសាស្តា ទើបគិតថា “នាងធ្វើកម្មអ្វីហ្ន៎ ទើបជាអ្នកស្និទ្ធស្នាល នឹងព្រះពុទ្ធយ៉ាងនេះ” លុះគិតដូច្នេះហើយ ក៏ទូលសួរព្រះសាស្តាថា “បពិត្រ ព្រះអង្គដ៏ចម្រើន ស្រ្តីនេះជាអ្វីនឹងព្រះអង្គ?” ។

ព្រះសាស្តា. ជាឧបដ្ឋាយិកា ជាកំពូលលើសស្រ្តីទាំងឡាយ ។

ស្រ្តី. បពិត្រព្រះអង្គដ៏ចម្រើន នាងធ្វើកម្មអ្វី ទើបប្រសើរជាងស្រ្តី ទាំងឡាយខាងឧបដ្ឋាយិកា?

ព្រះសាស្តា. នាងធ្វើសេចក្តីប្រាថ្នាទុកអស់ ១ សែន កប្ប ។

ស្រ្តី. បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គប្រាថ្នាហើយ អាច នឹងបានទេ?

ព្រះសាស្តា. អាច ។

ស្រ្តីនោះក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន បើដូច្នោះសូមព្រះអង្គ ព្រមទាំងភិក្ខុសង្ឃមួយសែនរូប មេត្តាទទួលភិក្ខាបស់ខ្ញុំព្រះអង្គ ៧ ថ្ងៃចុះ” ។ ព្រះសាស្តាក៏ទ្រង់ទទួលហើយ ។ ស្រ្តីនោះថ្វាយទានគ្រប់ ៧ ថ្ងៃ ក្នុងថ្ងៃចុង ក្រោយ បានប្រគេនសំពត់សាដកដើម្បីធ្វើចីវរ ហើយថ្វាយបង្គំព្រះសាស្តា

ក្រាបចុះទៀបបាទមូល តាំងសេចក្តីប្រាថ្នាថា “បពិត្រព្រះអង្គដ៏ចម្រើន ដោយផលនៃទាននេះ នាងខ្ញុំមិនប្រាថ្នាភាពជាធំក្នុងទេវលោក ជាដើមណាមួយទេ នាងខ្ញុំគប្បីបានពរ ៨ ប្រការ ក្នុងសម្នាក់នៃព្រះពុទ្ធអង្គ ហើយតាំងនៅក្នុងឋានៈដូចជាមាតា ជាកំពូលឧបាសិកាអ្នកអាចទំនុកបម្រុងដោយបច្ច័យ ៤” ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា “សេចក្តីប្រាថ្នារបស់ស្ត្រីនេះ នឹងសម្រេចឬទេ” ទ្រង់នឹកដល់អនាគតកាល ទ្រង់ពិចារណាមើលរហូតមួយសែនកប្ប ទើបត្រាស់ថា ក្នុងទីបំផុតមួយសែនកប្ប ព្រះពុទ្ធព្រះនាមគោតម ទ្រង់ឧប្បត្តិឡើង ក្នុងកាលនោះឯង នឹងបានជាឧបាសិកា **ឈ្មោះវិសាខា** បានពរ ៨ ប្រការ ក្នុងសម្នាក់របស់ព្រះអង្គ ហើយតាំងនៅក្នុងឋានៈជាមាតា នឹងបានជាកំពូលផ្នែកខាងឧបដ្ឋាយិកា ជាអ្នកទំនុកបម្រុងដោយបច្ច័យ ៤” ។ សម្បត្តិនោះ ដូចជានាងបានក្នុងថ្ងៃស្អែក ។

នាងធ្វើបុណ្យរហូតអស់អាយុ ចុតិចាកអត្តភាពនោះហើយ កើតក្នុងទេវលោក ត្រាច់រង្គាត់នៅក្នុងមនុស្ស និងទេវលោក ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ ជាធីតាព្រះនាមថា **សង្ឃទាសី** ដែលជាព្រះកនិដ្ឋានៃធីតាទាំង ៧ ព្រះអង្គ របស់ព្រះបាទដែនកាសី ព្រះនាមថា **កិកិ** នៅមិនទាន់បានទៅកាន់ត្រកូលដទៃ ទ្រង់ធ្វើបុណ្យមានទានជាដើម ជាមួយនឹងម្ចាស់បងទាំងនោះ រហូតអស់កាលយូរ បានធ្វើសេចក្តីប្រាថ្នាទុក ទៀបបាទមូលនៃព្រះសម្ពុទ្ធព្រះនាមកស្សបៈថា “ក្នុងអនាគតកាល សូមឲ្យខ្ញុំព្រះអង្គបានទទួលពរ

៨ ប្រការ ក្នុងសម្នាក់នៃព្រះពុទ្ធដូចព្រះអង្គ ហើយតាំងនៅក្នុងឋានៈដូចជាមាតា ជាកំពូលលើសឧបាសិកាអ្នកថ្វាយបច្ច័យ ៤” ចាប់តាំងពីកាលនោះមក នាង ត្រាច់វង្គាត់ទៅក្នុងមនុស្ស និងទេវលោក ។ ក្នុងអត្តភាពនេះ ជាធីតានៃធន-ញ្ជយសេដ្ឋី ដែលជាបុត្ររបស់មេណ្ឌកសេដ្ឋី ។ បានធ្វើបុណ្យជាច្រើនក្នុង សាសនារបស់តថាគត ។

## សត្វកើតមកហើយគួរតែធ្វើបុណ្យឱ្យច្រើន

ព្រះសាស្តា (លុះទ្រង់សម្តែងអតីតនិទានចប់ហើយ) ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ធីតារបស់តថាគត រមែងមិនច្រៀង ដោយប្រការដូច្នេះ ឯង តែនាងឃើញការសម្រេចនៃសេចក្តីប្រាថ្នាដែលតាំងទុកហើយ ទើបបន្លឺ ឧទាន” ។ កាលនឹងទ្រង់សម្តែងធម៌ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ នាយមាលាការដែលជាអ្នកឈ្លាស ធ្វើគំនរផ្កាផ្សេងៗ ឲ្យជាគំនរធំហើយ រមែង ធ្វើកម្រងផ្កាមានប្រការផ្សេងៗ បាន យ៉ាងណា ចិត្តរបស់នាងវិសាខា រមែង បង្អោនទៅដើម្បីកុសលមានប្រការផ្សេងៗ ដូច្នោះដូចគ្នា” ដូច្នេះ ហើយទ្រង់ ត្រាស់ព្រះគាថានេះថា ៖

យថាបិ បុប្ផរាសិម្ហា កយិរា មាលាគុណេ ពហូ
ឯវំ ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ ។

មាលាការ ចេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរនៃផ្កា
(ផ្សេងៗ គ្នា) ឲ្យច្រើនបាន យ៉ាងណាមិញ កុសល

ដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **បុប្ផរាសិម្ហា (ចាកគំនរផ្កា)** បានដល់ អំពីគំនរនៃផ្កាមានប្រការផ្សេងៗ ។ បទថា **កយិរា** ប្រែថា គប្បីធ្វើ ។ បទថា **មាលាគុណេ ពហូ (កម្រងផ្កាឲ្យច្រើន)** សេចក្ដីថា នូវសំណុំនៃកម្រងផ្កាច្រើនប្រភេទ ដែលផ្សេងដោយប្រភេទ មានផ្កាដែលក្រងដោយទងតែម្ខាងជាដើម ។ បទថា **មច្ចេន (ជននឹងគប្បីស្លាប់ជាសភាវៈ)** សេចក្ដីថា សត្វដែលបានឈ្មោះថា **មច្ចៈ** ព្រោះជាអ្នកមានសេចក្ដីស្លាប់ជាធម្មតា គួរធ្វើកុសលដោយកុសលមានការថ្វាយចីវរជាដើមទុកឲ្យច្រើន ។ ស័ព្ទ គឺ **បុប្ផរាសិ (គំនរផ្កា)** ក្នុងព្រះគាថានោះ សំដៅយកផ្កាច្រើនជាអត្ថ ។

ក៏បើផ្កាមានតិច នាយមាលាការអ្នកឈ្លាស ក៏មិនអាចធ្វើសំណុំនៃកម្រងផ្កាឲ្យច្រើនបាន ចំណែកនាយមាលាការដែលជាអ្នកមិនឈ្លាស កាលផ្កាមានតិចក្ដី ច្រើនក្ដី រមែងមិនអាចដោយពិត ។ តែកាលផ្កាមានច្រើន នាយមាលាការដែលជាអ្នកឈ្លាស រមែងព្យាយាម ចាត់ចែង ធ្វើសំណុំនៃកម្រងផ្កាឲ្យច្រើនបាន យ៉ាងណា បើសទ្ធារបស់បុគ្គលខ្លះមានតិច ចំណែកភោគៈមានច្រើន បុគ្គលនោះរមែងមិនអាចធ្វើកុសលឲ្យច្រើនបាន ឯកាលសទ្ធាក៏មានតិច ទាំងភោគៈក៏មានតិច គេក៏រមែងមិនអាច ។ កាលសទ្ធាមានច្រើន តែភោគៈតិច គេក៏រមែងមិនអាចដូចគ្នាដែរ ។ តែកាលមានសទ្ធាច្រើន ហើយភោគៈក៏

មានច្រើន គេរមែងអាចធ្វើបុណ្យកុសលឲ្យច្រើនបាន ដូច្នោះ ។ នាងវិសាខាឧបាសិកាជាមនុស្សដូច្នោះ ព្រះសាស្តាទ្រង់សំដៅយកនាងវិសាខានោះ ទើបទ្រង់ត្រាស់ពាក្យជាគាថាដូច្នេះថា ៖

នាយមាលាការ បេះធ្វើសំណុំនៃកម្រងផ្កា អំពីគំនរផ្កា
(ផ្សេងគ្នា) ឲ្យច្រើនបាន យ៉ាងណា សត្វជាអ្នកមានការ
ស្លាប់ជាធម្មតា គួរធ្វើបុណ្យទុកឲ្យបានច្រើន ដូច្នោះ ។

ក្នុងវេលាចប់ទេសនា ជនដ៏ច្រើនបានជាអរិយបុគ្គល មានសោតាបន្នបុគ្គលជាដើម ធម្មទេសនាបានជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះឯង ។

ចប់ រឿងនាងវិសាខា ទី ៨

# ៩. រឿងបញ្ហារបស់ព្រះអានន្ទត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី កាលនឹងទ្រង់ឆ្លើយបញ្ហារបស់ព្រះអានន្ទត្ថេរ ត្រាស់ធម្មទេសនានេះថា **ន បុប្ផគន្ធោ បដិវាតមេតិ (ក្លិនផ្កាផ្សាយទៅបញ្ច្រាសខ្យល់មិនបាន)** ជាដើម ។*

## ព្រះអានន្ទទូលសួរបញ្ហា

*បានស្តាប់មកថា ព្រះថេរៈចេញអំពីទីពួនសម្ងំ ក្នុងវេលារសៀល គិតថា "ព្រះមានព្រះភាគត្រាស់ក្លិនខ្ពស់បំផុតទុក ៣ យ៉ាង គឺ ក្លិនកើតអំពីឫស ក្លិនកើតអំពីខ្លឹម ក្លិនកើតអំពីផ្កា ។ ក្លិននៃគន្ធជាតិទាំងនោះ ផ្សាយទៅបានតាមបណ្តោយខ្យល់ប៉ុណ្ណោះ ទៅច្រាសខ្យល់មិនបានឡើយ ក្លិននៃគន្ធជាតិណាផ្សាយទៅបានសូម្បីច្រាសខ្យល់ គន្ធជាតិនោះ មានដែរឬហ្ន៎" គ្រានោះ ព្រះអានន្ទមានការគិតដូច្នេះថា "ប្រយោជន៍អ្វីចំពោះយើង ក្នុងបញ្ហាដែលវិនិច្ឆ័យដោយខ្លួនឯងនោះ យើងនឹងទូលសួរព្រះសាស្តា (ល្អជាង)" លោកចូលទៅគាល់ព្រះសាស្តាហើយទូលសួរ ។ ព្រោះហេតុនោះ ទើបព្រះធម្មសង្គាហកាចារ្យពោលទុកថា "គ្រានោះឯង ព្រះអានន្ទចេញអំពីទីពួនសម្ងំ ក្នុងវេលារសៀល ចូលទៅគាល់ព្រះមានព្រះភាគដល់ទីប្រថាប់ លុះចូលទៅដល់ហើយ បានក្រាបទូលពាក្យនេះនឹងព្រះមានព្រះភាគថា "បពិត្រព្រះមានព្រះភាគ ក្លិននៃគន្ធជាតិណា ផ្សាយទៅតាមខ្យល់តែម្យ៉ាង ផ្សាយទៅច្រាសខ្យល់មិនបាន គន្ធជាតិ*

នោះមាន ៣ យ៉ាង ។ គន្ធជាតិ ៣ យ៉ាង តើអ្វីខ្លះ? បពិត្រព្រះអង្គដ៏ចម្រើន ក្លិននៃគន្ធជាតិណា ផ្សាយទៅតាមខ្យល់តែម្យ៉ាង ផ្សាយទៅច្រាសខ្យល់មិនបាន គន្ធជាតិ ៣ យ៉ាងនោះ គឺ ក្លិនកើតអំពីឫស ក្លិនកើតអំពីខ្លឹម ក្លិនកើតអំពីផ្កា ។ បពិត្រព្រះអង្គដ៏ចម្រើន ក្លិននៃគន្ធជាតិណាផ្សាយទៅតាមខ្យល់ក៏បាន ក្លិននៃគន្ធជាតិណាផ្សាយទៅច្រាសខ្យល់ក៏បាន ក្លិននៃគន្ធជាតិណាដែលផ្សាយទៅតាមខ្យល់ និងច្រាសខ្យល់ក៏បាន គន្ធជាតិទាំងនោះ មានដែរឬទេព្រះអង្គ ។

## ព្រះសាស្តាទ្រង់ឆ្លើយបញ្ហា

គ្រានោះ ព្រះមានព្រះភាគ កាលនឹងទ្រង់ឆ្លើយបញ្ហាតបព្រះអានន្ទ ក៏ត្រាស់ថា "ម្នាលអានន្ទ ក្លិននៃគន្ធជាតិណា ផ្សាយទៅបណ្តោយខ្យល់ក៏បាន ក្លិននៃគន្ធជាតិណា ផ្សាយទៅច្រាសខ្យល់ក៏បាន ក្លិននៃគន្ធជាតិណាផ្សាយទៅតាមខ្យល់ និងច្រាសក៏បាន ក្លិននៃគន្ធជាតិទាំងនោះ មានដែរ" ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ក្លិននៃគន្ធជាតិណា ផ្សាយទៅតាមខ្យល់ក៏បាន ក្លិននៃគន្ធជាតិណាផ្សាយទៅច្រាសខ្យល់ក៏បាន ក្លិននៃគន្ធជាតិណាផ្សាយទៅតាមខ្យល់ និងច្រាសខ្យល់ក៏បាន គន្ធជាតិនោះតើដូចម្តេច ?

ព្រះសាស្តាទ្រង់ត្រាស់ថា "ម្នាលអានន្ទ ស្ត្រីក៏ដោយ បុរសក៏ដោយ ក្នុងស្រុក ឬក្នុងនិគម ក្នុងលោកនេះ ជាអ្នកដល់ព្រះពុទ្ធជាទីពឹង ជាអ្នកដល់ព្រះធម៌ជាទីពឹង ជាអ្នកដល់ព្រះសង្ឃជាទីពឹង ហើយជាអ្នកវៀរចាកការសម្លាប់

វៀរចាកការកាន់យកទ្រព្យដែលគេមិនបានឲ្យ វៀរចាកការប្រព្រឹត្តខុសក្នុងកាម វៀរចាកការពោលពាក្យកុហក វៀរចាកឋានៈដែលជាទីតាំងនៃសេចក្តីប្រមាទ គឺ ការផឹកទឹកស្រវឹង បានដល់ សុរា និងមេរ័យ ជាអ្នកមានសីល មានកល្យាណធម៌ មានចិត្តមានសេចក្តីកំណាញ់ជាមន្ទិលទៅប្រាសហើយ មានគ្រឿងបរិច្ចាគដែលលះបង់ហើយ មានបាតដៃដែលលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ការសូម ត្រេកអរក្នុងការចែកទាន រមែងនៅគ្រប់គ្រងផ្ទះ សមណៈ និងព្រាហ្មណ៍ក្នុងទិសទាំងឡាយ រមែងពោល (សរសើរ) កិត្តិគុណរបស់បុរស ឬស្ត្រីនោះថា (បុរស ឬស្ត្រីក្នុងនិគមឯណោះ ជាអ្នកដល់ព្រះពុទ្ធជាទីពឹង ។ល។ ត្រេកអរក្នុងការចែកទាន សូម្បីទេវតាទាំងឡាយ ក៏រមែងពោល (សរសើរ) កិត្តិគុណរបស់បុរស ឬស្ត្រីនោះថា បុរស ឬស្ត្រីក្នុងស្រុក ឬនិគមឯណោះ ជាអ្នកដល់ព្រះពុទ្ធជាទីពឹង ។ល។ ត្រេកអរក្នុងការចែកទាន ម្នាលអានន្ទ នេះឯងជាគុណជាត មានក្លិនផ្សាយទៅតាមខ្យល់ក៏បាន មានក្លិនផ្សាយទៅប្រាសខ្យល់ក៏បាន មានក្លិនផ្សាយទៅតាមខ្យល់ និងប្រាសខ្យល់ក៏បាន” ដូច្នេះ ទើបបានទ្រង់ភាសិតព្រះគាថាទាំងនេះថា ៖

ន បុប្ផគន្ធោ បដិវាតមេតិ
ន ចន្ទនំ តគរមល្លិកា វា
សតញ្ច គន្ធោ បដិវាតមេតិ
សព្វា ទិសា សប្បុរិសោ បវាយតិ ។

*ចន្ទនំ តគរំ វាបិ ឧប្បលំ អថ វស្សិកី*
*ឯតេសំ គន្ធជាតានំ សីលគន្ធោ អនុត្តរោ ។*

*ក្លិនផ្កាឈើ ផ្សាយទៅច្រាសខ្យល់ មិនបាន ក្លិនខ្លឹមចន្ទន៍ក្តី ក្លិនខ្លឹមក្រស្នាក្តី ក្លិនផ្កាម្លិះរួតក្តី ក៏ផ្សាយទៅច្រាសខ្យល់ មិនបាន ចំណែកក្លិនរបស់សប្បុរសទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ព្រោះសប្បុរស រមែងផ្សាយទៅបាន គ្រប់ទិស ។ ក្លិននៃសីល ជាគុណជាតប្រសើរបំផុត ជាង គន្ធជាតិទាំងនេះ គឺ ខ្លឹមចន្ទន៍ ខ្លឹមក្រស្នា ផ្កាឧប្បល ផ្កាម្លិះលា ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា ន បុប្ផគន្ធោ (ក្លិនផ្កាឈើ... មិនបាន) សេចក្តីថា ដើមបារិច្ឆត្រក្នុងតាវត្តិង្សព្រិកព មានបណ្តោយ និងទទឹងប្រមាណ ១០០ យោជន៍ រស្មីនៃដើមបារិច្ឆត្រនោះផ្សាយចេញទៅបានរហូត ៥០ យោជន៍ ក្លិនផ្សាយទៅបាន ១០០ យោជន៍ សូម្បីក្លិននោះ ក៏ផ្សាយទៅបានបណ្តោយខ្យល់ប៉ុណ្ណោះ មិនអាចផ្សាយទៅច្រាសខ្យល់បាន សូម្បី (ត្រឹម) កន្លះអង្គុលី ។ ក្លិនផ្កាឈើ សូម្បីបែបនេះ ផ្សាយទៅច្រាសខ្យល់មិនបាន ។ ដោយគន្ធជាតទាំងនេះ គឺ ក្រស្នា និងក្លាំពាក់ ក៏បំណាងយកដោយក្លិនដូចគ្នា ។ ពិតហើយ ក្លិនចន្ទន៍ក្រហមក្តី របស់ក្រស្នា និងក្លាំពាក់ក្តី ដែលជាកំពូលនៃក្លិនកើតពី*

ខ្ទឹមទាំងឡាយ រមែងផ្សាយទៅបណ្តាយខ្យល់ប៉ុណ្ណោះ ផ្សាយបញ្ច្រាសខ្យល់មិនបាន ។ បទថា **សតញ្ច គន្ធោ (តែក្លិនសប្បុរស)** សេចក្តីថា ចំណែកក្លិនសីលរបស់សប្បុរស គឺ របស់ព្រះពុទ្ធជាម្ចាស់ និងព្រះសាវកទាំងឡាយ រមែងផ្សាយទៅច្រាសខ្យល់បាន ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសប្បុរស រមែងផ្សាយទៅគ្រប់ទិសទី ។ អធិប្បាយថា ព្រោះសប្បុរស រមែងផ្សាយទៅគ្របដណ្តប់គ្រប់ទិស ដោយក្លិនសីល ដូច្នោះ សប្បុរសដែលបណ្ឌិតគួរពោលបានថា "ក្លិនរបស់លោកផ្សាយទៅច្រាសខ្យល់បាន" ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **បវាតិ (ផ្សាយទៅច្រាសខ្យល់)** ។ បទថា **វស្សិកី (ក្លិនផ្កាម្លិះ)** បានដល់ ផ្កាម្លិះ ។

បទថា **ឯតេសំ (ទាំងនោះ)** ជាដើម សេចក្តីថា ក្លិនសីលរបស់សប្បុរសអ្នកមានសីលនោះឯង ជាក្លិនដ៏ប្រសើរបំផុតជាងក្លិននៃគន្ធជាតិ មានក្លិនចន្ទន៍ក្រហមជាដើម គឺ រកក្លិនដែលដូចមិនមាន បានដល់ មិនមានចំណែកប្រៀប ។

ក្នុងកាលចប់ធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ទេសនាមានប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងបញ្ហារបស់ព្រះអានន្ទ ទី ៩

# ១០. រឿងការប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបៈ

*ព្រះសាស្តា កាលទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***អប្បមត្តោ អយំ គន្ធោ (ក្លិននេះ ត្រឹមតែជាក្លិនតិចតួច)*** *ជាដើម ។*

## ទេពធីតាចង់ធ្វើបុណ្យតែមិនបានដូចបំណង

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈចេញអំពីនិរោធសមាបត្តិ ហើយរំពឹងថា "នឹងត្រាច់បិណ្ឌបាតតាមលំដាប់ប្រកក្នុងក្រុងរាជគ្រឹះ" ។ ក្នុងសម័យនោះ ទេពធីតាប្រមាណ ៥០០ មានជើងដូចជាជើងព្រាប ជាបរិចារិកាបស់សក្កទេវរាជ កើតសេចក្តីប្រាថ្នាថា "នឹងប្រគេនបិណ្ឌបាតព្រះថេរៈ" ទើបបានត្រៀមបិណ្ឌបាត ៥០០ សម្រាប់ យកទៅឈរក្នុងចន្លោះផ្លូវ ហើយពោលថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទទួល បិណ្ឌបាតនេះដោយអនុគ្រោះផងចុះ" ។*

*ព្រះថេរៈ. ពួកនាងឯងចូរចៀសចេញទៅ អាត្មានឹងធ្វើសេចក្តីអនុគ្រោះចំពោះមនុស្សកម្សត់ ។*

*នាងទេព. សូមលោកម្ចាស់ កុំឲ្យពួកនាងខ្ញុំវិនាសឡើយ សូមមេត្តាធ្វើសេចក្តីអនុគ្រោះដល់ពួកនាងខ្ញុំផងចុះ ។*

*ព្រះថេរៈដឹងហើយ ទើបពោលហាមទៀត ហើយផ្ទាត់ម្រាមដៃ (ប្រាប់)*

នាងទេពធីតាទាំងនោះ ដែលមិនបំណងនឹងចេញទៅថា "ពួកនាងមិនស្គាល់ប្រមាណខ្លួន ចូរចៀសចេញទៅ" ។ នាងទេពធីតាទាំងនោះ ស្តាប់សំឡេងផ្ទាត់ម្រាមដៃរបស់ព្រះថេរៈហើយ មិនអាចឈររឹងទទឹងបាន ទើបចៀសចេញទៅកាន់ទេវលោកវិញ ដែលសក្កទេវរាជត្រាស់សួរថា "ពួកនាងមកពីណា" ក៏ទូលថា "នាងខ្ញុំម្ចាស់ទាំងឡាយនាំគ្នាទៅដោយបំណងថា នឹងប្រគេនបិណ្ឌ-បាតចំពោះលោកម្ចាស់មហាកស្សបៈ ដែលទើបតែចេញអំពីសមាបត្តិ ។

សក្ក. ពួកនាងបានប្រគេនហើយឬ ?

នាងទេពធីតា. ព្រះថេរៈមិនព្រមទទួល ។

សក្ក. ព្រះថេរៈនិយាយដូចម្តេច ?

នាងទេពធីតា. បពិត្រមហារាជ (លោកនិយាយថា នឹងធ្វើសេចក្តីអនុគ្រោះដល់មនុស្សកំសត់) ។

សក្ក. ពួកនាងទៅដោយអាការដូចម្តេច ?

នាងទេពធីតា. បពិត្រមហារាជ ទៅដោយអាការដូច្នេះឯង ។

### សក្កទេវរាជក្លែងខ្លួនធ្វើបុណ្យដល់ព្រះថេរៈ

សក្កទេវរាជត្រាស់ថា "ស្ត្រីដូចជាពួកនាង នឹងប្រគេនបិណ្ឌបាតចំពោះព្រះថេរៈបានដោយវិធីណាទៅ" ប្រាថ្នានឹងទៅប្រគេនដោយព្រះអង្គឯង ទើបក្លែងធ្វើជាមនុស្សចាស់ ទុរន់ទុរាដោយអំណាចជរា មានធ្មេញបាក់ សក់ស្កូវខ្នងកោង ជាជាងតម្បាញចាស់ម្នាក់ ចំណែកនាងសុជាតា ដែលជាទេពធីតា

ក៏ឲ្យធ្វើជាស្រ្ដីចាស់ដូចគ្នា ហើយទ្រង់និម្មិតផ្ទះល់ជាងតម្បាញមួយខ្សែ ប្រថាប់ឈរត្បាញនូវតម្បាញ ។ ចំណែកព្រះថេរៈ និមន្តបែរមុខចូលក្រុង ដោយសង្ឃឹមថា "នឹងធ្វើសេចក្ដីអនុគ្រោះដល់ពពួកមនុស្សកម្សត់" ឃើញផ្ទះល់ក្រៅក្រុងនោះឯង ក្រឡេកមើលក៏បានឃើញមនុស្សពីរនាក់ ។ ក្នុងខណៈនោះ សក្កទេវរាជកំពុងត្បាញនូវតម្បាញ នាងសុជាតាខាវនូវអម្បោះ ។ ព្រះថេរៈគិតថា ពីរនាក់នេះសូម្បីចាស់ហើយ ក៏នៅធ្វើកិច្ចការងារទៀត នៅក្នុងក្រុងនេះ អ្នកដែលក្រខ្សត់ជាងមនុស្សពីរនាក់នេះ ប្រហែលជាមិនមាន យើងនឹងទទួលកត្តសូម្បីប្រមាណ ១ វែក ដែលអ្នកទាំងពីរនេះប្រគេន ដើម្បីអនុគ្រោះមនុស្សពីរនាក់នេះ ព្រះថេរៈបានបែរមុខតម្រង់ទៅផ្ទះរបស់អ្នកទាំងពីរនោះ ។

សក្កទេវរាជទតឃើញព្រះថេរៈមក ទើបត្រាស់ជាមួយនាងសុជាតាថា "ម្នាលនាង លោកម្ចាស់ដ៏ចម្រើនរបស់យើងនិមន្តមកតាមផ្លូវនេះហើយ នាងចូរអង្គុយធ្វើដូចជាមិនឃើញចុះ ខ្ញុំនឹងកុហកលោកបន្តិច ហើយទើបប្រគេនបិណ្ឌបាត ។ ព្រះថេរៈបានមកឈរនៅឃ្នឹងទ្វារផ្ទះ ចំណែកពីរនាក់ប្ដីប្រពន្ធនោះ ក៏ធ្វើដូចជាមិនឃើញ ខំប្រឹងធ្វើតែការងាររបស់ខ្លួនប៉ុណ្ណោះ ។ គ្រានោះសក្កទេវរាជត្រាស់ថា "នៅឃ្នឹងទ្វារផ្ទះរបស់យើង ដូចមានព្រះថេរៈ ឈរនៅមួយរូប នាងចូរទៅមើលមើល៍" ។ នាងសុជាតាឆ្លើយថា "សូមលោកទៅមើលចុះ" សក្កទេវរាជចេញអំពីផ្ទះហើយ ទ្រង់ថ្វាយបង្គំព្រះថេរៈដោយបញ្ចង្គប្រតិស្ឋាន យកព្រះហស្តទាំងពីរច្រត់ព្រះជនុ ហើយដកដង្ហើមធំៗ ស្ដេចក្រោក

ឡើង បន្ទន់ព្រះអង្គចុះបន្តិច ត្រាស់ថា "លោកម្ចាស់ដ៏ចម្រើន ជាព្រះថេរៈរូបណាហ្ន៎" ហើយត្រាស់ថា "ក្អែករបស់ខ្ញុំស្រវាំងហើយ" ដូច្នេះ ហើយទ្រង់ដាក់ព្រះហស្តលើព្រះនលាដ (ថ្ងាស) ទ្រង់ងើយមើល ហើយត្រាស់ថា "ឱ ស្លាប់ហើយ លោកម្ចាស់កស្សបៈរបស់យើងទេតើ យូរៗ ទើបបានមកកាន់ខ្ទមរបស់យើងម្តង" មានអ្វីក្នុងផ្ទះខ្លះទេ? ឯនាងសុជាតា ធ្វើដូចជាប្រញាប់ប្រញាល់បន្តិច ទើបបានឆ្លើយថា "មាន" សក្កទេវរាជត្រាស់ថា លោកម្ចាស់ដ៏ចម្រើន សូមលោកកុំគិតឡើយថា ទានសៅហ្មង ឬប្រណីត មេត្តាធ្វើនូវសេចក្តីអនុគ្រោះដល់ពួកខ្ញុំទាំងពីរចុះ លុះពោលដូច្នេះហើយ ក៏ទ្រង់ទទួលបាត្រអំពីព្រះហស្តរបស់ព្រះថេរៈ ។ ព្រះថេរៈគិតថា "ទានដែលស្វាមីករិយានោះប្រគេនហើយ ទោះបីជាទឹកជ្រក់ ឬកន្ទក់មួយក្តាប់ក៏ដោយ យើងនឹងធ្វើសេចក្តីអនុគ្រោះដល់ជនពីរនាក់ប្តីប្រពន្ធនេះ" ដូច្នេះហើយ ទើបបានឲ្យបាត្រទៅ ។ សក្កទេវរាជស្តេចចូលទៅខាងក្នុងផ្ទះហើយ ទ្រង់ដួសបាយចេញអំពីឆ្នាំងដាក់ពេញបាត្រ បង្អោនមកប្រគេនព្រះថេរៈ បិណ្ឌបាតនោះ មានស្លបព្យញ្ជនៈដ៏ច្រើនសន្ធឹកសន្ធាប់ មានក្លិនក្រអូបផ្សាយទូទៅពេញក្រុងរាជគ្រឹះ ។

## សក្កទេវរាជច្រាប់ការពិតដល់ព្រះថេរៈ

ក្នុងកាលនោះ ព្រះថេរៈគិតថា "បុរសនេះមានសក្តិតូច តែបិណ្ឌបាតមានសក្តិធំ ដូចភោជនរបស់សក្កទេវរាជ តើគេជានរណាហ្ន៎" គ្រានោះ ព្រះថេរៈដឹងថា បុរសនោះជា "សក្កទេវរាជ" ទើបពោលថា ព្រះអង្គទ្រង់ដណ្តើម

សម្បត្តិរបស់មនុស្សក្រខ្សត់ “រាប់ថា” ធ្វើកម្មផ្ទូនហើយ នរណាៗ ក៏ដោយ ដែលជាអ្នកក្រខ្សត់ ថ្វាយទានដល់អាត្មាក្នុងថ្ងៃនេះ រមែងបាននូវតំណែងជាសេនាបតី ឬតំណែងសេដ្ឋី ។

សក្កទេវ. បពិត្រលោកម្ចាស់ដ៏ចម្រើន អ្នកដែលក្រជាងខ្ញុំម្ចាស់មិនមានឡើយ ។

ព្រះថេរៈ. មហារាជ ព្រះអង្គសោយសិរីសម្បត្តិក្នុងទេវលោក ហេតុដូចម្ដេច ព្រះអង្គពោលថា ព្រះអង្គជាមនុស្សក្រខ្សត់ទៅវិញ ?

សក្កទេវ. លោកម្ចាស់ដ៏ចម្រើន ដូចដែលលោកម្ចាស់មានថេរវាចាក៏ត្រូវ តែកាលព្រះពុទ្ធទ្រង់មិនទាន់ឧប្បត្តិឡើងក្នុងលោក ខ្ញុំបានធ្វើកល្យាណ-កម្មទុក កាលពុទ្ធុប្បាទនៅប្រព្រឹត្តទៅ ទេវបុត្រដែលមានសក្តិស្មើគ្នា ៣ អង្គ គឺ ចូឡរថទេវបុត្រ មហារថទេវបុត្រ អនេកវណ្ណទេវបុត្រ ធ្វើកល្យាណកម្មហើយ បានកើតក្នុងទីជិតខ្ញុំម្ចាស់ មានតេជះច្រើនជាងខ្ញុំម្ចាស់ ក៏ខ្ញុំម្ចាស់កាលទេវបុត្រទាំង ៣ អង្គនោះ នាំពួកបរិចារិកាចុះកាន់ថ្នល់ ដោយគិតថា នឹងលេងនក្ខត្តឫក្ស ត្រូវចៀសចូលដំណាក់ ព្រោះតេជះអំពីសរីរៈរបស់ទេវបុត្រទាំង ៣ អង្គនោះ គ្របដណ្ដប់សរីរៈរបស់ខ្ញុំម្ចាស់ តេជះផ្សាយចេញអំពីសរីរៈរបស់ខ្ញុំម្ចាស់ មិនគ្របដណ្ដប់សរីរៈរបស់ទេវបុត្រទាំង ៣ អង្គនោះទេ លោកម្ចាស់ដ៏ចម្រើន តើមាននរណាក្រជាងខ្ញុំម្ចាស់ទៀត ។

ព្រះថេរៈ. ណ្ហើយចុះមហារាជ អាត្មាភាពមិនថាអីទេ ប៉ុន្តែចាប់ពីពេល

នេះតទៅ ចូរមហារាជកុំកុហកអាត្មាភាព ដើម្បីបានឱកាសថ្វាយទានយ៉ាងនេះ ទៀត ។

សក្កទេវ. កាលខ្ញុំកុហក បានថ្វាយទានដល់លោកម្ចាស់ តើកុសលនឹង មានដល់ខ្ញុំ ឬក៏មិនមានទេ ?

ព្រះថេរៈ. មាន ព្រះអង្គ ។

សក្កទេវ. បើដូច្នោះ ការធ្វើកុសលកម្ម ក៏ចាត់ជានាទីរបស់ខ្ញុំម្ចាស់ដែរ លោកម្ចាស់ ។

សក្កទេវរាជត្រាស់យ៉ាងនោះហើយ ទ្រង់ថ្វាយបង្គំព្រះថេរៈ នាំនាង សុជាតាធ្វើប្រទក្សិណព្រះថេរៈហើយ ក៏ហោះឡើងទៅកាន់វេហាស៍ ទ្រង់បន្លឺ ឧទានថា ៖

ឱហ្ន៎! ទាន ដែលជាទានដ៏កំពូល យើងបានតម្កល់
ទុកល្អហើយក្នុង ព្រះមហាកស្សបៈ” ។

មហាកស្សបត្ថេរទានវត្ថុ

ព្រោះហេតុនោះ ព្រះធម្មសង្គាហកាចារ្យ ទើបពោលថា សម័យមួយ ព្រះមានព្រះភាគ ទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិត ក្រុងរាជគ្រឹះ ។ សម័យនោះឯង ព្រះមហាកស្សបៈដ៏មានអាយុ នៅក្នុងបិប្ផ-លិគុហា អង្គុយដោយភ្នែនតែមួយចូលសមាធិ* ណា អស់ ៧ ថ្ងៃ ។ លុះកន្លង

---

* សំដៅយកអរហត្តផលសមាធិ ។

៧ ថ្ងៃនោះហើយ ព្រះមហាកស្សបៈដ៏មានអាយុ ក៏ចេញអំពីសមាបត្តិនោះ ។ កាលបើមហាកស្សបៈដ៏មានអាយុចេញអំពីសមាបត្តិនោះហើយ មានសេចក្តីត្រិះរិះយ៉ាងនេះថា បើដូច្នោះ គួរតែអាត្មាអញចូលទៅបិណ្ឌបាតឯក្រុងរាជគ្រឹះចុះ ។ សម័យនោះឯង ពួកទេវតាចំនួន ៥០០ អង្គ ដល់នូវការខ្វល់ខ្វាយដើម្បីប្រគេនបិណ្ឌបាតដល់ព្រះមហាកស្សបៈដ៏មានអាយុ ។ លំដាប់នោះ ព្រះមហាកស្សបៈដ៏មានអាយុ ហាមឃាត់ទេវតាទាំង ៥០០ អង្គនោះ ហើយស្លៀកដណ្តប់ចីវរក្នុងបុព្វណ្ហសម័យ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ។

សម័យនោះឯង សក្កៈជាធំជាងពួកទេវតា មានបំណងដើម្បីប្រគេនបិណ្ឌបាតចំពោះព្រះមហាកស្សបៈដ៏មានអាយុ បាននិម្មិតខ្លួនជាជាងតម្បាញកំពុងត្បាញនូវតម្បាញ ។ ឯអសុរកញ្ញាឈ្មោះសុជាតា ក៏ខារអេម្បោះឲ្យពេញខ្នារ ។ គ្រានោះ ព្រះមហាកស្សបៈដ៏មានអាយុ កំពុងត្រាច់បិណ្ឌបាតសព្វប្រកក្នុងក្រុងរាជគ្រឹះ បានចូលទៅកាន់លំនៅរបស់ទេវរាជឈ្មោះ សក្កៈជាធំជាងពពួកទេវតា ។ សក្កៈជាធំជាងពួកទេវតា បានឃើញព្រះមហាកស្សបៈដ៏មានអាយុកំពុងតែបិណ្ឌបាតមកពីចម្ងាយ លុះបានឃើញហើយ ក៏ចេញអំពីផ្ទះទៅទទួលយកបាត្រអំពីព្រះហស្ត ចូលទៅកាន់ផ្ទះ ដួសបាយអំពីឆ្នាំងដាក់ឲ្យពេញបាត្រ រួចប្រគេនព្រះមហាកស្សបៈដ៏មានអាយុ ។ បិណ្ឌបាតនោះមានសម្លច្រើនមុខ ។ លំដាប់នោះ ព្រះមហាកស្សបៈដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា សត្វនេះជាអ្វីហ្ន៎ បានជាមានឥទ្ធានុភាពមានសភាពយ៉ាងនេះ ។

លំដាប់នោះ ព្រះមហាកស្សបៈដ៏មានអាយុ មានសេចក្ដីត្រិះរិះដូច្នេះទៀតថា ឱហ្ន៎ សក្កៈជាធំជាងពពួកទេវតាទេតើ ។ ព្រះមហាកស្សបៈដ៏មានអាយុ បានដឹងច្បាស់ដូច្នេះហើយ និយាយនឹងសក្កៈជាធំជាងពួកទេវតាថា បពិត្រកោសិយៈ ព្រះអង្គបានធ្វើអំពើនេះហើយ ក្រោយទៅព្រះអង្គ កុំធ្វើអំពើយ៉ាងនេះទៀត ។ សក្កទេវរាជត្រាស់ថា "ព្រះមហាកស្សបៈដ៏ចម្រើន សូម្បីពួកខ្ញុំក៏ត្រូវការបុណ្យ សូម្បីពួកខ្ញុំក៏គួរធ្វើបុណ្យ" ។ លំដាប់នោះ សក្កៈជាធំជាងពួកទេវតាថ្វាយបង្គំព្រះមហាកស្សបៈដ៏មានអាយុ រួចធ្វើប្រទក្សិណ ហើយហោះទៅកាន់ពួដ៏អាកាស បន្លឺនូវឧទានក្នុងអាកាសជាទីវាល អស់វារៈ ៣ ដងថា ៖

ឱ! ទានដែលជាទានដ៏ឧត្ដម យើងបានតម្កល់ទុកល្អហើយ ក្នុងព្រះមហាកស្សបៈ ឱ! ទានដែលជាទានដ៏ឧត្ដម យើងបានតម្កល់ទុកល្អហើយក្នុងព្រះមហាកស្សបៈ ឱ! ទានដែលជាទានដ៏ឧត្ដម យើងបានតម្កល់ទុកល្អហើយក្នុងព្រះមហាកស្សបៈ ។

ព្រះមានព្រះភាគ ប្រថាប់ឈរនៅឯវិហារនោះឯង ទ្រង់បានឮសំឡេងរបស់សក្កទេវរាជនោះ ទើបត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរមើលសក្កៈជាធំជាងទេវតា ទ្រង់បន្លឺឧទានស្ដេចទៅតាមផ្លូវអាកាស" ។

ភិក្ខុ. ក៏ស្ដេចសក្កៈនោះ ធ្វើអ្វីព្រះអង្គ ?

ព្រះសាស្តា. ស្តេចសក្កៈកុហក ថ្វាយបិណ្ឌបាតដល់កស្សបៈជាបុត្ររបស់តថាគត លុះថ្វាយបិណ្ឌបាតនោះហើយ សប្បាយព្រះទ័យ ទ្រង់បានបន្លឺឧទាន ។

ភិក្ខុ. ស្តេចទេវរាជជ្រាបយ៉ាងណាថា "គួរថ្វាយបិណ្ឌបាតដល់ព្រះថេរៈព្រះអង្គ ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ទាំងពួកទេវតា ទាំងពួកមនុស្ស រមែងពេញចិត្តក្នុងភិក្ខុអ្នកបិណ្ឌបាតជាវត្ត ដូចជាបុត្ររបស់តថាគត" ដូច្នេះ សូម្បីស្តេចទេវរាជអង្គឯងក៏ទ្រង់បន្លឺនូវឧទានហើយ ។

ក៏ក្នុងព្រះសូត្រនេះ ពាក្យនាំមកត្រឹមប៉ុណ្ណេះថា "ព្រះមានព្រះភាគទ្រង់បានស្តាប់ហើយនូវសំឡេងរបស់សក្កៈជាធំជាងទេវតា ដែលហោះទៅលើវេហាស៍ បានឧទាន ៣ ដង ក្នុងអាកាសថា ៖

ឱ! ទានដែលជាទានដ៏ឧត្តម យើងបានតម្កល់ទុកល្អហើយក្នុងព្រះមហាកស្សបៈ ឱ! ទានដែលជាទានដ៏ឧត្តម យើងបានតម្កល់ទុកល្អហើយក្នុងព្រះមហាកស្សបៈ ឱ! ទានដែលជាទានដ៏ឧត្តម យើងបានតម្កល់ទុកល្អហើយក្នុងព្រះមហាកស្សបៈ ។

ដោយព្រះសោតធាតុដែលជាទិព្វ បរិសុទ្ធ កន្លងនូវសោតធាតុរបស់មនុស្ស ។

គ្រានោះឯង ព្រះមានព្រះភាគជ្រាបទ្រង់ជ្រាបច្បាស់សេចក្ដីនុ៎ះហើយ ទើបបន្លឺឧទាននេះ ក្នុងវេលានោះថា ៖

ទេវតា និងមនុស្ស រមែងស្រឡាញ់ភិក្ខុអ្នកប្រព្រឹត្តបិណ្ឌបាត
ជាវត្ត ជាអ្នកចិញ្ចឹមខ្លួនឯង មិនចិញ្ចឹមបុគ្គលដទៃ ជាអ្នកនឹង-
ធឹង អ្នកចូលទៅស្ងប់ហើយ មានស្មារតីគ្រប់កាល ។

លុះទ្រង់បន្លឺឧទានហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សក្កៈជាធំជាងពួកទេវតា ស្ដេចបានមកប្រគេនបិណ្ឌបាតដល់បុត្រតថាគត ព្រោះក្លិនសីល" ដូច្នេះ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

អប្បមត្តោ អយំ គន្ធោ យាយំ តគរចន្ទនី
យោ ច សីលវតំ គន្ធោ វាតិ ទេវេសុ ឧត្តមោ ។

ក្លិនក្រស្នា និងក្លិនចន្ទន៍ណា ក្លិននេះក្រអូបមានប្រមាណ
តិចទេ ចំណែកក្លិននៃបុគ្គលមានសីលទាំងឡាយណា ក្លិន
នោះ ទើបក្រអូបលើសលប់ ផ្សាយទៅក្នុងទេវលោក និង
មនុស្សលោកបាន ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា អប្បមត្តោ (ត្រឹមតែជាក្លិនតិចតួច) គឺ មានប្រមាណតិចតួច ៗ ពីរបទថា យោ ច សីលវតំ (ចំណែកក្លិនរបស់បុគ្គលអ្នកមានសីលទាំងឡាយ) សេចក្ដីថា ចំណែកក្លិនសីលរបស់អ្នកមានសីល

ទាំងឡាយណា ក្លិនសីលនោះ មិនមែនមានក្លិនតិចតួច ដូចក្លិនក្រស្នា និងក្លិន ចន្ទន៍ក្រហមទេ គឺ ជាក្លិនដ៏ឧឡារ ផ្សាយទៅដ៏លើសលប់ ព្រោះហេតុនោះឯង ក្លិនសីលទើបជាក្លិនខ្ពស់បំផុត គឺ ប្រសើរលើសលប់ ផ្សាយទៅក្នុងពួកទេវតា និងមនុស្ស គឺ ផ្សាយទៅក្នុងពពួកមនុស្ស និងទេវតា បានដល់ រមែងក្រអូប ទូទៅ ។

ក្នុងវេលាចប់ព្រះទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនា កើតប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងការថ្វាយបិណ្ឌបាតដល់ព្រះមហាកស្សបៈ

# ១១. រឿងការបរិនិព្វានរបស់ព្រះគោធិកត្ថេរ

*ព្រះសាស្តា កាលស្តេចចូលទៅអាស្រ័យក្រុងរាជគ្រឹះ ទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធការបរិនិព្វានរបស់ព្រះគោធិកត្ថេរ ត្រាស់ធម្មទេសនានេះថា* ***តេសំ សម្បន្នសីលានំ (របស់អ្នកមានសីលដល់ព្រមហើយ)*** *ជាដើម ។*

## ព្រះថេរៈគិតសម្លាប់ខ្លួនព្រោះវិនាសចាកឈាន

*សេចក្តីពិស្តារថា លោកដ៏មានអាយុនោះ នៅជិតល្អាងកាឡសិលាខាងក្នុំឥសិគិលិ ជាអ្នកមិនប្រមាទ មានព្យាយាម មានចិត្តមានអារម្មណ៍តែមួយ ពាល់ត្រូវចេតោវិមុត្តិ ដែលកើតឡើងតាមសម័យ (កើតឡើងជាគ្រាៗ) បានវិនាសចាកចេតោវិមុត្តិ ដោយអំណាចនៃរោគមួយប្រភេទ ។ លោកញុំាងឈានទី ២ ខ្លះ ទី ៣ ខ្លះ ឲ្យកើតឡើងអស់ ៦ ដង ហើយក៏វិនាសចាកឈាននោះទៀត ក្នុងវារៈទី ៧ ក៏ញុំាងឈានឲ្យកើតឡើងហើយ បានគិតថា "យើងវិនាសចាកឈានអស់ ៦ ដងហើយ ក៏គតិរបស់អ្នកមានឈានវិនាសមិនទៀងទាត់ទេ បើដូច្នោះ យើងនឹងនាំសស្ត្រាមក" លុះគិតដូច្នោះហើយ ក៏កាន់កាំបិតសម្រាប់កោរសក់ ដេកលើគ្រែតូច បំណងនឹងកាត់.ក ។*

## មារទូលព្រះសាស្តាឱ្យទ្រង់ជ្រាប

*មារដឹងចិត្តរបស់ព្រះថេរៈហើយ គិតថា "ភិក្ខុនេះ ប្រាថ្នានឹងនាំសស្ត្រា*

មក ក៏ភិក្ខុទាំងឡាយកាលនាំសស្ត្រាមក រមែងជាអ្នកអស់សេចក្តីអាល័យក្នុងជីវិត ភិក្ខុទាំងនោះផ្តើមតាំងវិបស្សនាហើយ រមែងបានសម្រេចអរហត្ត បើយើងនឹងហាមឃាត់ភិក្ខុនោះ លោកនឹងមិនធ្វើតាមពាក្យរបស់យើង យើងនឹងទូលឲ្យព្រះសាស្តាហាម" ដូច្នេះ ទើបចូលទៅគាល់ព្រះសាស្តាដោយភេទដែលអ្នកដទៃមិនស្គាល់ ក្រាបទូលយ៉ាងនេះថា ៖

*បពិត្រព្រះមហាវីរៈ អ្នកមានបុណ្យច្រើន រុងរឿងដោយឫទ្ធិនិងយស កន្លងបាននូវពៀរ និងភ័យទាំងពួង ទ្រង់មានចក្ខុ ខ្ញុំព្រះអង្គសូមថ្វាយបង្គំព្រះបាទា ។ បពិត្រព្រះមហាវីរៈ សាវករបស់ព្រះអង្គ ត្រូវសេចក្តីស្លាប់គ្របសង្កត់ ប្រាថ្នាគិតដល់សេចក្តីស្លាប់ បពិត្រព្រះអង្គ អ្នកទ្រទ្រង់នូវសេចក្តីរុងរឿង សូមព្រះអង្គទ្រង់ហាមព្រះសាវកនោះ បពិត្រព្រះមានព្រះភាគ ទ្រង់ប្រាកដក្នុងប្រជុំជន សាវករបស់ព្រះអង្គត្រេកអរហើយក្នុងសាសនា (តែ) មានធម៌ មាននៅក្នុងចិត្តមិនទាន់បានសម្រេច នៅជាអ្នកត្រូវការសិក្សា គប្បីធ្វើមរណកាលដូចម្តេចបាន ។*

មារស្វែងរកវិញ្ញាណរបស់ព្រះគោធិកៈ

គ្រានោះឯង ព្រះថេរៈនាំសស្ត្រាមកហើយ ។ ព្រះសាស្តាទ្រង់ជ្រាបថា "បុគ្គលនេះជាមារ" ទើបត្រាស់ព្រះគាថានេះថា ៖

*អ្នកប្រាជ្ញទាំងឡាយ តែងធ្វើយ៉ាងនោះឯង រមែងមិនស្តាយក្នុង*

ជីវិត គោធិកៈ ដកតណ្ហាព្រមទាំងឫស បរិនិព្វានហើយ ។

គ្រានោះឯង ព្រះមានព្រះភាគស្ដេចបានយាងទៅកាន់ទីដែលព្រះថេរៈនាំសស្ត្រាមក ព្រមទាំងភិក្ខុជាច្រើន ។ ខណៈនោះ មារមានចិត្តបាបគិតថា "បដិសន្ធិវិញ្ញាណរបស់ព្រះគោធិកៈនេះ តាំងនៅក្នុងទីណាហ្ន៎" ដូច្នេះ ហើយក៏ជាដុំផ្សែង និងដុំពពក ស្វែងរកវិញ្ញាណរបស់ព្រះថេរៈក្នុងទិសទាំងពួង ។ ព្រះមានព្រះភាគ ទ្រង់សម្ដែងនូវមារនោះ ជាដុំផ្សែង និងដុំពពកនោះ ដល់ភិក្ខុទាំងឡាយ ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មារមានចិត្តបាបនោះស្វែងរកវិញ្ញាណរបស់កុលបុត្រឈ្មោះគោធិកៈ ដោយគិតថា វិញ្ញាណរបស់កុលបុត្រឈ្មោះគោធិកៈតាំងនៅក្នុងទីកន្លែងណា ម្នាលភិក្ខុទាំងឡាយ កុលបុត្រឈ្មោះគោធិកៈមានវិញ្ញាណមិនតាំងនៅឡើយ បរិនិព្វានហើយ" ។ សូម្បីមារ កាលមិនអាចរកទីតាំងវិញ្ញាណរបស់ព្រះគោធិកៈបាន ទើបក្លែងភេទជាកុមារកាន់ពិណមានពណ៌លឿងដូចផ្លែព្នៅ ចូលទៅគាល់ព្រះសាស្ដា ទូលសួរថា ៖

ខ្ញុំព្រះអង្គបានស្វែងរកហើយ (នូវវិញ្ញាណ) ក្នុងទិសខាងលើផង
ខាងក្រោមផង ទិសទទឹងផង ទិសធំផង ទិសតូចផង មិនបាន
ជួបប្រទះ ព្រះគោធិកៈនោះទៅក្នុងទីណា ។

គ្រានោះ ព្រះសាស្ដាត្រាស់នឹងមារនោះថា ៖

ភិក្ខុឈ្មោះគោធិកៈ ជាអ្នកប្រាជ្ញ សម្បូរដោយបញ្ញាជាគ្រឿង
កំណត់ មានឈាន ត្រេកអរហើយក្នុងឈានគ្រប់កាល ប្រកប

សេចក្តីព្យាយាមអស់ថ្ងៃ និងយប់ មិនជាប់ជំពាក់ក្នុងជីវិត ឈ្នះសេនារបស់មច្ចុ មិនមកកាន់ភពទៀត បានដកតណ្ហាព្រមទាំងឫសបរិនិព្វានហើយ ។

កាលព្រះសាស្តាត្រាស់យ៉ាងនោះហើយ

ពិណក៏បានរបូតធ្លាក់ពីឃ្លៀករបស់មារនោះ ព្រោះត្រូវសេចក្តីសោកគ្របសង្កត់ លំដាប់នោះ យក្សនោះក៏មានសេចក្តីតូចចិត្ត ហើយក៏បាត់អំពីទីនោះទៅ ។

សូម្បីព្រះសាស្តាទ្រង់ត្រាស់ថា "មារមានចិត្តបាប អ្នកឯងត្រូវការអ្វីដោយស្ថានទីដែលកុលបុត្រឈ្មោះគោធិកៈកើតហើយ ។ ព្រោះបុគ្គលដូចអ្នកទាំងរយទាំងពាន់ ក៏មិនអាចនឹងឃើញទីដែលគោធិកៈនោះកើតដែរ" ដូច្នេះហើយបានត្រាស់ព្រះគាថានេះថា ៖

តេសំ សម្បន្នសីលានំ អប្បមាទវិហារិនំ

សម្មទញ្ញា វិមុត្តានំ មារោ មគ្គំ ន វិន្ទតិ ។

មារាធិរាជ (ទុកជាខំស្វែងរក) ក៏មិនជួបនូវផ្លូវរបស់លោក អ្នកមានសីលបរិបូណ៌ អ្នកនៅដោយសេចក្តីមិនប្រមាទ អ្នករួចស្រឡះ (ចាកធម៌ជាគ្រឿងសៅហ្មង) ព្រោះដឹងច្បាស់តាមហេតុ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា តេសំ (ទាំងនោះ) គឺ នៃអ្នកដែលបរិនិព្វាន

ដូចជាកុលបុត្រឈ្មោះគោធិកៈ មានវិញ្ញាណមិនតាំងនៅ បានបរិនិព្វានហើយ ដូច្នោះ ។

បទថា **សម្បន្នសីលានំ** (របស់បុគ្គលអ្នកមានសីលដល់ព្រមហើយ) គឺ បុគ្គលអ្នកមានសីលបរិបូណ៌ហើយ ។ បទថា **អប្បមាទវិហារិនំ** (មានប្រក្រតីនៅដោយសេចក្ដីមិនប្រមាទ) គឺ អ្នកនៅដោយសេចក្ដីមិនប្រមាទ ពោល គឺ ការនៅមិនប្រាសចាកសតិ ។

បទថា **សម្មទញ្ញា វិមុត្តានំ** (រួចផុតវិសេសហើយព្រោះដឹងដ៏ប្រពៃ) សេចក្ដីថា អ្នករួចផុតវិសេសហើយ ដោយវិមុត្តិ ៥ យ៉ាងគឺ (តទង្គវិមុត្តិ វិក្ខម្ភនវិមុត្តិ សមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និស្សរណវិមុត្តិ) ព្រោះដឹងដោយហេតុ គឺ ដោយន័យ ដោយការណ៍ ។

បទថា **មារោ មគ្គំ ន វិន្ទតិ** (មាររមែងមិនជួបនូវផ្លូវ) សេចក្ដីថា មារសូម្បីស្វែងរកដោយពេញកម្លាំង ក៏រមែងមិនជួប គឺ រមែងមិនបានចំពោះបានដល់ រមែងមិនឃើញផ្លូវរបស់ព្រះខីណាស្រពទាំងឡាយបែបនេះ ដែលធ្វើដំណើរទៅហើយ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះធម្មទេសនា រមែងបានជាប្រយោជន៍ដល់មហាជន ដូច្នេះឯង ។

ចប់ រឿងការបរិនិព្វានរបស់ព្រះគោធិកត្ថេរ

# ១២. រឿងគរហទិន្នៈ

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងក្រុងវត្តជេតពន ទ្រង់ប្រារព្ធសាវក របស់និគ្រន្ថឈ្មោះ **គរហទិន្ន** ត្រាស់ព្រះធម្មទេសនានេះថា **យថា សង្ការ-ធានស្មឹ (ក្នុងគំនរសម្រាម... យ៉ាងណា)** ជាដើម ។*

ជាសម្លាញ់នឹងគ្នា តែជ្រះថ្លាក្នុងវត្ថុផ្សេងគ្នា

*សេចក្ដីពិស្ដារថា ក្នុងក្រុងសាវត្ថី មានជនដែលជាសម្លាញ់នឹងគ្នា ២ នាក់ គឺ សិរីគុត្តៈ ១ និងគរហទិន្នៈ ១ ។ ក្នុងបណ្ដាសម្លាញ់ ២ នាក់នោះ សិរីគុត្តៈជាឧបាសក គរហទិន្នៈជាសាវករបស់និគ្រន្ថ ។ ពួកនិគ្រន្ថ រមែង ពោលនឹងគរហទិន្នៈនោះរឿយៗ យ៉ាងនេះថា "ការដែលលោកនិយាយជាមួយ សិរីគុត្តៈ ដែលជាសម្លាញ់របស់លោកថា លោកចូលទៅរកសមណគោតម ធ្វើអ្វី? លោកនឹងបានអ្វី? ក្នុងសម្នាក់ព្រះសមណគោតមនោះ ដូច្នេះហើយ ពោលទូន្មានដោយអាការដែលសិរីគុត្តៈចូលមករកពួកយើង ហើយនឹងឲ្យនូវ ទេយ្យធម៌ដល់ពួកយើងមិនគួរឬ?" គរហទិន្នៈស្ដាប់ពាក្យរបស់និគ្រន្ថទាំងនោះ ហើយ ក៏ព្យាយាមនិយាយនឹងសិរីគុត្តៈក្នុងទីដែលគេឈរ និងអង្គុយជាដើម យ៉ាងនេះថា "ម្នាលសម្លាញ់ ប្រយោជន៍អ្វីដល់លោក ក្នុងសមណគោតម? លោកចូលទៅរកព្រះសមណគោតមនោះ នឹងបានអ្វី? ការដែលលោកចូល ទៅរកលោកម្ចាស់ដ៏ចម្រើនរបស់យើង ហើយថ្វាយនូវទានដល់លោកម្ចាស់ដ៏*

ចម្រើនរបស់យើងទាំងនោះ មិនគួរឬ?" សិរីគុត្តសូម្បីស្ដាប់ពាក្យរបស់គរហ-ទិន្នទោះហើយ ក៏ស្ងៀមអស់ជាច្រើនថ្ងៃ មិនសប្បាយចិត្ត ថ្ងៃមួយទើបបាននិយាយនឹងគរហទិន្នថា ម្នាលសម្លាញ់ លោកព្យាយាមមកនិយាយនឹងយើងក្នុងទីដែលយើងឈរជាដើម យ៉ាងនេះថា "ម្នាលសម្លាញ់ លោកចូលទៅរកព្រះសមណគោតមនោះ នឹងបានអ្វី? លោកចូលទៅរកលោកម្ចាស់របស់យើងថ្វាយទានដល់លោកម្ចាស់ទាំងនោះ ម្នាលគរហទិន្ន លោកចូរប្រាប់ដល់យើងមកមើលថា លោកម្ចាស់ទាំងឡាយរបស់លោក រមែងដឹងអ្វី?" ។

គរហទិន្ន "ឱ! នាយកុំនិយាយយ៉ាងនេះឡើយ ដែលឈ្មោះថា វត្ថុដែលលោកម្ចាស់ទាំងឡាយរបស់យើងមិនដឹង មិនមានឡើយ លោកម្ចាស់ទាំងឡាយ រមែងដឹងនូវហេតុដែលជាអតីត អនាគត និងបច្ចុប្បន្នទាំងអស់ កាយកម្ម វចីកម្ម មនោកម្មទាំងអស់ រមែងដឹងហេតុដែលគួរ និងមិនគួរទាំងអស់ថា ហេតុនេះ នឹងមាន ហេតុនេះ នឹងមិនមាន ។

សិរីគុត្ត. លោកនិយាយថា លោកម្ចាស់របស់លោក រមែងដឹងដូច្នេះមិនមែនឬ ។

គរហទិន្ន. ខ្ញុំបាននិយាយយ៉ាងនេះមែន ។

សិរីគុត្ត. បើដូច្នេះមែន ចុះហេតុអ្វីលោកមិនប្រាប់សេចក្ដីនេះដល់ខ្ញុំរហូតអស់កាលប្រមាណប៉ុណ្ណេះ រាប់ថា លោកធ្វើកម្មធ្ងន់ហើយ ថ្ងៃនេះ ខ្ញុំបានដឹងអានុភាពនៃញាណរបស់លោកម្ចាស់ទាំងឡាយហើយ ចូរសម្លាញ់ទៅ

ចុះ ចូរនិមន្តលោកម្ចាស់ទាំងឡាយតាមពាក្យរបស់ខ្ញុំ ។

គរហទិន្នទោះ ទៅកាន់សម្នាក់របស់ពួកនិគ្រន្ថ ថ្វាយបង្គំនិគ្រន្ថទាំងនោះហើយ ពោលថា "សិរីគុត្តសម្លាញ់របស់ខ្ញុំបាទ និមន្តលោកម្ចាស់ទាំងឡាយដើម្បីឆាន់ក្នុងថ្ងៃស្អែក" ។

និគ្រន្ថ. សិរីគុត្តនិយាយនឹងលោកយ៉ាងហ្នឹងឬ ។

គរហទិន្ន. យ៉ាងនោះហើយ លោកម្ចាស់ ។

និគ្រន្ថទាំងនោះ រីករាយត្រេកអរហើយ ពោលថា "កិច្ចរបស់ពួកយើងសម្រេចហើយ ចាប់ផ្តើមពីកាលដែលសិរីគុត្តជ្រះថ្លានឹងពួកយើង កាលណាសម្បត្តិឈ្មោះអ្វី នឹងមិនមានដល់ពួកយើង?" សូម្បីទីនៅរបស់សិរីគុត្ត ក៏ធំ ។

## សិរីគុត្តត្រៀមខ្លួនទទួលនិគ្រន្ថ

សិរីគុត្តនោះ ឲ្យគេជីករណ្តៅវែងពីរ ខាងក្នុងចន្លោះផ្ទះពីរខ្នង ហើយក៏ឲ្យគេយកលាមកការដាក់រហូតទាល់តែពេញ ឲ្យកប់បង្គោលទុកក្នុងទីបំផុតសងខាងខាងក្រៅរណ្តៅ ឲ្យចងខ្សែទុកនឹងបង្គោលទាំងនោះ ឲ្យដាក់ជើងខាងមុខនៃអាសនៈទាំងឡាយ ទុកខាងលើរណ្តៅ ឲ្យដាក់ជើងអាសនៈខាងក្រោមទុកនឹងខ្សែ ចំណាំទុកថា "ក្នុងវេលាដែលអង្គុយហើយយ៉ាងនេះឯង ពួកនិគ្រន្ថនឹងមានក្បាលដាំចុះ" ឲ្យគេក្រាលកម្រាលទុកខាងលើអាសនៈទាំងឡាយ ដោយអាការដែលរណ្តៅមិនប្រាកដ ឲ្យគេលាងពាងធំៗ ហើយឲ្យចងមាត់ដោយស្លឹកចេក និងសំពត់ចាស់ៗ ធ្វើពាងទទេទាំងនោះឯងឲ្យប្រឡាក់ ដោយគ្រាប់បបរ

បាយ ទឹកដោះថ្លា ស្ករអំពៅ និងនំអំពីខាងក្រៅ ហើយឲ្យគេលើកយកទៅតម្កល់ទុកខាងក្រោមផ្ទះ ។

គរហទិន្នប្រញាប់ទៅផ្ទះសិរីគុត្តតាំងពីព្រឹកព្រលឹម ហើយសួរថា "ម្នាលសម្លាញ់ លោកចាត់ចែងសក្ការៈដើម្បីលោកម្ចាស់ទាំងឡាយហើយឬ ?" ។

សិរីគុត្ត. អើសម្លាញ់ ខ្ញុំបានចាត់ចែងហើយ ។

គរហទិន្ន. ក៏សក្ការៈនោះនៅទីណា ។

សិរីគុត្ត. បបរក្នុងពាងទាំងឡាយនោះ ប្រមាណប៉ុណ្ណេះ បាយក្នុងពាងប្រមាណប៉ុណ្ណេះ ទឹកដោះថ្លា ស្ករអំពៅ នំជាដើម ក្នុងពាងប្រមាណប៉ុណ្ណេះ អាសនៈក្រាលទុកហើយ ។

គរហទិន្ននោះ ពោលថា "ប្រពៃហើយសម្លាញ់" ហើយក៏ទៅវិញ ។ ក្នុងវេលាដែលគរហទិន្នទៅផុត ពួកនិគ្រន្ថប្រមាណ ៥០០ នាក់ ក៏មកដល់ ។ សិរីគុត្តចេញអំពីផ្ទះ មកថ្វាយបង្គំពួកនិគ្រន្ថដោយបញ្ចង្គប្រតិស្ឋាន ហើយឈរផ្គងអញ្ជលីនៅខាងមុខនិគ្រន្ថទាំងនោះ ដោយគិតថា "បានឮថា លោកទាំងឡាយដឹងនូវហេតុគ្រប់យ៉ាង មានហេតុដែលជាអតីតជាដើម ឧបដ្ឋាករបស់ពួកលោកម្ចាស់ប្រាប់ខ្ញុំយ៉ាងនេះ បើពួកលោករមែងដឹងហេតុទាំងអស់នោះ សូមពួកលោក កុំចូលទៅកាន់ផ្ទះរបស់ខ្ញុំឲ្យសោះ ព្រោះកាលពួកលោកចូលទៅកាន់ផ្ទះរបស់ខ្ញុំហើយ បបរក៏មិនមាន បាយជាដើមក៏មិនមានដែរ បើពួកលោកមិនដឹងក៏ចូលទៅចុះ យើងឲ្យពួកលោកធ្លាក់ចូលទៅក្នុងរណ្តៅលាមក

ហើយនឹងឲ្យគេវាយពួកលោក" លុះគិតយ៉ាងនោះហើយ ក៏ឲ្យសញ្ញាដល់ពួកបុរសថា "ពួកលោកដឹងការៈ គឺ ការអង្គុយរបស់និគ្រន្ថទាំងនោះ" ហើយឈរនៅខាងក្រោយ គប្បីទាំកម្រាលខាងលើនៃអាសនៈទាំងឡាយចេញ កុំឲ្យអាសនៈទាំងនោះប្រឡាក់ដោយរបស់មិនស្អាតឡើយ ។ គ្រានោះ សិរីគុត្តនិយាយនឹងពួកនិគ្រន្ថថា "និមន្តមកខាងនេះចុះ លោកម្ចាស់" ។ ពួកនិគ្រន្ថចូលទៅហើយ ក៏ប្រារព្ធនឹងអង្គុយលើអាសនៈដែលគេក្រាលទុក គ្រានោះមនុស្សទាំងឡាយនិយាយនឹងនិគ្រន្ថទាំងនោះថា "សូមរង់ចាំសិនលោកម្ចាស់កុំទាន់អង្គុយ" ។

និគ្រន្ថ. ព្រោះហេតុអ្វី ។

មនុស្ស. ការដែលលោកម្ចាស់ទាំងឡាយ ចូលមកកាន់ផ្ទះរបស់ពួកខ្ញុំ ដឹងនូវធម្មទំនៀមហើយ ទើបអង្គុយរមែងគួរ ។

និគ្រន្ថ. ធ្វើយ៉ាងណាទៅលោក ទើបគួរ ។

មនុស្ស. ការដែលលោកម្ចាស់ទាំងអស់ឈរនៅជិតអាសនៈ ដែលដល់រៀងៗ ខ្លួនហើយ អង្គុយចុះព្រមគ្នាតែម្ដង ទើបគួរ ។

បានឮថា សិរីគុត្តនោះឲ្យធ្វើពិធីនេះ ក៏ដោយគិតឃើញថា "កាលនិគ្រន្ថម្នាក់ធ្លាក់ចុះក្នុងរណ្ដៅហើយ និគ្រន្ថដ៏សេសនឹងមិនអង្គុយទៀតទេ" ។ និគ្រន្ថទាំងនោះពោលថា "ប្រពៃហើយ" ហើយគិតថា "កាលដែលពួកយើងធ្វើតាមពាក្យដែលមនុស្សទាំងនេះប្រាប់ ទើបគួរ" ។

## និគ្រន្ថធ្លាក់រណ្ដៅលាមក

គ្រានោះ និគ្រន្ថទាំងអស់បានទៅជិតអាសនៈ ដែលដល់រៀងៗ ខ្លួនហើយ ដោយលំដាប់ ។ លំដាប់នោះ ពួកមនុស្សពោលនឹងនិគ្រន្ថទាំងនោះថា "បពិត្រលោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយអង្គុយព្រមគ្នាចុះ" ដឹងនូវការៈ គឺ ការអង្គុយរបស់និគ្រន្ថទាំងនោះហើយ ទើបនាំកម្រាលខាងលើអាសនៈទាំងឡាយចេញ ។ ពួកនិគ្រន្ថអង្គុយព្រមគ្នា ជើងអាសនៈដែលដាក់ទុកលើខ្សែក៏ភ្លាត់ធ្លាក់ចុះ ពួកនិគ្រន្ថក៏ដាំក្បាលចុះទៅក្នុងរណ្ដៅ ។ សិរីគុត្តកាលពួកនិគ្រន្ថទាំងនោះធ្លាក់ចុះទៅក្នុងរណ្ដៅហើយ ក៏បិទទ្វារ ឲ្យគេយកកំណាត់ឈើគគីរវាយពួកនិគ្រន្ថដែលស្រវាឡើង ដោយនិយាយថា "ព្រោះហេតុអ្វីពួកលោកមិនដឹងហេតុដែលជាអតីត អនាគត និងបច្ចុប្បន្ន?" ហើយប្រាប់ថា "ការធ្វើប៉ុណ្ណេះ នឹងសមគួរដល់ពួកនិគ្រន្ថទាំងនោះ" ដូច្នេះ ទើបឲ្យបើកទ្វារ ។ ពួកនិគ្រន្ថទាំងនោះចេញហើយ ប្រារព្ធដើម្បីនឹងគេចចេញទៅ ។ ក៏ក្នុងផ្លូវទៅនៃពួកនិគ្រន្ថទាំងនោះ សិរីគុត្តឲ្យមនុស្សធ្វើផ្ទៃដីដែលបរិកម្មដោយកំបោរ.សទុកឲ្យរអិល ។ សិរីគុត្តឲ្យគេវាយម្ដងទៀត ពួកនិគ្រន្ថទាំងនោះ ដែលជាអ្នកឈរនៅមិនបានក្នុងទីនោះ ដួលចុះហើយ ទើបបណ្ដេញឲ្យទៅដោយពាក្យថា "ការធ្វើប៉ុណ្ណេះល្មមសមគួរដល់អ្នកទាំងឡាយហើយ" និគ្រន្ថទាំងនោះ ខ្សឹកខ្សួល រៀបរាប់ថា "ពួកយើង គឺ លោកឲ្យវិនាសហើយ ពួកយើង គឺ លោកឲ្យវិនាសហើយ" បានទៅកាន់ខ្លោងទ្វារផ្ទះរបស់ឧបដ្ឋាក ។

## គរហទិន្នប្ដឹងសិរីគុត្តដល់ព្រះរាជា

គរហទិន្ន ឃើញអាការដែលប្លែករបស់និគ្រន្ថទាំងនោះហើយ ក៏ក្រោធថា "យើងដែលសិរីគុត្តឲ្យវិនាសហើយ វាឲ្យគេវាយលោកម្ចាស់ទាំងឡាយរបស់យើងដែលជាបុញ្ញក្ខេត្ត អ្នកមាននាមថា អាចដើម្បីនឹងឲ្យទេវលោកទាំង ៦ ជាន់ ដល់មនុស្សទាំងឡាយ អ្នកដែលគួរលាតដៃចេញ ថ្វាយបង្គំតាមការពេញចិត្ត ឲ្យដល់សេចក្ដីវិនាសហើយ" ទើបទៅកាន់រាជត្រកូល ក្រាបទូលឲ្យព្រះរាជាទ្រង់ពិន័យសិរីគុត្តនោះ ១.០០០ កហាបណៈ ។ គ្រានោះ ព្រះរាជាទ្រង់បញ្ជូនព្រះរាជសារទៅកាន់សិរីគុត្តនោះ ។ សិរីគុត្តទៅថ្វាយបង្គំព្រះរាជាហើយក្រាបទូល "បពិត្រមហារាជ សូមព្រះអង្គទ្រង់សាកសួរសិន សឹមពិន័យ បើទ្រង់មិនទាន់សាកសួរទេ កុំទាន់ពិន័យ" ។

ព្រះរាជា. យើងសាកសួរពិចារណាមើលហើយ ទើបនឹងពិន័យ ។

សិរីគុត្ត. ព្រះករុណាថ្លៃវិសេស បើដូច្នោះ សូមមហាបពិត្រពិន័យចុះ ។

ព្រះរាជា. បើដូច្នោះ ចូរអ្នកនិយាយមកមើល ។ សិរីគុត្តក្រាបទូលការប្រព្រឹត្តទៅនោះទាំងអស់ តាំងពីដើមរឿងថា "បពិត្រមហារាជ សម្លាញ់របស់ខ្ញុំព្រះអង្គជាសាវករបស់និគ្រន្ថ ចូលទៅរកខ្ញុំព្រះអង្គ ហើយពោលយ៉ាងនេះរឿយៗ ក្នុងទីដែលខ្ញុំព្រះអង្គឈរ អង្គុយជាដើមថា "ម្នាលសម្លាញ់ តើមានប្រយោជន៍អ្វី ដែលលោកចូលទៅរកព្រះសមណគោតម លោកចូលទៅ

រកព្រះសមណគោតមនោះ នឹងបានអ្វី?” ដូច្នេះ ហើយក្រាបទូលថា “បពិត្រមហារាជ បើការពិន័យព្រោះហេតុនេះគួរហើយ សូមទ្រង់ពិន័យចុះ” ។ ព្រះរាជាទតមើលគរហទិន្ន ហើយត្រាស់សួរថា “បានឮថា អ្នកនិយាយយ៉ាងនោះពិតមែនឬ?” ។

គរហទិន្ន. ពិតមែន ព្រះសម្មតិទេព ។

ព្រះរាជា. អ្នកគប់រកពួកនិគ្រន្ថ ដែលជាអ្នកមិនដឹងសូម្បីនូវហេតុត្រឹមតែប៉ុណ្ណេះ ថា “ជាគ្រូ” ហើយប្រាប់ដល់សាវករបស់ព្រះតថាគតថា រមែងដឹងគ្រប់យ៉ាង ដូច្នេះ កំហុសដែលអ្នកលើកឡើងដើម្បីឲ្យយើងពិន័យនោះ ចូរមានដល់អ្នកឯងចុះ ។

គរហទិន្នក៏ត្រូវព្រះរាជាទ្រង់ពិន័យ ចំណែកពួកនិគ្រន្ថ ដែលចូលទៅកាន់ត្រកូលរបស់គរហទិន្ននោះ ក៏ត្រូវសិរីគុត្តវាយបណ្តេញឲ្យចេញអំពីផ្ទះដោយប្រការដូច្នេះ ។

## គរហទិន្នត្រៀមសងសឹកសិរីគុត្ត

គរហទិន្ននោះខឹងនឹងសិរីគុត្ត ឈប់និយាយរកសិរីគុត្ត អស់ប្រមាណកន្លះខែ ក្រោយមកក៏គិតឃើញថា “ការធ្វើយ៉ាងនេះ មិនសមគួរដល់យើងឡើយ យើងគួរតែរកឧបាយណាមួយដើម្បី ធ្វើសេចក្តីវិនាសឲ្យដល់ពួកភិក្ខុដែលជាអ្នកចូលទៅកាន់ត្រកូលរបស់សិរីគុត្តនោះ” លុះគិតដូច្នេះហើយ ក៏ចូលទៅរកសិរីគុត្ត ពោលថា “សម្លាញ់សិរីគុត្ត” ។

សិរីគុត្ត. មានការអ្វីសម្លាញ់ ។

គរហទិន្ន. ធម្មតាញាតិ និងមិត្តទាំងឡាយ រមែងមានការឈ្លោះទាស់ទែងគ្នាជាធម្មតាខ្លះ វិវាទគ្នាខ្លះ ព្រោះហេតុអ្វី ទើបសម្លាញ់ឯងមិននិយាយរកខ្ញុំ ។

សិរីគុត្ត. សម្លាញ់ ខ្ញុំមិននិយាយ ក៏ព្រោះសម្លាញ់ឯងមិននិយាយនឹងខ្ញុំ កម្មឯណាដែលខ្ញុំធ្វើហើយ កម្មនោះ ចូរជាការធ្វើហើយចុះ យើងទាំងពីរនឹងមិនត្រូវទម្លាយមេត្រីភាពគ្នាឡើយ ។

ចាប់ពីពេលនោះមក សម្លាញ់ទាំងពីរនាក់នោះ តែងឈរ អង្គុយក្នុងទីមួយជាមួយគ្នា ។ ថ្ងៃមួយ សិរីគុត្តពោលនឹងគរហទិន្នថា "ម្នាលសម្លាញ់ប្រយោជន៍អ្វីរបស់លោកជាមួយនឹងពួកនិគ្រន្ថទៅ លោកចូលទៅរកពួកនិគ្រន្ថទាំងនោះបានប្រយោជន៍អ្វី ការចូលទៅរកព្រះសាស្តារបស់យើងក្តី ការថ្វាយនូវទានដល់លោកម្ចាស់ដ៏ចម្រើនទាំងឡាយក្តី នឹងមិនគួរដល់សម្លាញ់ឯងឬ?" ចំណែកគរហទិន្ន កំពុងរង់ចាំនូវហេតុនេះដែរ ព្រោះដូច្នោះ ពាក្យរបស់សិរីគុត្តនោះ ដូចជាកេះដំបៅដោយក្រចក គរហទិន្ននោះសួរសិរីគុត្តថា "ម្នាលសម្លាញ់ព្រះសាស្តារបស់សម្លាញ់ឯង រមែងដឹងនូវអ្វី?" ។

សិរីគុត្ត. "ម្នាលសម្លាញ់ សម្លាញ់ឯងកុំសួរយ៉ាងនោះឡើយ ដែលឈ្មោះថា វត្ថុណាមួយដែលព្រះសាស្តារបស់យើងមិនដឹងនោះ មិនមានឡើយ ព្រះសាស្តារបស់យើង រមែងដឹងនូវហេតុទាំងអស់ មានហេតុដែលជាអតីត

ជាដើម រមែងដឹងចិត្តរបស់សត្វទាំងឡាយដោយអាការ ១៦ យ៉ាងបាន ។

គរហទិន្ន. ខ្ញុំមិនដឹងយ៉ាងនេះ ព្រោះហេតុអ្វី ទើបសម្លាញ់ឯងមិនប្រាប់ខ្ញុំរហូតអស់កាលប្រមាណប៉ុណ្ណេះ បើដូច្នោះ សម្លាញ់ឯងចូរទៅ ចូរអារាធនានិមន្តព្រះសាស្តាដើម្បីភត្តាហារក្នុងថ្ងៃស្អែកនេះ ខ្ញុំនឹងឲ្យព្រះអង្គសោយ លោកចូរក្រាបទូល ដើម្បីទ្រង់ទទួលភិក្ខារបស់ខ្ញុំ ព្រមទាំងភិក្ខុសង្ឃ ៥០០ រូប ។

សិរិគុត្តចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន គរហទិន្នសម្លាញ់របស់ខ្ញុំព្រះអង្គ ពីងពាក់ខ្ញុំព្រះអង្គឲ្យអារាធនានិមន្តព្រះអង្គថា សូមព្រះអង្គ ព្រមទាំងភិក្ខុ ៥០០ រូប ទទួលភិក្ខាហាររបស់គរហទិន្ននោះ ក្នុងថ្ងៃស្អែកនេះ ក៏ក្នុងថ្ងៃមុន កម្មនេះដែលខ្ញុំព្រះអង្គធ្វើហើយដល់ពួកនិគ្រន្ថ ដែលជាអ្នកចូលកាន់ត្រកូលរបស់គរហទិន្ននោះ ខ្ញុំព្រះអង្គមិនជ្រាបសូម្បីការធ្វើតបចំពោះកម្មដែលខ្ញុំព្រះអង្គធ្វើហើយទេ ខ្ញុំព្រះអង្គមិនជ្រាបសូម្បីការដែលបរិស័ទរបស់ពួកនិគ្រន្ថនោះ ប្រាថ្នានឹងថ្វាយភិក្ខាចំពោះព្រះអង្គដោយចិត្តបរិសុទ្ធ ឬយ៉ាងណានោះទេ ដូច្នេះ សូមព្រះអង្គទ្រង់ពិចារណាសិន បើសមគួរសូមព្រះអង្គទ្រង់ទទួលចុះ បើមិនសមគួរសូមព្រះអង្គកុំទទួល" ។ ព្រះសាស្តាទ្រង់ពិចារណាថា "គរហទិន្នប្រាថ្នានឹងថ្វាយភត្តចំពោះតថាគត ឬក៏មិនមែនហ្ន៎" ទ្រង់បានឃើញថា "គរហទិន្ននោះ ឲ្យគេជីករណ្តៅធំមួយចន្លោះផ្ទះពីរខ្នង ហើយឲ្យគេនាំឈើគគីរមកប្រមាណ ៨០ រទេះ ដុតហើយ ត្រូវការនឹងឲ្យតថាគតធ្លាក់ចុះទៅក្នុងរណ្តៅរងើកភ្លើង ហើយ

សង្កត់សង្កិនតថាគត" ព្រះសាស្តា ក៏ទ្រង់ពិចារណាទៀតថា "ហេតុក្នុងការទៅទីនោះ ប្រយោជន៍នឹងមាន ឬក៏មិនមានទេ" លំដាប់នោះ ទ្រង់បានឃើញហេតុនេះថា "តថាគតនឹងជាន់លើរណ្ដៅរងើកភ្លើង កន្ទេលផែនដែលគ្របពីលើរណ្ដៅរងើកភ្លើងនោះនឹងបាត់ទៅ ផ្កាឈូកធំប្រមាណប៉ុនកង់រទេះ នឹងផុសឡើងទម្លាយនូវរណ្ដៅរងើកភ្លើងនោះ កាលបើដូច្នោះ តថាគតនឹងជាន់លើត្របកផ្កាឈូកទៅអង្គុយលើអាសនៈ ភិក្ខុទាំង ៥០០ រូប ក៏ដូច្នោះ មហាជននឹងមកប្រជុំគ្នាតថាគតនឹងធ្វើការអនុមោទនាដោយគាថា ២ គាថា ក្នុងសមាគមនោះ ក្នុងវេលាចប់ទេសនា ការត្រាស់ដឹងធម៌នឹងមានដល់សត្វ ៨៤.០០០ សិរីគុត្ត និងគរហទិន្ន នឹងបានជាសោតាបន្ន ហើយចំណាយគំនរទ្រព្យរបស់ខ្លួនក្នុងសាសនាការដែលតថាគតអាស្រ័យកុលបុត្រនេះ ហើយទៅកាន់ទីនោះ រមែងសមគួរ" លុះទ្រង់មានព្រះតម្រិះដូច្នោះហើយ ទើបទ្រង់ទទួលការនិមន្តរបស់គរហទិន្ន ។ សិរីគុត្តដឹងថា ព្រះសម្មាសម្ពុទ្ធទ្រង់ទទួលការនិមន្តហើយ ទើបប្រាប់គរហទិន្នថា "ម្នាលសម្លាញ់ លោកចូរធ្វើសក្ការៈដល់ព្រះលោកជេដ្ឋៈចុះ" ។

## គរហទិន្នត្រៀមទទួលព្រះសាស្តា

គរហទិន្នគិតថា "ឥឡូវនេះ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់ព្រះសមណគោតមហើយ" ទើបឲ្យគេជីករណ្ដៅមួយធំទុកក្នុងចន្លោះផ្ទះពីរខ្នង ឲ្យនាំឈើគគីរប្រមាណ ៨០ រទេះ ហើយឲ្យដុតធ្វើជារងើក អស់មួយយប់ទល់ភ្លឺ ហើយបញ្ជាឲ្យគេធ្វើគំនររងើកភ្លើងលើឈើដែលរៀបទៅលើមាត់រណ្ដៅ ឲ្យបិទដោយ

កន្ទេលផែង ឲ្យលាបដោយអាចម៍គោ ក្រាលកំណាត់ឈើពុកទុកម្ខាងហើយ ឲ្យធ្វើផ្លូវជាទីទៅ ដោយគិតថា "ក្នុងវេលាដែលពួកសមណៈជាន់ហើយយ៉ាង នេះ កាលបើកំណាត់ឈើទាំងឡាយបាក់ ពួកសមណៈក៏រមៀលធ្លាក់ទៅក្នុង រណ្ដៅរងើកភ្លើង" ឲ្យគេតម្កល់ពាងទុកខាងក្រោយផ្ទះ ដូចពិធីដែលសិរិគុត្ត ធ្វើហើយដែរ ឲ្យក្រាលអាសនៈទាំងឡាយទុកយ៉ាងនោះដែរ ។ សិរិគុត្តទៅ ផ្ទះរបស់គរហទិន្នទោះតាំងអំពីព្រលឹម ហើយសួរថា "ម្នាលសម្លាញ់ សម្លាញ់ ឯងរៀបចំគ្រឿងសក្ការៈហើយឬ ?" ។

គរហទិន្ន. អើសម្លាញ់ ខ្ញុំរៀបរួចហើយ ។

សិរិគុត្ត. ម្នាលសម្លាញ់ គ្រឿងសក្ការៈនោះនៅទីណា ?

គរហទិន្នឆ្លើយថា "ចូរមកសម្លាញ់ យើងនឹងទៅមើល" ហើយសម្ដែង វត្ថុទាំងអស់ ដោយពិធីដែលសិរិគុត្តសម្ដែងហើយនោះ ។ សិរិគុត្តពោលថា "ប្រពៃហើយសម្លាញ់" ។ ក៏កាលព្រះសាស្ដា ដែលពួកមិច្ឆាទិដ្ឋិនិមន្តហើយ ការប្រជុំធំរមែងមាន ចំណែកពួកមិច្ឆាទិដ្ឋិ រមែងមកប្រជុំគ្នាដោយគិតថា "ពួក យើងនឹងឃើញអាការដ៏ប្លែករបស់ព្រះសមណគោតម" ។ ចំណែកពួកដែល ជាសម្មាទិដ្ឋិ រមែងមកប្រជុំគ្នាដោយគិតថា "ថ្ងៃនេះព្រះសាស្ដានឹងទ្រង់សម្ដែង ធម៌ទេសនាយ៉ាងធំ ពួកយើងនឹងដឹងពុទ្ធវិស័យ ពុទ្ធលីលា" ថ្ងៃស្អែកឡើង ព្រះសាស្ដាយាងទៅកាន់ខ្លោងទ្វារផ្ទះរបស់គរហទិន្ន ព្រមជាមួយនឹងភិក្ខុ ៥០០ រូប គរហទិន្នទោះចេញអំពីផ្ទះហើយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ឈរ

ប្រណម្យអញ្ជលីនៅខាងមុខព្រះភក្ត្រព្រះសាស្ដា បានគិតថា "ព្រះអង្គដ៏ចម្រើន ឧបដ្ឋាករបស់ព្រះអង្គប្រាប់ខ្ញុំព្រះអង្គថា ព្រះអង្គរមែងជ្រាបនូវហេតុគ្រប់យ៉ាង មានហេតុដែលជាអតីតជាដើម រមែងដឹងចិត្តរបស់សត្វទាំងឡាយដោយអាការ ១៦ យ៉ាង បើព្រះអង្គទ្រង់ជ្រាប សូមព្រះអង្គកុំយាងចូលទៅកាន់ផ្ទះរបស់ខ្ញុំព្រះអង្គ ព្រោះកាលព្រះអង្គស្ដេចយាងចូលទៅហើយ យាគូមិនមានទេ ភត្តជាដើមក៏មិនមានដែរ ក៏ឯខ្ញុំព្រះអង្គនឹងញ៉ាំងព្រះអង្គ ព្រមទាំងភិក្ខុទាំងអស់ឲ្យធ្លាក់ទៅក្នុងរណ្ដៅរងើកភ្លើង ហើយសង្កត់សង្កិនបៀតបៀន" លុះគិតយ៉ាងនោះហើយ ទើបទទួលបាត្ររបស់ព្រះសាស្ដា ក្រាបទូលថា "សូមព្រះមានព្រះភាគ ស្ដេចយាងទៅតាមផ្លូវនេះ" ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែលមកកាន់ផ្ទះរបស់ខ្ញុំព្រះអង្គ ដឹងធម្មទំនៀមហើយមក ទើបគួរ" ។

ព្រះសាស្ដា. ម្នាលគរហទិន្ន តថាគតធ្វើយ៉ាងណា ទើបគួរ ។

គរហទិន្ន. ក្នុងពេលដែលភិក្ខុមួយរូបៗ ចូលទៅខាងមុខ អន្ទុយហើយ ភិក្ខុដទៃមកខាងក្រោយ ទើបគួរ ។

បានឮថា គរហទិន្ននោះ មានការគិតយ៉ាងនេះថា "ភិក្ខុដ៏សេសឃើញភិក្ខុខាងមុខធ្លាក់រណ្ដៅរងើកភ្លើងហើយ នឹងមិនមក យើងនឹងឲ្យភិក្ខុធ្លាក់ម្ដងមួយរូបៗ ប៉ុណ្ណោះ ហើយបៀតបៀន" ។ ព្រះសាស្ដាទ្រង់ត្រាស់ថា "ប្រពៃហើយ គរហទិន្ន" ហើយស្ដេចយាងចូលទៅតែមួយព្រះអង្គឯង ។ គរហទិន្ន

ទៅដល់រណ្តៅរងើកភ្លើងហើយ ថយចេញទៅឈរខាងក្រៅ ក្រាបទូលថា "សូមព្រះអង្គស្តេចយាងទៅខាងមុខចុះ" ។

គរហទិន្នជ្រះថ្លានឹងព្រះពុទ្ធជាម្ចាស់

លំដាប់នោះ ព្រះសាស្តាទ្រង់ឈានព្រះបាទជាន់លើរណ្តៅរងើកភ្លើង កន្ទេលផែនបាត់ទៅ ផ្កាឈូកប្រមាណប៉ុនកង់រទេះផុសឡើង ទម្លាយរណ្តៅរងើកភ្លើងនោះ ។ ព្រះសាស្តាទ្រង់ជាន់ត្របកផ្កាឈូក ស្តេចក៏យាងប្រថាប់លើពុទ្ធាសនៈ ដែលគេក្រាលទុក សូម្បីភិក្ខុទាំងឡាយក៏គង់លើអាសនៈនោះដែរ សេចក្តីក្តៅក្រហាយអន្ទះអន្ទែងបានកើតឡើងអំពីកាយរបស់គរហទិន្ន ។ គាត់ចូលទៅរកសិរីគុត្តដោយរហ័ស ហើយពោលថា "ម្នាលសម្លាញ់ សូមសម្លាញ់ឯងជាទីពឹងរបស់ខ្ញុំ" ។

សិរីគុត្ត. ម្នាលសម្លាញ់ តើមានហេតុអ្វី ។

គរហទិន្ន. ម្នាលសម្លាញ់ បបរ ឬកត្តជាដើម ដើម្បីភិក្ខុ ៥០០ រូប មិនមានក្នុងផ្ទះខ្ញុំទេ តើខ្ញុំធ្វើដូចម្តេចហ្ន៎ ។

សិរីគុត្ត. ម្នាលសម្លាញ់ តើសម្លាញ់ឯងបានធ្វើអ្វី ។

គរហទិន្ន. ខ្ញុំឲ្យមនុស្សធ្វើរណ្តៅធំក្នុងរវាងផ្ទះពីរខ្នង ពេញដោយរងើកភ្លើង ដោយបំណងថា "នឹងឲ្យពួកភិក្ខុធ្លាក់ទៅក្នុងរណ្តៅរងើកភ្លើងនោះ ហើយបៀតបៀន" ។ ពេលនោះ ផ្កាឈូកធំផុសឡើងទម្លាយរងើកភ្លើងនោះ ភិក្ខុទាំងអស់ជាន់លើត្របកផ្កាឈូក ទៅគង់លើអាសនៈដែលគេក្រាលទុក ឥឡូវ

នេះ ខ្ញុំនឹងត្រូវធ្វើដូចម្ដេច ។

សិរីគុត្ត. សម្លាញ់ឯងប្រាប់ខ្ញុំយ៉ាងនេះថា "ពាងបបរប៉ុណ្ណេះ ពាងកត្តជាដើមប៉ុណ្ណេះ មិនមែនឬ ។

គរហទិន្ន. ម្នាលសម្លាញ់ នោះកុហកទេ ពាងទទេ ទទេតើ ។

សិរីគុត្ត. ណ្ហើយចុះ សម្លាញ់ឯងចូរពិនិត្យមើលបបរជាដើមក្នុងពាងទាំងនោះមើល ។

ក្នុងខណៈនោះឯង បបរក្នុងពាងទាំងឡាយណាដែលគរហទិន្នទោះប្រាប់ហើយ ពាងទាំងនោះក៏ពេញដោយបបរ កត្តជាដើមក្នុងពាងណាដែលគរហ-ទិន្នប្រាប់ហើយ ពាងទាំងនោះក៏បានពេញហើយ ដោយកត្តជាដើមនោះឯង ។ ព្រោះការបានឃើញសម្បត្តិបែបនោះ សរីរៈរបស់គរហទិន្ន ពេញដោយបីតិនិងបាមោជ្ជៈ ចិត្តក៏ជ្រះថ្លាហើយ ។ គាត់អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយគោរព ប្រាថ្នានឹងឲ្យទ្រង់អនុមោទនា ទើបទទួលបាត្ររបស់ព្រះសាស្តា ដែលទ្រង់ធ្វើភត្តកិច្ចរួចស្រេចហើយ ។

សត្វមិនដឹងគុណព្រះសាស្តាព្រោះមិនមានបញ្ញា

ព្រះសាស្តាកាលនឹងអនុមោទនា ទ្រង់ត្រាស់ថា "សត្វទាំងនេះ មិនដឹងគុណសាវករបស់តថាគត និងព្រះពុទ្ធសាសនា ព្រោះមិនមានបញ្ញាចក្ខុ ទើបឈ្មោះថា ជាអ្នកខ្វាក់ អ្នកមានបញ្ញា ឈ្មោះថា មានចក្ខុ" ដូច្នេះ ហើយបានត្រាស់ព្រះគាថាទាំងនេះថា ៖

យថា សង្ការធានស្មឹ ឧជ្ឈិតស្មឹ មហាបថេ
បទុមំ តត្ថ ជាយេថ សុចិគន្ធំ មនោរមំ
ឯវំ សង្ការភូតេសុ អន្ធភូតេ បុថុជ្ជនេ
អតិរោចតិ បញ្ញាយ សម្មាសម្ពុទ្ធសាវកោ ។

ផ្កាឈូក ទុកជាកើតក្នុងទីគំនរសម្រាម ដែលគេចាក់
ចោលក្បែរផ្លូវធំនោះ ក៏គង់មានក្លិនក្រអូប ជាទីរីករាយ
នៃចិត្តបាន ដូចម្ដេចមិញ បណ្ដាជនដែលដូចជាគំនរ
សម្រាម សាវករបស់ព្រះសម្មាសម្ពុទ្ធ រមែងរុងរឿង
កន្លងផុតបុថុជ្ជនទាំងឡាយ ដែលល្ងិតល្ងង់ដោយប្រាជ្ញា
(របស់ខ្លួន) ដូច្នោះឯង ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា សង្ការធានស្មឹ (ក្នុងគំនរសម្រាម) គឺ ក្នុងទីដែលចោលសម្រាម អធិប្បាយថា ក្នុងគំនរសម្រាម ។ បទថា ឧជ្ឈិតស្មឹ មហាបថេ (ដែលបុគ្គលចោលហើយ ជិតផ្លូវធំ) គឺ ដែលបុគ្គលចាក់ចោលក្បែរផ្លូវធំ ។ បទថា សុចិគន្ធំ (មានក្លិនល្អ) គឺ មានក្លិនក្រអូប ។ បទថា មនោរមំ (ជាទីពេញចិត្ត) មានវិគ្រោះថា ចិត្តរមែងរីករាយក្នុងផ្កាឈូកនោះ ហេតុនោះ ផ្កាឈូកនោះឈ្មោះថា ជាទីរីករាយនៃចិត្ត ។ បទថា សង្ការភូតេសុ (ក្នុងកណ្ដាលបុថុជ្ជនអ្នកកើត ដូចគំនរសម្រាម) គឺ ដូចជាគំនរសម្រាម ។

បទថា បុថុជ្ជនេ (នូវបុថុជ្ជន) សេចក្តីថា ដែលលោកិយមហាជនទាំងឡាយ អ្នកមានឈ្មោះយ៉ាងនោះ ព្រោះញ៉ាំងកិលេសដ៏ក្រាស់ឲ្យកើត ។

ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះទុកថា "ផ្កាឈូកមានក្លិនក្រអូប ដែលដុះក្នុងគំនរសម្រាម ដែលបុគ្គលបោះចោលក្បែរផ្លូវធំ សូម្បីមិនស្អាត គួរខ្ពើម បដិកូល ផ្កាឈូកនោះ រមែងជាទីរីករាយនៃចិត្ត បានដល់ រមែងជារបស់គួរប្រតិស្ឋានទុកលើសិរសារបស់តស្សរជនទាំងឡាយ មានព្រះរាជា និងមហាមាត្យរបស់ព្រះរាជាជាដើម ដូចម្តេចមិញ សាវករបស់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ គឺ ភិក្ខុជាខីណាស្រព ក៏ដូច្នោះដែរ សូម្បីកើតក្នុងរវាងមហាជនអ្នកគ្មានបញ្ញា អ្នកមិនមានចក្ខុ ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ដោយកម្លាំងនៃបញ្ញារបស់ខ្លួន ចេញបួសហើយ រមែងរុងរោចន៍ គឺ ប្រសើរជាងពពួកបុថុជ្ជន ដែលដូចជាគំនរសម្រាម សូម្បីដោយគុណ គឺ បព្វជ្ជា ដែលមានខ្លួនប្រកបហើយដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ សូម្បីគុណត្រឹមតែបព្វជ្ជានោះក៏ក្រៃលែង ក៏រមែងរុងរឿង គឺ ល្អប្រសើរកន្លងនូវបុថុជ្ជនដែលល្ងីតល្ងង់ទាំងឡាយ" ។

គរហទិន្ន និងសិរីគុត្តបានសម្រេចសោតាបត្តិផល

ក្នុងវេលាចប់ទេសនា ការត្រាស់ដឹងធម៌ ក៏កើតមានហើយដល់សត្វ

៨៤.០០០ ។ គរហទិន្ន និងសិរិគុត្តបានសម្រេចសោតាបត្តិផល អ្នកទាំងពីរនោះ បានសាបព្រោះទ្រព្យទាំងអស់ក្នុងព្រះពុទ្ធសាសនា ចំណែកព្រះសាស្តាស្តេចក៏ក្រោកចាកអាសនៈយាងទៅកាន់វិហារវិញ ។

ភិក្ខុទាំងឡាយ បានញ៉ាំងនូវកថាឲ្យតាំងឡើងក្នុងសាលាធម្មសភាក្នុងវេលាល្ងាចថា "គួរឲ្យជ្រះថ្លាណាស់ ធម្មតាគុណរបស់ព្រះពុទ្ធជាម្ចាស់គួរឲ្យអស្ចារ្យ ផ្កាឈូកបានផុសឡើងទម្លាយគំនររងើកភ្លើងគគីរបែបនោះ" ព្រះសាស្តាស្តេចយាងមក ហើយទ្រង់ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះពួកអ្នកអង្គុយប្រជុំគ្នាដោយកថាអ្វី?" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ" ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ផ្កាឈូកទាំងឡាយផុសឡើងអំពីគំនររងើកភ្លើង ដើម្បីតថាគតជាព្រះពុទ្ធ ក្នុងកាលឥឡូវនេះមិនគួរឲ្យអស្ចារ្យឡើយ ក្នុងកាលមុន ផ្កាឈូកនោះផុសឡើងដើម្បីតថាគតសូម្បីនៅជាព្រះពោធិសត្វដែលកំពុងបំពេញនូវចំណែកនៃញាណ" កាលភិក្ខុទាំងនោះទូលអារាធនាថា "ក្នុងកាលណា ព្រះអង្គ សូមព្រះមានព្រះភាគ ទ្រង់ត្រាស់ប្រាប់ខ្ញុំព្រះអង្គទាំងឡាយ" ទើបទ្រង់នាំអតីតនិទានមក ត្រាស់ **ខទីរង្គារជាតក** នេះឲ្យពិស្តារថា ៖

*យើងមានជើងឡើងខាងលើ មានក្បាលចុះខាងក្រោម ហើយ*

ធ្លាក់ទៅកាន់រណ្តៅដោយពិត យើងនឹងមិនធ្វើនូវកម្មដែលមិន

មែនជារបស់ព្រះអរិយៈ សូមលោកទទួលនូវជុំបាយចុះ ដូច្នេះ ។

ចប់ រឿងគរហទិន្ន

## ចប់ បុប្ផវគ្គវណ្ណនា វគ្គទី ៤

ក្នុងវគ្គនេះរួមមាន ១២រឿង

១. រឿងភិក្ខុ ៥០០ រូប ខ្វល់ខ្វាយក្នុងបឋវីកថា
២. រឿងព្រះថេរៈអ្នកចម្រើនមរីចិកម្មដ្ឋាន
៣. រឿងព្រះទានវិឌូឌភៈ
៤. រឿងនាងបតិបូជិកា
៥. រឿងកោសិយសេដ្ឋី
៦. រឿងបាជិកាជីវក
៧. រឿងឆត្តបាណិឧបាសក
៨. រឿងនាងវិសាខា
៩. រឿងបញ្ហារបស់ព្រះអានន្ទ
១០. រឿងការថ្វាយបិណ្ឌបាតដល់ព្រះមហាកស្សបៈ
១១. រឿងការបរិនិព្វានរបស់ព្រះគោធិកត្ថេរ
១២. រឿងគរហទិន្នៈ

# ពាលវគ្គ ទី ៥

"ពោលដោយពួកបុគ្គលពាល "

## ១. រឿងបុរសម្នាក់

[១៥] *ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះបាទបសេនទិកោសល និងបុរសម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា* ***ទីឃា ជាគរតោ រត្តិ (រាត្រីយូរ របស់អ្នកដេកមិនលក់)*** *ជាដើម ។*

ព្រះរាជាប្រទក្សិណាព្រះនគរ

*បានឮថា ក្នុងថ្ងៃមហោស្រពមួយ ព្រះរាជាទ្រង់ព្រះនាមថា បសេនទិកោសល ស្តេចឡើងកាន់ដំរីសសុទ្ធមួយឈ្មោះ បុណ្ឌរីកៈ ដែលប្រដាប់តុបតែងហើយ ទ្រង់ប្រទក្សិណព្រះនគរដោយអានុភាពនៃព្រះរាជាដ៏ធំ ។ កាលអាជ្ញា ជាហេតុដេញឲ្យបុគ្គលចៀសចេញ កំពុងប្រព្រឹត្តទៅ មហាជនត្រូវរាជបុរសប្រហារដោយវត្ថុទាំងឡាយ មានដំបងជាដើម រត់ទៅបណ្តើរ បែរមើលព្រះរាជាបណ្តើរ ។ បានឮថា ការបែរមើលរបស់មហាជននោះ ជាផលនៃទានដែលព្រះរាជាទាំងឡាយទ្រង់ថ្វាយដោយល្អហើយ ។*

អំណាចនៃសេចក្តីស្រឡាញ់

*កិរិយារបស់ទុគ្គតបុរសម្នាក់ ឈរនៅត្រង់ផ្ទៃប្រាសាទជាន់ទី ៧ គ្រាន់*

តែបើកបង្អួចមើលព្រះរាជាហើយ ក៏បិទទៅវិញ ។ ការគេចចេញរបស់ស្ត្រីនោះ បានប្រាកដដល់ព្រះរាជា ដូចជាព្រះច័ន្ទពេញវង់ចូលទៅកាន់ចន្លោះនៃស្រទាប់ពពក ។ ព្រះរាជាក៏ទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធចំពោះស្ត្រីនោះ ព្រះរាជាមានអាការហាក់ដូចជាចង់ធ្លាក់ចុះអំពី.កដំរី ទ្រង់ធ្វើប្រទក្សិណព្រះនគរយ៉ាងប្រញាប់ហើយ ស្តេចចូលទៅកាន់បុរី ត្រាស់សួរអាមាត្យដែលស្និទ្ធស្នាលនឹងព្រះអង្គថា "ប្រាសាទដែលយើងសម្លឹងមើលក្នុងទីឯណោះ តើអ្នកបានឃើញដែរឬទេ?" ។

អាមាត្យ. ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គបានឃើញ ។

ព្រះរាជា. តើអ្នកឯងបានឃើញស្ត្រីម្នាក់លើប្រាសាទនោះទេ ។

អាមាត្យ. ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គបានឃើញដែរ ។

ព្រះរាជា. អ្នកឯងចូរទៅស៊ើបឲ្យបានដឹងច្បាស់ថា ស្ត្រីនោះមានស្វាមីហើយ ឬក៏មិនទាន់មានទេ ។

អាមាត្យនោះទៅហើយ បានដឹងច្បាស់ថាស្ត្រីនោះមានស្វាមីហើយ ក៏ត្រឡប់មកក្រាបទូលព្រះរាជាថា "ស្ត្រីនោះមានស្វាមីហើយ" ។ គ្រានោះព្រះរាជាត្រាស់ថា "បើដូច្នោះ អ្នកចូរទៅហៅស្វាមីរបស់ស្ត្រីនោះមក" អាមាត្យនោះក៏ទៅកាន់សំណាក់បុរសនោះ ហើយនិយាយថា "នែ! អ្នកដ៏ចម្រើន ព្រះរាជាត្រាស់ឲ្យហៅលោក" បុរសគិតថា "ភ័យកើតឡើងដល់យើងព្រោះអាស្រ័យកិរិយារបស់យើង" កាលមិនអាចទទឹងទាស់នឹងព្រះរាជអាជ្ញា ក៏ទៅថ្វាយបង្គំ

ព្រះរាជា ហើយឈរនៅក្នុងទីដ៏សមគួរមួយ ។ គ្រានោះ ព្រះរាជាត្រាស់ទៅកាន់បុរសនោះថា “អ្នកឯងចូរនៅបម្រើយើង” ។

បុរស. បពិត្រព្រះសម្មតិទេព កុំឡើយ ខ្ញុំព្រះអង្គធ្វើការងាររបស់ខ្លួន ហើយថ្វាយសួយដល់ព្រះអង្គ ការចិញ្ចឹមជីវិតនុ៎ះឯង សូមមានដល់ខ្ញុំព្រះអង្គចុះ ។

ព្រះរាជាត្រាស់ថា “យើងមិនត្រូវការសួយរបស់អ្នកឯងទេ ចាប់តាំងពីថ្ងៃនេះទៅ អ្នកឯងចូរនៅបម្រើយើង ហើយបញ្ជារាជបុរសឲ្យព្រះរាជទានខែល និងអាវុធដល់បុរសនោះ ។

បានឮថា ព្រះរាជាទ្រង់មានព្រះតម្រិះយ៉ាងនេះថា យើងនឹងលើកនូវទោសអ្វីមួយរបស់គេឡើង ហើយសម្លាប់ចោល យកប្រពន្ធ ។ គ្រានោះ គេភ័យខ្លាចស្លាប់ ក៏បម្រើព្រះរាជាដោយសេចក្តីមិនប្រមាទ ។ ព្រះរាជាទ្រង់មិនឃើញឱកាស (ទោស) របស់បុរស កាលសេចក្តីក្រោលរាលព្រោះកាមចម្រើនឡើងហើយ ក៏ទ្រង់ព្រះតម្រិះថា “យើងនឹងលើកទោសអ្វីមួយរបស់បុរសនោះឡើង ដាក់រាជអាជ្ញា” ទើបបញ្ជាឲ្យហៅបុរសនោះមក ហើយត្រាស់យ៉ាងនេះថា “អ្នកដ៏ចម្រើន ឯងចូរទៅកាន់ទីឯណោះនៃស្ទឹង ក្នុងទីបំផុតប្រមាណ ៥ យោជន៍ នាំយកផ្កាកុមុទ ផ្កាឧប្បល និងដីពណ៌អរុណមក (ឲ្យទាន់) ពេលយើងស្រង់ទឹកក្នុងវេលាល្ងាច ប្រសិនបើឯងមកមិនទាន់ក្នុងពេលនោះទេ យើងនឹងដាក់អាជ្ញាដល់ឯង” ។

## សេចក្តីលំបាកក្នុងរាជសំណាក់

បានឮថា សេវកៈ (អ្នកចូលគាល់) លំបាកជាងទាសៈសូម្បីទាំង ៤ ។ ពិតណាស់ ទាសៈទាំងឡាយ មានទាសៈដែលគេលោះមកដោយទ្រព្យជាដើម រមែងនឹងបានពោលថា "ខ្ញុំឈឺក្បាល ខ្ញុំឈឺខ្នង" ហើយសម្រាក ។

ពាក្យដែលទាសៈទាំងឡាយពោលហើយ បានសម្រាកនោះ រមែងមិនមានដល់សេវកៈ ការងារណាដែលព្រះរាជាទ្រង់បញ្ជាហើយ សេវកៈត្រូវតែធ្វើតាមបង្គាប់ប៉ុណ្ណោះ ព្រោះហេតុនោះ បុរសនោះក៏គិតថា "យើងត្រូវទៅដោយពិត ដែលឈ្មោះថា ដីពណ៌អរុណ និងផ្កាកុមុទ ព្រមទាំងផ្កាឧប្បល រមែងមានក្នុងពិភពនាគ យើងនឹងបានអំពីទីណា" សេចក្តីភ័យខ្លាចដល់មរណៈ ទើបទៅផ្ទះ ហើយសួរភរិយាថា "ម្នាលនាងដ៏ចម្រើន កត្តសម្រាប់ខ្ញុំសម្រេចហើយឬនៅ" ភរិយាឆ្លើយថា "អ្នក នៅលើចង្ក្រាននៅឡើយ" ។ បុរសនោះមិនអាចរង់ចាំដរាបដល់ភរិយាដាក់កត្តចុះបាន ក៏ប្រាប់ឲ្យភរិយាយកវែកដួសទឹកបាយ (លាយ) នឹងបាយដែលមិនទាន់ឆ្អិននោះឯង ដាក់ក្នុងស្មុកយកទៅធ្វើដំណើរទៅយ៉ាងលឿនបានចម្ងាយផ្លូវមួយយោជន៍ ។

កាលគេកំពុងធ្វើដំណើរទៅនោះឯង កត្តក៏បានឆ្អិនហើយដែរ ។ គេក៏រំលែកកត្តទុកបន្តិច ធ្វើមិនឲ្យជារបស់សំណល់ ហើយបរិភោគ បានជួបអ្នកដំណើរម្នាក់ក៏ពោលថា "អ្នកដ៏ចម្រើន កត្តខ្ញុំតិចតួចប៉ុណ្ណោះ ខ្ញុំរំលែកចេញធ្វើមិនឲ្យជារបស់សំណល់ លោកចូរទទួលយកបរិភោគចុះ" ។ អ្នកដំណើរ

នោះ ក៏ទទួលយកទៅបរិភោគ ។ ឯបុរសដែលទទួលរាជបញ្ជារបស់ព្រះរាជា បរិភោគហើយ ក៏បាចបាយទៅក្នុងទឹកមួយក្ដាប់ ខ្ពុរមាត់ហើយ ប្រកាសឡើង ៣ ដង ដោយសំឡេងខ្លាំងៗ ថា "សូមពួកនាគ គ្រុឌ និងទេវតាដែលអាស្រ័យនៅក្នុងប្រទេសនៃស្ទឹងនេះ ចូរស្ដាប់ពាក្យរបស់ខ្ញុំ ព្រះរាជាទ្រង់ប្រាថ្នានឹងដាក់អាជ្ញាដល់ខ្ញុំ ទ្រង់ត្រាស់បង្គាប់ខ្ញុំថា អ្នកចូរនាំយកដីពណ៌អរុណ និងផ្កាកុមុទព្រមទាំងផ្កាឧប្បលមក ក៏កត្តដែលខ្ញុំឲ្យដល់មនុស្សអ្នកដំណើរហើយ ជាទានមានអានិសង្សទាំងពាន់ កត្តដែលខ្ញុំឲ្យដល់ត្រីទាំងឡាយក្នុងទឹក ជាទានមានអានិសង្សទាំងរយ ខ្ញុំឲ្យចំណែកបុណ្យមានប្រមាណប៉ុណ្ណោះដល់អ្នកទាំងឡាយ សូមអ្នកទាំងឡាយនាំដីពណ៌អរុណ ផ្កាកុមុទ ព្រមទាំងផ្កាឧប្បលមកឲ្យខ្ញុំ ។ ស្ដេចនាគ ដែលអាស្រ័យនៅក្នុងទីនោះ បានឮសំឡេងនោះ ទើបទៅកាន់សំណាក់នៃបុរសនោះ ដោយភេទជាមនុស្សចាស់ ពោលថា "លោកនិយាយអ្វី" បុរសនោះក៏ពោលដដែលនោះឯង កាលស្ដេចនាគពោលថា "អ្នកឲ្យចំណែកបុណ្យនោះដល់យើងឬ" ទើបពោលថា "ខ្ញុំឲ្យ លោក" កាលស្ដេចនាគសួរបញ្ជាក់ថែមទៀតថា "លោកឲ្យមែនឬ" ក៏ពោលបញ្ជាក់ថា "ខ្ញុំឲ្យពិតមែន" ស្ដេចនាគឲ្យនាំចំណែកបុណ្យមកយ៉ាងនោះអស់វារៈ ២-៣ ដងហើយ ក៏បានឲ្យដីពណ៌អរុណ ផ្កាកុមុទ ព្រមទាំងផ្កាឧប្បលដល់បុរសនោះ ។

ចំណែកព្រះរាជាទ្រង់ព្រះតម្រិះថា "ធម្មតាមនុស្សទាំងឡាយ រមែងមានមន្តច្រើន បើបុរសនោះគប្បីបាន (របស់នោះ) ដោយឧបាយណានីមួយសោត

កិច្ចរបស់យើងក៏មិនសម្រេច" ព្រះរាជាក៏ត្រាស់បង្គាប់ឲ្យបិទទ្វារ (ក្រុង) តាំងពីថ្ងៃ ហើយបញ្ជាឲ្យនាំយកកូនសោទៅកាន់សម្នាក់របស់ព្រះអង្គ ។ ចំណែកបុរសនោះ មកទាន់ពេលព្រះរាជាទ្រង់ស្រង់ទឹកដែរ ប៉ុន្តែទ្វារបិទ កាលមិនបានទ្វារចូល ក៏ហៅអ្នកយាមទ្វារ ពោលថា "លោកចូរបើកទ្វារ" ។ អ្នកយាមទ្វារពោលថា "យើងមិនអាចបើកបាន ព្រោះព្រះរាជាស្តេចឲ្យនាំកូនសោទៅកាន់សំណាក់ព្រះអង្គតាំងអំពីថ្ងៃម្ល៉េះ" ។ សូម្បីបុរសនោះប្រាប់ថា "យើងជារាជទូតលោកចូរបើកទ្វារ" កាលមិនបានទ្វារ ទើបគិតថា "ឥឡូវនេះ យើងនឹងមិនមានជីវិត យើងនឹងធ្វើដូចម្តេចហ្ន៎" ក៏បោះដុំដីស្អិតទៅខាងលើនៃធរណីទ្វារ ព្យួរផ្កាទុកខាងលើនៃធរណីទ្វារនោះ ហើយស្រែកដោយសំឡេងយ៉ាងខ្លាំងអស់វារៈ ៣ ដងថា "ម្នាលអ្នកនគរដ៏ចម្រើនទាំងឡាយ សូមអ្នកទាំងឡាយចូរដឹងនូវកិច្ចដែលខ្ញុំធ្វើតាមព្រះរាជបញ្ជារបស់ព្រះរាជាផងចុះ ព្រះរាជាទ្រង់ប្រាថ្នានឹងញុំាងយើងឲ្យវិនាសដោយហេតុមិនសមគួរ" ហើយគិតថា "យើងនឹងទៅទីណាហ្ន៎" បានសម្រេចចិត្តថា "ធម្មតាភិក្ខុទាំងឡាយ មានចិត្តទន់ភ្លន់ យើងនឹងទៅកាន់វិហារហើយដេក" ។ ធម្មតាសត្វទាំងឡាយ កាលបានទទួលនូវសេចក្តីសុខ មិនជ្រាបសូម្បីភិក្ខុទាំងឡាយមានហើយទេ លុះត្រូវសេចក្តីទុក្ខគ្របសង្កត់ទើបប្រាថ្នានឹងទៅកាន់វិហារ ព្រោះហេតុនោះ សូម្បីបុរសនោះក៏គិតថា "ទីពឹងយ៉ាងដទៃរបស់យើងមិនមាន" ទើបទៅកាន់វិហារដេកក្នុងទីដ៏សមគួរមួយ ក្នុងកាលព្រះរាជាមិនបានផ្ទុំលក់អស់មួយរាត្រី ទ្រង់រំពឹងដល់ស្ត្រីនោះ សេចក្តី

ក្រហល់ក្រហាយព្រោះកាមកើតឡើង ។ ស្តេចទ្រង់គិតថា "ក្នុងខណៈនៃរាត្រីកន្លងទៅនោះឯង យើងនឹងសម្លាប់បុរសនោះ ហើយឲ្យនាំយកស្ត្រីនោះមក" ។

រឿងរបស់ប្រេតដែលពោល ទុ ស ន សោ

ក្នុងខណៈនោះឯង បុរស ៤ នាក់ ដែលកើតក្នុងនរក ឈ្មោះលោហកុម្ភី ដែលមានជម្រៅ ៦០ យោជន៍ ត្រូវភ្លើងនរកឆេះឲ្យត្រឡប់ទៅមក ដូចជាអង្ករក្នុងឆ្នាំងដែលភ្លើងឲ្យពុះឡើងហើយ (លិចចុះទៅ) ដល់ផ្ទៃខាងក្រោម ៣ ម៉ឺនឆ្នាំ ហើយ (អណ្តែតឡើងមក) ដល់កណ្តាប់មាត់ ៣ ម៉ឺនឆ្នាំទៀត ។ សត្វនរកទាំងនោះ ងើបក្បាលឡើងក្រឡេកមើលនូវគ្នានឹងគ្នាហើយ ប្រាថ្នានឹងពោលនូវគាថាមួយម្នាក់ (ប៉ុន្តែ) មិនអាចពោលបាន ពោលបានតែម្នាក់មួយអក្សរក៏លិចចុះទៅវិញ ។ ព្រះរាជា កាលផ្ទំមិនលក់ ក៏បានឮសំឡេងនោះនៅក្នុងចន្លោះនៃមជ្ឈិមយាម ទ្រង់ខ្លាច ទ្រង់មានព្រះទ័យតក់ស្លុត ទ្រង់ព្រះតម្រិះថា អន្តរាយនៃជីវិតនឹងមានដល់យើងឬហ្ន៎ ឬថា នឹងមានដល់អគ្គមហេសី ឬថារាជសម្បត្តិរបស់យើងនឹងវិនាស ។ ព្រះរាជាមិនអាចធ្មេចព្រះនេត្រទាំងពីរបានរហូតអស់រាត្រី ។ លុះពេលអរុណរះឡើង ព្រះអង្គក៏ត្រាស់ឲ្យហៅបុរោហិតមក ហើយត្រាស់ថា "អាចារ្យ សំឡេងដែលមានសភាពគួរខ្លាច យើងបានឮក្នុងចន្លោះនៃមជ្ឈិមយាម ។ យើងមិនដឹងថា អន្តរាយនឹងមានដល់រាជសម្បត្តិ ឬដល់អគ្គមហេសី ដល់យើង ឬក៏ដល់នរណា" ព្រោះហេតុនោះ ទើបយើងឲ្យហៅលោកមក ។

## ព្រាហ្មណ៍ល្ងង់ឱ្យព្រះរាជាបូជាយញ្ញ

*បុរោហិត. បពិត្រមហារាជ សំឡេងដែលព្រះអង្គទ្រង់បានព្រះសណ្ដាប់ហើយនោះ តើដូចម្ដេច ។*

*ព្រះរាជា. លោកអាចារ្យ យើងបានឮសំឡេងទាំងនេះថា ទុ. ស. ន. សោ. លោកចូរពិចារណាមើលនូវផលដែលនឹងសម្រេចមកអំពីសំឡេងទាំងនេះមើល ។*

*ហេតុអ្វីៗ រមែងមិនប្រាកដដល់ព្រាហ្មណ៍ ហាក់ដូចជាអ្នកចូលទៅកាន់ទីងងឹតដ៏ធំ ។ បុរោហិតនោះគិតថា ក៏កាលយើងក្រាបទូលព្រះរាជាថា ខ្ញុំព្រះអង្គមិនជ្រាប លាភសក្ការៈរបស់យើងនឹងសាបសូន្យ ទើបក្រាបទូលថា “បពិត្រមហារាជ ហេតុនេះធ្ងន់ណាស់” ។*

*ព្រះរាជា. ហេតុអ្វី លោកអាចារ្យ។*

*បុរោហិត. អន្តរាយនៃជីវិត នឹងប្រាកដដល់ព្រះអង្គ ។*

*ព្រះរាជាទ្រង់តក់ស្លុតជាទ្វេគុណ ត្រាស់ថា “លោកអាចារ្យ ហេតុជាគ្រឿងការពារនូវអន្តរាយនោះមានដែរឬទេ ។*

*បុរោហិត. បពិត្រមហារាជ មាន សូមព្រះអង្គកុំខ្លាចឡើយ ខ្ញុំព្រះអង្គដឹងនូវវេទ ៣[១] ។*

---

*វេទ ៣ គឺ ឥរុវេទ ជាគម្ពីរមានគាថាពោលដល់ឈ្មោះទេវតា និងអង្វរសូមឲ្យជួយកម្ចាត់ភ័យផ្សេងៗ ១ , យជុវេទ ជាគម្ពីរពោលដល់ពិធីការក្នុងការបូជាយញ្ញ ដូចជាបួងសួងផ្សេងៗ ១ , សាមវេទ ជាគម្ពីរពោលដល់ឧបាយឈ្នះសត្រូវ ១ ។*

ព្រះរាជា. យើងបាននូវវត្ថុអ្វី ទើបសមគួរ ។

បុរោហិត. បពិត្រព្រះសម្មតិទេព ព្រះអង្គទ្រង់បូជាយញ្ញ ដោយមានសត្វមួយមុខ ១០០ គ្រប់សត្វ នឹងបានជីវិត ។

ព្រះរាជា. បាននូវសត្វអ្វីខ្លះ ទើបគួរ ។

បុរោហិតនោះ ក្រាបទូលថា កាលនឹងឲ្យចាប់បាណជាតិមួយប្រភេទៗ ឲ្យបាន ១០០ គឺ ដំរី ១០០ សេះ ១០០ គោឧសភៈ ១០០ មេគោដែលរីតយកទឹកដោះ ១០០ ពពែ ១០០ ចៀម ១០០ មាន់ ១០០ ជ្រូក ១០០ ក្មេងប្រុស ១០០ ក្មេងស្រី ១០០ ទើបគិតថា "ប្រសិនបើយើងឲ្យចាប់យកតែជំពូកម្រឹគប៉ុណ្ណោះ ជនទាំងឡាយក៏នឹងនិយាយថា បុរោហិតឲ្យចាប់យកតែសត្វដែលជារបស់ស៊ីបានសម្រាប់ខ្លួនប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឲ្យចាប់ទាំងជំពូកដំរី សេះ និងមនុស្ស (ផង)" ។ ព្រះរាជាទ្រង់ព្រះតម្រិះថា "ការរស់នៅរបស់យើងនោះឯង ជាលាភរបស់យើង" ទើបត្រាស់ថា " លោកចូរចាប់សត្វគ្រប់ប្រភេទឲ្យប្រញាប់ៗ ។ ពួកមនុស្សដែលបានទទួលព្រះរាជបញ្ជា ក៏ចាប់យកមកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

ពិតណាស់ ព្រះធម្មសង្គាហកាចារ្យ ពោលសូម្បីពាក្យនេះទុកក្នុងកោសលសំយុត្តថា "ក៏ក្នុងសម័យនោះ យញ្ញធំជាអាការប្រាកដដោយចំពោះដល់ព្រះបាទបសេនទិកោសលហើយ គោឧសភៈ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ ត្រូវគេនាំចូលទៅរកសសរយញ្ញ

ហើយ ដើម្បីប្រយោជន៍ដល់យញ្ញ សូម្បីពួកជនណារបស់ព្រះបាទបសេនទិ-កោសលនោះ គឺ ទាសៈក្តី ទាសីក្តី អ្នកបម្រើក្តី កម្មករក្តី សូម្បីជនទាំងនោះក៏ត្រូវអាជ្ញាគម្រាមហើយ ត្រូវភ័យគម្រាមហើយ ក៏មានមុខទទឹកជោកដោយទឹកភ្នែក ស្រែកយំ ធ្វើនូវបរិកម្មទាំងឡាយ (ការខ្សឹកខ្សួល) ។

ព្រះនាងមល្លិកាទ្រង់ដោះទុក្ខរបស់សត្វ

មហាជនទួញយំរៀបរាប់ដល់ញាតិរបស់ខ្លួន បានធ្វើនូវសំឡេងលាន់ឮយ៉ាងខ្លាំង សំឡេងនោះ ដូចជាសំឡេងស្រុតផែនដី ។ គ្រានោះ ព្រះនាងមល្លិកាទេវីទ្រង់បានឮសំឡេងនោះហើយ ស្តេចទៅកាន់រាជដំណាក់ ទូលសួរព្រះរាជាថា "បពិត្រមហារាជ ព្រោះហេតុដូចម្តេច បានជាឥន្រ្ទិយ៍របស់ព្រះអង្គមិនតាំងនៅជាប្រក្រតី ព្រះអង្គទ្រង់ប្រាកដដូចជាមិនមានវិញ្ញាណ ។

ព្រះរាជា. ប្រយោជន៍អ្វីនាង មល្លិកា នាងមិនដឹងថាអាសិរពិសចូលមកជិតត្រចៀករបស់យើងទេឬ ។

មល្លិកា. បពិត្រមហារាជ ហេតុនោះដូចម្តេច ។

ព្រះរាជា. ក្នុងចំណែកនៃរាត្រី យើងបានឮសំឡេងបែបនេះ ទើបយើងសួរបុរោហិត បុរោហិតក៏ឆ្លើយប្រាប់យើងថា អន្តរាយនៃជីវិតនឹងប្រាកដដល់ព្រះអង្គ ព្រះអង្គទ្រង់បូជាយញ្ញដោយមានសត្វ ១ ប្រភេទៗ ១០០ គ្រប់ប្រភេទហើយ នឹងរួចផុតអំពីអន្តរាយនៃជីវិតបាន ម្នាលនាងមល្លិកា យើងបានគិតឃើញថា ជីវិត គឺ ការរស់នៅរបស់យើងប៉ុណ្ណោះ គឺ ជាលាភរបស់យើង

ទើបយើងឲ្យចាប់សត្វទាំងឡាយនេះទុក ។

ព្រះនាងមល្លិកាទេវីក្រាបទូលថា "បពិត្រមហារាជ ព្រះអង្គជាមនុស្ស អន្ធពាល ទ្រង់ជាអ្នកមានកិច្ចាហារដ៏ច្រើន ព្រះអង្គរមែងសោយនូវភោជនដែលគេចម្អិនដោយអន្ទរទាំងនាឡិៗ មានសម្ល និងម្ហូបច្រើនបែបសព្វយ៉ាង ព្រះអង្គទ្រង់គ្រងរាជ្យក្នុងដែនទាំងពីរក៏ពិត ប៉ុន្តែបញ្ញារបស់ព្រះអង្គនៅទន់ខ្សោយ ។

ព្រះរាជា. ព្រោះហេតុអ្វី ទើបនាងពោលយ៉ាងនេះ ។

មល្លិកា. ការបានជីវិតរបស់អ្នកដទៃ ព្រោះតែការស្លាប់អ្នកដទៃ ព្រះអង្គធ្លាប់ឃើញក្នុងទីណា ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់ជឿពាក្យរបស់ព្រាហ្មណ៍អន្ធពាល ហើយទ្រង់ឲ្យនូវទុក្ខទៅលើមហាជនយ៉ាងនេះ ព្រះសាស្តាទ្រង់ជាអគ្គបុគ្គលនៃលោក ព្រមទាំងទេវលោក មានព្រះញាណមិនទើសទាក់ក្នុងកាលទាំងឡាយ មានអតីតកាលជាដើម ទ្រង់គង់នៅក្នុងវិហារដ៏ជិត ព្រះអង្គទូលសួរព្រះសាស្តាហើយ សូមទ្រង់ធ្វើតាមព្រះឱវាទរបស់ព្រះអង្គចុះ ។

គ្រានោះឯង ព្រះរាជាស្តេចយាងទៅកាន់វិហារជាមួយព្រះនាងមល្លិកា ដោយយានតូច ទ្រង់ត្រូវមរណភ័យគម្រាមហើយ មិនអាចទូលនូវអ្វីៗ បានថ្វាយបង្គំព្រះសាស្តាហើយ ទ្រង់គង់ក្នុងទីដ៏សមគួរមួយ ។ គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់ព្រះរាជាមុនថា "មហាបពិត្រ ស្តេចមកអំពីទីណាទាំងកណ្តាលថ្ងៃ" ព្រះរាជាក៏ទ្រង់នៅស្ងៀម ។ លំដាប់នោះ ព្រះនាងមល្លិកា ក្រាបទូលព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះរាជាទ្រង់បានឮ

សំឡេងដ៏អាក្រក់ក្នុងចន្លោះនៃមជ្ឈិមយាម ហេតុនោះ ស្ដេចក៏ទ្រង់ប្រាប់ហេតុនោះដល់បុរោហិត បុរោហិតក៏ក្រាបទូលថា អន្តរាយនៃជីវិតនឹងមានដល់ព្រះអង្គ បើព្រះអង្គចាប់សត្វមួយប្រភេទៗ ១០០ គ្រប់ប្រភេទ បូជាយញ្ញដោយលោហិតក្នុងបំពង់.កនៃសត្វទាំងនោះ ដើម្បីការពារនូវអន្តរាយនោះ ព្រះអង្គនឹងបានជីវិត ព្រះរាជាត្រាស់ឲ្យចាប់សត្វជាច្រើន ព្រោះហេតុនោះ ទើបនាងខ្ញុំព្រះអង្គនាំព្រះរាជាមកកាន់ទីនេះ ។

ព្រះសាស្ដា. បពិត្រមហារាជ យ៉ាងនោះពិតមែនឬ ។

ព្រះរាជា. ពិតមែន ព្រះអង្គ ។

ព្រះសាស្ដា. សំឡេងដែលមហារាជទ្រង់បានឮហើយ ដូចម្ដេច ។

ព្រះរាជាក្រាបទូលដោយទំនងដែលព្រះអង្គទ្រង់បានឮ ។ ពន្លឺតែមួយបានប្រាកដដល់ព្រះតថាគត ព្រោះទ្រង់ព្រះសណ្ដាប់នូវសេចក្ដីនោះ ។ គ្រានោះព្រះសាស្ដាទ្រង់ត្រាស់ទៅកាន់ព្រះរាជាថា "ព្រះអង្គទ្រង់កុំខ្លាចឡើយ អន្តរាយនៃជីវិតមិនមានដល់ព្រះអង្គទេ សត្វទាំងឡាយដែលមានកម្មដ៏លាមក កាលធ្វើទុក្ខរបស់ខ្លួនឲ្យប្រាកដច្បាស់ ទើបពោលយ៉ាងនេះ" ។ ព្រះរាជាទូលសួរព្រះសាស្ដាថា "ក៏កម្មអ្វី ដែលសត្វទាំងនោះបានធ្វើទុក ព្រះអង្គ" ។

## ព្រះសាស្ដាទ្រង់សម្ដែងទោសបរទារិកកម្ម

ព្រះមានព្រះភាគ កាលទ្រង់សម្ដែងកម្មរបស់សត្វនរកទាំងនោះ ទើបត្រាស់ថា "បើដូច្នោះ ព្រះអង្គទ្រង់ស្ដាប់ មហាបពិត្រ" ហើយទ្រង់នាំអតីត-

និទានមក (ត្រាស់) ថា ៖

ក្នុងអតីតកាល កាលមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ព្រះមានព្រះភាគ ព្រះនាម **កស្សបៈ** ទ្រង់កើតឡើងក្នុងលោក ស្តេចត្រាច់ទៅកាន់ទីចារិក មួយអន្លើដោយព្រះខីណាស្រព ២ ម៉ឺនអង្គ ស្តេចបានទៅកាន់ក្រុងពារាណសី ។ អ្នកក្រុងពារាណសី ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើននាក់ខ្លះ រួមគ្នាជាពួក ញុំាងអាគន្តុកទានឲ្យប្រព្រឹត្តទៅ ។ ក្នុងកាលនោះ ក្នុងក្រុងពារាណសី មានសេដ្ឋីបុត្រ ៤ នាក់ មានសម្បត្តិ ៤០ កោដិ ជាសម្លាញ់នឹងគ្នា សេដ្ឋីបុត្រទាំងនោះប្រឹក្សាគ្នាថា ក្នុងផ្ទះរបស់ពួកយើងមានទ្រព្យច្រើនណាស់ ពួកយើងនឹងធ្វើនូវអ្វីដោយទ្រព្យនោះ ។

កាលព្រះពុទ្ធដ៏មានព្រះភាគ ស្តេចត្រាច់ទៅកាន់ទីចារិក បណ្តាសេដ្ឋីបុត្រទាំងនោះមិនបានពោលថា ពួកយើងនឹងឲ្យនូវទាន នឹងធ្វើនូវការបូជា នឹងរក្សាសីល សេដ្ឋីបុត្រម្នាក់ពោលយ៉ាងនេះមុនថា ពួកយើងផឹកសុរា ទំពាស៊ីសាច់ដ៏ឆ្ងាញ់ ការរស់នៅរបស់យើងបែបនេះ ទើបជាជីវិតដ៏ប្រសើរ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ពួកយើងនឹងបរិភោគកត្តនៃអង្ករស្រូវសាលី មានក្លិនក្រអូបដែលគេទុកដាក់អស់ ៣ ឆ្នាំហើយ ដោយរសដ៏ប្រណីតផ្សេងៗ ត្រាច់ទៅ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ពួកយើងនឹងឲ្យគេចម្អិនរបស់ដែលគួរទំពាស៊ីដ៏ត្រកាលមានប្រការផ្សេងៗ បរិភោគ ។

ម្នាក់ទៀត ពោលយ៉ាងនេះថា ម្នាលសម្លាញ់ ពួកយើងមិនចាំបាច់ធ្វើនូវកិច្ចអ្វីដទៃទេ ស្ត្រីទាំងឡាយ កាលយើងពោលថា នឹងឲ្យទ្រព្យ ដែលឈ្មោះថា មិនប្រាថ្នា រមែងមិនមាន ព្រោះហេតុនោះ ពួកយើងរួបរួមទ្រព្យទុកហើយ នឹងល្បួង (ស្ត្រី) ធ្វើបរទារិកកម្ម (ការប្រព្រឹត្តខុសក្នុងកិរិយារបស់អ្នកដទៃ) ។ សេដ្ឋីបុត្រទាំងអស់ ក៏ព្រមព្រៀងដោយពាក្យថា "ប្រពៃហើយៗ" បានតាំងនៅក្នុងពាក្យរបស់សេដ្ឋីបុត្រទី ៤ នោះ ។ តាំងពីពេលនោះមក សេដ្ឋីបុត្រទាំងនោះបានបញ្ជូនទ្រព្យទៅឲ្យស្ត្រីដែលមានរូបស្អាតៗ ធ្វើនូវបរទារិកកម្មអស់ ២ ម៉ឺនឆ្នាំ ធ្វើកាលកិរិយាហើយ ក៏ទៅកើតក្នុងអវិចីមហានរក ។ សេដ្ឋីបុត្រទាំងនោះ ឆេះក្នុងនរកអស់មួយចន្លោះព្រះពុទ្ធ រួចអំពីនរកនោះហើយ ដោយសេសផលកម្ម ក៏កើតក្នុងលោហកុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ (លិចចុះ) ដល់ផ្ទៃខាងក្រោម ៣ ម៉ឺនឆ្នាំ (អណ្តែតឡើងមក) ដល់កណ្តាប់មាត់ខ្ទះ អស់រយៈពេល ៣ ម៉ឺនឆ្នាំទៀត ជាអ្នកប្រាថ្នានឹងពោលនូវគាថាម្នាក់មួយគាថា (ប៉ុន្តែ) មិនអាចពោលបាន ពោលបានតែអក្សរមួយម្នាក់ ហើយក៏លិចចុះទៅកាន់ខ្ទះដែកដូចដើមវិញ មហារាជ ព្រះអង្គចូរប្រាប់មកមើល តើសំឡេងដែលព្រះអង្គទ្រង់ឮលើកដំបូងនោះដូចម្តេច ។

ព្រះរាជា. សំឡេងថា ទុ. ព្រះអង្គ ។

ព្រះសាស្តា កាលនឹងត្រាស់សម្តែងគាថាដែលសត្វនរកនោះពោលមិនពេញ ឲ្យពេញ ទើបត្រាស់យ៉ាងនេះថា ៖

ទុជ្ជីវិតមជីវិម្ហា យេសន្នោ ន ទទាម្ហសេ
សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហ អត្តនោ ។

យើងទាំងឡាយណា កាលភោគៈទាំងឡាយមានហើយមិន
បានថ្វាយទាន មិនបានធ្វើទីពឹងដល់ខ្លួន ពួកយើងទាំងនោះ
ចាត់ថា មានជីវិតរស់នៅដ៏អាក្រក់ ។

លំដាប់នោះ ព្រះសាស្តា លុះទ្រង់ប្រកាសនូវអត្ថនៃគាថានេះដល់ព្រះរាជាហើយ ក៏ទ្រង់ត្រាស់សួរថា មហាបពិត្រ សំឡេងទី ២-៣-៤ តើព្រះអង្គទ្រង់ព្រះសណ្តាប់យ៉ាងណា? កាលព្រះរាជាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮយ៉ាងនេះ កាលនឹងទ្រង់ញុំាងអត្ថដ៏សេសឲ្យបរិបូណ៌ ទើបទ្រង់ត្រាស់ (គាថា) ថា ៖

សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ
និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។

កាលយើងទាំងឡាយ ត្រូវភ្លើងឆេះនៅក្នុងនរក គ្រប់ ៦ ម៉ឺន
ឆ្នាំ ដោយប្រការទាំងពួង កាលណា ទីបំផុតនឹងប្រាកដ ។

នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ
តទា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស។

អ្នកនិរទុក្ខទាំងឡាយ ទីបំផុតរមែងមិនមាន ទីបំផុតនឹងមាន
អំពីទីណា ទីបំផុតនឹងមិនប្រាកដ ព្រោះថា កម្មអាក្រក់ដែល

យើង និងលោកបានធ្វើទុកហើយក្នុងកាលនោះ ។

សោហំ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ
វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំ ពហុំ ។

យើងនោះទៅអំពីទីនេះហើយ បានកំណើតជាមនុស្ស នឹងជាអ្នកដឹងពាក្យដែលស្មូមពោល ដល់ព្រមដោយសីល និងធ្វើកុសលឲ្យបានច្រើន ។

ព្រះសាស្តា លុះទ្រង់ត្រាស់ព្រះគាថាទាំងនេះលំដាប់ ប្រកាសហើយអត្ថហើយ ទើបទ្រង់ត្រាស់ថា "មហាបពិត្រ ជនទាំង ៤ នាក់នោះ ប្រាថ្នានឹងពោលគាថាមួយម្នាក់ កាលមិនអាចពោលបាន ក៏ពោលបានតែម្នាក់មួយអក្សរប៉ុណ្ណោះ ក៏លិចចុះទៅកាន់លោហកុម្ភីវិញ ដោយប្រការដូច្នេះ ។

បានឮថា ចាប់តាំងពីកាលដែលព្រះរាជាព្រះនាម បសេនទិកោសលទ្រង់ព្រះសណ្តាប់សំឡេងនោះ ជនទាំងនោះកំពុងលិចចុះទៅខាងក្រោមរហូតមកដល់សព្វថ្ងៃនេះ មិនទាន់កន្លង ១ ពាន់ឆ្នាំនៅឡើយ ។ សេចក្តីសង្វេគយ៉ាងខ្លាំង បានកើតឡើងដល់ព្រះរាជា ព្រោះទ្រង់ស្តាប់នូវទេសនានោះ ។ ព្រះរាជាទ្រង់ត្រិះរិះថា ដែលឈ្មោះថា បរទារិកកម្មនេះ មានទោសធ្ងន់ណាស់ហ្ន៎ បានឮថា ជនទាំង ៤ នាក់ ឆេះហើយក្នុងអវិចីនរកអស់មួយចន្លោះព្រះពុទ្ធ រួចពីអវិចីនរកនោះហើយ កើតក្នុងលោហកុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ ឆេះក្នុងលោហកុម្ភីនោះអស់ ៦ ម៉ឺនឆ្នាំ កាលនឹងរួចចាកទុក្ខរបស់ជនទាំងនោះ

នៅមិនប្រាកដ សូម្បីយើងធ្វើសេចក្ដីស្នេហាក្នុងកិរិយារបស់បុរសដទៃ មិនបាន ដេកលក់អស់រាត្រីទាំងមូល ឥឡូវនេះ ចាប់តាំងពីពេលនេះទៅ យើងនឹងមិន ចងចិត្តគួចលួចស្នេហ៍នឹងស្ត្រីដែលជាកិរិយារបស់បុរសដទៃឡើយ ទើបក្រាប ទូលព្រះតថាគតថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទើបបានជ្រាបនូវរាត្រី យូរក្នុងថ្ងៃនេះ" ។ ចំណែកបុរសនោះ អង្គុយនៅក្នុងទីនោះ ស្ដាប់ពាក្យនោះ ហើយ គិតថា "បច្ច័យដ៏មានកម្លាំង យើងបានហើយ" ទើបក្រាបទូលចំពោះ ព្រះសាស្ដាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជាទ្រង់ជ្រាបនូវរាត្រីយូរក្នុងថ្ងៃ នេះ ចំណែកខ្ញុំព្រះអង្គ ក៏បានជ្រាបនូវយោជន៍វែងឆ្ងាយ ក្នុងថ្ងៃម្សិលមិញ ។ ព្រះសាស្ដា ទ្រង់ប្រៀបធៀបពាក្យរបស់ជនទាំងពីររូបនោះហើយ ត្រាស់ថា "រាត្រីនៃបុគ្គលពួកខ្លះ ជាវេលាយូរ យោជន៍របស់បុគ្គលពួកខ្លះមានប្រមាណ ឆ្ងាយ ចំណែកសង្សារវដ្ដរបស់បុគ្គលពាល រមែងមានសភាពដ៏វែង" កាល នឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ
ទីឃោ ពាលាន សំសារោ សទ្ធម្មំ អវិជានតំ ។

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក (អ្នកដេកមិនលក់)
យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្ដវែង
ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

## អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា* ***ទីឃា (យូរ)*** *ជាដើម សេចក្តីថា ឈ្មោះថារាត្រី មានត្រឹមតែបីយាមប៉ុណ្ណោះ ប៉ុន្តែសម្រាប់អ្នកភ្ញាក់ (ដេកមិនលក់) ដូចជា យូរ គឺថា រមែងប្រាកដដូចជាគុណនឹងពីរ ឬគុណនឹងបី បុគ្គលដែលខ្ជិលប្រអូស ធ្វើខ្លួនឲ្យជាចំណីនៃពួកសង្អើច ដេកប្រែប្រួលៗ រហូតដល់ព្រះអាទិត្យរះឡើងក្តី បុគ្គលអ្នកសេពកាម បរិភោគភោជនដ៏ប្រណីតហើយ ដេកលើទីដេកដ៏មានសិរីក្តី រមែងមិនដឹងថារាត្រីនោះវែង ចំណែកព្រះយោគាវចរ អ្នកប្រារព្ធនូវសេចក្តីព្យាយាមរហូតអស់រាត្រីទាំងមូលក្តី ព្រះធម្មកថិកសម្តែងព្រះធម៌កថារហូតមួយយប់ទល់ភ្លឺក្តី បុគ្គលអ្នកស្តាប់ធម៌នៅទីជិតអាសនៈរហូតមួយយប់ទល់ភ្លឺក្តី អ្នកដែលត្រូវរោគទាំងឡាយ មានរោគក្នុងក្បាលជាដើមពាល់ត្រូវហើយ ឬអ្នកដល់នូវសេចក្តីទុក្ខ មានការកាត់ដៃជើងជាដើម ត្រូវវេទនាគ្របសង្កត់ក្តី អ្នកដើរផ្លូវឆ្ងាយ ដើររហូតអស់រាត្រីទាំងមូលក្តី រមែងដឹងនូវភាវៈនៃរាត្រីនោះជាវេលាដ៏វែង ។*

*បទថា* ***យោជនំ*** *ជាដើម សេចក្តីថា សូម្បីយោជន៍ ក៏មានប្រមាណត្រឹមតែ ៤ គាវុតប៉ុណ្ណោះ តែសម្រាប់បុគ្គលអ្នកនឿយហត់ គឺ អ្នកស្បើយកម្លាំង ដូចជាវែងឆ្ងាយ គឺថា រមែងប្រាកដដល់បុគ្គលនោះ ដូចជាគុណនឹងពីរ ឬនឹងបី ។ ពិតហើយ បុគ្គលអ្នកធ្វើដំណើរអស់មួយថ្ងៃ នឿយហត់ហើយ ជួបបុរសដែលធ្វើដំណើរបញ្ច្រាសទិសគ្នា ក៏សួរថា “ស្រុកខាងមុខនៅឆ្ងាយ*

ប៉ុនណា? កាលគេប្រាប់ថា មួយយោជន៍ ដើរទៅបានបន្តិច ក៏សួរអ្នកដទៃទៀត សូម្បីកាលអ្នកដទៃនោះប្រាប់ថា មួយយោជន៍ ដើរទៅបានបន្តិចទៀត ក៏សួរអ្នកដទៃទៀត សូម្បីគេក៏ប្រាប់ថា មួយយោជន៍ បុគ្គលទាំងនោះ ត្រូវអ្នកដំណើរនោះសួរហើយសួរទៀត ក៏ប្រាប់ថា មួយយោជន៍ អ្នកដំណើរនោះរមែងគិតថា យោជន៍នេះឆ្ងាយពិតមែនហ្ន៎ រមែងសម្គាល់មួយយោជន៍ ដូចជា ២-៣ យោជន៍ ។

បទថា **ពាលានំ (របស់បុគ្គលពាលទាំងឡាយ)** ជាដើម សេចក្តីថា ចំណែកសង្សារវដ្តរបស់ជនពាលទាំងឡាយ ដែលជាអ្នកមិនដឹងនូវប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ គឺ អ្នកមិនអាចធ្វើនូវទីបំផុតនៃសង្សារវដ្ត អ្នកមិនដឹងច្បាស់នូវព្រះសទ្ធម្ម មានពោធិបក្ខិយធម៌ ៣៧ ប្រការជាដើម ដែលព្រះអរិយៈទាំងឡាយដឹងច្បាស់ហើយ ធ្វើនូវទីបំផុតនៃសង្សារវដ្តបាន រមែងឈ្មោះថា វែង ។ ពិតណាស់ សង្សារវដ្តនោះ ឈ្មោះថា វែង តាមធម្មតារបស់ខ្លួនឯង ។ សមដូចព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ សង្សារវដ្តនេះ មានខាងដើម និងខាងចុង ដែលបុគ្គលណាៗ ដឹងមិនបាន ។ ខាងដើម ខាងចុង (នៃសង្សារវដ្តនោះ) រមែងមិនប្រាកដ" ។ តែសម្រាប់ជនពាលទាំងឡាយ ដែលជាអ្នកមិនអាចធ្វើនូវទីបំផុតបាន រមែងមានសភាពដ៏វែងឆ្ងាយដោយពិត ។

ក្នុងកាលចប់ព្រះធម៌ទេសនា បុរសនោះក៏បានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិ-

ផលជាដើម ព្រះធម៌ទេសនាមានប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ឯង ។

ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ ស្តេចយាងទៅ ត្រាស់បង្គាប់ឲ្យដោះលែងសត្វទាំងនោះអំពីចំណង ។ បណ្តាមនុស្ស និងសត្វទាំងនោះ ស្ត្រី និងបុរសទាំងឡាយផុតអំពីចំណង ងូតទឹក កក់ក្បាលហើយ ទៅកាន់ផ្ទះរៀងៗខ្លួន ពោលសរសើរព្រះគុណព្រះនាងមល្លិកាថា យើងទាំងឡាយ រួចផុតចាកសេចក្តីស្លាប់ បានរស់រានមានជីវិត ព្រោះអាស្រ័យព្រះទេវីអង្គណា សូមព្រះនាងមល្លិកាទេវីអង្គនោះ ដែលជាព្រះមេម្ចាស់របស់យើងទាំងឡាយ សូមទ្រង់មានព្រះជន្មយឺនយូរចុះ ។ ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងសាលាធម្មសភាថា "គួរឲ្យសរសើរ ព្រះនាងមល្លិកានេះឆ្លាតហ្ន៎ ទ្រង់អាស្រ័យព្រះបញ្ញារបស់ខ្លួនហើយ បានឲ្យនូវជីវិតទានដល់ជនមានប្រមាណប៉ុណ្ណេះ ។

ព្រះនាងមល្លិកាធ្លាប់ជួយជនអ្នកមានទុក្ខក្នុងជាតិមុន

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំគ្នានិយាយអំពីរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "អំពីរឿងឈ្មោះនេះ" ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះនាងមល្លិកា ទ្រង់អាស្រ័យព្រះបញ្ញារបស់ខ្លួនហើយ មិនមែនឲ្យនូវជីវិតទានដល់មហាជនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ សូម្បីក្នុងកាលមុន ព្រះនាងក៏ធ្លាប់បានឲ្យហើយដែរ កាលទ្រង់ប្រកាសសេចក្តីនោះ ទើបទ្រង់នាំអតីតនិទានមក

(ត្រាស់) ថា ៖

ក្នុងអតីតកាល ឱរសរបស់ព្រះរាជាក្រុងពារាណសីចូលទៅកាន់ដើមជ្រៃមួយដើម ហើយទ្រង់បន់ស្រន់ទេវតាដែលអាស្រ័យនៅនាដើមជ្រៃនោះថា "បពិត្រទេវរាជ ក្នុងជម្ពូទ្វីបនេះ មានព្រះរាជា ១០១ ព្រះអគ្គមហេសី ១០១ ប្រសិនបើខ្ញុំនឹងបានរាជសម្បត្តិក្នុងកាលកន្លងទៅនៃព្រះបិតាសោត ខ្ញុំនឹងធ្វើនូវពលីដោយឈាមក្នុងបំពង់កនៃព្រះរាជា និងព្រះអគ្គមហេសីទាំងនោះ" ។ ព្រះកុមារនោះ កាលព្រះបិតាសោយទិវង្គតហើយ បានទទួលរាជសម្បត្តិ (សមដូចព្រះបំណង) ទ្រង់គិតថា "យើងបានទទួលរាជសម្បត្តិ ដោយអានុភាពនៃទេវតា យើងនឹងធ្វើពលីដល់ទេវតានោះ" ទើបស្តេចចេញទៅដោយសេនាដ៏ធំ ធ្វើព្រះរាជា ១ អង្គ ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួនហើយ ធ្វើព្រះរាជាអង្គដទៃ និងអង្គដទៃទៀត ឲ្យនៅក្នុងអំណាចរបស់ខ្លួន ធ្វើព្រះរាជាទាំងអស់ឲ្យនៅក្នុងអំណាចរបស់ខ្លួន ដោយប្រការដូច្នេះ ហើយទ្រង់នាំព្រះរាជា និងព្រះអគ្គមហេសីទាំងឡាយ ទ្រង់បន្សល់ទុកតែព្រះទេវីព្រះនាម **ធម្មទិន្នា** ដែលទ្រង់ព្រះគភ៌ចាស់ ដែលជាអគ្គមហេសីរបស់ព្រះរាជាព្រះនាម **ឧគ្គសេន** ដែលជាព្រះរាជាអង្គតូចជាងព្រះរាជាទាំងពួងទុក ស្តេចទៅហើយ ទ្រង់ព្រះតម្រិះថា "យើងនឹងឲ្យជនទាំងនេះផឹកទឹកលាយដោយថ្នាំពិសឲ្យស្លាប់" ទើបត្រាស់បង្គាប់ឲ្យជនទាំងឡាយជម្រះនូវគល់ឈើឲ្យស្អាត ។

ទេវតាគិតថា "ព្រះរាជាអង្គនេះ កាលចាប់ព្រះរាជាប្រមាណប៉ុណ្ណោះ ទ្រង់

អាស្រ័យយើងទើបចាប់បាន ព្រះរាជាទ្រង់ប្រាថ្នានឹងធ្វើនូវពលីកម្មចំពោះយើង ដោយលោហិតក្នុងបំពង់.ករបស់ព្រះរាជាទាំងនោះ ប្រសិនបើព្រះរាជាអង្គនេះ នឹងសម្លាប់ព្រះរាជាទាំងនោះសោត ព្រះរាជវង្សក្នុងជម្ពូទ្វីបនឹងដាច់សូន្យ សូម្បីគល់ឈើរបស់យើងក៏នឹងមិនស្អាត យើងនឹងអាចហាមព្រះរាជានោះបានឬទេហ្ន៎" ទេវតានោះពិចារណាហើយក៏ដឹងថា "យើងមិនអាច" ទើបបានចូលទៅរកទេវតាអន្តដទៃប្រាប់សេចក្តីនោះហើយ ពោលថា "លោកអាចឬ" ទេវតានោះសូម្បីទេវតា (ដែលត្រូវសួរ) នោះហាមហើយ ក៏ចូលទៅរកទេវតាក្នុងចក្រវាឡទាំងអស់យ៉ាងនេះ គឺ ចូលទៅរកទេវតាអន្តដទៃ និងអន្តដទៃ សូម្បីត្រូវទេវតាទាំងនោះហាមហើយ ទើបចូលទៅកាន់សំណាក់របស់មហារាជទាំង ៤ សូម្បីមហារាជទាំង ៤ នោះ ក៏ហាមថា "ពួកយើងមិនអាច តែព្រះរាជារបស់យើងទាំងឡាយ ជាអ្នកវិសេសជាងពួកយើងដោយបុណ្យ និងបញ្ញា អ្នកចូរទូលសួរព្រះរាជាអង្គនោះចុះ" ដូច្នេះ ទើបចូលទៅគាល់សក្កទេវរាជ ក្រាបទូលសេចក្តីនោះហើយ ទូលថា "បពិត្រព្រះឧបបត្តិទេព កាលព្រះអង្គដល់នូវភាពជាអ្នកខ្វល់ខ្វាយតិចហើយ ខត្តិយវង្សនឹងដាច់សូន្យ សូមព្រះអង្គទ្រង់ជាទីពឹងនៃខត្តិយវង្សនោះ" ។

សក្កទេវរាជត្រាស់ថា "សូម្បីយើង ក៏មិនអាចហាមព្រះរាជាអង្គនោះបានដែរ ប៉ុន្តែយើងនឹងប្រាប់ឧបាយដល់អ្នក" ហើយទ្រង់ប្រាប់ឧបាយថា ម្នាលអ្នកដ៏ចម្រើន អ្នកទៅចុះ កាលព្រះរាជាទ្រង់ឃើញអ្នកទុះឯង អ្នកចូរស្លៀក

សំពត់ពណ៌ក្រហម ហើយសម្ដែង អាការដូចជាចេញអំពីដើមឈើរបស់ខ្លួន កាលអ្នកធ្វើដូច្នោះ ព្រះរាជាអង្គនោះនឹងទ្រង់ព្រះតម្រិះថា ទេវតារបស់យើងទៅណា យើងនឹងញុំាងទេវតានោះឲ្យត្រឡប់មកវិញ ហើយអង្វរអ្នកដោយប្រការផ្សេងៗ កាលនោះ អ្នកគប្បីពោលទៅកាន់ព្រះរាជាអង្គនោះថា លោកបន់ស្រន់ចំពោះយើងថា នឹងនាំព្រះរាជា ១០១ ព្រមទាំងអគ្គមហេសីទាំងឡាយមកធ្វើពលីដោយលោហិតក្នុងបំពង់.កនៃព្រះរាជាទាំងនោះ (ប៉ុន្តែ) ទ្រង់បន្សល់ទុកនូវព្រះទេវីរបស់ព្រះបាទឧគ្គសេនហើយស្ដេចមក យើងនឹងមិនទទួលពលីកម្មរបស់បុគ្គលអ្នកច្រើនទៅដោយការនិយាយកុហក ដូចព្រះអង្គទេ កាលអ្នកពោលយ៉ាងនេះ ព្រះរាជានឹងឲ្យនាំព្រះទេវីនោះមក ព្រះទេវីនោះនឹងសម្ដែងធម៌ដល់ព្រះរាជា ឲ្យនូវជីវិតទានដល់មហាជន មានប្រមាណប៉ុណ្ណោះ” ។ សក្កទេវរាជត្រាស់ប្រាប់ឧបាយនេះដល់ទេវតាដោយហេតុនេះ ទេវតាបានធ្វើដូច្នោះ សូម្បីព្រះរាជាក៏បញ្ជាឲ្យនាំព្រះរាជទេវីនោះមកហើយ ។

## ទេវតាបូជាព្រះនាងធម្មទិន្នា

ព្រះទេវីនោះមកហើយ ថ្វាយបង្គំព្រះរាជា (ដែលជាស្វាមី) របស់ខ្លួនប៉ុណ្ណោះ សូម្បីព្រះរាជាអង្គនោះគង់ក្នុងទីបំផុតនៃព្រះរាជាទាំងនោះ ។ ព្រះរាជាទ្រង់ខ្ញាល់នឹងព្រះទេវីនោះថា “កាលយើងដែលជាអ្នកប្រសើរជាងព្រះរាជាទាំងពួងឈរនៅទីនេះ នាងហ៊ានថ្វាយបង្គំស្វាមីរបស់ខ្លួន ដែលជាព្រះរាជាតូចបំផុតជាងព្រះរាជាទាំងពួង” ។ លំដាប់នោះ ព្រះនាងធម្មទិន្នាទេវីក្រាបទូល

ព្រះរាជានោះថា "រឿងអ្វីដែលខ្ញុំព្រះអង្គត្រូវទាក់ទងនឹងព្រះអង្គទៅ ក៏ព្រះរាជាអង្គនេះ ជាស្វាមីអ្នកឲ្យនូវកាពជាធំដល់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គមិនថ្វាយបង្គំព្រះរាជាអង្គនេះហើយ នឹងថ្វាយបង្គំព្រះអង្គដូចម្តេចទៅ" កាលព្រះរាជាទាំងនោះកំពុងឃើញនោះឯង រុក្ខទេវតាក៏ពោលថា "យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន" ហើយបូជាព្រះទេវីនោះ ដោយផ្កាឈើមួយក្តាប់ ។

ព្រះរាជាត្រាស់ទៀតថា "បើនាងមិនថ្វាយបង្គំយើង ព្រោះហេតុអ្វី ទើបនាងមិនថ្វាយបង្គំទេវតារបស់យើងដែលមានអានុភាពធំយ៉ាងនេះ ជាអ្នកឲ្យនូវសិរី គឺ ភាវៈជាព្រះរាជាដល់យើង" ។ ព្រះទេវីទូលថា "បពិត្រមហារាជ ព្រះរាជាទាំងឡាយ ដែលព្រះអង្គតាំងនៅក្នុងបុណ្យរបស់ព្រះអង្គ ទ្រង់ចាប់បាននោះ មិនមែនទេវតាចាប់ថ្វាយទេ" ។ ទេវតាពោលនឹងព្រះទេវីទៀតថា "យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន" ហើយបូជាព្រះទេវីនោះ ដោយផ្កាឈើមួយក្តាប់ទៀត ។ ព្រះទេវីទូលព្រះរាជាទៀតថា "ព្រះអង្គត្រាស់ថា ព្រះរាជាទាំងឡាយមានប្រមាណប៉ុណ្ណេះ ទេវតាចាប់ឲ្យយើង" ។ ឥឡូវនេះ ដើមឈើត្រូវភ្លើងឆេះនៅខាងឆ្វេង ខាងលើនៃទេវតារបស់ព្រះអង្គព្រោះហេតុអ្វី ទើបទេវតានោះមិនអាចញុំាងភ្លើងនោះឲ្យរលត់បាន បើទេវតាមានអានុភាពច្រើនយ៉ាងនោះ ។ ទេវតាពោលនឹងព្រះទេវីទៀតថា "យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន" ហើយបូជាព្រះទេវី

ដោយផ្កាឈើមួយក្តាប់ទៀត ។ ព្រះទេវីឈរត្រាស់ ទាំងទ្រង់ព្រះកន្សែង ទាំងទ្រង់សើច ។ គ្រានោះ ព្រះរាជាត្រាស់ទៅកាន់ព្រះទេវីនោះថា "នាងជាស្ត្រីឆ្កួតឬ" ។

ព្រះទេវី. បពិត្រមហារាជ ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់សួរយ៉ាងនោះ ស្ត្រីទាំងឡាយដូចខ្ញុំម្ចាស់ មិនមែនជាស្ត្រីឆ្កួតទេ ។

ព្រះរាជា. បើដូច្នោះ ព្រោះហេតុអ្វី ទើបនាងយំផង សើចផង ។

ព្រះទេវីទូលថា "សូមព្រះអង្គទ្រង់សណ្តាប់ចុះ កាលពីជាតិមុន ខ្ញុំម្ចាស់ជាកុលធីតា កាលទៅនៅក្នុងត្រកូលស្វាមី ឃើញភ្ញៀវដែលជាសម្លាញ់របស់ស្វាមីមកហើយ ប្រាថ្នានឹងជាំស្ងួដើម្បីភ្ញៀវនោះ ក៏ឲ្យកហាបណៈដល់នាងទាសីដោយពាក្យថា "នាងដ៏ចម្រើន នាងចូរទៅទិញសាច់មក កាលនាងទាសីនោះមិនបានសាច់ហើយ ត្រឡប់មកប្រាប់ថា សាច់មិនមានទេ ទើបកាត់ក្បាលមេពពែដែលដេកនៅខាងក្រោយផ្ទះ ចាត់ចែងកត្ត ខ្ញុំបានកាត់ក្បាលមេពពែមួយត្រូវឆេះក្នុងនរក ដោយសេសសល់ផលនៃកម្ម ក៏ត្រូវបានគេកាត់ក្បាលដោយការរាប់ចំនួនរោមមេពពែនោះ ចុះបើព្រះអង្គសម្លាប់ជនមានប្រមាណប៉ុណ្ណោះ កាលណាទៅនឹងរួចផុតចាកទុក្ខបាន ខ្ញុំម្ចាស់រឭកដល់ទុក្ខដ៏ធំរបស់ព្រះអង្គនេះ ទើបខ្ញុំព្រះអង្គយំ" ទើបពោលគាថានេះថា ៖

ខ្ញុំកាត់ក្បាលមេពពែមួយ ឆេះហើយ (ក្នុងនរក) ដោយ
ការរាប់ចំនួនរោមនៃមេពពែ បពិត្រព្រះអង្គដែលជាក្សត្រ

ព្រះអង្គកាត់ក្បាលនៃមនុស្សដ៏ច្រើន នឹងទៅជាយ៉ាងណា ។

ព្រះរាជា. ចុះហេតុអ្វី បានជានាងសើច ។

ព្រះទេវី. បពិត្រមហារាជ ខ្ញុំម្ចាស់ត្រេកអរថា យើងរួចផុតចាកទុក្ខនោះហើយ ទើបខ្ញុំព្រះអង្គសើច ។

ទេវតាពោលនឹងព្រះទេវីនោះទៀតថា "យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន យ៉ាងនោះឯង ព្រះទេវីដ៏ចម្រើន" ហើយបូជាព្រះទេវីដោយផ្កាឈើមួយក្តាប់ទៀត ។

ព្រះរាជាទ្រង់ព្រះតម្រិះថា "ឱគួរឲ្យតក់ស្លុតណាស់! កម្មរបស់យើងធ្ងន់ណាស់ បានឮថា ព្រះទេវីនេះសម្លាប់មេពពែតែមួយ ត្រូវឆេះក្នុងនរក ដោយសេសសល់ផលនៃកម្ម ត្រូវគេកាត់ក្បាលដោយការរាប់ចំនួនរោមនៃមេពពែនោះ យើងសម្លាប់ជនមានប្រមាណប៉ុណ្ណេះ នឹងដល់នូវសិរីសួស្តីអំពីទីណា" ដូច្នេះ ទើបទ្រង់លែងព្រះរាជាទាំងអស់ ថ្វាយបង្គំព្រះរាជាដែលចាស់ជាងខ្លួន ទ្រង់ផ្គងនូវអញ្ជលីចំពោះព្រះរាជាដែលចាស់ជាងខ្លួន ញ៉ាំងព្រះរាជាទាំងអស់ ឲ្យអត់ទោសឲ្យហើយ ទ្រង់បញ្ជូនទៅកាន់នគររៀងៗ ខ្លួន ដូចដើមវិញ ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះនាងមល្លិកាអាស្រ័យព្រះបញ្ញារបស់ខ្លួន ប្រទាននូវជីវិតទានដល់មហាជនក្នុងកាលឥឡូវនេះក៏ទេ សូម្បីក្នុងកាលមុន ព្រះនាងក៏ធ្លាប់បានប្រទានហើយដែរ ហើយទ្រង់ប្រជុំរឿងអតីតថា "ព្រះរាជាក្រុងពារាណសី

ក្នុងកាលនោះ បានមកជាព្រះបាទបសេនទិកោសល ព្រះនាងធម្មទិន្នាទេវី បានមកជាព្រះនាងមល្លិកា រុក្ខទេវតា គឺ តថាគតនេះឯង” ។ លុះទ្រង់ប្រជុំរឿងអតីតយ៉ាងនោះហើយ កាលនឹងទ្រង់សម្ដែងធម៌តទៅទៀត ក៏ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថា បាណាតិបាត ជាធម៌មានទោស បុគ្គលមិនគប្បីធ្វើ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វជាប្រក្រតី រមែងសោកសៅអស់កាលយូរ ទើបត្រាស់ព្រះគាថានេះថា ៖

ប្រសិនបើសត្វទាំងឡាយបានដឹងយ៉ាងនេះថា ជាតិសម្ភព
នេះជាទុក្ខ សត្វទាំងឡាយមិនគប្បីសម្លាប់សត្វ ព្រោះថា
បុគ្គលអ្នកសម្លាប់សត្វជាប្រក្រតី រមែងសោកសៅ ។

ចប់ រឿងបុរសម្នាក់

# ២. រឿងសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធសទ្ធិវិហារិករបស់ព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា* **ចរញ្ចេ នាធិគច្ឆេយ្យ (បើបុគ្គលត្រាច់ទៅ មិនគប្បីប្រសព្វ)** *ជាដើម ។*

បុគ្គលអ្នកខ្ជិលច្រអូសច្រើនអាងអំពើល្អរបស់អ្នកដទៃ

*ទេសនាបានតាំងឡើងហើយនៅក្នុងក្រុងរាជគ្រឹះ ។ បានឮថា ភិក្ខុដែលជាសទ្ធិវិហារិក ២ រូប ឧបដ្ឋាកព្រះថេរៈអ្នកអាស្រ័យក្រុងរាជគ្រឹះ នៅត្រង់ល្អាងបិប្ផលិ ។ បណ្តាភិក្ខុ ២ រូបនោះ មួយរូបធ្វើវត្តដោយប្រពៃ មួយរូបទៀត សម្តែងវត្តដែលគេធ្វើហើយ ឲ្យដូចជាវត្តដែលខ្លួនធ្វើ ដឹងថា ទឹកសម្រាប់លាងមុខ និងឈើសម្រាប់ជម្រះធ្មេញ ភិក្ខុនោះចាត់ចែងហើយ ក៏ប្រាប់ (ព្រះថេរៈ) ថា "ទឹកលាងមុខ និងឈើជម្រះធ្មេញ ខ្ញុំចាត់ចែងហើយ សូមលោកម្ចាស់លុបលាងមុខចុះ" ។ សូម្បីក្នុងកាលធ្វើកិច្ច មានការស្រង់ទឹក និងលាងជើងជាដើម ក៏រមែងប្រាប់យ៉ាងនោះដែរ ។ ភិក្ខុមួយរូបទៀតគិតថា "ភិក្ខុនេះសម្តែងវត្តដែលយើងធ្វើហើយ ឲ្យដូចជាវត្តដែលខ្លួនធ្វើហើយអស់កាលជានិច្ចល្អិយចុះ រឿងនោះលើកទុកសិនចុះ យើងនឹងធ្វើនូវអំពើដែលគួរធ្វើដល់លោក" កាលភិក្ខុនោះឆាន់ ហើយសឹងលក់ ក៏ដាំទឹកសម្រាប់ស្រង់ហើយដួសដាក់ក្នុងឆ្នាំងមួយ លើកតម្កល់ទុកខាងក្រោយបន្ទប់ទឹក ប៉ុន្តែបានបន្សល់ទឹកទុកក្នុងឆ្នាំង*

ដាំទឹកប្រមាណមួយបោយ ហើយតម្កល់ទុកលើចង្ក្រានឲ្យនៅមានផ្សែងហុយៗ ។

### កម្មតាមទាន់

ក្នុងវេលាល្ងាច ភិក្ខុក្រៅនេះ ក្រោកឡើងឃើញផ្សែងហុយៗ ចេញអំពីឆ្នាំង ក៏គិតថា “ភិក្ខុនោះដាំទឹកពុះហើយ តម្កល់ទុកក្នុងបន្ទប់ទឹកជាប្រាកដ” ក៏ប្រញាប់ទៅថ្វាយបង្គំព្រះថេរៈ ហើយប្រាប់ថា “ទឹកខ្ញុំដាំទុកក្នុងបន្ទប់ហើយ និមន្តលោកម្ចាស់ទៅស្រង់ចុះ” ហើយចូលទៅកាន់បន្ទប់ជាមួយព្រះថេរៈ ។ ព្រះថេរៈកាលមិនឃើញទឹក ក៏សួរថា “អាវុសោ ទឹកនៅឯណា” ភិក្ខុកំលោះទៅកាន់រោងភ្លើងហើយ ដាក់បោយចុះទៅក្នុងឆ្នាំង ក៏ដឹងថា ឆ្នាំងទទេគ្មានទឹក ក៏លើកទោសភិក្ខុដែលធ្វើវត្តដោយសេចក្ដីគោរពនោះ ប្រាប់ព្រះថេរៈថា “សូមលោកម្ចាស់មើលនូវកម្មរបស់ភិក្ខុក្បាលរឹង ប្រដៅក្រនេះចុះ លោកយកឆ្នាំងទទេដាក់លើចង្ក្រាន ហើយចេញទៅណាបាត់ ខ្ញុំករុណាប្រាប់លោកម្ចាស់ដោយសម្គាល់ថា ទឹកមាននៅក្នុងបន្ទប់” ដូច្នេះ ទើបបានយកក្អមទៅកាន់កំពង់ទឹក ។ ចំណែកភិក្ខុក្រៅនេះ នាំយកទឹកមកអំពីខាងក្រោយបន្ទប់ ហើយតម្កល់ទុកក្នុងបន្ទប់ ។ សូម្បីព្រះថេរៈក៏គិតថា “ភិក្ខុកំលោះរូបនេះពោលថា ទឹកខ្ញុំដាំទុកក្នុងបន្ទប់ហើយ និមន្តលោកម្ចាស់មកស្រង់ចុះ” ឥឡូវនេះ បែរជាលើកទោសរបស់ភិក្ខុដទៃ ហើយយកក្អមទៅកាន់កំពង់ទឹក រឿងនេះតើដូចម្ដេចហ្ន៎” លោកពិចារណាមើលក៏ដឹងថា “ភិក្ខុកំលោះរូបនេះ ប្រកាសកិច្ចវត្តដែលភិក្ខុដទៃធ្វើហើយ ឲ្យដូចជាកិច្ចវត្តដែលខ្លួនធ្វើ រហូតអស់កាលប្រមាណប៉ុណ្ណោះ ពេលល្ងាច

កាលភិក្ខុនោះមកអង្គុយក្នុងសំណាក់របស់ខ្លួន ក៏បានឲ្យឱវាទថា “អាវុសោ ឈ្មោះថា ភិក្ខុ គួរពោលកិច្ចដែលខ្លួនធ្វើហើយនោះឯងថា ខ្លួនធ្វើហើយ រមែងគួរ នឹងពោលកិច្ចដែលខ្លួនមិនបានធ្វើថា ជាកិច្ចដែលខ្លួនធ្វើ រមែងមិនគួរ ឥឡូវនេះ លោកពោលថា ទឹកខ្ញុំដាំទុកក្នុងបន្ទប់ទឹកហើយ និមន្តលោកម្ចាស់ស្រង់ចុះ កាលយើងចូលទៅឈរនៅក្នុងបន្ទប់ទឹកនោះ លោកបែរជាយកក្អមទៅកាន់កំពង់ទឹកវិញ ដែលឈ្មោះថា បព្វជិតធ្វើយ៉ាងនោះ មិនសមគួរឡើយ” ។ ភិក្ខុនោះពោលថា “លោកម្ចាស់ទាំងឡាយ ចូរមើលកម្មរបស់ព្រះថេរៈនេះចុះ ព្រះថេរៈអាស្រ័យហេតុត្រឹមតែទឹក ក៏ពោលនឹងយើងយ៉ាងនេះ” ក៏ខឹងក្រោធឡើងហើយថ្ងៃស្អែកឡើង មិនចូលទៅបិណ្ឌបាតជាមួយនឹងព្រះថេរៈ ។ ព្រះថេរៈចូលទៅកាន់ស្រុកជាមួយនឹងភិក្ខុក្រៅនេះ ។ កាលព្រះថេរៈទៅហើយ ភិក្ខុនោះទៅកាន់ត្រកូលឧបដ្ឋាក ត្រូវឧបដ្ឋាកសួរថា “ព្រះថេរៈទៅណា លោកម្ចាស់?” ក៏ប្រាប់ថា “ការមិនសប្បាយកើតដល់ព្រះថេរៈ លោកគង់នៅក្នុងវិហារនោះឯង” ។

ឧបដ្ឋាក. តើបានអ្វីហ្ន៎ ទើបគួរ លោកម្ចាស់ ។

ភិក្ខុ. អ្នកទាំងឡាយចូរប្រគេនអាហារបែបនេះ ។

ឧបដ្ឋាកទាំងឡាយ បានចាត់ចែងអាហារតាមទំនងដែលភិក្ខុនោះប្រាប់ប្រគេនហើយ ។ ភិក្ខុនោះ ឆាន់អាហារនោះក្នុងចន្លោះផ្លូវអស់ហើយ ទើបទៅកាន់វិហារ ។

## ព្រះថេរៈចាប់ល្បិចអាក្រក់របស់សិស្សបាន

ចំណែកព្រះថេរៈ បានសំពត់សាច់ល្អិតមួយផ្ទាំងធំក្នុងទីដែលនិមន្ត ក៏បានឲ្យភិក្ខុកំលោះដែលទៅជាមួយខ្លួន ។ ភិក្ខុកំលោះនោះ ជ្រលក់សំពត់នោះហើយ បានធ្វើឲ្យជាសំពត់សម្រាប់ដណ្តប់របស់ខ្លួន ។ ថ្ងៃស្អែកឡើង ព្រះថេរៈក៏បានទៅកាន់ត្រកូលឧបដ្ឋាក កាលពួកឧបដ្ឋាកសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំម្ចាស់ទាំងឡាយបានឮថា ការមិនសប្បាយបានកើតមានដល់លោកម្ចាស់ ក៏ចាត់ចែងអាហារបញ្ជូនទៅ តាមទំនងដែលភិក្ខុកំលោះប្រាប់ហើយនោះឯង សេចក្តីសប្បាយកើតមានដល់លោកម្ចាស់ ព្រោះបានឆាន់អាហារនោះឬ" លោកក៏នៅស្ងៀម ។ ព្រះថេរៈកាលនិមន្តទៅកាន់វិហារវិញ ពោលនឹងភិក្ខុកំលោះនោះឯងដែលមកថ្វាយបង្គំក្នុងពេលល្ងាច យ៉ាងនេះថា "អាវុសោ បានឮថា ម្សិលមិញ លោកធ្វើកម្មឈ្មោះនេះ កម្មនេះ មិនគួរដល់បព្វជិតឡើយ បព្វជិតធ្វើវិញ្ញត្តិ (សូម) ហើយឆាន់ រមែងមិនគួរ" ។

## ប្រទូស្តចំពោះអ្នកមានគុណស្លាប់នៅកើតក្នុងអវិចីនរក

ភិក្ខុនោះក្រោធហើយ ចងគំនុំនឹងព្រះថេរៈថា "ពីថ្ងៃមុន ព្រះថេរៈអាស្រ័យហេតុត្រឹមតែទឹកស្រង់ បានធ្វើយើងឲ្យជាអ្នកនិយាយកុហក ថ្ងៃនេះព្រោះហេតុតែយើងបរិភោគកត្តអង្ករមួយក្តាប់ ក្នុងផ្ទះនៃឧបដ្ឋាករបស់ខ្លួន ក៏ពោលនឹងយើងថា បព្វជិតធ្វើវិញ្ញត្តិហើយ បរិភោគមិនគួរ សូម្បីសំពត់ លោកក៏ឲ្យដល់ភិក្ខុអ្នកបម្រើខ្លួនប៉ុណ្ណោះ ឱ! កម្មរបស់ព្រះថេរៈនេះធ្ងន់ណាស់ យើង

នឹងដឹងនូវកិច្ចដែលយើងគួរធ្វើដល់ព្រះថេរៈនោះ ។ ស្អែកឡើង កាលព្រះថេរៈ ចូលទៅកាន់ស្រុក ក៏ពួនសម្ងំនៅក្នុងវិហារ កាលព្រះថេរៈនិមន្តទៅផុត ចាប់ដំបងវាយបំបែកវត្ថុទាំងឡាយ មានភាជនៈសម្រាប់ប្រើប្រាស់ជាដើម ហើយដុតបណ្ណសាលារបស់ព្រះថេរៈ វត្ថុណាដែលភ្លើងមិនឆេះ ក៏យកដំបងវាយវត្ថុនោះ ហើយគេចចេញទៅ ធ្វើកាលកិរិយាហើយ ក៏កើតក្នុងអវីចីនរក ។ មហាជនតាំងរឿងសន្ទនាគ្នាថា "បានឮថា សទ្ធិវិហារិករបស់ព្រះថេរៈមិនអត់ធន់ត្រឹមតែការពោលទូន្មាន ខឹងក្រោធដុតបណ្ណសាលាហើយគេចចេញទៅ" ។

ក្រោយមក ភិក្ខុមួយរូប ចេញអំពីក្រុងរាជគ្រឹះ ប្រាថ្នានឹងគាល់ព្រះសាស្តា ទៅដល់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរ ព្រះសាស្តាទ្រង់ធ្វើបដិសណ្ឋារៈហើយ ត្រាស់សួរថា "ភិក្ខុ អ្នកមកពីណា" ក្រាបទូលថា "មកពីក្រុងរាជគ្រឹះ ព្រះអង្គ" ។

ព្រះសាស្តា. មហាកស្សបបុត្ររបស់តថាគត សុខសប្បាយទេឬ ។

ភិក្ខុ. សុខសប្បាយទេ ព្រះអង្គ ។ ប៉ុន្តែសទ្ធិវិហារិករបស់លោកមួយរូប ខឹងក្រោធដោយហេតុត្រឹមតែការពោលប្រៀនប្រដៅ ដុតបណ្ណសាលាហើយគេចចេញទៅ ។

ព្រះសាស្តាត្រាស់ថា "ភិក្ខុនោះស្តាប់ឱវាទហើយខឹងក្រោធ មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ក៏ធ្លាប់ខឹងក្រោធដែរ ភិក្ខុនោះប្រទូស្តចំពោះកុដិមិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ក៏

ធ្លាប់ប្រទូស្តដែរ" ដូច្នេះ ហើយទ្រង់ក៏នាំអតីតនិទានមក (ត្រាស់) ថា ៖

រឿងសត្វក្រលេងក្រលោង និងស្វាវិវាទគ្នា

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្ត សោយរាជ្យនៅក្នុងក្រុងពា-រាណសី សត្វក្រលេងក្រលោងមួយធ្វើសំបុកនៅក្នុងហេមវន្តប្រទេស ។ ថ្ងៃមួយ កាលភ្លៀងកំពុងធ្លាក់ ស្វាមួយរងាញ័រព្រោះត្រជាក់ បានទៅកាន់ប្រទេសនោះ ។ ក្រលេងក្រលោងឃើញស្វានោះហើយ ក៏ពោលគាថាថា ៖

ម្នាលពានរ ក្បាល និងជើងដៃរបស់អ្នក ក៏មានដូចមនុស្សដែរ
កាលបើដូច្នោះ ព្រោះទោសអ្វីហ្ន៎ ទើបផ្ទះរបស់អ្នកមិនមាន ។

ស្វាគិតថា ដៃ និងជើងរបស់យើងមានក៏ពិតមែនហើយ តែថា យើងពិចារណាហើយ ការធ្វើផ្ទះដោយបញ្ញាឯណា បញ្ញានោះ រមែងមិនមានដល់យើងទេ ។ ប្រាថ្នានឹងញ៉ាំងក្រលេងក្រលោងឲ្យដឹងនូវសេចក្តីនោះ ទើបពោលគាថានេះថា ៖

ម្នាលក្រលេងក្រលោង ក្បាល និងដៃជើងរបស់យើង រមែង
មានដូចរបស់មនុស្សដែរ បណ្ឌិតទាំងឡាយពោលថា បញ្ញា
ដ៏ប្រសើរឯណាមានក្នុងមនុស្សទាំងឡាយ បញ្ញានោះ មិនមាន
ដល់យើងទេ ។

លំដាប់នោះ ក្រលេងក្រលោងកាលនឹងតិះដៀលស្វានោះថា "ការនៅគ្រប់គ្រងផ្ទះនឹងសម្រេចដល់បុគ្គលបែបនេះ បានយ៉ាងណា" ទើបពោល ២

គាថានេះថា ៖

សេចក្ដីសុខ រមែងមិនមានដល់បុគ្គលអ្នកមានចិត្តមិនតាំងមាំ
មានចិត្តស្រោល មានការប្រទូស្តមិត្ត មានប្រក្រតីមិនខ្វាប់ខ្ជួន
អស់កាលជានិច្ច អ្នកនោះឯងចូរធ្វើនូវអានុភាពចុះ ចូរប្រព្រឹត្ត
កន្លងនូវភាពជាប្រក្រតី (របស់ខ្លួន) ចេញ នែស្វា ចូរធ្វើនូវខ្ទម
ដែលជាគ្រឿងការពារនូវត្រជាក់ និងខ្យល់ចុះ ។

ស្វាគិតថា "គ្រលេងគ្រលោងនេះ រមែងធ្វើយើងឲ្យជាអ្នកមានចិត្តមិនតាំងមាំ មានចិត្តស្រោល មានប្រក្រតីប្រទូស្តមិត្ត មានចិត្តមិនខ្វាប់ខ្ជួន ឥឡូវនេះ យើងនឹងសម្ដែងនូវការៈនៃយើងជាអ្នកមានប្រក្រតីប្រទូស្តមិត្ត ចំពោះវា" ទើបបោចនូវសំបុកឲ្យរាត់រាយអស់ ។ គ្រលេងគ្រលោង កាលស្វានោះចាប់បោចសំបុកនោះឯង ខ្លួនក៏គេចចេញទៅកាន់ទីម្ខាង ។

ប្រជុំប្រមូលជាតក

ព្រះសាស្ដា លុះទ្រង់នាំព្រះធម៌ទេសនានេះមកហើយ ទ្រង់ប្រជុំជាតកថា "ស្វាក្នុងកាលនោះ បានមកជាភិក្ខុអ្នកប្រទូស្តកុដិក្នុងកាលឥឡូវនេះ សត្វគ្រលេងគ្រលោង បានមកជាកស្សបៈ" ។ លុះទ្រង់ប្រមូលជាតកមកហើយក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រទូស្តកុដិនោះ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុនោះក៏ក្រោធនឹងការឲ្យឱវាទ ហើយប្រទូស្តកុដិដែរ ការនៅរបស់កស្សបបុត្រតថាគតតែម្នាក់ឯងប៉ុណ្ណោះ ប្រសើរជាងការ

នៅរួមជាមួយនឹងបុគ្គលពាលបែបនោះ ដូច្នេះ ទើបត្រាស់ព្រះគាថានេះថា ៖

ចរញ្ចេ នាធិគច្ឆេយ្យ សេយ្យំ សទិសមត្តនោ

ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា ។

បុគ្គលកាលស្វះស្វែងរកកល្យាណមិត្ត បើមិនបានមិត្តដ៏ប្រសើរជាងខ្លួន ឬមិត្តដែលស្មើនឹងខ្លួនទេ គប្បីប្រព្រឹត្តទៅតែឯងឲ្យខ្ជាប់ខ្ជួនវិញ ព្រោះថា សហាយតាគុណមិនមានក្នុងបុគ្គលពាលឡើយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ចរំ** (ត្រាច់) សេចក្តីថា បណ្ឌិតគប្បីជ្រាបការត្រាច់ទៅដោយចិត្ត មិនទាក់ទងការត្រាច់ទៅដោយឥរិយាបថ អធិប្បាយថា កាលស្វែងរកនូវកល្យាណមិត្ត ។ បទថា **សេយ្យំ សទិសមត្តនោ** (មិត្តអ្នកប្រសើរជាង ឬស្មើដោយ (គុណ) របស់ខ្លួន) សេចក្តីថា ប្រសិនបើ មិនបាននូវសម្លាញ់ដែលប្រសើរជាង ឬស្មើគ្នា ដោយគុណ មានសីល សមាធិ បញ្ញា នឹងខ្លួនទេ ។

បទថា **ឯកចរិយំ** (គប្បីត្រាច់ទៅតែឯង) សេចក្តីថា ក៏ក្នុងបណ្តាសម្លាញ់ទាំងនោះ បុគ្គលកាលបានសម្លាញ់ប្រសើរជាងខ្លួន រមែងចម្រើនដោយគុណទាំងឡាយ មានសីលជាដើម កាលបានសម្លាញ់ស្មើនឹងខ្លួន រមែងមិនសាបសូន្យចាកគុណមានសីលជាដើម ប៉ុន្តែកាលនៅរួមជាមួយនឹងសម្លាញ់ដែលអន់

ជាខ្លួន អប្បឥតប្រាជ្ញា ធ្វើនូវការសម្ភោគៈ និងបរិភោគដោយភាពជាពួកជាគ្នា រមែងសាបសូន្យចាកគុណទាំងឡាយ មានសីលជាដើម ។ ព្រោះហេតុនោះទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា "បុគ្គលបែបនោះ បណ្ឌិតមិនគប្បីសេព មិនគប្បីគប់រក មិនគប្បីចូលទៅអង្គុយជិត វៀរតែសេចក្ដីអាណិត វៀរតែការអនុគ្រោះ" ។

ព្រោះហេតុនោះ ប្រសិនបើបុគ្គលអាស្រ័យករុណា គិតថា "បុគ្គលនេះអាស្រ័យយើង នឹងចម្រើនដោយគុណទាំងឡាយ មានសីលគុណជាដើម មិនសង្ឃឹមការតបគុណអំពីបុគ្គលនោះ ឈ្មោះថា រមែងអាចសង្គ្រោះបុគ្គលនោះបាន អាស្រ័យករុណាសង្គ្រោះដូច្នោះ នោះជាការល្អ បើមិនអាចសង្គ្រោះបានទេ គប្បីត្រាច់ទៅតែម្នាក់ឯងដោយសេចក្ដីមិនប្រមាទ គឺថា ធ្វើនូវការៈជាអ្នកត្រាច់ទៅតែម្នាក់ឯងឲ្យមាំទាំ នៅតែម្នាក់ឯងក្នុងឥរិយាបថទាំងពួង ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះគុណដែលជាសម្លាញ់ រមែងមិនមានក្នុងបុគ្គលពាល ។ អធិប្បាយថា ចូឡសីល មជ្ឈិមសីល មហាសីល កថាវត្ថុ ១០ ធុតង្គគុណ ១៣ វិបស្សនាគុណ មគ្គ ៤ ផល ៤ វិជ្ជា ៣ អភិញ្ញា ៦ ឈ្មោះថា គុណធម៌ជាសម្លាញ់ ។ គុណធម៌ជាសម្លាញ់នេះរមែងមិនមានក្នុងបុគ្គលពាលឡើយ ។

ក្នុងកាលចប់ព្រះធម៌ទេសនា អាគន្តុកភិក្ខុបានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម

*ទេសនាបានជាកថាមានប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។*

ចប់ រឿងសទ្ធិវិហារិករបស់ព្រះមហាកស្សបៈ

# ៣. រឿងអានន្ទសេដ្ឋី

*ព្រះសាស្តា កាលប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធអានន្ទសេដ្ឋី ត្រាស់ព្រះធម៌ទេសនានេះថា* ***បុត្តាមត្ថិ ធនមត្ថិ (បុត្រទាំងឡាយរបស់យើងមានហើយ ទ្រព្យរបស់យើងមានហើយ)*** *ជាដើម ។*

អានន្ទសេដ្ឋីប្រៀនប្រដៅបុត្រឱ្យកំណាញ់

*បានឮថា នៅក្នុងក្រុងសាវត្ថី មានសេដ្ឋីម្នាក់ឈ្មោះអានន្ទៈ មានទ្រព្យ-សម្បត្តិប្រមាណ ៨០ កោដិ (ប៉ុន្តែ) ជាអ្នកមានសេចក្តីកំណាញ់យ៉ាងខ្លាំង ។ អានន្ទសេដ្ឋីនោះ ឲ្យពួកញាតិប្រជុំគ្នារាល់ៗ កន្លះខែ រមែងទូន្មានបុត្រ (របស់ខ្លួន) ដែលមានឈ្មោះថា មូលសិរី ក្នុងមួយថ្ងៃ ៣ ដង យ៉ាងនេះថា "កូនឯងកុំសម្គាល់ថា ទ្រព្យ ៤០[១] កោដិ នេះច្រើន កូនមិនគប្បីឲ្យទ្រព្យដែលមានឲ្យអស់ទៅឡើយ គួរញ៉ាំងទ្រព្យថ្មីឲ្យកើតឡើង ព្រោះថា បុគ្គលកាលធ្វើនូវកហាបណៈសូម្បីម្តងមួយៗ ឲ្យរលោះទៅ ទ្រព្យរមែងអស់ទៅអាស្រ័យហេតុនោះដោយពិត ព្រោះហេតុនោះ*

> ***បណ្ឌិត គប្បីឃើញនូវការអស់ទៅនៃថ្នាំបន្តក់ភ្នែកផង នូវការពូនផ្តុំនៃកណ្តៀរទាំងឡាយផង និងការប្រមូលមកនៃសត្វឃ្មុំទាំងឡាយ ហើយនៅគ្រប់គ្រងផ្ទះចុះ ។***

---

*១ ក្នុងអដ្ឋកថា ខាងដើម ៨០ កោដិ , ខាងក្រោយ ៤០ កោដិ ។*

## អានន្ទសេដ្ឋីស្លាប់ទៅកើតក្នុងត្រកូលចណ្ឌាល

ក្នុងសម័យក្រោយមក អានន្ទសេដ្ឋីនោះមិនបានប្រាប់នូវកំណប់ទ្រព្យធំៗ ៥ កន្លែងរបស់ខ្លួនដល់បុត្រ ហួងហែងទ្រព្យ មានសៅហ្មងព្រោះមន្ទិល គឺ សេចក្តីកំណាញ់ ធ្វើកាលកិរិយាហើយ បដិសន្ធិក្នុងផ្ទៃនៃស្ត្រីចណ្ឌាលម្នាក់ក្នុងចំណោមត្រកូលចណ្ឌាលមួយពាន់ត្រកូល ដែលនៅក្នុងស្រុកមួយជិតទ្វារនគរនោះឯង ។ ព្រះរាជាទ្រង់ជ្រាបថា អានន្ទសេដ្ឋីធ្វើកាលកិរិយាហើយ ក៏ត្រាស់បង្គាប់ឲ្យហៅមូលសិរីដែលជាបុត្ររបស់អានន្ទសេដ្ឋីនោះមក ទ្រង់តាំងទុកក្នុងតំណែងសេដ្ឋី ។

ត្រកូលនៃមនុស្សចណ្ឌាលមួយពាន់នោះ ធ្វើការងារស៊ីឈ្នួល ដើម្បីចិញ្ចឹមជីវិត រស់នៅក្នុងពួកជាមួយគ្នា ចាប់តាំងពីទារកនោះបដិសន្ធិមក កិច្ចការងារធ្វើមិនបានទទួលថ្លៃឈ្នួល ទាំងមិនបានសូម្បីនូវដុំបាយដទៃ ក្រៅអំពីអាហារដែលគ្រាន់តែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ពួកគេគិតថា ឥឡូវនេះយើងទាំងឡាយសូម្បីធ្វើការងារយ៉ាងណាក៏ដោយ ក៏មិនបានអាហារយ៉ាងដទៃក្រៅអំពីអាហារដែលគ្រាន់តែញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ប្រហែលជាមានស្រីកាឡកណ្ណីនៅក្នុងចំណោមនៃពួកយើងទាំងឡាយហើយមើលទៅ គិតដូច្នេះហើយ ទើបរំលែកគ្នាចេញជាពីរពួក រហូតដល់បំបែកមាតាបិតារបស់ទារកនោះឲ្យនៅដោយឡែកអំពីគេ បណ្តេញមាតារបស់ទារកនោះចេញ ដោយគិតថា "នាងនេះជាស្រីកាឡកណ្ណី" ។ ទារកនោះនៅក្នុងផ្ទៃស្ត្រីនោះដរាបណា

ស្ត្រីនោះបាននូវអាហារ ដែលគ្រាន់តែញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយលំបាក ដរាបប្រសូតបុត្រនោះ ។

ទារកនោះកើតមកហើយ មានដៃ និងជើង ភ្នែក ត្រចៀក ច្រមុះ និងមាត់មិនតាំងនៅក្នុងទីជម្មតា (គឺខុសប្លែកអំពីគេ) ។ ទារកនោះ ប្រកបដោយភាពវិកលវិការនៃអវយវៈបែបនោះ មានរូបគួរឲ្យខ្ពើមក្រៃលែងណាស់ ដូចជាបិសាចប្រឡាក់ធូលី ។ សូម្បីកូនមានសភាពដូច្នោះក៏ដោយ មាតាក៏មិនលះបង់បុត្រនោះ ។ ពិតហើយ មាតារមែងមានសេចក្តីអាណិតអាសូរជាកម្លាំងក្នុងបុត្រដែលនៅក្នុងផ្ទៃ ។ នាងចិញ្ចឹមទារកនោះដោយលំបាក ថ្ងៃណាដែលនាំយកបុត្រនោះទៅជាមួយ ថ្ងៃនោះរមែងមិនបានអ្វីៗ ឡើយ ថ្ងៃណាដែលខ្លួនទុកទារកនោះឲ្យនៅផ្ទះ ហើយទៅតែឯង ទើបបាននូវថ្លៃឈ្នួល ។

## មាតាបណ្តោយបុត្រឲ្យទៅសុំទានចិញ្ចឹមជីវិតខ្លួនឯង

តមក ក្នុងកាលដែលទារកនោះអាចដើរទៅបាន ដើម្បីជុំបាយចិញ្ចឹមខ្លួនឯង នាងក៏ដាក់នូវអំបែងក្នុងដៃ ហើយពោលនឹងបុត្រនោះថា "នែ៎ កូនមាតាអាស្រ័យកូនដល់នូវសេចក្តីលំបាកខ្លាំងណាស់ ឥឡូវនេះ មាតាមិនអាចចិញ្ចឹមកូនបានទៀតទេ អាហារ វត្ថុទាំងឡាយមានបាយជាដើម ដែលគេចាត់ចែងទុកដើម្បីមនុស្សទាំងឡាយ មានជនកំព្រា និងអ្នកដំណើរជាដើម មាននៅក្នុងនគរនេះ កូនចូរត្រាច់ទៅដើម្បីភិក្ខាក្នុងនគរនោះ ចិញ្ចឹមជីវិតចុះ" ។ ដូច្នេះហើយក៏ឲ្យបុត្រនោះទៅ ។ ទារកនោះដើរទៅតាមលំដាប់ផ្ទះ ទៅដល់ផ្ទះដែល

ខ្លួនធ្លាប់នៅក្នុងកាលដែលខ្លួនជាអានន្ទសេដ្ឋី រឭកជាតិបាន ក៏ចូលទៅកាន់ផ្ទះរបស់ខ្លួន ។ នរណាៗ មិនឃើញគេត្រង់ស៊ុំទ្វារទាំង ៣ កាលគេដើរចូលទៅដល់ខ្លោងទ្វារទី ៤ ពួកបុត្រតូចៗ របស់មូលសិរីសេដ្ឋី ឃើញ (គេ) ហើយក៏មានចិត្តតក់ស្លុតស្រែកយំ ។ លំដាប់នោះ ពួកបុរសរបស់សេដ្ឋីពោលនឹងទារកនោះថា "នែ៎ មនុស្សកាឡកណ្ណី ឯងចូរចេញទៅ" ហើយវាយអូសចេញទៅ បោះចោលនៅលើគំនរសំរាម ។

ព្រះសាស្តាសម្តែងធម៌ដល់មូលសិរីសេដ្ឋី

ព្រះសាស្តា មានព្រះអានន្ទជាបច្ឆាសមណៈ ស្តេចយាងទៅបិណ្ឌបាតដល់ទីនោះហើយ ទតមើលព្រះថេរៈ កាលដែលព្រះថេរៈនោះទូលសួរហើយ ក៏ត្រាស់ប្រាប់ព្រឹត្តិការណ៍នោះ ព្រះថេរៈឲ្យគេទៅអញ្ជើញមូលសិរីមក ។ ពេលនោះ មហាជនក៏បានមកប្រជុំគ្នានៅទីនោះដែរ ។ ព្រះសាស្តា ត្រាស់ហៅមូលសិរីមក ហើយត្រាស់សួរថា " អ្នកស្គាល់ទារកនេះទេ?" កាលមូលសិរីសេដ្ឋីទូលថា "ខ្ញុំព្រះអង្គមិនស្គាល់ទេ" ទើបត្រាស់ថា "ទារកនោះ គឺ អានន្ទសេដ្ឋីដែលជាបិតារបស់អ្នក" ហើយញ៉ាំងទារកនេះឲ្យប្រាប់ (កំណប់ទ្រព្យ) ដោយព្រះតម្រាស់ថា "អានន្ទសេដ្ឋី អ្នកចូរប្រាប់កំណប់ទ្រព្យធំៗ ៥ កន្លែងដល់បុត្ររបស់អ្នកចុះ" ហើយទ្រង់ញ៉ាំងមូលសិរីដែលជាអ្នកមិនជឿនោះឯង ឲ្យជឿ ។ មូលសិរីសេដ្ឋីនោះ បានដល់ព្រះសាស្តាជាសរណៈ ។ ព្រះសាស្តាកាលនឹងសម្តែងធម៌ដល់មូលសិរី ទើបត្រាស់ព្រះគាថានេះថា ៖

*បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ*
*អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។*

*ជនពាលតែងព្រួយលំបាក ដោយសេចក្ដីសម្គាល់ថា*
*កូនទាំងឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាម*
*ដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូន*
*ទាំងឡាយ នឹងរាប់ថាមានអំពីណាបាន ទ្រព្យនឹងរាប់ថា*
*មានអំពីណាបាន ។*

អធិប្បាយគាថា

*គប្បីជ្រាបអត្ថនៃគាថានោះថា ៖*

*បុគ្គលពាលរមែងក្ដៅក្រហាយ គឺ លំបាកជាទុក្ខ ព្រោះការជាប់ជំពាក់ក្នុងបុត្រ និងការជាប់ជំពាក់ក្នុងទ្រព្យថា បុត្រទាំងឡាយរបស់យើងមាន ទ្រព្យរបស់យើងមាន រមែងក្ដៅក្រហាយថា បុត្រទាំងឡាយរបស់យើងវិនាសហើយ រមែងក្ដៅក្រហាយថា វិនាសហើយ សូម្បីក្នុងទ្រព្យក៏មានន័យដូចគ្នា ។ បុគ្គលពាល រមែងកន្ទក់កន្ទេញដោយអាការ ៦ យ៉ាង ដោយប្រការដូច្នេះ បុគ្គលពាល កាលព្យាយាមនៅក្នុងទីទាំងឡាយ មានផ្លូវគោក និងផ្លូវទឹកជាដើម ទាំងពេលយប់ និងពេលថ្ងៃដោយប្រការផ្សេងៗ ដោយគិតថា យើងនឹងចិញ្ចឹមបុត្រទាំងឡាយ ឈ្មោះថា រមែងក្ដៅក្រហាយ សូម្បីធ្វើកម្មទាំងឡាយ មានការជួញ*

ជាដើម ដោយគិតថា យើងនឹងញ៉ាំងទ្រព្យឲ្យកើតឡើង ក៏ឈ្មោះថា រមែងក្ដៅក្រហាយដូចគ្នា ក៏កាលគេក្ដៅក្រហាយយ៉ាងនេះ ខ្លួននោះឯងឈ្មោះថា រមែងមិនមានដល់ខ្លួន កាលគេមិនអាចធ្វើខ្លួនដែលដល់នូវសេចក្ដីទុក្ខ ដោយការចង្អៀតចង្អល់នោះ ឲ្យដល់នូវសេចក្ដីសុខបាន សូម្បីក្នុងកាលជាបច្ចុប្បន្ន ខ្លួនរបស់គេ ឈ្មោះថា រមែងមិនមានដល់ខ្លួន កាលគេដេកនៅលើគ្រែសម្រាប់ស្លាប់ ត្រូវវេទនាទាំងឡាយ មានសេចក្ដីស្លាប់ជាទីបំផុតដុតរោល ហាក់ដូចជាត្រូវអណ្ដាតភ្លើងដុត កាលគ្រឿងត និងគ្រឿងចង (សរសៃ) នឹងដាច់ទៅកាលរាងឆ្អឹងនឹងបែកធ្លាយទៅ សូម្បីកាលគេបិទភ្នែក ឃើញលោកខាងមុខបើកភ្នែកឃើញលោកនេះ ខ្លួនដែលគេផ្ចួតទឹកឲ្យមួយថ្ងៃ ២ ដង ឲ្យបរិភោគមួយថ្ងៃ ៣ ដង ប្រដាប់តុបតែងដោយគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចិញ្ចឹមរក្សារហូតអស់មួយជីវិត ក៏ឈ្មោះថា រមែងមិនមានដល់ខ្លួន ព្រោះមិនអាចការពារទុក្ខឲ្យខ្លួនឯងបាន បុត្រនឹងមានអំពីទីណា ទ្រព្យនឹងមានអំពីទីណា គឺថា ក្នុងសម័យនោះ បុត្រ ឬទ្រព្យនឹងធ្វើអ្វីឲ្យបានទៅ សូម្បីកាលអានន្ទសេដ្ឋីមិនឲ្យអ្វីៗ ដល់នរណាៗ សន្សំទ្រព្យទុកដើម្បីបុត្រ ដេកលើគ្រែសម្រាប់ស្លាប់ក្នុងកាលមុនក្ដី ដល់នូវសេចក្ដីទុក្ខក្នុងបច្ចុប្បន្នក្ដី បុត្រនឹងមានអំពីទីណា? ទ្រព្យនឹងមានអំពីទីណា? គឺថា បុត្រ ឬទ្រព្យនាំទុក្ខអ្វីទៅបាន? ឬញ៉ាំងសុខអ្វីឲ្យកើតឡើងបាន? ជួយអ្វីបានខ្លះ? ។

*ក្នុងកាលចប់ព្រះធម៌ទេសនា ការត្រាស់ដឹងធម៌ ក៏បានមានដល់សត្វ ៨៤.០០០ ព្រះធម៌ទេសនាមានប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។*

ចប់ រឿងអានន្ទសេដ្ឋី

# ៤. រឿងចោរទម្លាយបង្វេចទ្រព្យ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធចោរជាអ្នកទម្លាយនូវបង្វេចទ្រព្យ ត្រាស់ព្រះធម្មទេសនានេះថា **យោ ពាលោ មញ្ញតិ ពាល្យំ (ជនណាជាបុគ្គលពាល រមែងដឹងថាខ្លួនជាពាល)** ជាដើម ។*

ចោរលួចរបស់ដែលគេខ្ចប់ទុកនឹងជាយសំពត់

*បានឮថា ចោរពីរនាក់ជាសម្លាញ់នឹងគ្នា ទៅកាន់វត្តជេតពនជាមួយនឹងមហាជនដែលទៅដើម្បីត្រូវការស្តាប់ធម៌ ចោរម្នាក់បានស្តាប់ធម្មកថា ចោរម្នាក់ទៀតដើរគយគន់រកមើលនូវវត្ថុដែលខ្លួនគប្បីកាន់យក ។ បណ្តាចោរទាំងពីរនាក់នោះ ចោរអ្នកស្តាប់ធម៌បានសម្រេចសោតាបត្តិផល ។ ចោរម្នាក់ទៀតបានទ្រព្យប្រមាណ ៥ មាសក: ដែលខ្ចប់នឹងជាយសំពត់របស់ឧបាសកម្នាក់ ។ ទ្រព្យនោះបានជាតម្លៃអាហារក្នុងផ្ទះរបស់ចោរនោះ មិនសម្រេចផលដល់ផ្ទះរបស់ចោរដែលជាសោតាបន្នទេ ។*

*គ្រានោះ ចោរដែលជាសម្លាញ់ និងកិរិយារបស់ខ្លួន បានពោលចំអកឲ្យចោរដែលជាសោតាបន្ននោះថា អ្នកមិនញុាំងតម្លៃអាហារឲ្យសម្រេចដល់ផ្ទះរបស់ខ្លួន ព្រោះតែខ្លួនជាអ្នកឈ្លាសវៃពេក ។ សម្លាញ់ដែលជាសោតាបន្ននោះគិតថា "បុគ្គលនេះ រមែងសម្គាល់យើងដែលជាបណ្ឌិត ថាជាបុគ្គលពាលទៅវិញ" ក៏ទៅកាន់វត្តជេតពនជាមួយនឹងញាតិទាំងឡាយ ដើម្បីក្រាបទូលរឿង*

នោះចំពោះព្រះសាស្តា ។

អ្នកដឹងខ្លួនថាពាល រមែងជាបណ្ឌិតបាន

ព្រះសាស្តា កាលនឹងទ្រង់សម្តែងធម៌ដល់គេនោះ បានត្រាស់ព្រះគាថានេះថា ៖

យោ ពាលោ មញ្ញតី ពាល្យំ   បណ្ឌិតោ វាបិ តេន សោ
ពាលោ ច បណ្ឌិតមានី   ស វេ ពាលោតិ វុច្ចតិ ។

អ្នកណាជាមនុស្សពាល ហើយដឹងនូវភាពនៃខ្លួនថាជាពាល
អ្នកនោះនឹងទៅជាបណ្ឌិតបានខ្លះ ដោយហេតុដែលដឹងខ្លួន
ថា ជាពាលនោះ ម្យ៉ាងទៀត អ្នកណា ជាមនុស្សពាល
មានសេចក្តីប្រកាន់ថា ខ្លួនជាបណ្ឌិត អ្នកនោះ ឈ្មោះថា
ជាមនុស្សពាល ដោយពិត ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា យោ ពាលោ (អ្នកណាជាមនុស្សពាល) សេចក្តីថា អ្នកណាជាមនុស្សពាល គឺ មិនមែនជាបណ្ឌិត ហើយសម្គាល់ គឺ ដឹងនូវភាវៈនៃខ្លួនថាជាមនុស្សពាល គឺ ភាពជាមនុស្សល្ងង់ខ្លៅនោះដោយខ្លួនឯងថា "យើងជាមនុស្សពាល" ។

បទថា តេន សោ (បុគ្គលនោះ... ព្រោះហេតុនោះ) សេចក្តីថា ព្រោះ

ហេតុនោះ បុគ្គលនោះនឹងជាបណ្ឌិតបានខ្លះ ឬស្មើនឹងបណ្ឌិតបានខ្លះ ។

ពិតហើយ បុគ្គលនោះកាលដឹងថា "យើងជាបុគ្គលពាល" ចូលទៅរក ចូលទៅអង្គុយជិតអ្នកដទៃដែលជាបណ្ឌិត កាលបណ្ឌិតនោះ ទូន្មានប្រៀនប្រដៅ ដើម្បីប្រយោជន៍ដល់ភាពជាបណ្ឌិត រៀនយកឱវាទនោះហើយ រមែងជាបណ្ឌិត ឬជាបណ្ឌិតដ៏ក្រៃលែងបាន ។

បទថា *ស វេ ពាលោ* (ចំណែកអ្នកណាជាបុគ្គលពាល) សេចក្តីថា ចំណែកអ្នកណាជាមនុស្សពាល ហើយសម្គាល់ថាខ្លួនជាបណ្ឌិតតែម្យ៉ាង យ៉ាងនេះថា "អ្នកដទៃណាជាពហុស្សូត ជាធម្មកថិក ជាអ្នកទ្រទ្រង់វិន័យ មានវាទៈ ពោលនូវគុណដែលជាគ្រឿងជុះសខាត់កិលេសប្រាកដស្មើនឹងយើង" បុគ្គលនោះ មិនចូលទៅរក មិនចូលទៅអង្គុយជិតបុគ្គលដទៃដែលជាបណ្ឌិត រមែងមិនរៀន យកព្រះបរិយត្តិ រមែងមិនបំពេញនូវវត្តបដិបត្តិ រមែងដល់នូវភាពជាបុគ្គល ពាលដោយពិត ។ បុគ្គលនោះ រមែងដូចជាចោរដែលទម្លាយនូវបង្វេចទ្រព្យ ដូច្នោះ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ពាក្យនេះថា *ស វេ ពាលោតិ វុច្ចតិ* (បុគ្គលនោះឯង តថាគតហៅថាមនុស្សពាល) ។

ក្នុងកាលចប់ព្រះទេសនា មហាជនព្រមទាំងញាតិទាំងឡាយរបស់ចោរ ដែលជាសោតាបន្ននោះ បានសម្រេចសោតាបត្តិផល ដូច្នេះឯង ។

ចប់ រឿងចោរទម្លាយបង្វេចទ្រព្យ

# ៥. រឿងព្រះឧទាយី

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះឧទាយី ត្រាស់ព្រះធម៌ទេសនានេះថា **យាវជីវម្បិ ចេ ពាលោ (បើបុគ្គលពាល... សូម្បីដរាបអស់ជីវិត)** ជាដើម ។

បុគ្គលល្ងង់ខ្លៅច្រើនតែប្រកាន់ខ្លួន

បានឮថា ព្រះឧទាយីនោះ កាលព្រះមហាថេរៈចេញទៅអស់ហើយ ក៏ចូលទៅកាន់ធម្មសភាហើយ គង់លើធម្មាសនៈ ។ ថ្ងៃមួយ ពួកភិក្ខុអាគន្តុកៈ ឃើញព្រះឧទាយីនោះហើយ សម្គាល់ថា ភិក្ខុនេះប្រាកដជាព្រះមហាថេរៈ ជាពហុស្សូត ក៏សួរបញ្ហាប្រកបដោយបរមត្ថធម៌ មានខន្ធជាដើម ហើយក៏តិះដៀលលោកដែលជាអ្នកមិនចេះនូវព្រះពុទ្ធវចនៈអ្វីៗ ថា នេះជាព្រះថេរៈស្អី នៅក្នុងវិហារមួយជាមួយនឹងព្រះសម្ពុទ្ធ មិនចេះធម៌សូម្បីត្រឹមតែខន្ធ ធាតុ អាយតនៈ ដូច្នេះ ហើយក្រាបទូលសេចក្តីនោះចំពោះព្រះតថាគត ។ លំដាប់នោះ ព្រះសាស្តា កាលនឹងទ្រង់សម្តែងធម៌ដល់ពួកភិក្ខុអាគន្តុកៈនោះ ក៏ត្រាស់ព្រះគាថានេះថា ៖

*យាវជីវម្បិ ចេ ពាលោ បណ្ឌិតំ បយិរុបាសតិ*
*ន សោ ធម្មំ វិជានាតិ ទព្វី សូបរសំ យថា ។*

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់

មួយជីវិត ក៏ឥតបានដឹងរសធម៌អ្វីឲ្យច្បាស់លាស់ឡើយ

ដូចវែក ដែលមិនដឹងរសសម្ល ។

អធិប្បាយគាថា

គប្បីជ្រាបអត្ថនៃព្រះគាថានេះថា ៖

ឈ្មោះថា បុគ្គលពាលនេះ បើចូលទៅរក ចូលទៅអង្គុយជិតបណ្ឌិត សូម្បីអស់មួយជីវិត ក៏រមែងមិនដឹងនូវព្រះបរិយត្តិធម៌យ៉ាងនេះថា នេះជាព្រះពុទ្ធវចនៈ ព្រះពុទ្ធវចនៈមានប្រមាណប៉ុណ្ណេះ ឬមិនដឹងនូវបដិបត្តិធម៌ និងបដិវេធធម៌យ៉ាងនេះថា ធម៌នេះជាគ្រឿងនៅ ធម៌នេះជាមារយាទ នេះជាគោចរកម្ម កម្មនេះមានទោស កម្មនេះមិនមានទោស កម្មនេះគួរសេព កម្មនេះមិនគួរសេព ធម៌នេះគប្បីចាក់ធ្លុះ ធម៌នេះគួរធ្វើឲ្យជាក់ច្បាស់ ។

សួរថា ដូចអ្វី ។

ឆ្លើយថា ដូចវែកដែលមិនដឹងរសជាតិសម្ល ដូច្នោះ ។

អធិប្បាយថា ដូចជា វែក សូម្បីអ្នកស្លកូរក្នុងសម្លគ្រឿងមានប្រការផ្សេងៗ ដរាបដល់រលួយអស់ទៅ ក៏រមែងមិនដឹងនូវរសសម្លថា មានរសប្រៃ មានរសសាប មានរសល្វីង មានរសហាង មានរសហឹរ មានរសជូរ មានរសមិនជូរ មានរសចត់ យ៉ាងណា បុគ្គលពាល សូម្បីចូលទៅអង្គុយជិតបណ្ឌិតរហូតអស់ជីវិត ក៏រមែងមិនដឹងនូវធម៌មានប្រការដូចពោលហើយនោះដែរ ។

ក្នុងកាលចប់ទេសនា ចិត្តរបស់ពួកអាគន្តុកភិក្ខុ ក៏រួចផុតចាកអាសវៈ

ទាំងឡាយ ។

ចប់ រឿងព្រះឧទាយិត្ថេរ

# ៦. រឿងភិក្ខុអ្នកក្រុងបាដ្ឋា

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធពួកភិក្ខុអ្នកក្រុងបាដ្ឋាប្រមាណ ៣០ រូប ត្រាស់ព្រះធម្មទេសនានេះថា **មុហុត្តម្បិ ចេ វិញ្ញូ (បើវិញ្ញូជន... សូម្បីមួយរំពេច)** ជាដើម ។

## ភិក្ខុសមាទានធុតង្គ

សេចក្តីពិស្តារថា ព្រះមានព្រះភាគទ្រង់សម្តែងធម៌គ្រាដំបូងក្នុងដងព្រៃដ៏ដេរដាសដោយដើមកប្បាស (ព្រៃកប្បាស) ដល់សម្លាញ់ ៣០ នាក់ ដែលជាអ្នកស្វែងរកស្ត្រី ។ ក្នុងកាលនោះ សម្លាញ់ទាំងអស់នោះ ក៏បានជាឯហិភិក្ខុទ្រទ្រង់បាត្រ និងចីវរដែលសម្រេចអំពីឫទ្ធិ សមាទានធុតង្គទាំង ១៣ ដោយការកន្លងទៅនៃកាលយូរ ក៏ចូលទៅគាល់ព្រះសាស្តាម្តងទៀត ស្តាប់អនមតគ្គធម្ម-ទេសនា ក៏បានសម្រេចព្រះអរហត្តនៅលើអាសនៈនោះឯង ។

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងធម្មសភាថា "គួរឲ្យអស្ចារ្យណាស់ហ្ន៎ ! ភិក្ខុទាំងនេះបានដឹងច្បាស់នូវធម៌យ៉ាងឆាប់រហ័ស" ។ ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវកថានោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែក្នុងកាលឥឡូវនេះទេ សូម្បីក្នុងកាលមុន ភិក្ខុទាំងនេះជាអ្នកលេង ជាសម្លាញ់នឹងគ្នាប្រមាណ ៣០ នាក់ ស្តាប់ធម៌ទេសនារបស់ជ្រូកឈ្មោះមហាតុណ្ឌិលៈ ក្នុងតុណ្ឌិលជាតក ដឹងច្បាស់នូវធម៌បានឆាប់រហ័ស ហើយសមាទានសីល ៥ ផង

ដែរ ព្រោះឧបនិស្ស័យនោះឯង ភិក្ខុទាំងនោះ ទើបសម្រេចព្រះអរហត្តនៅលើអាសនៈដែលខ្លួនអង្គុយក្នុងកាលឥឡូវនេះ ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

មុហុត្តម្បិ ចេ វិញ្ញូ បណ្ឌិតំ បយិរុបាសតិ
ខិប្បំ ធម្មំ វិជានាតិ ជិវ្ហា សូបរសំ យថា ។

វិញ្ញូជន បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីតែមួយរំពេច រមែងយល់រសធម៌ដោយឆាប់រហ័ស ដូចអណ្តាតដឹងនូវរសសម្ល ។

អធិប្បាយគាថា

គប្បីជ្រាបសេចក្តីនៃព្រះគាថានោះថា ៖

បើវិញ្ញូជន គឺ បុរសដែលជាបណ្ឌិត ចូលទៅអង្គុយជិតបណ្ឌិតដទៃសូម្បីតែមួយរំពេច បណ្ឌិតនោះរៀន សាកសួរបណ្ឌិតដទៃនោះ ឈ្មោះថា រមែងដឹងច្បាស់នូវព្រះបរិយត្តិធម៌បាន យ៉ាងឆាប់រហ័ស តអំពីនោះ គេឲ្យបណ្ឌិតប្រាប់នូវកម្មដ្ឋានហើយ ព្យាយាមនៅក្នុងវត្តបដិបត្តិ ជាបណ្ឌិត រមែងដឹងច្បាស់សូម្បីនូវលោកុត្តរធម៌បានយ៉ាងឆាប់រហ័ស ដូចបុរសអ្នកមានជិវ្ហាបសាទដែលរោគមិនទាន់កម្ចាត់ លុះដាក់អាហារត្រង់អណ្តាតដើម្បីនឹងដឹងរស ក៏រមែងដឹងរសផ្សេងៗ មានរសប្រៃជាដើមបានយ៉ាងឆាប់រហ័ស ដូច្នោះ ។

ក្នុងកាលចប់ព្រះទេសនា ភិក្ខុជាច្រើន ក៏បានសម្រេចព្រះអរហត្ត ។

*ព្រះធម៌ទេសនា សម្រេចនូវប្រយោជន៍ដល់មហាជន ដូច្នេះឯង ។*

ចប់ រឿងភិក្ខុអ្នកក្រុងចាដ្ឋា

# ៧. រឿងសុប្បពុទ្ធកុដ្ឋិ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរសកើតឃ្លង់ឈ្មោះ សុប្បពុទ្ធកុដ្ឋិ ត្រាស់ព្រះធម្មទេសនានេះថា* ***ចរន្តិ ពាលា ទុម្មេធា (បុគ្គលពាលទាំងឡាយ មានបញ្ញាថោកទាប...ត្រាច់ទៅ)*** *ជាដើម ។*

## សុប្បពុទ្ធកុដ្ឋិក្រាបទូលគុណវិសេសចំពោះព្រះសាស្តា

*រឿងសុប្បពុទ្ធកុដ្ឋិនេះ មានមកហើយក្នុងគម្ពីរឧទាននោះឯង ។ ក៏ក្នុងកាលនោះ សុប្បពុទ្ធកុដ្ឋិអង្គុយខាងចុងបរិស័ទ ស្តាប់ព្រះធម៌ទេសនារបស់ព្រះមានព្រះភាគហើយ បានសម្រេចសោតាបត្តិផល បំណងនឹងក្រាបទូលគុណវិសេសដែលខ្លួនបានហើយចំពោះព្រះសាស្តា (ប៉ុន្តែ) មិនអាចនឹងចូលទៅក្នុងកណ្តាលបរិស័ទបាន ក៏បានទៅកាន់វិហារ ក្នុងកាលដែលមហាជនថ្វាយបង្គំព្រះសាស្តាត្រឡប់ទៅផ្ទះវិញ ។*

## បុគ្គលអ្នកមានអរិយទ្រព្យ ៧ ប្រការ ជាអ្នកមិនទាល់ក្រ

*ខណៈនោះ សក្កទេវរាជទ្រង់ជ្រាបថា "សុប្បពុទ្ធកុដ្ឋិប្រាថ្នាដើម្បីនឹងធ្វើគុណវិសេសដែលខ្លួនបានហើយ ក្នុងសាសនារបស់ព្រះសាស្តាឲ្យប្រាកដ" ។ ទ្រង់ព្រះតម្រិះថា "យើងនឹងល្បងមើលសុប្បពុទ្ធកុដ្ឋិនោះមើល៍" ស្តេចទៅឈរពួដ៏អាកាស ហើយបានត្រាស់ពាក្យនេះថា "សុប្បពុទ្ធៈ អ្នកជាមនុស្សទ័លក្រជាមនុស្សឥតទីពឹង យើងនឹងឲ្យទ្រព្យដែលរកទីបំផុតមិនបានដល់អ្នក អ្នកចូរ*

ពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃ ព្រះពុទ្ធកុំមានដល់យើង ព្រះធម៌កុំមានដល់យើង ព្រះសង្ឃកុំមានដល់យើងឡើយ ។ លំដាប់នោះ សុប្បពុទ្ធកុដ្ឋិពោលនឹងសក្កទេវរាជនោះថា លោកជានរណា?” ។

សក្កៈ. យើងជាសក្កទេវរាជ ។

សុប្បពុទ្ធៈ. នែបុគ្គលអន្ធពាល មិនចេះអៀនខ្មាស អ្នកជាបុគ្គលមិនសមគួរនិយាយជាមួយយើងទេ អ្នកនិយាយនឹងយើងថា យើងជាមនុស្សទ័លក្រ ជាមនុស្សដល់នូវសេចក្តីលំបាក ជាមនុស្សកំព្រាឥតទីពឹង ប៉ុន្តែយើងមិនមែនជាមនុស្សដល់នូវសេចក្តីលំបាក មិនមែនជាមនុស្សទ័លក្រ មិនមែនជាមនុស្សកំព្រាឥតទីពឹងដូចអ្នកនិយាយនោះទេ យើងជាអ្នកមាននូវសេចក្តីសុខ មានទ្រព្យច្រើន ៖

> ទ្រព្យទាំងនេះ គឺ ទ្រព្យ គឺ សទ្ធា ១ ទ្រព្យ គឺ សីល ១
> ទ្រព្យ គឺ ហិរិ ១ ទ្រព្យ គឺ ឱត្តប្បៈ ១ ទ្រព្យ គឺ សុតៈ ១
> ទ្រព្យ គឺ ចាគៈ ១ បញ្ញា ជាទ្រព្យទី ៧ រមែងមានដល់
> បុគ្គលណា ទោះបីជាស្ត្រីក្តី ជាបុរសក្តី បណ្ឌិតទាំងឡាយ
> ពោលបុគ្គលនោះថា ជាមនុស្សមិនទ័លក្រ ជីវិតរបស់បុគ្គល
> នោះ មិនសាបសូន្យទេ ។

ព្រោះហេតុនោះ អរិយទ្រព្យ ៧ ប្រការនេះ មានដល់ជនទាំងឡាយណា

ជនទាំងឡាយនោះ ព្រះពុទ្ធទាំងឡាយ ឬព្រះបច្ចេកពុទ្ធទាំងឡាយ រមែងមិនពោលថា ជាមនុស្សទ័លក្រឡើយ ។

សក្កទេវរាជ ទ្រង់ស្តាប់នូវពាក្យរបស់សុប្បពុទ្ធៈនោះហើយ ទ្រង់លះបង់សុប្បពុទ្ធកុដ្ឋិទុកត្រង់ចន្លោះផ្លូវហើយ ស្តេចទៅកាន់សំណាក់របស់ព្រះសាស្តា ក្រាបទូលនូវការឆ្លើយឆ្លងទាំងអស់ចំពោះព្រះសាស្តា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងសក្កទេវរាជថា "ម្នាលសក្កៈ សូម្បីទាំងរយទាំងពាន់នៃទេវតាទាំងឡាយប្រាកដដូចជាព្រះអង្គ ក៏មិនអាចនឹងញ៉ាំងសុប្បពុទ្ធកុដ្ឋិឲ្យពោលថា ព្រះពុទ្ធមិនមែនព្រះពុទ្ធ ព្រះធម៌មិនមែនព្រះធម៌ ព្រះសង្ឃមិនមែនព្រះសង្ឃបានឡើយ ។

ចំណែកសុប្បពុទ្ធកុដ្ឋិ ទៅកាន់សំណាក់ព្រះសាស្តា បានទទួលនូវបដិសណ្ឋារៈអំពីព្រះសាស្តាហើយ ក្រាបទូលគុណដែលខ្លួនបានហើយចំពោះព្រះសាស្តា ក្រោកចាកអាសនៈចៀសចេញទៅ ។ គ្រានោះ មេគោកូនខ្ចីវែធផ្តាច់ជីវិតសុប្បពុទ្ធកុដ្ឋិ ដែលជាអ្នកចៀសចេញទៅមិនយូរប៉ុន្មាននោះ ។

## បុព្វកម្មរបស់សុប្បពុទ្ធកុដ្ឋិ និងមេគោ

បានឮថា មេគោដែលមានកូនខ្ចីនោះ មានយក្ខិនីមួយរូប ចូលមេគោនោះ និងបានផ្តាច់ផ្តិលនូវជីវិតជន ៤ នាក់ គឺ កុលបុត្រឈ្មោះបុក្កុសាតិ ១ ពាហិយទារុចីរិយៈ ១ នាយចោរឃាតកៈឈ្មោះតម្ពទាឋិកៈ (ចង្កូមក្រហម) ១ និងសុប្បពុទ្ធកុដ្ឋិ ១ ម្នាក់មួយរយអត្តភាព ។

បានឮថា ក្នុងអតីតកាល ជនទាំងនោះជាសេដ្ឋីបុត្រទាំង ៤ នាក់ នាំស្ត្រីពេស្យាដែលជានគរសោភិនីម្នាក់ទៅកាន់ឧទ្យាន សប្បាយអស់មួយថ្ងៃ ក្នុងវេលាល្ងាច ប្រឹក្សាគ្នាយ៉ាងនេះថា ក្នុងទីនេះមិនមានអ្នកដទៃ យើងទាំងឡាយនឹងកាន់យកកហាបណៈ ១ ពាន់ និងគ្រឿងប្រដាប់ទាំងអស់ដែលពួកយើងឲ្យដល់ស្ត្រីនេះ ហើយសម្លាប់ស្ត្រីនេះចោលសឹមទៅ ។ ស្ត្រីនោះស្តាប់ពាក្យសម្តីរបស់សេដ្ឋីបុត្រទាំងនោះហើយ គិតថា ជនទាំងនេះមិនមានសេចក្តីអៀនខ្មាសអភិរម្យ (ត្រេកត្រអាល) ជាមួយនឹងយើងហើយ ឥឡូវនេះ ប្រាថ្នានឹងសម្លាប់យើងទៀត យើងនឹងដឹងកិច្ចដែលគួរធ្វើដល់ជនទាំងនេះ ។ កាលត្រូវជនទាំងនោះសម្លាប់ ក៏បានធ្វើសេចក្តីប្រាថ្នាថា សូមឲ្យយើងបានជាយក្ខិនី ជាស្ត្រីអាចដើម្បីញ៉ាំងសេដ្ឋីបុត្រទាំងនោះឲ្យស្លាប់ ដូចដែលពួកអ្នកទាំងនេះសម្លាប់យើង ដូច្នោះ ។

ភិក្ខុច្រើនរូប ក្រាបទូលការធ្វើកាលកិរិយារបស់សុប្បពុទ្ធកុដ្ឋិ ចំពោះព្រះមានព្រះភាគ ហើយទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន គតិរបស់សុប្បពុទ្ធកុដ្ឋិនោះ តើដូចម្តេច ព្រោះហេតុអ្វី ទើបសុប្បពុទ្ធកុដ្ឋិដល់នូវភាពជាមនុស្សមានរោគឃ្លង់" ។ ព្រះសាស្តា ទ្រង់ព្យាករណ៍សុប្បពុទ្ធកុដ្ឋិនោះ បានសម្រេចសោតាបត្តិផលហើយ កើតក្នុងភពតាវត្តិង្ស និងការឃើញ **ព្រះតគរសិខី-បច្ចេកពុទ្ធ** ហើយខាកស្តោះ (ទឹកមាត់) ហើយចៀសចេញទៅខាងឆ្វេង[1] ធេះ

---

១ អបព្យាមំ កត្វា : គេចចេញខាងឆ្វេង ។ ធម្មតាបណ្ឌិត ឃើញពុទ្ធបុគ្គល រមែងគេចខាងស្តាំ ។

ក្នុងនរកអស់កាលដ៏យូរ ដល់នូវភាពជាអ្នកមានរោគឃ្លង់ ក្នុងកាលឥឡូវនេះ ដោយវិបាកកម្មដ៏សេស ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សត្វទាំងនេះ ធ្វើតែកម្មដែលមានផលដ៏ឈឺផ្សាចំពោះខ្លួនឯង ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ឲ្យក្រៃលែងឡើង ក៏ត្រាស់ព្រះគាថានេះថា ៖

ចរន្តិ ពាលា ទុម្មេធា អមិត្តេនេវ អត្តនា
ករោន្តា បាបកំ កម្មំ យំ ហោតិ កដុកប្ផលំ ។

ពួកជនពាលមិនមានប្រាជ្ញា មានខ្លួនដូចជាសត្រូវ តែង
ធ្វើកម្មលាមក ដែលជាអំពើមានផលដ៏ក្តៅក្រហាយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ចរន្តិ** (ត្រាច់ទៅ) សេចក្តីថា រមែងត្រាច់ទៅ ធ្វើនូវកម្មដែលជាអកុសលតែម្យ៉ាង ដោយឥរិយាបថទាំង ៤ ។ ជនទាំងឡាយ អ្នកមិនដឹងនូវប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ឈ្មោះថា ពាល ក្នុងបទថា ពាលា នេះ ។ បទថា **ទុម្មេធា** (មានបញ្ញាថោកទាប) គឺ អ្នកមានបញ្ញាអាក្រក់ (ឥតបញ្ញា) ។ បទថា **អមិត្តេនេវ** (មានខ្លួនដូចជាសត្រូវ) សេចក្តីថា ប្រៀបដូចជាបុគ្គលមានពៀរ មិនមែនជាមិត្ត ។ បទថា **កដុកប្ផលំ** (មានផលដ៏ក្តៅក្រហាយ) សេចក្តីថា មានផលដ៏ឈឺផ្សា គឺ មានទុក្ខជាផល ។

ក្នុងកាលចប់ព្រះទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ

*មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ ។*

ចប់ រឿងសុប្បពុទ្ធកុដ្ឋិ

# ៨. រឿងបុរសអ្នកស្រែ

ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបុរសអ្នកភ្ជួរស្រែម្នាក់ ត្រាស់ព្រះធម៌ទេសនានេះថា **ន តំ កម្មំ កតំ សាធុ (កម្មនោះដែលបុគ្គលធ្វើហើយ មិនល្អឡើយ)** ជាដើម ។

ចោរចូលលួចទ្រព្យត្រកូលអ្នកស្ដុកស្ដម្ភ

បានឮថា អ្នកស្រែនោះ ភ្ជួរស្រែមួយកន្លែង ដែលនៅមិនឆ្ងាយអំពីក្រុងសាវត្ថី ។ ពួកចោរចូលទៅកាន់នគរតាមលូទឹក ជីកឧម្មង្គ (រូងដែលជីកលុងក្នុងដី ឬភ្នំអាចដើរបាន) ចូលក្នុងត្រកូលអ្នកស្ដុកស្ដម្ភមួយ លួចយកមាសនិងប្រាក់ជាច្រើន ហើយក៏ចេញទៅតាមលូទឹកនោះឯង ។ ចោរម្នាក់មានចិត្តមិនស្មោះត្រង់នឹងចោរទាំងនោះ បានលាក់បង្វេចទ្រព្យ ១ ពាន់ ទុកក្នុងថ្នក់សំពត់ ហើយធ្វើដំណើរទៅដល់ស្រែនោះ ក៏បែងចែកទ្រព្យជាមួយនឹងចោរទាំងនោះ ហើយកាន់ដើរទៅ ដោយមិនបានដឹងថា បង្វេចទ្រព្យដែលលាក់ទុកនឹងថ្នក់សំពត់ធ្លាក់នៅទីដែលចែកទ្រព្យនោះ ។

ព្រះសាស្ដាទ្រង់ឃើញឧបនិស្ស័យរបស់អ្នកស្រែ

ក្នុងថ្ងៃនោះ ពេលជិតភ្លឺ ព្រះសាស្ដាទ្រង់ពិចារណាមើលសត្វលោក ទ្រង់ឃើញបុរសអ្នកភ្ជួរស្រែនោះ ចូលក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ហើយទ្រង់ពិចារណាថា "ហេតុអ្វីហ្ន៎ នឹងមាន" ទ្រង់ឃើញហេតុនេះថា

អ្នកស្រែនោះ នឹងទៅភ្ជួរស្រែពីព្រលឹម សូម្បីពួកម្ចាស់ទ្រព្យក៏ទៅតាមស្នាមជើងរបស់ចោរទាំងឡាយ ហើយឃើញបង្វេចទ្រព្យ ១ ពាន់ ក្នុងស្រែរបស់បុរសអ្នកភ្ជួរស្រែនោះ ហើយក៏នឹងចាប់បុរសអ្នកភ្ជួរស្រែនោះ វៀរតថាគតចេញហើយ អ្នកដទៃជាសាក្សីរបស់បុរសអ្នកភ្ជួរស្រែនោះមិនមាន សូម្បីធម៌ដែលជាឧបនិស្ស័យនៃសោតាបត្តិមគ្គរបស់អ្នកស្រែនោះក៏មាន តថាគតគួរទៅកាន់ទីនោះ" ។ ចំណែកអ្នកស្រែនោះ ទៅភ្ជួរស្រែពីព្រលឹម ។ ព្រះសាស្តាមានព្រះអានន្ទត្ថេរជាបច្ឆាសមណៈ ស្តេចយាងទៅកាន់ទីនោះ ។ អ្នកស្រែឃើញព្រះសាស្តា ក៏ចូលទៅថ្វាយបង្គំព្រះមានព្រះភាគ ហើយភ្ជួរស្រែតទៅទៀត ។ ព្រះសាស្តាទ្រង់មិនបានត្រាស់នូវពាក្យអ្វីៗ ទៅកាន់អ្នកស្រែនោះឡើយ ស្តេចទៅកាន់ទីដែលបង្វេចទ្រព្យ ១ ពាន់ នោះធ្លាក់ ទ្រង់ទតឃើញបង្វេចទ្រព្យនោះហើយ ក៏ត្រាស់ទៅកាន់ព្រះអានន្ទថា "ម្នាលអានន្ទ អ្នកឃើញអាសិរពិសទេ" ព្រះអានន្ទទូលថា "ឃើញ ព្រះអង្គ អាសិរពិសកាច" ។ អ្នកស្រែបានឮពាក្យនោះហើយ ក៏គិតថា "ទីនេះ ជាទីត្រាច់ទៅក្នុងកាល ឬក្នុងវេលាវិកាលរបស់យើង បានឮថា អាសិរពិសមាននៅទីនោះ" កាលព្រះសាស្តាត្រាស់ពាក្យមានប្រមាណប៉ុណ្ណោះ ទ្រង់ចៀសចេញទៅ ក៏កាន់យកជន្ទញដើរទៅ ដោយតាំងចិត្តថា យើងនឹងសម្លាប់អាសិរពិសនោះ ឃើញបង្វេចទ្រព្យនោះហើយ គិតថា "ពាក្យនោះ ប្រាកដជាពាក្យដែលព្រះសាស្តា ត្រាស់សំដៅយកបង្វេចទ្រព្យនេះហើយមើលទៅ ក៏កាន់យកបង្វេចទ្រព្យនោះត្រឡប់ទៅវិញ ព្រោះខ្លួនជាមនុស្ស

មិនឃ្លាស ទើបបិទបាំងដោយអាចម៍ដីក្នុងទីដ៏សមគួរមួយ ហើយភ្ជួរស្រែបន្តទៅទៀត ។

## អ្នកស្រែត្រូវចាប់យកទៅប្រហារជីវិត

ម្ចាស់ទ្រព្យនោះ កាលរាត្រីទៅ ទើបដឹងថា ចោរចូលលួចទ្រព្យក្នុងផ្ទះ ក៏ដើរតាមស្នាមជើងចោរ ទៅដល់ស្រែនោះ ឃើញនូវទីកន្លែងដែលពួកចោរចែកទ្រព្យគ្នាក្នុងស្រែនោះ បានឃើញស្នាមជើងរបស់អ្នកស្រែ ។ មនុស្សទាំងនោះ ទៅតាមស្នាមជើងរបស់អ្នកស្រែនោះ ឃើញនូវទីកន្លែងនៃបង្វេចទ្រព្យដែលបុរសអ្នកភ្ជួរស្រែនោះលាក់ទុក កកាយអាចម៍ដីចេញហើយ កាន់យកនូវបង្វេចទ្រព្យ គម្រាមថា "ឯងប្លន់ផ្ទះយើងហើយ មកធ្វើដូចជាអ្នកភ្ជួរស្រែអ្វី វាយដោយដំបងនាំទៅថ្វាយព្រះរាជា ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវរឿងនោះហើយ ក៏បញ្ជាឲ្យប្រហារជីវិតបុរសអ្នកភ្ជួរស្រែនោះ ។ ពួករាជបុរស ចងបុរសអ្នកស្រែនោះឲ្យមានដៃទៅខាងក្រោយ វាយដោយរំពាត់ផ្តៅនាំទៅកាន់ទីសម្លាប់ ។ បុរសអ្នកភ្ជួរស្រែនោះ ត្រូវរាជបុរសវាយដោយផ្តៅ មិនពោលនូវពាក្យអ្វីៗដទៃឡើយ ពោលតែពាក្យថា "ម្នាលអានន្ទ អ្នកឃើញអាសិរពិសទេ ឃើញព្រះអង្គ អាសិរពិសកាច" ។ គ្រានោះ ពួករាជបុរសសួរបុរសអ្នកភ្ជួរស្រែនោះថា "អ្នក ពោលពាក្យរបស់ព្រះសាស្ដា និងពាក្យរបស់ព្រះអានន្ទប៉ុណ្ណោះ ព្រោះហេតុអ្វី" បុរសអ្នកភ្ជួរស្រែនោះឆ្លើយថា "កាលយើងបានគាល់ព្រះរាជា ទើបយើងប្រាប់" ក៏នាំទៅកាន់សម្នាក់ព្រះរាជា ក្រាបទូលរឿងនោះចំពោះព្រះរាជា ។

## អ្នកស្រែរួចអំពីទោសព្រោះអាងព្រះសាស្តាជាសាក្សី

គ្រានោះ ព្រះរាជាត្រាស់សួរបុរសអ្នកភ្ជួរស្រែនោះថា “ព្រោះហេតុអ្វីទើបឯងពោលពាក្យដូច្នោះ” បុរសអ្នកភ្ជួរស្រែនោះ ក្រាបទូលថា “បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនមែនចោរទេ” ហើយក៏ក្រាបទូលរឿងថ្វាយព្រះរាជាទាំងអស់ គឺ ចាប់ផ្តើមពីកាលដែលខ្លួនចេញទៅភ្ជួរស្រែ ។ ព្រះរាជាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់បុរសអ្នកភ្ជួរស្រែនោះហើយ ត្រាស់ថា “នែ! អ្នកទាំងឡាយ បុរសអ្នកភ្ជួរស្រែនេះអាងព្រះសាស្តា ដែលជាអគ្គបុគ្គលលើលោកជាសាក្សី យើងលើកលែងទោសឲ្យបុរសអ្នកភ្ជួរស្រែនេះមិនទាន់សមគួរទេ យើងនឹងដឹងនូវកិច្ចដែលគួរធ្វើក្នុងរឿងនេះ” ដូច្នេះ ហើយទ្រង់នាំបុរសអ្នកភ្ជួរស្រែនោះទៅកាន់សំណាក់របស់ព្រះសាស្តាក្នុងវេលាល្ងាច ទូលសួរព្រះសាស្តាថា “បពិត្រព្រះមានព្រះភាគ ព្រះអង្គស្តេចបានទៅកាន់កន្លែងដែលអ្នកស្រែនោះភ្ជួរជាមួយនឹងព្រះអានន្ទឬ” ។

ព្រះសាស្តា. ថ្វាយព្រះពរ មហាបពិត្រ តថាគតទៅ ។

ព្រះរាជា. ព្រះអង្គទ្រង់ទតឃើញអ្វីក្នុងស្រែនោះ ។

ព្រះសាស្តា. ថ្វាយព្រះពរ មហាបពិត្រ តថាគតទតឃើញបង្វេចទ្រព្យ ១ ពាន់ ។

ព្រះរាជា. ព្រះអង្គទ្រង់ទតឃើញហើយ ទ្រង់ត្រាស់នូវពាក្យអ្វីខ្លះ ។

ព្រះសាស្តា. ថ្វាយព្រះពរ មហាបពិត្រ តថាគតត្រាស់នូវពាក្យនេះ ។

*ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើបុរសនេះ មិនបានអាង បុគ្គលដូចព្រះអង្គជាសាក្សីទេ គេនឹងមិនមាននូវជីវិត ប៉ុន្តែបុរសអ្នកភ្ជួរស្រែ នេះ បានពោលពាក្យដែលព្រះអង្គត្រាស់ហើយ ទើបបាននូវជីវិត ។*

មិនគួរធ្វើកម្មដែលឱ្យផលដ៏ក្តៅក្រហាយក្នុងកាលជាខាងក្រោយទេ

*ព្រះសាស្តា ទ្រង់ស្តាប់នូវព្រះរាជតម្រាស់នោះហើយ ត្រាស់ថា "ថ្វាយ ព្រះពរមហាបពិត្រ តថាគតពោលពាក្យមានប្រមាណប៉ុណ្ណេះ ហើយទៅ សេចក្តី ក្តៅក្រហាយក្នុងកាលជាខាងក្រោយរមែងមាន ព្រោះធ្វើនូវកម្មណា កម្មនោះ បុគ្គលដែលជាបណ្ឌិត មិនគប្បីធ្វើឡើយ" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិ ដើម្បីសម្តែងព្រះធម៌ ក៏ត្រាស់ព្រះគាថានេះថា ៖*

*ន តំ កម្មំ កតំ សាធុ យំ កត្វា អនុតប្បតិ*
*យស្ស អស្សុមុខោ រោទំ វិបាកំ បដិសេវតិ ។*

*បុគ្គលធ្វើកម្មណាហើយ រមែងក្តៅក្រហាយ ឬមានមុខ*
*ប្រឡាក់ដោយទឹកភ្នែក ស្រែកយំ ទទួលផលនៃកម្មណា*
*កម្មដែលគេធ្វើហើយនោះ ឈ្មោះថា ជាកម្មមិនល្អឡើយ ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **យំ កត្វា** (ធ្វើកម្មណាហើយ) សេចក្តីថា បុគ្គលធ្វើនូវកម្មណា ដែលអាចញុំាងសត្វឲ្យកើតក្នុងអបាយភូមិទាំងឡាយ មាន នរកជាដើម បានដល់ មានទុក្ខជាកម្រៃ កាលតាមរឭកដល់ ឈ្មោះថា រមែង*

ក្តៅក្រហាយក្នុងកាលជាខាងក្រោយ គឺ រមែងសោយសោករឿយៗ ក្នុងខណៈដែលរឭកដល់ កម្មនោះ ដែលបុគ្គលធ្វើហើយមិនល្អឡើយ គឺ មិនប្រពៃ បានដល់ មិនល្អ ។ បទថា **យស្ស អស្សុមុខោ (ជាអ្នកមានមុខជោកដោយទឹកភ្នែក... នៃកម្មណា)** សេចក្តីថា ជាអ្នកមានមុខទទឹកដោយទឹកភ្នែក ទួញយំសោយនូវផលនៃកម្មណា ។

ក្នុងកាលចប់ព្រះធម៌ទេសនា ឧបាសកអ្នកក្លូវស្រែ បានសម្រេចសោតាបត្តិផល ។ សូម្បីភិក្ខុដែលមកប្រជុំគ្នាក្នុងទីនោះ ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះឯង ។

ចប់ រឿងអ្នកស្រែ

# ៩. រឿងនាយសុមនមាលាការ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធនាយមាលាការឈ្មោះ សុមនៈ ត្រាស់ព្រះធម៌ទេសនានេះថា* ***តញ្ច កម្មំ កតំ សាធុ (កម្មនោះឯង ដែលបុគ្គលធ្វើហើយជាកម្មល្អ)*** *ជាដើម ។*

## ព្រះសាស្តាស្តេចយាងបិណ្ឌបាត

*បានស្តាប់មកថា នាយមាលាការឈ្មោះសុមនៈ បម្រើព្រះបាទពិម្ពិសារ ដោយផ្កាម្លិះ ៨ នាឡិអំពីព្រឹករាល់ៗ ថ្ងៃ រមែងបានកហាបណៈមួយថ្ងៃៗ ៨ កហាបណៈ ។ ថ្ងៃមួយ កាលនាយមាលាការនោះ កាន់ផ្កាទៅដើម្បីថ្វាយព្រះបាទពិម្ពិសារ គ្រាន់តែចូលទៅកាន់ព្រះនគរភ្លាម ព្រះមានព្រះភាគជាម្ចាស់ ដែលមានភិក្ខុសង្ឃជាច្រើនអង្គហែហម ទ្រង់បញ្ចេញនូវព្រះរស្មីមានពណ៌ ៦ ប្រការ ទ្រង់ចូលទៅកាន់ព្រះនគរដើម្បីបិណ្ឌបាត ដោយអានុភាពដ៏ធំ ដោយពុទ្ធលីលាដ៏ធំ ។ ពិតហើយ ក្នុងកាលខ្លះ ព្រះមានព្រះភាគទ្រង់បិទបាំងព្រះរស្មីមានពណ៌ ៦ ដោយចីវរ ហើយស្តេចយាងទៅ ដូចជាភិក្ខុដែលមានការត្រាច់ទៅបិណ្ឌបាតជាវត្តមួយរូប ដូចជាកាលស្តេចយាងទៅទទួលព្រះអង្គុលិមាល អស់ចម្ងាយផ្លូវ ៣០ យោជន៍ , គ្រាខ្លះ ទ្រង់បញ្ចេញព្រះរស្មីមានពណ៌ ៦ ប្រការ ដូចក្នុងកាលដែលទ្រង់បញ្ចេញព្រះរស្មីក្នុងពេលស្តេចចូលទៅកាន់ក្រុងកបិលពស្តុជាដើម ។ សូម្បីក្នុងថ្ងៃនោះ ព្រះមានព្រះភាគ ក៏ទ្រង់បញ្ចេញ*

ព្រះរស្មីមានពណ៌ ៦ អំពីព្រះសរីរៈ ស្តេចចូលទៅកាន់ក្រុងរាជគ្រឹះ ដោយពុទ្ធានុភាពដ៏ធំ ដោយព្រះពុទ្ធលីលាដ៏ធំ ។

នាយមាលាការបូជាព្រះសាស្តាដោយផ្កាម្លិះ

គ្រានោះ នាយមាលាការឃើញអត្តភាពរបស់ព្រះមានព្រះភាគ ប្រាកដស្មើដោយរតនៈដ៏មានតម្លៃ និងមាសដ៏មានតម្លៃ រមិលមើលនូវអត្តភាពដែលប្រដាប់ហើយដោយលក្ខណៈ ៣២ ប្រការ មានចំណែកលម្អនៃសិរី គឺ អនុព្យញ្ជនៈ ៨០ ក៏មានចិត្តជ្រះថ្លា ហើយគិតថា “តើយើងបានវត្ថុអ្វីដើម្បីបូជាព្រះតថាគត ឲ្យសមនឹងព្រះសរីរៈរបស់ព្រះអង្គទៅហ្ន៎” កាលមិនឃើញវត្ថុដទៃក្រៅអំពីផ្កាម្លិះ ដែលត្រូវយកទៅថ្វាយព្រះរាជា ក៏គិតថា “យើងនឹងបូជាព្រះមានព្រះភាគ ដោយផ្កាម្លិះទាំងនេះ” ក៏បានគិតទៀតថា “ផ្កាម្លិះទាំងនេះ ជាផ្កាសម្រាប់ថ្វាយព្រះរាជា ជាប្រចាំ” ព្រះរាជា កាលទ្រង់មិនបានផ្កាទាំងនេះ នឹងបញ្ជាឲ្យចាប់យើងចង ឬក៏បញ្ជាឲ្យសម្លាប់យើង ឬក៏ទ្រង់បញ្ជាឲ្យនិរទេសយើងចេញចាកដែនមិនខាន យើងនឹងធ្វើដូចម្តេចហ្ន៎” គ្រានោះ ការគិតយ៉ាងនេះបានកើតមានដល់នាយមាលាការនោះថា “ទោះព្រះរាជាទ្រង់សម្លាប់យើងក៏ដោយ ឬក៏ទ្រង់និរទេសយើងចេញចាកដែនក៏ដោយ យើងយល់ព្រមទាំងអស់ ក៏ព្រះរាជានោះ សូម្បីកាលព្រះរាជទានទ្រព្យដល់យើង ក៏ព្រះរាជទានទ្រព្យឲ្យគ្រាន់តែចិញ្ចឹមជីវិតក្នុងអត្តភាពនេះប៉ុណ្ណោះ ចំណែកការបូជាព្រះសាស្តា នឹងបានជាប្រយោជន៍ និងសេចក្តីសុខដល់យើងអស់សែនកោដិកប្បជាអនេក ក៏បាន”

លះបង់ជីវិតរបស់ខ្លួនថ្វាយព្រះតថាគត ។ នាយមាលាការនោះគិតថា "បើចិត្តជ្រះថ្លារបស់យើងមិនត្រឡប់ត្រឹមណា យើងនឹងធ្វើការបូជាត្រឹមនោះ" គេជាអ្នករីករាយហើយ បានបូជាផ្កាម្លិះចំពោះព្រះសាស្តាដោយចិត្តរីករាយនោះ ។

## សេចក្តីអស្ចារ្យរបស់ផ្កាម្លិះដែលជាពុទ្ធបូជា

នាយមាលាការនោះបូជាដូចម្តេច? ដំបូង នាយមាលាការបាចផ្កាពីរក្តាប់ឡើងទៅខាងលើព្រះតថាគត ។ ផ្កាពីរក្តាប់នោះ បានតាំងនៅជាពិដានខាងលើព្រះសិរសា ។ គាត់បាចផ្កាពីរក្តាប់ដទៃទៀត ផ្កាពីរក្តាប់នោះ បានសំយុងចុះមកតាំងនៅខាងព្រះហស្តស្តាំព្រះមានព្រះភាគ មានអាការដូចជាវាំងយោល ។ គាត់បាចផ្កាពីរក្តាប់ដទៃទៀត ផ្កាពីរក្តាប់នោះ បានសំយុងចុះមកតាំងនៅខាងក្រោយព្រះបិដ្ឋ: (ខ្នង) នៃព្រះមានព្រះភាគដូចគ្នា ។ គាត់បាចផ្កាពីរក្តាប់ដទៃទៀត ផ្កាពីរក្តាប់នោះបានសំយុងចុះមកតាំងនៅខាងព្រះហស្តឆ្វេង ។ ផ្កា ៨ នាឡិ ជា ៨ ក្តាប់ ហ៊ុំព័ទ្ធព្រះតថាគតក្នុងទិសទាំង ៤ ដោយប្រការដូច្នេះ ។ មានផ្លូវល្មមដូចទ្វារសម្រាប់យាងទៅខាងមុខប៉ុណ្ណោះ ។ ដួងនៃផ្កាទាំងឡាយមានមុខបែរចូលខាងក្នុង ចំណែកត្របកចេញទៅខាងក្រៅ ។ ព្រះមានព្រះភាគព្រះអង្គស្តេចយាងទៅ ហាក់ដូចជាស្រោបដោយផែនប្រាក់ ។ ផ្កាទាំងឡាយសូម្បីមិនមានចិត្ត អាស្រ័យបុគ្គលអ្នកមានចិត្តមិនបែកខ្ញែក មិនធ្លាក់ចុះ រមែងទៅជាមួយព្រះសាស្តា រមែងឈប់ក្នុងទីដែលព្រះមានព្រះភាគទ្រង់ប្រថាប់ ។ ព្រះរស្មីទាំងឡាយ ហាក់ដូចជាផ្លេកបន្ទោរទាំងសែន ផ្សាយចេញអំពីព្រះសរីរៈ

របស់ព្រះសាស្តា ព្រះរស្មីដែលផ្សាយចេញ (អំពីព្រះកាយនោះ) ផ្សាយចេញទាំងខាងមុខខាងក្រោយ ទាំងខាងឆ្វេងខាងស្តាំ និងខាងលើព្រះសិរ ។ ព្រះរស្មីសូម្បីតែ ១ មិនបានបាត់ឡើយ រមែងផ្សាយទៅតាមត្រង់ខាងព្រះភក្រ្ត ធ្វើប្រទក្សិណព្រះសាស្តា ៣ ជុំហើយ បានជាព្រះរស្មីមានប្រមាណប៉ុនដើមត្នោតជំទង់ ផ្សាយត្រង់ទៅខាងមុខ ។ អ្នកនគរទាំងអស់បានភ្ញាក់ផ្អើលគ្រប់ៗ គ្នា ។ បណ្តាជន ១៨ កោដិ គឺ ខាងក្នុងព្រះនគរ ៩ កោដិ ខាងក្រៅ ៩ កោដិ បុរស ឬស្រ្តីសូម្បីតែម្នាក់ ឈ្មោះថា មិនកាន់យកកិក្ខាចេញទៅ មិនមាន ។ មហាជនបន្លឺសីហនាទ លើកនូវផ្ទាំងសំពត់ទាំងពាន់ឡើងនៅខាងមុខព្រះសាស្តានោះឯង ។ សូម្បីព្រះសាស្តា ដើម្បីនឹងធ្វើគុណរបស់នាយមាលាការ ឲ្យប្រាកដ ស្តេចក៏បានត្រាច់ទៅក្នុងព្រះនគរអស់ប្រមាណ ៣ គាវុត តាមផ្លូវដែលលាន់ឮដោយសំឡេងស្គរនោះឯង ។ សរីរៈទាំងអស់របស់នាយមាលាការ ពេញប្រៀបទៅដោយបីតិ ៥ ប្រការ ។ នាយមាលាការ ទៅជាមួយព្រះសាស្តាបានបន្តិចក៏ចូលទៅខាងក្នុងពុទ្ធរស្មី ហាក់ដូចជាលិចចុះក្នុងរសនៃមនោសិលា សរសើរព្រះសាស្តា ថ្វាយបង្គំរួច កាន់កញ្ច្រែងទទេនោះឯងទៅផ្ទះ ។

គ្រានោះ ភរិយាសួរគាត់ថា ផ្កានៅទីណា ។

មាលាការ. យើងបូជាព្រះសាស្តាហើយ ។

ភរិយា. ឥឡូវនេះ អ្នកនឹងបានអ្វីថ្វាយព្រះរាជា ។

មាលាការ. ព្រះរាជាទ្រង់នឹងសម្លាប់យើងក៏បាន និរទេសយើងចេញ

ចាកដៃនក៏បាន យើងសុខចិត្តទាំងអស់ ពីព្រោះយើងបានលះបង់ជីវិតបូជាព្រះសាស្តាហើយ ផ្កាទាំងអស់មាន ៨ ក្តាប់ ការបូជាបែបនេះបានកើតឡើងហើយ មហាជនធ្វើនូវការហ៊ោដោយមានសំឡេងទាំងពាន់ ត្រាច់ទៅជាមួយព្រះសាស្តា ទុំះជាសំឡេងហ៊ោរបស់មហាជន ក្នុងទីនោះ ។

ភរិយាមិនជ្រះថ្លាប្តីព្រះរាជា

លំដាប់នោះ ភរិយារបស់នាយមាលាការ ជាស្ត្រីអន្ធពាល មិនញុំាងសេចក្តីជ្រះថ្លាក្នុងព្រះបាដិហារ្យបែបនោះឲ្យកើតឡើង ជេរគាត់ ហើយពោលថា "ធម្មតាព្រះរាជាទាំងឡាយ ជាមនុស្សកាច ទ្រង់ខ្វាល់តែម្តង ក៏រមែងធ្វើនូវសេចក្តីវិនាសសូម្បីច្រើន មានការកាត់ដៃ និងជើងជាដើម សេចក្តីវិនាសក៏គប្បីមានដល់ខ្ញុំ ព្រោះកម្មដែលអ្នកធ្វើហើយ" ក៏នាំបុត្រទាំងឡាយទៅកាន់រាជត្រកូល ត្រូវព្រះរាជាត្រាស់ឲ្យហៅមក ហើយសួរថា "នាងដ៏ចម្រើន តើមានហេតុអ្វី" ក៏ក្រាបទូលព្រះរាជាថា "បពិត្រព្រះសម្មតិទេព ស្វាមីរបស់នាងខ្ញុំម្ចាស់ យកផ្កាសម្រាប់ថ្វាយព្រះអង្គ បូជាព្រះសាស្តាហើយ មានដៃទទេមកកាន់ផ្ទះ ត្រូវនាងខ្ញុំម្ចាស់សួរថា ផ្កានៅទីណា ក៏ពោលពាក្យបែបនេះ នាងខ្ញុំម្ចាស់ជេរគាត់ ហើយពោលថា ធម្មតា ព្រះរាជាទាំងឡាយទ្រង់ជាមនុស្សកាច ទ្រង់ខ្វាល់តែម្តង ក៏រមែងធ្វើនូវសេចក្តីវិនាសសូម្បីច្រើន ដោយមានការកាត់អវយវៈទាំងឡាយមានដៃ និងជើងជាដើម សេចក្តីវិនាសគប្បីមានសូម្បីដល់យើង ព្រោះកម្មដែលអ្នកបានធ្វើហើយ" ដូច្នេះ ទើបបោះបង់គាត់ចោលមក

កាន់ទីនេះ កម្មដែលគាត់បានធ្វើហើយ ទោះជាកម្មល្អក្តី ជាកម្មអាក្រក់ក្តី កម្មនោះចូរជារបស់គាត់តែម្នាក់ឯងចុះ បពិត្រមហារាជ សូមព្រះអង្គទ្រង់ជ្រាបថានាងខ្ញុំម្ចាស់លះបង់គាត់ចោលហើយ ។

ព្រះរាជាទ្រង់ធ្វើដូចជាខ្វាល់

ព្រះរាជាទ្រង់សម្រេចសោតាបត្តិផល ដល់ព្រមដោយសទ្ធា ជាអរិយសាវក តាំងពីបានជួបព្រះអង្គលើកដំបូងម៉្លេះ ទ្រង់ព្រះតម្រិះថា ឱហ្ន៎! ស្ត្រីនេះជាមនុស្សអន្ធពាល មិនញុំាងសេចក្តីជ្រះថ្លាក្នុងគុណបែបនេះឲ្យកើតឡើង ។ ព្រះរាជាទ្រង់ធ្វើដូចជាខ្វាល់ ហើយត្រាស់ថា "នាងនិយាយអ្វី នាយមាលាការនោះ យកផ្កាសម្រាប់បម្រើយើង បូជាព្រះសាស្តាឬ" ស្ត្រីនោះទូលថា "ព្រះករុណាថ្លៃវិសេស" ។ ព្រះរាជាទ្រង់ត្រាស់ថា "ការដែលនាងលះបង់គេចោលនោះ ប្រពៃពេកណាស់ យើងនឹងដឹងកិច្ចដែលគួរធ្វើដល់នាយមាលាការដែលជាអ្នកយកផ្កាសម្រាប់ថ្វាយយើង បូជាចំពោះព្រះសាស្តា" ។ ទ្រង់បញ្ជូនស្ត្រីនោះទៅហើយ ស្តេចទៅកាន់សំណាក់ព្រះសាស្តាដោយរហ័ស ថ្វាយបង្គំហើយស្តេចយាងទៅជាមួយព្រះសាស្តា ។ ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីជ្រះថ្លាក្នុងព្រះហឫទ័យរបស់ព្រះរាជានោះ ស្តេចក៏យាងទៅកាន់ព្រះនគរតាមថ្នល់ដែលបន្ទឹដោយសំឡេងស្គរ ហើយបានស្តេចយាងទៅកាន់ទ្វារនៃព្រះរាជដំណាក់របស់ព្រះរាជា ។ ព្រះរាជាទ្រង់ទទួលបាត្រ និងទ្រង់មានព្រះបំណងដើម្បីអារាធនាព្រះសាស្តា ឲ្យស្តេចចូលទៅកាន់ព្រះរាជដំណាក់ ។ ប៉ុន្តែព្រះសាស្តា ទ្រង់បាន

សម្តែងនូវអាការ គឺ ការប្រថាប់នៅនាព្រះលានហ្លួងនោះឯង ។ ព្រះរាជាទ្រង់ជ្រាបអាការនោះហើយ ក៏ត្រាស់បង្គាប់ឲ្យរាជបុរសធ្វើបារាំក្នុងខណៈនោះឯង ដោយព្រះតម្រាស់ថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរធ្វើបារាំដោយរហ័ស" ។ ព្រះសាស្តាទ្រង់ប្រថាប់ជាមួយពួកភិក្ខុក្នុងបារាំនោះឯង ។

សួរថា ព្រោះហេតុអ្វី ទើបព្រះសាស្តាស្តេចមិនយាងចូលទៅកាន់រាជដំណាក់ ។

ឆ្លើយថា (ព្រោះ) ថា ព្រះតម្រិះយ៉ាងនេះបានកើតមានដល់ព្រះអង្គថា "ប្រសិនបើតថាគតចូលទៅប្រថាប់នៅខាងក្នុង មហាជនមិនបានឃើញតថាគត គុណរបស់នាយមាលាការនឹងមិនប្រាកដ តែថា មហាជននឹងបានឃើញតថាគតដែលប្រថាប់នៅនាព្រះលានហ្លួង គុណរបស់នាយមាលាការនឹងប្រាកដ" ។

ព្រះរាជាទ្រង់ព្រះរាជទានវត្ថុមួយយ៉ាង ៨

ពិតណាស់ ព្រះពុទ្ធដ៏មានព្រះភាគជាម្ចាស់របស់យើងប៉ុណ្ណោះ ទើបអាចធ្វើនូវគុណរបស់បុគ្គលអ្នកមានគុណទាំងឡាយឲ្យប្រាកដបាន ជនដ៏សេសកាលនឹងពោលគុណរបស់បុគ្គលអ្នកមានគុណទាំងឡាយ រមែងប្រព្រឹត្តទៅដោយសេចក្តីកំណាញ់ (គឺបិទបាំង) ។ ផែនផ្កា ៤ ផ្ទាំង បានតាំងនៅក្នុងទិសទាំង ៤ ។ មហាជនចោមរោមព្រះសាស្តាហើយ ។ ព្រះរាជាទ្រង់អង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីត ។ ក្នុងវេលាស្រេចភត្តកិច្ច ព្រះសាស្តាទ្រង់ធ្វើអនុមោទនា ដែលផែនផ្កាទាំង ៤ ផ្ទាំងហែហម ដូចន័យមុន

នោះឯង កាលមហាជនបន្លឺសីហនាទអបអរ ស្តេចក៏ទ្រង់យាងទៅកាន់វិហារវិញ ។ ព្រះរាជាតាមជូនព្រះសាស្តាទៅ ត្រឡប់មកវិញ ត្រាស់បង្គាប់ឲ្យហៅនាយមាលាការមក ហើយត្រាស់សួរថា "អ្នកឃើញអ្វី ទើបបូជាព្រះសាស្តាដោយផ្កា ដែលខ្លួនគប្បីនាំមកសម្រាប់យើង" នាយមាលាការក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គគិតដូច្នេះថា ព្រះរាជាសម្លាប់យើងក្តី បំបរបង់យើងចេញចាកដែនក្តី ដូច្នេះ ទើបលះបង់ជីវិតបូជាព្រះសាស្តា" ។ ព្រះរាជាត្រាស់ថា "អ្នកឈ្មោះថាជាមហាបុរស" ហើយព្រះរាជទានរបស់ដែលគួរឲ្យឈ្មោះពួក ៨ នៃវត្ថុទាំងពួងនេះ គឺ ដំរី ៨ សេះ ៨ ទាសៈ ៨ ទាសី ៨ គ្រឿងប្រដាប់ធំៗ ៨ កហាបណៈ ៨ ពាន់ នារី ៨ នាក់ ដែលនាំមកអំពីព្រះរាជត្រកូល ប្រដាប់ដោយគ្រឿងអលង្ការទាំងពួង និងស្រុកសួយ ៨ ។

ព្រះសាស្តាទ្រង់សរសើរនាយមាលាការ

ព្រះអានន្ទត្ថេរគិតថា "ថ្ងៃនេះ សំឡេងសីហនាទទាំងពាន់ និងការលើកផ្ទាំងសំពត់ឡើងទាំងពាន់ ប្រព្រឹត្តទៅតាំងអំពីព្រលឹម ។ វិបាករបស់នាយមាលាការជាយ៉ាងណាហ្ន៎" ព្រះអានន្ទ ក៏បានទូលសួរព្រះសាស្តា ។ លំដាប់នោះព្រះសាស្តា ទ្រង់ត្រាស់ទៅកាន់ព្រះអានន្ទថា "ម្នាលអានន្ទ អ្នកកុំគិតថា កម្មដែលនាយមាលាការបានធ្វើហើយនោះ មានប្រមាណតិចតួចឲ្យសោះ ព្រោះនាយមាលាការបានលះបង់ជីវិតបូជាតថាគតហើយ គេបានញុំាងចិត្តឲ្យជ្រះថ្លាក្នុងតថាគតដោយអាការយ៉ាងនេះ នឹងមិនទៅកាន់ទុគ្គតិរហូតអស់សែនកប្ប

ដូច្នេះ ទើបទ្រង់ត្រាស់ថា ៖

> នាយមាលាការ នឹងតាំងនៅក្នុងទេវតា និងមនុស្សទាំងឡាយ នឹងមិនទៅកាន់ទុគ្គតិរហូតអស់សែនកប្ប នេះជាផលនៃកម្មនោះ ខាងក្រោយគេនឹងបានជាព្រះបច្ចេកពុទ្ធមួយអង្គ នាមថា សុមនៈ ។

ក៏កាលដែលព្រះសាស្តាស្តេចយាងដល់វិហារ ចូលទៅកាន់ព្រះគន្ធកុដិ ផ្កាម្លិះទាំងនោះ ក៏ធ្លាក់ចុះនៅត្រង់ទ្វារ ។

គួរធ្វើនូវកម្មដែលមានផលមិនក្តៅក្រហាយ

ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងសាលាធម្មសភាថា "ឱ! កម្មរបស់នាយមាលាការនេះ គួរឲ្យអស្ចារ្យណាស់ គាត់បានលះបង់ជីវិតបូជាចំពោះព្រះពុទ្ធ ដែលនៅមានព្រះជន្ម ធ្វើការបូជាដោយផ្កា ហើយបានទទួលព្រះរាជអំណោយ ឈ្មោះពួក ៨ នៃវត្ថុ ក្នុងខណៈនោះឯង" ។ ព្រះសាស្តាស្តេចចេញចាកព្រះគន្ធកុដិហើយ ទ្រង់ចូលទៅកាន់ធម្មសភា ដោយស្តេចទៅ ៣ យ៉ាង ណាមួយ ទ្រង់គង់ប្រថាប់លើពុទ្ធាសនៈហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះអ្នកទាំងឡាយអង្គុយប្រជុំគ្នាដោយកថាអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "ដោយកថាឈ្មោះនេះ" ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះពិតមែន សេចក្តីក្តៅក្រហាយក្នុងកាលជាខាងក្រោយរមែង

មិនមាន សោមនស្សប៉ុណ្ណោះ រមែងកើតឡើងក្នុងខណៈដែលរឭកដល់ហើយៗ កម្មបែបនោះ ដែលបុគ្គលគួរធ្វើដោយពិត” កាលទ្រង់តបន្តអនុសន្ធិដើម្បីសម្តែងព្រះធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

តញ្ច កម្មំ កតំ សាធុ  យំ កត្វា នានុតប្បតិ
យស្ស បតីតោ សុមនោ  វិបាកំ បដិសេវតិ ។

បុគ្គលធ្វើកម្មណាហើយ រមែងមិនក្តៅក្រហាយ ឬដល់
នូវសេចក្តីពេញចិត្ត មានចិត្តល្អ ទទួលផលនៃកម្មណា
កម្មដែលគេធ្វើហើយនោះឯង ឈ្មោះថា ជាកម្មល្អ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា យំ កត្វា (បុគ្គលធ្វើកម្មណាហើយ) សេចក្តីថា បុគ្គលធ្វើនូវកម្មណា គឺ កម្មដែលអាចញុំាងសម្បត្តិទេវតា សម្បត្តិមនុស្ស និងសម្បត្តិព្រះនិព្វានឲ្យកើតឡើង គឺ មានសុខជាកម្រៃ រមែងមិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ ដោយពិត បុគ្គលនោះ ឈ្មោះថា ជាអ្នកត្រេកអរហើយដោយកម្លាំងនៃបីតិ និងឈ្មោះថា មានចិត្តរីករាយដោយកម្លាំងនៃសោមនស្ស ក្នុងខណៈដែលរឭក ជាអ្នកកើតបីតិ និងសោមនស្សក្នុងកាលតទៅ រមែងបានសោយផលក្នុងទិដ្ឋធម៌នោះឯង កម្មនោះ ដែលបុគ្គលធ្វើហើយ ជាកម្មញុំាងប្រយោជនឲ្យសម្រេច គឺ ជាកម្ម បានដល់ ជាកម្មថ្លៃថ្នូរ ។

*ក្នុងកាលចប់ព្រះទេសនា ការត្រាស់ដឹងធម៌ ក៏បានកើតមានដល់សត្វ ៨៤.០០០ ដោយប្រការដូច្នេះឯង ។*

ចប់ រឿងនាយសុមនមាលាការ

# ១០. រឿងព្រះនាងឧប្បលវណ្ណាថេរី

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរីឈ្មោះឧប្បលវណ្ណា ត្រាស់ព្រះធម្មទេសនានេះថា **មធុវា មញ្ញតី ពាលោ** (ជនពាលរមែងសម្គាល់បាបដូចជាទឹកឃ្មុំ) ជាដើម ។*

ព្រះថេរីតាំងសេចក្ដីប្រាថ្នា

*បានស្ដាប់មកថា ព្រះថេរីនោះ តាំងសេចក្ដីប្រាថ្នាទុកទៀបបាទមូលនៃព្រះពុទ្ធទ្រង់ព្រះនាមថា **បទុមុត្តរៈ** បានធ្វើបុញ្ញកម្មទាំងឡាយអស់សែនកប្បអន្ទោលទៅមកក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ ចុតិចាកទេវលោកហើយ បដិសន្ធិក្នុងត្រកូលសេដ្ឋីនាក្រុងសាវត្ថី ។ មាតាបិតាបានដាក់ឈ្មោះឲ្យនាងថា **ឧប្បលវណ្ណា** ព្រោះនាងមានពណ៌សម្បុរដូចត្របកផ្កាឧប្បលខៀវ ។ ក្រោយមក ក្នុងកាលដែលនាងចម្រើនវ័យហើយ ព្រះរាជា និងសេដ្ឋីទាំងឡាយក្នុងជម្ពូទ្វីប បានបញ្ជូនបណ្ណាការទៅកាន់សម្នាក់របស់សេដ្ឋី ដោយពាក្យថា "សូមសេដ្ឋីឲ្យធីតាដល់យើង" ។ ឈ្មោះថា អ្នកមិនបញ្ជូនបណ្ណាការទៅ រមែងមិនមាន ។ ក្នុងគ្រានោះ សេដ្ឋីគិតថា "យើងមិនអាចយកចិត្តមនុស្សទាំងអស់បានទេ ប៉ុន្តែយើងនឹងធ្វើឧបាយមួយ" ។ សេដ្ឋីហៅធីតាមក ហើយពោលថា "កូន កូនអាចបួសបានទេ" ពាក្យរបស់សេដ្ឋីនោះ ហាក់ដូចជាប្រេងដែលគេរម្ងាស់ហើយមួយរយដង ដែលស្រោចទៅលើក្បាល ព្រោះនាងជាស្ត្រី*

កើតហើយក្នុងជាតិចុងក្រោយ ព្រោះដូច្នោះ ទើបនាងពោលទៅកាន់បិតាថា "លោកឪពុក ខ្ញុំនឹងបួស" ។ សេដ្ឋីនោះធ្វើនូវគ្រឿងសក្ការៈជាច្រើនដល់នាង ហើយនាំនាងទៅកាន់សំណាក់នាងភិក្ខុនី ឲ្យបួសហើយ ។

ព្រះនាងឧប្បលវណ្ណាថេរីសម្រេចព្រះអរហត្ត

កាលនាងបួសហើយមិនយូរ វារៈរក្សារោងឧបោសថ នាងអុជប្រទីបបោសរោងឧបោសថ ឈរកាន់យកនូវនិមិត្តនៃអណ្តាតប្រទីប សម្លឹងមើលហើយមើលទៀត ក៏ញុំាងឈាន ដែលមានតេជោកសិណជាអារម្មណ៍ឲ្យកើតឡើង ហើយធ្វើឈាននោះឯងឲ្យជាបាទ បានសម្រេចព្រះអរហត្ត ព្រមដោយបដិសម្ភិទា និងអភិញ្ញាទាំងឡាយ ។ ក្នុងសម័យថ្ងៃមួយ ព្រះថេរីនោះ ត្រាច់ទៅកាន់ទីចារិកក្នុងជនបទ ត្រឡប់មកវិញហើយ ក៏ចូលទៅកាន់ព្រៃអន្ធវ័ន ។ ក្នុងកាលនោះ ព្រះសាស្តាមិនទាន់ហាមការនៅក្នុងព្រៃរបស់ពួកនាងភិក្ខុនី ។ គ្រានោះ ពួកមនុស្សធ្វើខ្ទម (កុដិតូចៗ) ដាក់គ្រែ បាំងវាំងននទុកក្នុងព្រៃនោះ ដល់ព្រះថេរីនោះ ។ ព្រះថេរីនោះ ចូលទៅបិណ្ឌបាតក្នុងក្រុងសាវត្ថី ហើយត្រឡប់មកវិញ ។

នន្ទមាណពប្រទុស្តព្រះថេរី

ចំណែកនន្ទមាណព ដែលជាបុត្រឪពុកធំខាងមាតារបស់ព្រះថេរីនោះ មានចិត្តស្រឡាញ់ព្រះថេរីតាំងអំពីកាលដែលព្រះថេរីនៅជាគ្រហស្ថម្ល៉េះ បានដឹងថា ព្រះថេរីត្រឡប់មកវិញ ក៏ចូលទៅកាន់ព្រៃអន្ធវ័នមុនព្រះថេរីមកដល់

ចូលទៅកាន់ខ្ទមពួននៅខាងក្រោមគ្រែ លុះព្រះថេរីមកដល់ ក៏ចូលទៅកាន់ខ្ទម បិទទ្វារគង់លើគ្រែ កាលកាពងងឹតក្នុងគន្ធងចក្ខុមិនទាន់បាត់ទៅ ព្រោះអាស្រ័យ ពន្លឺថ្ងៃខាងក្រៅ នន្ទមាណពក៏ចេញមកអំពីខាងក្រោមគ្រែ ឡើងកាន់គ្រែ ត្រូវ ព្រះថេរីហាមថា "បុគ្គលពាល អ្នកកុំវិនាសឡើយ បុគ្គលពាល អ្នកកុំវិនាស ឡើយ" ក៏ទ្រូស្តនីងព្រះថេរី ធ្វើនូវកម្មដែលខ្លួនប្រាថ្នាហើយ រួចក៏គេចចេញ ទៅ ។ គ្រានោះ មហាប្រឹថពីហាក់ដូចជាមិនអាចទ្រទ្រង់ទុកនូវទោសរបស់គេ នោះបាន ក៏បែកចេញជាពីរចំណែក ។ គេក៏ធ្លាក់ចូលទៅកាន់ចន្លោះផែនដី ស្លាប់ហើយទៅកើតក្នុងអវីចិមហានរក ។ ចំណែកព្រះថេរី ប្រាប់រឿងនោះដល់ ភិក្ខុនីទាំងឡាយ ។ ភិក្ខុនីក៏ប្រាប់រឿងនោះដល់ភិក្ខុទាំងឡាយ ។ ពួកភិក្ខុក៏ ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។ ព្រះសាស្តា លុះទ្រង់ព្រះជ្រាបរឿងនោះ ហើយ ត្រាស់ហៅភិក្ខុទាំងឡាយមក ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បណ្តាភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ណាមួយជាពាល កាលធ្វើកម្មលាមក ជាអ្នកត្រេអរីករាយ ហាក់ដូចជាមានចិត្តអណ្តែតឡើងឰដ៏ខាងលើ រមែងធ្វើ បាន ដូចជាបុរសទំពារស៊ីរសផ្អែម មានទឹកឃ្មុំ និងដុំស្ករជាដើម ណាមួយ" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីនឹងសម្តែងធម៌ បានត្រាស់ព្រះគាថានេះ ថា ៖

មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ ។

*បាបមិនទាន់ឲ្យផលត្រឹមណា ជនពាល តែងសម្គាល់នូវ*
*បាបនោះថា ដូចទឹកឃ្មុំ លុះតែកាលណាបាបឲ្យផល ជន*
*ពាលទើបប្រទះនូវសេចក្តីទុក្ខ ក្នុងកាលណោះ ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **មធុវា** (ដូចជាទឹកឃ្មុំ) ជាដើម សេចក្តីថា ក៏កាលបុគ្គលពាលធ្វើបាប គឺ អកុសលកម្ម កម្មនោះរមែងប្រាកដដូចជាទឹកឃ្មុំ គឺ ដូចជាវត្ថុដែលមានរសផ្អែម បានដល់ ដូចជាអំពើដែលគួរប្រាថ្នា គួរពេញចិត្ត បុគ្គលពាលនោះ រមែងសម្គាល់បាបនោះថា ដូចជាទឹកផ្អែម ដោយប្រការដូច្នេះ ។ បទថា **យាវ** (ដរាបណា) គឺ អស់កាលត្រឹមណា ។ បទថា **បាបំ ន បច្ចតិ** (បាបមិនទាន់ឲ្យផល) សេចក្តីថា ជនពាល រមែងសម្គាល់បាបនោះយ៉ាងនោះ ដរាបណាដែលបាបមិនទាន់ឲ្យផលក្នុងទិដ្ឋធម៌ ឬក្នុងសម្បរាយភព ។ បទថា **យទា ច** (ក៏កាលណា) សេចក្តីថា ក៏ក្នុងកាលណា កាលជនពាលនោះ ត្រូវទទួលនូវទារុណកម្មផ្សេងៗ ក្នុងទិដ្ឋធម៌ ឬសោយទុក្ខធំក្នុងអបាយ មាននរកជាដើមក្នុងសម្បរាយភព បាបនោះឈ្មោះថា រមែងឲ្យផល ក្នុងកាលនោះ ជនពាលនោះរមែងចូលដល់ គឺ ប្រសព្វ បានដល់ រមែងបានចំពោះនូវទុក្ខ ។*

*ក្នុងកាលចប់ព្រះទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។*

## ព្រះខីណាស្រពមិនត្រេកអរនឹងកាមសុខ

ក្នុងសម័យដទៃ មហាជនសន្ទនាគ្នាក្នុងធម្មសភាថា "សូម្បីព្រះខីណាស្រពទាំងឡាយ ក៏នៅតែត្រេកអរនឹងកាមសុខ នៅសេពកាម ដូចម្តេចនឹងមិនសេព ព្រោះព្រះខីណាស្រពទាំងនោះ មិនមែនជាឈើពុក មិនមែនជាដំបូកកណ្តៀរឯណា មានសាច់ឈាមនៅស្រស់ដូចគ្នាដែរទេតើ ព្រោះដូច្នោះ សូម្បីព្រះខីណាស្រពទាំងនោះ ក៏នៅត្រេកអរនឹងកាមសុខ នៅសេពកាមដែរ" ។ ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះអ្នកទាំងឡាយសន្ទនាគ្នាអំពីរឿងអ្វី" កាលពួកភិក្ខុក្រាបទូលថា "អំពីរឿងឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រះខីណាស្រពទាំងឡាយ មិនត្រេកអរនឹងកាមសុខ មិនសេពកាមទេ ដូចជា ដំណក់ទឹកធ្លាក់លើស្លឹកឈូករមែងមិនជាប់ រមែងមិនជក់នៅ តែងតែរមៀលធ្លាក់ទៅដោយពិត និងដូចគ្រាប់ស្ពៃ រមែងមិនជាប់ រមែងមិនតាំងនៅលើចុងដែកស្រួច តែងតែរមៀលធ្លាក់ទៅ យ៉ាងណា កាម សូម្បីទាំងពីរយ៉ាង ក៏រមែងមិនជ្រួតជ្រាប រមែងមិនតាំងនៅក្នុងចិត្តរបស់ព្រះខីណាស្រព ដូច្នោះ" ។ កាលនឹងទ្រង់បន្តអនុសន្ធិ ដើម្បីសម្តែងធម៌ ក៏ត្រាស់ព្រះគាថានេះ ក្នុងព្រាហ្មណវគ្គថា ៖

តថាគតពោល ជនណាមិនជាប់នៅក្នុងកាមទាំងឡាយ ដូចទឹកលើស្លឹកឈូក ឬដូចគ្រាប់ស្ពៃមិនជាប់នៅលើចុងដែកស្រួច នោះថា ជាព្រាហ្មណ៍ ។

សេចក្ដីនៃព្រះគាថានេះ នឹងជាក់ច្បាស់នៅក្នុងព្រាហ្មណវគ្គនោះឯង ។

ភិក្ខុនីគួរនៅក្នុងព្រះនគរ

ព្រះសាស្ដា ត្រាស់បង្គាប់ឲ្យយាងព្រះបាទបសេនទិកោសលមក ហើយត្រាស់ថា "ថ្វាយព្រះពរមហាបពិត្រ សូម្បីកុលធីតាទាំងឡាយ ក្នុងសាសនានេះ លះបង់នូវពួកញាតិ និងគំនរនៃភោគៈដ៏ច្រើនហើយបួស រមែងនៅក្នុងព្រៃ ដូចជាកុលបុត្រទាំងឡាយដែរ បុគ្គលលាមក ត្រូវរាគៈរួបរឹតហើយ រមែងបៀតបៀនភិក្ខុនីដែលជាអ្នកនៅក្នុងព្រៃទាំងនោះ ដោយអំណាចនៃការមើលងាយខ្លះ ធ្វើឲ្យដល់នូវអន្តរាយនៃព្រហ្មចរិយៈខ្លះ ព្រោះហេតុនោះ ព្រះអង្គគួរធ្វើលំនៅខាងក្នុងព្រះនគរសម្រាប់ភិក្ខុនីសង្ឃ" ។ ព្រះរាជាទ្រង់ទទួលថា "ប្រពៃហើយ" ដូច្នេះហើយ ត្រាស់បង្គាប់ឲ្យសាងលំនៅដើម្បីភិក្ខុនីក្នុងចំណែកម្ខាងនៃព្រះនគរ ។ ចាប់ផ្ដើមអំពីកាលនោះមក ពួកភិក្ខុនី រមែងនៅក្នុងចន្លោះស្រុកប៉ុណ្ណោះ ។

ចប់ រឿងព្រះនាងឧប្បលវណ្ណាថេរី

# ១១. រឿងជម្ពុកាជីវក

*កាលព្រះសាស្តាប្រថាប់គង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធជម្ពុកាជីវក ត្រាស់ព្រះធម្មទេសនានេះថា* ***មាសេ មាសេ កុសគ្គេន*** *(ដោយចុងស្បូវរាល់ៗ ខែ) ជាដើម ។*

### កុដុម្ពិកទំនុកបម្រុងព្រះថេរ

*បានឮថា ក្នុងអតីតកាល ក្នុងកាលនៃព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា* ***កស្សបៈ*** *កុដុម្ពិកម្នាក់បានសាងវិហារ (ប្រគេន) ព្រះថេរៈមួយរូប ហើយទំនុក-បម្រុងព្រះថេរៈដែលនៅក្នុងវិហារនោះដោយបច្ច័យ ៤ ជានិច្ច ។ ព្រះថេរៈឆាន់នៅក្នុងផ្ទះកុដុម្ពិកនោះជានិច្ច ។ គ្រានោះ ព្រះខីណាស្រពមួយរូប និមន្តបិណ្ឌ-បាត និមន្តទៅៗ ក៏ដល់ទ្វារផ្ទះរបស់កុដុម្ពិកនោះ ។ កុដុម្ពិកឃើញលោកហើយ ក៏មានចិត្តជ្រះថ្លានឹងឥរិយាបថរបស់លោក និមន្តឲ្យចូលទៅកាន់ផ្ទះ អង្គាសដោយភោជនដ៏ប្រណីតដោយគោរព ប្រគេនសំពត់សាដកមួយផ្ទាំងធំ ដោយប្រាប់ថា “លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ជ្រលក់នូវសំពត់សាដកនេះស្លៀកចុះ” ហើយប្រាប់ថា “លោកម្ចាស់ដ៏ចម្រើន ព្រះកេសរបស់លោកម្ចាស់វែងហើយ ខ្ញុំព្រះករុណានឹងនាំខ្មាន់ព្រះកេស មកដាក់ព្រះកេសឲ្យលោកម្ចាស់” នឹងឲ្យគេចាត់ចែងគ្រែនាំមកដើម្បីប្រយោជន៍ដល់ការសឹង ។ ភិក្ខុកុលុបកៈ (អ្នកឆាន់នៅក្នុងត្រកូលជានិច្ច) ឃើញនូវសក្ការៈរបស់ព្រះខីណាស្រពនោះហើយ*

មិនអាចញ៉ាំងចិត្តឲ្យជ្រះថ្លាបាន ក៏គិតថា "កុដុម្ពិក៍នេះ ធ្វើគ្រឿងសក្ការបូជា បែបនេះ ដល់ភិក្ខុដែលខ្លួនឃើញហើយសូម្បីមួយរំពេចប៉ុណ្ណោះ ម្តេចក៏មិន បូជាយើងដែលជាអ្នកធាន់នៅក្នុងផ្ទះអស់កាលជានិច្ច" ដូច្នេះ ក៏បានទៅកាន់ វិហារ ។ សូម្បីភិក្ខុជាព្រះខីណាស្រព ក៏បានទៅវិហារជាមួយនឹងភិក្ខុនោះដែរ ជ្រលក់សំពត់សាដកដែលកុដុម្ពិក៍ប្រគេន ហើយស្លៀក ។ កុដុម្ពិក៍ ក៏បាននាំ ខ្ញាន់ព្រះកេសទៅឲ្យដាក់ព្រះកេសប្រគេនព្រះថេរៈ និងប្រើឲ្យអ្នកបម្រើចាត់ចែង រៀបចំគ្រែហើយប្រាប់ថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តសឹង លើនេះចុះ" និមន្តព្រះថេរៈទាំងពីររូប ដើម្បីធាន់ក្នុងថ្ងៃស្អែក ហើយក៏ចៀស ចេញទៅ ។ ភិក្ខុចៅអាវាសមិនអាចអត់ទ្រាំនឹងគ្រឿងសក្ការៈ ដែលកុដុម្ពិក៍ បូជាចំពោះព្រះខីណាស្រពនោះបាន ។

### ជេរព្រះអរហន្តដោយអាការ ៤ យ៉ាង មានទោស

លុះក្នុងវេលាល្ងាច ភិក្ខុចៅអាវាសបានទៅកាន់សំណាក់ព្រះថេរៈនោះ ហើយជេរព្រះថេរៈដោយអាការ ៤ យ៉ាងថា "អាវុសោអាគន្តុកៈ ការទំពាស៊ី លាមក ប្រសើរជាងបរិភោគភត្តក្នុងផ្ទះរបស់កុដុម្ពិក៍ ការឲ្យគេកោរសក់ដោយ ជាងត្នោត ប្រសើរជាងការកោរសក់ដែលកុដុម្ពិក៍ឲ្យនាំមក ការអាក្រាតកាយ ដើរទៅ ប្រសើរជាងការស្លៀកសំពត់សាដកដែលកុដុម្ពិក៍ប្រគេន ដេកនៅលើ ផែនដីទៅ ប្រសើរជាងការដេកលើគ្រែដែលកុដុម្ពិក៍នាំមក" ។ ចំណែកព្រះថេរៈ គិតថា "ភិក្ខុពាលនេះ កុំវិនាសព្រោះអាស្រ័យយើងឡើយ" ដូច្នេះ ហើយក៏មិន

អើពើដល់ការនិមន្តរបស់កុដុម្ពិក៍ ក្រោកឡើងតាំងអំពីព្រលឹម ហើយបាននិមន្ត ទៅតាមសប្បាយ ។ ចំណែកភិក្ខុចៅអាវាស ធ្វើវត្តដែលគួរធ្វើក្នុងវិហារតាំង អំពីព្រលឹមហើយ គោះរគាំងដោយម្រាមដៃ ដើម្បីដាស់ព្រះថេរៈអាគន្តុកៈឲ្យ ភ្ញាក់ឡើងថា "វេលានេះ ជាវេលាត្រាច់ទៅដើម្បីភិក្ខា ពីព្រោះលោកសម្គាល់ ថា វេលានេះភិក្ខុអាគន្តុកៈសឹងលក់នៅឡើយ លោកគប្បីភ្ញាក់ដោយសំឡេង រគាំង" ដូច្នេះ ហើយក៏ចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ កុដុម្ពិក៍នោះត្រៀម គ្រឿងសក្ការៈហើយ អង្គុយចាំមើលផ្លូវព្រះថេរៈទាំងពីររូប ឃើញតែភិក្ខុចៅ អាវាសមក ទើបសួរថា "លោកម្ចាស់ដ៏ចម្រើន ព្រះថេរៈនិមន្តទៅណា" ភិក្ខុ ចៅអាវាសពោលទៅកាន់កុដុម្ពិក៍ថា "កុដុម្ពិក៍ លោកកុំនិយាយដល់ព្រះថេរៈ របស់លោកឡើយ ភិក្ខុកុលុបកៈរបស់លោកនោះ ចូលទៅកាន់បន្ទប់តូច ឈាន ចុះកាន់ការលង់លក់ តាំងអំពីកាលដែលលោកចេញមកពីថ្ងៃម្សិលម៉្ងៃ កាល អាត្មាភាពធ្វើសំឡេងបោសវិហារក្តី សំឡេងត្រងទឹកដាក់ក្នុងក្អមសម្រាប់ឆាន់ និងក្អមទឹកសម្រាប់ប្រើប្រាស់ក្តី សំឡេងរគាំងក្តី ក៏នៅតែមិនដឹងខ្លួនទៀត ។ កុដុម្ពិក៍គិតថា "ដែលឈ្មោះថា ការសឹងលក់រហូតដល់ថ្មើរនេះ រមែងមិនមាន ដល់លោកម្ចាស់ដ៏ចម្រើនរបស់យើង ដែលជាអ្នកប្រកបដោយឥរិយាបថសម្បត្តិ ដូច្នោះ ប៉ុន្តែលោកម្ចាស់រូបនេះ ពោលពាក្យទាំងអស់នេះ ប្រាកដជាលោក ឃើញយើងបូជាព្រះថេរៈ ដោយគ្រឿងសក្ការៈអំពីថ្ងៃមុនហើយមើលទៅ" ។ ព្រោះអាស្រ័យការឈ្លាសវៃរបស់ខ្លួន កុដុម្ពិក៍នោះ ក៏និមន្តភិក្ខុចៅអាវាសឲ្យ

ធាន់ដោយគោរព លាងបាត្ររបស់ភិក្ខុចៅអាវាសឲ្យស្អាត ហើយដាក់ភោជន មានរសដ៏ប្រណីតៗ ពេញបាត្រ ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន បើលោកម្ចាស់ ឃើញលោកម្ចាស់ដ៏ចម្រើនរបស់ខ្ញុំព្រះករុណា សូមលោកម្ចាស់ប្រគេនបិណ្ឌបាតនេះ ដល់លោកម្ចាស់ដ៏ចម្រើនរបស់ខ្ញុំព្រះករុណាផង ។ ភិក្ខុចៅអាវាសទទួលបិណ្ឌបាតនោះហើយ ក៏និមន្តមកកាន់វិហារវិញ ពេលដែលលោកកំពុងនិមន្តតាមផ្លូវនោះ ក៏បានគិតឃើញថា "ប្រសិនបើភិក្ខុនោះ នឹងបានបរិភោគបិណ្ឌបាតបែបនេះសោត លោកនឹងជាប់នៅក្នុងទីនេះ" ក៏ចាក់បិណ្ឌ-បាតនោះចោលក្នុងចន្លោះផ្លូវ កាលទៅដល់វិហារហើយ ក៏ទៅកាន់លំនៅរបស់ព្រះថេរៈ រកមើលព្រះថេរៈមិនឃើញក្នុងទីនោះ ក៏កើតកុក្កុច្ចៈក្តៅក្រហាយនឹងអំពើដ៏លាមករបស់ខ្លួនយ៉ាងខ្លាំង ។ ពេលនោះ សមណធម៌ដែលលោកធ្វើមកអស់ ២ ម៉ឺនឆ្នាំ ក៏មិនអាចជួយលោកបាន ព្រោះលោកធ្វើកម្មមានប្រមាណប៉ុណ្ណោះ ។ ក៏ក្នុងកាលអស់អាយុ លោកកើតហើយក្នុងអវីចីនរក សោយទុក្ខដ៏ធំអស់មួយចន្លោះព្រះពុទ្ធ ។ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងត្រកូលស្តុក-ស្តម្ភមួយក្នុងក្រុងរាជគ្រឹះ ។

## ទោសនៃការជេរព្រះអរហន្ត

ចាប់តាំងអំពីចេះដើរមក ក្មេងនោះមិនប្រាថ្នានឹងដេកលើទីដេក មិនប្រាថ្នានឹងបរិភោគភត្ត ទំពាស៊ីតែសរីរវលញ្ជៈ (លាមក) របស់ខ្លួនប៉ុណ្ណោះ ។ មាតាបិតាចិញ្ចឹមក្មេងនោះ ដោយសម្គាល់ថា ក្មេងមិនដឹង ព្រោះវានៅក្មេង

ទើបធ្វើយ៉ាងនេះ ។ សូម្បីធំហើយ ក៏មិនប្រាថ្នានឹងស្លៀកសំពត់ ចូលចិត្តតែអាក្រាត ដេកតែលើផែនដី ទំពាស៊ីតែសរីរវលញ្ជៈរបស់ខ្លួនប៉ុណ្ណោះ ។ គ្រានោះ មាតាបិតារបស់ក្មេងនោះ គិតគ្នាថា "បុត្ររបស់យើង មិនសមគួរដល់ផ្ទះនៃត្រកូល ក្មេងនេះសមគួរដល់ពួកអាជីវកប៉ុណ្ណោះ" ដូច្នេះ ហើយក៏នាំទៅកាន់សំណាក់របស់ពួកអាជីវក ប្រគល់ឲ្យ ដោយពាក្យថា "សូមលោកម្ចាស់ទាំងឡាយបំបួសក្មេងនេះចុះ" ។ គ្រានោះ អាជីវកទាំងនោះក៏បំបួសក្មេងនោះ លុះបំបួសហើយ ពួកអាជីវកទាំងនោះ ឲ្យក្មេងនោះឈរក្នុងរណ្តៅប្រមាណត្រឹម.ក ដាក់ឃ្នាបខាងលើចង្កួយស្មាទាំងពីរ អង្គុយលើឈើទាំងនោះ ហើយដកសក់ដោយធាងត្នោត ។ គ្រានោះ មាតាបិតារបស់គេ ក៏អញ្ជើញអាជីវកទាំងនោះដើម្បីឆាន់ក្នុងថ្ងៃស្អែក ហើយចៀសចេញទៅ ។ ថ្ងៃស្អែកឡើង ពួកអាជីវកពោលប្រាប់គេថា "លោកចូរមក ពួកយើងនឹងចូលទៅកាន់ស្រុក" ។ គេពោលថា "សូមលោកម្ចាស់ទាំងឡាយអញ្ជើញទៅចុះ ខ្ញុំមិនទៅទេ ខ្ញុំនឹងនៅទីនេះឯង" ។ គ្រានោះ អាជីវកទាំងឡាយបាននាំគ្នាទៅ ដោយទុកគេឲ្យនៅទីនោះម្នាក់ឯង ។ គេដឹងថា អាជីវកទាំងនោះទៅហើយ ក៏បើកទ្វារវច្ចកុដិ ចុះទៅទំពាស៊ីដុំលាមកដោយដៃទាំងពីរ ពួកអាជីវកក៏បាននាំអាហារពីក្នុងស្រុកដើម្បីគេ ។ គេមិនប្រាថ្នាសូម្បីអាហារនោះ ត្រូវពួកអាជីវកពោលអង្វររឿយៗ ក៏ពោលថា "ខ្ញុំមិនត្រូវការអាហារនេះទេ ខ្ញុំបានអាហារហើយ" ។ ពួកអាជីវកសួរថា "លោកបានអាហារអំពីណា" គេឆ្លើយថា "បានក្នុងទីនេះឯង" ។

សូម្បីក្នុងថ្ងៃទី ២-៣-៤ គេត្រូវពួកអាជីវកនោះពោលពាក្យសូម្បីច្រើនដង ក៏នៅតែពោលថា "ខ្ញុំមិនទៅទេ ខ្ញុំនៅទីនេះឯង" មិនប្រាថ្នានឹងទៅស្រុក ។ ពួកអាជីវកគិតថា "អាជីវកនេះ មិនប្រាថ្នានឹងចូលទៅកាន់ស្រុករាល់ៗ ថ្ងៃ មិនបរិភោគអាហារដែលពួកយើងនាំមកឲ្យ ពោលថា "អាហារយើងបានហើយក្នុងទីនេះឯង អាជីវកនេះធ្វើនូវអ្វីហ្ន៎ ពួកយើងនឹងចាប់កំហុសគេ" ដូច្នេះហើយ កាលនឹងចូលទៅកាន់ស្រុក ក៏ទុកអាជីវកមួយនាក់ពីរនាក់ ដើម្បីឃ្លាំមើលគេហើយ ទើបទៅ ។ អាជីវកទាំងនោះ ធ្វើដូចជាទៅខាងក្រោយ ហើយពួននៅក្នុងទីមួយ ។ សូម្បីគេដឹងថា អាជីវកទាំងនោះទៅអស់ហើយ ក៏ចុះកាន់វច្ចកុដិ ទំពាស៊ីលាមកដោយន័យដូចមុននោះឯង ។ ពួកអាជីវកក្រៅពីនេះ ឃើញកិរិយារបស់គេហើយ ក៏ប្រាប់អាជីវកទាំងឡាយ ។ ពួកអាជីវកស្តាប់ពាក្យនោះហើយគិតថា "ឱ! កម្មនេះធ្ងន់ណាស់ បើសាវករបស់សមណគោតមបានដឹង នឹងប្រកាសនូវកេរ្តិ៍ឈ្មោះមិនល្អរបស់ពួកយើងថា អាជីវកទាំងឡាយស៊ីលាមក អាជីវកនេះមិនគួរដល់ពួកយើងទេ" ក៏បណ្តេញគេឲ្យចេញពីសម្នាក់របស់ខ្លួន ។ គេត្រូវពួកអាជីវកទាំងនោះបណ្តេញចេញហើយ ។ មានថ្មដាមួយផ្ទាំង ដែលគេទុកក្នុងទីបន្ទោបង់ឧច្ចារៈរបស់មហាជន មានត្រពាំងធំមួយនៅក្បែរថ្មដានោះ មហាជនអាស្រ័យថ្មដានោះ បន្ទោបង់ឧច្ចារៈ ។ គេទៅកាន់ទីនោះ ទំពាស៊ីលាមកក្នុងពេលយប់ ក្នុងកាលដែលមហាជនមកបន្ទោបង់ឧច្ចារៈ គោងជុំថ្មដោយដៃម្ខាង លើកជើងម្ខាងដាក់លើជង្គង់ ឈរហាមាត់ ។ មហាជនឃើញ

គេហើយ ចូលទៅរក ថ្វាយបង្គំ សួរថា “លោកម្ចាស់ ព្រោះហេតុអ្វី ទើបលោកម្ចាស់ឈរហាមាត់”

អាជីវក. (ព្រោះ) យើងជាអ្នកមានខ្យល់ជាអាហារ អាហារយ៉ាងដទៃរបស់យើងមិនមានទេ ។

មហាជន. ចុះហេតុអ្វី ទើបលោកម្ចាស់លើកជើងម្ខាងឡើងដាក់លើជង្គង់ហើយឈរយ៉ាងនេះ ។

អាជីវក. យើងមានតបៈខ្ពស់ មានតបៈខ្លាំងក្លា ផែនដីត្រូវយើងជាន់ដោយជើងទាំងពីរហើយរមែងញាប់ញ័រ ព្រោះដូច្នោះ ទើបយើងលើកជើងម្ខាងដាក់លើជង្គង់ហើយឈរយ៉ាងនេះ យើងឈរយ៉ាងនេះឯង ញុំាងកាលឲ្យកន្លងទៅ មិនអង្គុយ មិនដេក ។

ធម្មតា ពួកមនុស្សដោយច្រើន ច្រើនជឿត្រឹមតែការបានឮប៉ុណ្ណោះ ព្រោះហេតុនោះ អ្នកស្រុកដែនអង្គៈ និងមគធៈដោយច្រើនភ្ញាក់ផ្អើលថា “ឱ! គួរឲ្យអស្ចារ្យណាស់ បុគ្គលអ្នកមានតបៈបែបនេះ បុគ្គលដូច្នេះពួកយើងមិនធ្លាប់ឃើញឡើយ” ហើយតែងតែនាំសក្ការៈជាច្រើនទៅរាល់ៗ ខែ ដើម្បីបូជាអាជីវកនោះ ។ អាជីវកនោះពោលថា “យើងស៊ីខ្យល់តែម្យ៉ាង មិនស៊ីអាហារយ៉ាងដទៃឡើយ ព្រោះកាលយើងទំពាស៊ីអាហារយ៉ាងដទៃ តបៈរបស់យើងនឹងវិនាស” ដូច្នេះ ហើយមិនប្រាថ្នានូវវត្ថុអ្វីៗ ដែលពួកមនុស្សទាំងនោះនាំមកឡើយ ។ ពួកមនុស្ស អង្វររឿយៗ ថា “លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់

កុំញុំាងយើងទាំងឡាយឲ្យវិនាសឡើយ ការបរិភោគដែលបុគ្គលអ្នកមានតបៈដ៏ខ្លាំងក្លាដូចលោកម្ចាស់ធ្វើហើយ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ និងដើម្បីសេចក្តីសុខដល់ពួកយើងអស់កាលដ៏យូរអង្វែង" ។ អាជីវកពោលថា យើងមិនពេញចិត្តនូវអាហារយ៉ាងដទៃឡើយ" ប៉ុន្តែត្រូវមហាជនបៀតបៀនដោយការអង្វរ ទើបដាក់កេសជ្ជៈ មានទឹកដោះថ្លា និងទឹកអំពៅជាដើម ដែលជនទាំងនោះនាំមកលើចុងអណ្តាតដោយចុងស្បូវហើយ ពោលពាក្យថា "ពួកលោកចូរនាំយកទៅវិញចុះ ប៉ុណ្ណេះល្មមជាបច្ច័យដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខដល់អ្នកទាំងឡាយហើយ ។ អាជីវកនោះ ជាមនុស្សអាក្រាត ទំពាសុីលាមកដកសក់ដោយធាងត្នោត ដេកលើផែនដីអស់កាលប្រមាណ ៥៥ ឆ្នាំ ដោយប្រការដូច្នេះ ។

## ព្រះពុទ្ធស្តេចយាងទៅប្រោសជម្ពុកាជីវក

ការពិចារណាមើលលោកក្នុងពេលជិតភ្លឺ ជាពុទ្ធកិច្ច គឺ ព្រះពុទ្ធទាំងឡាយទ្រង់មិនលះបង់ចោលឡើយ ព្រោះហេតុនោះ កាលព្រះមានព្រះភាគទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាជិតភ្លឺនាថ្ងៃនោះ ជម្ពុកាជីវកនោះបានប្រាកដខាងក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ។ ព្រះសាស្តា ទ្រង់រំពឹងមើលថា "អ្វីហ្ន៎នឹងមាន" ទ្រង់ឧបនិស្ស័យនៃព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទារបស់ជម្ពុកាជីវកហើយ ទ្រង់ព្រះតម្រិះថា "តថាគតនឹងធ្វើជម្ពុកាជីវកនោះឲ្យជាដើមហេតុ ហើយត្រាស់ព្រះគាថា ក្នុងកាលចប់គាថា សត្វ ៨៤.០០០

នឹងបានត្រាស់ដឹងធម៌អាស្រ័យកុលបុត្រនោះ មហាជននឹងដល់នូវសិរីសួស្តី" ដូច្នេះ ។ ថ្ងៃស្អែកឡើងស្តេចយាងទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ស្តេចត្រឡប់អំពីបិណ្ឌបាត ហើយត្រាស់ទៅកាន់ព្រះអានន្ទថា "ម្នាលអានន្ទ តថាគតនឹងទៅកាន់សំណាក់របស់ជម្ពុកាជីវក" ។

អានន្ទ. ព្រះអង្គប៉ុណ្ណោះ ស្តេចយាងទៅឬ ព្រះអង្គ ។

ព្រះសាស្តា. ម្នាលអានន្ទ តថាគតទៅតែឯងទេ ។

ព្រះសាស្តា លុះត្រាស់យ៉ាងនោះហើយ ក្នុងវេលារសៀលស្តេចយាងទៅកាន់សំណាក់របស់ជម្ពុកាជីវកនោះ ។ ទេវតាទាំងឡាយដឹងថា ព្រះសាស្តាស្តេចទៅកាន់សំណាក់ជម្ពុកាជីវកក្នុងវេលារសៀលនេះ ក៏ជម្ពុកាជីវកនោះ នៅលើថ្មដាដ៏គួរខ្ពើម ជាកន្លែងបន្ទោបង់ឧច្ចារៈ-បស្សាវៈរបស់អ្នកដែនអង្គៈ និងដែនមគធៈ សៅហ្មងដោយឈើជម្រះធ្មេញ ពួកយើងគួរញុំាងភ្លៀងឲ្យធ្លាក់ដូច្នេះ ហើយក៏ញុំាងភ្លៀងឲ្យធ្លាក់ ដោយអានុភាពរបស់ខ្លួន ។ ថ្មដាបានជារបស់ស្អាតប្រាសចាកមន្ទិល ។ គ្រានោះ ទេវតាទាំងឡាយញុំាងភ្លៀងជាវិការនៃផ្កា ៥ ពណ៌ ឲ្យធ្លាក់ចុះលើថ្មដានោះ ។ ក្នុងវេលារសៀល ព្រះសាស្តាស្តេចទៅកាន់សំណាក់របស់ជម្ពុកាជីវកហើយ បានបន្លឺព្រះសូរសៀងថា "នែជម្ពុកៈ" ។ ជម្ពុកៈគិតថា "អ្នកណាហៅយើងដោយវាទៈថា ជម្ពុកៈ" ក៏សួរថា នរណាហ្នឹង?" ។

ព្រះសាស្តា. ម្នាលជម្ពុកៈ តថាគត ។

ជម្ពុកៈ. មហាសមណៈ មានការអ្វី ។

ព្រះសាស្តា. ថ្ងៃនេះ តថាគតសុំសម្រាកនៅទីនេះមួយរាត្រី ។

ជម្ពុកៈ. មហាសមណៈ មិនមានកន្លែងទេ ។

ព្រះសាស្តា. ម្នាលជម្ពុកៈ អ្នកកុំធ្វើយ៉ាងនោះឡើយ អ្នកចូរឲ្យទីនូវសម្រាកដល់តថាគតមួយរាត្រីចុះ ដែលឈ្មោះថា បព្វជិត រមែងប្រាថ្នាបព្វជិត ពួកមនុស្សរមែងប្រាថ្នាពួកមនុស្ស ពួកបសុសត្វរមែងប្រាថ្នាពួកបសុសត្វ ។

ជម្ពុកៈ. ក៏លោកជាបព្វជិតឬ ។

ព្រះសាស្តា. អើ តថាគតជាបព្វជិត ។

ជម្ពុកៈ. ប្រសិនបើលោកជាបព្វជិត ឃ្លោករបស់លោកនៅឯណា វែកសម្រាប់ដួសផ្សែងរបស់លោកនៅឯណា ខ្សែអំបោះ (ខ្សែជាគ្រឿងសម្គាល់វណ្ណៈព្រាហ្មណ៍) សម្រាប់បូជាយញ្ញរបស់លោកនៅឯណា ។

ព្រះសាស្តា. ឃ្លោកជាដើមនោះ របស់តថាគតមាន តែការយកជាផ្នែកៗ ត្រាច់ទៅលំបាក ព្រោះដូច្នោះ តថាគតរក្សាទុក ហើយត្រាច់ទៅ ។ អាជីវកនោះ ខឹងថា "លោកមិនអាចកាន់យកឃ្លោកជាដើមនោះ ត្រាច់ទៅបានឬ" លំដាប់នោះ ព្រះសាស្តាត្រាស់ទៅកាន់អាជីវកនោះថា "ណ្ហើយចុះ ជម្ពុកៈ អ្នកកុំក្រោធឡើយ អ្នកចូរប្រាប់ទីសម្រាប់សម្រាកដល់តថាគតចុះ" ។ គេពោលថា "មហាសមណៈ ទីសម្រាកក្នុងទីនេះ មិនមាន" ។

ព្រះសាស្តា កាលនឹងទ្រង់សម្តែងបង្ហាញញកភ្នំមួយ ដែលនៅមិនឆ្ងាយ

អំពីលំនៅរបស់ជម្ពុកាជីវក ក៏ត្រាស់ថា "ម្នាលជម្ពុកៈ ញកភ្នំនោះ នរណានៅទីនោះ" ។

ជម្ពុកៈ. មហាសមណៈ ញកភ្នំនោះ មិនមាននរណានៅទេ ។

ព្រះសាស្តា. បើដូច្នោះ អ្នកចូរឲ្យញកភ្នំនោះដល់តថាគតចុះ ។

ជម្ពុកៈ. មហាសមណៈ លោកចូរដឹងខ្លួនឯងចុះ ។

ព្រះសាស្តា ទ្រង់ក្រាលនូវសំពត់និសីទនៈត្រង់ញកភ្នំនោះ ហើយប្រថាប់គង់នៅទីនោះ ។

## ជម្ពុកាជីវកបានសម្រេចព្រះអរហត្ត

គ្រានោះ ស្តេចមហារាជទាំង ៤ អង្គ ធ្វើទិសទាំង ៤ ឲ្យភ្លឺស្វាងហើយមកកាន់សំណាក់ព្រះអង្គក្នុងបឋមយាម ។ ជម្ពុកៈឃើញពន្លឺនោះហើយ គិតថា "ពន្លឺនោះ ជាពន្លឺអ្វី" ។ ក្នុងមជ្ឈិមយាម សក្កទេវរាជស្តេចក៏មកដែរ ។ ជម្ពុកៈឃើញសក្កទេវរាជនោះហើយ គិតថា "នុ៎ះ ជានរណា" ក្នុងបច្ឆិមយាម មហាព្រហ្ម អ្នកអាចញុំាងចក្រវាឡមួយឲ្យភ្លឺដោយម្រាមដៃមួយ ញុំាងចក្រវាឡពីរ ។បេ។ ញុំាងចក្រវាឡ ១០ ឲ្យភ្លឺដោយម្រាមដៃ ១០ ញុំាងព្រៃទាំងអស់ឲ្យភ្លឺរុងរឿង ។ ជម្ពុកៈឃើញស្តេចមហាព្រហ្មនោះហើយ គិតថា "តើនុ៎ះជានរណា" ដូច្នេះ ក៏ទៅកាន់សំណាក់ព្រះសាស្តាពីព្រលឹម ធ្វើបដិសណ្ឋារៈហើយឈរក្នុងទីដ៏សមគួរមួយ ទូលសួរព្រះសាស្តាថា "មហាសមណៈ នរណាញុំាងទិសទាំង ៤ ឲ្យភ្លឺស្វាង មកកាន់សំណាក់របស់លោកក្នុងបឋមយាម" ។

ព្រះសាស្ដា. ស្ដេចមហារាជទាំង ៤ ។

ជម្ពុកៈ. មកព្រោះហេតុអ្វី ។

ព្រះសាស្ដា. មកដើម្បីបម្រើតថាគត ។

ជម្ពុកៈ. មហាសមណៈ ជាអ្នកធំជាងមហារាជទាំង ៤ នោះទៀតឬ ។

ព្រះសាស្ដា. អើ ជម្ពុកៈ តថាគតជាព្រះរាជាដ៏ក្រៃលែងជាងព្រះរាជាទាំងឡាយ ។

ជម្ពុកៈ. ក៏ក្នុងមជ្ឈិមយាម នរណាមក ។

ព្រះសាស្ដា. ស្ដេចសក្កទេវរាជ ។

ជម្ពុកៈ. សក្កទេវរាជមកធ្វើអ្វី ។

ព្រះសាស្ដា. មកដើម្បីបម្រើតថាគតដែរ ។

ជម្ពុកៈ. ក៏លោកជាអ្នកខ្ពង់ខ្ពស់ជាងសក្កទេវរាជឬ ។

ព្រះសាស្ដា. អើ ជម្ពុកៈ តថាគតជាអ្នកប្រសើរខ្ពង់ខ្ពស់ជាងសក្កទេវរាជ ក៏សក្កទេវរាជនោះ ជាគិលានុបដ្ឋាករបស់តថាគត ដូចសាមណេរអ្នកធ្វើនូវកប្បិយការកៈ ។

ជម្ពុកៈ. ក៏នរណាញុំាងព្រៃទាំងអស់ឲ្យភ្លឺស្វាង មកក្នុងបច្ឆិមយាម ។

ព្រះសាស្ដា. ព្រោះនរណា ជនទាំងឡាយមានព្រាហ្មណ៍ជាដើមក្នុងលោក ភ្ញាក់មាត់ហើយថា “សូមការនមស្ការ ចូរមានដល់មហាព្រហ្ម” បុគ្គលនោះឯងជា មហាព្រហ្ម ។

ជម្ពុកៈ. ក៏លោកធំជាងមហាព្រហ្មទៀតឬ ។

ព្រះសាស្តា. អើ! ជម្ពុកៈ តថាគតជាព្រហ្មក្រៃលែងជាងព្រហ្ម ។

ជម្ពុកៈ. មហាសមណៈ លោកជាមនុស្សអស្ចារ្យណាស់ ក៏កាលយើងនៅទីនេះអស់ ៥៥ ឆ្នាំ បណ្តាទេវតាទាំងនោះ សូម្បីតែ ១ អង្គ ក៏មិនធ្លាប់មកដើម្បីបម្រើយើងដែរ យើងជាអ្នកមានខ្យល់ជាអាហារ រមែងឈរតែម្យ៉ាងញ៉ាំងកាលយូរប្រមាណប៉ុណ្ណេះឲ្យកន្លងទៅហើយ ទេវតាទាំងនោះក៏មិនធ្លាប់មកកាន់ទីបម្រើយើងឡើយ ។

លំដាប់នោះ ព្រះសាស្តាត្រាស់ទៅកាន់ជម្ពុកៈនោះថា "ម្នាលជម្ពុកៈ អ្នកកុហកមហាជនអ្នកមានភ្នែកខ្វាក់ក្នុងលោក និងនៅប្រាថ្នាកុហកតថាគតទៀតឬ អ្នកទំពាស៊ីតែលាមកប៉ុណ្ណោះ ដេកនៅលើផែនដីតែម្យ៉ាង ជាមនុស្សអាក្រាត ដកសក់ដោយធាងត្នោតអស់ ៥៥ ឆ្នាំហើយ មិនមែនឬ" អ្នកបានកុហកសត្វលោកថា "យើងជាអ្នកមានខ្យល់ជាអាហារ ឈរដោយជើងម្ខាង មិនអង្គុយ មិនដេកអស់កាលប្រមាណប៉ុណ្ណេះហើយ ឥឡូវនេះនៅហ៊ានកុហកតថាគតទៀតឬ" សូម្បីក្នុងកាលមុន អ្នកអាស្រ័យទិដ្ឋិដ៏អាក្រក់លាមក ជាអ្នកមានលាមកជាអាហារអស់កាលមានប្រមាណប៉ុណ្ណេះ ជាអ្នកដេកនៅលើផែនដីជាមនុស្សអាក្រាត ដល់នូវការដកសក់ដោយធាងត្នោត ឥឡូវនេះ អ្នកនៅតែប្រកាន់ទិដ្ឋិដ៏អាក្រក់លាមកនោះដដែល" ។

ជម្ពុកៈ. មហាសមណៈ ក៏យើងបានធ្វើកម្មអ្វីទុក ។

គ្រានោះ ព្រះសាស្តា ត្រាស់ប្រាប់នូវកម្មដែលជម្ពុកាជីវកធ្វើហើយក្នុងកាលមុនដល់គេ ។ កាលព្រះសាស្តា កំពុងត្រាស់ប្រាប់នោះឯង សេចក្តីសង្វេគបានកើតឡើងដល់ជម្ពុកាជីវក ហិរិឱត្តប្បៈក៏ប្រាកដឡើង ។ គ្រានោះជម្ពុកាជីវក មានខ្លួនអាក្រាតអន្ទុយប្រហោងនៅចំពោះព្រះភក្ត្រនៃព្រះសម្មាសម្ពុទ្ធ ។ ព្រះសម្មាសម្ពុទ្ធឃើញដូច្នោះ ក៏បោះនូវសំពត់សាដកសម្រាប់ងូតទឹកទៅឲ្យជម្ពុកាជីវកនោះ ។ ជម្ពុកាជីវកស្លៀកសំពត់នោះហើយ ថ្វាយបង្គំព្រះសាស្តា អង្គុយក្នុងទីដ៏សមគួរមួយ ។ ចំណែកព្រះសាស្តា ទ្រង់ត្រាស់អនុបុព្វីកថា សម្តែងធម៌ដល់គេ ។ ក្នុងកាលចប់ព្រះទេសនា ជម្ពុកាជីវកបានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទា ថ្វាយបង្គំព្រះសាស្តាហើយ ក្រោកចាកអាសនៈទូល សូមបព្វជ្ជា និងឧបសម្បទា ។ ដោយអាការត្រឹមតែប៉ុណ្ណេះ កម្មដែលជម្ពុកៈបានធ្វើអំពីជាតិមុននោះ ក៏បានអស់ទៅ ។ ក៏ជម្ពុកៈនេះ ជេរព្រះមហាថេរៈជាព្រះខីណាស្រព ដោយអក្កោសវត្ថុ ៤ យ៉ាង ឆេះក្នុងអវីចីជរាបដល់ផែនដីដុះឡើងកម្រាស់ ១ យោជន៍ និង ៣ គាវុត ដល់នូវអាការដ៏គួរខ្ពើមយ៉ាងនេះអស់ ៥៥ ឆ្នាំ ដោយសំណល់នៃផលកម្ម ព្រោះការជេរព្រះខីណាស្រពនោះ កម្ម គឺ ការជេរព្រះខីណាស្រពនោះអស់ហើយ ព្រោះលោកបានសម្រេចព្រះអរហត្ត កម្មដែលលោកធ្វើហើយនោះ មិនអាចញុំាងផលនៃសមណធម៌ ដែលលោកបំពេញហើយអស់ ២ ម៉ឺនឆ្នាំឲ្យវិនាសបាន ព្រោះដូច្នោះ ទើបព្រះសាស្តាទ្រង់លាតព្រះហស្តខាងស្តាំចេញហើយ ត្រាស់

ទៅកាន់ជម្ពុកៈនោះថា "អ្នក ចូរជាភិក្ខុចុះ ចូរប្រព្រឹត្តព្រហ្មចរិយៈចុះ" ។ ខណៈនោះឯង ភេទគ្រហស្ថរបស់លោកក៏វិនាសទៅ លោកជាអ្នកទ្រទ្រង់នូវបរិក្ខារទាំង ៨ ហាក់ដូចជាព្រះថេរៈអ្នកមានវស្សា ៦០ ហើយ ។

ជម្ពុកៈច្រាប់ការពិតដល់មហាជន

បានឮថា ថ្ងៃនោះ ជាថ្ងៃនៃអ្នកដែនអង្គៈ និងមគធៈកាន់យកនូវគ្រឿងសក្ការៈមកដើម្បីជម្ពុកៈនោះ ព្រោះដូច្នោះ អ្នកស្រុកទាំងពីរដែនកាន់យកគ្រឿងសក្ការៈមកហើយ ឃើញព្រះសាស្តា ក៏គិតថា "ជម្ពុកៈដែលជាលោកម្ចាស់របស់ពួកយើងធំជាងព្រះសមណគោតម ឬក៏ព្រះសមណគោតមធំជាងលោកម្ចាស់របស់យើង" ក៏គិតទៀតថា "ប្រសិនបើព្រះសមណគោតមធំជាងលោកម្ចាស់របស់យើងសោត ម៉្លេះលោកម្ចាស់របស់យើង ទៅកាន់សំណាក់របស់ព្រះសមណគោតមហើយ ប៉ុន្តែព្រោះលោកម្ចាស់របស់ពួកយើងធំជាង ទើបព្រះសមណគោតមមកកាន់សំណាក់នៃលោកម្ចាស់របស់ពួកយើង" ។

ព្រះសាស្តា ទ្រង់ជ្រាបសេចក្តីត្រិះរិះរបស់មហាជនហើយ ទើបត្រាស់ថា "ម្នាលជម្ពុកៈ អ្នកចូរកាត់សេចក្តីសង្ស័យនៃពួកឧបដ្ឋាករបស់អ្នកចេញ" ។ លោកក្រាបទូលថា "សូម្បីខ្ញុំព្រះអង្គ ក៏រង់ចាំនូវព្រះពុទ្ធតម្រាស់មានប្រមាណប៉ុណ្ណេះដែរ ព្រះអង្គ" ដូច្នេះ ហើយចូលឈានទី ៤ ក្រោកឡើង ហោះទៅកាន់វេហាស៍កម្ពស់ប្រមាណមួយដើមត្នោត ក្រាបទូលថា "បពិត្រព្រះអង្គ ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក" ហើយចុះមកថ្វាយ

បន្តិ ហោះឡើងកាន់វេហាស៍កម្ពស់ប្រមាណ ៧ ដើមត្នោតទៀត ដោយអាការយ៉ាងនេះ គឺ ប្រមាណពីរដើមត្នោត ប្រមាណបីដើមត្នោត ហើយចុះមក ញ៉ាំងមហាជនឲ្យដឹងថា ខ្លួនជាសាវករបស់ព្រះសម្មាសម្ពុទ្ធ ។ មហាជនឃើញនូវអាការនោះហើយ គិតថា "ឱ! ធម្មតាព្រះពុទ្ធទាំងឡាយ ជាមនុស្សអស្ចារ្យ មានព្រះគុណមិនថោកថយឡើយ" ។

ព្រះសាស្តា បានត្រាស់ទៅកាន់មហាជនយ៉ាងនេះថា "ជម្ពុកៈនេះ ដាក់គ្រឿងសក្ការៈ ដែលអ្នកទាំងឡាយនាំមកហើយលើចុងអណ្តាតដោយចុងស្បូវ រហូតអស់កាលប្រមាណប៉ុណ្ណេះ នៅក្នុងទីនេះដោយសង្ឃឹមថា យើងនឹងបំពេញនូវការប្រព្រឹត្តិតបៈ បើជម្ពុកៈនេះខំបំពេញតបៈបែបនេះអស់ ១ រយឆ្នាំ ដោយឧបាយយ៉ាងនេះសោត ការបំពេញតបៈនោះ មិនដល់នូវចំណែកសូម្បីទី ១៦ នៃកុសលចេតនា ដែលជាគ្រឿងកាត់បង់នូវភត្តរបស់បុគ្គលអ្នកវៀសត្រកូលឬភត្ត ហើយមិនបរិភោគក្នុងកាលឥឡូវនេះ" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

មាសេ មាសេ កុសគ្គេន ពាលោ ភុញ្ជេថ ភោជនំ
ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសឹ ។

ជនពាល ទុកជាបរិភោគភោជនដោយចុងស្បូវរាល់ៗ ខែ
ជនពាលនោះ ក៏មិនដល់មួយចំណិតនៃចំណែកទី ១៦ ៗ
លើក របស់បុគ្គលទាំងឡាយ ដែលមានធម៌បានដឹង ឬ

បានពិចារណាហើយឡើយ ។

អធិប្បាយគាថា

គប្បីជ្រាបសេចក្ដីនៃព្រះគាថានោះថា ៖

ប្រសិនបើជនពាល គឺ អ្នកមានធម៌មិនទាន់កំណត់ដឹង ឃ្លាតឆ្ងាយចាក គុណមានសីលជាដើម បួសក្នុងលទ្ធិតិរ្ថិយ៍ បរិភោគភោជនដោយចុងស្បូវ រាល់ៗខែ ហើយសង្ឃឹមថា "យើងនឹងបំពេញតបៈ" គប្បីបរិភោគភោជនរហូតអស់ ១ រយឆ្នាំ" ។

ក្នុងបទថា **ន សោ សង្ខាតធម្មានំ កលំ អគ្ឃតិ សោឡសី (គេរមែងមិនបានទទួលផល "នៃការបដិបត្តិ" ត្រឹមចំរៀកទី ១៦ នៃអ្នកមានធម៌ដែលរាប់បានហើយ)** សម្ដែងជាបុគ្គលាធិដ្ឋាន "លោកអ្នកមានធម៌ដឹងហើយ គឺ អ្នកមានធម៌ដែលថ្លឹងបានហើយ ហៅថា អ្នកមានធម៌ដែលរាប់បានហើយ បណ្ដាលោកទាំងនោះ ថ្នាក់ទាបបំផុត ជាព្រះសោតាបន្ន ឈ្មោះថា អ្នកមានធម៌ដែលរាប់បានហើយ ថ្នាក់ខ្ពស់ ជាព្រះខីណាស្រព ឈ្មោះថា អ្នកមានធម៌ដែលរាប់ហើយបាន ជនពាល រមែងមិនដល់នូវចំណែកទី ១៦ របស់លោកដែលមានធម៌រាប់បានហើយទាំងនោះ ។

ចំណែកខ្លឹមសារក្នុងសេចក្ដីនេះ គប្បីជ្រាបដូច្នេះ

ក៏ចេតនារបស់ជនពាលនោះ ដែលជាអ្នកប្រព្រឹត្តតបៈយ៉ាងនោះរហូតអស់ ១ រយឆ្នាំ ប្រព្រឹត្តទៅអស់រាត្រីដ៏យូរដល់ម៉្លោះ ក៏មិនដល់ចំណែកទី ១៦

នៃកុសលចេតនាដែលជាគ្រឿងកាត់បង់នូវកត្តមួយជង របស់បុគ្គលអ្នកមានធម៌ ដែលរាប់បានហើយ រង្កៀសក្នុងត្រកូល ឬកត្ត ហើយមិនបរិភោគ ។ ព្រះសាស្តា ទ្រង់អធិប្បាយទុកដូច្នេះថា "ផលនៃចំណែកនីមួយៗ ចាកផលនៃចេតនារបស់បុគ្គលអ្នកមានធម៌ដែលរាប់បានហើយ ដែលធ្វើឲ្យជា ១៦ ចំណែក មួយចំណែក ១៦ ជង នៅច្រើនជាងការប្រព្រឹត្តិតបៈរបស់ជនពាលនោះ ។

ក្នុងកាលចប់ព្រះទេសនា ធម្មាភិសម័យកើតមានដល់សត្វ ៨ ម៉ឺន ៤ ពាន់ដោយប្រការដូច្នេះឯង ។

ចប់ រឿងជម្ពុកាជីវក

# ១២. រឿងអហិប្រេត (ប្រេតពស់)

*ព្រះសាស្តា កាលទ្រង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធប្រេតដែលមានអត្តភាពដូចជាពស់មួយរូប ត្រាស់ព្រះធម្មទេសនានេះថា* ***ន ហិ បាបំ កតំ កម្មំ (ក៏កម្មអាក្រក់ដែលបុគ្គលធ្វើហើយ មិនទាន់ឲ្យផល)*** *ជាដើម ។*

## ព្រះមហាមោគ្គល្លានត្ថេរញញឹម

*សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះលក្ខណត្ថេរ ដែលក្នុងចំណោមជដិល ១ ពាន់ និងព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដដោយគិតថា "យើងនឹងត្រាច់ទៅបិណ្ឌបាតក្រុងរាជគ្រឹះ" ។ បណ្តាព្រះថេរៈទាំងពីររូបនោះ ព្រះមហាមោគ្គល្លានឃើញអហិប្រេតមួយ បានធ្វើការញញឹមឲ្យប្រាកដ ។ គ្រានោះ ព្រះលក្ខណត្ថេរសួរព្រះមោគ្គល្លានថា "អាវុសោ ព្រោះហេតុអ្វី លោកទើបធ្វើការញញឹមឲ្យប្រាកដ" ព្រះថេរៈឆ្លើយថា "អាវុសោ ពេលនេះមិនមែនជាពេលវិសជ្ជនាបញ្ហានេះទេ លោកគប្បីសួរខ្ញុំក្នុងសំណាក់ព្រះមានព្រះភាគចុះ" ។ កាលព្រះថេរៈទាំងពីរអង្គនោះ និមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយ ទៅកាន់សំណាក់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរមួយ ព្រះលក្ខណៈសួរថា "អាវុសោមោគ្គល្លាន កាលលោកចុះអំពីភ្នំគិជ្ឈកូដ បានធ្វើការញញឹមឲ្យប្រាកដ ខ្ញុំសួរដល់ហេតុនៃការញញឹមនោះ លោកបានពោលថា អាវុសោលក្ខណៈ លោកគប្បីសួរខ្ញុំក្នុងសំណាក់ព្រះមានព្រះភាគចុះ ឥឡូវនេះ លោកចូរប្រាប់ហេតុនោះ*

ចុះ” ។

ព្រះថេរៈពោលថា “ខ្ញុំបានឃើញ អហិប្រេតមួយ ទើបបានធ្វើញញឹម ការញញឹមឲ្យប្រាកដ អត្តភាពរបស់ប្រេតនោះបែបនេះ ក្បាលរបស់វា ដូចជាក្បាលមនុស្ស អត្តភាពដ៏សេសដូចជាពស់ ប្រេតនោះឈ្មោះថា អហិប្រេត (អត្តភាព) ប្រមាណ ២៥ យោជន៍ អណ្តាតភ្លើងតាំងឡើងអំពីក្បាលរបស់វា ឆេះរាលរហូតទៅដល់កន្ទុយ តាំងឡើងអំពីកន្ទុយឆេះរាលរហូតដល់ក្បាល តាំងឡើងត្រង់ពាក់កណ្តាលខ្លួន ឆេះរាលដាលទៅទាំងពីរខាង តាំងឡើងទាំងពីរខាង ឆេះរួមចូលមកត្រង់កណ្តាល” ។ បានឮថា អត្តភាពរបស់ប្រេតទាំងពីរនោះ (គឺ អហិប្រេត និងកាកប្រេត) មានប្រមាណ ២៥ យោជន៍ របស់ប្រេតដ៏សេសប្រមាណ ៣ គាវុត បណ្តាប្រេតទាំងពីរនោះ រឿងរបស់អហិប្រេតមានដូច្នេះ ។

បុព្វកម្មរបស់កាកប្រេត

ព្រះមហាមោគ្គល្លាន ឃើញសូម្បីកាកប្រេត ដែលភ្លើងកំពុងឆេះនៅលើកំពូលភ្នំគិជ្ឈកូដ ក៏សួរអំពីបុព្វកម្មរបស់ប្រេតនោះ ដោយគាថានេះថា ៖

អណ្តាតរបស់អ្នកប្រមាណ ៥ យោជន៍ ក្បាលរបស់អ្នក
ប្រមាណ ៩ យោជន៍ កាយរបស់អ្នកខ្ពស់ប្រមាណ ២៥
យោជន៍ អ្នកធ្វើកម្មអ្វីទុក ទើបដល់នូវសេចក្តីទុក្ខដូច្នេះ ។

គ្រានោះ កាកប្រេតក៏បានឆ្លើយប្រាប់ព្រះថេរៈនោះ ដោយគាថានេះថា

បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ខ្ញុំស៊ីកត្តតាមប្រាថ្នាដែល
គេនាំមកដើម្បីសង្ឃសាវករបស់ព្រះពុទ្ធ ទ្រង់ព្រះនាមថា
កស្សបៈ អ្នកស្វែងរកគុណដ៏ធំ ។

ដូច្នេះ ទើបពោលតទៅថា "លោកម្ចាស់ដ៏ចម្រើន ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាម កស្សបៈ ពួកភិក្ខុច្រើនរូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ពួកមនុស្សឃើញភិក្ខុទាំងឡាយហើយ មានសេចក្ដីជ្រះថ្លា ស្រឡាញ់ពេញចិត្ត និមន្តឲ្យគង់ក្នុងរោងឆាន់ លាងជើង លាបដោយប្រេង ប្រគេនយាគូ និងរបស់គួរទំពាស៊ីដល់ភិក្ខុទាំងឡាយ ហើយអង្គុយស្ដាប់ធម៌ ដើម្បីរង់ចាំបិណ្ឌបាតកាល ។ ក្នុងកាលចប់ធម្មកថា ពួកមនុស្សទទួលបាត្ររបស់ភិក្ខុទាំងឡាយ ហើយញុំាងភោជនដែលមានរសដ៏ប្រណីតៗ ឲ្យពេញបាត្រក្នុងផ្ទះរបស់ខ្លួនៗ ហើយនាំមក ។ ក្នុងគ្រានោះ ខ្ញុំម្ចាស់ជាក្អែកទំនៅលើដំបូលរោងឆាន់ ឃើញភោជននោះហើយ បានចឹកយកដុំបាយ ៣ ដុំ ពេញៗ មាត់ ៣ ដង អំពីបាត្រដែលមនុស្សម្នាក់កំពុងកាន់ ប៉ុន្តែកត្តនោះ មិនមែនជាកត្តរបស់សង្ឃទេ មិនមែនជាកត្តដែលគេកំណត់ដើម្បីប្រគេនសង្ឃទេ ជាកត្តដែលសល់អំពីភិក្ខុទាំងឡាយឆាន់ ដែលពួកមនុស្សនាំទៅកាន់ផ្ទះរបស់ខ្លួនបរិភោគក៏មិនមែន គ្រាន់តែជាកត្តដែលគេនាំមកចំពោះសង្ឃតែម្យ៉ាងប៉ុណ្ណោះ ខ្ញុំម្ចាស់ចឹកយកដុំបាយ ៣ ដុំ អំពីបាត្រទាំងនោះ កម្មប៉ុណ្ណេះ ជាបុព្វកម្មខ្ញុំ ខ្ញុំធ្វើកាលកិរិយាហើយក៏ឆេះក្នុងអវិចី ព្រោះវិបាកនៃកម្មនោះ ក្នុងកាលឥឡូវនេះ កើតជាកាកប្រេតសោយ

ទុក្ខនៅក្នុំគិជ្ឈកូដនេះ ដោយផលកម្មដ៏សេសព្រោះកម្មនោះ ។ រឿងកាកប្រេត មានប៉ុណ្ណេះ ។

ប៉ុន្តែក្នុងរឿងនេះ ព្រះថេរៈពោលថា "ខ្ញុំឃើញអហិប្រេត ទើបបានធ្វើនូវការញញឹមឲ្យប្រាកដ" ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជាសាក្សីរបស់ព្រះថេរៈ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានិយាយពិត តថាគតក៏បានឃើញប្រេតនោះ ក្នុងថ្ងៃដែលតថាគតសម្រេចនូវពោធិញ្ញាណដែរ តែតថាគតមិនសម្តែង ព្រោះអនុគ្រោះដល់បុគ្គលដទៃថា បុគ្គលណាមិនជឿពាក្យរបស់តថាគត ការមិនជឿនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដល់បុគ្គលទាំងនោះ" ។ ក៏ក្នុងកាលដែលព្រះមហាមោគ្គល្លានឃើញប្រេតហើយនោះឯង ព្រះសាស្តាទ្រង់ជាសាក្សីរបស់លោក ទ្រង់ត្រាស់រឿង ២០ រឿង ក្នុងលក្ខណសំយុត្ត ។ សូម្បីរឿងនេះ ព្រះថេរៈនោះ ក៏ពោលទុកយ៉ាងនោះដែរ ។ ភិក្ខុទាំងឡាយស្តាប់រឿងនោះហើយ ទើបទូលសួរបុព្វកម្មរបស់ប្រេតនោះ ។ សូម្បីព្រះសាស្តាក៏ត្រាស់ដល់ភិក្ខុទាំងនោះថា ៖

## បុព្វកម្មរបស់អហិប្រេត

បានឮថា ក្នុងអតីតកាល ពួកជនអាស្រ័យក្រុងពារាណសី សាងបណ្ណសាលាទុកដើម្បីព្រះបច្ចេកពុទ្ធ ក្បែរឆ្នេរស្ទឹង ។ ព្រះបច្ចេកពុទ្ធនោះ គង់នៅក្នុងបណ្ណសាលានោះ រមែងត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងជានិច្ច ។ សូម្បីពួកអ្នកក្រុងពារាណសី ក៏មានដៃកាន់សក្ការៈ មានគ្រឿងក្រអូប និងផ្កាកម្រង

ជាដើម ទៅកាន់ទីបម្រើរបស់ព្រះបច្ចេកពុទ្ធ ទាំងព្រឹកទាំងល្ងាច ។ បុរសអ្នកក្រុងពារាណសីម្នាក់អាស្រ័យនូវផ្លូវនោះ ភ្ជួរស្រែ ។ មហាជន កាលទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធ តែងតែជាន់ស្រែនោះទាំងព្រឹកទាំងល្ងាច ។ សូម្បីអ្នកស្រែនោះហាមថា "សូមពួកលោកកុំជាន់ស្រែរបស់ខ្ញុំ" ក៏មិនអាចហាមបាន ។ គ្រានោះ អ្នកស្រែនោះ បានគិតយ៉ាងនេះថា "ប្រសិនបើបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធ មិននៅទីនេះសោត ជនទាំងឡាយ ក៏មិនបានជាន់ស្រែរបស់យើងដែរ" ។ ក្នុងកាលដែលព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាត អ្នកស្រែនោះវាយបំបែកភាជនៈសម្រាប់ប្រើប្រាស់ ហើយដុតនូវបណ្ណសាលាចោល ។ ព្រះបច្ចេកពុទ្ធ ឃើញបណ្ណសាលាត្រូវភ្លើងឆេះហើយ ក៏បានចៀសចេញទៅតាមសប្បាយ ។ មហាជនកាន់គ្រឿងក្រអូប និងផ្កាកម្រងមក ឃើញបណ្ណសាលាត្រូវភ្លើងឆេះ ក៏ពោលថា "លោកម្ចាស់ដ៏ចម្រើនរបស់ពួកយើងនិមន្តទៅណាហ្ន៎" សូម្បីអ្នកស្រែនោះ ក៏មកជាមួយនឹងមហាជនដែរ ឈរនៅកណ្តាលមហាជន និយាយយ៉ាងនេះថា "បណ្ណសាលារបស់ព្រះបច្ចេកពុទ្ធនេះ ខ្ញុំជាអ្នកដុត" ។ គ្រានោះ ជនទាំងឡាយនិយាយថា "ពួកលោកចូរចាប់ ពួកយើងអាស្រ័យបុរសអាក្រក់នេះ ទើបមិនបានឃើញព្រះបច្ចេកពុទ្ធ" ដូច្នេះ ហើយក៏វាយអ្នកស្រែនោះ ដោយគ្រឿងប្រហារទាំងឡាយ មានដំបងជាដើម ឲ្យដល់នូវការអស់ជីវិត ។ ក្រោយអំពីស្លាប់ អ្នកស្រែនោះ ក៏កើតក្នុងអវិចី ឆេះក្នុងនរកដរាបដល់ផែនដីនេះដុះបានកម្រាស់ឡើងប្រមាណមួយយោជន៍ ក្នុងពុទ្ធុប្បាទកាល

នេះ កើតជាអហិប្រេត នៅនាភ្នំគិជ្ឈកូដ ដោយផលកម្មដ៏សេស ។

ព្រះសាស្ដាទ្រង់ប្រៀបធៀបផលកម្ម

ព្រះសាស្ដា លុះទ្រង់ត្រាស់បុព្វកម្មរបស់អហិប្រេតនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថាបាបកម្មនោះ ប្រៀបដូចជាទឹកដោះ ទឹកដោះស្រស់ដែលបុគ្គលកំពុងរឹត មិនទាន់ប្រែប្រួលទៅ យ៉ាងណា កម្មដែលបុគ្គលកំពុងធ្វើ ក៏មិនទាន់ឲ្យផលដូច្នោះដែរ តែក្នុងកាលណាកម្មឲ្យផល ក្នុងកាលនោះ អ្នកធ្វើរមែងជួបប្រសព្វនូវសេចក្ដីទុក្ខបែបនោះ" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ក៏ត្រាស់ព្រះគាថានេះថា ៖

ន ហិ បាបំ កតំ កម្មំ សជ្ជុ ខីរំវ មុច្ចតិ
ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ បាវកោ ។

កម្មលាមក ដែលជនពាលធ្វើហើយ មិនទាន់ឲ្យផលនោះក៏មាន
ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ (ក្នុងមួយរំពេច) ដូច្នោះ
បាបកម្មនោះ តាមដុតបុគ្គលពាល ដូចរងើកភ្លើងដែលបិទបាំងទុក
ដោយផេះ ដូច្នោះ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា សជ្ជុ ខីរំ (ទឹកដោះដែលរឹតក្នុងខណៈនោះ) សេចក្ដីថា ទឹកដោះស្រស់ដែលហូរចេញអំពីដោះមេគោក្នុងខណៈនោះ នៅក្ដៅ មិនទាន់ប្រែប្រួល គឺ មិនទាន់ប្រែប្រួលនៅឡើយ ។ ព្រះសាស្ដា ទ្រង់ត្រាស់

អធិប្បាយទុកដូច្នេះថា "ទឹកដោះស្រស់ដែលគេរឹតក្នុងខណៈនោះ មិនទាន់ប្រែប្រួល គឺ មិនប្រែប្រួល បានដល់ មិនទាន់លះបង់ភាពប្រក្រតីក្នុងខណៈនោះឯង តែកាលគេរឹតដាក់ក្នុងភាជនៈណា ក៏មិនទាន់លះបង់ភាពប្រក្រតីដរាបណា គេមិនទាន់ដាក់របស់ជូរជាដើមចូលក្នុងក្នុងភាជនៈនោះ គឺ ដរាបណាមិនទាន់ដល់ភាជនៈដែលមានរបស់ជូរ មានដោះគោទឹកដោះស្រស់ជាដើម ទើបលះបង់នូវភាពប្រក្រតីក្នុងខាងក្រោយ យ៉ាងណា សូម្បីបាបកម្មដែលបុគ្គលកំពុងធ្វើ ក៏មិនទាន់ឲ្យផលក្នុងខណៈនោះដូចគ្នា ។ ប្រសិនបើបាបកម្មឲ្យផល (ក្នុងខណៈកំពុងធ្វើ) នរណាៗ មិនគប្បីធ្វើបាបកម្មឡើយ ក៏ខន្ធទាំងឡាយដែលកើតអំពីកុសលនៅមានដរាបណា ខន្ធទាំងនោះ រមែងរក្សាបុគ្គលនោះបានដរាបនោះ កាលខន្ធទាំងឡាយកើតក្នុងអបាយ ព្រោះការបែកធ្លាយទៅនៃខន្ធទាំងនោះ បាបរមែងឲ្យផល ក៏កាលបាបឲ្យផល ឈ្មោះថា រមែងតាមដុតជនពាល ។

សួរថា ដូចអ្វី ?

ឆ្លើយថា ដូចរងើកភ្លើងបិទបាំងដោយផេះ ។

អធិប្បាយថា ដូចរងើកភ្លើងមានអណ្តាតទៅប្រាសហើយ ដែលបិទបាំងដោយផេះ សូម្បីបុគ្គលជាន់ហើយ ក៏មិនទាន់រលាកភ្លាមទេ ព្រោះផេះបិទបាំងតែញ៉ាំងផេះឲ្យក្តៅហើយ រមែងធ្វើឲ្យរលាករហូតដល់ខួរឆ្អឹង ដោយអំណាចនៃការឆេះអវយវៈ មានស្បែកជាដើមយ៉ាងណា សូម្បីបាបកម្មក៏ដូច្នោះដូចគ្នា ជាបាបកម្មដែលបុគ្គលណាធ្វើទុក រមែងតាមដុតបុគ្គលនោះ ដែលជាជនពាល

កើតហើយក្នុងអបាយ មាននរកជាដើម ក្នុងអត្តភាពទី ២ ឬទី ៣ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានសំរេចអរិយផល មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងអហិប្រេត

# ១៣. រឿងសដ្ឋិកូដប្រេត

*ព្រះសាស្ដា កាលប្រថាប់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសដ្ឋិកូដប្រេត (ប្រេតដែលត្រូវញញួរ ៦ ម៉ឺនសំពងក្បាលរាល់ថ្ងៃ) ត្រាស់ព្រះធម៌ទេសនានេះថា **យាវទេវ អនត្ថាយ** (គ្រាន់តែសេចក្ដីវិនាសប៉ុណ្ណោះ) ជាដើម ។*

ព្រះមោគ្គល្លានឃើញសដ្ឋិកូដប្រេត

*សេចក្ដីពិស្ដារថា ព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដមួយអន្ទើដោយព្រះលក្ខណត្ថេរ ធ្វើការញញឹមក្នុងប្រទេសមួយដោយន័យដូចដែលមានហើយក្នុងកាលមុន ត្រូវព្រះលក្ខណត្ថេរសួរដល់ហេតុនៃការញញឹម ក៏ពោលថា "អាវុសោលក្ខណៈ លោកគប្បីសួរខ្ញុំក្នុងសម្នាក់ព្រះមានព្រះភាគចុះ" ក្នុងកាលដែលព្រះមហាមោគ្គល្លានត្រាច់ទៅបិណ្ឌបាតរួចហើយ ចូលគាល់ព្រះសាស្ដាថ្វាយបង្គំហើយ គង់ក្នុងទីដ៏សមគួរ ត្រូវព្រះថេរៈសួរ ក៏ពោលថា "អាវុសោខ្ញុំបានឃើញប្រេតមួយ មានអត្តភាពប្រមាណ ៣ គាវុត ត្រូវញញួរដែក ៦ ម៉ឺន ដែលមានភ្លើងឆេះសន្ធោសន្ធៅ ធ្លាក់មកលើក្បាលរបស់ប្រេតនោះ ហើយវាយបំបែកក្បាលប្រេតនោះ ក្បាលដែលបែកហើយ ត្រឡប់ប្រាកដដូចដើមវិញ ញញួរមែងតាំងឡើងទៀត អត្តភាពបែបនេះខ្ញុំមិនធ្លាប់បានឃើញទេ ខ្ញុំឃើញអត្តភាពនោះ ទើបធ្វើការញញឹមឲ្យប្រាកដ" ។ ពិតហើយ ក្នុងរឿងប្រេត ព្រះមហាមោគ្គល្លានសំដៅដល់ប្រេតនោះឯង ទើបពោលពាក្យជាដើម*

ថា ៖

ញញួរដែក ៦ ម៉ឺន បរិបូណ៌ហើយដោយប្រការទាំងពួង
ធ្លាក់មកលើក្បាលរបស់គេ ទម្លាយក្បាលរបស់គេជានិច្ច ។

ព្រះសាស្តាទ្រង់ទទួលថា ប្រេតមាន

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រះថេរៈហើយ ក៏ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ សត្វនេះសូម្បីកាលតថាគតគង់នៅនាពោធិមណ្ឌលប្រទេស ក៏តថាគតបានឃើញដែរ តែតថាគតមិនសម្តែងប្រាប់ ព្រោះអនុគ្រោះដល់ជនដទៃថា ជនទាំងឡាយណា មិនជឿពាក្យរបស់តថាគត ការមិនជឿនោះគប្បីមានដើម្បីកម្មមិនជាប្រយោជន៍អស់កាលដ៏យូរ ដល់ជនទាំងនោះ តែថាឥឡូវនេះ តថាគតជាសាក្សីរបស់មោគ្គល្លាន ទើបបានសម្តែងប្រាប់” ។ ភិក្ខុទាំងឡាយស្តាប់ព្រះតម្រាស់នោះហើយ ក៏ទូលសួរដល់ បុព្វកម្មរបស់ប្រេតនោះ ។ ព្រះសាស្តា ក៏ត្រាស់បុព្វកម្មរបស់ប្រេតនោះប្រាប់ភិក្ខុទាំងនោះ ៖

បុព្វកម្មរបស់សដ្ឋិកូដប្រេត

បានឮថា ក្នុងអតីតកាល នៅក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ស្ទាត់ជំនាញខាងផ្ទាត់គ្រាប់ក្រួស ។ បុរសនោះ អង្គុយនៅក្រោមដើមជ្រៃក្រឹមមួយដើម ក្បែរទ្វារនគរ ត្រូវពួកក្មេងអ្នកស្រុកពោលថា “លោកចូរផ្ទាត់គ្រាប់ក្រួស ចោះស្លឹកជ្រៃក្រឹមនោះសម្តែងរូបដំរី រូបសេះដល់ពួកយើង” ក៏សម្តែងរូបទាំងឡាយដែលពួកក្មេងប្រាថ្នា បាននូវវត្ថុទាំងឡាយ មានរបស់ទំពាស៊ីជា

ដើមអំពីពួកក្មេងទាំងនោះ ។ ថ្ងៃមួយ ព្រះរាជាស្ដេចយាងទៅកាន់ព្រះរាជ-ឧទ្យាន ស្ដេចយាងដល់កន្លែងនោះ ពួកក្មេងទាំងនោះក៏លាក់បុរសខ្វិនទុកក្នុងចន្លោះនៃពួរជ្រៃ ហើយនាំគ្នារត់ចេញទៅ ។ កាលព្រះរាជា ស្ដេចចូលទៅកាន់គល់ជ្រៃ ជាវេលាថ្ងៃត្រង់ ស្រមោលនៃប្រហោងនោះ ផ្សាយទៅកាន់សរីរៈរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ព្រះតម្រិះថា "នេះជាអ្វីហ្ន៎" ទ្រង់ងៀងមើលខាងលើឃើញរូបទាំងឡាយ មានរូបដំរីជាដើមត្រង់ស្លឹកឈើ ក៏ត្រាស់សួរថា "នេះជាកម្មរបស់អ្នកណា" ទ្រង់ព្រះសណ្ដាប់ថា របស់បុរសខ្វិន ក៏ត្រាស់ឲ្យហៅបុរសខ្វិននោះមក ហើយត្រាស់ថា "ម្នាលអ្នកដ៏ចម្រើន បុរោហិតរបស់យើងមានមាត់រឹងណាស់ កាលយើងពោលពាក្យមានប្រមាណតិច ក៏និយាយពាក្យយ៉ាងច្រើន រមែងបៀតបៀនយើងដោយពាក្យសំដី អ្នកអាចផ្ទាត់អាចម៍ពពែប្រមាណមួយនាឡិចូលទៅក្នុងមាត់របស់បុរោហិតនោះបានទេ" បុរសខ្វិននោះក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គអាច សូមព្រះអង្គាឲ្យមនុស្សនាំអាចម៍ពពែមក ហើយប្រថាប់គង់ខាងក្នុងវាំងននជាមួយនឹងបុរោហិតចុះ ខ្ញុំព្រះអង្គនឹងដឹងកម្មដែលគួរធ្វើក្នុងរឿងនេះ" ។ ព្រះរាជា ក៏ទ្រង់ធ្វើតាមបុរសខ្វិននោះ ។ បុរសខ្វិនបានឲ្យគេធ្វើប្រហោងវាំងននដោយចុងកន្ត្រៃ គ្រាន់តែបុរោ-ហិតហាមាត់និយាយជាមួយនឹងព្រះរាជា ក៏ផ្ទាត់អាចម៍ពពែទៅម្ដងមួយដុំៗ ។ បុរោហិតបានលេបអាចម៍ពពែដែលចូលទៅក្នុងមាត់នោះ ។ កាលអាចម៍ពពែអស់ហើយ បុរសខ្វិនក៏ញាំងវាំងននឲ្យញ័រ ព្រះរាជាទ្រង់ជ្រាបថា អាចម៍ពពែ

អស់ដោយសញ្ញានោះ ហើយក៏ត្រាស់ថា "ម្នាលអាចារ្យ យើងនិយាយជាមួយនឹងលោកមិនដែលឈ្នះ លោកសូម្បីលេបអាចម៍ពពែមួយនាឡិហើយ ក៏នៅស្ងៀមមិនបាន លោកជាមនុស្សមានមាត់រឹងណាស់" ។ ព្រាហ្មណ៍មានសេចក្ដីអៀនខ្មាសនឹងព្រះរាជា ចាប់តាំងពីថ្ងៃនោះមក មិនហ៊ានហាមាត់ចរចាជាមួយនឹងព្រះរាជាទៀតឡើយ ។ ព្រះរាជាត្រាស់បង្គាប់ឲ្យហៅបុរសខ្វិនមក ហើយត្រាស់ថា "ម្នាលអ្នកដ៏ចម្រើន យើងបានសេចក្ដីសុខព្រោះអាស្រ័យអ្នក" ទ្រង់ពេញព្រះទ័យ ទើបព្រះរាជទានពួក ៨ នៃវត្ថុទាំងពួងដល់បុរសខ្វិននោះ បានព្រះរាជទានស្រុកសួយ ៤ ក្នុងទិសទាំង ៤ នៃក្រុង ដល់បុរសខ្វិននោះ ។ អាមាត្យអ្នកប្រៀនប្រដៅអត្ថ និងធម៌របស់ព្រះរាជាដឹងសេចក្ដីនោះហើយ ក៏ពោលគាថាដូច្នេះថា ៖

ឈ្មោះថា សិល្បៈ សូម្បីសិល្បៈណាមួយ ក៏ញុំាង
ប្រយោជន៍ឲ្យសម្រេចបាន លោកចូរមើលចុះ ដោយ
ការផ្ទាត់អាចម៍ពពែរបស់បុរសខ្វិន បុរសខ្វិននោះ
បានស្រុកសួយ ដែលតាំងនៅក្នុងទិសទាំង ៤ ។

(ក៏អាមាត្យ) ក្នុងសម័យនោះ គឺ តថាគតនេះឯង) ។ គ្រានោះ បុរសម្នាក់ឃើញបុរសខ្វិននោះបានលាភសក្ការៈដូច្នេះ ក៏គិតថា "បុរសនេះជាមនុស្សខ្វិនអាស្រ័យសិល្បៈនេះ ទើបបានទទួលនូវមហាសម្បត្តិ សូម្បីយើងក៏គួរសិក្សាសិល្បៈនេះ" ។ បុរសនោះ ក៏ចូលទៅរកបុរសខ្វិន ហើយសំពះសូមរៀនសិល្បៈ

ដោយពោលថា "លោកអាចារ្យ សូមបង្រៀនសិល្បៈនេះដល់ខ្ញុំផងចុះ" ។ បុរសខ្វិនពោលថា "ម្នាលបា យើងមិនអាចបង្រៀនបានទេ" ។ គេត្រូវបុរសខ្វិននោះហាមហើយ ក៏គិតថា "ណ្ហើយចុះ យើងនឹងធ្វើបុរសខ្វិននោះឲ្យត្រេកអរ" ទើបធ្វើកិច្ច មានការច្របាច់ដៃ និងជើងជាដើមឲ្យបុរសខ្វិននោះ ញុំាងបុរសខ្វិននោះឲ្យត្រេកអរហើយ អស់កាលមិនយូរ ក៏អង្វរទៀត ។ បុរសខ្វិននោះគិតថា "បុរសនេះជាអ្នកមានឧបការៈច្រើនចំពោះយើង" ក៏មិនអាចហាមឃាត់បុរសនោះបាន ឲ្យបុរសនោះសិក្សាហើយ ទើបពោលថា "ម្នាលបា សិល្បៈរបស់អ្នកសម្រេចហើយ ឥឡូវនេះ អ្នកនឹងធ្វើអ្វី" ។

បុរស. ខ្ញុំនឹងទៅល្បងមើលសិល្បៈខាងក្រៅ ។

បុរសខ្វិន. អ្នកនឹងធ្វើដូចម្ដេច ។

បុរស. ខ្ញុំនឹងប្រហារមេគោ ឬមនុស្សឲ្យស្លាប់ ។

បុរសខ្វិនពោលថា "ម្នាលបា កាលអ្នកសម្លាប់មេគោនឹងត្រូវពិន័យ ១០០ កាលអ្នកប្រហារមនុស្សនឹងត្រូវពិន័យ ១.០០០ អ្នកព្រមទាំងបុត្រ និងភរិយាក៏មិនអាចបង់ពិន័យនោះបានដែរ អ្នកចូរកុំវិនាសឡើយ អ្នកត្រូវពិចារណារកមើលនូវបុគ្គលណាមួយដែលមិនមានមាតាបិតា ទើបមិនត្រូវពិន័យ ។ បុរសនោះទទួលថា "សាធុ" ហើយយកគ្រាប់គ្រួសដាក់ក្នុងថ្នក់ដើររកបុគ្គលដូច្នោះ ឃើញមេគោហើយ មិនហ៊ានប្រហារ ដោយគិតឃើញថា "មេគោនេះមានម្ចាស់" ឃើញមនុស្សហើយមិនហ៊ានប្រហារ ដោយគិតថា "មនុស្សនេះ

មានមាតាបិតា” ។

ក៏ក្នុងសម័យនោះ ព្រះបច្ចេកពុទ្ធព្រះនាម សុនេត្ត អាស្រ័យបណ្ណ-សាលា នៅក្នុងព្រះនគរ ។ បុរសនោះ ឃើញព្រះបច្ចេកពុទ្ធនោះ ដែលជាអ្នកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឈរនៅត្រង់ចន្លោះទ្វារនគរ ក៏គិតថា “ព្រះបច្ចេកពុទ្ធនេះ ជាអ្នកមិនមានមាតាបិតា កាលយើងផ្ទាត់គ្រាប់ក្រួសប្រហារព្រះបច្ចេកពុទ្ធនេះ រមែងមិនត្រូវពិន័យ យើងនឹងផ្ទាត់គ្រាប់ក្រួសប្រហារព្រះបច្ចេកពុទ្ធនេះ ដើម្បីល្បងមើលសិល្បៈ” ដូច្នេះ ហើយក៏ផ្ទាត់ដុំក្រួសសំដៅត្រង់រន្ធត្រចៀកខាងស្តាំរបស់ព្រះបច្ចេកពុទ្ធ ។ ដុំក្រួសចូលទៅតាមរន្ធត្រចៀកខាងស្តាំ ធ្លុះចេញមកតាមរន្ធត្រចៀកខាងឆ្វេង ។ ទុក្ខវេទនាក៏កើតឡើង ។ ព្រះបច្ចេកពុទ្ធ មិនអាចនឹងត្រាច់ទៅដើម្បីភិក្ខាបាន ក៏ចូលទៅកាន់បណ្ណសាលាតាមអាកាស ហើយក៏បរិនិព្វានទៅ ។ ពួកមនុស្សកាលមិនឃើញព្រះបច្ចេក-ពុទ្ធមក ក៏គិតថា “ប្រហែលជាលោកម្ចាស់ដ៏ចម្រើនរបស់ពួកយើង មានអាពាធទេដឹង ក៏ទៅកាន់បណ្ណសាលានោះ ឃើញព្រះបច្ចេកពុទ្ធបរិនិព្វានហើយ ក៏ខ្សឹកខ្សួល យំរៀបរាប់ ។ បុរសនោះ ឃើញមហាជនទៅកាន់បណ្ណសាលាក៏ទៅដែរ លុះទៅដល់បណ្ណសាលានោះហើយ ចាំព្រះបច្ចេកពុទ្ធបាន ក៏ពោលថា “ព្រះបច្ចេកពុទ្ធអង្គនេះ កាលចូលទៅដើម្បីបិណ្ឌបាត ជួបយើងនៅត្រង់ចន្លោះទ្វារនគរ យើងកាលនឹងល្បងមើលសិល្បៈរបស់ខ្លួន ក៏ប្រហារព្រះបច្ចេក-ពុទ្ធអង្គនេះ” ។ ពួកមនុស្សពោលថា “បានឮថា មនុស្សអាក្រក់នេះប្រហារព្រះ-

បច្ចេកពុទ្ធ អ្នកទាំងឡាយចូរចាប់” ទើបវាយប្រហារបុរសនោះឲ្យដល់នូវការអស់ជីវិតក្នុងទីនុ៎ះឯង ។ បុរសនោះកើតក្នុងអវីចិ ឆេះក្នុងនរកនោះ រហូតមហាប្រឹថពីដុះឡើងកម្រាស់ ១ យោជន៍ កើតជាសដ្ឋិកូដប្រេត នៅនាកំពូលភ្នំគិជ្ឈកូដ ដោយផលកម្មដែលនៅសល់ ។

ព្រះសាស្តាត្រាស់ប្រៀនប្រដៅពួកភិក្ខុ

ព្រះសាស្តា លុះត្រាស់នូវបុព្វកម្មរបស់ប្រេតនោះហើយ ក៏ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ សិល្បៈ ឬភាពជាឥស្សរៈ កាលកើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ ត្បិតថា ជនពាលបាននូវសិល្បៈ ឬភាពជាឥស្សរៈហើយ រមែងធ្វើនូវអំពើដែលនាំមកនូវសេចក្តីវិនាសឲ្យដល់ខ្លួនតែប៉ុណ្ណោះ” ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ក៏ត្រាស់ព្រះគាថានេះថា ៖

យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ
ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស វិបាតយំ ។

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តី
វិនាសប៉ុណ្ណោះ រមែងញុំាងបញ្ញាឲ្យធ្លាក់ចុះ បំផ្លិចបំផ្លាញចំណែក
ធម៌ស គឺ កុសលរបស់បុគ្គលពាលនោះ ។

អធិប្បាយគាថា

បទថា យាវទេវ (ត្រឹមតែដើម្បី) ក្នុងគាថានេះជានិបាត ក្នុងអត្ថ គឺ

ការកំណត់នូវព្រំដែន ។ ការៈ គឺ សេចក្ដីដឹង ឈ្មោះថា **ញត្តំ** (សេចក្ដីដឹង) ។ បុគ្គលរមែងចេះនូវសិល្បៈឯណានីមួយ ឬបុគ្គលតាំងនៅក្នុងភាពជាធំឯណាមួយ ឬដោយការដល់ព្រមដោយយសឯណា ដែលជនរមែងដឹង គឺ ប្រាកដ បានដល់ ជាអ្នកដឹងទូទៅ ។ បទថា **ញត្តំ** នេះ ជាឈ្មោះនៃសិល្បៈ ភាពជាធំនិងការដល់ព្រមដោយយសនោះឯង ។ ពិតណាស់ សិល្បៈ ឬភាពជាធំជាដើម កើតឡើងដល់ជនពាល គ្រាន់តែដើម្បីសេចក្ដីវិនាសប៉ុណ្ណោះ គឺ ជនពាលនោះ អាស្រ័យសិល្បៈជាដើមនោះហើយ រមែងធ្វើសេចក្ដីវិនាសឲ្យដល់ខ្លួនឯងតែប៉ុណ្ណោះ ។ បទថា **ហន្តិ** (**រមែងសម្លាប់**) បានដល់ ឲ្យវិនាស ។ បទថា **សុក្កំសំ** (**ការៈល្អ**) គឺ ចំណែកនៃកុសល ។ អធិប្បាយថា ក៏សិល្បៈ ឬភាពជាធំ កាលកើតឡើងដល់ជនពាល រមែងកើតឡើងដើម្បីសម្លាប់នូវចំណែកនៃកុសលតែប៉ុណ្ណោះ ។ បទថា **មុទ្ធំ** (**ពិចារណា**) នេះ ជាឈ្មោះនៃបញ្ញា ។ បទថា **វិបាតយំ** (**ឲ្យធ្លាក់ចុះ**) គឺ កម្ចាត់ អធិប្បាយថា ក៏ការចេះដឹងនោះ រមែងសម្លាប់ចំណែកនៃកុសលរបស់ជនពាលនោះ ញុំាងមុទ្ធា ពោលគឺ បញ្ញាឲ្យធ្លាក់ចុះ គឺ កម្ចាត់នោះឯង ឈ្មោះថា សម្លាប់ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងសដ្ឋិក្ខូដប្រេត

# ១៤. រឿងព្រះសុធម្មត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសុធម្មត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា **អសន្តំ ភាវមិច្ឆេយ្យ** (គប្បីប្រាថ្នាសេចក្តីសរសើរ ដែលមិនមាន) ជាដើម ។*

ចិត្តគហបតីថ្វាយឧទ្យានជាសង្ឃារាម

*ក៏ទេសនាតាំងឡើងនៅក្នុង មច្ឆិកាសណ្ឌនគរ ចប់ហើយនៅក្នុងក្រុងសាវត្ថី ។*

*សេចក្តីពិស្តារថា **ចិត្តគហបតី** ដែលជាអ្នកនៅក្នុងមច្ឆិកាសណ្ឌនគរ ឃើញព្រះមហានាមត្ថេរ ត្រាច់បិណ្ឌបាត ជ្រះថ្លាក្នុងឥរិយាបថរបស់ព្រះថេរៈហើយ ក៏ទទួលបាត្រ និមន្តឲ្យចូលទៅកាន់ផ្ទះ ញ៉ាំងព្រះថេរៈឲ្យឆាន់ ក្នុងកាលស្រេចភត្តកិច្ច ស្តាប់ធម្មកថា សំរេចសោតាបត្តិផលហើយ ជាអ្នកមានសទ្ធាមិនញាប់ញ័រ ប្រាថ្នានឹងធ្វើឧទ្យានរបស់ខ្លួនដែលមានឈ្មោះថា **អម្ពាដកវ័ន** ឲ្យជាសង្ឃារាម ទើបប្រូចទឹកដាក់ព្រះហស្តរបស់ព្រះថេរៈ ហើយវេរឧទ្យានប្រគេនសង្ឃ ។ ក្នុងខណៈនោះ មហាប្រឹថពី ដែលមានទឹកជាទីបំផុត ក៏ញាប់ញ័រដោយប្រាប់ហេតុថា "ព្រះពុទ្ធសាសនាតាំងមាំហើយ" ។ មហាសេដ្ឋី ឲ្យគេសាងមហាវិហារក្នុងឧទ្យាន ដើម្បីពួកភិក្ខុដែលត្រាច់មកអំពីទិសទាំងពួង ។ ព្រះសុធម្មត្ថេរ បានជាចៅអាវាសនៅក្នុងមច្ឆិកាសណ្ឌៈទុំះឯង ។*

## គហបតីសម្រេចអនាគាមិផល

ក្នុងសម័យមួយ ព្រះអគ្គសាវកទាំងពីរ ស្ដាប់កថាដែលពណ៌នាគុណរបស់ចិត្តគហបតីហើយ ប្រាថ្នានឹងធ្វើសេចក្ដីអនុគ្រោះដល់ចិត្តគហបតីនោះ ក៏បានទៅកាន់មច្ឆិកាសណ្ឌនគរ ។ ចិត្តគហបតី បានឮថា ព្រះអគ្គសាវកទាំងពីរនិមន្តមក ក៏ទៅទទួលអស់ចម្ងាយផ្លូវប្រមាណកន្លះយោជន៍ នាំព្រះអគ្គសាវកទាំងពីរនោះមក ហើយនិមន្តឲ្យចូលទៅកាន់វិហាររបស់ខ្លួន និងធ្វើអាគន្តុកវត្តអារាធនាព្រះធម្មសេនាបតីថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាប្រាថ្នាស្ដាប់ធម្មកថា ។ គ្រានោះ ព្រះថេរៈពោលទៅកាន់ចិត្តគហបតីថា "ឧបាសកអាត្មាទាំងឡាយ មានកាយលំបាកដោយផ្លូវឆ្ងាយ ប៉ុន្តែលោកចូរស្ដាប់បន្តិចចុះ" ដូច្នេះ ហើយក៏ពោលធម្មកថាដល់ចិត្តគហបតី ។ ចិត្តគហបតី ស្ដាប់ធម្មកថារបស់ព្រះថេរៈនោះឯង ក៏បានសម្រេចអនាគាមិផល ។ លុះស្ដាប់ព្រះធម្មកថាចប់ គាត់ក៏ថ្វាយបង្គំអារាធនានិមន្តអគ្គសាវកទាំងពីរថា "លោកម្ចាស់ដ៏ចម្រើនថ្ងៃស្អែក សូមលោកម្ចាស់ទាំងពីរអង្គ មួយអន្លើដោយភិក្ខុមួយពាន់រូប ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះករុណា" ហើយនិមន្តព្រះសុធម្មត្ថេរដែលជាចៅអាវាសជាខាងក្រោយថា "លោកម្ចាស់ដ៏ចម្រើន ថ្ងៃស្អែកនេះ សូម្បីលោកម្ចាស់ក៏គប្បីនិមន្តទៅកាន់ផ្ទះរបស់ខ្ញុំព្រះករុណា ដើម្បីទទួលភិក្ខាជាមួយនឹងព្រះថេរៈទាំងឡាយដែរ ។

## ព្រះសុធម្មត្ថេរជេរគហបតី

ព្រះសុធម្មត្ថេរនោះក្រោធថា ឧបាសកនេះ និមន្តយើងខាងក្រោយ ក៏ប្រកែកមិនទទួលនិមន្ត សូម្បីគហបតីអង្វរហើយអង្វរទៀត ក៏នៅតែប្រកែកមិនព្រមទទួលដដែល ។ ឧបាសកពោលថា "លោកម្ចាស់ បើដូច្នោះ តាមអធ្យាស្រ័យរបស់លោកម្ចាស់ចុះ" ហើយក៏ចៀសចេញទៅ ថ្ងៃស្អែកឡើងបានចាត់ចែងមហាទានទុកក្នុងផ្ទះរបស់ខ្លួន ។ ក្នុងវេលាជិតភ្លឺនាថ្ងៃនោះ សូម្បីព្រះសុធម្មត្ថេរគិតថា "គហបតីចាត់ចែងគ្រឿងសក្ការៈដើម្បីអគ្គសាវកទាំងពីរដូចម្តេចទៅហ្ន៎ ថ្ងៃស្អែកនេះ យើងនឹងទៅមើលមើល៍" ហើយបានកាន់បាត្រនិងចីវរទៅកាន់ផ្ទះរបស់គហបតីនោះទាំងព្រលឹម ។ ព្រះសុធម្មត្ថេរនោះ សូម្បីគហបតីពោលថា "លោកម្ចាស់ សូមលោកម្ចាស់និមន្តគង់ចុះ" ក៏ពោលថា "អាត្មាមិនគង់ទេ អាត្មានឹងត្រាច់បិណ្ឌបាត" ហើយសម្លឹងមើលនូវគ្រឿងសក្ការៈដែលគហបតីចាត់ចែងទុកដើម្បីអគ្គសាវកទាំងពីរ ប្រាថ្នានឹងជៀមជាមចំពោះគហបតីដោយជាតិ ក៏ពោលថា "ម្នាលគហបតី គ្រឿងសក្ការៈរបស់លោកដ៏លើសលប់ (អស្ចារ្យ) ប៉ុន្តែថា ក្នុងគ្រឿងសក្ការៈនេះខ្វះវត្ថុមួយមុខ" ។

គហបតី. លោកម្ចាស់ វត្ថុអ្វី ?

ព្រះថេរៈឆ្លើយថា "ម្នាលគហបតី គឺ នំលាយដោយល្ង (ទ្រាបល្ង)" ត្រូវគហបតីពោលបន្អាក់ដោយវាចាថា "ជាបុគ្គលឧបមាដូចក្អែក" ក៏ក្រោធ ហើយពោលថា "ម្នាលគហបតី នុ៎ះអាវាសរបស់លោក អាត្មានឹងលាទៅហើយ" ។

សូម្បីគហបតីហាមឃាត់អស់វារៈ ៣ ដង ក៏នៅតែមិនព្រម បានចៀសចេញទៅកាន់សំណាក់ព្រះសាស្តា ក្រាបទូលពាក្យដែលចិត្តគហបតី និងខ្លួនពោល ។

ព្រះសុធម្មត្ថេរត្រូវសង្ឃដាក់បដិសារណីយកម្ម

ព្រះសាស្តាត្រាស់ថា "ឧបាសកជាអ្នកមានសទ្ធាជ្រះថ្លា ដែលអ្នកជេរ (បន្ទាប់) ហើយ ដោយពាក្យដ៏ថោកទាប ដូច្នេះ ទើបទ្រង់លើកទោសរបស់ព្រះសុធម្មត្ថេរឡើង ហើយត្រាស់ឲ្យសង្ឃដាក់បដិសារណីយកម្ម (កម្មដែលឲ្យរឭកដល់កំហុស) ហើយទ្រង់បញ្ជូនទៅថា "ម្នាលភិក្ខុ អ្នកចូរទៅសុំទោសគហបតីចុះ" ។ ព្រះថេរៈទៅកាន់ទីនោះហើយ ពោលថា "ម្នាលគហបតី ទុំះជាកំហុសរបស់អាត្មាប៉ុណ្ណោះ សូមគហបតីអត់ទោសឲ្យអាត្មាផងចុះ" ។ ត្រូវគហបតីនោះប្រកែកថា "ខ្ញុំព្រះករុណាមិនអត់ទោសឲ្យទេ ក៏មានការអៀនខ្មាស ព្រោះមិនអាចឲ្យគហបតីនោះអត់ទោសឲ្យបាន ក៏ត្រឡប់មកកាន់សម្នាក់ព្រះសាស្តាម្តងទៀត ។ ព្រះសាស្តា សូម្បីទ្រង់ជ្រាបថា "ឧបាសកមិនអត់ទោសឲ្យព្រះសុធម្មទេ" ទ្រង់ក៏មានព្រះតម្រិះថា "ភិក្ខុនេះ រឹងត្អឹងដោយមានះ ទៅកាន់ផ្លូវអស់ ៣០ យោជន៍ហើយ ត្រឡប់មកវិញ" ទ្រង់ក៏មិនប្រាប់ឧបាយដែលជាគ្រឿងញុំាងគហបតីឲ្យអត់ទោសឲ្យឡើយ ទ្រង់ក៏បញ្ជូនទៅទៀត ។

សមណៈមិនគួរធ្វើមានះ និងឥស្សា

ក្នុងកាលដែលព្រះសុធម្មត្ថេរនោះត្រឡប់មកម្តងទៀត ព្រះសាស្តា ក៏ប្រទានភិក្ខុអនុទូតដល់ព្រះសុធម្មត្ថេរ ដែលជាអ្នកនាំមានះចេញហើយ ត្រាស់

ថា “ម្នាលភិក្ខុ អ្នកចូរទៅចុះ ចូរទៅជាមួយនឹងភិក្ខុដែលជាអនុទូតនេះ ហើយញ៉ាំងឧបាសកឲ្យអត់ទោសឲ្យចុះ” ហើយទ្រង់ត្រាស់ថា “ធម្មតាសមណៈ មិនគួរធ្វើមានះ ឬឥស្សា ថា វិហាររបស់យើង លំនៅរបស់យើង ឧបាសករបស់យើង ឧបាសិការបស់យើង ព្រោះបើសមណៈធ្វើយ៉ាងនោះ ពួកកិលេសមានឥស្សា និងមានះជាដើមរមែងចម្រើន” កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ក៏ត្រាស់ព្រះគាថាទាំងនេះថា ៖

អសន្តំ ភាវមិច្ឆេយ្យ បុរេក្ខារញ្ច ភិក្ខុសុ
អាវាសេសុ ច ឥស្សរិយំ បូជា បរកុលេសុ ច ។

ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរ ដែលមិនមាន (ក្នុងខ្លួន) ផង នូវការធ្វើក្នុងខាងមុខ គឺ ជាប្រមុខក្នុងពួកភិក្ខុផង នូវភាពជាឥស្សរៈ ក្នុងអាវាសទាំងឡាយផង នូវការបូជាទាំងឡាយ ក្នុងត្រកូលទាំងឡាយដទៃផង ។

មមេវ កត មញ្ញន្តុ គិហិបព្វជិតា ឧភោ
មមេវ អតិវសា អស្សុ កិច្ចាកិច្ចេសុ កិស្មិចិ
ឥតិ ពាលស្ស សង្កប្បោ ឥស្សា មានោ ច វឌ្ឍតិ ។

ភិក្ខុពាល តែងមានសេចក្តីត្រិះរិះថា គ្រហស្ថ និងបព្វជិតទាំង ២ ពួក ចូរសម្គាល់នូវកិច្ចដែលមនុស្សដទៃធ្វើហើយថាជារបស់អញវិញ អំណាចដ៏ក្រៃលែងរបស់អញ ចូរ

មានក្នុងកិច្ច តូច ធំ ណាៗ មួយ (កាលបើយ៉ាងនេះ)
ឫស្យា និងមានះ រមែងចម្រើន ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អសន្តំ (ដែលមិនមាន)** សេចក្តីថា ភិក្ខុពាល រមែងប្រាថ្នានូវសេចក្តីសរសើរដែលមិនមានក្នុងខ្លួន គឺ ភិក្ខុពាលមិនមានសទ្ធា ជាអ្នកទ្រុស្តសីល ស្តាប់តិច មិនស្ងប់ស្ងាត់ ខ្ជិលច្រអូស មានសតិមិនតាំងមាំ មានចិត្តមិនតាំងមាំ ជាអ្នកមានបញ្ញាអន់ថយ (ឥតបញ្ញា) មិនមែនជាព្រះខីណាស្រព រមែងប្រាថ្នាការសរសើរដែលមិនមានក្នុងខ្លួនថា "ធ្វើដូចម្តេចហ្ន៎ ជនទាំងឡាយគប្បីដឹងយើងថា ភិក្ខុនេះមានសទ្ធា មានសីល ជាពហុស្សូត ជាអ្នកស្ងប់ស្ងាត់ ប្រារព្ធសេចក្តីព្យាយាម មានសតិតាំងមាំ មានចិត្តតាំងមាំ មានបញ្ញា ជាព្រះខីណាស្រព" សមដូចន័យដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកក្នុងបាបិច្ឆតានិទ្ទេសថា "ភិក្ខុពាល ជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា ជនទាំងឡាយ ចូរដឹងយើងថា ជាអ្នកមានសទ្ធាជាដើម" ។ បទថា **បុរេក្ខារំ (ហែហម)** បានដល់ បរិវារ គឺ ការចោមរោម ។ អធិប្បាយថា ភិក្ខុពាលតាំងនៅក្នុងសេចក្តីប្រាថ្នាយ៉ាងនេះថា "ធ្វើដូចម្តេចហ្ន៎ ភិក្ខុក្នុងវិហារទាំងអស់គប្បីចោមរោមសួរបញ្ហាយើង" ឈ្មោះថា ប្រាថ្នាការហែហមចោមរោមអំពីភិក្ខុទាំងឡាយ ។

បទថា **អាវាសេសុ (ក្នុងអាវាស)** បានដល់ ក្នុងអាវាសដែលជារបស់

សង្ឃ ។ អធិប្បាយថា ភិក្ខុពាល ចាត់ចែងសេនាសនៈដ៏ប្រណីតៗ ក្នុងកណ្ដាលវិហារ ដើម្បីភិក្ខុទាំងឡាយដែលជាមិត្តត្រឹមតែឃើញ និងមិត្តដែលគប់គ្នាជាដើមរបស់ខ្លួន ដោយប្រាប់ថា "ពួកលោកចូរនៅក្នុងសេនាសនៈនេះ" ចំណែកខ្លួនឯងខ្វល់ខ្វាយរើសរកតែសេនាសនៈដ៏ល្អៗ ចាត់ចែងសេនាសនៈដ៏ស្មោកគ្រោក និងសេនាសនៈដែលអមនុស្សហួងហែង ដែលតាំងនៅខាងចុងវិហារ ដើម្បីអាគន្តុកៈដ៏សេសទាំងឡាយ ដោយប្រាប់ថា "ពួកលោកចូរនៅក្នុងសេនាសនៈនេះ" ឈ្មោះថា ប្រាថ្នាភាពជាធំក្នុងអាវាស ។

បទថា **បូជា បរកុលេសុ ច** (ការបូជាក្នុងត្រកូលនៃជនដទៃ) សេចក្ដីថា ភិក្ខុពាល រមែងមិនប្រាថ្នាការបូជាដោយបច្ច័យ ៤ ក្នុងត្រកូលរបស់មាតាបិតាឡើយ សូម្បីតែត្រកូលរបស់ពួកញាតិ ក៏មិនប្រាថ្នា (ប៉ុន្តែ) រមែងប្រាថ្នាក្នុងត្រកូលនៃជនដទៃប៉ុណ្ណោះ ដោយប្រាថ្នាយ៉ាងនេះថា "ធ្វើដូចម្ដេចហ្ន៎ ជនទាំងនេះគប្បីឲ្យតែយើងម្នាក់ កុំគប្បីឲ្យដល់ភិក្ខុដទៃឡើយ" ។

បទថា **មមេវ កតមញ្ញន្តុ** (ចូរសម្គាល់កម្មដែលគេធ្វើស្រេចហើយព្រោះអាស្រ័យយើងតែម្នាក់) សេចក្ដីថា ក៏សេចក្ដីត្រិះរិះរមែងកើតឡើងដល់ភិក្ខុពាលឯណាថា "ពួកគ្រហស្ថ និងបព្វជិតសូម្បីទាំងពីរពួក ចូរសម្គាល់នូវកិច្ចដែលខ្លួនធ្វើហើយថា ជាកិច្ចសម្រេចហើយ ព្រោះអាស្រ័យអាត្មាអញឯណោះវិញ" ដោយបំណងយ៉ាងនេះថា "នវកម្មឯណានីមួយ ដែលគេធ្វើហើយក្នុងវិហារ ដោយអំណាចនវកម្ម មានរោងឧបោសថជាដើម នវកម្មទាំងអស់នោះ

ព្រះថេរៈធ្វើហើយដើម្បីពួកយើងទាំងឡាយ" ។

បទថា **មមេវ អតិវសា អស្សុ** (ចូរប្រព្រឹត្តក្នុងអំណាចរបស់យើងប៉ុណ្ណោះ) សេចក្តីថា សេចក្តីត្រិះរិះរមែងកើតឡើង (ដល់ភិក្ខុពាលនោះ) ថា "គ្រហស្ថ និងបព្វជិតសូម្បីទាំងអស់ ចូរប្រព្រឹត្តនៅក្នុងអំណាចរបស់យើងតែម្នាក់ គឺ ពាហនៈ និងគ្រឿងឧបករណ៍ទាំងឡាយជាដើមថា រទេះ គោ កាំបិត-ព្រា ពូថៅ ឬយ៉ាងហោចទៅ កិច្ចត្រឹមតែការកម្តៅបបរឲ្យក្តៅហើយហុត ដែលគ្រហស្ថ និងបព្វជិតគប្បីបានក៏ដោយចុះ ប៉ុន្តែបណ្តាកិច្ចតូច និងកិច្ចធំទាំងឡាយ គឺ បណ្តាករណីយកិច្ចទាំងតូច ទាំងធំបែបនេះ គ្រហស្ថនិងបព្វជិតទាំងឡាយ ចូរប្រព្រឹត្តទៅតាមអំណាចរបស់យើងប៉ុណ្ណោះ ក្នុងកិច្ចអ្វីណាមួយ គឺសូម្បីក្នុងកិច្ចតែមួយ" ។ អធិប្បាយថា ចូរសួរយើងប៉ុណ្ណោះ ទើបធ្វើ ។

បទថា **ឥតិ ពាលស្ស** (ដល់ភិក្ខុពាល) សេចក្តីថា សេចក្តីប្រាថ្នានោះ និងសេចក្តីត្រិះរិះបែបនេះ រមែងកើតឡើងដល់ភិក្ខុពាលឯណា វិបស្សនា មគ្គ និងផល រមែងមិនចម្រើនដល់ភិក្ខុពាលនោះដោយពិត តែអគតិធម៌ មានតណ្ហាដែលអាស្រ័យឆន្ទៈជាដើម ដែលកើតតាមទ្វារ ៦ និងមានៈ ៩ យ៉ាង រមែងចម្រើនឡើងដល់ភិក្ខុពាលនោះដោយពិត ដូចទឹក រមែងចម្រើនដល់សមុទ្រ ក្នុងកាលព្រះច័ន្ទខាងខ្នើត ដូច្នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

## ព្រះសុធម្មត្ថេរ សម្រេចព្រះអរហត្ត

ព្រះសុធម្មត្ថេរ ស្ដាប់ព្រះឱវាទនេះហើយ ថ្វាយបង្គំព្រះសាស្ដា ក្រោកចាកអាសនៈ ប្រទក្សិណព្រះសម្មាសម្ពុទ្ធ ៣ ជុំ ហើយក៏និមន្តទៅជាមួយភិក្ខុដែលជាអនុទូតនោះ សម្ដែងអាបត្តិក្នុងគន្លងចក្ខុរបស់ឧបាសក ញ៉ាំងឧបាសកឲ្យអត់ទោសឲ្យ ។ ចិត្តគហបតីបានអត់ទោសឲ្យព្រះសុធម្មត្ថេរដោយពាក្យថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាអត់ទោសឲ្យលោកម្ចាស់ ប្រសិនបើទោសរបស់ខ្ញុំមាន សូមលោកម្ចាស់អត់ទោសឲ្យខ្ញុំព្រះករុណាផង" ក៏ព្រះសុធម្មត្ថេរក្រោយអំពីបានចិត្តគហបតីអត់ទោសឲ្យមក តាំងនៅក្នុងព្រះឱវាទដែលព្រះសាស្ដាប្រទានហើយ អស់កាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទា ។

## ចិត្តគហបតីនៅគាល់ព្រះសាស្ដា

ចំណែកឧបាសកគិតថា "កាលយើងបានសម្រេចសោតាបត្តិផល មិនទាន់បានចូលទៅគាល់ព្រះសាស្ដា សូម្បីបានសម្រេចអនាគាមិផលហើយ ក៏នៅតែមិនទាន់បានចូលទៅគាល់ព្រះសាស្ដាទៀត យើងគួរតែចូលទៅគាល់ព្រះសាស្ដា" ។ គហបតីនោះ ប្រើបម្រើឲ្យត្រៀមរទេះ ៥០០ ដែលពេញដោយវត្ថុទាំងឡាយ មានល្ង អង្ករ ទឹកដោះថ្លា ស្ករអំពៅ និងសំពត់ស្លៀកដណ្ដប់ជាដើម ហើយឲ្យប្រាប់ពួកភិក្ខុថា "លោកម្ចាស់ដ៏ចម្រើនទាំងឡាយណា ប្រាថ្នានឹងទៅគាល់ព្រះសាស្ដា សូមលោកម្ចាស់ទាំងឡាយនិមន្ត នឹងមិនលំបាកដោយ

បិណ្ឌបាតជាដើម” ដូច្នេះ ហើយក៏ឲ្យប្រាប់សូម្បីពួកភិក្ខុនី ទាំងពួកឧបាសក ទាំងពួកឧបាសិកា ។ ភិក្ខុប្រមាណ ៥០០ រូប ភិក្ខុនីប្រមាណ ៥០០ រូប ឧបាសកប្រមាណ ៥០០ រូប ឧបាសិកាប្រមាណ ៥០០ រូប ចេញទៅជាមួយនឹងគហបតីនោះ ។ គហបតីត្រៀមវត្ថុគ្រប់យ៉ាង សូម្បីតែអង្ករសម្រាប់ដាំបបរ និងកត្តក៏មិនខ្វះ ក្នុងចម្ងាយផ្លូវប្រមាណ ៣០ យោជន៍ ដើម្បីជន ៣ ពាន់នាក់ គឺ ដើម្បីពួកភិក្ខុជាដើម និងដើម្បីបរិស័ទរបស់ខ្លួន ។ ចំណែកពួកទេវតាដឹងថា ពួកឧបាសកនោះចេញទៅហើយ ក៏ចាត់ចែងធ្វើនូវទីស្នាក់ក្នុងមួយយោជន៍មួយ បម្រើមហាជនទាំងនោះដោយអាហារវត្ថុ មានបបរ របស់គួរទំពា កត្តនិងទឹកផឹកជាដើមដែលជាទិព្វ ។ ការខ្វះខាតវត្ថុណាៗ មិនបានមានដល់នរណាៗឡើយ ។ មហាជនដែលទេវតាបម្រើហើយយ៉ាងនោះ ធ្វើដំណើរមួយថ្ងៃបានមួយយោជន៍ មួយខែទើបដល់ក្រុងសាវត្ថី ។ រទេះទាំង ៥០០ នៅពេញដូចដើម ។ គហបតីបានលះបង់បណ្ណាការដែលពួកទេវតា និងមនុស្សទាំងឡាយនាំមក ហើយទៅ ។

## ការកើតមានបាដិហារ្យ

ព្រះសាស្តាត្រាស់ទៅកាន់អានន្ទថា ម្នាលអានន្ទ ក្នុងវេលារសៀលនេះ ចិត្តគហបតី ដែលមានឧបាសក ៥០០ ហែហមនឹងមកថ្វាយបង្គំតថាគត ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន ក៏ក្នុងកាលដែលចិត្តគហបតីនោះថ្វាយបង្គំព្រះអង្គ បាដិហារ្យណាៗ នឹងមានឬ ?

ព្រះសាស្តា. ម្នាលអានន្ទ នឹងមាន ។

ព្រះអានន្ទ. បពិត្រព្រះអង្គដ៏ចម្រើន បាដិហារ្យអ្វី ?

ព្រះសាស្តា. ក្នុងកាលដែលចិត្តគហបតីនោះមក ថ្វាយបង្គំតថាគត ភ្លៀងផ្កាឈើដែលជាទិព្វមានពណ៌ ៥ ប្រការ នឹងធ្លាក់ចុះមកប្រមាណត្រឹមជង្គង់ ក្នុងប្រទេសប្រមាណ ៨ ករីសៈ ដោយវេទ្វាស់នៃព្រះរាជា ។ អ្នកក្រុងស្តាប់ដំណឹងនោះហើយ គិតថា "បានឮថា ចិត្តគហបតី ជាអ្នកមានបុណ្យច្រើន នឹងមកថ្វាយបង្គំព្រះសាស្តាក្នុងថ្ងៃនេះ បានឮថា បាដិហារ្យបែបនេះនឹងមាន សូម្បីពួកយើងក៏នឹងបានឃើញអ្នកមានបុណ្យធំបែបនោះ" ដូច្នេះ ហើយបាន កាន់យកគ្រឿងបណ្ណាការទៅឈរនៅសងខាងផ្លូវ ។ ក្នុងកាលដែលចិត្តគហ-បតីមកជិតដល់វិហារ ភិក្ខុ ៥០០ រូបមកដល់មុន ។ ចិត្តគហបតីពោលទៅកាន់ឧបាសិកាថា "ម្នាលឧបាសិកាទាំងឡាយ ពួកនាងចូរមកខាងក្រោយ ចំណែកខ្លួនដែលឧបាសក ៥០០ ហែហម បានទៅកាន់សំណាក់របស់ព្រះសាស្តា ។ ក៏ជនទាំងឡាយដែលឈរក្តី អង្គុយក្តី ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះពុទ្ធ មិនមានក្នុងខាងនេះ ឬក្នុងខាងនោះ ។ រមែងឈរណែនណាន់តាន់តាប់ក្នុងសងខាងនៃពុទ្ធវិថី ។ ឯចិត្តគហបតីក៏ឈានចុះកាន់ពុទ្ធវិថីដ៏ធំហើយ ។ ទីដែលព្រះអរិយសាវកអ្នកសម្រេចផល ៣ ក្រឡេកមើលហើយៗ ក៏រមែងកម្រើកញាប់ញ័រ ។ មហាជនសម្លឹងមើលហើយដោយគិតថា "ម្នាក់នោះឬ គឺជាចិត្ត-គហបតី" ។ គហបតីនោះចូលទៅគាល់ព្រះសាស្តា ចូលទៅខាងក្នុងរង្វើរបស់

ព្រះពុទ្ធដែលមានពណ៌ ៦ ប្រការ ចាប់ព្រះបាទព្រះសាស្តា ត្រង់.កព្រះបាទទាំងពីរ ហើយថ្វាយបង្គំ ។ ក្នុងខណៈនោះឯង ភ្លៀងផ្កាឈើមានប្រការដូចពោលហើយ ក៏ធ្លាក់ចុះមក ។ សំឡេងសាធុការ ១.០០០ បានប្រព្រឹត្តទៅ ។

ចិត្តគហបតីថ្វាយទាន

ចិត្តគហបតីនៅក្នុងសម្នាក់ព្រះសាស្តាអស់មួយខែ បាននិមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យគង់ក្នុងវិហារ ហើយថ្វាយមហាទាន ។ ធ្វើភិក្ខុអ្នកមកជាមួយនឹងខ្លួន ទុកខាងក្នុងវិហារនោះឯង ហើយផ្គត់ផ្គង់ភិក្ខុទាំងនោះ ។ មិនបានកាន់យកនូវវត្ថុអ្វីៗ ក្នុងរទេះរបស់ខ្លួនសូម្បីតែមួយថ្ងៃ ។ បានធ្វើកិច្ចគ្រប់យ៉ាង ដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយនាំមកប៉ុណ្ណោះ ។ ចិត្តគហបតី ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមកដោយសេចក្តីប្រាថ្នាថា នឹងថ្វាយមហាទានចំពោះព្រះអង្គ បានសម្រាកនៅតាមផ្លូវអស់ ១ ខែ នៅក្នុងទីនេះអស់ ១ ខែទៀត ខ្ញុំព្រះអង្គមិនទាន់បានកាន់យកវត្ថុអ្វីៗ ដែលខ្ញុំព្រះអង្គនាំមកនៅឡើយ បានថ្វាយទានអស់កាលប្រមាណប៉ុណ្ណោះ ដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយនាំមកប៉ុណ្ណោះ សូម្បីខ្ញុំព្រះអង្គនៅក្នុងទីនេះអស់ ១ ឆ្នាំ ក៏នឹងមិនបានប្រគេនទេយ្យធម៌របស់ខ្ញុំព្រះអង្គដោយពិត ខ្ញុំព្រះអង្គប្រាថ្នានឹងដោះនូវរទេះទាំងឡាយហើយទៅ សូមព្រះអង្គមេត្តាត្រាស់ប្រាប់ទីសម្រាប់ទុកដាក់នូវវត្ថុទាំងអស់នេះដល់ខ្ញុំព្រះអង្គផងចុះ" ។ ព្រះសាស្តា ត្រាស់ទៅកាន់ព្រះអានន្ទថា

“ម្នាលអានន្ទ អ្នកចូរញុំាងភិក្ខុទាំងឡាយឲ្យចាត់ចែងទីកន្លែងមួយទំនេរ ដើម្បីឧបាសក ។ ព្រះថេរៈក៏បានធ្វើតាមព្រះពុទ្ធដីកា ។ បានឮថា ព្រះសាស្តាទ្រង់អនុញ្ញាតកប្បិយភូមិដល់ចិត្តគហបតីហើយ ។

ចិត្តគហបតីធ្វើដំណើរត្រឡប់នៅវិញ

ចំណែកឧបាសក និងជន ៣ ពាន់រូប ដែលមកជាមួយខ្លួន ធ្វើដំណើរត្រឡប់ទៅវិញដោយរទេះទទេ ។ ពួកទេវតា និងមនុស្សក្រោកឡើងហើយពោលថា “លោកម្ចាស់របស់ពួកយើង លោកធ្វើកម្ម គឺ ការធ្វើដំណើរទៅដោយរទេះទទេ” ដូច្នេះ ក៏ញុំាងរទេះឲ្យពេញដោយរតនៈ ៧ ប្រការ ។ គហបតីនោះ បានផ្គត់ផ្គង់មហាជនដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សទាំងឡាយនាំមកដើម្បីខ្លួន ។

ព្រះអានន្ទត្ថេរថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ចិត្តគហបតី សូម្បីកាលមកកាន់សំណាក់របស់ព្រះអង្គ ក៏មកហើយអស់រយៈពេលមួយខែទើបដល់ នៅក្នុងទីនេះអស់មួយខែដូចគ្នាដែរ បានថ្វាយមហាទាន ដោយគ្រឿងបណ្ណាការដែលទេវតា និងមនុស្សនាំមកប៉ុណ្ណោះអស់កាលប្រមាណប៉ុណ្ណោះ បានឮថា ឥឡូវនេះ ចិត្តគហបតីនោះធ្វើរទេះ ៥០០ ឲ្យទទេ ត្រឡប់ទៅវិញអស់រយៈពេលមួយខែដែរ ក៏ទេវតា និងមនុស្សទាំងឡាយក្រោកឡើងហើយ ពោលដល់គហបតីនោះថា “លោកម្ចាស់របស់ពួកយើងធ្វើដំណើរតាមផ្លូវដោយរទេះទទេ ដូច្នេះ ក៏ញុំាងរទេះឲ្យពេញដោយរតនៈ ៧ ប្រការ

បានពុទ្ធថា ចិត្តគហបតីផ្គត់ផ្គង់មហាជនដោយបណ្ណាការដែលទេវតា និងមនុស្ស ទាំងឡាយនាំមកដើម្បីខ្លួននោះឯង បពិត្រព្រះអង្គដ៏ចម្រើន ក៏គ្រឿងសក្ការៈនេះ កើតឡើងដល់គហបតីអ្នកមកកាន់សម្នាក់របស់ព្រះអង្គតែប៉ុណ្ណោះឬ ឬសូម្បី ទៅកាន់ទីដទៃក៏កើតឡើងដែរ" ។

ព្រះសាស្តាត្រាស់ថា "ម្នាលអានន្ទ ចិត្តគហបតីនោះ មកកាន់សម្នាក់ របស់តថាគតក្តី ទៅកាន់ទីដទៃក្តី សក្ការៈរមែងកើតឡើងទាំងអស់ ព្រោះ ឧបាសកនេះជាអ្នកមានសទ្ធា មានសេចក្តីជ្រះថ្លា មានសីលបរិបូណ៌ ឧបាសក បែបនេះ ទោះបី (ទៅ) ប្រទេសណាៗ ក៏ដោយ លាភសក្ការៈរមែងកើតឡើង ដល់ឧបាសកនោះ ក្នុងប្រទេសនោះៗ ជានិច្ច ដូច្នេះ ទើបត្រាស់ព្រះគាថាក្នុង បកិណ្ណកវគ្គដូច្នេះថា ៖

សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ
យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្កប់ស្កល់
ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ
គេតែងបូជា ក្នុងប្រទេសនោះៗ ។

ក៏សេចក្តីនៃព្រះគាថានេះ នឹងជាក់ច្បាស់នៅក្នុងបកិណ្ណកវគ្គនោះឯង ។

បុព្វកម្មរបស់ចិត្តគហបតី

កាលព្រះសាស្តា ត្រាស់យ៉ាងនោះហើយ ព្រះអានន្ទត្ថេរ ក៏ក្រាបទូល

សួរដល់បុព្វកម្មរបស់ចិត្តគហបតី ។ លំដាប់នោះ ព្រះសាស្តាកាលទ្រង់ត្រាស់ ដល់ព្រះអានន្ទត្ថេរនោះ ទើបត្រាស់ថា ៖

“ម្នាលអានន្ទ ចិត្តគហបតីនេះ មានអភិនីហារដែលធ្វើទុកហើយទៀប បាទមូលនៃព្រះមានព្រះភាគ ទ្រង់ព្រះនាមថា **បទុមុត្តរៈ** អន្ទោលទៅមកក្នុង ទេវតា និងមនុស្សអស់សែនកប្ប ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា **កស្សបៈ** កើតក្នុងត្រកូលព្រានម្រឹគ ចម្រើនវ័យហើយ ថ្ងៃមួយ កាលភ្លៀងធ្លាក់ បាន យកលំពែងទៅកាន់ព្រៃដើម្បីនឹងសម្លាប់ពួកម្រឹគ កាលគយគន់រកមើលម្រឹគ ឃើញភិក្ខុមួយរូបគង់ទទួរសិរសាក្នុងញកដែលកើតឯងមួយ ក៏គិតថា “លោក ម្ចាស់រូបនេះ ប្រហែលគង់ធ្វើសមណធម៌ហើយមើលទៅ យើងនឹងនាំអាហារ មកដើម្បីលោកម្ចាស់រូបនេះ” ដូច្នេះហើយ ប្រញាប់ទៅកាន់ផ្ទះ ឲ្យគេអាំងសាច់ ដែលខ្លួននាំមកអំពីថ្ងៃមុនលើចង្ក្រានមួយ ឲ្យគេដាំបាយដោយចង្ក្រានមួយ ឃើញ ភិក្ខុពួកដទៃត្រាច់បិណ្ឌបាត ក៏ទទួលបាត្ររបស់ភិក្ខុទាំងនោះ និមន្តឲ្យគង់លើ អាសនៈដែលចាត់ចែងទុក ត្រៀមភិក្ខាហើយ ប្រាប់អ្នកដទៃថា “ពួកលោកចូរ អង្គាសលោកម្ចាស់ទាំងឡាយ” ហើយដាក់កត្តនោះទៅក្នុងថង់កាន់ដើរទៅ បេះ ផ្កាឈើផ្សេងៗ តាមផ្លូវ វេចដោយស្លឹកឈើ ធ្វើដំណើរទៅកាន់ទីកន្លែងដែល ព្រះថេរៈគង់ ហើយពោលថា “បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ មេត្តាអនុគ្រោះដល់ខ្ញុំព្រះករុណាចុះ” ដូច្នេះ ហើយទទួលបាត្ររបស់ព្រះថេរៈ ញុំាងបាត្រឲ្យពេញដោយកត្ត ហើយដាក់លើព្រះហស្តរបស់ព្រះថេរៈ ធ្វើការ

បូជាដោយផ្កាឈើទាំងនោះ តាំងសេចក្ដីប្រាថ្នាថា "បិណ្ឌបាតដ៏មានឱជាព្រម ទាំងផ្កាឈើនេះ ជាគ្រឿងបូជាញុំាងចិត្តរបស់ខ្ញុំព្រះករុណាឲ្យត្រេកអរ យ៉ាង ណា សូមគ្រឿងបណ្ណាការមួយពាន់ ចូរមកញុំាងចិត្តរបស់ខ្ញុំព្រះករុណាឲ្យបាន ត្រេកអរក្នុងទីដែលខ្ញុំព្រះករុណាកើតហើយៗ ដូច្នោះចុះ ហើយសូមភ្លៀងផ្កា ឈើដែលមានពណ៌ ៥ ប្រការ ចូរធ្លាក់មក ។ ព្រានម្រឹគនោះ បំពេញកុសល រហូតអស់មួយជីវិត ក្រោយពីការអស់ជីវិត ក៏បដិសន្ធិក្នុងទេវលោក ភ្លៀង ផ្កាឈើទិព្វធ្លាក់ចុះមកប្រមាណត្រឹមជង្គង់ក្នុងទីដែលគាត់កើត ។ សូម្បីក្នុងកាល ឥឡូវនេះ ភ្លៀងផ្កាឈើ (ទិព្វ) ក៏ធ្លាក់ចុះមកក្នុងថ្ងៃដែលគាត់កើត និងកាល ដែលគាត់មកកាន់ទីនេះ ការនាំបណ្ណាការមក និងរទេះពេញដោយរតនៈ ៧ ប្រការ ក៏ជាផលនៃកម្មនោះឯង ។

ចប់ រឿងព្រះសុជម្មត្ថេរ

# ១៥. រឿងព្រះវនវាសីតិស្សៈ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះតិស្សត្ថេរ អ្នកមានប្រក្រតីនៅក្នុងព្រៃ ត្រាស់ព្រះធម៌ទេសនានេះថា* ***អញ្ញា ហិ លាភូប-និសា (វត្តបដិបត្តិដែលចូលទៅអាស្រ័យលាភ មួយ៉ាង)*** *ជាដើម ។*

## ព្រះសារីបុត្រអនុគ្រោះព្រាហ្មណ៍ជាស្នួម

*ទេសនាតាំងឡើងហើយនៅក្នុងក្រុងរាជគ្រឹះ ។ បានឮថា សម្លាញ់របស់វង្គន្តព្រាហ្មណ៍ ដែលជាបិតារបស់ព្រះសារីបុត្រឈ្មោះ មហាសេនព្រាហ្មណ៍ អាស្រ័យនៅក្នុងក្រុងរាជគ្រឹះ ។ ថ្ងៃមួយ ព្រះសារីបុត្រនិមន្តបិណ្ឌបាត បានទៅកាន់ទ្វារផ្ទះរបស់មហាសេនព្រាហ្មណ៍នោះ ដើម្បីអនុគ្រោះគាត់ ។ ប៉ុន្តែព្រាហ្មណ៍នោះ ជាអ្នកមានភោគសម្បត្តិវិនាសហើយ ជាអ្នកទីទ័លក្រ ។ គេគិតថា “បុត្ររបស់យើងនិមន្តមកដើម្បីបិណ្ឌបាត ឈរនៅទាទ្វារផ្ទះរបស់យើង តែយើងជាមនុស្សទ័លក្រ ប្រហែលជាបុត្ររបស់យើងមិនដឹងថា យើងជាអ្នកក្រទេដឹង! ទេយ្យធម៌អ្វីៗ របស់យើងក៏មិនមាន” កាលមិនហ៊ានចេញទៅជួបព្រះថេរៈ ក៏ពួនមិនឲ្យព្រះថេរៈឃើញ ។ ថ្ងៃក្រោយមក ព្រះថេរៈក៏បានទៅម្តងទៀត ។ ព្រាហ្មណ៍ក៏បានពួនដូចលើកមុនទៀត ។ ព្រាហ្មណ៍នោះបានគិតថា “បើយើងបានវត្ថុអ្វីៗ យើងនឹងប្រគេន តែមិនបានអ្វីសោះៗ” ។ គ្រាមួយ គាត់បានផ្តិលដែលពេញដោយបាយាស មួយអន្ទើដោយសំពត់ដែលមានសាច់*

គ្រោតគ្រាតមួយផ្ទាំង ក្នុងរោងដែលជាទីពោលលទ្ធិរបស់ព្រាហ្មណ៍ គ្រាន់តែកាន់យកទៅដល់ផ្ទះភ្លាម ក៏នឹកដល់ព្រះថេរៈថា “ការដែលយើងប្រគេនបិណ្ឌ-បាតនេះដល់ព្រះថេរៈ រមែងគួរ” ។

ក្នុងខណៈនោះឯង ព្រះថេរៈក៏ចូលឈាន ចេញអំពីសមាបត្តិហើយ ឃើញព្រាហ្មណ៍នោះ ទើបគិតថា “ព្រាហ្មណ៍បានទេយ្យធម៌ហើយ ប្រាថ្នាឲ្យយើងនិមន្តទៅទីនោះ, កាលដែលយើងទៅកាន់ទីនោះ រមែងគួរ” ដូច្នេះហើយ ក៏ដណ្តប់សំពត់សង្ឃាដិ កាន់បាត្រ សម្តែងខ្លួនឈរទៀបទ្វារផ្ទះរបស់ព្រាហ្មណ៍នោះឯង ។ គ្រាន់តែឃើញព្រះថេរៈ ចិត្តរបស់ព្រាហ្មណ៍ក៏រីករាយជ្រះថ្លាភ្លាមដែរ ។ គ្រានោះ គាត់ចូលទៅរកព្រះថេរៈ ថ្វាយបង្គំហើយ ធ្វើបដិសណ្ឋារៈនិមន្តឲ្យគង់ខាងក្នុងផ្ទះ កាន់យកផ្តិលដែលពេញដោយបាយាស ចាក់ចូលទៅក្នុងបាត្ររបស់ព្រះថេរៈ ។ ព្រះថេរៈទទួលពាក់កណ្តាលហើយ ក៏យកដៃបិទបាត្រ ។ គ្រានោះ ព្រាហ្មណ៍ពោលទៅកាន់ព្រះថេរៈថា “បពិត្រលោកម្ចាស់ បាយាសនេះ ជាចំណែកនៃបុគ្គលតែម្នាក់ប៉ុណ្ណោះឯង សូមលោកម្ចាស់អនុគ្រោះដល់ខ្ញុំព្រះករុណាក្នុងបរលោកចុះ កុំធ្វើសេចក្តីអនុគ្រោះក្នុងលោកនេះឡើយ ខ្ញុំព្រះករុណាប្រាថ្នាប្រគេនមិនឲ្យមានចំណែកសល់” ហើយក៏ចាក់បិណ្ឌបាតនោះទាំងអស់ ។ ព្រះថេរៈបានទទួលបាយាសរបស់ព្រាហ្មណ៍ហើយ ក៏គង់ឆាន់ក្នុងទីនោះឯង ។ លុះវេលាស្រេចភត្តកិច្ច ព្រាហ្មណ៍ក៏បានប្រគេនសំពត់សាដកនោះដល់ព្រះថេរៈ ថ្វាយបង្គំហើយ ពោលយ៉ាងនេះថា “បពិត្រលោក

"ម្ចាស់ដ៏ចម្រើន សូមឲ្យខ្ញុំព្រះករុណាបានសម្រេចធម៌ ដែលលោកម្ចាស់បាន ឃើញហើយផងចុះ" ។ ព្រះថេរៈ ធ្វើអនុមោទនាដល់ព្រាហ្មណ៍នោះថា ម្នាល "ព្រាហ្មណ៍ចូរសម្រេចយ៉ាងនោះចុះ" ក៏ក្រោកចាកអាសនៈ ចៀសចេញទៅកាន់ វត្តជេតពនវិញ ។

## ព្រាហ្មណ៍ផ្លាស់ចាកស្លាប់ទៅកើតក្នុងក្រុងសាវត្ថី

ក៏ទានដែលបុគ្គលឲ្យក្នុងកាលដែលធ្លាក់ខ្លួនក្រ រមែងញុំាងជននោះឲ្យ រីករាយយ៉ាងក្រៃលែង ព្រោះហេតុនោះ ព្រាហ្មណ៍ថ្វាយទាននោះហើយ មាន ចិត្តជ្រះថ្លា កើតសោមនស្សរីករាយ ហើយបានធ្វើសេចក្ដីស្នេហាមានប្រមាណ ដ៏ក្រៃលែងក្នុងព្រះថេរៈ ។ ដោយសេចក្ដីស្នេហាក្នុងព្រះថេរៈនោះឯង ព្រាហ្មណ៍ នោះ ធ្វើកាលកិរិយាហើយ ក៏បដិសន្ធិក្នុងត្រកូលឧបដ្ឋាករបស់ព្រះថេរៈក្នុង ក្រុងសាវត្ថី ។ ក៏ក្នុងខណៈនោះឯង មាតារបស់ទារកនោះប្រាប់ស្វាមីថា សត្វ ដែលអាស្រ័យគភ៌កើតឡើងក្នុងផ្ទៃរបស់ខ្ញុំហើយ ។ ស្វាមីនោះបានឲ្យគ្រឿង រក្សាគភ៌ដល់មាតានោះ ។ កាលនាងវៀរចាកការបរិភោគអាហារ មានរបស់ ក្ដៅខ្លាំង ត្រជាក់ខ្លាំង និងជូរខ្លាំងជាដើម ហើយរក្សាគភ៌បានដោយសេចក្ដីសុខ ការចាញ់គភ៌បែបនេះកើតឡើងថា "ធ្វើដូចម្ដេចហ្ន៎ យើងគប្បីនិមន្តភិក្ខុ ៥០០ រូប មានព្រះសារីបុត្រជាប្រធាន ឲ្យគង់ក្នុងផ្ទះ ប្រគេនបាយាសលាយដោយ ទឹកដោះសុទ្ធ" សូម្បីខ្លួនឯងក៏ស្លៀកដណ្ដប់សំពត់កាសាវៈ កាន់ការជន៍មាស អង្គុយក្នុងទីបំផុតនៃអាសនៈ ហើយបរិភោគបាយាសដែលសល់ពីភិក្ខុប្រមាណ

ប៉ុណ្ណោះ ។ បានឮថា ការចាញ់គភ៌ចង់ស្លៀកសំពត់កាសាវៈរបស់នាងនោះ ជាបុព្វនិមិត្ត នៃការបព្វជ្ជាក្នុងព្រះពុទ្ធសាសនារបស់បុត្រក្នុងផ្ទៃ ។ លំដាប់នោះញាតិរបស់នាងគិតថា "ការចាញ់គភ៌នៃធីតាពួកយើងប្រកបដោយធម៌" ដូច្នេះហើយក៏ប្រគេនបាយាសលាយដោយទឹកដោះសុទ្ធដល់ភិក្ខុ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធាន ។ សូម្បីនាងក៏ស្លៀកសំពត់កាសាវៈមួយផ្ទាំង ដណ្ដប់មួយផ្ទាំង កាន់ភាជន៍មាសអង្គុយក្នុងទីបំផុតនៃអាសនៈ បរិភោគបាយាសដែលសល់អំពីភិក្ខុ ។ លុះនាងបានបរិភោគបាយាស ដែលសល់អំពីភិក្ខុហើយ ការចាញ់គភ៌ ក៏ស្ងប់រម្ងាប់ទៅដែរ ។ ក្នុងមង្គលដែលគេធ្វើហើយក្នុងចន្លោះៗដល់នាងនោះ រហូតដល់សត្វកើតក្នុងគភ៌ប្រសូតក្ដី ក្នុងមង្គលដែលគេធ្វើហើយដល់នាងដែលប្រសូតបុត្រហើយបាន ១០ ខែក្ដី ពួកញាតិក៏បានប្រគេនទូវមធុបាយាសមានទឹកតិចដល់ភិក្ខុប្រមាណ ៥០០ រូប មានព្រះសារីបុត្តត្ថេរជាប្រធានដូចគ្នា ។ បានឮថា នេះជាផលនៃបាយាសដែលទារកប្រគេនហើយក្នុងកាលដែលខ្លួននៅជាព្រាហ្មណ៍ក្នុងជាតិមុន ។ ក៏ក្នុងពិធីមង្គលដែលពួកញាតិធ្វើក្នុងថ្ងៃដែលទារកកើត ពួកញាតិឲ្យទារកនោះងូតទឹកអំពីព្រលឹម ស្អិតស្អាងហើយ ឲ្យដេកលើសំពត់កម្ពលដែលមានតម្លៃមួយសែន លើទីដេកដ៏មានសិរី ។

## ទារកបរិច្ចាគទាន

ទារកដេកនៅលើសំពត់កម្ពលនោះឯង សម្លឹងមើលព្រះថេរៈ ហើយគិត

ថា "ព្រះថេរៈនេះ ជាបុព្វាចារ្យរបស់យើង យើងបានទទួលសម្បត្តិបែបនេះ ព្រោះអាស្រ័យព្រះថេរៈនេះ យើងគួរតែបរិច្ចាគនូវវត្ថុអ្វីមួយដល់ព្រះថេរៈនេះ ដែលញាតិនាំទៅដើម្បីទទួលសិក្ខាបទ" បានយកម្រាមកូនដៃក្តាប់សំពត់កម្ពល នោះយ៉ាងណែន ។ គ្រានោះ ពួកញាតិទាំងឡាយរបស់ទារកនោះគិតថា "សំពត់កម្ពលជាប់ត្រង់ម្រាមដៃ ក៏ប្រារព្ធនឹងនាំចេញ" ។ ទារកនោះក៏ស្រែកយំ ពួកញាតិពោលថា "សូមអ្នកទាំងឡាយ ចូរចៀសចេញទៅចុះ អ្នកទាំងឡាយកុំញ៉ាំងទារកឲ្យយំឡើយ" ហើយក៏នាំទារកនោះទៅ ព្រមទាំងសំពត់កម្ពលនោះឯង ។ ក្នុងវេលាថ្វាយបង្គំព្រះថេរៈ ទារកនោះទាញម្រាមដៃចេញអំពីសំពត់កម្ពល ធ្វើឲ្យសំពត់កម្ពលធ្លាក់ចុះក្នុងទីជិតព្រះបាទរបស់ព្រះថេរៈ ។ លំដាប់នោះ ពួកញាតិមិនបានពោលថា "ក្មេងតូចមិនដឹង បានធ្វើហើយ" តែពោលថា "លោកម្ចាស់ដ៏ចម្រើន សំពត់ដែលបុត្ររបស់ខ្ញុំព្រះករុណាទាំងឡាយប្រគេនហើយ ជារបស់ដែលគេលះបង់ហើយ" ដូច្នេះ ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឲ្យសិក្ខាបទដល់ទាសៈរបស់លោកម្ចាស់ ដែលជាអ្នកធ្វើការបូជាដោយសំពត់កម្ពលមានតម្លៃមួយសែនចុះ" ។

ព្រះថេរៈ. ទារកនេះឈ្មោះអ្វី ?

ពួកញាតិ. លោកម្ចាស់ដ៏ចម្រើន ឈ្មោះដូចលោកម្ចាស់ ។

ព្រះថេរៈ. ទារកនោះនឹងជាអ្នកមានឈ្មោះថា តិស្សៈ ។

បានឮថា ព្រះថេរៈកាលនៅជាគ្រហស្ថ មានឈ្មោះថា ឧបតិស្សមាណព

សូម្បីមាតារបស់ក្មេងនោះក៏គិតថា "យើងមិនគួរទម្លាយអធ្យាស្រ័យរបស់បុត្រយើងទេ" ។ ពួកញាតិ លុះធ្វើមង្គល គឺ ការដាក់ឈ្មោះឲ្យទារកនោះហើយ ក្នុងមង្គល គឺ ការបរិភោគអាហាររបស់ទារកនោះក្តី ក្នុងមង្គល គឺ ការចោះត្រចៀករបស់ទារកនោះក្តី ក្នុងមង្គល គឺ ការស្លៀកសំពត់របស់ទារកនោះក្តី ក្នុងមង្គល គឺ ការធ្វើជុករបស់ទារកនោះក្តី បានប្រគេនមធុបាយាសដែលមានទឹកតិចដល់ភិក្ខុប្រមាណ ៥០០ រូប ដែលមានព្រះសារីបុត្តត្ថេរជាប្រធានគ្រប់ពិធីមង្គល ។ ក្មេងនោះចម្រើនវ័យហើយ ក្នុងកាលដែលខ្លួនមានអាយុ ៧ ខួប ក៏បានពោលទៅកាន់មាតាថា "ម៉ែ ខ្ញុំនឹងបួសក្នុងសំណាក់របស់ព្រះថេរៈ" ។ មាតានោះយល់ព្រមថា "ប្រពៃហើយ កូន កាលមុន មាតាក៏បានធ្វើទុកក្នុងចិត្តថា យើងមិនគួរទម្លាយអធ្យាស្រ័យរបស់កូនយើងទេ កូនចូរបួសចុះ" ដូច្នេះហើយឲ្យគេទៅនិមន្តព្រះថេរៈមក ប្រគេនភិក្ខាដល់ព្រះថេរៈហើយ ពោលថា "លោកម្ចាស់ដ៏ចម្រើន ទាសៈរបស់លោកម្ចាស់ពោលថា នឹងបួស ពួកខ្ញុំព្រះករុណានឹងនាំទាសៈរបស់លោកម្ចាស់ ទៅកាន់វិហារក្នុងវេលាល្ងាច" បញ្ជូនព្រះថេរៈទៅហើយ ក្នុងវេលាល្ងាច នាំបុត្រទៅកាន់វិហារដោយគ្រឿងសក្ការៈជាច្រើន ហើយក៏ប្រគល់ក្មេងនោះប្រគេនព្រះថេរៈ ។

## ការបួសធ្វើបានដោយក្រ

ព្រះថេរៈពោលនឹងក្មេងនោះថា "ម្នាលតិស្សៈ ដែលឈ្មោះថា ការបួសជាអំពើដែលបុគ្គលធ្វើបានដោយក្រ កាលត្រូវការរបស់ក្តៅ រមែងបានរបស់

ត្រជាក់ ត្រូវការរបស់ត្រជាក់ រមែងបានរបស់ក្តៅ ដែលឈ្មោះថា អ្នកបួស រមែងរស់នៅដោយលំបាក ឯអ្នកតាំងនៅហើយក្នុងសេចក្តីសុខ” ។

តិស្សៈ. លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណានឹងអាចធ្វើបានគ្រប់យ៉ាងតាមទំនងដែលលោកម្ចាស់ទូន្មានហើយ ។

ព្រះថេរៈពោលថា ប្រពៃហើយ ហើយក៏ប្រាប់តចបញ្ចកកម្មដ្ឋានដោយអំណាចនៃការធ្វើទុកក្នុងចិត្ត ដោយភាពជារបស់បដិកូលដល់ក្មេងនោះ ហើយបានបំបួសក្មេងនោះ ។ ពិតណាស់ ការដែលភិក្ខុប្រាប់អាការទាំង ៣២ សូម្បីទាំងអស់សមគួរដោយពិត កាលមិនអាចប្រាប់បានទាំងអស់ គប្បីប្រាប់ត្រឹមតែតចបញ្ចកកម្មដ្ឋានក៏បាន ត្បិតថា កម្មដ្ឋាននេះ ព្រះពុទ្ធគ្រប់ៗ ព្រះអង្គទ្រង់មិនលះបង់ឡើយ ។ ភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ដែលសម្រេចព្រះអរហត្ត ព្រោះបានធ្វើទុកក្នុងចិត្តទៅលើអាការទាំងឡាយ មានសក់ជាដើមរកប្រមាណមិនបាន ។ ក៏ភិក្ខុទាំងឡាយ អ្នកមិនឈ្លាស កាលញ៉ាំងកុលបុត្រឲ្យបួស រមែងញ៉ាំងឧបនិស្ស័យនៃព្រះអរហត្តឲ្យវិនាស ព្រោះហេតុនោះ ព្រះថេរៈលុះប្រាប់កម្មដ្ឋានហើយ ទើបបំបួស ឲ្យតាំងនៅក្នុងសីល ១០ ។ មាតាបិតាកាលធ្វើសក្ការៈដល់បុត្រដែលបួសហើយ បានប្រគេនមធុបាយាស មានទឹកតិចប៉ុណ្ណោះដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវិហារនោះឯងអស់ ៧ ថ្ងៃ ។ ចំណែកភិក្ខុទាំងឡាយត្អូញត្អែរថា “យើងទាំងឡាយមិនអាចនឹងឆាន់មធុបាយាសដែលមានទឹកតិចជានិច្ចបានទេ” ។ មាតាបិតារបស់សាមណេរនោះ

បានទៅកាន់ផ្ទះក្នុងវេលាល្ងាចថ្ងៃទី ៧ ។ ក្នុងថ្ងៃទី ៨ សាមណេរក៏ចូលទៅបិណ្ឌបាតជាមួយភិក្ខុទាំងឡាយ ។

## សាមណេរមានលាភច្រើនព្រោះកុសលទានក្នុងកាលមុន

អ្នកក្រុងសាវត្ថីពោលថា "បានឮថា សាមណេរនឹងចូលទៅបិណ្ឌបាតក្នុងថ្ងៃនេះ ពួកយើងនឹងធ្វើសក្ការៈបូជាដល់សាមណេរនោះ" ដូច្នេះហើយ ក៏ធ្វើកន្ទោងដោយសំពត់ប្រមាណ ៥០០ ផ្ទាំង ចាត់ចែងបិណ្ឌបាតប្រមាណ ៥០០ សម្រាប់ បានកាន់យកទៅឈរនៅក្នុងផ្លូវ ហើយប្រគេនសាមណេរ ។ ថ្ងៃស្អែកឡើង បាននាំគ្នាមកប្រគេនបិណ្ឌបាតដល់សាមណេរនៅនាព្រៃជិតវិហារ ។ តែពីរថ្ងៃប៉ុណ្ណោះ សាមណេរបានបិណ្ឌបាត ១.០០០ និងសំពត់សាដក ១.០០០ ដោយអាការយ៉ាងនេះ ។ សាមណេរក៏បានញុំាងបុគ្គលឲ្យប្រគេនបិណ្ឌបាតនោះដល់ភិក្ខុសង្ឃ ។ បានឮថា នោះជាផលនៃសំពត់សាដកសាច់គ្រោតគ្រាតដែលសាមណេរប្រគេនហើយ ក្នុងកាលដែលខ្លួននៅជាព្រាហ្មណ៍ ។ គ្រានោះ ភិក្ខុទាំងឡាយឲ្យឈ្មោះសាមណេរនោះថា "**បិណ្ឌបាតទាយកតិស្សៈ**" (តិស្សៈអ្នកឲ្យនូវបិណ្ឌបាត) ។ ថ្ងៃមួយ ក្នុងរដូវរងា សាមណេរនិមន្តទៅកាន់វិហារ ឃើញភិក្ខុទាំងឡាយអាំងភ្លើងក្នុងទីទាំងឡាយ មានរោងភ្លើងជាដើម ក៏សួរថា "លោកម្ចាស់ដ៏ចម្រើន ហេតុអ្វីទើបលោកម្ចាស់ទាំងឡាយអង្គុយអាំងភ្លើង?"

ពួកភិក្ខុ. ម្នាលសាមណេរ រងាបៀតបៀនពួកយើង ។

សាមណេរ. លោកម្ចាស់ដ៏ចម្រើន ធម្មតាក្នុងរដូវរងា លោកម្ចាស់ទាំង

ឡាយគួរតែជណ្តប់សំពត់កម្ពល ព្រោះសំពត់កម្ពលនោះ ការពាររងាបាន" ។

ពួកភិក្ខុ. ម្នាលសាមណេរ អ្នកមានបុណ្យច្រើន រមែងបានសំពត់កម្ពល ពួកយើងនឹងបានសំពត់កម្ពលអំពីទីណា?

សាមណេរពោលថា "លោកម្ចាស់ដ៏ចម្រើន បើដូច្នោះ លោកម្ចាស់ទាំងឡាយណា ដែលមានសេចក្តីត្រូវការសំពត់កម្ពល សូមមកតាមខ្ញុំករុណាចុះ" ហើយឲ្យប្រាប់ភិក្ខុក្នុងវិហារទាំងអស់ ។ ភិក្ខុទាំងឡាយគិតថា "ពួកយើងនឹងទៅជាមួយសាមណេរហើយ នាំសំពត់កម្ពលមក អាស្រ័យសាមណេរអ្នកមានអាយុ ៧ ឆ្នាំ ក៏នាំគ្នាចេញទៅប្រមាណ ១.០០០ រូប ។ សាមណេរនោះមិនបានសូម្បីញ៉ាំងចិត្តឲ្យកើតឡើងថា "យើងនឹងបានសំពត់កម្ពលអំពីទីណាដើម្បីភិក្ខុប្រមាណប៉ុណ្ណេះ" ក៏នាំពួកភិក្ខុទាំងនោះនិមន្តសំដៅទៅកាន់នគរ ។ ពិតណាស់ ទានដែលបុគ្គលថ្វាយហើយដោយល្អ រមែងមានអានុភាពដូច្នេះ ។ សាមណេរនោះ និមន្តទៅតាមលំដាប់ផ្ទះខាងក្រៅព្រះនគរ បានសំពត់កម្ពលប្រមាណ ៥០០ ផ្ទាំង ហើយក៏ចូលទៅកាន់ព្រះនគរ ។ ពួកមនុស្សនាំសំពត់កម្ពលអំពីទីនេះ ទីនោះ មកប្រគេនសាមណេរ ។ ឯបុរសម្នាក់ធ្វើដំណើរតាមផ្សារ ឃើញអ្នកផ្សារម្នាក់ដែលអង្គុយលាសំពត់កម្ពល ៥០០ ផ្ទាំង ក៏និយាយថា "នែ! អ្នកដ៏ចម្រើន សាមណេរមួយអង្គនិមន្តប្រមូលសំពត់កម្ពល អ្នកចូរលាក់សំពត់កម្ពលរបស់អ្នកឯងចុះ" ។

អ្នកផ្សារ. ក៏សាមណេរនោះ កាន់យកវត្ថុដែលគេឲ្យ ឬក៏វត្ថុដែលគេ

មិនឲ្យ ក៏កាន់យកដែរ ។

បុរស. កាន់យកតែវត្ថុដែលគេឲ្យប៉ុណ្ណោះ ។

អ្នកផ្សារនិយាយថា "បើដូច្នោះ បើយើងប្រាថ្នានឹងឲ្យ យើងឲ្យ បើយើងមិនប្រាថ្នា យើងនឹងមិនឲ្យ អ្នកចូរទៅចុះ" ដូច្នេះ ហើយក៏បញ្ជូនបុរសនោះទៅ ។

## លក្ខណៈមនុស្សកំណាញ់

ពិតហើយ ពួកបុគ្គលកំណាញ់ជាជនអន្ធពាល កាលជនដទៃឲ្យទានយ៉ាងនេះ ក៏កំណាញ់ហើយ ទើបកើតក្នុងនរក ដូចជាកាឡអាមាត្យ ឃើញនូវអសទិសទានហើយ កំណាញ់ដូច្នោះ ។ អ្នកផ្សារគិតថា "បុរសនេះមកតាមធម្មតារបស់ខ្លួន ពោលនឹងយើងថា នែ! អ្នកដ៏ចម្រើន អ្នកចូរលាក់នូវសំពត់កម្ពលរបស់អ្នកទៅ សូម្បីយើងក៏បានពោលថា ប្រសិនបើសាមណេរនោះកាន់យកតែវត្ថុដែលគេឲ្យប៉ុណ្ណោះ បើយើងប្រាថ្នា យើងនឹងឲ្យ បើមិនប្រាថ្នា យើងក៏នឹងមិនឲ្យ ក៏កាលយើងមិនឲ្យរបស់ដែលសាមណេរឃើញហើយ សេចក្តីអៀនខ្មាសរមែងកើតឡើងដល់យើង កាលយើងលាក់របស់ខ្លួនទុក ក៏មិនមានទោស បណ្តាសំពត់កម្ពល ៥០០ ផ្ទាំង សំពត់កម្ពល ២ ផ្ទាំង មានតម្លៃដល់មួយសែន ការលាក់សំពត់ ២ ផ្ទាំងនេះទុក រមែងគួរ" ដូច្នេះ ក៏ចងសំពត់កម្ពល ២ ផ្ទាំងនោះជាប់គ្នា ហើយលាក់ទុកក្នុងចន្លោះនៃសំពត់ទាំងនោះ ។ ឯសាមណេរទៅដល់ទីនោះជាមួយនឹងភិក្ខុ ១.០០០ រូប ។ គ្រាន់តែបានឃើញ

សាមណេរនោះភ្លាម សេចក្តីស្រឡាញ់ដូចជាបុត្រ ក៏កើតឡើងដល់អ្នកផ្សារនោះ ។ សរីរៈទាំងអស់បានពេញប្រៀបហើយដោយសេចក្តីស្រឡាញ់ ។ អ្នកផ្សារនោះគិតថា "សំពត់កម្ពលទាំងឡាយចូរលើកទុកសិនចុះ យើងឃើញសាមណេរនេះហើយ ឲ្យសូម្បីទូវសាច់ គឺ ហទយៈក៏គួរ" ។ អ្នកផ្សារនោះនាំសំពត់កម្ពលទាំងពីរផ្ទាំងនោះចេញមកតម្កល់ទុកទៀបបាទមូលរបស់សាមណេរ ថ្វាយបង្គំហើយ បានពោលថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាគប្បីមានចំណែកនៃធម៌ដែលលោកម្ចាស់ឃើញហើយចុះ" ។ សាមណេរនោះបានធ្វើអនុមោទនាដល់អ្នកផ្សារនោះថា "ចូរសម្រេចតាមសេចក្តីប្រាថ្នារបស់អ្នកចុះ" សាមណេរបានសំពត់កម្ពល ៥០០ ផ្ទាំង ខាងក្នុងព្រះនគរទៀត ។ តែមួយថ្ងៃប៉ុណ្ណោះ សាមណេរបានសំពត់កម្ពល ១.០០០ ហើយបានប្រគេនសំពត់កម្ពលទាំងនោះដល់ភិក្ខុ ១.០០០ រូប ដោយប្រការដូច្នេះ ។ គ្រានោះភិក្ខុទាំងឡាយ ឲ្យនាមសាមណេរនោះថា "**កម្ពលទាយកតិស្សៈ**" ។ សំពត់កម្ពលដែលសាមណេរឲ្យក្នុងថ្ងៃដាក់ឈ្មោះ ដល់ភាពជាសំពត់កម្ពល ១.០០០ ក្នុងកាលដែលខ្លួនមានអាយុ ៧ ឆ្នាំ ដោយប្រការដូច្នេះ ។

## ឲ្យរបស់តិចតែបានផលច្រើន

របស់តិច ដែលបុគ្គលឲ្យក្នុងឋានៈណា រមែងមានផលច្រើន របស់ច្រើនដែលបុគ្គលឲ្យក្នុងឋានៈណា រមែងមានផលច្រើនជាង ឋានៈដទៃនោះវៀរព្រះពុទ្ធសាសនាចេញហើយ រមែងមិនមាន ។ ព្រោះហេតុនោះ ទើបព្រះ

មានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ របស់តិចដែលបុគ្គលឲ្យក្នុងពួកភិក្ខុណា មានផលច្រើន របស់ច្រើនដែលបុគ្គលឲ្យក្នុងពួកភិក្ខុណា មានផលច្រើនជាង ពួកភិក្ខុនេះក៏ដូច្នោះដែរ ។

សុប្បិយសាមណេរមានអាយុ ៧ ឆ្នាំ បានសំពត់កម្ពល ១.០០០ ដោយផលនៃសំពត់កម្ពលមួយផ្ទាំង ដោយប្រការដូច្នេះ ។

កាលសាមណេរនោះនៅក្នុងវត្តជេតពន ពួកក្មេងដែលជាញាតិ មកកាន់សំណាក់និយាយចរចាប្រាស្រ័យរឿយៗ ។ សាមណេរនោះគិតថា "យើងនៅក្នុងទីនេះ កាលក្មេងដែលជាញាតិមកនិយាយចរចាប្រាស្រ័យជាមួយ មិននិយាយចរចាជាមួយ មិនបាន ដោយការយឺតយូរ គឺ ការសន្ទនាជាមួយនឹងក្មេងទាំងនេះ យើងមិនអាចធ្វើនូវទីពឹងឲ្យខ្លួនបាន ធ្វើដូចម្ដេចហ្ន៎ យើងគប្បីរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដា" ហើយក៏ចូលទៅកាន់ព្រៃ ។ តិស្ស-សាមណេរចេញទៅកាន់ព្រៃ ធ្វើសមណធម៌ តិស្សសាមណេរនោះ ចូលទៅគាល់ព្រះសាស្ដាថ្វាយបង្គំហើយ អារាធនាព្រះសាស្ដាឲ្យត្រាស់ប្រាប់កម្មដ្ឋានរហូតដល់ព្រះអរហត្ត ថ្វាយបង្គំព្រះឧបជ្ឈាយហើយ កាន់បាត្រ និងចីវរចេញចាកវិហារ ហើយគិតថា "ប្រសិនបើយើងនឹងនៅក្នុងទីជិតនេះសោត ពួកញាតិនឹងហៅយើងឲ្យទៅវិញ" ក៏បានធ្វើដំណើរទៅអស់ចម្ងាយផ្លូវ ១២០ យោជន៍ ។ គ្រានោះ សាមណេរធ្វើដំណើរទៅតាមទ្វារស្រុកមួយ ឃើញបុរសចាស់ម្នាក់ក៏សួរថា "ឧបាសក វិហារក្នុងព្រៃរបស់ភិក្ខុទាំងឡាយអ្នកនៅក្នុងទីនេះ មាន

ដែរឬទេ" ។

ឧបាសក. លោកម្ចាស់ មាន ។

សាមណេរ. បើដូច្នោះ ឧបាសកចូរប្រាប់ផ្លូវដល់អាត្មាផង ។

ក៏សេចក្ដីស្រឡាញ់ដូចជាកូន ក៏កើតឡើងដល់ឧបាសក ព្រោះតែបានឃើញសាមណេរនោះ ។ លំដាប់នោះ ឧបាសកឈរនៅទីនោះ បានប្រាប់ផ្លូវដល់សាមណេរនោះដោយពាក្យថា "លោកម្ចាស់ និមន្តមកចុះ ខ្ញុំករុណានឹងប្រាប់ផ្លូវដល់លោកម្ចាស់" ហើយបាននាំសាមណេរនោះទៅ ។ សាមណេរកាលទៅជាមួយនឹងឧបាសកចាស់នោះ ឃើញប្រទេស ៥-៦ កន្លែង ដែលប្រដាប់ដោយផ្កា និងផ្លែឈើផ្សេងៗ ក្នុងរវាងផ្លូវ ក៏សួរថា "ម្នាលឧបាសកប្រទេសនេះឈ្មោះអ្វី" ចំណែកឧបាសកនោះប្រាប់ឈ្មោះប្រទេសទាំងនោះដល់សាមណេរនោះ ទៅដល់វិហារដែលនៅក្នុងព្រៃហើយ ពោលថា "លោកម្ចាស់ទីនេះជាទីសប្បាយ សូមលោកម្ចាស់នៅទីនេះចុះ" ហើយសួរឈ្មោះសាមណេរថា "លោកម្ចាស់ឈ្មោះអ្វី" កាលសាមណេរប្រាប់ថា "ឧបាសក អាត្មាឈ្មោះ **វនវាសីតិស្សៈ**" ។ ឧបាសកបានពោលថា "ថ្ងៃស្អែកនេះ សូមលោកម្ចាស់និមន្តទៅបិណ្ឌបាតក្នុងស្រុករបស់ពួកខ្ញុំករុណាចុះ" ហើយត្រឡប់ទៅកាន់ផ្ទះរបស់ខ្លួន ប្រាប់ពួកមនុស្សថា "សាមណេរឈ្មោះវនវាសីតិស្សៈ មកកាន់វិហារហើយ សូមអ្នកទាំងឡាយចាត់ចែងអាហារ មានយាគូ និងភត្តជាដើមដើម្បីសាមណេរនោះ ។ មុនដំបូង សាមណេរមានឈ្មោះថា **តិស្សៈ** លំដាប់

អំពីនោះ មានឈ្មោះ ៣ ទៀត គឺ **បិណ្ឌបាតទាយកតិស្សៈ កម្ពលទាយក-តិស្សៈ វនវាសីតិស្ស** សាមណេរនេះ មានឈ្មោះ ៤ ក្នុងកាលដែលខ្លួនមានអាយុ ៧ ឆ្នាំ ។ ថ្ងៃស្អែកឡើង សាមណេរចូលទៅកាន់ស្រុកនោះពីព្រលឹមដើម្បីបិណ្ឌបាត ។ ពួកមនុស្សប្រគេនកិក្ខា ហើយបានថ្វាយបង្គំសាមណេរ ។ សាមណេរពោលថា "សូមអ្នកទាំងឡាយ ដល់នូវសេចក្តីសុខ ចូររួចផុតចាកទុក្ខចុះ" ។ មនុស្សដែលនាំកិក្ខាមកប្រគេនសាមណេរនោះ គ្មាននរណាម្នាក់ត្រឡប់ទៅផ្ទះឡើយ គឺថា មិនអាចត្រឡប់ទៅផ្ទះវិញបាន បានឈរសម្លឹងមើលសាមណេរទាំងអស់គ្នានោះឯង ។ សូម្បីសាមណេរ ក៏ទទួលយកកត្តត្រឹមតែល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ។ អ្នកស្រុកទាំងអស់ក្រាបចុះទៀបបាទមូលរបស់សាមណេរនោះ ហើយប្រាប់ថា "លោកម្ចាស់ដ៏ចម្រើនកាលលោកម្ចាស់នៅទីនេះអស់មួយត្រៃមាស ពួកខ្ញុំព្រះករុណានឹងទទួលនូវត្រៃសរណៈ តាំងនៅក្នុងសីល ៥ និងរក្សានូវឧបោសថកម្ម ៨ ដង ក្នុង ១ ខែ ។ សូមលោកម្ចាស់ឲ្យប្តេជ្ញាដល់ខ្ញុំព្រះករុណាទាំងឡាយដើម្បីប្រយោជន៍ដល់ការនៅទីនេះចុះ ។ សាមណេរបានកំណត់នូវឧបការៈ ទើបឲ្យប្តេជ្ញាដល់មនុស្សទាំងនោះ និមន្តបិណ្ឌបាតក្នុងស្រុកនោះជាប្រចាំ ។ ក៏ក្នុងខណៈដែលពុទ្ធបរិស័ទមកថ្វាយបង្គំហើយ សាមណេរពោលតែពាក្យពីរបទថា "សូមអ្នកទាំងឡាយបានសេចក្តីសុខ ចូររួចផុតចាកទុក្ខចុះ" ដូច្នេះហើយ ក៏ចៀសចេញទៅ ។ សាមណេរនោះ ញ៉ាំងខែទី ១ និងខែទី ២ ឲ្យកន្លងទៅក្នុងទីនោះ កាល

ខែទី ៣ កន្លងទៅ ក៏បានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទា ។

ឧបជ្ឈាយ៍ទៅសួរសុខទុក្ខសាមណេរ

លុះបវារណាចេញវស្សាហើយ ព្រះឧបជ្ឈាយ៍របស់សាមណេរ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់តិស្សសាមណេរ" ។

ព្រះសាស្តា. ម្នាលសារីបុត្រ អ្នកទៅចុះ ។

ព្រះសារីបុត្តត្ថេរ កាលនាំភិក្ខុប្រមាណ ៥០០ រូប ដែលជាបរិវាររបស់ខ្លួនចៀសចេញទៅ បានពោលទៅកាន់ព្រះមោគ្គល្លានថា "អាវុសោមោគ្គល្លាន ខ្ញុំនឹងទៅកាន់សំណាក់តិស្សសាមណេរ" ព្រះមោគ្គល្លានក៏ពោលថា "អាវុសោ ខ្ញុំទៅដែរ" ដូច្នេះ ហើយក៏ចេញទៅជាមួយនឹងភិក្ខុប្រមាណ ៥០០ រូប ។ ព្រះមហាសាវកទាំងពួង គឺ ព្រះមហាកស្សបត្ថេរ ព្រះអនុរុទ្ធត្ថេរ ព្រះឧបាលិត្ថេរ ព្រះបុណ្ណត្ថេរ នាំភិក្ខុដែលជាបរិវាររបស់ខ្លួនមួយអង្គ ៥០០ រូប ទៅសួរសុខទុក្ខសាមណេរ ។ បរិវាររបស់ព្រះមហាសាវកទាំងអស់បានជាភិក្ខុប្រមាណ ៤ ម៉ឺនអង្គ ។ ឧបាសកទំនុកបម្រុងសាមណេរជាប្រចាំនោះ ឃើញភិក្ខុទាំងនោះ ដែលជាអ្នកធ្វើដំណើរផ្លូវឆ្ងាយប្រមាណ ១២០ យោជន៍ ដល់គោចរគ្រាមហើយ នៅក្បែរទ្វារស្រុកនោះ ក៏ទៅទទួល ហើយថ្វាយបង្គំភិក្ខុទាំងនោះ ។ គ្រានោះ ព្រះសារីបុត្រសួរឧបាសកនោះថា "ម្នាលឧបាសក វិហារដែលតាំងនៅក្នុងព្រៃក្នុងប្រទេសនេះ មានដែរឬ" ។

ឧបាសក. មាន លោកម្ចាស់ ។

ព្រះថេរៈ. មានភិក្ខុនៅទេ ។

ឧបាសក. មាន លោកម្ចាស់ ។

ព្រះថេរៈ. នរណា នៅទីនោះ ។

ឧបាសក. វនវាសីតិស្សសាមណេរ លោកម្ចាស់ ។

ព្រះថេរៈ. បើដូច្នោះ លោកចូរប្រាប់ផ្លូវដល់ពួកអាត្មាចុះ ។

ឧបាសក. បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ជាភិក្ខុពួកណា ។

ព្រះថេរៈ. ពួកអាត្មាភាពមកកាន់សំណាក់របស់សាមណេរ ។

ឧបាសកសម្លឹងមើលភិក្ខុទាំងនោះហើយ ក៏ចាំបានព្រះមហាសាវកទាំងនោះ តាំងអំពីព្រះធម្មសេនាបតីជាដើម ។ ឧបាសកនោះ មានសរីរៈដែលបីតិពាល់ត្រូវហើយមិនមានចន្លោះ បានពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់រង់ចាំបន្តិចសិនចុះ" ហើយក៏ចូលទៅកាន់ស្រុកដោយរហ័ស ឃោសនាថា "ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ព្រះអសីតិមហាសាវកដ៏ចម្រើនទាំងឡាយ មានព្រះសារីបុត្រជាដើម បានមកកាន់សំណាក់របស់សាមណេរជាមួយនឹងបរិវាររបស់ខ្លួនៗ អ្នកទាំងឡាយចូរកាន់យកនូវវត្ថុទាំងឡាយ មានគ្រែ តាំង កម្រាល ប្រទីប និងប្រេងជាដើម ចេញទៅដោយរហ័សចុះ ។ ក្នុងខណៈនោះ ពួកមនុស្សក៏ជញ្ជូនគ្រែជាដើម ដើរតាមស្នាមព្រះបាទព្រះថេរៈទាំងឡាយទៅ ចូលទៅកាន់វិហារព្រមជាមួយនឹងព្រះថេរៈទាំងនោះឯង ។ សាមណេរ

ចាំពួកភិក្ខុបាន ក៏ទៅទទួលបាត្រ និងចីវររបស់ព្រះមហាថេរៈ ២-៣ អង្គ ហើយបានធ្វើវត្ត ។ សាមណេរចាត់ចែងទឹកខ្ទេងដើម្បីប្រគេនដល់ព្រះថេរៈទាំងឡាយ សម្រាប់ទុកដាក់បាត្រ និងចីវរនោះឯង កាលក៏ងងឹតល្មម ។ ព្រះសារីបុត្តត្ថេរពោលទៅកាន់ពួកឧបាសកថា "ម្នាលឧបាសកទាំងឡាយ អ្នកទាំងឡាយទៅផ្ទះវិញចុះ កាពងងឹតកើតឡើងដល់អ្នកទាំងឡាយហើយ ។

ពួកឧបាសក. លោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះជាថ្ងៃស្តាប់ធម៌ ពួកខ្ញុំព្រះករុណាទាំងឡាយមិនទាន់ទៅទេ នៅស្តាប់ធម៌សិន ពីមុនមកពួកខ្ញុំព្រះករុណាទាំងឡាយ មិនដែលបានស្តាប់ព្រះធម៌ឡើយ ។

ព្រះថេរៈ. សាមណេរ បើដូច្នោះ អ្នកចូរជុតប្រទីប ហើយប្រកាសវេលាស្តាប់ធម៌ចុះ ។

សាមណេរនោះ ក៏បានធ្វើហើយ ។

លំដាប់នោះ ព្រះថេរៈពោលទៅកាន់សាមណេរថា "ម្នាលតិស្សៈ ពួកឧបដ្ឋាករបស់អ្នក ពោលថា ពួកយើងប្រាថ្នានឹងស្តាប់ធម៌ អ្នកចូរសម្តែងធម៌ដល់ឧបដ្ឋាកទាំងនោះ" ។ ពួកឧបាសកក្រោកឡើងព្រមគ្នាក្នាម ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់របស់ខ្ញុំព្រះករុណាទាំងឡាយលើកឡើងតែពីរបទនេះ គឺ សូមអ្នកទាំងឡាយចូរបានសេចក្តីសុខ ចូររួចផុតចាកទុក្ខចុះ មិនចេះធម្មកថាយ៉ាងដទៃទេ សូមលោកម្ចាស់ទាំងឡាយ ឲ្យព្រះធម្មកថិករូបដទៃដល់ពួកខ្ញុំព្រះករុណាចុះ" ។ ឯសាមណេរ សូម្បីបានសម្រេច

ព្រះអរហត្តហើយក៏ដោយ ក៏មិនដែលបានសម្ដែងធម្មកថាឲ្យឧបដ្ឋាករបស់ខ្លួនស្ដាប់ឡើយ ។

## ហេតុឱ្យដល់សុខ និងរួចផុតចាកទុក្ខ

ក៏ក្នុងកាលនោះឯង ព្រះឧបជ្ឈាយសួរសាមណេរនោះថា "សាមណេរ មនុស្សទាំងឡាយនឹងមានសេចក្ដីសុខបានយ៉ាងណា (ហើយ) នឹងរួចផុតចាកទុក្ខបានយ៉ាងណា? អ្នកចូរអធិប្បាយសេចក្ដីនៃបទទាំងពីរនោះដល់យើងទាំងឡាយ" ។ សាមណេរទទួលថា "សាធុ លោកម្ចាស់" ហើយកាន់ផ្លិតដ៏វិចិត្រឡើងកាន់ធម្មាសនៈ ទាញហេតុផលមកអំពីនិកាយទាំង ៥ ចែកខន្ធ ធាតុ អាយតនៈ និងពោធិបក្ខិយធម៌ ដូចមហាមេឃតាំងឡើងក្នុងទ្វីបទាំង ៤ ញុំាងភ្លៀងព្រិលឲ្យធ្លាក់ចុះ ពោលធម្មកថាដល់កំពូល គឺ ព្រះអរហត្ត ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន សេចក្ដីសុខរមែងមានដល់បុគ្គលដែលបានសម្រេចព្រះអរហត្ត យ៉ាងនេះ បុគ្គលអ្នកសម្រេចព្រះអរហត្តហើយនោះឯង រមែងរួចផុតចាកទុក្ខ បុគ្គលដ៏សេសមិនរួចផុតចាកជាតិទុក្ខជាដើម និងមិនរួចផុតចាកទុក្ខក្នុងនរកជាដើមបានឡើយ" ។ ព្រះថេរៈពោលថា "សាធុ សាមណេរ សេចក្ដីនៃបទទាំងពីរនោះ អ្នកពោលបានល្អហើយ ឥឡូវនេះ អ្នកចូរពោលសរភញ្ញចុះ" ។ សាមណេរនោះ ក៏បានពោលសរភញ្ញទៀត ។ កាលអរុណរះឡើង ពួកមនុស្សដែលបម្រើសាមណេរនោះ បានបែកជាពីរពួក ។ ពួកខ្លះមានសេចក្ដីក្រោធថា "ក្នុងកាលមុន ពួកយើងមិនធ្លាប់ឃើញបុគ្គលអ្នករឹងរូស

ដូច្នេះសោះ គួរឲ្យធ្ងល់ដែរ ហេតុអ្វីសាមណេរចេះនូវធម្មកថាបែបនេះ ក៏មិនពោលបទនៃធម៌សូម្បីតែមួយ ដល់ពួកបុគ្គលដែលតាំងនៅក្នុងតំណែងដូចជាមាតាបិតា ហើយបម្រើអស់កាលប្រមាណប៉ុណ្ណេះ" ។ មនុស្សពួកខ្លះត្រេកអរ រីករាយថា "ជាលាភរបស់ពួកយើងដោយពិត ពួកយើងជាអ្នកមិនដឹងនូវគុណនិងទោស បានបម្រើលោកម្ចាស់ដ៏ចម្រើនបែបនេះ មិនត្រឹមតែប៉ុណ្ណោះ ពួកយើងបានស្តាប់ធម៌ក្នុងសំណាក់លោកម្ចាស់ដ៏ចម្រើនបែបនោះទៀត" ។ ក្នុងវេលាជិតភ្លឺថ្ងៃនោះ សូម្បីព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ពិចារណាមើលនូវសត្វលោក ទ្រង់ឃើញពួកឧបដ្ឋាករបស់វនវាសីតិស្សសាមណេរ ចូលទៅក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ព្រះអង្គទ្រង់ពិចារណាថា គុណជាតអ្វីនឹងមាន ទ្រង់ឃើញថា "ពួកឧបដ្ឋាករបស់វនវាសីតិស្សសាមណេរ ពួកខ្លះក្រោធនឹងសាមណេរ ពួកខ្លះត្រេកអរ ក៏ពួកដែលក្រោធខឹងនឹងសាមណេរដែលជាបុត្ររបស់តថាគតនឹងទៅកាន់នរក តថាគតគួរតែទៅកាន់ទីនោះ កាលតថាគតទៅកាន់ទីនោះ មនុស្សទាំងអស់នោះ នឹងញ៉ាំងមេត្តាចិត្តឲ្យកើតឡើងក្នុងសាមណេរ ហើយរួចផុតចាកទុក្ខ" ។ មនុស្សទាំងនោះ និមន្តភិក្ខុសង្ឃហើយទៅកាន់ស្រុក ញ៉ាំងគ្នានិងគ្នាឲ្យធ្វើនូវមណ្ឌប ចាត់ចែងអាហារ មានយាគូ និងភត្តជាដើម ក្រាលអាសនៈទុកហើយ អង្គុយរង់ចាំមើលការមករបស់ភិក្ខុសង្ឃ ។ ភិក្ខុទាំងឡាយជម្រះសរីរៈហើយ កាលនឹងចូលទៅកាន់ស្រុកក្នុងវេលាភិក្ខា ក៏សួរសាមណេរថា "អាវុសោតិស្សៈ អ្នកនឹងទៅជាមួយពួកយើង ឬក៏ទៅក្រោយ" ។

សាមណេរ. ខ្ញុំព្រះករុណានឹងទៅក្នុងវេលាដែលខ្ញុំព្រះករុណាធ្លាប់ទៅ សូមលោកម្ចាស់ទាំងឡាយនិមន្តទៅមុនចុះ ។

ពួកមនុស្សជ្រះថ្លានឹងតិស្សសាមណេរ

ភិក្ខុទាំងឡាយក៏កាន់បាត្រ និងចីវរចូលទៅកាន់ស្រុក ។ ព្រះសាស្តាទ្រង់ឃ្លុំចីវរក្នុងវត្តជេតពននោះឯង ហើយទ្រង់ប្រដាប់បាត្រ និងចីវរ ស្តេចយាងទៅកាន់ទីនោះ ដោយចិត្តតែមួយខណៈ ក៏ទ្រង់សម្តែងព្រះអង្គឲ្យឋិតនៅខាងមុខភិក្ខុទាំងឡាយ ។ អ្នកស្រុកទាំងអស់ភ្ញាក់ផ្អើលថា ព្រះសម្មាសម្ពុទ្ធទ្រង់យាងមកហើយ ។ ពួកមនុស្សមានចិត្តត្រេកអររីករាយ និមន្តភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យគង់ហើយ ប្រគេនយាគូ និងបង្អែម ។ វេលាភត្តកាលមិនទាន់សម្រេចនោះឯង សាមណេរក៏បានចូលទៅកាន់ស្រុក ។ អ្នកស្រុកបាននាំភិក្ខាចេញទៅប្រគេនសាមណេរដោយគោរព ។ សាមណេរនោះទទួលភិក្ខាត្រឹមតែល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅប៉ុណ្ណោះ ហើយក៏ទៅកាន់សម្នាក់ព្រះសាស្តា បង្អោនបាត្រចូលទៅ ។ ព្រះសាស្តាត្រាស់ថា "ម្នាលតិស្សៈ អ្នកនាំមកចុះ" ហើយទ្រង់លាព្រះហស្តទទួលបាត្រ ទ្រង់បង្ហាញព្រះថេរៈថា "ម្នាលសារីបុត្រ អ្នកចូរមើលបាត្រសាមណេររបស់អ្នកចុះ" ។ ព្រះថេរៈទទួលបាត្រអំពីព្រះហស្តព្រះសាស្តា ឲ្យសាមណេរ ហើយពោលថា "សាមណេរ អ្នកចូរទៅអង្គុយធ្វើភត្តកិច្ចក្នុងទីដែលគួរដល់ខ្លួនចុះ" ។ អ្នកស្រុកអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយក៏ទូលសូមអនុមោទនាគាថាអំពីព្រះសាស្តា ។

ព្រះសាស្តា កាលទឹងទ្រង់ធ្វើអនុមោទនា ក៏ត្រាស់យ៉ាងនេះថា “ម្នាលឧបាសក និងឧបាសិកាទាំងឡាយ ជាលាភរបស់អ្នកទាំងឡាយហើយ ដែលបានឃើញអសីតិមហាសាវក គឺ សារីបុត្រ មោគ្គល្លាន កស្សបៈជាដើម ព្រោះអាស្រ័យសាមណេរអ្នកចូលដល់ត្រកូលរបស់ខ្លួន សូម្បីតថាគតមកកាន់ទីនេះ ក៏ព្រោះអាស្រ័យសាមណេរដែលចូលដល់ត្រកូលរបស់អ្នកទាំងឡាយដែរ សូម្បីការឃើញព្រះពុទ្ធ ដែលអ្នកទាំងឡាយបានឃើញហើយ ក៏ព្រោះអាស្រ័យសាមណេរនេះឯង នេះជាលាភរបស់អ្នកទាំងឡាយ អត្តភាពជាមនុស្សនេះ អ្នកទាំងឡាយបានដោយល្អហើយ ។ មនុស្សទាំងឡាយគិតថា គួរឲ្យត្រេកអរណាស់ ជាលាភរបស់ពួកយើងមែន ព្រោះពួកយើងបានឃើញលោកម្ចាស់ដ៏ចម្រើនរបស់ពួកយើង ដែលជាអ្នកញុំាងព្រះសម្ពុទ្ធឲ្យជ្រោសប្រណី មិនត្រឹមតែប៉ុណ្ណោះ ថែមទាំងបានប្រគេនទេយ្យធម៌ដល់លោកម្ចាស់ដ៏ចម្រើនទាំងនោះទៀត ។ ពួកមនុស្សដែលក្រោធនឹងសាមណេរ ត្រឡប់បាននូវសេចក្តីត្រេកអរវិញ ។ ពួកមនុស្សដែលត្រេកអរហើយ ក៏ជ្រះថ្លាមានប្រមាណយ៉ាងក្រៃលែង ។ ក៏ក្នុងវេលាចប់អនុមោទនា ជនជាច្រើនក៏បានសំរេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។ ព្រះសាស្តា ស្តេចក្រោកចាកអាសនៈចៀសចេញទៅ ។ មនុស្សទាំងឡាយតាមជូនព្រះសាស្តាស្តេចយាងទៅ ថ្វាយបង្គំហើយក៏ត្រឡប់មកវិញ ។

ព្រះសាស្តា ស្តេចយាងទៅដោយព្រះធុរៈដ៏ស្មើជាមួយនឹងសាមណេរ

ត្រាស់សួរប្រទេសដែលឧបាសកសម្ដែងហើយដល់សាមណេរនោះ ក្នុងកាលមុនថា "ម្នាលសាមណេរ ប្រទេសនេះឈ្មោះអ្វី ប្រទេសនេះឈ្មោះអ្វី" ដូច្នេះហើយ បានទ្រង់យាងទៅ ។ សូម្បីសាមណេរក៏ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ប្រទេសនេះឈ្មោះនេះ" បានទៅហើយ ។

ទឹកភ្នែករបស់មនុស្សច្រើនជាងទឹកក្នុងមហាសមុទ្ទ

ព្រះសាស្ដា ទ្រង់យាងដល់ទីនៅរបស់សាមណេរនោះហើយ ទ្រង់ឡើងកាន់កំពូលភ្នំ ។ ក៏មហាសមុទ្រ រមែងប្រាកដដល់ជនទាំងឡាយដែលឈរនៅលើកំពូលភ្នំនោះ ។ ព្រះសាស្ដាត្រាស់សួរសាមណេរថា "ម្នាលតិស្សៈ អ្នកឈរនៅលើកំពូលភ្នំ ក្រឡេកមើលខាងនោះ និងខាងនេះ ឃើញអ្វីខ្លះ?"

សាមណេរ. បពិត្រព្រះអង្គដ៏ចម្រើន ឃើញមហាសមុទ្ទ ។

ព្រះសាស្ដា. ឃើញមហាសមុទ្ទហើយ គិតដូចម្ដេច ។

សាមណេរ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតយ៉ាងនេះថា កាលយើងយំក្នុងគ្រាដែលយើងដល់នូវសេចក្ដីទុក្ខ ទឹកភ្នែកគប្បីច្រើនជាងទឹកមហាសមុទ្ទទាំង ៤ ។

ព្រះសាស្ដាត្រាស់ថា "ប្រពៃហើយៗ តិស្សៈ សេចក្ដីនុ៎ះពិតយ៉ាងនោះមែនហើយ ព្រោះទឹកភ្នែកដែលហូរចេញ ក្នុងកាលដែលសត្វម្នាក់ៗ ដល់នូវសេចក្ដីទុក្ខ រមែងជារបស់ច្រើនជាងទឹកក្នុងមហាសមុទ្ទទាំង ៤ ដោយពិត" លុះត្រាស់ពាក្យនេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

ទឹកក្នុងមហាសមុទ្ទទាំង ៤ តិចតួច ទឹក គឺ ទឹកភ្នែកនៃនរៈ
ដែលសេចក្ដីទុក្ខពាល់ត្រូវហើយ សោកសៅ មានប្រមាណ
មិនតិច ច្រើនជាងទឹកក្នុងមហាសមុទ្ទទាំង ៤ នោះ ម្នាល
សម្លាញ់ ព្រោះហេតុអ្វី ទើបអ្នកនៅប្រមាទ ។

ស្ថានទីដែលសត្វធ្លាប់ស្លាប់ និងមិនធ្លាប់ស្លាប់

គ្រានោះ ព្រះសាស្ដាត្រាស់សួរសាមណេរនោះទៀតថា ម្នាល តិស្សៈ អ្នកនៅទីណា ។

សាមណេរ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនៅក្នុងញកភ្នំនេះឯង ។

ព្រះសាស្ដា. ក៏កាលអ្នកនៅក្នុងទីនោះ គិតដូចម្ដេចដែរ ។

សាមណេរ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតថា ការកំណត់ទីដាក់ចុះនូវសរីរៈ ដែលយើងមិនធ្លាប់ស្លាប់នៅក្នុងទីនេះ មិនមាន ។

ព្រះសាស្ដា. ត្រូវហើយៗ តិស្សៈ សេចក្ដីនេះ យ៉ាងនោះមែន ព្រោះថា ហេតុដែលជាទីតាំងនៃសត្វទាំងនេះ មិនដេកហើយលើផែនដី មិនមានដូច្នេះ ហើយក៏ត្រាស់ ឧបសាឡ្ហកជាតក ក្នុងទុកនិបាតដូច្នេះថា ៖

ព្រាហ្មណ៍អ្នកមានឈ្មោះថា ឧបសាឡ្ហកៈ ចំនួន ១ ម៉ឺន
៤ ពាន់ ត្រូវភ្លើងឆេះហើយក្នុងប្រទេសនេះ ក្នុងលោក
រកទីដែលសត្វមិនធ្លាប់ស្លាប់ រមែងមិនមាន ក្នុងលោក
សច្ចៈ ១ ធម្មៈ ១ អហិង្សា ការមិនបៀតបៀន ១ សញ្ញមៈ

សេចក្តីសង្រ្គម ១ ទម: ការទូន្មាននូវឥន្រ្ទិយ៍ ១ មាននៅក្នុងទីណា ព្រះអរិយ:ទាំងឡាយរមែងសេពទីនោះ ទីនោះឈ្មោះថា ជាទីដែលសត្វមិនធ្លាប់ស្លាប់ក្នុងលោក ។

កាលសត្វទាំងឡាយ ធ្វើការដាក់ចុះសរីរ:លើផែនដី សត្វទាំងឡាយឈ្មោះថា ស្លាប់ក្នុងប្រទេសដែលមិនធ្លាប់ស្លាប់ រមែងមិនមាន ដោយប្រការដូច្នេះ ។ ឯព្រះថេរ:ទាំងឡាយ ដូចជាព្រះអានន្ទ រមែងបរិនិព្វានក្នុងប្រទេសដែលសត្វមិនធ្លាប់ស្លាប់ ។

ការបរិនិព្វានរបស់ព្រះអានន្ទ

បានស្តាប់មកថា ព្រះអានន្ទត្រួតពិចារណាមើលអាយុសង្ខារ ក្នុងកាលដែលខ្លួនមានអាយុបាន ១២០ ឆ្នាំ ដឹងថា អាយុសង្ខារនោះជាសភាវ:អស់ទៅដោយជុំវិញហើយ ក៏ប្រាប់ពុទ្ធបរិស័ទថា អាត្មានឹងបរិនិព្វានក្នុងថ្ងៃទី ៧ រាប់អំពីថ្ងៃនេះ ។ បណ្តាមនុស្សទាំងឡាយ ដែលនៅនាត្រើយទាំងពីរនៃស្ទឹងរោហិណី ឮដំណឹងនោះហើយ អ្នកដែលនៅនាត្រើយខាងអាយពោលថា "ពួកយើងមានឧបការ:ច្រើនចំពោះព្រះថេរ: ព្រះថេរ:នឹងបរិនិព្វានក្នុងសម្នាក់ពួកយើង" ។ អ្នកដែលនៅត្រើយខាងនាយ ក៏ពោលថា "ពួកយើងមានឧបការ:ច្រើនចំពោះព្រះថេរ: ព្រះថេរ:នឹងបរិនិព្វានក្នុងសម្នាក់ពួកយើង" ។ ព្រះថេរ:ស្តាប់ពាក្យរបស់ជនទាំងនោះហើយ គិតថា "ពួកជនអ្នកនៅនាត្រើយទាំងពីរសុទ្ធតែមានឧបការ:ច្រើនដល់យើងទាំងអស់ យើងមិនអាចពោលថា ជនទាំង

នេះ មិនមានឧបការៈបានទេ បើយើងនឹងបរិនិព្វានត្រើយខាងអាយ អ្នកដែលនៅត្រើយខាងនាយនឹងធ្វើការឈ្លោះទាស់ទែងនឹងពួកអ្នកដែលនៅត្រើយខាងអាយ ដើម្បីនឹងយក (អដ្ឋិ) ធាតុ បើយើងនឹងបរិនិព្វានទៅត្រើយខាងនាយ ពួកជនដែលនៅត្រើយខាងអាយ ក៏នឹងធ្វើយ៉ាងនោះ ការឈ្លោះទាស់ទែង សូម្បីកាលនឹងកើត ក៏កើតឡើងព្រោះអាស្រ័យយើងដោយពិត សូម្បីកាលនឹងស្ងប់ទៅ ក៏នឹងស្ងប់អាស្រ័យយើងដែរ" ដូច្នេះ ហើយពោលថា "ទាំងអ្នកដែលនៅត្រើយខាងអាយ រមែងមានឧបការៈដល់យើង ទាំងអ្នកដែលនៅត្រើយខាងនាយ ក៏មានឧបការៈដល់យើង នរណាៗ ដែលឈ្មោះថាមិនមានឧបការៈដល់យើង រមែងមិនមាន ពួកអ្នកដែលនៅត្រើយខាងអាយ ចូរប្រជុំគ្នានៅត្រើយខាងអាយចុះ ពួកអ្នកដែលនៅត្រើយខាងនាយ ក៏ចូរប្រជុំគ្នានៅត្រើយខាងនាយចុះ" ។ ក្នុងថ្ងៃទី ៧ អំពីថ្ងៃនោះ ព្រះថេរៈគង់ពែនភ្នែនព្ពដ៏អាកាស កំពស់ប្រមាណ ៧ ដើមត្នោត នៅត្រង់កណ្តាលស្ទឹង សម្តែងធម្មកថាដល់មហាជន ហើយអធិដ្ឋានថា "សរីរៈរបស់យើង ចូរបែកត្រង់ពាក់កណ្តាល មួយចំណែកចូរធ្លាក់ចុះមកត្រើយខាងអាយ មួយចំណែក ចូរធ្លាក់ចុះទៅត្រើយខាងនាយ" ហើយគង់តាមប្រក្រតីនោះឯង ចូលសមាបត្តិ មានតេជោធាតុជាអារម្មណ៍ ។ អណ្តាតភ្លើងក៏តាំងឡើង ។ សរីរៈក៏បែកត្រង់ពាក់កណ្តាល មួយចំណែកធ្លាក់ចុះមកត្រើយខាងអាយ មួយចំណែកធ្លាក់ចុះទៅត្រើយខាងនាយ ។ មហាជនបានឃើញអដ្ឋិធាតុរបស់ព្រះថេរៈហើយ ក៏ស្រែកយំ ។ សំឡេងយំ ហាក់ដូច

ជាសំឡេងស្រុតផែនដី សំឡេងយំនោះ គួរឲ្យករុណាក្រៃលែងជាងសំឡេងយំ ក្នុងថ្ងៃដែលព្រះសាស្តារបស់យើងទ្រង់បរិនិព្វានទៅទៀត ។ ពួកមនុស្សយំរៀបរាប់រហូត ៤ ខែ ដើរយំរៀបរាប់ថា "កាលព្រះថេរៈអ្នកកាន់បាត្រ និងចីវររបស់ព្រះសាស្តាទៅមានជ្រះជន្ម បានប្រាកដដល់ពួកយើង ដូចជាព្រះសាស្តាទ្រង់ព្រះជន្មនៅ ឥឡូវនេះ ព្រះសាស្តារបស់ពួកយើងបរិនិព្វានហើយ" ។

ព្រះសាស្តាសន្ទនាជាមួយនឹងតិស្សសាមណេរ

ព្រះសាស្តា ត្រាស់នឹងសាមណេរទៀតថា "ម្នាលតិស្សៈ អ្នកមិនខ្លាចសំឡេងសត្វទាំងឡាយ មានសំឡេងខ្លាដំបងជាដើម ក្នុងដងព្រៃនេះទេឬ" ។

សាមណេរក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនខ្លាចទេ ម្យ៉ាងទៀត សេចក្តីត្រេកអរក្នុងព្រៃ រមែងកើតដល់ខ្ញុំព្រះអង្គ ព្រោះបានស្តាប់សំឡេងសត្វទាំងនោះ" ហើយពោលពណ៌នាដោយគាថាប្រមាណ ៦០ គាថា ។

គ្រានោះ ព្រះសាស្តាត្រាស់ហៅសាមណេរនោះថា "តិស្សៈ" ។

សាមណេរ. បពិត្រព្រះអង្គដ៏ចម្រើន មានការអ្វី ។

ព្រះសាស្តា. ពួកយើងនឹងទៅ អ្នកនឹងទៅ ឬនឹងត្រឡប់ ។

សាមណេរ. បពិត្រព្រះអង្គដ៏ចម្រើន កាលឧបជ្ឈាយរបស់ខ្ញុំព្រះអង្គនាំទៅ ខ្ញុំព្រះអង្គនឹងទៅ កាលឧបជ្ឈាយរបស់ខ្ញុំព្រះអង្គ ឲ្យខ្ញុំព្រះអង្គត្រឡប់ ខ្ញុំព្រះអង្គក៏នឹងត្រឡប់ ។

ព្រះសាស្តា ក៏ស្តេចយាងចេញទៅជាមួយភិក្ខុសង្ឃ ។ ប៉ុន្តែអធ្យាស្រ័យ

របស់សាមណេរ ប្រាថ្នានឹងត្រឡប់តែម្យ៉ាង ។ ព្រះថេរៈជ្រាបអធ្យាស្រ័យរបស់សាមណេរនោះហើយ ក៏ពោលថា "ម្នាលតិស្សៈ ប្រសិនបើអ្នកប្រាថ្នាត្រឡប់ក៏ចូរត្រឡប់ទៅចុះ" ។ សាមណេរថ្វាយបង្គំព្រះសាស្តា និងថ្វាយបង្គំភិក្ខុសង្ឃហើយក៏ត្រឡប់ ។ ព្រះសាស្តា ស្តេចយាងទៅកាន់វត្តជេតពនវិញ ។

## ពួកភិក្ខុសរសើរសាមណេរ

ការសន្ទនារបស់ភិក្ខុទាំងឡាយ កើតឡើងក្នុងធម្មសភាថា "គួរអស្ចារ្យណាស់! តិស្សសាមណេរធ្វើកម្មដែលបុគ្គលធ្វើបានក្រ ចាប់តាំងអំពីបដិសន្ធិមកពួកញាតិរបស់លោក បានប្រគេនមធុបាយាសដែលមានទឹកតិចដល់ពួកភិក្ខុប្រមាណ ៥០០ រូប ក្នុងពិធីមង្គល ៧ ដង ក្នុងកាលបួសហើយ ក៏បានប្រគេនមធុបាយាសដែលមានទឹកតិចដូចគ្នា ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានខាងក្នុងវិហារអស់ ៧ ថ្ងៃ លុះបួសហើយ ក្នុងថ្ងៃទី ៨ ចូលទៅកាន់ស្រុក បានទទួលបិណ្ឌបាត ១.០០០ និងសំពត់សាដក ១.០០០ តែពីរថ្ងៃប៉ុណ្ណោះ ថ្ងៃស្អែកឡើង បានសំពត់កម្ពល ១.០០០ ។ ក្នុងវេលាដែលលោកនៅក្នុងទីនេះលាភ និងសក្ការៈច្រើន ក៏កើតឡើងហើយដោយប្រការដូច្នេះ ឥឡូវនេះ លោកលះបង់លាភ និងសក្ការៈបែបនោះចោល ហើយចូលទៅកាន់ព្រៃ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយអាហារដែលលាយគ្នា សាមណេរធ្វើកម្មដែលបុគ្គលធ្វើបានដោយកម្រហ្ន៎" ។

## វត្តបដិបត្តិ ២ យ៉ាង

ព្រះសាស្តា ស្តេចមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា អំពីរឿងឈ្មោះនេះ ក៏ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា វត្តបដិបត្តិដែលចូលទៅអាស្រ័យលាភនោះផ្សេង វត្តបដិបត្តិដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វានផ្សេង ក៏អបាយភូមិ ៤ មានទ្វារបើកហើយនោះឯង រង់ចាំភិក្ខុអ្នករក្សាវត្តបដិបត្តិដែលចូលទៅអាស្រ័យលាភ ដោយអំណាចនៃការសមាទានធុតង្គ មានការនៅព្រៃជាដើម ដោយសង្ឃឹមថា យើងនឹងបានលាភដោយវត្តបដិបត្តិយ៉ាងនេះ ចំណែកភិក្ខុអ្នកលះបង់លាភ និងសក្ការៈដែលកើតឡើងដោយវត្តបដិបត្តិ ដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វាន ហើយចូលទៅកាន់ព្រៃ ព្យាយាម រមែងកាន់យកនូវព្រះអរហត្តបាន" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទ្រង់ក៏ត្រាស់ព្រះគាថានេះថា ៖

អញ្ញា ហិ លាភូបនិសា អញ្ញា និព្វានគាមិនី
ឯវមេតំ អភិញ្ញាយ ភិក្ខុ ពុទ្ធស្ស សាវកោ
សក្ការំ នាភិនន្ទេយ្យ វិវេកមនុព្រូហយេ ។

បដិបទា អាស្រ័យនូវលាភផ្សេង បដិបទា ជាដំណើរទៅ
កាន់ព្រះនិព្វានផ្សេង ភិក្ខុជាសាវករបស់ព្រះពុទ្ធ ដឹង
ច្បាស់នូវហេតុទាំងនុះយ៉ាងនេះហើយ មិនគួរត្រេកអរចំពោះ

សក្ការៈឡើយ គប្បីញ៉ាំងវិវេកឲ្យចម្រើនដោយលំដាប់ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អញ្ញា ហិ លាភូបនិសា** (វត្តបដិបត្តិដែលចូលទៅអាស្រ័យលាភ ផ្សេង) សេចក្ដីថា ឈ្មោះថា វត្តបដិបត្តិដែលចូលទៅអាស្រ័យលាភនោះ ផ្សេង បដិបទាដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វានផ្សេង ។ ពិតណាស់ ភិក្ខុអ្នកញ៉ាំងលាភឲ្យកើតឡើង គួរធ្វើអកុសលកម្មតិចតួច ដោយអំពើទាំងឡាយ មានការវៀចដោយផ្លូវកាយជាដើម ជាអំពើដែលភិក្ខុគប្បីធ្វើដើម្បីលាភ ។ ព្រោះថា ក្នុងកាលណាភិក្ខុធ្វើអំពើវៀចទាំងឡាយ មានវៀចដោយកាយជាដើម ក្នុងកាលនោះ លាភរមែងកើតឡើង ។ ដូចជា កាលភិក្ខុលូកដៃចុះទៅក្នុងកាជន៍នៃមធុបាយាសដោយត្រង់ មិនធ្វើឲ្យងឡើង ហើយលើកឡើងវិញ ដៃគ្រាន់តែប្រឡាក់មធុបាយាសប៉ុណ្ណោះ ប៉ុន្តែកាលភិក្ខុធ្វើដៃឲ្យងហើយលូកចូលទៅ លើកឡើងវិញ ដៃរមែងគាស់ឡើងនូវដុំមធុបាយាសចេញមកដោយពិត ។ លាភ និងសក្ការៈរមែងកើតឡើងក្នុងកាលធ្វើអំពើវៀចទាំងឡាយ មានវៀចដោយកាយជាដើមយ៉ាងនេះ នេះចាត់ជាវត្តបដិបត្តិដែលចូលទៅអាស្រ័យលាភដែលមិនត្រូវតាមធម៌ ។ ប៉ុន្តែលាភដែលកើតឡើងដោយហេតុបែបនេះ គឺ ការដល់ព្រមដោយឧបធិ[១] ការទ្រទ្រង់នូវចីវរ (ការគ្រង

១ ឧបធិ ជាឈ្មោះរបស់កិលេសក៏មាន របស់រាងកាយក៏មាន ក្នុងទីនេះ ជាឈ្មោះរបស់រាងកាយ ទើបសំដៅដល់ រូបសម្បត្តិ ។

នូវចីវរ) ភាពជាពហូសូត ការមានបរិវារ ការនៅព្រៃ ឈ្មោះថា ប្រកបដោយធម៌ ។ ក៏ភិក្ខុអ្នកបំពេញវត្តបដិបត្តិដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វាន មិនមែនជាមនុស្សខ្វាក់ គប្បីធ្វើដូចជាមនុស្សខ្វាក់ មិនមែនជាមនុស្ស.គ គប្បីធ្វើដូចមនុស្ស.គ មិនមែនជាមនុស្សថ្លង់ គប្បីធ្វើដូចជាមនុស្សថ្លង់ ។

បទថា **ឯវមេតំ (សេចក្តីនោះយ៉ាងនេះឯង)** ជាដើម សេចក្តីថា ភិក្ខុឈ្មោះថាជាសាវក ព្រោះអត្ថថា កើតក្នុងទីបំផុតនៃការស្តាប់ ឬព្រោះអត្ថថាស្តាប់ឱវាទ និងអនុសាសនីរបស់បុគ្គលអ្នកមានឈ្មោះថា ពុទ្ធៈ ព្រោះអត្ថថាត្រាស់ដឹងនូវសង្ខតធម៌ និងអសង្ខធម៌ទាំងអស់ ដឹងច្បាស់នូវវត្តបដិបត្តិដែលជាគ្រឿងញ៉ាំងលាភឲ្យកើតឡើងផង និងវត្តបដិបត្តិដែលញ៉ាំងសត្វឲ្យដល់ព្រះនិព្វានផង យ៉ាងនេះហើយ មិនគួរត្រេកអរចំពោះលាភសក្ការៈ គឺ បច្ច័យ ៤ ដែលមិនប្រកបដោយធម៌ និងមិនគប្បីហាមឃាត់សក្ការៈ ដែលប្រកបដោយធម៌ឡើយ គប្បីញ៉ាំងវិវេក មានកាយវិវេកជាដើម ។ បណ្តាវិវេកទាំងនោះ ភាពជាអ្នកមានកាយតែម្នាក់ឯង ឈ្មោះថា កាយវិវេក , សមាបត្តិ ៨ (រូបឈាន ៤ អរូបឈាន ៤) ឈ្មោះថា ចិត្តវិវេក , ព្រះនិព្វាន ឈ្មោះថា ឧបធិវិវេក (ឧបធិមាន ៤ គឺ ខន្ធូបធិ, កិលេសូបធិ, អភិសង្ខារូបធិ, កាមូបធិ) ។ បណ្តាវិវេកទាំងនោះ កាយវិវេក រមែងបន្ទោបង់ការស្និទ្ធស្នាលដោយពួក , ចិត្តវិវេក រមែងបន្ទោបង់នូវការជាប់ជំពាក់ដោយកិលេស , ឧបធិវិវេក រមែងបន្ទោបង់នូវការជាប់ជំពាក់ក្នុងសង្ខារ កាយវិវេករមែងជាបច្ច័យដល់ចិត្តវិវេក

ចិត្តវិវេករមែងជាបច្ច័យដល់ឧបធិវិវេក សមដូចពាក្យដែលសារីបុត្តត្ថេរពោលទុកថា "កាយវិវេករបស់អ្នកមានកាយស្ងប់ហើយ ត្រេកអរហើយក្នុងការចេញបួស ចិត្តវិវេករបស់អ្នកមានចិត្តបរិសុទ្ធហើយ ដល់នូវភាពផូរផង់ក្រៃលែង និងឧបធិវិវេករបស់បុគ្គលអ្នកមិនមានឧបធិ រមែងដល់ព្រះនិព្វាន" គប្បីចម្រើន គឺ គប្បីកពូន អធិប្បាយថា គប្បីចូលទៅដល់វិវេក ៣ នេះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

ចប់ រឿងព្រះវនវាសីតិស្សត្ថេរ

## ចប់ ពាលវគ្គវណ្ណនា វគ្គទី ៥

ក្នុងវគ្គនេះរួមមាន ១៥ រឿង


១.រឿងបុរសម្នាក់ ២.រឿងសិស្សរបស់ព្រះមហាកស្សបៈ
៣.រឿងអានន្ទសេដ្ឋី ៤.រឿងចោរឧម្ចាយបង្វេច
៥.រឿងព្រះឧទាយី ៦.រឿងភិក្ខុអ្នកក្រុងបាដ្ឋា
៧.រឿងសុប្បពុទ្ធកុដ្ឋិ ៨.រឿងអ្នកស្រែ
៩.រឿងសុមនមាលាការ ១០.រឿងព្រះនាងឧប្បលវណ្ណាថេរី
១១.រឿងជម្ពុកាជីវក ១២.រឿងអហិប្រេត
១៣.រឿងសដ្ឋិកូដប្រេត ១៤.រឿងព្រះសុធម្មត្ថេរៈ
១៥.រឿងព្រះវនវាសីតិស្សត្ថេរៈ

# បណ្ឌិតវគ្គ ទី ៦

## ១. រឿងព្រះរាធត្ថេរ

[១៦] *ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះរាធៈ ត្រាស់ព្រះធម្មទេសនានេះថា* ***និធីនំវ បវត្តារំ*** *(ប្រៀបដូចជាអ្នកប្រាប់កំណប់ទ្រព្យឲ្យ)* ជាដើម ។

រាធព្រាហ្មណ៍ស្គាំងស្គមព្រោះមិនបានបួស

*បានឮថា ព្រះរាធៈនោះ កាលនៅជាគ្រហស្ថ ជាព្រាហ្មណ៍ទីទ័លក្រនៅក្នុងក្រុងសាវត្ថី ។ គេគិតថា "យើងនឹងចិញ្ចឹមជីវិតក្នុងសម្នាក់នៃភិក្ខុទាំងឡាយ" ហើយទៅកាន់វិហារជម្រះស្មៅ បោសបរិវេណ ប្រគេនវត្ថុទាំងឡាយមានទឹកសម្រាប់លុបមុខជាដើមដល់ភិក្ខុទាំងឡាយដែលនៅក្នុងវិហារនោះ ។*

*ភិក្ខុទាំងឡាយ បានសង្គ្រោះគាត់ដោយបាយ ទឹក នំ ចំណី តែមិនឲ្យគាត់បួស ។*

*រាធព្រាហ្មណ៍កាលមិនបានបួស ក៏ទៅជាស្គាំងស្គម ស្លេកស្លាំង ។*

រាធព្រាហ្មណ៍មានឧបនិស្ស័យព្រះអរហត្ត

*ថ្ងៃមួយ ព្រះសាស្តាទ្រង់ប្រមើលមើលនូវសត្វលោក ក្នុងវេលាជិតភ្លឺ ឃើញព្រាហ្មណ៍នោះហើយ ទ្រង់ពិចារណាថា "ហេតុអ្វីនឹងមាន" ដូច្នេះហើយ*

ទ្រង់ជ្រាបថា "រាធព្រាហ្មណ៍នឹងបានជាព្រះអរហន្ត" ។ ក្នុងវេលាល្ងាច ទ្រង់មានអាការហាក់ដូចជាស្តេចត្រាច់ទៅកាន់ទីចារិកក្នុងវិហារ ស្តេចយាងទៅកាន់សម្នាក់របស់រាធព្រាហ្មណ៍ ហើយត្រាស់សួរថា "ព្រាហ្មណ៍ អ្នកធ្វើអ្វី" គេក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្វើនូវវត្តតូច និងវត្តធំចំពោះភិក្ខុទាំងឡាយ ។

ព្រះសាស្តា. អ្នក បានទទួលការសង្គ្រោះអំពីសម្នាក់នៃភិក្ខុទាំងនោះដែរឬ ។

ព្រាហ្មណ៍. បានព្រះអង្គ ខ្ញុំព្រះអង្គបានត្រឹមតែអាហារប៉ុណ្ណោះ ខ្ញុំព្រះអង្គចង់បួស តែភិក្ខុទាំងនេះមិនព្រមឲ្យខ្ញុំព្រះអង្គបួស ។

ព្រះសារីបុត្រជាកតញ្ញូកតវេទី

ព្រោះអាស្រ័យរឿងនោះ ព្រះសាស្តា ក៏ទ្រង់ត្រាស់ឲ្យភិក្ខុសង្ឃប្រជុំគ្នា ហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ មានភិក្ខុរូបណារឭកនូវគុណរបស់ព្រាហ្មណ៍នេះបានដែរឬទេ" ។ ព្រះសារីបុត្តក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គរឭកបាន កាលខ្ញុំព្រះអង្គនិមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ព្រាហ្មណ៍នេះ បានប្រើគេឲ្យប្រគេនបាយមួយវែក ដែលគេនាំមកដើម្បីខ្លួនដល់ខ្ញុំព្រះអង្គ ។ កាលព្រះសាស្តាត្រាស់ថា "សារីបុត្រ ការដែលអ្នកដោះព្រាហ្មណ៍អ្នកមានឧបការៈ ដែលបានធ្វើទុកហើយយ៉ាងនេះ ឲ្យរួចផុតចាកទុក្ខមិនគួរទេឬ" ។ ព្រះសារីបុត្រក្រាបទូលថា "ប្រពៃហើយ ព្រះអង្គ ខ្ញុំព្រះអង្គ

នឹងឲ្យគេបួស" ទើបឲ្យព្រាហ្មណ៍នោះបួសហើយ ។

ព្រាហ្មណ៍បួសហើយជាមនុស្សប្រដៅងាយ

អាសនៈខាងចុងក្នុងរោងភត្ត ជាអាសនៈរបស់លោក ធ្វើឲ្យលោកមានការលំបាកដោយអាហារវត្ថុ មានយាគូ និងភត្តជាដើម ។ ព្រះថេរៈនាំលោកចេញទៅកាន់ទីចារិក ទូន្មាន ប្រៀនប្រដៅលោករឿយៗ ថា "វត្ថុនេះអ្នកមិនគួរធ្វើ វត្ថុនេះអ្នកគួរធ្វើ) ជាដើម ។ លោកបានជាអ្នកប្រដៅងាយ មានប្រក្រតីទទួលយកឱវាទដោយគោរព ព្រោះដូច្នោះ កាលលោកបដិបត្តិតាមឱវាទដែលព្រះថេរៈឲ្យហើយ អស់រយៈកាល ២-៣ ថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចព្រះអរហត្ត ។ ព្រះថេរៈនាំលោកទៅកាន់សម្នាក់ព្រះសាស្ដា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះសាស្ដា ទ្រង់ធ្វើបដិសណ្ឋារៈចំពោះព្រះថេរៈហើយ ត្រាស់សួរថា "ម្នាលសារីបុត្រ អន្តេវាសិករបស់អ្នក ជាអ្នកប្រដៅងាយឬ" ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន យ៉ាងនោះពិតមែន លោកជាអ្នកប្រដៅងាយណាស់ ក្នុងទោសណាៗ ដែលខ្ញុំព្រះអង្គទូន្មានហើយ លោកមិនដែលក្រោធឡើយ ។

ព្រះសាស្ដា. ម្នាលសារីបុត្រ អ្នកកាលបានសទ្ធិវិហារិកបែបនេះ នឹងគប្បីទទួលបានប៉ុន្មាន ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគប្បីទទួលបានសូម្បីច្រើន ។

ថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា "ព្រះសារីបុត្រ ជាកតញ្ញូ-កតវេទីបុគ្គល រឭកដល់ឧបការគុណត្រឹមតែបាយមួយវែក ញុំាងព្រាហ្មណ៍ដែលក្រលំបាកឲ្យបានបួស សូម្បីព្រះរាធៈ ក៏ជាអ្នកអត់ធន់ក្នុងឱវាទ ដែលសមគួរដល់ការឲ្យឱវាទដែរ" ។

ព្រះសាស្តាទ្រង់សម្តែងអលីនចិត្តជាតក

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវកថារបស់ភិក្ខុទាំងនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុនសារីបុត្រក៏ជាកតញ្ញូកតវេទីបុគ្គលដែរ" ដូច្នេះហើយ ដើម្បីនឹងប្រកាសសេចក្តីនោះឲ្យជាក់ច្បាស់ ទើបត្រាស់អលីនចិត្តជាតកទុកក្នុងទុកនិបាតឲ្យពិស្តារថា ៖

សេនាពួកធំ អាស្រ័យអលីនចិត្តរាជកុមារ រីករាយហើយ
បានញុំាងដំរីឲ្យចាប់យកព្រះបាទកោសលទាំងរស់ ដែល
មិនពេញព្រះទ័យដោយរាជសម្បត្តិ ក៏ភិក្ខុអ្នកដល់ព្រម
ដោយនិស្ស័យយ៉ាងនេះ ជាអ្នកមានសេចក្តីព្យាយាមប្រារព្ធ
ហើយ កាលចម្រើននូវកុសលធម៌ ដើម្បីសម្រេចធម៌ជា
ដែនក្សេមចាកយោគៈ គប្បីដល់ធម៌ជាទីអស់ទៅនៃសំយោ-
ជនៈទាំងពួងដោយលំដាប់ ។

បានឮថា ដំរីនោះឯងត្រាច់ទៅតែម្នាក់ឯង ដឹងនូវឧបការៈដែលពួកជាងឈើធ្វើហើយដល់ខ្លួន គឺ ធ្វើជើងឲ្យជារោគហើយ ឲ្យកូនដំរីសសុទ្ធក្នុងគ្រា

នោះ ក៏បានមកជាព្រះសារីបុត្តក្នុងកាលឥឡូវនេះ ។

ភិក្ខុគួរជាអ្នកប្រដៅងាយដូចព្រះរាធៈ

ព្រះសាស្តា លុះទ្រង់ត្រាស់ជាតកប្រារព្ធចំពោះព្រះថេរៈ យ៉ាងនោះហើយ ទ្រង់ប្រារព្ធព្រះរាធៈ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាភិក្ខុគួរតែធ្វើខ្លួនឲ្យគេប្រដៅបានងាយដូចរាធៈ សូម្បីអាចារ្យចង្អុលប្រាប់នូវទោស ហើយទូន្មានប្រៀនប្រដៅមិនគប្បីខឹង មួយវិញទៀត គប្បីឃើញបុគ្គលអ្នកឲ្យឱវាទ ថាដូចជាអ្នកប្រាប់នូវកំណប់ទ្រព្យឲ្យ ដូច្នោះ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីនឹងសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

និធីនំវ  បវត្តារំ  យំ បស្សេ វជ្ជទស្សិនំ
និគ្គយ្ហវាទី  មេធាវី  តាទិសំ បណ្ឌិតំ ភជេ
តាទិសំ ភជមានស្ស  សេយ្យោ ហោតិ ន បាបិយោ ។

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យ ដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ (ព្រោះថា) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្តីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា និធីនំ (រណ្តៅទ្រព្យ) បានដល់ ឆ្នាំងនៃ

កំណាប់ទ្រព្យដែលពេញដោយមាសប្រាក់ជាដើម ដែលគេកប់ទុកក្នុងទីនោះៗ ។

បទថា **បវត្តារំ (អ្នកប្រាប់)** គឺ ដូចអ្នកធ្វើនូវសេចក្តីអនុគ្រោះចំពោះមនុស្សទុគ៌តដែលរស់នៅដោយលំបាក ហើយបបួលថា អ្នកចូរមក យើងនឹងប្រាប់ឧបាយដែលជាគ្រឿងចិញ្ចឹមជីវិតដោយស្រួលដល់ឯង ដូច្នេះ ហើយនាំទៅកាន់ទីតាំងនៃកំណាប់ទ្រព្យ លើកដៃចេញចង្អុលប្រាប់ថា "អ្នកចូរកាន់យកទ្រព្យនេះ ចិញ្ចឹមជីវិតតាមសប្បាយចុះ" ។ វិនិច្ឆ័យក្នុងបទថា **វជ្ជទស្សិនំ (អ្នកបង្ហាញទោស)** ភិក្ខុអ្នកចង្អុលប្រាប់ទោស មាន ២ ពួក គឺ ភិក្ខុអ្នកស្វែងរកទោស ដោយគិតដូច្នេះថា "យើងនឹងផ្ចាញ់ផ្ចាល់ភិក្ខុនោះ" ដោយកម្មដែលមិនគួរ ឬដោយការក្ជាំងក្ជាត់កណ្តាលជំនុំសង្ឃ ១ ពួក, ភិក្ខុអ្នកតាំងនៅដោយភាវៈរបស់ខ្លួន ជាអ្នកឃ្លាំចាំមើលទោសនោះៗ ដើម្បីប្រយោជន៍ឲ្យដឹងនូវហេតុដែលមិនទាន់ដឹង ដើម្បីត្រូវការឲ្យកាន់យកនូវហេតុដែលដឹងហើយ ព្រោះជាអ្នកប្រាថ្នានូវសេចក្តីចម្រើននៃគុណ មានសីលគុណជាដើមដល់បុគ្គលនោះៗ ១ ពួក, ភិក្ខុជំពូកក្រោយនេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នាយកក្នុងបទថា **វជ្ជទស្សិនំ** នេះ ។ មនុស្សទុគ៌តត្រូវអ្នកដទៃគំរាមក្តី វាយក្តី ហើយចង្អុលប្រាប់កំណាប់ទ្រព្យថា អ្នកចូរកាន់យកកំណាប់ទ្រព្យនេះចុះ រមែងមិនញ៉ាំងសេចក្តីក្រោធឲ្យកើតឡើង មានតែសេចក្តីត្រេកអររីករាយប៉ុណ្ណោះ យ៉ាងណា កាលបុគ្គលបែបនោះឃើញមារយាទ មិនសមគួរក្តី ការក្ជាំងក្ជាត់ក្តី ហើយប្រាប់ អ្នកទទួលនូវការប្រាប់នោះ មិនគួរឲ្យសេចក្តីក្រោធ កើតឡើងដល់អ្នកប្រាប់នោះឡើយ

គួរតែជាអ្នកត្រេកអរតែម្យ៉ាងប៉ុណ្ណោះ ដូច្នោះដែរ គប្បីបវារណាថា "លោកដ៏ចម្រើន កម្មដ៏ធំនេះ ដែលអ្នកតាំងនៅក្នុងឋានៈជាអាចារ្យ និងឧបជ្ឈាយ៍របស់ខ្ញុំ ហើយទូន្មានប្រៀនប្រដៅខ្ញុំ ខ្ញុំត្រេកអរខ្លាំងណាស់ តទៅអ្នកគប្បីទូន្មានខ្ញុំទៀត" ដូច្នេះ ។

បទថា **និគ្គយ្ហវាទី (អ្នកពោលហាម)** សេចក្តីថា ក៏អាចារ្យពួកខ្លះឃើញមារយាទដែលមិនសមគួរ ឬការខ្វាំងខ្វាត់របស់ពួកសិស្ស មានសទ្ធិវិហារិកជាដើមហើយ មិននិយាយ ព្រោះខ្លាចថាសិស្សនេះ បម្រើយើងដោយកិច្ចវត្តមានឲ្យទឹកខ្ពុរមាត់ជាដើមដល់យើងដោយគោរព ប្រសិនបើយើងស្តីបន្ទោសលោកៗ នឹងមិនបម្រើយើងតទៅទៀត សេចក្តីវិនាសនឹងមានដល់យើងដោយអាការយ៉ាងនេះ ដូច្នេះហើយ មិនពោលសង្កត់សង្កិនទេ បុគ្គលនោះឈ្មោះថាអ្នករោយនូវទោស ដែលដូចជាសម្រាមក្នុងសាសនានេះ ។ ចំណែកអាចារ្យណា កាលឃើញទោសបែបនោះហើយ គំរាម បណ្តេញ ដាក់ទណ្ឌកម្ម នាំចេញចាកវិហារតាមសមគួរដល់ទោស ឲ្យសិក្សា បុគ្គលបែបនេះ ឈ្មោះថា ជាអ្នកមានប្រក្រតីពោលពាក្យសង្កត់សង្កិន តួយ៉ាងដូចជាព្រះសម្មាសម្ពុទ្ធ ។ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលអានន្ទ តថាគតនឹងសង្កត់សង្កិន ម្នាលអានន្ទ តថាគតនឹងសរសើរបុគ្គលណាដែលមានសារៈ បុគ្គលនោះនឹងតាំងនៅបាន" ។ បទថា **មេធាវី (អ្នកមានបញ្ញា)** គឺ អ្នកប្រកបដោយបញ្ញាដ៏រុងរឿងក្នុងធម៌ ។ បទថា **តាទិសំ (អ្នកនោះ)** ជាដើម សេចក្តីថា បុគ្គល

គប្បីគប់ គឺ គប្បីចូលទៅអង្គុយជិតបណ្ឌិតបែបនោះ ព្រោះកាលអន្តេវាសិកគប់រកអាចារ្យដូច្នោះ គុណវិសេសដ៏ប្រសើររមែងមាន ទោសដ៏លាមករមែងមិនមាន គឺ មានតែសេចក្តីចម្រើនម្យ៉ាងប៉ុណ្ណោះ សេចក្តីសាបសូន្យមិនមានឡើយ ។

ក្នុងទីបំផុតនៃទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។

ចប់ រឿងព្រះរាធត្ថេរ

# ២. រឿងភិក្ខុអស្សជិ និងបុនព្វសុកៈ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធភិក្ខុ អស្សជិ និងបុនព្វសុកៈ ត្រាស់ព្រះធម្មទេសនានេះថា* ***ឱវទេយ្យានុសាសេយ្យ (គប្បីពោល គប្បីទូន្មាន)*** *ជាដើម ក៏ទេសនាតាំងឡើងនៅឯ កិដាគិរី ។*

ភិក្ខុលាមកត្រូវបព្វាជនិយកម្ម

*បានស្តាប់មកថា ភិក្ខុពីររូបនោះ គឺ អស្សជិ និងបុនព្វសុកៈ ជាសទ្ធិ-វិហារិករបស់ព្រះអគ្គសាវកទាំងពីរក៏ពិត តែលោកជាអលជ្ជី ជាភិក្ខុអាក្រក់ ។ ភិក្ខុពីររូបនោះ កាលនៅឯកិដាគិរីជាមួយនឹងភិក្ខុ ៥ រយរូប ដែលជាបរិវាររបស់ខ្លួន (សុទ្ធតែ) ជាភិក្ខុលាមក ឥតអៀនខ្មាស ប្រព្រឹត្តអនាចារច្រើនបែបច្រើនយ៉ាង មានដាំផ្កាខ្លួនឯងខ្លះ ប្រើគេឲ្យដាំខ្លះជាដើម ធ្វើកម្មរបស់ភិក្ខុអ្នកទ្រុស្តត្រកូល ចិញ្ចឹមជីវិតដោយបច្ច័យដែលកើតឡើងអំពីកម្មនោះ បានធ្វើអាវាសនោះ មិនឲ្យជាទីនៅនៃពួកភិក្ខុអ្នកមានសីលជាទីស្រឡាញ់ ។ ព្រះសាស្តាទ្រង់ជ្រាបដំណឹងនោះហើយ ទ្រង់មានព្រះបំណងនឹងធ្វើបព្វាជនីយកម្មដល់ភិក្ខុទាំងនោះ ទើបត្រាស់ហៅអគ្គសាវកទាំងពីរព្រមទាំងបរិវារមក ហើយត្រាស់ថា "ម្នាលសារីបុត្រ និងមោគ្គល្លាន អ្នកទាំងឡាយនាំគ្នាទៅចុះ បណ្តាភិក្ខុទាំងនោះ ភិក្ខុណាមិនស្តាប់ពាក្យទូន្មានរបស់អ្នក អ្នកចូរធ្វើបព្វាជនីយកម្មដល់ភិក្ខុនោះ ចំណែកភិក្ខុណាស្តាប់ពាក្យទូន្មានរបស់អ្នក អ្នកចូរទូន្មានភិក្ខុនោះ*

ចុះ ។ ធម្មតាអ្នកទូន្មានប្រៀនប្រដៅ រមែងមិនជាទីស្រឡាញ់នៃបុគ្គលដែលមិនមែនជាបណ្ឌិតឡើយ ប៉ុន្តែរមែងជាទីស្រឡាញ់ពេញចិត្តរបស់បណ្ឌិតទាំងឡាយ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបបានត្រាស់ព្រះគាថានេះថា ៖

ឱវទេយ្យានុសាសេយ្យ អសព្ភា ច និវារយេ
សតំ ហិ សោ បិយោ ហោតិ អសតំ ហោតិ អប្បិយោ ។
បណ្ឌិតគួរទូន្មានប្រៀនប្រដៅ គួរហាមឃាត់នូវជនទាំងឡាយ
ចាកអំពើអសប្បុរស បណ្ឌិតនោះ រមែងជាទីស្រឡាញ់របស់
សប្បុរសតែម្យ៉ាង មិនជាទីស្រឡាញ់នៃអសប្បុរសឡើយ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ឱវទេយ្យ (គប្បីទូន្មាន) សេចក្ដីថា កាលរឿងកើតឡើងហើយ ទើបទូន្មាន ឈ្មោះថា ឱវាទ កាលរឿងមិនទាន់កើតឡើង សម្ដែងនូវទោសដែលមិនទាន់មកដល់ដោយអំណាចនៃពាក្យ មានពាក្យដូច្នេះជាដើមថា (ទោសនឹងគប្បីមានដល់អ្នក) ឈ្មោះថា អនុសាសនី (ប្រៀនប្រដៅ) ពោលចំពោះមុខ ឈ្មោះថា ឱវាទ (ទូន្មាន) បញ្ជូនទូត ឬសាសន៍ (បណ្ដាំទៅ) ក្នុងទីកំបាំងមុខ ឈ្មោះថា អនុសាសនី ពោលតែមួយលើក ឈ្មោះថា ឱវាទ ពោលរឿយៗ ឈ្មោះថា អនុសាសនី ។ ម្យ៉ាងទៀត កំពុងឲ្យឱវាទនុ៎ះឯង ឈ្មោះថា អនុសាសនី គប្បីទូន្មានប្រៀនប្រដៅយ៉ាងនេះ ដោយប្រការ

ដូច្នេះ ។ បទថា *អសព្ភា (ចេញចាកធម៌របស់អសប្បុរស)* សេចក្ដីថា គប្បីហាមឃាត់ចាកអកុសលធម៌ គប្បីឲ្យតាំងនៅក្នុងកុសលធម៌ ។ បទថា *សតំ (របស់សប្បុរសទាំងឡាយ)* សេចក្ដីថា បុគ្គលបែបនោះ រមែងជាទីស្រឡាញ់នៃសប្បុរសទាំងឡាយ មានព្រះសម្ពុទ្ធជាម្ចាស់ជាដើម តែមិនជាទីស្រឡាញ់នៃពួកបុគ្គលដែលមិនឃើញធម៌ មានបរលោកទៅប្រាសហើយ មានចក្ខុសម្លឹងរកមើលតែអាមិស បួសដើម្បីចិញ្ចឹមជីវិតតែម្យ៉ាងប៉ុណ្ណោះ ពួកអសប្បុរសរមែងចាក់ដោតដោយលំពែង គឺ មាត់យ៉ាងនេះថា "លោកជាអាចារ្យ ឬឧបជ្ឈាយ៍របស់ពួកយើងឬ? លោកមិនមែនជាអាចារ្យ មិនមែនជាឧបជ្ឈាយ៍របស់ពួកយើងទេ ហេតុអ្វីបានជា លោកប្រៀនប្រដៅពួកយើង?" ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចំណែកព្រះសារីបុត្រ និងព្រះមោគ្គល្លាន ទៅកាន់កិដាគិរីជនបទនោះហើយ ក៏ទូន្មានប្រៀនប្រដៅភិក្ខុទាំងនោះ ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុខ្លះក៏ទទួលយកឱវាទ តាំងចិត្តបដិបត្តិដោយគោរព ពួកខ្លះក៏សឹក ពួកខ្លះក៏ត្រូវបណ្ដេញចេញ ដោយប្រការដូច្នេះឯង ។

ចប់ រឿងភិក្ខុអស្សជិ និងបុនព្វសុកៈ

# ៣. រឿងព្រះឆន្នត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះថេរៈឈ្មោះ **ឆន្នៈ** ត្រាស់ព្រះធម្មទេសនានេះថា **ន ភជេ បាបកេ មិត្តេ** (មិនគួរសេពគប់បាបមិត្ត) ជាដើម ។*

ព្រះឆន្នៈជេរព្រះអគ្គសាវក

*បានស្តាប់មកថា ព្រះឆន្នៈនោះ ជេរព្រះអគ្គសាវកទាំងពីរថា កាលយើងតាមអយ្យបុត្ររបស់យើង ស្តេចចេញមហាអភិនេស្រ្កមណ៍ក្នុងវេលានោះ មិនឃើញបុគ្គលដទៃសូម្បីតែមួយរូប ស្រាប់តែឥឡូវនេះ ពួកលោកនេះដើរពោលថា "យើងឈ្មោះសារីបុត្រ យើងឈ្មោះមោគ្គល្លាន ពួកយើងជាអគ្គសាវក" ។ ព្រះសាស្តាទ្រង់ជ្រាបដំណឹងនោះអំពីសម្នាក់នៃភិក្ខុទាំងឡាយហើយ ត្រាស់ឲ្យហៅព្រះឆន្នៈមក ហើយទ្រង់ទូន្មានប្រៀនប្រដៅ ។ លោកនៅស្ងៀមតែក្នុងខណៈនោះប៉ុណ្ណោះ ក្រោយមក ក៏បានជេរព្រះអគ្គសាវកទាំងពីរអង្គដូចមុនទៀត ។ ព្រះសាស្តាត្រាស់ឲ្យហៅព្រះឆន្នៈដែលកំពុងជេរព្រះអគ្គសាវកទាំងពីរមក ហើយប្រៀនប្រដៅយ៉ាងនុ៎ះអស់ ៣ ដង និងជាស់តឿនថា "ឆន្នៈ អគ្គសាវកទាំងពីរអង្គនេះ ជាកល្យាណមិត្រ ជាបុរសដ៏ខ្ពស់បំផុតរបស់អ្នក អ្នកចូរសេពគប់កល្យាណមិត្របែបនេះចុះ" ដូច្នេះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖*

ន ភជេ បាបកេ មិត្តេ ន ភជេ បុរិសាធមេ

ភជេថ មិត្តេ កល្យាណេ ភជេថ បុរិសុត្តមេ ។

បុគ្គល មិនគួរគប់មិត្តអាក្រក់ មិនគួរគប់បុរសថោក

ទាប គួរគប់តែមិត្តដែលល្អ គួរគប់តែបុរសជាន់ខ្ពស់ ។

អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះថា "ជនអ្នកត្រេកអរក្នុងអកុសលកម្ម មានកាយទុច្ចរិតជាដើម ឈ្មោះថា **បាបមិត្រ** បុគ្គលអ្នកដឹកនាំក្នុងហេតុដែលមិនសមគួរ មានការកាត់ទូវទី.តជាដើមក្តី ឬថាមានការស្វែងរកមិនសមគួរ ២១ យ៉ាងក្តី ឈ្មោះថា **បុរសថោកទាប** ។ ម្យ៉ាងទៀត ជនពីរពួកនោះ ឈ្មោះថា បាបមិត្រផង ឈ្មោះថា បុរសថោកទាបផង ។ បុគ្គលមិនគួរគប់រក គឺ មិនគួរចូលទៅអង្គុយជិតបុគ្គលទាំងនោះឡើយ ចំណែកជនផ្ទុយអំពីនេះ ឈ្មោះថា កល្យាណមិត្រផង ឈ្មោះថាសប្បុរសផង ។ បុគ្គលគួរគប់រក គឺ គួរចូលទៅអង្គុយជិតជនទាំងនោះ ។

ក្នុងវេលាចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ព្រះសាស្តាត្រាស់ឱ្យដាក់ព្រហ្មទណ្ឌដល់ឆន្នភិក្ខុ

ចំណែកព្រះឆន្នៈ សូម្បីបានស្តាប់ឱវាទរបស់ព្រះមានព្រះភាគហើយក៏ដោយ ក៏នៅតែជេរពួកភិក្ខុដដែលទៀត ។ សូម្បីពួកភិក្ខុក៏ក្រាបទូលព្រះសាស្តា

ទៀត ។ ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ កាលតថាគតនៅមានជីវិត ពួកអ្នកមិនអាចញ៉ាំងឆន្នៈឲ្យសិក្សាបានទេ តែកាលតថាគតបរិនិព្វាន ទើបអ្នកទាំងឡាយអាច" ដូច្នេះហើយ កាលព្រះអានន្ទទូលសួរក្នុងវេលាជិតបរិនិព្វានថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គគប្បីបដិបត្តិចំពោះព្រះឆន្នៈយ៉ាងណា?" ទើបត្រាស់បង្គាប់ថា "ម្នាលអានន្ទ ពួកអ្នកគប្បីដាក់ព្រហ្មទណ្ឌ ដល់ឆន្នៈចុះ" ។ ព្រះឆន្នៈនោះ កាលព្រះសាស្ដាស្ដេចបរិនិព្វានហើយ បានដឹងថា ព្រះអានន្ទត្រូវដាក់ព្រហ្មទណ្ឌដល់ខ្លួន ក៏កើតទុក្ខ ខូចចិត្ត ដួលសន្លប់ ៣ ដង ហើយអង្វរថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់កុំញ៉ាំងខ្ញុំករុណាឲ្យវិនាសឡើយ" ដូច្នេះហើយ បំពេញវត្តដោយប្រពៃ ក្នុងកាលមិនយូរ ក៏បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ។

ចប់ រឿងព្រះថេរៈឈ្មោះឆន្នៈ

# ៤. រឿងព្រះមហាកប្បិន

*ព្រះសាស្តាកាលប្រថាប់នៅក្នុងព្រះជេតពន ទ្រង់ប្រារព្ធព្រះមហាកប្បិន ត្រាស់ព្រះធម្មទេសនានេះថា* ***ធម្មប្បីតិ សុខំ សេតិ (បុគ្គលអ្នកត្រេកអរក្នុងធម៌... រមែងនៅជាសុខ)*** *ជាដើម ។ ក្នុងរឿងនោះ មានអនុបុព្វីកថាដូចតទៅនេះ ៖*

ព្រះបច្ចេកពុទ្ធសូមហត្ថកម្មធ្វើសេនាសនៈ

*បានឮថា ក្នុងអតីតកាល ព្រះមហាកប្បិនមានអភិនីហារបានធ្វើទុកនៅទៀបបាទមូលនៃព្រះពុទ្ធទ្រង់ព្រះនាម* ***បទុមុត្តរៈ*** *អន្ទោលទៅមកក្នុងសង្សារ បានជាប្រធានជាងតម្បាញ ក្នុងស្រុកមួយ មិនឆ្ងាយអំពីក្រុងពារាណសី ។*

*គ្រានោះ ព្រះបច្ចេកពុទ្ធប្រមាណ ១.០០០ អង្គ គង់នៅក្នុងហិមវន្តប្រទេស ៨ ខែ និងនៅក្នុងជនបទ ៤ ខែ ក្នុងរដូវភ្លៀង ។ សម័យថ្ងៃមួយ ព្រះបច្ចេកពុទ្ធទាំងនោះ សម្រាកនៅក្នុងទីមិនឆ្ងាយអំពីក្រុងពារាណសី បានបញ្ជូនព្រះបច្ចេកពុទ្ធ ២ អង្គ ទៅកាន់សម្នាក់ព្រះរាជាដោយពាក្យថា លោកទាំងឡាយចូរទៅទូលសូមហត្ថកម្ម ដើម្បីធ្វើសេនាសនៈ ។ ក៏ក្នុងកាលនោះ ជាថ្ងៃវប្បមង្គលរបស់ព្រះរាជា ។ ព្រះរាជាទ្រង់ស្តាប់ថា "ព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តមក" ទើបស្តេចចេញទៅសួរដល់ហេតុដែលមក ហើយត្រាស់ថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ថ្ងៃនេះមិនទាន់មានឱកាសទេ (ព្រោះ) ថ្ងៃស្អែក*

នេះ ខ្ញុំព្រះករុណាទាំងឡាយធ្វើវប្បមង្គលពិធី (មង្គលដែលជានិមិត្តនៃការសាបព្រោះ) ខ្ញុំព្រះករុណានឹងធ្វើក្នុងថ្ងៃទី ៣" ទ្រង់មិនបានអារាធនាព្រះបច្ចេកពុទ្ធទាំងឡាយទុកផង ស្ដេចក៏យាងចូលទៅវិញ ។ ព្រះបច្ចេកពុទ្ធទាំងឡាយគិតថា យើងទាំងឡាយនឹងចូលទៅកាន់ស្រុកដទៃទៀត ហើយក៏ចៀសចេញទៅ ។

## ពួកអ្នកស្រុកតម្បាញធ្វើបុណ្យ

ក្នុងគ្រានោះ ភរិយារបស់ប្រធានជាងតម្បាញ ទៅកាន់ក្រុងពារាណសីដោយកិច្ចឯណានីមួយ ឃើញព្រះបច្ចេកពុទ្ធទាំងនោះហើយ ថ្វាយបង្គំសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ទាំងឡាយនិមន្តមកក្នុងវេលាវិកាលព្រោះហេតុអ្វី?" បានដឹងរឿងរ៉ាវនោះទាំងអស់ហើយ ជាស្ត្រីមានសទ្ធា ដល់ព្រមដោយបញ្ញា ក៏បាននិមន្តព្រះបច្ចេកពុទ្ធថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ទាំងឡាយ និមន្តទទួលភិក្ខារបស់ខ្ញុំម្ចាស់ទាំងឡាយ ក្នុងថ្ងៃស្អែកនេះ" ។

ព្រះបច្ចេកពុទ្ធ. ម្នាលប្អូនស្រី ពួកយើងមានគ្នាច្រើន ។

ស្ត្រី. លោកម្ចាស់ដ៏ចម្រើន មានប៉ុន្មានអង្គ?

ព្រះបច្ចេកពុទ្ធ. ម្នាលប្អូនស្រី មានប្រមាណ ១.០០០ អង្គ ។

ស្ត្រីនោះពោលថា "លោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំម្ចាស់ក៏មានប្រមាណមួយពាន់នាក់ដែរ ម្នាក់ៗ នឹងប្រគេនភិក្ខាចំពោះលោកម្ចាស់មួយអង្គៗ សូមលោកម្ចាស់ទាំងឡាយទទួលចុះ ខ្ញុំម្ចាស់នឹងឲ្យគេធ្វើលំនៅសម្រាប់លោកម្ចាស់

ទាំងឡាយ” ។

ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ទទួលនិមន្តដោយតុណ្ហីភាព ។ នាងចូលទៅកាន់ស្រុក ហើយឃោសនាថា “យើងឃើញព្រះបច្ចេកពុទ្ធប្រមាណ ១.០០០ អង្គ ថែមទាំងបាននិមន្តទុកហើយ អ្នកទាំងឡាយចូរចាត់ចែងសេនាសនៈដល់ព្រះបច្ចេកពុទ្ធទាំងឡាយ ចូរចាត់ចែងអាហារទាំងឡាយ មានបបរ និងភត្តជាដើម ដើម្បីលោកម្ចាស់ទាំងឡាយចុះ” ហើយឲ្យគេធ្វើបារាំនៅត្រង់កណ្តាលស្រុក ក្រាលអាសនៈទុក ថ្ងៃស្អែកឡើង ទើបនិមន្តព្រះបច្ចេកពុទ្ធទាំងឡាយឲ្យគង់ ហើយអង្គាសដោយភោជនដ៏ប្រណីត ក្នុងវេលាស្រេចភត្តកិច្ច ទើបនាំស្រ្តីទាំងអស់ក្នុងស្រុកនោះ មកថ្វាយបង្គំព្រះបច្ចេកពុទ្ធទាំងឡាយ ហើយអារាធនានិមន្តព្រះបច្ចេកពុទ្ធឲ្យគង់ចាំវស្សានៅទីនោះរហូតអស់ ៣ ខែ ហើយឃោសនាដល់អ្នកស្រុកទៀតថា “ម៉ែ និងពុកទាំងឡាយ បុរសម្នាក់ៗ អំពីត្រកូលមួយៗ ចូរកាន់យកឧបករណ៍ មានកាំបិតជាដើមចូលទៅកាន់ព្រៃ នាំយកទព្វសម្ភារៈមកសាងលំនៅ ប្រគេនលោកម្ចាស់ទាំងឡាយចុះ” ។

ពួកអ្នកស្រុកតាំងនៅក្នុងឱវាទរបស់នាងហើយ ម្នាក់ៗ បានធ្វើនូវបណ្ណសាលា ប្រក់ដោយស្លឹកឈើ ព្រមទាំងទីសម្រាកពេលថ្ងៃ និងពេលយប់មួយៗ ប្រគេនព្រះបច្ចេកពុទ្ធ ហើយបម្រើព្រះបច្ចេកពុទ្ធ ដែលគង់នៅចាំវស្សាក្នុងបណ្ណសាលារៀងៗ ខ្លួន ដោយតាំងចិត្តថា យើងនឹងបម្រើដោយគោរព យើងនឹងបម្រើដោយគោរព ។ ក្នុងវេលាចេញវស្សា នាងបបួលគេថា “អ្នកទាំង

ឡាយចូរត្រៀមសំពត់ចីវរដើម្បី (ប្រគេន) ព្រះបច្ចេកពុទ្ធទាំងឡាយដែលជាអ្នកនៅចាំវស្សាក្នុងកុដិរបស់ខ្លួនៗ ចុះ ហើយឲ្យគេប្រគេនចីវរមានតម្លៃ ១.០០០ ចំពោះព្រះបច្ចេកពុទ្ធមួយអង្គៗ ។ ព្រះបច្ចេកពុទ្ធទាំងឡាយចេញវស្សាហើយ ធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។

## អានិសង្សទាន នាំឱ្យកើតក្នុងឋានតាវត្តិង្ស

ពួកអ្នកស្រុកជាងតម្បាញនោះ លុះធ្វើបុណ្យនោះហើយ ចុតិចាកអត្ត-ភាពនោះ ក៏កើតក្នុងឋានតាវត្តិង្ស មានទាមថា **គណទេវបុត្រ** ។ ទេវបុត្រទាំងនោះ សោយទិព្វសម្បត្តិក្នុងឋានតាវត្តិង្សនោះអស់មួយចន្លោះព្រះពុទ្ធ ក្នុងកាលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមថា **កស្សប:** បានមកកើតក្នុងត្រកូលកុដុម្ពិក៍ ដែលនៅក្នុងក្រុងពារាណសី ។ ប្រធានជាងតម្បាញ បានជាបុត្ររបស់កុដុម្ពិក៍ដែលជាធំ ។ ចំណែកភរិយារបស់គេ ក៏បានជាធីតារបស់កុដុម្ពិក៍ដែលជាធំដែរ ។ ស្ត្រីទាំងអស់នោះចម្រើនវ័យហើយ កាលនឹងទៅកាន់ត្រកូលស្វាមី ក៏បានទៅកាន់ផ្ទះរបស់បុរសទាំងនោះឯង ។

## កុដុម្ពិក៍ថ្វាយមហាទាន

ថ្ងៃមួយ មានគេដើរឃោសនាការស្តាប់ធម៌នៅក្នុងវិហារ ។ កុដុម្ពិក៍ទាំងអស់នោះបានឮថា ព្រះសាស្តាទ្រង់នឹងសម្តែងធម៌ ក៏ប្រឹក្សាគ្នាថា "យើងទាំងឡាយនឹងទៅស្តាប់ធម៌ ហើយបានទៅកាន់វិហារជាមួយនឹងភរិយាខ្លួន ។ ក្នុងខណៈដែលជនទាំងនោះចូលទៅដល់វិហារ ភ្លៀងក៏បានបង្អុរចុះមក ។

បព្វជិតទាំងឡាយមានសាមណេរជាដើម ដែលជាកុលុបកៈ ឬជាញាតិរបស់ជនទាំងឡាយណាមានហើយ ជនទាំងនោះ ក៏ចូលទៅកាន់បរិវេណរបស់បព្វ-ជិតទាំងនោះ ។ ឯកុដុម្ពិកទាំងនោះ មិនអាចចូលទៅកាន់ទីណាៗ បាន ព្រោះបព្វជិតដែលជាកុលុបកៈ ឬជាញាតិរបស់ខ្លួនមិនមាន ក៏បានឈរនៅកណ្តាលវិហារនោះឯង ។ គ្រានោះ កុដុម្ពិកដែលជាប្រធានបានពោលទៅកាន់កុដុម្ពិកដែលជាបរិវារទាំងនោះថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយចូរមើលអាការដ៏គួរប្លែករបស់ពួកយើង ធម្មតាកុលបុត្រទាំងឡាយ ខ្មាសអៀនដោយហេតុមានប្រមាណប៉ុណ្ណេះ សមគួរហើយ ។

បរិវារ. នាយ ពួកយើងនឹងធ្វើយ៉ាងណា ?

កុដុម្ពិក. ពួកយើងដល់នូវអាការដែលប្លែកនេះ ព្រោះមិនមានបុគ្គលដែលស្និទ្ធស្នាល យើងទាំងអស់គ្នារួមទ្រព្យគ្នាសាងបរិវេណចុះ ។

បរិវារ. ប្រពៃហើយ នាយ ។

កុដុម្ពិកដែលជាប្រធានបានចេញ ១.០០០ ជនដ៏សេសម្នាក់ៗ ៥០០ ភរិយានៃជនទាំងនោះម្នាក់ៗ ២៥០ ។ ជនទាំងនោះប្រមូលបានទ្រព្យហើយ ផ្តើម (កសាង) បរិវេណមួយធំ ដែលមានផ្ទះកំពូល ១.០០០ ជាបរិវារ ដើម្បីជាទីប្រថាប់នៃព្រះសាស្តា ។ កាលទ្រព្យមិនគ្រប់គ្រាន់ (ខ្វះ) ព្រោះនវកម្មថ្មីជាកម្មដ៏ធំ ទើបបានចំណាយទ្រព្យម្នាក់ពាក់កណ្តាលៗ អំពីទ្រព្យដែលខ្លួនបានចំណាយហើយអំពីមុននោះ ។ កាលបរិវេណស្រេចហើយ ជនទាំងនោះក៏ធ្វើ

ពិធីធ្វើ ដោយមានការថ្វាយមហាទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អស់ ៧ ថ្ងៃ ហើយចាត់ចែងចីវរប្រគេនភិក្ខុសង្ឃប្រមាណពីរម៉ឺនរូប ។ ចំណែកភរិយារបស់កុដុម្ពីក៏ជាធំនោះ មិនធ្វើឲ្យមានចំណែកស្មើនឹងជនទាំងអស់នោះទេ តាំងនៅក្នុងបញ្ញារបស់ខ្លួនហើយ បានគិតថា “យើងនឹងបូជាព្រះសាស្តាឲ្យក្រៃលែង (ជាងគេ)” ទើបកាន់យកប្រអប់ដែលពេញដោយផ្កានោង និងសំពត់សាដកមានពណ៌ដូចផ្កានោង ដែលមានតម្លៃ ១.០០០ ក្នុងវេលាដែលព្រះសម្មាសម្ពុទ្ធអនុមោទនា បូជាព្រះសាស្តាដោយផ្កានោង និងសំពត់សាដកនោះ ហើយតាំងសេចក្តីប្រាថ្នាថា “បពិត្រព្រះអង្គដ៏ចម្រើន សូមឲ្យសរីរៈរបស់ខ្ញុំព្រះអង្គ មានពណ៌ដូចផ្កានោងក្នុងទីដែលខ្ញុំម្ចាស់កើតហើយៗ ចុះ សូមឲ្យខ្ញុំម្ចាស់មាននាមថា **អនោជា**” ។ ព្រះសាស្តា ទ្រង់ធ្វើអនុមោទនាថា “ចូរសម្រេចយ៉ាងនោះចុះ” ។

## កុដុម្ពីក៏ និងភរិយាព្រមទាំងបរិវារកើតក្នុងរាជត្រកូល

ជនទាំងអស់នោះ តាំងនៅរហូតអស់អាយុហើយ ចុតិចាកអត្តភាពនោះក៏កើតក្នុងទេវលោក ។ ក្នុងពុទ្ធុប្បាទកាលនេះ ក៏ចុតិចាកទេវលោកហើយកុដុម្ពីក៏ដែលជាធំ កើតក្នុងរាជត្រកូល ក្នុងកុក្កុដវតីនគរ ចម្រើនវ័យហើយ បានជាព្រះរាជាទ្រង់ព្រះនាមថា **ព្រះបាទមហាកប្បិន** ជនដ៏សេសកើតក្នុងត្រកូលអាមាត្យ ភរិយារបស់កុដុម្ពីក៏ដែលជាធំ កើតក្នុងរាជត្រកូលក្នុងសាគលនគរដែនមទ្ទរដ្ឋ នាងមានព្រះសរីរៈដូចផ្កានោង ពួកញាតិថ្វាយព្រះនាមឲ្យព្រះនាង

ថា **អនោជា** នោះឯង ។ នាងចម្រើនវ័យហើយ ក៏បានជាអគ្គមហេសីរបស់ព្រះបាទមហាកប្បិន ស្ត្រីដ៏សេសក៏កើតក្នុងត្រកូលអាមាត្យទាំងឡាយ ចម្រើនវ័យហើយ ក៏បានជាភរិយារបស់អាមាត្យទាំងនោះដែរ ។ ជនទាំងអស់នោះគ្រប់ៗ គ្នា សុទ្ធតែបានសោយសម្បត្តិដូចសម្បត្តិរបស់ព្រះរាជាដែរ ។ ក្នុងកាលណាព្រះរាជាទ្រង់ប្រដាប់គ្រឿងអលង្ការទាំងពួង ហើយស្តេចឡើងកាន់ដំរីត្រាច់ទៅ ក្នុងកាលនោះ ជនទាំងអស់នោះ ក៏ត្រាច់ទៅដូច្នោះដូចគ្នា ។ កាលព្រះរាជាស្តេចយាងទៅដោយសេះ ឬដោយរថ ជនទាំងនោះក៏ទៅដូច្នោះ ។ ជនទាំងនោះសោយសម្បត្តិរួមគ្នា ព្រោះអានុភាពនៃបុណ្យដែលធ្វើរួមគ្នា ដោយប្រការដូច្នេះ ។

ព្រះរាជាមានសេះ ៥ គឺ សេះឈ្មោះពលៈ ១ ពលវាហនៈ ១ បុប្ផៈ ១ បុប្ផវាហនៈ ១ សុបត្តៈ ១ ។ បណ្តាសេះទាំងនោះ សេះឈ្មោះសុបត្តៈ ជាទីនាំងរបស់ព្រះរាជា ។ សេះ ៤ ក្រៅពីនេះ បានព្រះរាជទានឲ្យដល់ពួកអ្នកបម្រើ ដើម្បីប្រយោជណ៍នាំដំណឹង ។ ព្រះរាជា ឲ្យអ្នកជិះសេះទាំងនោះបរិភោគពីព្រលឹមហើយ ទ្រង់បញ្ជូនទៅដោយព្រះតម្រាស់ថា “ម្នាលអ្នកទាំងឡាយ ពួកអ្នកទៅ ចូរត្រាច់ទៅ ២ ឬ ៣ យោជន៍ ហើយដឹងថា ព្រះពុទ្ធ ព្រះធម៌ ឬព្រះសង្ឃកើតឡើងហើយ ចូរនាំដំណឹងដែលឲ្យកើតសេចក្តីសុខមកថ្វាយយើង” ។ អ្នកជិះសេះទាំងនោះចេញតាមខ្វាងទ្វារទាំង ៤ ត្រាច់ទៅបាន ២ ឬ ៣ យោជន៍ មិនបានដំណឹង ក៏ត្រឡប់មកវិញ ។

## ព្រះរាជាបានទទួលដំណឹងព្រះរតនត្រ័យអំពីឈ្មួញ

តមកថ្ងៃមួយ ព្រះរាជាទ្រង់ឡើងកាន់សេះឈ្មោះ សុបត្តៈ មានអាមាត្យ ១.០០០ ហែហម ស្តេចបានយាងទៅកាន់ព្រះរាជឧទ្យាន ទតឃើញពួកឈ្មួញ ប្រមាណ ៥០០ នាក់ ដែលមានរាងកាយល្វន់ល្វើយ ព្រោះអស់កម្លាំង កំពុង ចូលទៅកាន់ព្រះនគរ ទ្រង់ព្រះតម្រិះថា “ជនទាំងនេះលំបាកព្រោះការធ្វើដំណើរ ផ្លូវឆ្ងាយ យើងនឹងបានដំណឹងអ្វីមួយអំពីសម្នាក់នៃជនទាំងនេះដោយពិត” ។ ទើបត្រាស់បង្គាប់ឲ្យហៅឈ្មួញទាំងនោះមក ហើយសួរថា “អ្នកទាំងឡាយមក អំពីក្រុងណា?” ។

ឈ្មួញ. បពិត្រមហារាជ ពួកខ្ញុំព្រះអង្គមកអំពីនគរឈ្មោះសាវត្ថី ដែល នៅឆ្ងាយអំពីនគរនេះប្រមាណ ១២០ យោជន៍ ។

ព្រះរាជា. ក្នុងប្រទេសរបស់ពួកអ្នកឯង មានដំណឹងអ្វី កើតឡើងដែរ ឬទេ ។

ឈ្មួញ. បពិត្រមហារាជ ដំណឹងអ្វីៗ យ៉ាងដទៃមិនមានទេ ប៉ុន្តែព្រះ សម្មាសម្ពុទ្ធទ្រង់កើតឡើងហើយក្នុងលោក ។

ព្រះរាជាមានព្រះសរីរៈដែលបីតិ ៥ ប្រការ ពាល់ត្រូវហើយ រំពេច នោះឯង ក៏មិនអាចកំណត់អ្វីៗ បាន ទ្រង់ព្រះវិសញ្ញី (សន្លប់) មួយភ្លែត ទើប ទ្រង់មានសតិឡើងវិញ ត្រាស់សួរថា “អម្បាញ់មិញនេះ ពួកអ្នកនិយាយអ្វី” ពួកឈ្មួញក្រាបទូលថា “មហារាជ ព្រះពុទ្ធទ្រង់កើតឡើងហើយក្នុងលោក” ។

សូម្បីលើកទី ២ លើកទី ៣ ព្រះរាជាក៏ទ្រង់វិសជ្ជីទៀត ក្នុងវារៈទី ៤ ទ្រង់ត្រាស់សួរថា "ពួកអ្នកនិយាយអ្វី កាលឈ្មួញទាំងនោះ ក្រាបទូលថា "បពិត្រមហារាជ ព្រះពុទ្ធទ្រង់កើតឡើងហើយ" ទើបត្រាស់ថា "ម្នាលអ្នកទាំងឡាយ យើងឲ្យទ្រព្យ ១ សែនដល់ពួកអ្នក" ហើយត្រាស់សួរថា "ម្នាលអ្នកដ៏ចម្រើន ដំណឹងអ្វីៗ យ៉ាងដទៃទៀត មានដែរឬទេ?" ពួកឈ្មួញក្រាបទូលថា "បពិត្រមហារាជ មាន គឺ ព្រះធម៌កើតឡើងហើយ" ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ទ្រង់វិសជ្ជីអស់ ៣ ដង ដូចមុនដែរ ក្នុងវារៈទី ៤ កាលពួកឈ្មួញពោលបទថា **ធម្មោ** ទើបត្រាស់ថា "ដោយអំណាចនៃបទនេះ យើងឲ្យទ្រព្យពួកអ្នក ១ សែន" ហើយត្រាស់សួរថា "នៅមានដំណឹងដទៃទៀតដែរឬទេ?" ពួកឈ្មួញក្រាបទូលថា "បពិត្រមហារាជ មាន ព្រះសង្ឃរតនៈកើតឡើងហើយ" ។ ព្រះរាជា ទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ ទ្រង់ក៏វិសជ្ជីអស់ ៣ ដង ទៀត ក្នុងវារៈទី ៤ កាលពួកឈ្មួញក្រាបទូលបទថា "**សង្ឃោ**" ទើបត្រាស់ថា "ដោយអំណាចនៃបទនេះ យើងឲ្យទ្រព្យ ១ សែនដល់ពួកអ្នក" ហើយទ្រង់ត្រាស់សួរអាមាត្យទាំងនោះថា "ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយនឹងធ្វើយ៉ាងណា?" ។

អាមាត្យ. បពិត្រមហារាជ ព្រះអង្គនឹងទ្រង់ធ្វើយ៉ាងណាដែរ ។

ព្រះរាជា. ម្នាលអ្នកទាំងឡាយ យើងបានស្ដាប់នូវពាក្យថា "ព្រះពុទ្ធទ្រង់កើតឡើងហើយ ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ យើង

នឹងមិនត្រឡប់ចូលទៅកាន់ព្រះនគរវិញទេ យើងនឹងឧទ្ទិសចំពោះព្រះសាស្តា ទៅបួសក្នុងសម្នាក់ព្រះអង្គ ។

អាមាត្យ. បពិត្រមហារាជ សូម្បីខ្ញុំព្រះអង្គទាំងឡាយ ក៏នឹងទៅបួស ជាមួយព្រះអង្គដែរ ។

## ព្រះរាជាចេញបួសជាមួយនឹងអាមាត្យ

ព្រះរាជាត្រាស់បង្គាប់ឲ្យស្មៀនចារឹកអក្សរក្នុងផ្ទាំងមាសហើយ ត្រាស់ទៅកាន់ពួកឈ្មួញថា "ព្រះទេវីព្រះនាមអនោជានឹងព្រះរាជទានទ្រព្យ ៣ សែន ដល់ពួកអ្នក ហើយពួកអ្នកគប្បីទូលព្រះទេវីយ៉ាងនេះថា ព្រះរាជាទ្រង់លះបង់ រាជសម្បត្តិថ្វាយព្រះនាងហើយ សូមព្រះនាងសោយសម្បត្តិតាមសប្បាយចុះ ប្រសិនបើ ព្រះទេវីត្រាស់សួរពួកអ្នកថា ព្រះរាជាស្តេចយាងទៅទីណា? ពួកអ្នកគប្បីទូលថា ព្រះរាជាត្រាស់ថា នឹងបួសឧទ្ទិសចំពោះព្រះសាស្តា" ហើយស្តេចយាងទៅ សូម្បីអាមាត្យទាំងឡាយក៏បញ្ជូនដំណឹងទៅប្រាប់ភរិយារបស់ខ្លួនយ៉ាងនោះដែរ ។ ព្រះរាជាទ្រង់បញ្ជូនពួកឈ្មួញទៅហើយ ស្តេចក៏យាងចេញទៅក្នុងខណៈនោះឯង ដោយមានអាមាត្យ ១.០០០ ហែហម ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញព្រះបាទមហាកប្បិន ព្រមទាំងបរិវារ ចូលទៅក្នុងសំណាញ់ គឺព្រះញាណរបស់ព្រះអង្គ ទ្រង់ព្រះតម្រិះថា "ព្រះបាទមហាកប្បិន ទ្រង់បានព្រះស្តាប់ថា ព្រះរតនត្រ័យកើតឡើងហើយអំពីសម្នាក់នៃពួកឈ្មួញ ទើបទ្រង់

បូជាពាក្យរបស់ឈ្មួញទាំងនោះដោយទ្រព្យ ៣ សែន ទ្រង់លះបង់រាជសម្បត្តិដែលមានអាមាត្យ ១ ពាន់ហែហម ទ្រង់ប្រាថ្នានឹងបួសឧទ្ទិសចំពោះតថាគត តថាគតនឹងចេញទៅក្នុងថ្ងៃនេះ ព្រះរាជាព្រមទាំងបរិវារនឹងបានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ តថាគតនឹងទៅទទួល" ដូច្នេះហើយ ថ្ងៃស្អែកឡើង ទ្រង់ប្រដាប់បាត្រ និងចីវរ ស្តេចយាងតែមួយព្រះអង្គឯង អស់ចម្ងាយផ្លូវ ១២០ យោជន៍ ដើម្បីទទួលព្រះរាជាមហាកប្បិន ដូចស្តេចចក្រ-ពត្តិទ្រង់ទទួលចៅហ្វាយស្រុកដូច្នោះ ទ្រង់ប្រថាប់ផ្សាយព្រះរស្មីមានពណ៌ ៦ ប្រការ ក្រោមម្លប់នៃដើមនិគ្រោធ ក្បែរឆ្នេរស្ទឹងចន្ទភាគានទី ។

ចំណែកព្រះរាជា ស្តេចយាងមកដល់ស្ទឹងទីមួយហើយ ត្រាស់សួរថា "ស្ទឹងនេះឈ្មោះអ្វី?"

អាមាត្យ. បពិត្រមហារាជ ឈ្មោះអារវបច្ឆានទី ។

ព្រះរាជា. ម្នាលអ្នកទាំងឡាយ ស្ទឹងនេះមានប្រមាណប៉ុន្មាន ។

អាមាត្យ. បពិត្រមហារាជ ជម្រៅ ១ គាវុត ទទឹង ២ គាវុត ។

ព្រះរាជា. ក្នុងស្ទឹងនេះ មានទូក ឬក្បូនទេ ។

អាមាត្យ. បពិត្រមហារាជ មិនមានទេ ។

ព្រះរាជាត្រាស់ថា "កាលយើងទាំងឡាយរវល់តែរកយាន មានទូកជាដើម ជាតិរមែងនាំទៅកាន់ជរា ជរារមែងនាំទៅកាន់មរណៈ យើងចេញបួសឧទ្ទិសចំពោះព្រះរតនត្រ័យដោយគ្មានសង្ស័យ ដោយអានុភាពនៃព្រះរតនត្រ័យ

នោះ ទឹកនេះ កុំដូចជាទឹកឡើយ” ដូច្នេះហើយ ទ្រង់រឭកដល់គុណព្រះរតនត្រ័យ រឭកដល់ពុទ្ធានុស្សតិថា “សូម្បីព្រោះហេតុនោះ ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តសម្មាសម្ពុទ្ធដូច្នេះជាដើម” ព្រះរាជាព្រមទាំងបរិវារ ស្ដេចយាងទៅលើខ្នងទឹកដោយសេះ ១.០០០ ។ សេះសិន្ធពទាំងឡាយរត់លើទឹកដូចរត់លើថ្ម សូម្បីតែចុងក្រចក ក៏មិនទទឹក ។

ព្រះរាជាស្ដេចឆ្លងស្ទឹងនោះហើយ ស្ដេចយាងទៅបានបន្តិច ទតឃើញស្ទឹងមួយទៀត ក៏ត្រាស់សួរថា “ស្ទឹងនេះ ឈ្មោះអ្វី?” ។

អាមាត្យ. បពិត្រមហារាជ ស្ទឹងនេះឈ្មោះ នីលវាហានាទី ។

ព្រះរាជា. ស្ទឹងនេះមានប្រមាណប៉ុន្មាន ។

អាមាត្យ. បពិត្រមហារាជ ទាំងជម្រៅ ទាំងទទឹង មានប្រមាណកន្លះយោជន៍ ។ ពាក្យដ៏សេសដូចពាក្យមុននោះឯង ។

ព្រះរាជាទតឃើញស្ទឹងនោះហើយ ទ្រង់រឭកដល់ធម្មានុស្សតិថា “ព្រះធម៌ដែលព្រះមានព្រះភាគត្រាស់ល្អហើយ” ជាដើម ស្ដេចយាងទៅហើយ ។ លុះស្ដេចឆ្លងស្ទឹងនោះហើយ ទ្រង់ទតឃើញ ស្ទឹងដទៃទៀត ក៏ត្រាស់សួរថា “ស្ទឹងនេះ ឈ្មោះអ្វី?”

អាមាត្យ. បពិត្រមហារាជ ស្ទឹងនេះឈ្មោះ ចន្ទភាគានទី ។

ព្រះរាជា. ស្ទឹងនេះប្រមាណ ប៉ុន្មាន?

អាមាត្យ. បពិត្រមហារាជ ទាំងជម្រៅ ទាំងទទឹងប្រមាណ ១ យោជន៍ ។

ពាក្យដ៏សេសដូចគ្នានឹងពាក្យមុននោះឯង ។

ចំណែកព្រះរាជាទតឃើញស្ពានោះហើយ ទ្រង់រឭកដល់សង្ឃានុស្សតិថា "ព្រះសង្ឃសាវករបស់ព្រះមានព្រះភាគ ជាអ្នកបដិបត្តិល្អហើយ" ជាដើម ស្ដេចយាងទៅហើយ ។ កាលស្ដេចចូលស្ពានោះហើយ ទ្រង់ទតឃើញព្រះរស្មីមានពណ៌ ៦ ប្រការ ដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្ដា ។ មែក ប្រគាប និងស្លឹកនៃដើមនិគ្រោធដូចជាមាស ។

## ព្រះរាជា និងអាមាត្យបានសម្រេចគុណវិសេស

ព្រះរាជាទ្រង់ព្រះតម្រិះថា ពន្លឺនេះ មិនមែនជាពន្លឺព្រះច័ន្ទ មិនមែនជាពន្លឺព្រះអាទិត្យ មិនមែនជាពន្លឺទេវតា មារ ព្រហ្ម នាគ គ្រុឌ ជាដើមទេ យើងមានចិត្តឧទ្ទិសចំពោះព្រះសាស្ដា ទើបមកកាន់ទីនេះ ប្រាកដជាព្រះពុទ្ធព្រះនាមមហាគោតម ទ្រង់ ឃើញយើងហើយ ។ ខណៈនោះឯង ទ្រង់ចុះអំពីខ្នងសេះ ហើយឱនព្រះសរីរៈចូលទៅគាល់ព្រះសាស្ដា តាមព្រះរស្មីនោះ ស្ដេចចូលទៅខាងក្នុងព្រះពុទ្ធរស្មី ដូចជាមុជចុះក្នុងរសនៃមនោសិលាដូច្នោះ ថ្វាយបង្គំព្រះសាស្ដាហើយ ទ្រង់គង់ក្នុងទីដ៏សមគួរជាមួយនឹងអាមាត្យទាំង ១.០០០ នោះ ព្រះសាស្ដាក៏ទ្រង់សម្ដែងអនុបុព្វីកថា ។ លុះវេលាចប់ព្រះធម្មទេសនា ព្រះរាជាព្រមទាំងបរិវារ ក៏តាំងនៅក្នុងសោតាបត្តិផល ។ លំដាប់នោះ ព្រះរាជា និងអាមាត្យទាំង ១.០០០ នោះ ក្រោកឡើងទូលសូមបព្វជ្ជា ។ ព្រះសាស្ដាទ្រង់ពិចារណាមើលថា "បាត្រ ចីវរសម្រេចដោយឫទ្ធិរបស់កុលបុត្រទាំងនេះ នឹង

មកដែរឬទេ” ទ្រង់ជ្រាបថា “កុលបុត្រទាំងនេះបានប្រគេនចីវរ ១.០០០ ផ្ទាំង ចំពោះព្រះបច្ចេកពុទ្ធ ១.០០០ អង្គ ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ បានប្រគេនចីវរ ២ ម៉ឺនផ្ទាំង ចំពោះភិក្ខុ ២ ម៉ឺនអង្គ ការមកនៃបាត្រ និងចីវរ ដែលសម្រេចដោយឫទ្ធិរបស់កុលបុត្រទាំងនេះ មិនជាអស្ចារ្យទេ” ដូច្នេះហើយ ទ្រង់លាតព្រះហស្តស្តាំត្រាស់ថា “អ្នកទាំងឡាយចូរជាភិក្ខុចុះ ចូរប្រព្រឹត្តនូវព្រហ្មចរិយៈ ដើម្បីធ្វើនូវទីបំផុតនៃសេចក្តីទុក្ខដោយប្រពៃចុះ” ។ ក្នុងខណៈនោះឯង កុលបុត្រទាំងនោះ ក៏ដូចជាព្រះថេរៈដែលមានវស្សា ១០០ ទ្រទ្រង់បរិក្ខារទាំង ៨ ហោះឡើងទៅកាន់វេហាស៍ ត្រឡប់ចុះមកថ្វាយបង្គំព្រះសាស្តាហើយ គង់ក្នុងទីដ៏សមគួរ ។

## ព្រះនាងអនោជា ស្តេចចេញបួស

ចំណែកឈ្នួញទាំងនោះ ទៅដល់រាជត្រកូលហើយ ញុំាងរាជបុរសឲ្យក្រាបទូលដំណឹងដែលព្រះរាជាទ្រង់បញ្ជូនមក កាលព្រះទេវីត្រាស់ថា “ចូលមកចុះ” ក៏ចូលទៅថ្វាយបង្គំហើយ ឈរក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះទេវីត្រាស់សួរពួកឈ្នួញទាំងនោះថា “អ្នកទាំងឡាយ អ្នកទាំងឡាយមកព្រោះហេតុអ្វី ?”

ឈ្នួញ. ព្រះរាជា ទ្រង់បញ្ជូនពួកខ្ញុំព្រះអង្គមកកាន់សម្នាក់របស់ព្រះនាងឲ្យព្រះនាងព្រះរាជទានទ្រព្យ ៣ សែន ដល់ពួកខ្ញុំព្រះអង្គ ។

ព្រះទេវី. ម្នាលអ្នកទាំងឡាយ អ្នកទាំងឡាយនិយាយច្រើនហួស តើ

អ្នកទាំងឡាយបានធ្វើអ្វីថ្វាយព្រះរាជា? ព្រះរាជា ទ្រង់ជ្រះថ្លានឹងអ្វីរបស់ពួកអ្នក? ទើបបញ្ជាឲ្យព្រះរាជទានទ្រព្យមានប្រមាណប៉ុណ្ណេះ? ។

ឈ្មួញ. បពិត្រព្រះនាងជាម្ចាស់ អ្វីៗ យ៉ាងដទៃ ពួកខ្ញុំព្រះអង្គមិនបានធ្វើទេ ប៉ុន្តែពួកខ្ញុំព្រះអង្គ បានក្រាបទូលដំណឹងចំពោះព្រះរាជា ។

ព្រះទេវី. ម្នាលអ្នកទាំងឡាយ តើអ្នកទាំងឡាយអាចប្រាប់ដំណឹងនោះដល់យើងបានដែរឬទេ ។

ឈ្មួញ. បពិត្រព្រះនាងជាម្ចាស់ បាន ។

ព្រះទេវី. បើដូច្នោះ អ្នកទាំងឡាយចូរប្រាប់មកចុះ ។

ឈ្មួញ. ព្រះនាងជាម្ចាស់ ព្រះពុទ្ធទ្រង់កើតឡើងហើយក្នុងលោក ។

ព្រះទេវីទ្រង់ព្រះសណ្ដាប់នូវពាក្យនោះហើយ មានព្រះសរីរៈដែលបីតិពាល់ត្រូវហើយដូចព្រះរាជាដែរ ទ្រង់កំណត់អ្វីៗ មិនបានដល់ ៣ ដង ក្នុងវារៈទី ៤ ទ្រង់ព្រះសណ្ដាប់នូវបទថា ពុទ្ធោ ហើយក៏ត្រាស់សួរថា “ម្នាលអ្នកទាំងឡាយ ដោយបទនេះ ព្រះរាជាព្រះរាជទានអ្វីដល់អ្នកទាំងឡាយ?” ។

ឈ្មួញ. បពិត្រព្រះនាងជាម្ចាស់ ទ្រព្យ ១ សែន ។

ព្រះទេវី. ម្នាលអ្នកទាំងឡាយ ព្រះរាជាទ្រង់ព្រះស្ដាប់នូវដំណឹងបែបនេះហើយ ព្រះរាជទានទ្រព្យ ១ សែនដល់អ្នកទាំងឡាយ (ឈ្មោះថា) ទ្រង់ធ្វើមិនសមគួរឡើយ យើងនឹងឲ្យអ្នកទាំងឡាយ ៣ សែន ដោយទ្រព្យដ៏ខ្សត់ខ្សោយរបស់យើង ដំណឹងអ្វីដទៃដែលអ្នកទាំងឡាយទូលថ្វាយព្រះរាជា នៅ

មានទៀតដែរទេ? ។

ឈ្មួញទាំងនោះ ក្រាបទូលដំណឹងពីរយ៉ាងដទៃទៀតថា ដំណឹងយ៉ាងនេះៗ ។

ព្រះទេវីមានព្រះសរីរៈដែលបីតិពាល់ត្រូវហើយ ទ្រង់វិសជ្ជី ដោយន័យដូចមុននោះឯង ទ្រង់កំណត់អ្វីៗ មិនបានដល់ ៣ ដង ក្នុងវារៈទី ៤ ទ្រង់ព្រះសណ្ដាប់យ៉ាងនោះហើយ ត្រាស់បង្គាប់ឲ្យព្រះរាជទានទ្រព្យក្នុង ១ បទ ៣ សែន ។ ឈ្មួញទាំងនោះ បានទ្រព្យទាំងអស់ ១២ សែន ។

គ្រានោះ ព្រះទេវីត្រាស់សួរឈ្មួញទាំងនោះថា "ម្នាលអ្នកទាំងឡាយ ព្រះរាជាស្ដេចយាងទៅណា?" ។

ឈ្មួញ. បពិត្រព្រះនាងជាម្ចាស់ ព្រះរាជាត្រាស់ថា "យើងនឹងបួសឧទ្ទិសចំពោះព្រះសាស្ដា" ។

ព្រះទេវី. ដំណឹងអ្វី ដែលព្រះរាជាព្រះរាជទានដល់យើង? ។

ឈ្មួញ. បពិត្រព្រះនាងជាម្ចាស់ ព្រះរាជាទ្រង់លះបង់រាជសម្បត្តិថ្វាយព្រះនាងហើយ ។ ព្រះរាជាមានព្រះតម្រាស់ថា "សូមព្រះនាងសោយរាជ្យតាមព្រះបំណងចុះ" ។

ព្រះទេវី. ម្នាលអ្នកទាំងឡាយ ពួកអាមាត្យទៅណា? ។

ឈ្មួញ. បពិត្រព្រះនាងជាម្ចាស់ សូម្បីអាមាត្យទាំងនោះ ក៏ពោលថា "យើងនឹងបួសជាមួយព្រះរាជាដែរ ។ ហើយក៏នាំគ្នា ធ្វើដំណើរទៅជាមួយព្រះ

រាជា ។

ព្រះនាងអនោជា ត្រាស់បង្គាប់ឲ្យហៅភរិយារបស់អាមាត្យទាំងនោះមក ហើយត្រាស់ថា “ម្នាលនាងដ៏ចម្រើន ស្វាមីរបស់ពួកនាងពោលថា យើងនឹងបួសជាមួយព្រះរាជា ហើយក៏នាំគ្នា ធ្វើដំណើរទៅបួសជាមួយព្រះរាជាហើយ” ពួកនាងនឹងធ្វើយ៉ាងណា? ។

ស្ត្រី. ព្រះនាងជាម្ចាស់ ក៏ដំណឹងអ្វីខ្លះ ដែលពួកគេបញ្ជូនមកឲ្យពួកនាងខ្ញុំ? ។

ព្រះទេវី. ម្នាលនាងដ៏ចម្រើន បានឮថា អាមាត្យទាំងនោះលះបង់សម្បត្តិរៀងៗ ខ្លួន ឲ្យពួកនាង បានផ្តាំមកថា “ឲ្យពួកនាងបរិភោគសម្បត្តិនោះ តាមសប្បាយចុះ” ។

ស្ត្រី. បពិត្រព្រះនាងជាម្ចាស់ តើព្រះនាងទ្រង់ធ្វើដូចម្តេចដែរក្នុងរឿងនេះ? ។

ព្រះទេវី. ម្នាលនាងដ៏ចម្រើន ព្រះរាជាទ្រង់បានជ្រាបនូវដំណឹងនោះហើយ ទ្រង់បូជាព្រះរតនត្រ័យដោយទ្រព្យ ៣ សែន ទ្រង់លះបង់សម្បត្តិដូចជាទឹកមាត់ ត្រាស់ថា “យើងនឹងបួស ហើយក៏ស្តេចយាងចេញទៅបួសទៅ” ចំណែកយើងបានស្តាប់ដំណឹងព្រះរតនត្រ័យហើយ បូជាព្រះរតនត្រ័យដោយទ្រព្យ ៩ សែន ដែលឈ្មោះថា សម្បត្តិ មិនមែននាំទុក្ខមកឲ្យព្រះរាជាតែមួយព្រះអង្គប៉ុណ្ណោះទេ រមែងជាហេតុនាំមកនូវទុក្ខឲ្យយើងផងដែរ នរណានឹង

លុតជង្គង់លិទ្ធទឹកមាត់ ដែលព្រះរាជាទ្រង់ខាកចោលទៅ? យើងមិនត្រូវការនូវសម្បត្តិទាំងនេះទេ សូម្បីយើងក៏នឹងទៅបួសឧទ្ទិសព្រះសាស្ដាដែរ" ។

ស្ត្រី. បពិត្រព្រះនាងជាម្ចាស់ សូម្បីពួកខ្ញុំម្ចាស់ ក៏នឹងបួសជាមួយព្រះនាងដែរ ។

ព្រះទេវី. ប្រសិនបើពួកនាងអាច ក៏ជាការប្រពៃហើយ ។

ស្ត្រី. បពិត្រព្រះនាងជាម្ចាស់ ពួកខ្ញុំម្ចាស់អាច ។

ព្រះទេវីត្រាស់ថា "បើដូច្នោះ ពួកនាងចូរមក" ដូច្នេះ ហើយត្រាស់បង្គាប់ឲ្យទឹមនូវរថ ១.០០០ ស្ដេចឡើងរថធ្វើដំណើរចេញទៅជាមួយនឹងស្ត្រីទាំងនោះ ទ្រង់ទតឃើញស្ទឹងទី ១ តាមផ្លូវហើយ ត្រាស់សួរ ដូចព្រះរាជាត្រាស់សួរពួកអាមាត្យដែរ ទ្រង់ព្រះសណ្ដាប់នូវការប្រព្រឹត្តិទៅសព្វគ្រប់ហើយត្រាស់ថា "ពួកនាងចូររកមើលនូវផ្លូវដែលព្រះរាជាយាងទៅមើល៍" កាលស្ត្រីទាំងនោះក្រាបទូលថា "បពិត្រព្រះនាងជាម្ចាស់ ពួកនាងខ្ញុំរកមើលមិនឃើញស្នាមជើងសេះសិន្ធពទាំងឡាយទេ" ក៏ទ្រង់មានព្រះតម្រិះថា "ព្រះរាជាប្រាកដជាទ្រង់ធ្វើសច្ចកិរិយាថា យើងបួសឧទ្ទិសចំពោះព្រះរតនត្រ័យ សូម្បីយើងក៏ចេញបួសឧទ្ទិសចំពោះព្រះរតនត្រ័យដែរ ដោយអានុភាពនៃព្រះរតនត្រ័យ សូមទឹកនេះកុំដូចជាទឹកឡើយ" ដូច្នេះ ហើយទ្រង់រឭកដល់គុណព្រះរតនត្រ័យ ទ្រង់បញ្ជូនរថ ១.០០០ ទៅ ។ ទឹកបានប្រាកដដូចជាផែនថ្ម ។ សូម្បីខ្នងកង់រទេះទាំងឡាយ ក៏មិនទទឹក ។ ព្រះទេវីទ្រង់ឆ្លងស្ទឹងទាំងពីរនេះ បានដោយឧបាយ

យ៉ាងនេះឯង ។

ព្រះសាស្តាទ្រង់ជ្រាបថា "ព្រះទេវីស្តេចយាងមក" ទ្រង់ក៏បានធ្វើមិនឲ្យព្រះទេវីឃើញភិក្ខុទាំងឡាយ គង់ក្នុងសម្នាក់ព្រះអង្គ ។ សូម្បីព្រះទេវីស្តេចយាងទៅ ក៏ទ្រង់ទតឃើញនូវព្រះរស្មី ដែលផ្សាយចេញអំពីព្រះសរីរៈរបស់ព្រះសាស្តា ទ្រង់មានព្រះចិន្តាដូចព្រះរាជតម្រិះរបស់ព្រះរាជាដែរ ហើយស្តេចចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទ្រង់គង់ក្នុងទីដ៏សមគួរមួយ ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជាមហាកប្បិន ស្តេចចេញបួសឧទ្ទិសចំពោះព្រះអង្គ ស្តេចប្រហែលជាយាងមកកាន់ទីនេះហើយ តើស្តេចគង់នៅទីណា ព្រះអង្គទ្រង់មិនសម្តែងដល់ពួកនាងខ្ញុំម្ចាស់ទេឬ?" ព្រះសាស្តាត្រាស់ថា "ម្នាលនាងទាំងឡាយ នាងទាំងឡាយចូរអង្គុយសិនចុះ នាងទាំងឡាយនឹងបានឃើញព្រះរាជាក្នុងទីនេះឯង" ។ ស្ត្រីទាំងនោះ មានចិត្តត្រេកអរគ្រប់ៗ គ្នាហើយអង្គុយដោយគិតថា "ពួកយើងអង្គុយក្នុងទីនេះ នឹងបានឃើញពួកស្វាមីរបស់ខ្លួន" ។

ព្រះសាស្តាទ្រង់ត្រាស់អនុបុព្វីកថា ។ លុះចប់ទេសនា ព្រះនាងអនោជាព្រមទាំងបរិវារ បានសម្រេចសោតាបត្តិផលហើយ ។

ព្រះមហាកប្បិនត្ថេរព្រមទាំងបរិវារ ស្តាប់ព្រះធម្មទេសនា ដែលព្រះសាស្តាសម្តែងដល់ពួកស្ត្រីទាំងនោះ ក៏បានសម្រេចព្រះអរហត្ត ព្រមដោយបដិ-សម្ភិទាទាំងឡាយ ។ ក្នុងខណៈនោះឯង ព្រះសាស្តាក៏ទ្រង់ញុំាងភិក្ខុទាំងនោះ

ដែលជាអ្នកសំរេចព្រះអរហត្តហើយ ឲ្យប្រាកដដល់ស្ត្រីទាំងនោះ ។

បានឮថា ក្នុងខណៈដែលស្ត្រីទាំងនោះមកដល់នោះឯង ចិត្ត (របស់ពួកនាង) មិនគប្បីមានអារម្មណ៍តែមួយ ព្រោះឃើញស្វាមីរបស់ខ្លួនៗ ដែលជាអ្នកទ្រទ្រង់សំពត់ជ្រលក់ដោយទឹកចត់ មានសីសៈត្រងោល ព្រោះហេតុនោះស្ត្រីទាំងនោះមិនអាចសម្រេចមគ្គផលបាន ព្រោះដូច្នោះ ក្នុងវេលាស្ត្រីទាំងនោះ តាំងនៅក្នុងសទ្ធាមិនកម្រើកហើយ ព្រះសាស្តាទើបទ្រង់សម្តែងភិក្ខុទាំងនោះដែលសម្រេចព្រះអរហត្តហើយ ដល់ស្ត្រីទាំងនោះ ។ សូម្បីស្ត្រីទាំងនោះឃើញភិក្ខុទាំងនោះហើយ ក៏ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន កិច្ចនៃបព្វជិតរបស់លោកម្ចាស់ទាំងឡាយ ដល់ទីបំផុតមុន" ដូច្នេះ ហើយថ្វាយបង្គំព្រះសាស្តា ឈរក្នុងទីដ៏សមគួរមួយ ទូលសូមបព្វជ្ជា ។ អាចារ្យពួកខ្លះពោលថា "បានឮថា កាលស្ត្រីទាំងនោះក្រាបទូលយ៉ាងនោះហើយ ព្រះសាស្តាទ្រង់ព្រះតម្រិះនូវការមករបស់ព្រះនាងឧប្បលវណ្ណាថេរី" ។ តែព្រះសាស្តាត្រាស់ទៅកាន់ឧបាសិកាទាំងនោះថា "ឧបាសិកាទាំងឡាយ នាងទាំងឡាយទៅកាន់ក្រុងសាវត្ថី បព្វជ្ជាក្នុងសម្នាក់ភិក្ខុនីចុះ" ។ ឧបាសិកាទាំងនោះ ត្រាច់ទៅកាន់ទីចារិកដោយលំដាប់ មានសក្ការៈ និងការគោរពរាប់អាន ដែលមហាជននាំមកចំពោះហើយ តាមផ្លូវធ្វើដំណើរទៅដោយជើងទទេ អស់ចម្ងាយផ្លូវ ១២០ យោជន៍ បួសក្នុងសម្នាក់ភិក្ខុនី ហើយបានសម្រេចព្រះអរហត្ត ។ សូម្បីព្រះសាស្តា ក៏ទ្រង់នាំភិក្ខុ ១.០០០ រូបនោះ ទៅ

កាន់វត្តជេតពនតាមផ្លូវអាកាសដែរ ។

បានឮថា បណ្ដាភិក្ខុទាំងនោះ ព្រះមហាកប្បិនតែងតែបន្លឺឧទានក្នុងទីទាំងឡាយ មានទីសម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ជាដើមថា "សុខណាស់ហ្ន៎! សុខណាស់ហ្ន៎!" ភិក្ខុទាំងឡាយបានឮ ក៏ក្រាបទូលព្រះមានព្រះ-ភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហាកប្បិន តែងតែបន្លឺនូវឧទានក្នុងទីទាំងឡាយថា សុខណាស់ហ្ន៎ សុខណាស់ហ្ន៎" ប្រហែលជាលោកពោលប្រារព្ធនូវសេចក្ដីសុខក្នុងរាជសម្បត្តិរបស់ខ្លួនហើយមើលទៅ ។ ព្រះសាស្ដាត្រាស់ឲ្យហៅព្រះមហាកប្បិនមក ហើយត្រាស់សួរថា "ម្នាលកប្បិន បានឮថា អ្នកបន្លឺនូវឧទានប្រារព្ធសុខក្នុងកាម សុខក្នុងរាជសម្បត្តិពិតមែនឬ?" ព្រះមហាកប្បិនទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគរមែងទ្រង់ជ្រាបការបន្លឺ ឬមិនបន្លឺនូវឧទានប្រារព្ធកាមសុខ និងរាជសុខរបស់ខ្ញុំព្រះអង្គនោះហើយ" ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុត្ររបស់តថាគត មិនមែនបន្លឺឧទានប្រារព្ធនូវសុខក្នុងកាម សុខក្នុងរាជសម្បត្តិទេ តែថា សេចក្ដីរីករាយក្នុងធម៌ រមែងកើតឡើងដល់បុត្ររបស់តថាគត បុត្ររបស់តថាគតនោះ រមែងបន្លឺនូវឧទានយ៉ាងនោះ ព្រោះប្រារព្ធអមតមហានិព្វាន" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

ធម្មប្បីតិ សុខំ សេតិ វិប្បសន្នេន ចេតសា

អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។

បណ្ឌិត ដែលមានសេចក្ដីឆ្អែតក្នុងធម៌ មានចិត្ត
ជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុង
ធម៌ដែលព្រះអរិយៈប្រកាសទុកហើយ គ្រប់ពេល ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **ធម្មប្បីតិ (អ្នករីករាយក្នុងធម៌)** សេចក្ដីថា អ្នកឆ្អែតក្នុងធម៌ អធិប្បាយថា អ្នកផឹកធម៌ ។ ដែលឈ្មោះថា ព្រះធម៌នោះ មិនមាននរណាអាចផឹកបាន ដូចជាផឹកយាគូជាដើមដោយភាជនៈនោះទេ តែថា បុគ្គលណាពាល់ត្រូវនូវលោកុត្តរធម៌ ៩ យ៉ាង ដោយនាមកាយ ធ្វើឲ្យជាក់ច្បាស់ដោយភាពជាអារម្មណ៍ ចាក់ធ្លុះអរិយសច្ចៈ មានទុក្ខសច្ចៈជាដើមដោយកិច្ច មានការចាក់ធ្លុះធម៌ដោយការកំណត់ដឹងជាដើម ឈ្មោះថា រមែងផឹកនូវធម៌ ។ បទថា **សុខំ សេតិ (រមែងនៅជាសុខ)** នេះ ត្រឹមតែជាមាតិកានៃធម៌ទេសនាប៉ុណ្ណោះ អធិប្បាយថា រមែងនៅជាសុខក្នុងឥរិយាបថទាំង ៤ ។ បទថា **វិប្បសន្នេន (ផូរផង់)** គឺ មិនកករល្អក់ បានដល់ មិនមាន ឧបក្កិលេស ។ បទថា **អរិយប្បវេទិតេ (ក្នុងធម៌ដែលព្រះអរិយប្រកាសហើយ)** សេចក្ដីថា ក្នុងពោធិបក្ខិយធម៌ទាំងឡាយ មានសតិប្បដ្ឋាន ៤ ជាដើម ដែលព្រះអរិយៈទាំងឡាយ មានព្រះសម្មាសម្ពុទ្ធជាដើម ទ្រង់ប្រកាសហើយ ។ បទថា **សទា រមតិ (រមែងរីករាយ... គ្រប់កាល)** សេចក្ដីថា បណ្ឌិតដែលរីករាយក្នុងធម៌បែបនោះ មានចិត្តផូរផង់ ប្រកបព្រមដោយភាពជាបណ្ឌិត រមែងត្រេកអរ

*គឺ រមែងត្រេកអរគ្រប់កាល ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនបានជាព្រះអរិយបុគ្គល មាន ព្រះសោតាបន្នជាដើម ដូច្នេះ ។*

ចប់ រឿងព្រះមហាកប្បិន

# ៥. រឿងបណ្ឌិតសាមណេរ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធបណ្ឌិតសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា* ***ឧទកំ ហិ នយន្តិ (ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ)*** *ជាដើម ។*

ព្រះសាស្តាទ្រង់ត្រាស់អនុមោទនាកថា

*បានស្តាប់មក ក្នុងអតីតកាល ព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាម* ***កស្សបៈ*** *មានព្រះខីណាស្រពពីរម៉ឺនអង្គជាបរិវារ ស្តេចយាងទៅកាន់ក្រុងពារាណសី ។ មនុស្សទាំងឡាយកំណត់នូវកម្លាំងរៀងៗ ខ្លួន ហើយរួមគ្នា ៨ នាក់ខ្លះ ១០ នាក់ខ្លះ ថ្វាយអាគន្តុកទាន ។*

*ថ្ងៃមួយ ក្នុងកាលស្រេចភត្តកិច្ចហើយ ព្រះសាស្តាទ្រង់ធ្វើអនុមោទនាយ៉ាងនេះថា "ម្នាលឧបាសក និងឧបាសិកាទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ គិតថា យើងនឹងឲ្យទេយ្យធម៌របស់ខ្លួនប៉ុណ្ណោះ រមែងសមគួរ ប្រយោជន៍អ្វីដោយការដើរបបួលអ្នកដទៃ" ដូច្នេះហើយ ទើបឲ្យទានដោយខ្លួនឯងប៉ុណ្ណោះ មិនបានដើរបបួលអ្នកដទៃ បុគ្គលនោះរមែងបាននូវភោគសម្បត្តិ ប៉ុន្តែមិនមានបរិវារសម្បត្តិក្នុងទីដែលខ្លួនកើតហើយៗ បុគ្គលខ្លះ បបួលអ្នកដទៃឲ្យធ្វើ តែមិនធ្វើដោយខ្លួនឯង បុគ្គលនោះ រមែងបានបរិវារសម្បត្តិ តែមិនមានភោគសម្បត្តិក្នុងទីដែលខ្លួនកើតៗ បុគ្គលខ្លះ មិនឲ្យដោយខ្លួនឯងផង ទាំងមិនបាន*

បបួលអ្នកដទៃផង បុគ្គលនោះ រមែងមិនមានភោគសម្បត្តិផង បរិវារសម្បត្តិផង រស់នៅដោយការស៊ីដែលក្នុងទីដែលខ្លួនកើតហើយ បុគ្គលខ្លះ ធ្វើទានដោយខ្លួនឯងផង បបួលអ្នកដទៃឲ្យធ្វើផង បុគ្គលនោះ លុះកើតក្នុងទីណាៗ រមែងមានភោគសម្បត្តិផង បរិវារសម្បត្តិផង ។

## អ្នកជ្រះថ្លាក្នុងអនុមោទនាកថា

បុរសដែលជាបណ្ឌិតម្នាក់ ឈរនៅក្នុងទីជិតនោះ បានស្ដាប់អនុមោទនាកថានោះហើយ គិតថា “ឥឡូវនេះ យើងនឹងធ្វើតាមដែលសម្បត្តិទាំងពីរឲ្យមានដល់យើង” ។ គេថ្វាយបង្គំព្រះសាស្ដាហើយ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គមេត្តាទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែក” ។

ព្រះសាស្ដា. ត្រូវការភិក្ខុប៉ុន្មានអង្គ ?

បណ្ឌិត. បពិត្រព្រះអង្គដ៏ចម្រើន បរិវាររបស់ព្រះអង្គមានប៉ុន្មាន ?

ព្រះសាស្ដា. មានភិក្ខុពីរម៉ឺនរូប ។

បណ្ឌិត. បពិត្រព្រះអង្គដ៏ចម្រើន ថ្ងៃស្អែកនេះ សូមព្រះអង្គព្រមទាំងភិក្ខុទាំងអស់ មេត្តាទទួលភិក្ខារបស់ខ្ញុំព្រះអង្គ ។

ព្រះសាស្ដាទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ គេចូលទៅកាន់ស្រុកហើយ ដើរប្រាប់បុណ្យថា “ម៉ែ និងពុកទាំងឡាយ ខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទុក (ដើម្បីទទួលភិក្ខា) ក្នុងថ្ងៃស្អែកនេះ អ្នកទាំងឡាយចូរប្រគេនភិក្ខាដល់ភិក្ខុប្រមាណប៉ុន្មាន តាមដែលខ្លួនអាចប្រព្រឹត្តទៅបានចុះ” ។

កាលជនទាំងឡាយកំណត់នូវកម្លាំងរបស់ខ្លួនៗ ហើយ ពោលថា "ពួកយើងនឹងទទួលភិក្ខុ ១០ រូប, ពួកយើងនឹងទទួល ភិក្ខុ ២០, ពួកយើង ១០០ រូប, ពួកយើង ៥០០ រូប, ដូច្នេះហើយ ក៏សរសេរឈ្មោះរបស់មនុស្សទាំងអស់នោះទុកក្នុងបញ្ជី តាំងពីដើមមក ។

បុរសក្រីក្រម្នាក់ត្រេកអរទទួលភិក្ខុមួយរូប

ក៏ក្នុងសម័យនោះ ក្នុងក្រុងនោះមានបុរសម្នាក់ឈ្មោះថា មហាទុគ្គតៈ ព្រោះគាត់ជាមនុស្សក្រយ៉ាងក្រៃលែង ។ បុរសដែលជាបណ្ឌិតនោះ ឃើញមហាទុគ្គតបុរសនោះមកចំពោះមុខ ក៏ប្រាប់ថា "នែមហាទុគ្គតៈសម្លាញ់ ខ្ញុំបាននិមន្តភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទុកដើម្បីឆាន់ក្នុងថ្ងៃស្អែកនេះ ថ្ងៃស្អែកនេះ អ្នកក្រុងនឹងថ្វាយទានជាពួកៗ អ្នកត្រូវការភិក្ខុប៉ុន្មានអង្គ?"

មហាទុគ្គតៈ. អ្នកដ៏ចម្រើន ខ្ញុំត្រូវការភិក្ខុមកធ្វើអ្វី? ព្រោះថា សេចក្តីត្រូវការភិក្ខុនោះ ជារបស់បុគ្គលអ្នកមានទ្រព្យ ចំណែកខ្ញុំ សូម្បីត្រឹមតែអង្ករមួយនាឡិសម្រាប់ដាំបបរក្នុងថ្ងៃស្អែកនេះមិនទាន់មានផង ខ្ញុំធ្វើការស៊ីឈ្នួលគេចិញ្ចឹមជីវិតមួយថ្ងៃរស់មួយថ្ងៃ តើខ្ញុំត្រូវការភិក្ខុមកធ្វើអ្វី ។

ធម្មតាបុគ្គលអ្នកបបួលគេ ជាអ្នកឈ្លាសវៃ ។ ព្រោះដូច្នោះ បុរសដែលជាបណ្ឌិតនោះ សូម្បីមហាទុគ្គតបុរសនោះពោលថា "មិនមាន" ក៏មិននៅស្ងៀម បានពោលតទៅទៀតថា "ម្នាលមហាទុគ្គតៈ មនុស្សជាច្រើនក្នុងក្រុងនេះ បរិភោគភោជនយ៉ាងប្រណីត ស្លៀកដណ្តប់សំពត់សាច់ដ៏ម៉ដ្ឋ ប្រដាប់

ដោយគ្រឿងអាភរណៈផ្សេងៗ ដេកលើទីដេកដ៏មានសិរី រមែងសោយសុខក្នុងគំនរទ្រព្យសម្បត្តិ ចំណែកអ្នកធ្វើការស៊ីឈ្នួលគេពេញមួយថ្ងៃ សូម្បីវត្ថុដែលគ្រាន់តែញ៉ាំងផ្ទៃឲ្យពេញ មិនមានផង បើដូច្នេះ អ្នកមិនទាន់ដឹងខ្លួនថា យើងកើតមកជាមនុស្សក្រីក្រតោកយ៉ាកលំបាកយ៉ាងនេះ ព្រោះមិនបានធ្វើបុណ្យអ្វីៗ ទុក ក្នុងកាលមុនទេឬ" ។

មហាទុគ្គតៈ. អ្នកដ៏ចម្រើន ខ្ញុំដឹង ។

បណ្ឌិត. ចុះបើអ្នកដឹងហើយ ហេតុអ្វីទើបអ្នកមិនធ្វើបុណ្យ អ្នកនៅក្មេង មានកម្លាំងបរិបូណ៌ អ្នកធ្វើការស៊ីឈ្នួលគេ ហើយឲ្យទានតាមកម្លាំងរបស់ខ្លួន មិនគួរឬ ។

មហាទុគ្គតបុរស កាលបុរសជាបណ្ឌិតនោះពោល ឲ្យដល់នូវសេចក្តីសង្វេគហើយ ទើបនិយាយថា "អ្នកដ៏ចម្រើន សូមលោកចុះភិក្ខុក្នុងបញ្ជីឲ្យខ្ញុំមួយអង្គចុះ" ។ បុរសជាបណ្ឌិតគិតថា "ភិក្ខុមួយអង្គ ចាំបាច់ចុះក្នុងបញ្ជីធ្វើអ្វី" ដូច្នេះ ក៏មិនបានចុះក្នុងបញ្ជី ។

ចំណែកមហាទុគ្គតៈទៅដល់ផ្ទះហើយ ក៏និយាយនឹងភរិយាថា "ម្នាលនាង ថ្ងៃស្អែកនេះ អ្នកក្រុងគេចាត់ចែងកត្តដើម្បីប្រគេនភិក្ខុសង្ឃជាពួកៗ សូម្បីខ្ញុំក៏ត្រូវអ្នកបបួលប្រាប់ថា ចូរប្រគេនភិក្ខាដល់ភិក្ខុ ១ រូប ពួកយើងនឹងប្រគេនភិក្ខាចំពោះភិក្ខុ ១ រូប ថ្ងៃស្អែកនេះ" ។

គ្រានោះ ភរិយារបស់មហាទុគ្គតៈ មិនបាននិយាយថា "ពួកយើងជា

អ្នកក្រ នាយទទួលពាក្យរបស់គេធ្វើអ្វី?” ត្រឡប់ជាពោលថា “នាយ អ្នកធ្វើនេះប្រពៃហើយ កាលពីមុនយើងមិនបានឲ្យអ្វីៗ ទើបជាតិនេះយើងកើតជាអ្នកក្រ យើងទាំងពីរនាក់ស៊ីឈ្នួលគេហើយ នឹងថ្វាយភិក្ខាដល់ភិក្ខុមួយរូប” ។ ទាំងពីរនាក់ស្វាមីភរិយា បានចេញទៅកាន់ទីធ្វើការងារ ។ មហាសេដ្ឋីឃើញមហាទុគ្គតៈហើយ សួរថា “ម្នាលមហាទុគ្គតៈ អ្នកដើររកការងារធ្វើឬ?” ។

មហាទុគ្គតៈ. បាទ ពិតមែនហើយ ។

មហាសេដ្ឋី. នឹងធ្វើកិច្ចការងារអ្វី ។

មហាទុគ្គតៈ. ស្រេចតែលោកឲ្យធ្វើ ។

មហាសេដ្ឋីពោលថា “បើដូច្នោះ ល្អហើយ ពីព្រោះថ្ងៃស្អែកនេះ យើងនិមន្តភិក្ខុសង្ឃ ២-៣ រយអង្គ ដើម្បីឆាន់ក្នុងផ្ទះរបស់យើង អ្នកចូរមកពុះឧសឲ្យយើងចុះ” ហើយក៏យកកាំបិត និងពូថៅមកឲ្យមហាទុគ្គតៈ ។ មហាទុគ្គតៈចងក្បិនយ៉ាងមាំហើយ ពុះឧសយ៉ាងស្វាហាប់ ដាក់កាំបិតចាប់ពូថៅ ដាក់ពូថៅចាប់កាំបិត ។

លំដាប់នោះ សេដ្ឋីសួរមហាទុគ្គតៈថា “ម្នាលមហាទុគ្គតៈ ថ្ងៃនេះ អ្នកខំប្រឹងធ្វើកិច្ចការងារខ្លាំងម្ល៉េះ មានហេតុអ្វីឬ?” ។

មហាទុគ្គតៈ. នាយ ខ្ញុំអង្គាសភិក្ខុមួយរូប ។

សេដ្ឋីស្តាប់ពាក្យនោះហើយ មានចិត្តជ្រះថ្លា គិតថា “គួរឲ្យអស្ចារ្យហ្ន៎ មហាទុគ្គតៈនេះ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ” គេមិនមាននូវសេចក្តី

ព្រងើយកន្តើយដោយគិតថា យើងក្រ បាននិយាយថា នឹងធ្វើការងារស៊ីឈ្នួល ដើម្បីអង្គាសភិក្ខុមួយរូប ។

ចំណែកកិរិយារបស់សេដ្ឋី ឃើញកិរិយារបស់មហាទុគ្គតៈហើយ ក៏សួរថា "នាងដ៏ចម្រើន នាងនឹងធ្វើនូវកិច្ចការអ្វី?" កាលនាងឆ្លើយថា "ស្រេចតែប្រើខ្ញុំឲ្យធ្វើ" ក៏ឲ្យចូលទៅកាន់រោងត្បាល់ក្បៀងហើយ យកឧបករណ៍ មានចង្អេរ និងអង្រែជាដើមឲ្យ ។ នាងមានចិត្តរីករាយ ទាំងបុកទាំងអុំអង្ករ ដូចជាគេរាំលោន ។

គ្រានោះ កិរិយាសេដ្ឋីសួរនាងថា "ម្នាលនាងដ៏ចម្រើន ហេតុដូចម្តេចបានជានាងធ្វើការងារដោយចិត្តសប្បាយរីករាយខ្លាំងម៉្លេះ មានហេតុអ្វីឬ?" ។

នាង. នាងម្ចាស់ ពួកនាងខ្ញុំធ្វើការស៊ីឈ្នួលនេះហើយ នឹងអង្គាសភិក្ខុមួយរូប ។

ចំណែកកិរិយារបស់សេដ្ឋី ស្តាប់ពាក្យនោះហើយ ជ្រះថ្លានឹងនាងថា "គួរឲ្យជ្រះថ្លាហ្ន៎ នាងនេះបានធ្វើកម្មដែលគេធ្វើបានដោយកម្រ ។

ក្នុងកាលដែលមហាទុគ្គតៈពុះឧសស្រេចហើយ សេដ្ឋីបញ្ជាឲ្យឲ្យអង្ករស្រូវសាលី ៤ នាឡិ ដោយនិយាយពាក្យថា "នេះជាតម្លៃឈ្នួលរបស់អ្នក" ហើយបញ្ជាឲ្យ ៤ នាឡិទៀត ដោយនិយាយថា "នេះជាចំណែកបន្ថែម" ព្រោះយើងមានសេចក្តីជ្រះថ្លានឹងអ្នក ។

គេទៅដល់ផ្ទះហើយប្រាប់ភរិយាថា "ខ្ញុំទទួលតម្លៃឈ្នួលបានអង្ករស្រូវ

សាលីមក ឯចំណែកនេះទុកសំរាប់តម្លៃម្ហូប ។ នាងចូរកាន់យកវត្ថុទាំងឡាយមានទឹកដោះជូរ ប្រេង និងគ្រឿងទេសដោយតម្លៃឈ្នួលរបស់នាងចុះ" ។

ចំណែកភរិយារបស់សេដ្ឋី បានឲ្យទឹកដោះថ្លាមួយជប ទឹកដោះជូរមួយក្រឡ គ្រឿងទេស និងអង្ករស្រូវសាលីប្រភេទល្អមួយនាឡិដល់ភរិយារបស់មហាទុគ្គតៈ ។ គេទាំងពីរនាក់ប្ដីប្រពន្ធបានអង្ករស្រូវសាលី ៥ នាឡិ ដោយប្រការដូច្នេះ ។ គេទាំងពីរនាក់ មានចិត្តសប្បាយរីករាយ ដោយគិតឃើញថា "យើងបានទេយ្យធម៌ហើយ" ស្អែកឡើងក្រោកតាំងពីព្រលឹម ភរិយានិយាយនឹងមហាទុគ្គតៈថា "នាយ ទៅរកបន្លែមក" មហាទុគ្គតៈក៏បានទៅផ្សារ មិនឃើញមានបន្លែនៅក្នុងទីផ្សារ ក៏ទៅកាន់ស្ទឹង ទាំងចិត្តរីករាយថា "យើងបានប្រគេនភោជនដល់លោកម្ចាស់ដ៏ចម្រើន" ច្រៀងផង ដើរបេះបន្លែផង ។ អ្នកប្រមង់ម្នាក់ដែលឈរបង់សំណាញ់នៅទីនោះ បានដឹងថា "នេះជាសំឡេងរបស់មហាទុគ្គតៈ" ក៏ហៅគេមកសួរថា "អ្នកសប្បាយចិត្តខ្លាំងម្លេះ បេះបន្លែបណ្ដើរស្រែកច្រៀងបណ្ដើរ តើមានហេតុអ្វី?" ។

មហាទុគ្គតៈ. សម្លាញ់ ខ្ញុំដើរបេះបន្លែ ។

អ្នកប្រមង់. បេះធ្វើអ្វី ។

មហាទុគ្គតៈ. ចាត់ចែងភត្តប្រគេនភិក្ខុមួយរូប ។

អ្នកប្រមង់. ឱ! ភិក្ខុណាដែលបានឆាន់បន្លែរបស់អ្នក ។

មហាទុគ្គតៈ. នឹងធ្វើអ្វីបាន សម្លាញ់ ខ្ញុំត្រូវចាត់ចែងភត្តដល់ភិក្ខុមួយ

រូប ដោយចំណែកដែលខ្ញុំបាន ។

អ្នកប្រមង់. បើដូច្នោះ មកទីនេះចុះ ។

មហាទុគ្គតៈ. នឹងធ្វើអ្វី សម្លាញ់ ។

អ្នកប្រមង់. ចូរធ្វើត្រីទាំងនេះឲ្យជាត្រណោត មានតម្លៃមួយបាទខ្លះ កន្លះបាទខ្លះ មួយកហាបណៈខ្លះ ។ មហាទុគ្គតៈក៏បានធ្វើយ៉ាងនោះ ។

អ្នកក្រុងទិញត្រីដែលមហាទុគ្គតៈធ្វើជាត្រណោតៗ យកទៅចាត់ចែងកត្តប្រគេនភិក្ខុដែលខ្លួនបាននិមន្តហើយ ។ កាលគេកំពុងធ្វើត្រីឲ្យជាត្រណោតនោះ ក៏ដល់វេលាភិក្ខាចារ ។ គេកំណត់វេលាហើយ ពោលថា "សម្លាញ់ ខ្ញុំទៅផ្ទះហើយ ព្រោះពេលនេះ ជាវេលាដែលភិក្ខុនិមន្តមក" ។

អ្នកប្រមង់. តើត្រណោតត្រីនៅមានទេ ។

មហាទុគ្គតៈ. សម្លាញ់ មិនមានទេ អស់ហើយ ។

អ្នកប្រមង់. បើដូច្នោះ ត្រីឆ្អិន ៤ ដែលខ្ញុំកប់ក្នុងដីខ្សាច់ ទុកដើម្បីខ្លួន បើអ្នកត្រូវការចាត់ចែងកត្តប្រគេនភិក្ខុ ចូរកាន់យកត្រីទាំងនោះចុះ ពោលដូច្នេះហើយ ក៏បានឲ្យត្រីទាំងនោះដល់មហាទុគ្គតៈ ។

មហាទុគ្គតៈចានថ្វាយទានចំពោះព្រះពុទ្ធ

ក៏ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញមហាទុគ្គតៈចូលក្នុងសំណាញ់ គឺ ព្រះញាណរបស់ព្រះអង្គ ទ្រង់រំពឹងថា "ទីងមានហេតុអ្វីកើតឡើងហ្ន៎" ទ្រង់ព្រះតម្រិះថា មហាទុគ្គតៈគិត

ថា នឹងប្រគេនភត្តដល់ភិក្ខុមួយរូប ទើបធ្វើការស៊ីឈ្នួលជាមួយប្រពន្ធ កាល ពីម្សិល គេនឹងបានភិក្ខុរូបណាហ្ន៎?" ទើបទ្រង់ពិចារណាថា "មនុស្សទាំងឡាយ នឹងនាំភិក្ខុទៅតាមឈ្មោះ ដែលចុះក្នុងបញ្ជីហើយ ឲ្យគង់ក្នុងផ្ទះរៀងៗ ខ្លួន វៀរ តថាគតចេញហើយ មហាទុគ្គតៈនឹងមិនបានភិក្ខុដទៃឡើយ ។ បានឮថា ព្រះ ពុទ្ធទាំងឡាយ ទ្រង់តែងតែធ្វើសេចក្តីអនុគ្រោះចំពោះអ្នកក្រ ។ ព្រោះដូច្នោះ ព្រះសាស្តាទ្រង់ធ្វើសរីរកិច្ចពីព្រលឹមហើយ ស្តេចចូលកាន់ព្រះគន្ធកុដិ ទ្រង់ ប្រថាប់គង់ដោយព្រះតម្រិះថា "នឹងសង្គ្រោះមហាទុគ្គតៈ" ។ ក្នុងកាលមហា-ទុគ្គតៈកំពុងតែកាន់ត្រីដើរទៅកាន់ផ្ទះ បណ្ឌុកម្ពលសិលាសនៈរបស់សក្កទេវ-រាជក៏សម្តែងអាការក្តៅ ។ សក្កទេវរាជទ្រង់ពិចារណាថា "មានហេតុអ្វីហ្ន៎?" ទ្រង់ត្រិះរិះថា "ពីថ្ងៃម្សិល មហាទុគ្គតៈបានធ្វើការស៊ីឈ្នួលជាមួយនឹងប្រពន្ធ របស់ខ្លួន ដោយតាំងចិត្តថា នឹងប្រគេនភិក្ខាចំពោះភិក្ខុមួយរូប តើគេនឹងបាន ភិក្ខុរូបណាហ្ន៎?" ទ្រង់ជ្រាបថា "ភិក្ខុដទៃមិនមានសម្រាប់គេទេ តែព្រះសាស្តា ទ្រង់ប្រថាប់គង់ក្នុងព្រះគន្ធកុដិ ដោយតាំងព្រះទ័យថា នឹងសង្គ្រោះមហាទុគ្គតៈ មហាទុគ្គតៈនឹងថ្វាយភត្តដែលមានបន្លែជាម្ជូប ដែលជាអាហាររបស់ខ្លួនប្រចាំ ថ្ងៃ ចំពោះព្រះតថាគត" បើដូច្នោះ យើងគួរទៅកាន់ផ្ទះរបស់មហាទុគ្គតៈ ធ្វើ នាទីជាអ្នកគ្រួ" ដូច្នេះហើយ ក៏ទ្រង់ក្លែងភេទមិនឲ្យនរណាស្គាល់ ស្តេចយាង ទៅកាន់ទីជិតផ្ទះរបស់មហាទុគ្គតៈនោះ ហើយត្រាស់សួរថា "តើមាននរណា ជួលមនុស្សឲ្យធ្វើការទេ?" មហាទុគ្គតៈឃើញសក្កទេវរាជហើយ ក៏សួរថា "ម្នាល

សម្លាញ់ អ្នកនឹងធ្វើការងារអ្វី?" ។

បុរសក្លែងភេទ. នាយ ខ្ញុំចេះវិជ្ជាគ្រប់យ៉ាង ឈ្មោះថាវិជ្ជាការណាៗ ដែលខ្ញុំមិនចេះ មិនមានឡើយ សូម្បីការចំអិនបបរ និងកត្តជាដើម ។

មហាទុគ្គតៈ. ម្នាលសម្លាញ់ ពួកខ្ញុំមានសេចក្តីត្រូវការ ដោយការងាររបស់អ្នកដែរ តែមិនទាន់មានថ្លៃឈ្នួលឲ្យអ្នក ។

បុរសក្លែងភេទ. តើលោកត្រូវការធ្វើអ្វី ។

មហាទុគ្គតៈ. សម្លាញ់ ខ្ញុំប្រាថ្នានឹងប្រគេនភិក្ខាដល់ភិក្ខុមួយរូប ខ្ញុំប្រាថ្នាចាត់ចែងបបរ និងកត្តប្រគេនភិក្ខុនោះ ។

បុរសក្លែងភេទ. ប្រសិនបើលោកនឹងប្រគេនភិក្ខាដល់ភិក្ខុ ខ្ញុំមិនត្រូវការថ្លៃឈ្នួលទេ លោកឲ្យបុណ្យដល់ខ្ញុំ មិនគួរឬ ។

មហាទុគ្គតៈ. សម្លាញ់ បើដូច្នោះ ប្រពៃហើយ សូមអញ្ជើញចូលមក ។

សក្កទេវរាជ ស្តេចចូលទៅកាន់ផ្ទះរបស់មហាទុគ្គតៈហើយ ឲ្យមហាទុគ្គតៈនាំអង្ករជាដើមមក ទ្រង់បង្គាប់មហាទុគ្គតៈឲ្យទៅនិមន្តភិក្ខុ ដោយពាក្យថា "អ្នកដ៏ចម្រើន អ្នកចូរទៅនាំភិក្ខុដែលដល់ខ្លួនមក" ។

ចំណែកអ្នកចាត់ចែងទាន បានចាត់ចែងភិក្ខុទៅកាន់ផ្ទះរបស់ពួកជនដទៃៗ តាមឈ្មោះដែលបានចុះក្នុងបញ្ជី ។ មហាទុគ្គតៈទៅកាន់សម្នាក់បុរសនោះហើយនិយាយថា "លោកដ៏ចម្រើន ចូរឲ្យភិក្ខុដែលដល់ខ្ញុំចុះ" បុរសនោះបានសតិក្នុងខណៈនោះ ក៏និយាយថា "ខ្ញុំភ្លេចចាត់ចែងភិក្ខុទុកសម្រាប់អ្នកហើយ"

មហាទុគ្គតៈបានឮដូច្នោះ ក៏មានអាការដូចជាត្រូវគេប្រហារត្រង់ពោះ ដោយលំពែងដ៏មុត ដូច្នោះ ផ្គងដៃឡើង ខ្សឹកខ្សួលពោលរៀបរាប់ថា "ហេតុអ្វីទើបលោកញ៉ាំងខ្ញុំឲ្យវិនាសយ៉ាងនេះ ខ្ញុំត្រូវលោកបបួលកាលពីម្សិលជាមួយករិយាក៏បានធ្វើការស៊ីឈ្នួលគេពេញមួយថ្ងៃ ថ្ងៃនេះទៅកាន់មាត់ស្ទឹង ដើម្បីបេះបន្លែតាំងពីព្រឹក សូមលោកចូរឲ្យភិក្ខុដល់ខ្ញុំមួយរូបចុះ" ។

មហាទុគ្គតៈនៅនិមន្តព្រះសាស្តា

មនុស្សទាំងឡាយដែលមកប្រជុំគ្នាហើយ សួរថា "មហាទុគ្គតៈ ហេតុអ្វីបានជាអ្នកខ្សឹកខ្សួលយ៉ាងនេះ" មហាទុគ្គតៈប្រាប់សេចក្តីនោះហើយ មនុស្សទាំងនោះ ក៏សួរអ្នកចាត់ការទានថា "លោកដ៏ចម្រើន រឿងនុ៎ះពិតមែនឬ បានឮថា មហាទុគ្គតៈនេះត្រូវអ្នកបបួលថា ចូរធ្វើការស៊ីឈ្នួលគេ ហើយប្រគេនភិក្ខាចំពោះភិក្ខុមួយរូប ដូច្នេះពិតមែនឬ?" ។

អ្នកចាត់ការ. អ្នកទាំងឡាយ យ៉ាងនុ៎ះពិតមែនហើយ ។

មហាជន. អ្នកចាត់ចែងភិក្ខុមានប្រមាណប៉ុណ្ណេះ ឲ្យទៅអ្នកដទៃ មិនបានឲ្យភិក្ខុដល់មហាទុគ្គតៈត្រឹមតែមួយរូប អ្នកបានធ្វើកម្មធ្ងន់ណាស់ ។ អ្នកចាត់ការទាន អៀនខ្មាសនឹងពាក្យរបស់មហាជន ក៏និយាយនឹងមហាទុគ្គតៈនោះថា "មហាទុគ្គតៈសម្លាញ់ អ្នកកុំញ៉ាំងខ្ញុំឲ្យវិនាសឡើយ ខ្ញុំដល់នូវសេចក្តីលំបាកព្រោះហេតុតែអ្នក មនុស្សទាំងឡាយនាំភិក្ខុដែលបានរៀងៗ ខ្លួន ទៅតាមឈ្មោះដែលបានចុះក្នុងបញ្ជី ឈ្មោះថា អ្នកដែលដកភិក្ខុដែលអង្គុយក្នុង

ផ្ទះរបស់ខ្លួនឲ្យ មិនមាន ចំណែកព្រះសាស្តាទ្រង់ជម្រះព្រះភក្ត្រ ហើយប្រថាប់គង់ក្នុងព្រះគន្ធកុដិទុំះឯង ព្រះរាជា និងព្រះយុវរាជ និងមន្ត្រីធំៗ មានសេនាបតីជាដើម អង្គុយរង់ចាំព្រះសម្មាសម្ពុទ្ធស្តេចចេញអំពីព្រះគន្ធកុដិ ដោយគិតថា យើងនឹងទទួលបាត្ររបស់ព្រះសាស្តា ធម្មតាព្រះពុទ្ធទាំងឡាយ តែងតែទ្រង់អនុគ្រោះបុគ្គលក្រីក្រ អ្នកចូរទៅកាន់វិហារហើយ ក្រាបទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គជាអ្នកទុគ៌តយ៉ាងក្រៃលែង សូមព្រះអង្គមេត្តាអនុគ្រោះខ្ញុំព្រះអង្គផងចុះ បើអ្នកមានបុណ្យ អ្នកនឹងបានដោយពិត" គេក៏បានទៅកាន់វិហារហើយ ។

ព្រះសាស្តាប្រទានបាត្រឱ្យមហាទុគ្គតៈ

លំដាប់នោះ ព្រះរាជា និងព្រះយុវរាជជាដើម ត្រាស់ទៅកាន់មហាទុគ្គតៈថា "មហាទុគ្គតៈ ពេលនេះមិនមែនជាវេលាកត្តទេ អ្នកមកធ្វើអ្វី?" ព្រះរាជាជាដើមពោលយ៉ាងនេះ ព្រោះធ្លាប់ឃើញមហាទុគ្គតៈជាអ្នកស៊ីដែល នៅក្នុងវិហារក្នុងថ្ងៃមុនៗ ។ មហាទុគ្គតៈក្រាបទូលថា "ខ្ញុំព្រះអង្គជ្រាបថា វេលានេះ មិនមែនជាវេលាកត្តទេ តែខ្ញុំព្រះអង្គមកនេះក៏ដើម្បីថ្វាយបង្គំព្រះសាស្តាដែរ" ពោលដូច្នេះហើយ ក៏តម្កល់នូវសីសៈទុកទៀបទ្វារព្រះគន្ធកុដិ ថ្វាយបង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែលទុគ៌តជាងខ្ញុំព្រះអង្គក្នុងព្រះនគរនេះ មិនមានទេ សូមព្រះអង្គទ្រង់ជាទីពឹងដល់ខ្ញុំព្រះអង្គផងចុះ សូមព្រះអង្គ ទ្រង់ធ្វើសេចក្តីអនុគ្រោះដល់ខ្ញុំព្រះអង្គ

ផងចុះ” ព្រះសាស្តាទ្រង់បើកទ្វារព្រះគន្ធកុដិហើយ ទ្រង់នាំបាត្រមកតម្កល់ទុកក្នុងដៃរបស់មហាទុគ្គតៈ ។ មហាទុគ្គតៈមានអាការដូចជាដល់នូវសិរី គឺ ភាពជាស្តេចចក្រពត្តិ ។ ឥស្សរជនទាំងឡាយ មានព្រះរាជា និងព្រះយុវរាជជាដើម ទ្រង់សំឡឹងមើលព្រះភក្ត្រគ្នាទៅវិញទៅមក ។

ពិតណាស់ បុគ្គលណាៗ ឈ្មោះថា អាចដើម្បីនឹងទទួលបាត្រ ដែលព្រះសាស្តាប្រទានឲ្យមហាទុគ្គតៈ ដោយអំណាចភាពជាធំ រមែងមិនមាន ។ បានត្រឹមតែពោលយ៉ាងនេះថា “ម្នាលមហាទុគ្គតៈ អ្នកចូរឲ្យបាត្ររបស់ព្រះសាស្តាដល់ពួកយើង ពួកយើងនឹងឲ្យទ្រព្យមានប្រមាណប៉ុណ្ណេះ គឺ មួយពាន់ ឬមួយសែន ដល់អ្នក អ្នកជាមនុស្សទុគ៌ត ចូរទទួលយកទ្រព្យចុះ បាត្រនោះមានប្រយោជន៍អ្វីដល់អ្នក” មហាទុគ្គតៈ ឆ្លើយថា “បពិត្រមហារាជ ខ្ញុំព្រះអង្គមិនឲ្យបុគ្គលណាទាំងអស់ ខ្ញុំព្រះអង្គមិនត្រូវការទ្រព្យទេ ខ្ញុំព្រះអង្គប្រាថ្នាតែថ្វាយភត្តចំពោះព្រះសាស្តាប៉ុណ្ណោះ” ។ ជនទាំងឡាយដ៏សេស អង្វរគេមិនបានបាត្រ ក៏ត្រឡប់វិញទៅ ។ ចំណែកព្រះរាជា ទ្រង់ព្រះចិន្តាថា “មហាទុគ្គតៈនេះ សូម្បីត្រូវយើងលួងលោមដោយទ្រព្យ ក៏មិនព្រមឲ្យបាត្រព្រះសាស្តាមកយើង បុគ្គលណាៗ ក៏មិនអាចទទួលបាត្រ ដែលព្រះសាស្តាទ្រង់ប្រទានដោយព្រះហស្តព្រះអង្គបានដែរ ទេយ្យធម៌របស់មហាទុគ្គតៈនេះ មានប្រមាណប៉ុនណាទៅ? ក្នុងកាលដែលមហាទុគ្គតៈនេះថ្វាយទេយ្យធម៌ស្រេចហើយ យើងនឹងនាំព្រះសាស្តាទៅកាន់រាជដំណាក់ ថ្វាយអាហារដែលគេចាត់ចែងទុកសម្រាប់យើង”

ដូច្នេះហើយ ក៏បានយាងទៅតាមព្រះសាស្តាដែរ ។

ព្រះសាស្តាស្តេចយាងនៅកាន់ផ្ទះរបស់មហាទុគ្គតៈ

ឯសក្កទេវរាជចាត់ចែងអាហារ មានបបរ បាយ និងបន្លែជាដើម ក្រាលអាសនៈដ៏សមគួរដល់ការប្រថាប់របស់ព្រះសាស្តាហើយ គង់រង់ចាំមើលផ្លូវព្រះសាស្តា ។ មហាទុគ្គតៈយាងព្រះសាស្តាទៅដល់ផ្ទះហើយ ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សូមស្តេចយាងចូលចុះ" ។ ក៏ផ្ទះរបស់មហាទុគ្គតៈ ទាបអ្នកដែលមិនឱន មិនអាចចូលទៅបានទេ តែធម្មតា ព្រះពុទ្ធទាំងឡាយ កាលស្តេចចូលទៅកាន់ផ្ទះ មិនចាំបាច់ឱនចូលទៅទេ ត្បិតថា កាលស្តេចចូលទៅកាន់ផ្ទះ ផែនដីដ៏ធំរមែងផតចុះទៅខាងក្រោម ឬផ្ទះរមែងខ្ពស់ឡើង ។ ហេតុដ៏អស្ចារ្យនេះជាផលនៃទាន ដែលព្រះពុទ្ធទាំងឡាយទ្រង់ថ្វាយដោយល្អហើយ ។ ក្នុងវេលាដែលព្រះសម្មាសម្ពុទ្ធ ព្រះអង្គស្តេចយាងចេញហើយ វត្ថុគ្រប់យ៉ាងរមែងតាំងនៅដូចដើម ព្រោះហេតុនោះ ព្រះសាស្តាស្តេចយាងចូលទៅកាន់ផ្ទះរបស់មហាទុគ្គតៈ ដោយមិនចាំបាច់ឱនទេ ហើយទ្រង់ប្រថាប់គង់លើអាសនៈដែលសក្កទេវរាជក្រាលទុក ។ កាលព្រះសាស្តាទ្រង់ប្រថាប់ហើយ ព្រះរាជាទ្រង់ត្រាស់ថា "ម្នាលមហាទុគ្គតៈ អ្នកមិនឲ្យបាត្ររបស់ព្រះសាស្តា ដល់ពួកយើងដែលជាអ្នកអង្វរហើយអង្វរទៀត ពួកយើងសូមមើលនូវគ្រឿងសក្ការៈដែលអ្នកចាត់ចែងទុកដើម្បីថ្វាយសាស្តានោះមើល តើដូចម្តេចទៅ" គ្រានោះសក្កទេវរាជបើកភាជនៈយាគូ និងកត្តបន្លាញ ព្រះរាជា ។ ក្លិនគ្រឿងអប់កត្ត

ទាំងនោះ បានផ្សាយទូទៅពាសពេញព្រះនគរ ហើយតាំងនៅ ។ ព្រះរាជាទ្រង់ទតមើលនូវយាគូជាដើមហើយ ក្រាបទូលព្រះមានព្រះភាគថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតថា ទេយ្យធម៌របស់មហាទុគ្គតៈនេះដូចម្តេចទៅ កាលមហាទុគ្គតៈថ្វាយទេយ្យធម៌ហើយ នឹងនាំព្រះអង្គទៅកាន់ផ្ទះ ថ្វាយអាហារដែលគេចាត់ចែងទុកដើម្បីខ្លួន ដូច្នេះហើយ ទើបមកកាន់ទីនេះ អាហារបែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ កាលខ្ញុំព្រះអង្គនៅទីនេះ មហាទុគ្គតៈនឹងត្រូវលំបាក ខ្ញុំព្រះអង្គត្រឡប់ទៅវិញហើយ" ថ្វាយបង្គំព្រះសាស្តាហើយ ក៏ចៀសចេញទៅ ។

## ផ្ទះរបស់មហាទុគ្គតៈពេញដោយកែវ ៧ ប្រការ

ចំណែកសក្កទេវរាជ ថ្វាយយាគូជាដើមចំពោះព្រះសាស្តាដោយគោរព រីឯព្រះសាស្តាទ្រង់ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ក៏ធ្វើអនុមោទនា លុះទ្រង់ធ្វើអនុមោទនារួចហើយ ស្តេចក្រោកឡើងចៀសចេញទៅ ។ សក្កទេវរាជបានឲ្យសញ្ញាដល់មហាទុគ្គតៈ ។ មហាទុគ្គតៈទទួលយកបាត្រអំពីព្រះហស្តរបស់សាស្តាហើយ ចេញទៅតាមព្រះសាស្តា ។ សក្កទេវរាជ មុននឹងស្តេចត្រឡប់ទ្រង់ប្រថាប់ឈរនៅត្រង់ទ្វារផ្ទះរបស់មហាទុគ្គតៈ ទ្រង់សម្លឹងមើលទៅអាកាសហើយញ៉ាំងភ្លៀងរតនៈ ៧ ប្រការ ឲ្យធ្លាក់ចុះអំពីអាកាស ឲ្យពេញភាជនៈទាំងអស់ក្នុងផ្ទះរបស់គេ ហើយញ៉ាំងផ្ទះឲ្យពេញដោយរតនៈ ៧ ប្រការ ។ ក្នុងផ្ទះរបស់គេមិនមានកន្លែងទំនេរ ភរិយារបស់គេបានដឹកដៃពួកក្មេង ចេញទៅ

ឈរខាងក្រៅផ្ទះ ។ គេយាងព្រះសាស្តាទៅកាន់វិហារហើយ ត្រឡប់មកវិញ ឃើញពួកក្មេងៗ ឈរនៅខាងក្រៅផ្ទះ ក៏សួរថា "មានហេតុអ្វី" ភរិយារបស់គាត់បានឆ្លើយប្រាប់ថា "នាយ ផ្ទះរបស់យើងពេញទៅដោយកែវ ៧ ប្រការ មិនមានផ្លូវចូលទៅទេ" ។ គេគិតថា "ទានរបស់យើងឲ្យផលក្នុងថ្ងៃនេះហើយ" គិតដូច្នេះហើយ ក៏ទៅកាន់ព្រះរាជដំណាក់ ថ្វាយបង្គំព្រះរាជា កាលព្រះរាជាត្រាស់សួរថា "ម្នាលអ្នកដ៏ចម្រើន អ្នកមកធ្វើអ្វី" ទើបក្រាបទូលថា "បពិត្រមហារាជ ផ្ទះរបស់ខ្ញុំព្រះអង្គពេញទៅដោយកែវ ៧ ប្រការ សូមព្រះអង្គទ្រង់កាន់យកទ្រព្យនោះចុះ" ។ ព្រះរាជាទ្រង់ព្រះតម្រិះថា "គួរឲ្យអស្ចារ្យណាស់ ទានដែលមហាទុគ្គតៈថ្វាយចំពោះព្រះពុទ្ធ ដល់ទីបំផុតក្នុងថ្ងៃនេះហើយ" លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ត្រាស់ទៅកាន់មហាទុគ្គតៈថា "អ្នកត្រូវការអ្វី?"

មហាទុគ្គតៈ. មហារាជ សូមព្រះអង្គទ្រង់ប្រទានរទេះ ១ ពាន់ ដើម្បីនាំទ្រព្យនោះមក ។

ព្រះរាជាទ្រង់បញ្ជូនរទេះ ១.០០០ ទៅ ដើម្បីនាំទ្រព្យនោះ មកចាក់គរត្រង់ព្រះលានហ្លួង ។ គំនរទ្រព្យមានកំពស់ប្រមាណមួយដើមត្នោត ។ ព្រះរាជាត្រាស់បង្គាប់ឲ្យអ្នកក្រុងប្រជុំគ្នា ហើយត្រាស់សួរថា "ក្នុងក្រុងនេះ មាននរណាមានទ្រព្យប្រមាណប៉ុណ្ណេះទេ?"

អ្នកក្រុង. មិនមានទេ ព្រះអង្គ ។

ព្រះរាជា. តើយើងគួរធ្វើយ៉ាងណា? ទើបសមគួរដល់អ្នកមានទ្រព្យ

ច្រើនយ៉ាងនេះ ។

អ្នកក្រុង. ព្រះអង្គ គួរតែងតាំងជាសេដ្ឋី ។

ព្រះរាជា ទ្រង់ព្រះរាជទានគ្រឿងសក្ការៈជាច្រើនដល់មហាទុគ្គតៈហើយ តែងតាំងមហាទុគ្គតៈឲ្យទៅជាសេដ្ឋី ។ គ្រានោះ ព្រះរាជាត្រាស់ប្រាប់នូវទីតាំងផ្ទះរបស់សេដ្ឋីម្នាក់ក្នុងកាលមុនដល់មហាទុគ្គតៈហើយ ត្រាស់ថា "អ្នកចូរឲ្យគេឆ្ការគុម្ពោតដែលកើតទីនោះ ហើយសាងផ្ទះនៅទីនេះចុះ" ។ កាលមហាទុគ្គតៈឲ្យគេជម្រះទីនោះ ធ្វើផ្ទៃដីឲ្យរាបស្មើ ឆ្នាំងនៃកំណប់ទ្រព្យទាំងឡាយបានផុសឡើងជាប់គ្នា ។ មហាទុគ្គតៈក៏ក្រាបទូលព្រះរាជា ព្រះរាជាក៏ត្រាស់ថា "ឆ្នាំងនៃកំណប់ទ្រព្យកើតឡើង ព្រោះអាស្រ័យបុណ្យរបស់អ្នកហើយ អ្នកចូរកាន់យកចុះ" ។

### មហាទុគ្គតៈស្លាប់ហើយ បដិសន្ធិក្នុងក្រុងសាវត្ថី

មហាទុគ្គតសេដ្ឋីធ្វើផ្ទះហើយ បានថ្វាយមហាទានចំពោះ ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ។ ក្រោយអំពី ៧ ថ្ងៃនោះមក គាត់បានបំពេញបុណ្យរហូតអស់ជីវិត ក្នុងទីបំផុតនៃអាយុ គឺ ក្រោយអំពីចុតិ ក៏បានបដិសន្ធិក្នុងទេវលោក សោយសម្បត្តិទិព្វអស់មួយចន្លោះព្រះពុទ្ធ ក្នុងពុទ្ធុប្បាទកាលនេះ ចុតិចាកទេវលោកហើយ បដិសន្ធិក្នុងផ្ទៃនៃធីតាច្បងក្នុងត្រកូលឧបដ្ឋាករបស់ព្រះសារីបុត្រ ក្នុងក្រុងសាវត្ថី ។

គ្រានោះ មាតាបិតារបស់នាងដឹងថា នាងមានគភ៌ ក៏បានឲ្យគ្រឿងរក្សា

គតិ ។ ក្នុងសម័យដទៃ នាងចាញ់គភ៌បែបនេះថា "ឱ! ធ្វើដូចម្ដេចហ្ន៎ យើងគប្បីបានប្រគេនរសត្រីធ្ងិនចំពោះភិក្ខុ ៥០០ រូប ដែលមានព្រះសារីបុត្រជាប្រធាន និងស្លៀកសំពត់ដែលជ្រលក់ដោយទឹកចត់ អង្គុយក្នុងទីបំផុតនៃអាសនៈបរិភោគភត្ត ដែលជារបស់សល់អំពីភិក្ខុទាំងនោះ" ។ នាងប្រាប់រឿងនោះដល់មាតាបិតាហើយ មាតាបិតារបស់នាងក៏បានធ្វើតាមសេចក្ដីប្រាថ្នារបស់នាង ។ ការចាញ់គភ៌ក៏បានស្ងប់រម្ងាប់ទៅ ។ តមក មានពិធីមង្គល ៧ ដងទៀត មាតាបិតារបស់នាងក៏បានប្រគេនភត្តដល់ភិក្ខុ ៥០០ រូប មានព្រះធម្មសេនាបតីសារីបុត្រជាប្រធាន ដោយរសត្រីធ្ងិនដូចគ្នាដែរ ។

គប្បីជ្រាបរឿងទាំងអស់ តាមន័យដូចដែលបានពោលហើយ ក្នុងរឿងតិស្សកុមារនោះឯង ។

## ទារកចេញបួសជាសាមណេរ

ក្នុងថ្ងៃដែលដាក់ឈ្មោះឲ្យទារកនោះ កាលមាតារបស់ទារកនោះពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មេត្តាឲ្យសិក្ខាបទទាំងឡាយដល់ទាសៈរបស់លោកម្ចាស់ចុះ" ព្រះថេរៈក៏សួរថា "ក្មេងនេះឈ្មោះអ្វី" មាតារបស់ក្មេងឆ្លើយថា "លោកម្ចាស់ដ៏ចម្រើន ចាប់តាំងអំពីទារកនេះបដិសន្ធិក្នុងផ្ទៃកាលណា មនុស្សល្ងីល្ងើក្ដី គ.ថ្លង់ក្ដី ក៏ត្រឡប់ទៅជាមនុស្សឈ្លាសវៃ ព្រោះដូច្នោះ បុត្ររបស់ខ្ញុំម្ចាស់ គប្បីមានឈ្មោះថា **បណ្ឌិតកុមារ** ចុះ" ។ ព្រះថេរៈក៏បានឲ្យសិក្ខាបទទាំងឡាយហើយ ។ តាំងអំពីថ្ងៃដែលបណ្ឌិតកុមារកើតមក

ការគិតបានកើតឡើងដល់មាតារបស់គេថា "យើងនឹងមិនទម្លាយអធ្យាស្រ័យបុត្ររបស់យើងឡើយ" ។ ក្នុងវេលាដែលទារកនោះមានអាយុបាន ៧ ខួប ក៏បានពោលទៅកាន់មាតាថា "អ្នកម៉ែ ខ្ញុំនឹងបួសក្នុងសម្នាក់ព្រះថេរៈ" ។ នាងពោលថា "បាន! កូនសំឡាញ់ ម៉ែក៏បានគិតទុកហើយយ៉ាងនេះថា នឹងមិនទម្លាយអធ្យាស្រ័យរបស់កូនទេ" ដូច្នេះ ក៏បាននិមន្តព្រះថេរៈឲ្យឆាន់ ហើយពោលថា "លោកម្ចាស់ដ៏ចម្រើន ទាសៈរបស់លោកម្ចាស់ប្រាថ្នានឹងបួស ខ្ញុំព្រះករុណានឹងនាំក្មេងនេះទៅកាន់វិហារក្នុងវេលាល្ងាច" និមន្តព្រះថេរៈទៅហើយត្រឡប់មកវិញ ឲ្យពួកញាតិប្រជុំគ្នា ហើយពោលថា "ម្នាលអ្នកដ៏ចម្រើនទាំងឡាយ ថ្ងៃនេះពួកយើងនឹងធ្វើនូវសក្ការៈ ដែលយើងគួរធ្វើដល់បុត្ររបស់យើងក្នុងវេលានៅជាគ្រហស្ថ ក្នុងថ្ងៃនេះឯង" ដូច្នេះហើយ ក៏បានឲ្យគេធ្វើសក្ការៈយ៉ាងច្រើន ហើយនាំបណ្ឌិតកុមារនោះទៅកាន់វិហារ ប្រគល់ឲ្យព្រះថេរៈថា "សូមលោកម្ចាស់បំបួសក្មេងនេះចុះ" ។ ព្រះថេរៈក៏ប្រាប់អំពីការបួស ជាកិច្ចដែលធ្វើបានដោយលំបាក កាលទារកនោះអះអាងថា "ខ្ញុំព្រះករុណានឹងធ្វើតាមឱវាទរបស់លោកម្ចាស់" ទើបពោលថា "បើដូច្នោះ អ្នកចូរមកចុះ" ញ៉ាំងសក់ទាំងឡាយរបស់ទារកនោះឲ្យទទឹក ប្រាប់តចបញ្ចកកម្មដ្ឋាន ហើយក៏បានបំបួសក្មេងនោះ ។ សូម្បីមាតាបិតារបស់បណ្ឌិតសាមណេរ ក៏នៅក្នុងវិហារនោះអស់ ៧ ថ្ងៃ ថ្វាយទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយរសត្រីផ្តិតតែម្យ៉ាង ក្នុងថ្ងៃទី ៧ វេលាល្ងាចទើបបានត្រឡប់ទៅផ្ទះវិញ ។

ក្នុងថ្ងៃទី ៨ ព្រះថេរៈបាននាំសាមណេរនោះទៅជាមួយ មិនបានទៅជាមួយពួកភិក្ខុទេ ។ ព្រោះហេតុអ្វី? ព្រោះថា ការស្លៀកដណ្ដប់ចីវរ និងការកាន់បាត្រ ឬឥរិយាបថរបស់សាមណេរនោះ មិនទាន់នាំមកនូវសេចក្ដីជ្រះថ្លានៅឡើយ ម្យ៉ាងទៀត ព្រះថេរៈនៅមានវត្តដែលត្រូវធ្វើក្នុងវិហារ ម្យ៉ាងទៀត ព្រះថេរៈកាលភិក្ខុសង្ឃចូលទៅកាន់ស្រុកហើយ និមន្តទៅទូទាំងវិហារ បោសប្រាស់នូវទីដែលភិក្ខុទាំងឡាយមិនទាន់បានបោស ដងទឹកឆាន់ ទឹកប្រើប្រាស់ ដាក់ក្នុងភាជនៈដែលគ្មានទឹក រៀបចំទុកដាក់គ្រែ តាំងជាដើម ដែលភិក្ខុទាំងឡាយទុកដាក់មិនបានរៀបរយ ទើបចូលទៅកាន់ស្រុកក្រោយភិក្ខុទាំងឡាយ ម្យ៉ាងទៀត ព្រះថេរៈគិតថា កុំឲ្យពួកតិរ្ថីយ៍ដែលចូលមកកាន់វិហារហើយ តិះដៀលថា មើលទីអង្គុយពួកសាវករបស់សមណគោតមចុះ ដូច្នេះហើយ ទើបបានចាត់ចែងវិហារទាំងអស់រួចហើយ ទើបចូលទៅកាន់ស្រុកជាក្រោយ ព្រោះដូច្នោះទើបថ្ងៃនោះ ព្រះថេរៈឲ្យសាមណេរកាន់បាត្រ និងចីវរចូលទៅកាន់ស្រុកក្រោយភិក្ខុទាំងឡាយ ។ សាមណេរ កាលទៅបិណ្ឌបាតជាមួយនឹងព្រះឧបជ្ឈាយ៍ បានឃើញប្រឡាយទឹកមួយដែលនៅតាមផ្លូវ ទើបសួរថា "បពិត្រលោកម្ចាស់ដ៏ចម្រើន តើនេះជាអ្វី?" ។

ព្រះថេរៈ. នេះជាប្រឡាយទឹក សាមណេរ ។

សាមណេរ. លោកម្ចាស់ គេធ្វើអ្វីដោយប្រឡាយទឹកនេះ ។

ព្រះថេរៈ. គេធ្វើប្រឡាយទឹក ទុកសម្រាប់បង្ហូរទឹកអំពីទីដទៃៗ ដើម្បី

ធ្វើស្រែចំការរបស់គេ ។

សាមណេរ. លោកម្ចាស់ តើទឹកមានចិត្តដែរឬទេ ។

ព្រះថេរ:. មិនមានទេ សាមណេរ ។

សាមណេរ. លោកម្ចាស់ ជនទាំងឡាយរមែងបង្ហូរទឹកដែលមិនមានចិត្តបែបនេះ ទៅកាន់ទីដែលខ្លួនប្រាថ្នាបានឬ ។

ព្រះថេរ:. បាន សាមណេរ ។

សាមណេរនោះគិតថា "ប្រសិនបើជនទាំងឡាយបង្ហូរទឹកដែលមិនមានចិត្តបែបនេះ ទៅកាន់ទីដែលខ្លួនប្រាថ្នាហើយៗ ធ្វើការងារបាន ចុះហេតុដូចម្តេច? មនុស្សមានចិត្តពិតៗ មិនអាចដើម្បីធ្វើចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាច ហើយបំពេញសមណធម៌ទៅ?" ។

សាមណេរនោះនិមន្តទៅខាងមុខ ក៏បានឃើញពួកជាងសរ កំពុងយកកូនសររោលភ្លើង ហើយសម្លឹងមើលដោយកន្ទុយភ្នែកដើម្បីពត់ឲ្យត្រង់ ក៏សួរថា "លោកម្ចាស់ ពួកជនទាំងនេះជាអ្វី?" ។

ព្រះថេរ:. ជនទាំងនេះជាជាងធ្វើព្រួញ សាមណេរ ។

សាមណេរ. លោកម្ចាស់ ពួកគេធ្វើអ្វី ។

ព្រះថេរ:. សាមណេរ ពួកគេយកកំណាត់ឈើរោលភ្លើង ហើយពត់ឲ្យត្រង់ធ្វើជាកូនសរ ។

សាមណេរ. លោកម្ចាស់ តើកូនសរនោះ មានចិត្តដែរឬ ។

ព្រះថេរ. មិនមានទេ សាមណេរ ។

សាមណេរនោះគិតថា "ប្រសិនបើមនុស្សទាំងឡាយយកកំណាត់ឈើដែលមិនមានចិត្តពេលភ្លើង ហើយពត់ឲ្យត្រង់ធ្វើជាកូនសរបាន ចុះហេតុអ្វីមនុស្សមានចិត្ត មិនធ្វើចិត្តរបស់ខ្លួនឲ្យប្រព្រឹត្តទៅក្នុងអំណាច ហើយបំពេញសមណធម៌ហ្ន៎" ។

លុះសាមណេរនិមន្តទៅមុខទៀត ក៏ឃើញជនទាំងឡាយកំពុងឈូសឈើធ្វើគ្រឿងសម្ភារៈ មានខ្នងកង់ និងដុំជាដើម ក៏សួរថា "លោកម្ចាស់ ពួកជនទាំងនេះ ជាអ្វី?" ។

ព្រះថេរ. សាមណេរ ជនទាំងនេះជាជាងឈើ ។

សាមណេរ. លោកម្ចាស់ ជនទាំងនេះគេធ្វើអ្វី ។

ព្រះថេរ. សាមណេរ គេយកឈើមកឈូសធ្វើជាកង់រទេះជាដើម ។

សាមណេរ. លោកម្ចាស់ ឈើទាំងនោះ មានចិត្តឬទេ ។

ព្រះថេរ. សាមណេរ មិនមានទេ ។

### សាមណេរត្រឡប់ទៅធ្វើសមណធម៌

គ្រានោះ សាមណេរមានសេចក្តីត្រិះរិះយ៉ាងនេះថា "ប្រសិនបើជនទាំងឡាយ កាន់យកកំណាត់ឈើដែលមិនមានចិត្ត ធ្វើជាកង់រទេះជាដើមបាន ចុះហេតុអ្វី មនុស្សមានចិត្តដែរ មិនធ្វើចិត្តរបស់ខ្លួនឲ្យនៅក្នុងអំណាច ហើយបំពេញសមណធម៌ហ្ន៎" សាមណេរឃើញហេតុនោះហើយ ក៏សួរថា "លោក

ម្ចាស់ ប្រសិនបើលោកម្ចាស់កាន់បាត្រ និងចីវររបស់លោកម្ចាស់បាន ខ្ញុំនឹងត្រឡប់ទៅវិញ” ។ ព្រះថេរៈមិនបានញ៉ាំងចិត្តឲ្យកើតឡើងថា “សាមណេរតូចនេះ បួសអម្បាញ់មិញនេះ តាមយើងមក ហ៊ានពោលយ៉ាងនេះជាមួយនឹងយើង” ត្រឡប់ជាពោលថា “សាមណេរ អ្នកចូរនាំយកបាត្រមកឲ្យយើង” ហើយក៏ទទួលយកបាត្រ និងចីវររបស់ខ្លួន ។ ចំណែកសាមណេរ ថ្វាយបង្គំព្រះឧបជ្ឈាយ៍ហើយ កាលនឹងត្រឡប់ទៅវិញ ក៏បានប្រាប់ថា “លោកម្ចាស់ ប្រសិនបើលោកម្ចាស់នាំយកអាហារមកដើម្បីខ្ញុំព្រះករុណា សូមលោកម្ចាស់នាំយករសនៃត្រីឆ្អិនចុះ ។

ព្រះថេរៈ. យើងនឹងបានក្នុងទីណា សាមណេរ ។

សាមណេរប្រាប់ថា បើមិនបានដោយបុណ្យរបស់លោកម្ចាស់ទេ ក៏នឹងបានដោយបុណ្យរបស់ខ្ញុំព្រះករុណាដែរ ព្រះថេរៈគិតថា “អន្តរាយនឹងគប្បីមានដល់សាមណេរតូច ដែលគង់ខាងក្រៅ” ទើបឲ្យកូនសោទៅសាមណេរ ហើយប្រាប់ថា “សាមណេរ អ្នកបើកទ្វារបន្ទប់របស់ខ្ញុំហើយ ចូលទៅគង់ខាងក្នុងចុះ” ។ សាមណេរក៏បានធ្វើយ៉ាងនោះឯង អង្គុយញ៉ាំងញាណឲ្យប្រព្រឹត្តទៅក្នុងករជកាយរបស់ខ្លួន ហើយពិចារណានូវអត្តភាពនេះ ។

អាសនៈរបស់សក្កទេវរាជក្តៅព្រោះគុណរបស់សាមណេរ

គ្រានោះ អាសនៈរបស់សក្កទេវរាជ សម្តែងនូវអាការក្តៅដោយតេជៈនៃគុណរបស់សាមណេរនោះ ។ សក្កទេវរាជទ្រង់ពិចារណាថា “តើមានហេតុ

អ្វីហ្ន៎?” ទ្រង់ព្រះតម្រិះឃើញថា បណ្ឌិតសាមណេរប្រគេនបាត្រ និងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់ទៅវិញ ដោយតាំងចិត្តថា នឹងបំពេញសមណធម៌ សូម្បីយើងក៏គួរទៅកាន់ទីនោះ លុះទ្រង់ព្រះតម្រិះដូច្នេះហើយ ក៏ទ្រង់ត្រាស់ហៅមហារាជទាំង ៤ មក ហើយត្រាស់ថា “ម្នាលអ្នកដ៏ចម្រើនទាំងឡាយ អ្នកទាំងឡាយចូរទៅដេញបក្សី ដែលធ្វើសំឡេងចចេកចចាចនៅក្នុងព្រៃជិតវិហារ ឲ្យចៀសចេញទៅ ហើយរក្សាដោយជុំវិញ” ត្រាស់ទៅកាន់ចន្ទទេវបុត្រថា “ម្នាលចន្ទ: អ្នកចូរទប់មណ្ឌលព្រះច័ន្ទ” ត្រាស់ទៅកាន់សុរិយទេវបុត្រថា “ម្នាលសុរិយ: អ្នកចូរទប់មណ្ឌលព្រះអាទិត្យ” ដូច្នេះហើយ ព្រះអង្គក៏បានទៅប្រថាប់ឈរដើម្បីការពារសាមណេរនៅក្នុងទីមួយ ក្នុងវិហារសូម្បីតែសំឡេងស្លឹកឈើទុំជ្រុះ ក៏មិនមាន ។ ចិត្តរបស់សាមណេរក៏ជាធម្មជាតិមានអារម្មណ៍តែមួយ ។ សាមណេរពិចារណាអត្តភាពហើយ ក៏បានសម្រេចផល ៣ ក្នុងចន្លោះនៃវេលាកត្តនោះឯង ។ ចំណែកព្រះថេរៈគិតថា “សាមណេរគង់ក្នុងវិហារ យើងនឹងបានភោជនដែលជាទីប្រាថ្នារបស់លោក ក្នុងត្រកូលឯណោះ” ដូច្នេះហើយ ក៏បានទៅកាន់ត្រកូលឧបដ្ឋាកដែលប្រកបដោយសេចក្តីស្រឡាញ់ និងសេចក្តីគោរពមួយ ក៏ក្នុងថ្ងៃនោះ មនុស្សទាំងឡាយ បានត្រៀមគ្រឿងទិន្នជាច្រើន ហើយអង្គុយរង់ចាំមើលផ្លូវព្រះថេរៈ ។ ពួកគេឃើញព្រះថេរៈកំពុងនិមន្តមក ក៏ពោលថា “លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់និមន្តមកនេះជាការល្អណាស់” ហើយក៏និមន្តព្រះថេរៈឲ្យចូលទៅខាងក្នុង ប្រគេនយាគូ និងរបស់ទំពាជាដើម

ហើយបានប្រគេនបិណ្ឌបាតដោយរសត្រីផ្អិន ។ ព្រះថេរៈសម្តែងអាការនឹងចេញទៅ ។ ពួកមនុស្សក៏បានប្រាប់ថា "លោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់និមន្តធាន់ចុះ លោកម្ចាស់នឹងបានកត្តសម្រាប់នាំទៅក្នុងវេលាស្រេចកត្ត-កិច្ចរបស់លោកម្ចាស់" មនុស្សទាំងឡាយក៏បានយកភោជនដែលប្រកបដោយរសត្រីផ្អិន ដាក់ពេញក្នុងបាត្រ ហើយប្រគេនព្រះថេរៈ ។ ព្រះថេរៈគិតថា "សាមណេររបស់យើងឃ្លានហើយ" ក៏បាននិមន្តទៅយ៉ាងប្រញាប់ ។

## ព្រះសាស្តាទ្រង់រក្សាសាមណេរ

ក្នុងថ្ងៃនោះ សូម្បីព្រះសាស្តា ក៏ព្រះអង្គទ្រង់សោយអំពីព្រលឹម ហើយស្តេចចូលទៅកាន់វិហារ ទ្រង់ពិចារណាថា "បណ្ឌិតសាមណេរឲ្យបាត្រ និងចីវរដល់ព្រះឧបជ្ឈាយ៍ ហើយត្រឡប់មកវិញ ដោយតាំងចិត្តថា នឹងបំពេញសមណ-ធម៌ កិច្ចនៃបព្វជិតរបស់សាមណេរសម្រេចហើយ ឬក៏មិនទាន់សម្រេចទេ" ទ្រង់ជ្រាបថា "សាមណេរសម្រេចផល ៣ ហើយ ក៏ទ្រង់ពិចារណាថា ឧប-និស្ស័យនៃព្រះអរហត្តរបស់សាមណេរមានដែរឬទេ" ទ្រង់ឃើញថា "មាន" ទ្រង់ពិចារណាទៀតថា "តើសាមណេរ អាចបានព្រះអរហត្តមុនកត្ត ឬក៏មិនអាច" ក៏ទ្រង់ជ្រាបថា "អាច" ។ គ្រានោះ ព្រះសម្មាសម្ពុទ្ធ ក៏ទ្រង់ត្រិះរិះយ៉ាងនេះថា "សារីបុត្រនាំកត្តមកដើម្បីសាមណេរយ៉ាងប្រញាប់ ដូច្នោះ សារីបុត្រអាចធ្វើអន្តរាយដល់សាមណេរនោះបាន តថាគតនៅត្រង់ទ្វារ" គ្រានោះ តថាគតនឹងសួរបញ្ហាសារីបុត្រ ៤ យ៉ាង កាលសារីបុត្រឆ្លើយបញ្ហាហើយ សាមណេរក៏

បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ដូច្នេះហើយ ក៏ស្តេចយាង ចេញចាកវិហារ ទៅប្រថាប់ឈរនៅក្បែរទ្វារ ត្រាស់សួរបញ្ហាព្រះសារីបុត្រ ដែលនិមន្តមកដល់ ៤ ប្រការ ។ ព្រះថេរៈក៏ឆ្លើយបញ្ហាដែលព្រះសាស្តាទ្រង់ ត្រាស់សួរ ។

បណ្តាបញ្ហានោះ មានបុច្ឆាវិសជ្ជនាដូចតទៅនេះ ៖

បានឮថា ព្រះសាស្តាទ្រង់ត្រាស់សួរព្រះសារីបុត្រថា ម្នាលសារីបុត្រ អ្នកបានអ្វីមក ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន បានអាហារ ។

ព្រះសាស្តា. សារីបុត្រ ដែលឈ្មោះថាអាហារ រមែងនាំអ្វីមក ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន រមែងនាំវេទនាមក ។

ព្រះសាស្តា. សារីបុត្រ វេទនា រមែងនាំអ្វីមក ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន រមែងនាំមកនូវរូប ។

ព្រះសាស្តា. សារីបុត្រ រូប រមែងនាំអ្វីមក ។

ព្រះថេរៈ. បពិត្រព្រះអង្គដ៏ចម្រើន រមែងនាំមកនូវផស្សៈ ។

ក្នុងបញ្ហានោះ មានសេចក្តីអធិប្បាយដូច្នេះ ៖

ពិតណាស់ អាហារដែលបុគ្គលអ្នកស្រេកឃ្លាន បរិភោគហើយ រមែង កម្ចាត់បង់នូវសេចក្តីស្រេកឃ្លានរបស់បុគ្គលនោះ ហើយនាំសុខវេទនាមក ។ កាលសុខវេទនាកើតឡើងដល់បុគ្គលអ្នកមានសេចក្តីសុខ ព្រោះការបរិភោគ

អាហារហើយ វណ្ណសម្បត្តិរមែងមានក្នុងសរីរៈ វេទនា ឈ្មោះថា នាំមកនូវរូប ដោយអាការយ៉ាងនេះ , ក៏បុគ្គលអ្នកមានសុខ នឹងកើតសុខសោមនស្ស ដោយអំណាចរូបដែលកើតអំពីអាហារហើយ ដេកក្តី អង្គុយក្តី ដោយគិតថា ឥឡូវនេះ អស្សាទៈ គឺ សេចក្តីត្រេកអរកើតឡើងដល់យើងហើយ រមែងបាននូវសុខសម្ផស្ស ។

សាមណេរបានសម្រេចព្រះអរហត្តផល

កាលព្រះថេរៈដោះស្រាយបញ្ហាទាំង ៤ ប្រការនេះ យ៉ាងនោះហើយ សាមណេរក៏បានសម្រេចព្រះអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ ចំណែកព្រះសាស្តា ត្រាស់ទៅកាន់ព្រះសារីបុត្រថា "ម្នាលសារីបុត្រ អ្នកចូរយកភត្តទៅឲ្យសាមណេររបស់អ្នកចុះ" ។ ព្រះថេរៈនិមន្តទៅ គោះទ្វារហើយ សាម-ណេរក៏ចេញមក ទទួលបាត្រអំពីព្រះហស្តរបស់ព្រះថេរៈ ដាក់ទុកក្នុងទីដ៏សមគួរមួយ ហើយចាប់យកផ្ចិតស្លឹកត្នោតបក់ប្រគេនព្រះថេរៈ ។ គ្រានោះ ព្រះថេរៈពោលទៅកាន់សាមណេរថា "សាមណេរ អ្នកចូរធ្វើភត្តកិច្ចចុះ" ។

សាមណេរ. លោកម្ចាស់ ចុះលោកម្ចាស់ ?

ព្រះថេរៈ. សាមណេរ អ្នកចូរឆាន់ចុះ ខ្ញុំករុណាឆាន់រួចហើយ ។

ក្មេងអាយុ ៧ ខួប បួសបាន ៨ ថ្ងៃ សម្រេចព្រះអរហត្ត ដូចជាផ្កាឈូកដែលរីកក្នុងខណៈនោះ បានគង់ពិចារណានូវទីដាក់ភត្តដើម្បីធ្វើភត្តកិច្ច ។ ក្នុងខណៈដែលលោកលាងបាត្រទុកដាក់ ចន្ទទេវបុត្រ ក៏ព្រលែងមណ្ឌលព្រះច័ន្ទ

សុរិយទេវបុត្រ ក៏ព្រលែងមណ្ឌលព្រះអាទិត្យ មហារាជទាំង ៤ ដែលរក្សាក្នុងទិសទាំង ៤ នោះ ក៏ឈប់រក្សា សក្កទេវរាជលើកនូវការរក្សាក្នុងទីនៃខ្សែទប់ ព្រះអាទិត្យក៏ជ្រេទៅ ។

## ធម្មតាបណ្ឌិត រមែងទូន្មានខ្លួន

ភិក្ខុទាំងឡាយលើកទោសថា “ស្រមោលព្រះអាទិត្យជ្រេហួសប្រមាណទៅហើយ ព្រះអាទិត្យក៏ជ្រេទៅហើយដែរ សាមណេរទើបតែឆាន់រួចអម្បាញ់-មិញនេះឯង តើរឿងនេះ ដូចម្ដេចទៅហ្ន៎” ។ ព្រះសាស្ដាទ្រង់ជ្រាបរឿងនោះហើយ ស្ដេចយាងមក ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនិយាយគ្នាអំពីរឿងអ្វី?” ។

ពួកភិក្ខុ. រឿងប្រការនេះ ព្រះអង្គ ។

ព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ក្នុងកាលដែលបុគ្គលអ្នកមានបុណ្យបំពេញសមណធម៌ ចន្ទទេវបុត្រ ទាញទប់មណ្ឌលព្រះច័ន្ទ, សុរិយ-ទេវបុត្រទប់មណ្ឌលព្រះអាទិត្យ, មហារាជទាំង ៤ រក្សាទិសទាំង ៤ ក្នុងព្រៃជិតវិហារ សក្កទេវរាជមករក្សាត្រង់ទីនៃខ្សែទប់ សូម្បីតថាគតក៏មានសេចក្ដីខ្វល់ខ្វាយតិច ដោយគិតថា “យើងជាព្រះពុទ្ធ ក៏គង់នៅមិនបាន បានទៅរក្សាបុត្ររបស់តថាគតនៅត្រង់ខ្លោងទ្វារដែរ” ពួកបណ្ឌិតឃើញអ្នកបង្ហូរទឹកកំពុងបង្ហូរទឹកអំពីប្រឡាយ ជាងព្រួញកំពុងធ្វើព្រួញ និងជាងឈូសកំពុងឈូសឈើហើយ តែងកាន់នូវហេតុមានប្រមាណប៉ុណ្ណេះ ឲ្យជាអារម្មណ៍ ទូន្មានខ្លួន

ហើយ រមែងកាន់យកនូវព្រះអរហត្តបាន ដោយពិត ដូច្នេះហើយ កាលទ្រង់នឹងបន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

ឧទកញ្ហិ នយន្តិ នេត្តិកា ឧសុការា នមយន្តិ តេជនំ
ទារុំ នមយន្តិ តច្ឆកា អត្តានំ ទមយន្តិ បណ្ឌិតា ។

ធម្មតាអ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅ អ្នកធ្វើ
ព្រួញ តែងពត់ព្រួញ (ឲ្យត្រង់) អ្នកចាំងឈើ
តែងចាំងឈើ ឯបណ្ឌិតទាំងឡាយតែងទូន្មាន
ខ្លួន (ដូច្នោះដែរ) ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ឧទកំ** (ទឹក) ជាដើម សេចក្តីថា ជនទាំងឡាយជីកនូវទីទួលនៃផែនដី លុបរណ្តៅឲ្យពេញធ្វើជាប្រឡាយ ឬតម្កល់ឈើធ្វើជាស្នូក ហើយបង្ហូរទឹកទៅកាន់ទីដែលខ្លួនប្រាថ្នា ព្រោះដូច្នោះ ទើបឲ្យឈ្មោះថា អ្នកបង្ហូរទឹក ។ បទថា **តេជនំ** (សរ) បានដល់ កូនសរ ។ មានពុទ្ធាធិប្បាយត្រាស់ទុកដូច្នេះថា "អ្នកបង្ហូរទឹក តែងបង្ហូរទឹកទៅតាមការពេញចិត្តរបស់ខ្លួន សូម្បីជាងព្រួញ ក៏តែងពត់ព្រួញឲ្យត្រង់ ចំណែកជាងចាំង កាលនឹងចាំងឈើដើម្បីជាប្រយោជន៍ដល់ទព្វសម្ភារៈ មានខ្នងកង់ជាដើម តែងពត់ឈើ គឺ ធ្វើឲ្យត្រង់ ឬកោង តាមការពេញចិត្តរបស់ខ្លួន ។ បណ្ឌិតទាំងឡាយធ្វើហេតុមានប្រមាណប៉ុណ្ណេះ ឲ្យជាអារម្មណ៍ហើយ ញុំាងមគ្គ មានសោតា-

បត្តិមគ្គជាដើមឲ្យកើតឡើង ឈ្មោះថា ទូន្មានខ្លួន តែកាលសម្រេចព្រះអរហត្ត ហើយ រមែងចាត់ថា ទូន្មានខ្លួនដោយសព្វគ្រប់” ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងបណ្ឌិតសាមណេរ

# ៦. រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ

*ព្រះសាស្តា កាលទ្រង់ប្រថាប់នៅព្រះជេតពន ទ្រង់ប្រារព្ធ ព្រះលកុ-ណ្ឌកភទ្ទិយៈ ត្រាស់ព្រះធម៌ទេសនានេះថា សេលោ យថា (ភ្នំថ្មសុទ្ធ... យ៉ាងណា) ជាដើម ។*

ព្រះថេរៈត្រូវចំអកឡកឡឺយ

*បានឮថា សហធម្មិកៈ មានសាមណេរជាដើមដែលជាបុថុជ្ជន ឃើញព្រះថេរៈហើយ ចាប់សីសៈខ្លះ ត្រចៀកខ្លះ ច្រមុះខ្លះ ហើយពោលថា "លោកមាមិនអផ្សុកទេឬ នៅតែត្រេកអរក្នុងព្រះសាសនាឬ" ព្រះថេរៈមិនបានក្រោធ មិនបានប្រទូស្តចំពោះសហធម្មិកៈទាំងនោះឡើយ ។ ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងធម្មសភាថា "អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលចុះ សហធម្មិកៈមានសាមណេរជាដើម ឃើញព្រះលកុណ្ឌកភទ្ទិយៈហើយ រមែងបៀតបៀនយ៉ាងនេះផង យ៉ាងនោះផង លោកមិនក្រោធ មិនប្រទូស្តចំពោះសហធម្មិកៈទាំងនោះឡើយ ។*

ព្រះខីណាស្រពដូចជាសិលា

*ព្រះសាស្តា ស្តេចយាងមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនិយាយគ្នាអំពីរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន អំពីរឿងឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ*

យ៉ាងនោះហើយ ធម្មតាព្រះខីណាស្រព រមែងមិនក្រោធខឹង មិនប្រទូស្តចំពោះបុគ្គលណាឡើយ ព្រោះព្រះខីណាស្រព មិនកម្រើក មិនញាប់ញ័រ ដូចជាភ្នំថ្មតាន់" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា ។

ភ្នំថ្មតាន់ មិនរំកើបព្រោះខ្យល់ ដូចម្តេចមិញ បណ្ឌិតទាំងឡាយ ក៏មិនរំកើបព្រោះពាក្យតិះដៀល និងពាក្យសរសើរ (ជាដើម) ដូច្នេះដែរ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា និន្ទាបសំសាសុ (ព្រោះសរសើរ និងនិន្ទា) នេះ ព្រះមានព្រះភាគ ទ្រង់ត្រាស់សំដៅយកលោកធម៌តែ ២ បទ ក៏ពិត តែគប្បីជ្រាបសេចក្តីដោយរួមលោកធម៌សូម្បីទាំង ៨ ។ អធិប្បាយថា ដូចភ្នំថ្មតាន់ មិនមានប្រហោង រមែងមិនកម្រើក គឺ រមែងមិនរញ្ជួយ មិនញាប់ញ័រដោយខ្យល់ មានខ្យល់ដែលបក់មកអំពីទិសខាងកើតជាដើម យ៉ាងណា កាលលោកធម៌សូម្បីទាំង ៨ គ្របសង្កត់ហើយ បណ្ឌិតទាំងឡាយរមែងមិនកម្រើក គឺ មិនរញ្ជួយ មិនញាប់ញ័រដោយអំណាចនៃសេចក្តីថ្នាំងថ្នាក់ ឬដោយអំណាចនៃសេចក្តីត្រេកអរដូច្នោះដែរ ។

*ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។*

ចប់ រឿងព្រះលកុណ្ឌកភទ្ទិយត្ថេរ

# ៧. រឿងមាតារបស់នាងកាណា

*ព្រះសាស្តា កាលទ្រង់ប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធមាតារបស់នាងកាណា ត្រាស់ព្រះធម៌ទេសនានេះថា* ***យថាបិ រហទោ គម្ភីរោ (ដូចអន្លង់ទឹកជ្រៅ)*** *ជាដើម ។*

*រឿងមានមកហើយនៅក្នុងព្រះវិន័យនុ៎ះឯង ។*

នាងកាណាជេរភិក្ខុ

*ក៏ក្នុងគ្រានោះ កាលមាតារបស់នាងកាណា ធ្វើនំដើម្បីឲ្យនាងកាណាកុំឲ្យនាងធ្វើដំណើរទៅកាន់ត្រកូលស្វាមីដោយដៃទទេ ហើយបានប្រគេននំចំពោះភិក្ខុ ៤ រូប រហូតអស់ ៤ ដង ព្រះសាស្តាក៏ទ្រង់បញ្ញត្តសិក្ខាបទព្រោះរឿងនោះ កាលស្វាមីរបស់នាងកាណានាំកិរិយាថ្មីមក នាងកាណាបានស្តាប់រឿងនោះហើយ ទើបជេរផ្តាសាពួកភិក្ខុដែលខ្លួនឃើញហើយៗ ថា "ការគ្រប់គ្រងផ្ទះរបស់យើង ភិក្ខុទាំងនេះធ្វើឲ្យវិនាសហើយ" ។ ភិក្ខុទាំងឡាយ មិនអាចនិមន្តទៅកាន់ផ្លូវនោះបាន ។ ព្រះសាស្តាទ្រង់ជ្រាបរឿងនោះហើយ ទើបស្តេចយាងទៅកាន់ទីនោះ ។ មាតារបស់នាងកាណា ថ្វាយបង្គំព្រះសាស្តាហើយនិមន្តព្រះសាស្តាឲ្យគង់លើអាសនៈដែលខ្លួនក្រាលទុក ហើយបានថ្វាយយាគូនិងរបស់គួរទំពាចំពោះព្រះសម្មាសម្ពុទ្ធ ។*

*ព្រះសាស្តា ទ្រង់សោយព្រះក្រយាហារពេលព្រឹករួចហើយ ត្រាស់សួរ*

ថា "នាងកាណាទៅណា" ។

កាណមាតា. បពិត្រព្រះអង្គដ៏ចម្រើន នាងឃើញព្រះអង្គហើយ មានសេចក្តីអៀនខ្មាស ឈរយំនៅខាងក្រៅ ។

ព្រះសាស្តា. ព្រោះហេតុអ្វី ?

កាណមាតា. បពិត្រព្រះអង្គដ៏ចម្រើន នាងបានជេរផ្តាសាពួកភិក្ខុ ព្រោះដូច្នោះ នាងឃើញព្រះអង្គហើយ ទើបមានសេចក្តីអៀនខ្មាស ឈរយំនៅខាងក្រៅ ។

គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់ឲ្យហៅនាងកាណាមក ហើយត្រាស់សួរថា "កាណា នាងឃើញតថាគតហើយ អៀនខ្មាស ឈរយំមែនឬ?" គ្រានោះ មាតារបស់នាងក្រាបទូលនូវអំពើដែលនាងធ្វើ (ឲ្យទ្រង់ជ្រាប) ។ ពេលនោះ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់មាតារបស់នាងកាណាថា "កាណមាតា សាវកទាំងឡាយរបស់តថាគត កាន់យកនូវវត្ថុដែលនាងឲ្យ ឬក៏កាន់យកវត្ថុដែលនាងមិនបានឲ្យ?"

កាណមាតា. បពិត្រព្រះអង្គដ៏ចម្រើន កាន់យកវត្ថុដែលខ្ញុំព្រះករុណាប្រគេនហើយប៉ុណ្ណោះ ។

ព្រះសាស្តា. ប្រសិនបើសាវករបស់តថាគត ត្រាច់បិណ្ឌបាតដល់ទ្វារផ្ទះរបស់នាងហើយ ទទួលយកវត្ថុដែលនាងឲ្យហើយប៉ុណ្ណោះ តើសាវករបស់តថាគតមានទោសអ្វីទៅ ? ។

កាណមាតា. បពិត្រព្រះអង្គដ៏ចម្រើន សាវករបស់ព្រះអង្គ មិនមានទោសទេ នេះជាទោសកូនស្រីរបស់ខ្ញុំព្រះអង្គ ប៉ុណ្ណោះ ។

ព្រះសាស្តា ត្រាស់ទៅកាន់នាងកាណាថា "កាណា សាវករបស់តថាគតត្រាច់បិណ្ឌបាត មកដល់ទ្វារផ្ទះនេះហើយ មាតារបស់នាងបានប្រគេននំដល់សាវកទាំងនោះ ក្នុងរឿងនេះ តើសាវករបស់តថាគតមានកំហុសអ្វីឬ?" ។

នាងកាណា. បពិត្រព្រះអង្គដ៏ចម្រើន សាវករបស់ព្រះអង្គ មិនមានកំហុសទេ ខ្ញុំព្រះអង្គប៉ុណ្ណោះជាអ្នកខុស ។ នាងកាណាថ្វាយបង្គំព្រះសាស្តាហើយ សូមឲ្យព្រះអង្គទ្រង់អត់ទោសឲ្យ ។ គ្រានោះ ព្រះសាស្តាបានត្រាស់អនុបុព្វីកថាដល់នាង ។ នាងក៏បានសម្រេចសោតាបត្តិផល ។

## ព្រះរាជាទ្រង់តែងតាំងនាងកាណាទុកក្នុងតំណែងជេដ្ឋធីតា

ព្រះសាស្តា ស្តេចក្រោកចាកអាសនៈហើយ កាលស្តេចនឹងយាងទៅកាន់វិហារ ស្តេចយាងទៅតាមផ្លូវព្រះលានហ្លួង ។ ព្រះរាជាទ្រង់ទតឃើញព្រះសាស្តាហើយ ត្រាស់សួរថា "នែនាយ! នុ៎ះដូចជាព្រះសាស្តា កាលរាជបុរសក្រាបទូលថា "ព្រះករុណាថ្លៃវិសេស ត្រូវហើយ" ដូច្នេះហើយ ទើបបញ្ជូនរាជបុរសទៅដោយរាជតម្រាស់ថា "នែនាយ! អ្នកចូរទៅក្រាបទូលព្រះសាស្តាថា យើងនឹងមកថ្វាយបង្គំ" ហើយបានចូលទៅគាល់ព្រះសាស្តា ដែលប្រថាប់ឈរនៅនាព្រះលានហ្លួង ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានហើយ ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គស្តេចយាងទៅណា" ។

*ព្រះសាស្តា. មហាបពិត្រ តថាគតទៅកាន់ផ្ទះមាតារបស់នាងកាណា ។*

*ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ព្រោះហេតុអ្វី ទើបព្រះអង្គស្តេចយាងទៅកាន់ទីនោះ ។*

*ព្រះសាស្តា. តថាគតបានឮដំណឹងថា នាងកាណាជេរផ្តាសាពួកភិក្ខុ ទើបតថាគតទៅកាន់ទីនោះ ។*

*ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ធ្វើនាងកាណាឲ្យឈប់ជេរពួកភិក្ខុហើយឬ ។*

*ព្រះសាស្តា. ថ្វាយព្រះពរមហាបពិត្រ តថាគតបានធ្វើនាងឲ្យជាឈប់ជេរពួកភិក្ខុហើយ ថែមទាំងធ្វើនាងឲ្យជាម្ចាស់នៃលោកុត្តរទ្រព្យទៀតផង ។*

*ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ការដែលព្រះអង្គទ្រង់ធ្វើនាងឲ្យជាម្ចាស់នៃទ្រព្យដែលជាលោកុត្តរៈហើយនោះ សូមលើកទុកសិនចុះ ចំណែកខ្ញុំព្រះអង្គនឹងធ្វើនាងឲ្យជាម្ចាស់នៃទ្រព្យដែលជាលោកិយៈ ដូច្នេះហើយ ថ្វាយបង្គំព្រះសាស្តា ស្តេចត្រឡប់ទៅវិញ ទ្រង់បញ្ជូនយានធំដែលបិទបាំងទៅ ត្រាស់បង្គាប់ឲ្យហៅនាងកាណាមក ឲ្យប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ទ្រង់តែងតាំងនាងទុកក្នុងតំណែងជាធីតាច្បង ហើយត្រាស់សួរថា "នរណាអាចចិញ្ចឹមធីតារបស់យើងបាន អ្នកនោះចូរទទួលយកនាងចុះ" ។ គ្រានោះ មហាមាត្យអ្នកសម្រេចរាជកិច្ចទាំងពួងម្នាក់ ក្រាបទូលព្រះរាជាថា "បពិត្រមហារាជខ្ញុំព្រះអង្គនឹងចិញ្ចឹមធីតារបស់មហាបពិត្រ" ដូច្នេះហើយ ក៏បាននាំនាងទៅកាន់*

ផ្ទះរបស់ខ្លួន ប្រគល់នូវភាពជាធំឲ្យនាង ហើយពោលថា "នាងចូរធ្វើបុណ្យតាមសេចក្ដីពេញចិត្តចុះ" ។ ចាប់តាំងពីថ្ងៃនោះមក នាងកាណាតាំងបុរសទុកត្រង់ទ្វារផ្ទះទាំង ៤ ក៏នៅតែមិនបានភិក្ខុ និងភិក្ខុនីដែលខ្លួនគប្បីបម្រើ ។ របស់ទំពាស៊ី និងរបស់គួរបរិភោគ ដែលនាងកាណាបម្រុងទុកទៀបទ្វារផ្ទះដូចជាអន្លង់ទឹកធំ ។ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា "ម្នាលអ្នកដ៏មានអាយុក្នុងកាលមុនព្រះថេរៈ ៤ រូប ធ្វើឲ្យនាងកាណាក្ដៅក្រហាយ, នាងសូម្បីក្ដៅក្រហាយយ៉ាងនោះហើយក៏ដោយ តែអាស្រ័យព្រះសាស្ដា ក៏ជាអ្នកដល់ព្រមដោយសទ្ធា ព្រះសាស្ដាបានទ្រង់ធ្វើទ្វារផ្ទះរបស់នាង ឲ្យជាស្ថានទីដែលគួរចូលទៅរបស់ពួកភិក្ខុថែមទៀតផង ឥឡូវនេះ សូម្បីនាងស្វែងរកភិក្ខុ ឬភិក្ខុនីទាំងឡាយ ដែលខ្លួនគប្បីបម្រើក៏មិនបាន ឱហ្ន៎! ព្រះពុទ្ធទាំងឡាយ មានគុណដ៏អស្ចារ្យពិតហ្ន៎" ។

ព្រះសាស្ដា ស្ដេចមកហើយត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ឥឡូវនេះអង្គុយប្រជុំគ្នានិយាយអំពីរឿងអ្វី" ។ កាលភិក្ខុទាំងនោះក្រាបទូលថា "អំពីរឿងឈ្មោះនេះ" ។ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុចាស់ទាំងនោះធ្វើឲ្យនាងកាណាក្ដៅក្រហាយ មិនមែនតែឥឡូវនេះប៉ុណ្ណោះទេ សូម្បីក្នុងកាលមុន ភិក្ខុចាស់ទាំងនោះ ក៏ធ្លាប់ធ្វើឲ្យនាងក្ដៅក្រហាយដែរម្យ៉ាងទៀត តថាគតបានធ្វើឲ្យនាងកាណាធ្វើតាមពាក្យរបស់តថាគត មិនមែនតែក្នុងកាលឥឡូវនេះប៉ុណ្ណោះទេ សូម្បីកាលមុន ក៏តថាគតបានធ្វើហើយដែរ"

ពួកភិក្ខុអ្នកប្រាថ្នានឹងស្តាប់នូវសេចក្តីនោះ ទូលអារាធនាហើយ ទើបត្រាស់នូវពព្ពុជាតក នេះ ដោយពិស្តារថា ៖

ឆ្មាមួយបានកណ្តុរ និងសាច់ក្នុងទីណា ឆ្មាទីពីរ ក៏កើតក្នុងទីនោះ
ឆ្មាទីបី ឆ្មាទីបួន រមែងកើតក្នុងទីនោះ ឆ្មាទាំងនោះទម្លាយនូវបំពង់
នេះហើយ (ក៏ដល់នូវសេចក្តីស្លាប់) ។

ហើយទ្រង់ប្រជុំជាតកថា "ភិក្ខុចាស់ ៤ រូប (ក្នុងកាលឥឡូវនេះ) បានជាឆ្មាទាំង ៤ ក្នុងកាលនោះ កណ្តុរបានជានាងកាណា ជាងកែវ គឺ តថាគតនេះឯង" ដូច្នេះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូម្បីក្នុងអតីតកាលនាងកាណា ក៏បានជាអ្នកមានចិត្តក្តៅក្រហាយ មានចិត្តកករល្អក់ដែរ (ប៉ុន្តែ) ឥឡូវនេះ បានជាអ្នកមានចិត្តថ្លាថ្លូវផង់ដូចអន្លង់ទឹក ដែលមានទឹកដ៏ថ្លា ដោយពាក្យរបស់តថាគត" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យថាបិ រហទោ គម្ភីរោ វិប្បសន្នោ អនាវិលោ
ឯវំ ធម្មានិ សុត្វាន វិប្បសីទន្តិ បណ្ឌិតា ។

អន្លង់ទឹកដែលជ្រៅ រមែងថ្លាមិនល្អក់យ៉ាងណា
បណ្ឌិតទាំងឡាយ បើបានស្តាប់ធម៌ទេសនាហើយ
រមែងជ្រះថ្លាស៊ប់ស្ងួន យ៉ាងនោះ ។

## អធិប្បាយគាថា

*អន្លង់ទឹកឯណា សូម្បីសេនាទាំង ៤ ពួក (ចតុរង្គសេនា គឺ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង) ឆ្លងហើយ មិនរលក មិនរញ្ជួយ អន្លង់ទឹកបែបនេះ ឈ្មោះថា **រហទោ (អន្លង់ទឹក)** ក្នុងព្រះគាថានេះ ។ ក៏ទីលមហាសមុទ្រដែលមានជម្រៅ ៨៤.០០០ យោជន៍ ដោយអាការទាំងពួង ឈ្មោះថា អន្លង់ទឹក ។ ពិតណាស់ ទឹកក្នុងទីមានប្រមាណ ៤ ម៉ឺនយោជន៍ ដែលនៅខាងក្រោមទីលមហាសមុទ្រនោះ រមែងកម្រើកញាប់ញ័រព្រោះហ្វូងត្រី ទឹកមានប្រមាណ ៤ ម៉ឺនយោជន៍ដែលនៅខាងលើ រមែងកម្រើកញាប់ញ័រព្រោះខ្យល់ (ចំណែក) ទឹកក្នុងទីមានប្រមាណ ៤ ពាន់យោជន៍ ដែលនៅត្រង់កណ្តាល (ទីលមហាសមុទ្រនោះ) រមែងមិនកម្រើកញាប់ញ័រ តាំងនៅហ្នឹងថ្កល់ អន្លង់ទឹកនេះ ឈ្មោះថា អន្លង់ទឹកដ៏ជ្រៅ ។ បទថា **ធម្មានិ (ធម៌)** បានដល់ ព្រះធម៌ទេសនាទាំងឡាយ ។ ព្រះមានព្រះភាគត្រាស់អធិប្បាយទុកថា “អន្លង់ទឹកនោះ ឈ្មោះថា ថ្លា ព្រោះជាទឹកមិនប្រឡូកប្រឡំ ឈ្មោះថា មិនកករល្អក់ ព្រោះជាទឹកមិនកម្រើកញាប់ញ័រ យ៉ាងណា បណ្ឌិតទាំងឡាយ ស្តាប់ព្រះធម៌ទេសនារបស់តថាគតហើយ រមែងមានចិត្តប្រាសចាកឧបក្កិលេស ដោយអំណាចនៃមគ្គ មានសោតាបត្តិមគ្គជាដើម ឈ្មោះថា ថ្លា ដូច្នោះដែរ ។ ចំណែកបុគ្គលអ្នកសម្រេចព្រះអរហត្តហើយ រមែងជាអ្នកមានចិត្តថ្លាផូរផង់ ដោយប្រការទាំងពួង ។*

*ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។*

ចប់ រឿងនាងកាណា

# ៨. រឿងភិក្ខុ ៥០០ រូប

*ព្រះសាស្តា កាលប្រថាប់នៅព្រះជេតពន ទ្រង់ប្រារព្ធភិក្ខុ ៥០០ រូប ត្រាស់ព្រះទេសនានេះថា **សព្វត្ថ វេ សប្បុរិសា វជន្តិ (សប្បុរសទាំងឡាយ រមែងវៀរចាកក្នុងធម៌ទាំងពួង)** ដូច្នេះជាដើម ។*

*ព្រះធម្មទេសនាតាំងឡើងនៅក្រុងវេរញ្ជា ។*

## ព្រះសាស្តាយាងទៅកាន់ក្រុងវេរញ្ជា

*សេចក្តីពិស្តារថា ក្នុងបឋមពោធិកាល ព្រះមានព្រះភាគ ស្តេចយាងទៅកាន់ក្រុងវេរញ្ជា ព្រាហ្មណ៍ឈ្មោះវេរញ្ជៈ និមន្តព្រះសាស្តាប្រថាប់គង់ចាំវស្សានៅទីនោះ ទើបស្តេចចាំវស្សានៅទីនោះជាមួយនឹងភិក្ខុ ៥០០ រូប ។ វេរញ្ជព្រាហ្មណ៍ ត្រូវមារបណ្តាលចិត្ត មិនឲ្យនឹកឃើញដល់ព្រះសាស្តាសូម្បីត្រឹមតែមួយថ្ងៃ សូម្បីក្រុងវេរញ្ជានោះ ក៏ជាក្រុងមានភិក្ខាក្រ ។ ពួកភិក្ខុត្រាច់ទៅបិណ្ឌបាតពេញក្រុងទាំងមូល ទាំងខាងក្នុងក្រុងទាំងខាងក្រៅក្រុង ក៏នៅតែមិនបានបិណ្ឌបាត កាលមិនបានបិណ្ឌបាត ទើបដល់នូវសេចក្តីលំបាកដ៏យ៉ាងក្រៃលែង ។ ពួកឈ្មួញសេះសេះបានចាត់ចែងភិក្ខា មានបាយក្រហម ប្រមាណមួយបត្ថៈៗ (១ កំប៉ុង) ដើម្បីភិក្ខុទាំងនោះ ។ ព្រះមហាមោគ្គល្លាន ឃើញពួកភិក្ខុទាំងឡាយលំបាកដោយអាហារយ៉ាងនោះ ក៏មានសេចក្តីប្រាថ្នានឹងញ៉ាំងភិក្ខុទាំងនោះ ឲ្យឆាន់នូវឱជានៃផែនដីផង ប្រាថ្នានឹងញ៉ាំងពួកភិក្ខុឲ្យចូលទៅកាន់*

ឧត្តរកុរុទ្វីបដើម្បីបិណ្ឌបាតផង ព្រះសាស្ដាក៏ទ្រង់ហាមឃាត់ ។ ពួកភិក្ខុមិនមានសេចក្ដីតក់ស្លុតព្រោះប្រារព្ធបិណ្ឌបាត សូម្បីតែមួយថ្ងៃ ។ ភិក្ខុទាំងនោះ វៀរចាកការប្រព្រឹត្តដោយអំណាចនៃការប្រាថ្នា ហើយរស់នៅ ។

ព្រះសាស្ដាស្ដេចយាងទៅកាន់ក្រុងសាវត្ថី

ព្រះសាស្ដា ទ្រង់ប្រថាប់នៅក្នុងក្រុងវេរញ្ជានោះអស់បីខែហើយ ទ្រង់លាវេរញ្ជព្រាហ្មណ៍ មានគ្រឿងសក្ការៈដែលព្រាហ្មណ៍នោះធ្វើហើយ ទ្រង់ញ៉ាំងព្រាហ្មណ៍ឲ្យតាំងនៅក្នុងសរណៈ ហើយស្ដេចចេញចាកក្រុងវេរញ្ជានោះ យាងទៅកាន់ទីចារិកតាមលំដាប់ សម័យមួយ ស្ដេចយាងទៅដល់ក្រុងសាវត្ថី ទ្រង់ប្រថាប់នៅជេតពនវិហារ អ្នកក្រុងសាវត្ថី ក៏ធ្វើអាគន្តុកភត្ត ថ្វាយចំពោះព្រះសាស្ដា ។ ក៏ក្នុងកាលនោះ ពួកអ្នកស៊ីដែល ៥០០ នាក់ រស់នៅអាស្រ័យពួកភិក្ខុនៅក្នុងវិហារនោះឯង ។ ពួកអ្នកស៊ីដែលទាំងនោះ បរិភោគភោជនដ៏ប្រណីតដែលសល់អំពីភិក្ខុទាំងឡាយ ហើយក៏ដេកលក់ ក្រោកឡើងហើយទៅកាន់មាត់ស្ទឹង ហ៊ោកញ្ជៀវ លេងចម្បាប់ និងលេងប្រដាល់ និងលេងសើចដោយប្រការផ្សេងៗ ប្រព្រឹត្តតែអំពើអនាចារប៉ុណ្ណោះ ទាំងខាងក្នុងវិហារទាំងខាងក្រៅវិហារ ។ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា "ម្នាលអ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយមើលចុះ ក្នុងវេលាកើតទុព្ភិក្ខភ័យ ពួកអ្នកស៊ីដែលទាំងនេះ មិនបានសម្ដែងនូវវិការៈអ្វីៗ នៅក្នុងក្រុងវេរញ្ជាឡើយ តែឥឡូវនេះ ស៊ីភោជនដ៏ប្រណីតបែបនេះហើយ បានដើរសម្ដែងអាការប្លែកៗ ជាអនេកប្បការ

ចំណែកពួកភិក្ខុស្ងប់ទាំងកាលដែលនៅក្នុងក្រុងវេរញ្ជា ទាំងក្នុងកាលឥឡូវនេះ”។

ព្រះសាស្តាទ្រង់ត្រាស់វារុណិកជាតក

ព្រះសាស្តា ស្តេចយាងទៅកាន់ធម្មសភាហើយ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនិយាយគ្នាអំពីរឿងអ្វី” កាលពួកភិក្ខុក្រាបទូលថា “អំពីរឿងឈ្មោះនេះ” ដូច្នេះហើយ ក៏ទ្រង់ត្រាស់ថា “ក្នុងកាលមុនអ្នកស៊ីសំណល់ទាំងនេះ កើតក្នុងកំណើតលា ជាលា ៥០០ បានផឹកទឹកដែលមានរសតិច ដែលជាទឹកដ៏ថោកទាប ដល់នូវការរាប់ថា ទឹកសាប ព្រោះទឹកនោះជាទឹកដែលគេច្របាច់លាយដោយកាកផ្លែចន្ទន៍ ដែលសល់អំពីទឹកបានៈនៃផ្លែចន្ទន៍ ដែលមានរសដ៏ស្រស់ ដែលសេះសិន្ធពអាជានេយ្យ ៥០០ ផឹកហើយ ត្រង់ដោយកំណាត់សំពត់សំបកក្រចៅចាស់ៗ មានអាការដូចជាស្រវឹងទឹកផ្អែមដើរស្រែកឡូឡា” កាលទីងទ្រង់សម្តែងមារយាទរបស់លាទាំងនោះឲ្យប្រាកដ ទើបត្រាស់ វារុណិកជាតក នេះ ដោយពិស្តារថា ៖

សេចក្តីស្រវឹង រមែងកើតដល់ពួកលា ព្រោះផឹកនូវទឹក
សាប មានរសតិច ជាទឹកដ៏ថោកទាប តែសេចក្តីស្រវឹង
រមែងមិនកើតមានដល់សេះសិន្ធពទាំងឡាយ ព្រោះផឹក
នូវរសដ៏ប្រណីតនេះ ។

បពិត្រព្រះរាជា លានោះជាសត្វដ៏ថោកទាប ផឹកនូវទឹក
ដែលមានរសតិច ដែលរសនោះពាល់ត្រូវហើយ រមែង

ស្រវឹង ចំណែកសេះអាជានេយ្យ អ្នកនាំនូវធុរៈទៅជា
ប្រប្រតី កើតក្នុងត្រកូល (ដ៏ល្អ) ផឹកនូវរសដ៏ប្រសើរ
ហើយ ក៏មិនស្រវឹង ។

ហើយត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សប្បុរសវៀរចាកធម៌ គឺ ការលោកហើយ រមែងជាអ្នកមិនមានវិការៈប្លែកឡើយ ទាំងក្នុងវេលាបានសុខ ទាំងក្នុងវេលាបានជួបប្រសព្វទុក្ខ ដូច្នេះ" កាលទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

សព្វត្ថ វេ សប្បុរិសា វជន្តិ
ន កាមកាមា លបយន្តិ សន្តោ
សុខេន ផុដ្ឋា អថ វា ទុខេន
ន ឧច្ចាវចំ បណ្ឌិតា ទស្សយន្តិ ។

ពួកសប្បុរស តែងលះ (ឆន្ទរាគៈ) ក្នុងធម៌ទាំងពួង
ពួកលោកអ្នកស្ងប់ រមែងមិនរអែរអូវ ព្រោះសេចក្តី
ប្រាថ្នាក្នុងកាម ពួកបណ្ឌិតបើសេចក្តីសុខ ឬទុក្ខពាល់
ត្រូវហើយ រមែងមិនសំដែងអាការឡើងចុះឡើយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា សព្វត្ថ (ក្នុងធម៌ទាំងពួង) បានដល់ ក្នុងធម៌ទាំងពួង មានខន្ធជាដើម ។ បុរសល្អ ឈ្មោះថា សប្បុរិសោ (សប្បុរស) ។

បទថា **វជន្តិ** (រមែងវៀរ) សេចក្តីថា សប្បុរស កាលកម្ចាត់ឆន្ទរាគៈ ចេញដោយអរហត្តមគ្គញាណហើយ ឈ្មោះថា លះបង់ឆន្ទរាគៈ ។

បទថា **ន កាមកាមា** (មិនរអែរអូរព្រោះសេចក្តីប្រាថ្នាក្នុងកាម) បានដល់ អ្នកប្រាថ្នាកាម (ម្យ៉ាងទៀត) បានដល់ ព្រោះហេតុនៃកាម គឺ ព្រោះមានកាមជាហេតុ ។ បទថា **លបយន្តិ សន្តោ** (សប្បុរស "រមែងមិន" រអែ-រអូរ) សេចក្តីថា សប្បុរសទាំងឡាយ មានព្រះពុទ្ធជាដើម រមែងមិនរអែរអូរដោយខ្លួនឯង (ទាំងមិន) ញ៉ាំងអ្នកដទៃឲ្យរអែរអូរព្រោះហេតុនៃកាម ។ ពិតណាស់ ភិក្ខុពួកណាចូលទៅដើម្បីភិក្ខាតាំងនៅក្នុងឥច្ចាចារ ពោលពាក្យជាដើមថា "ម្នាលឧបាសក បុត្រភរិយារបស់អ្នកសុខសប្បាយជាទេឬ ឧបទ្រវៈណាៗ ដោយអំណាចនៃរាជភ័យ និងចោរភ័យជាដើម មិនមានក្នុងសត្វជើង ៤ និងសត្វជើង ២ របស់អ្នកទេឬ?" ភិក្ខុទាំងនោះ ឈ្មោះថា រមែងរអែរអូរដោយខ្លួនឯង ។ លុះពោលយ៉ាងនោះហើយ (និយាយ) ឲ្យគេនិមន្តខ្លួនថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំព្រះករុណាគ្រប់គ្នា មានសេចក្តីសុខសប្បាយជាទេ ឧបទ្រវៈណាមិនមានឡើយ ឥឡូវនេះ ផ្ទះរបស់ពួកខ្ញុំមានបាយ និងទឹកដ៏ច្រើន និមន្តលោកម្ចាស់នៅទីនេះហើយ" ដូច្នេះ ឈ្មោះថា ញ៉ាំងអ្នកដទៃឲ្យរអែរអូរ ។ ចំណែកសប្បុរសទាំងឡាយ រមែងមិនធ្វើនូវការរអែរអូរ សូម្បីទាំងពីរយ៉ាងនោះ ។

បទថា **សុខេន ផុដ្ឋា អថ វា ទុខេន** (ដែលសុខ ឬទុក្ខពាល់ត្រូវហើយ)

នេះ ត្រឹមតែជាទេសនា ។ អធិប្បាយថា "បណ្ឌិតទាំងឡាយ បើលោកធម៌ទាំង ៨ ពាល់ត្រូវហើយ រមែងមិនសម្ដែងអាការឡើងចុះ ដោយអំណាចនៃសេចក្ដីត្រេកអរ និងសេចក្ដីមិនត្រេកអរ ឬដោយអំណាចនៃការពោលគុណនិងទោសឡើយ" ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងភិក្ខុ៥០០រូប

# ៩. រឿងព្រះធម្មិកត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធ ព្រះធម្មិកត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា* ***ន អត្តហេតុ (បណ្ឌិត រមែងមិនធ្វើបាបព្រោះហេតុនៃខ្លួន)*** *ដូច្នេះជាដើម ។*

ឧបាសកគាត់ទៅបួសបានសម្រេចព្រះអរហត្ត

*បានឮថា ឧបាសកម្នាក់នៅក្នុងក្រុងសាវត្ថី គ្រប់គ្រងផ្ទះប្រកបដោយធម៌ ។ ឧបាសកនោះ ប្រាថ្នានឹងបួស ថ្ងៃមួយ កាលអង្គុយសន្ទនាជល់ពាក្យដែលប្រារព្ធនូវសេចក្តីសុខជាមួយនឹងភរិយា ក៏និយាយថា "នាងដ៏ចម្រើន ខ្ញុំប្រាថ្នានឹងបួស" ។ ភរិយារបស់គាត់អង្វរថា "នាយ កុំអាលអី រង់ចាំខ្ញុំប្រសូតបុត្រដែលនៅក្នុងផ្ទៃសិនចុះ" ។ ឧបាសកនោះ ក៏រង់ចាំតាមពាក្យអង្វររបស់ភរិយា ក្នុងវេលាដែលក្មេងនោះដើរបាន ក៏លាភរិយាម្តងទៀត កាលភរិយាអង្វរថា "អ្នកបង កុំអាលអី រង់ចាំក្មេងនេះចម្រើនវ័យសិនចុះ" ។ ក៏គិតថា "ប្រយោជន៍អ្វីដល់យើងព្រោះអាស្រ័យស្ត្រីនេះ ដែលយើងលា ឬមិនលានោះ យើងនឹងធ្វើការរលាស់ចេញចាកទុក្ខចំពោះខ្លួនឯង" ដូច្នេះហើយ ក៏ចេញទៅបួស ។ ភិក្ខុនោះរៀនកម្មដ្ឋាន ប្រឹងប្រែងព្យាយាម ញុំាងកិច្ចនៃបព្វជិតឲ្យសម្រេចហើយ ក៏ (ត្រឡប់) ទៅកាន់ក្រុងសាវត្ថីវិញ ដើម្បីសួរសុខទុក្ខបុត្រ និងភរិយា ហើយសម្តែងធម្មកថា ឲ្យបុត្រ និងភរិយាស្តាប់ ។*

## បុត្រ និងភរិយាចេញបួសបានសម្រេចព្រះអរហត្ត

សូម្បីបុត្រនោះក៏ចេញបួសដែរ ។ លុះបួសហើយ មិនយូរប៉ុន្មានក៏បាន សម្រេចព្រះអរហត្ត ។ ចំណែកភរិយាចាស់របស់ភិក្ខុនោះ គិតថា “យើង នៅគ្រប់គ្រងផ្ទះ ដើម្បីប្រយោជន៍ដល់ជនទាំងឡាយណា ជនទាំងឡាយនោះ ក៏បួសអស់ហើយ ឥឡូវនេះ ការដែលយើងនៅគ្រប់គ្រងផ្ទះ តើបានប្រយោជន៍ អ្វី យើងនឹងបួសដែរ” ហើយក៏ចេញទៅបួសក្នុងសម្នាក់ភិក្ខុនី លុះបួសហើយ មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ។

ក្រោយមកថ្ងៃមួយ ពួកភិក្ខុសន្ទនាគ្នាក្នុងធម្មសភាថា “អ្នកមានអាយុ ទាំងឡាយ ធម្មិកឧបាសកចេញបួស បានសម្រេចព្រះអរហត្តហើយ ថែមទាំង បានជាទីពឹងដល់បុត្រ និងភរិយាទៀតផង នេះក៏ព្រោះលោកជាអ្នកតាំងនៅ ក្នុងធម៌” ។

ព្រះសាស្តាស្តេចយាងមកហើយ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយប្រជុំគ្នានិយាយរឿងអ្វី” កាលពួកភិក្ខុក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន អំពីរឿងឈ្មោះនេះ” ទើបត្រាស់ថា “ម្នាលភិក្ខុទាំង ឡាយ ធម្មតា បណ្ឌិតមិនគប្បីប្រាថ្នានូវការសម្រេចព្រោះហេតុនៃខ្លួន (និង) មិនគប្បីប្រាថ្នានូវការសម្រេចព្រោះហេតុនៃអ្នកដទៃឡើយ តែគប្បីជាអ្នកតាំង នៅក្នុងធម៌ មានធម៌ជាទីពឹងដោយពិត” កាលទ្រង់នឹងបន្តអនុសន្ធិដើម្បីសម្តែង ព្រះធម៌ ក៏បានត្រាស់ព្រះគាថានេះថា ៖

ន អត្តហេតុ ន បរស្ស ហេតុ
ន បុត្តមិច្ឆេ ន ធនំ ន រដ្ឋំ
ន ឥច្ឆេយ្យ អធម្មេន សមិទ្ធិមត្តនោ
ស សីលវា បញ្ញវា ធម្មិកោ សិយា ។

បណ្ឌិតមិនគួរធ្វើអាក្រក់ ព្រោះហេតុនៃខ្លួន មិន
គួរធ្វើអាក្រក់ ព្រោះហេតុនៃអ្នកដទៃ មិនគួរប្រាថ្នា
កូន មិនគួរប្រាថ្នាទ្រព្យ មិនគួរប្រាថ្នារដ្ឋ មិនគួរ
ប្រាថ្នាសិទ្ធិដើម្បីខ្លួន ដោយហេតុមិនមែនជាធម៌ឡើយ
លោកគួរជាអ្នកមានសីល មានប្រាជ្ញាប្រកបដោយ
ធម៌ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ន អត្តហេតុ (មិន...ព្រោះហេតុនៃខ្លួន) សេចក្ដីថា ធម្មតាបណ្ឌិត រមែងមិនធ្វើបាបព្រោះហេតុនៃខ្លួន ឬព្រោះហេតុនៃអ្នកដទៃ ។

បទថា ន បុត្តមិច្ឆេ (មិនគប្បីប្រាថ្នាបុត្រ) សេចក្ដីថា បណ្ឌិតមិនគប្បីប្រាថ្នានូវបុត្រ ឬទ្រព្យ ឬដែន ដោយអំណាចកម្មដ៏លាមកឡើយ បណ្ឌិតកាលប្រាថ្នានូវវត្ថុទាំងនោះហើយ រមែងមិនធ្វើនូវកម្មដ៏លាមកឡើយ ។

បទថា សមិទ្ធិមត្តនោ (សេចក្ដីសម្រេចដើម្បីខ្លួន) សេចក្ដីថា បណ្ឌិត

មិនគួរប្រាថ្នា សូម្បីសេចក្តីសម្រេចដើម្បីខ្លួន ដែលមិនមែនជាធម៌ អធិប្បាយថា បណ្ឌិតរមែងមិនធ្វើបាប ព្រោះហេតុនៃសេចក្តីសម្រេចឡើយ ។

បទថា *ស សីលវា (បណ្ឌិតនោះ គប្បីជាអ្នកមានសីល)* សេចក្តីថា បុគ្គលបែបនេះ គប្បីជាអ្នកមានសីល មានបញ្ញា និងប្រកបដោយធម៌ អធិ-ប្បាយថា មិនគប្បីជាយ៉ាងដទៃ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងព្រះធម្មិកត្ថេរ

# ១០. រឿងការស្តាប់ធម៌

ព្រះសាស្តា កាលប្រថាប់គង់នៅនាវត្តជេតពន ទ្រង់ប្រារព្ធការស្តាប់ធម៌ ត្រាស់ព្រះធម្មទេសនានេះថា **អប្បកា តេ មនុស្សេសុ (បណ្តាមនុស្ស ជនអ្នកដល់ត្រើយមានចំនួនតិច)** ជាដើម ។

បុគ្គលអាស្រ័យភពហើយជាប់នៅក្នុងភពមានច្រើន

បានស្តាប់មកថា ពួកមនុស្សដែលនៅក្នុងថ្នល់មួយ នាក្រុងសាវត្ថី ជាអ្នកព្រមព្រៀងគ្នា ថ្វាយទានរួមគ្នាជាពួកៗ ហើយ ក៏ធ្វើការស្តាប់ធម៌អស់រាត្រីទាំងមូល តែមិនអាចស្តាប់ធម៌អស់រាត្រីទាំងមូលបាន ពួកខ្លះអាស្រ័យសេចក្តីត្រេកអរក្នុងកាម ក៏ត្រឡប់ទៅកាន់ផ្ទះវិញ, ពួកខ្លះអាស្រ័យទោសៈក៏ត្រឡប់ទៅកាន់ផ្ទះដែរ, តែពួកខ្លះជាអ្នកបរិបូណ៌ដោយថីនមិទ្ធៈ ក៏អង្គុយងោកនៅក្នុងទីនោះឯង មិនអាចស្តាប់ធម៌បាន ។ ស្អែកឡើង ពួកភិក្ខុញ៉ាំងពាក្យឲ្យតាំងឡើងក្នុងធម្មសភា ប្រារព្ធចំពោះរឿងនោះ ។ ព្រះសាស្តា ស្តេចយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយអង្គុយសន្ទនាគ្នាអំពីរឿងអ្វី" កាលភិក្ខុទាំងឡាយក្រាបទូលថា "អំពីរឿងឈ្មោះនេះ" ទើបទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាសត្វដែលអាស្រ័យភព ហើយជាប់នៅក្នុងភពនោះ មានច្រើន ឯសត្វដែលដល់នូវត្រើយ គឺ ព្រះនិព្វាន មានចំនួនតិច" កាលនឹងទ្រង់បន្តអនុសន្ធិ ដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា ៖

*អប្បកា តេ មនុស្សេសុ　　យេ ជនា បារគាមិនោ*
*អថាយំ ឥតរា បជា　　តីរមេវានុធាវតិ ។*
*យេ ច ខោ សម្មទក្ខាតេ　　ធម្មេ ធម្មានុវត្តិនោ*
*តេ ជនា បារមេស្សន្តិ　　មច្ចុធេយ្យំ សុទុត្តរំ ។*

*បណ្តាមនុស្សទាំងឡាយ ពួកជនណា ដែលឆ្លងដល់ត្រើយ គឺ ព្រះនិព្វាន ពួកជននោះ មានប្រមាណតិច ចំណែកពួកសត្វក្រៅនេះ រមែងស្ទុះទៅកាន់ត្រើយ (គឺសក្កាយទិដ្ឋិ) ។ ជនទាំងឡាយណា ប្រព្រឹត្តតាមធម៌ក្នុងធម៌ ដែលព្រះតថា-គតទ្រង់សម្តែងទុកហើយដោយប្រពៃ ជនទាំងនោះនឹងឆ្លងនូវលំនៅនៃមច្ចុ ដែលមិនងាយឆ្លងបាន ហើយដល់នូវព្រះនិព្វាន ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **អប្បកា** (មានចំនួនតិច) គឺ តិចតួច បានដល់ មិនច្រើន ។ បទថា **បារគាមិនោ** (ជនអ្នកដល់ត្រើយ) គឺ បានសម្រេចព្រះនិព្វាន ។ បទថា **អថាយំ ឥតរា បជា** (ចំណែកជនក្រៅអំពីនេះ) សេចក្តីថា ចំណែកប្រជាដ៏សេស រមែងស្ទុះទៅកាន់ត្រើយ គឺ សក្កាយទិដ្ឋិនេះឯងច្រើនណាស់ ។ បទថា **សម្មទក្ខាតេ** (ក្នុងធម៌ដែលតថាគតត្រាស់ល្អហើយ) គឺ ទ្រង់ត្រាស់សម្តែងដោយប្រពៃ បានដល់ ទ្រង់ត្រាស់សម្តែងត្រឹមត្រូវ ។ បទ*

ថា **ធម្មេ** **(ក្នុងធម៌)** គឺ ក្នុងព្រះធម៌ទេសនា ។ បទថា **ធម្មានុវត្តិនោ** **(ប្រព្រឹត្តសមគួរដល់ធម៌)** សេចក្ដីថា ប្រព្រឹត្តធម៌សមគួរដល់ធម៌ ដោយអំណាចនៃការស្ដាប់ធម៌នោះហើយ បំពេញបដិបទាសមគួរដល់ធម៌នោះ ធ្វើមគ្គផលឲ្យជាក់ច្បាស់ ។ បទថា **បារមេស្សន្តិ** **(នឹងដល់ត្រើយ)** សេចក្ដីថា ជនទាំងនោះ គឺ បែបនោះ នឹងដល់ត្រើយ គឺ ព្រះនិព្វាន ។ បទថា **មច្ចុធេយ្យំ** **(អន្ទាក់មារ)** បានដល់ វដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលជាលំនៅរបស់មច្ចុ ពោលគឺកិលេសមារ ។ បទថា **សុទុត្តរំ** **(ឆ្លងបានសែនលំបាក)** សេចក្ដីថា ជនទាំងឡាយណា ប្រព្រឹត្តធម៌សមគួរដល់ធម៌ ជនទាំងនោះរមែងកន្លង គឺ កន្លងនូវអន្ទាក់មារ ដែលបុគ្គលឆ្លងបានសែនលំបាក គឺ ឈានកន្លងបានសែនលំបាកនោះ នឹងដល់នូវត្រើយ គឺ ព្រះនិព្វាន ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើន បានសម្រេចនូវអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះឯង ។

ចប់ រឿងការស្ដាប់ធម៌

# ១១. រឿងភិក្ខុអាគន្តុកៈ

*ព្រះសាស្តា កាលប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធដល់ពួកអាគន្តុកភិក្ខុ ៥០០ ត្រាស់ព្រះធម៌ទេសនានេះថា **កណ្ហំ ធម្មំ វិប្បហាយ** (លះធម៌ខ្មៅហើយ) ដូច្នេះជាដើម ។*

ព្រះសាស្តាទ្រង់ត្រាស់ព្រះវាចាតាមអជ្ឈាស្រ័យរបស់ភិក្ខុ

*បានឮថា ភិក្ខុប្រមាណ ៥០០ រូប ចាំវស្សានៅក្នុងដែនកោសល ចេញវស្សាហើយ ប្រឹក្សាគ្នាថា "នឹងគាល់ព្រះសាស្តា" ទើបទៅកាន់វត្តជេតពន ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរមួយ ។ ព្រះសាស្តា ទ្រង់ពិចារណាធម៌ដែលជាបដិបក្ខដល់ចរិយារបស់ពួកភិក្ខុទាំង ៥០០ កាលនឹងទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា ៖*

*កណ្ហំ ធម្មំ វិប្បហាយ　សុក្កំ ភាវេថ បណ្ឌិតោ*
*ឱកា អនោកមាគម្ម　វិវេកេ យត្ថ ទូរមំ*
*តត្រាភិរតិមិច្ឆេយ្យ　ហិត្វា កាមេ អកិញ្ចនោ*
*បរិយោទបេយ្យ អត្តានំ　ចិត្តក្លេសេហិ បណ្ឌិតោ ។*
*យេសំ សម្ពោធិយង្គេសុ　សម្មា ចិត្តំ សុភាវិតំ*
*អាទានប្បដិនិស្សគ្គេ　អនុបាទាយ យេ រតា*
*ខីណាសវា ជុតិមន្តោ　តេ លោកេ បរិនិព្វុតា ។*

បណ្ឌិតគួរលះបង់ធម៌ខ្មៅចេញ ញុំាងធម៌សឲ្យចម្រើនឡើង (ដោយវិធី) ចេញចាកអាល័យ គឺ កាមគុណ ហើយឈម

ទៅរកព្រះនិព្វាន ជាធម្មជាតមិនមានអាល័យ គប្បីលះបង់កាមទាំងឡាយចេញ ជាអ្នកមិនមានកង្វល់ ប្រាថ្នានូវសេចក្តីត្រេកអរក្នុងវិវេក ដែលពួកសត្វត្រេកអរបានដោយក្រនោះ បណ្ឌិតគួរ ញុំាងខ្លួនឲ្យផូរផង់ ចាកនូវគ្រឿងសៅហ្មងរបស់ចិត្ត ។ ចិត្តដែលបណ្ឌិតទាំងឡាយណា បានអប់រំល្អហើយក្នុងអង្គនៃធម៌ជាគ្រឿងត្រាស់ដឹងទាំងឡាយ ឬបណ្ឌិតទាំងឡាយណា មិនប្រកាន់មាំ ត្រេកអរតែក្នុងការលះនូវសេចក្តីប្រកាន់មាំ បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈ មានសេចក្តីរុងរឿង បរិនិព្វានក្នុងលោក ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា កណ្ហំ ធម្មំ (ធម៌ខ្មៅ) សេចក្តីថា លះ គឺលះបង់អកុសលធម៌ មានកាយទុច្ចរិតជាដើម ។ បទថា សុក្កំ ភាវេថ (ចម្រើនធម៌ស) សេចក្តីថា ភិក្ខុដែលជាបណ្ឌិត គួរចម្រើនធម៌ស មានកាយសុចរិតជាដើម តាំងអំពីចេញបួស រហូតដល់អរហត្តមគ្គ ។ ចម្រើនយ៉ាងណា? គឺ ចេញចាកអាល័យ ប្រារព្ធធម៌ដែលមិនមានអាល័យ ។ អធិប្បាយថា ធម៌ដែលជាហេតុធ្វើឲ្យមានអាល័យ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ហៅថា ឱកៈ ធម៌ជា

ហេតុធ្វើមិនឲ្យមានអាល័យ ទ្រង់ត្រាស់ហៅថា **អនោកៈ** បណ្ឌិតចេញចាកធម៌ដែលជាហេតុធ្វើឲ្យមានអាល័យ ហើយឈមទៅរក គឺ ប្រារព្ធព្រះនិព្វាន ពោលគឺ ធម៌ដែលមិនមានអាល័យ កាលប្រាថ្នាព្រះនិព្វាននោះ គួរចម្រើនធម៌ស ។ បទថា **តត្រាភិរតិមិច្ឆេយ្យ (គប្បីប្រាថ្នាសេចក្ដីត្រេកអរក្នុងវិវេក)** សេចក្ដីថា គប្បីប្រាថ្នានូវសេចក្ដីត្រេកអរឲ្យក្រៃលែងក្នុងវិវេក ដែលជាធម៌មិនមានអាល័យ គឺ ព្រះនិព្វាន ដែលសត្វទាំងនោះអភិរម្យបានដោយក្រ ។ បទថា **ហិត្វា កាមេ (លះកាមទាំងឡាយហើយ)** សេចក្ដីថា លះវត្ថុកាម និងកិលេសកាមហើយ ជាអ្នកអស់កង្វល់ គប្បីប្រាថ្នាសេចក្ដីត្រេកអរក្នុងវិវេក ។ បទថា **ចិត្តក្លេ-សេហិ (ចាកគ្រឿងសៅហ្មងនៃចិត្ត)** សេចក្ដីថា គប្បីធ្វើខ្លួនឲ្យផូរផង់ចាកនូវគ្រឿងសៅហ្មងរបស់ចិត្ត គឺ ឲ្យបរិសុទ្ធចាកនីវរណៈទាំង ៥ ។

បទថា **សម្ពោធិយង្គេសុ (ក្នុងធម៌ជាគ្រឿងត្រាស់ដឹង)** បានដល់ ក្នុងអង្គធម៌ដែលជាគ្រឿងត្រាស់ដឹង ។ បទថា **សម្មា ចិត្តំ សុភាវិតំ (អប់រំចិត្តល្អហើយដោយប្រពៃ)** សេចក្ដីថា (ជនទាំងឡាយណា) អប់រំ គឺ ចម្រើនចិត្តដោយល្អហើយ តាមហេតុ គឺ តាមន័យ ។ បទថា **អាទានប្បដិនិស្សគ្គេ (ក្នុងការលះបង់សេចក្ដីប្រកាន់)** សេចក្ដីថា ការប្រកាន់មាំ ត្រាស់ហៅថា **អាទាន** បណ្ឌិតទាំងឡាយណា មិនប្រកាន់មាំនូវអ្វីៗ ដោយឧបាទាន ៤ ត្រេកអរក្នុងការលះនូវសេចក្ដីប្រកាន់មាំ ពោលគឺ ការលះបង់សេចក្ដីប្រកាន់មាំនោះ ។

បទថា **ជុតិមន្តោ (រុងរឿង)** សេចក្ដីថា អ្នកមានអានុភាព គឺ ជាអ្នក

ញ៉ាំងធម៌ទាំងឡាយ មានខន្ធជាដើមឲ្យរុងរឿង ហើយតាំងនៅ ដោយពន្លឺ គឺ អរហត្តមគ្គញ្ញាណ ។ បទថា **តេ លោកេ** (ជនទាំងនោះ... **ក្នុងលោក**) ជាដើម សេចក្តីថា បណ្ឌិតទាំងឡាយនោះៗ រមែងជាអ្នកអស់អាសវៈហើយ រុងរឿងក្នុងខន្ធាទិលោកនេះ គឺ បរិនិព្វាន ដោយបរិនិព្វានពីរយ៉ាង គឺ ដោយបរិនិព្វានដែលមានឈ្មោះថា **សឧបាទិសេសនិព្វាន** ព្រោះកិលេសវដ្តៈដែលខ្ជួនធ្វើឲ្យអស់ហើយ ក្នុងវេលាដែលបានសម្រេចព្រះអរហត្ត និងដោយបរិ-និព្វានដែលមានឈ្មោះថា **អនុបាទិសេសនិព្វាន** ព្រោះខន្ធវដ្តៈដែលខ្ជួនធ្វើឲ្យអស់ហើយ ដោយរំលត់ចរិមចិត្ត (ចិត្តចុងក្រោយ) គឺ ដល់ការបញ្ញត្តិមិនបាន ដូចប្រទីបមានប្រេងអស់ ដូច្នោះ ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងភិក្ខុអាគន្តុកៈ

## ចប់ បណ្ឌិតវគ្គវណ្ណនា វគ្គទី ៦

ក្នុងវគ្គនេះរួមមាន ១១ រឿង


១.រឿងព្រះរាធៈ
២.រឿងភិក្ខុអស្សជិ និងបុនព្វសុកៈ
៣.រឿងព្រះឆន្នត្ថេរ
៤.រឿងព្រះមហាកប្បិនៈ
៥.រឿងបណ្ឌិតសាមណេរ
៦.រឿងព្រះលកុណ្ឌកភទ្ទិយៈ
៧.រឿងមាតារបស់នាងកាណា
៨.រឿងភិក្ខុ ៥០០ រូប
៩.រឿងព្រះថេរៈតាំងនៅក្នុងធម៌
១០.រឿងការស្តាប់ធម៌
១១.រឿងភិក្ខុអាគន្តុកៈ

# អរហន្តវគ្គ ទី ៧

## ១. រឿងពេទ្យឈ្មោះជីវក

[១៧] *ព្រះសាស្តា កាលប្រថាប់នៅក្នុងព្រៃស្វាយរបស់ពេទ្យឈ្មោះជីវក ទ្រង់ប្រារព្ធបញ្ហា ដែលពេទ្យជីវកទូលសួរ បានត្រាស់ព្រះធម្មទេសនានេះថា* ***គតទ្ធិនោ*** *(អ្នកដល់ផ្លូវឆ្ងាយ) ដូច្នេះជាដើម ។*

### ព្រះទេវទត្តធ្វើលោហិតុប្បាទកម្ម

*រឿងពេទ្យជីវកនេះ លោកបានឲ្យពិស្តារហើយ ក្នុងខន្ធកៈនោះឯង ។*

*សេចក្តីពិស្តារថា សម័យមួយ ព្រះទេវទត្តរួមគំនិតជាមួយនឹងព្រះរាជាព្រះនាមអជាតសត្រូវ ជាអ្នកមានចិត្តត្រូវទោសប្រទូស្តហើយ ឡើងកាន់ភ្នំគិជ្ឈកូដ ដោយគិតថា "យើងនឹងផ្តាច់ព្រះជន្មព្រះសាស្តា" ទើបប្រមៀលដុំថ្មទម្លាក់ចុះ ។ កំពូលភ្នំទាំងពីរ ទទួលដុំថ្មនោះមិនឲ្យធ្លាក់ចុះមក ។ បំណែកថ្មដែលបែកចេញអំពីដុំថ្មនោះ ខ្ទាតទៅប៉ះព្រះបាទរបស់ព្រះមានព្រះភាគ ញ៉ាំងព្រះលោហិតឲ្យពុរពងឡើង ។ វេទនាដ៏ខ្លាំងក្លាប្រព្រឹត្តទៅហើយ ។*

### ពេទ្យជីវកធ្វើការព្យាបាលដំទៅថ្វាយព្រះសម្ពុទ្ធ

*ភិក្ខុទាំងឡាយ យាងព្រះសាស្តាទៅកាន់សួនមទ្ទកុច្ឆិ ។ ព្រះសាស្តាមានព្រះបំណងនឹងស្តេចចេញចាកសួនឈ្មោះមទ្ទកុច្ឆិនោះ ទៅកាន់ជីវកម្ពវ័នរបស់*

ពេទ្យជីវក ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរនាំតថាគត ទៅកាន់ជីវកម្ពវ័ន របស់ពេទ្យជីវក" ។ ពួកភិក្ខុ ក៏បានយាងព្រះមានព្រះភាគទៅ កាន់ជីវកម្ពវ័នរបស់ពេទ្យជីវក ។ ពេទ្យជីវកដឹងរឿងនោះហើយ ក៏ទៅកាន់ សម្នាក់ព្រះសាស្តា ថ្វាយនូវភេសជ្ជៈដ៏ខ្លាំង (ថ្នាំខ្លាំង) ដើម្បីប្រយោជន៍ដល់ ការព្យាបាលដំបៅ រុំដំបៅស្រេចហើយ បានក្រាបទូលពាក្យនេះនឹងព្រះសាស្តា ថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គត្រូវផ្សំថ្នាំឲ្យដល់មនុស្សម្នាក់ ខាងក្នុង នគរ ខ្ញុំព្រះអង្គនឹងទៅកាន់សម្នាក់របស់មនុស្សនោះហើយ នឹង (ត្រឡប់) មក គាល់ព្រះអង្គវិញ ការរុំដំបៅនេះ ចូរតាំងនៅតាមនិយាម ដែលខ្ញុំព្រះអង្គបាន រុំទុកចុះ ទម្រាំខ្ញុំព្រះអង្គនឹងត្រឡប់មក" ។ ពេទ្យជីវក ទៅធ្វើកិច្ចដែលគួរធ្វើ ដល់បុរសនោះហើយ ត្រឡប់មកវិញ មិនមានឱកាសបានចូលទៅគាល់ព្រះអង្គ ព្រោះមកក្នុងវេលាបិទទ្វារ ។ គ្រានោះ សេចក្តីត្រិះរិះយ៉ាងនេះបានកើតឡើង ដល់ពេទ្យជីវកនោះថា "ឱ! ស្លាប់ហើយអញៗ បានធ្វើកម្មដ៏ធ្ងន់ហើយ អញ បានប្រគេនថ្នាំដ៏ខ្លាំង រុំដំបៅព្រះបាទរបស់ព្រះតថាគត ដូចជាបុរសសាមញ្ញ វេលានេះ ជាវេលាស្រាយនូវសំពត់រុំដំបៅនោះ កាលដំបៅនោះ ដែលអញ មិនទាន់ស្រាយ សេចក្តីក្តៅក្រហាយក្នុងព្រះសរីរៈរបស់ព្រះមានព្រះភាគ នឹង កើតរហូតមួយយប់ទល់ភ្លឺ ។ ដំបៅរបស់ព្រះសាស្តាក៏សះស្បើយហើយ ខណៈ នោះ ព្រះសាស្តាត្រាស់ហៅព្រះអានន្ទមក ហើយត្រាស់ប្រាប់ថា "ម្នាលអានន្ទ ពេទ្យជីវកមកក្នុងវេលាល្ងាច មិនបានឱកាសចូលមកគាល់តថាគត ក៏គិតថា

វេលានេះ ជាវេលាស្រាយសំពត់រុំដំបៅ អ្នកចូរស្រាយសំពត់រុំដំបៅនោះចុះ" ។ ព្រះថេរៈក៏ស្រាយសំពត់រុំដំបៅនោះតាមពាក្យព្រះពុទ្ធដីកា ។ មុខដំបៅក៏ជាសះស្បើយ ដូចក្រមរឈើ របើកចេញអំពីដើមឈើ ។

ព្រះអរហន្តមិនមានសេចក្តីក្តៅក្រហាយ

ព្រឹកឡើង ពេទ្យជីវកទៅកាន់សម្នាក់ព្រះសាស្តាយ៉ាងប្រញាប់ លុះទៅដល់ហើយ ក៏ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីក្តៅក្រហាយកើតឡើងក្នុងព្រះសរីរៈរបស់ព្រះអង្គដែរឬ?" ព្រះសាស្តាត្រាស់ថា "ជីវក សេចក្តីក្តៅក្រហាយទាំងពួងរបស់តថាគត បានស្ងប់រម្ងាប់ហើយ តាំងអំពីតថាគតគង់នៅត្រង់មណ្ឌលពោធិព្រឹក្សម្ល៉េះ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងព្រះធម៌ បានត្រាស់ព្រះគាថានេះថា ៖

គតទ្ធិនោ វិសោកស្ស វិប្បមុត្តស្ស សព្វធិ
សព្វគន្ថប្បហីនស្ស បរិឡាហោ ន វិជ្ជតិ ។

សេចក្តីក្តៅក្រហាយ រមែងមិនមានដល់លោកអ្នកមាន
ផ្លូវឆ្ងាយដើរដល់ហើយ មិនមានសេចក្តីសោក រួចស្រឡះ
ចាកធម៌ទាំងពួង (មានខន្ធជាដើម) មានកិលេសជា
គ្រឿងចាក់ស្រេះទាំងពួង លះបង់ហើយ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា គតទ្ធិនោ (អ្នកដល់ផ្លូវឆ្ងាយហើយ) បាន

ដល់ អ្នកមានផ្លូវឆ្ងាយដែលដើរដល់ហើយ ។ ឈ្មោះថា ផ្លូវឆ្ងាយមាន ២ យ៉ាង គឺ ផ្លូវឆ្ងាយ គឺ កន្តារៈ , ផ្លូវឆ្ងាយ គឺ វដ្តៈ បណ្តាផ្លូវ ២ យ៉ាងនោះ អ្នកដើរផ្លូវកន្តារ មិនទាន់ដល់ទីដែលខ្លួនប្រាថ្នាដរាបណា ក៏ឈ្មោះថា អ្នកដើរផ្លូវឆ្ងាយដរាបនោះ តែកាលផ្លូវឆ្ងាយនោះ ដែលគេដើរដល់ហើយ រមែងមានឈ្មោះថា អ្នកមានផ្លូវឆ្ងាយដែលដើរដល់ហើយ ។ ចំណែកសត្វទាំងឡាយដែលអាស្រ័យវដ្តៈ នៅក្នុងវដ្តៈដរាបណា ក៏មានឈ្មោះថា អ្នកដើរផ្លូវឆ្ងាយដរាបនោះ មានពាក្យសួរថា "ព្រោះហេតុអ្វី" ឆ្លើយថា ព្រោះមិនទាន់បានកាត់ផ្តាច់វដ្តៈ ។ សូម្បីព្រះអរិយបុគ្គលទាំងឡាយ មានព្រះសោតាបន្នជាដើម ក៏ឈ្មោះថា ជាអ្នកដើរផ្លូវឆ្ងាយដូចគ្នា ចំណែកព្រះខីណាស្រព កាត់ផ្តាច់វដ្តៈបានហើយ ទើបឈ្មោះថា អ្នកមានផ្លូវឆ្ងាយដែលដើរដល់ហើយ ។ បទថា **វិសោកស្ស (រកសេចក្តីសោកមិនបាន)** គឺឈ្មោះថា អ្នកមិនមានសេចក្តីសោក ព្រោះសេចក្តីសោក ដែលមានវដ្តៈជាមូលប្រាសទៅហើយ ។ បទថា **វិប្ប-មុត្តស្ស សព្វធិ (រួចផុតហើយក្នុងធម៌ទាំងពួង)** គឺ អ្នករួចស្រឡះចាកធម៌ទាំងពួង មានខន្ធជាដើម ។ បទថា **សព្វគន្ថប្បហីនស្ស (អ្នកលះកិលេសជាគ្រឿងជោតក្រងទាំងពួងបានហើយ)** គឺ ឈ្មោះថា អ្នកលះកិលេសជាគ្រឿងជោតក្រងទាំងពួងបាន ព្រោះកិលេសជាគ្រឿងជោតក្រងទាំង ៤ យ៉ាង ដែលខ្លួនលះបានហើយ ។ បទថា **បរិឡាហោ ន វិជ្ជតិ (សេចក្តីក្តៅក្រហាយរមែងមិនមាន)** សេចក្តីថា សេចក្តីក្តៅក្រហាយមាន ២ យ៉ាង គឺ សេចក្តីក្តៅក្រហាយ

ប្រព្រឹត្តទៅតាមផ្លូវកាយ ១ សេចក្តីក្តៅក្រហាយប្រព្រឹត្តទៅតាមផ្លូវចិត្ត ១ ។ បណ្តាសេចក្តីក្តៅក្រហាយ ២ យ៉ាងនោះ សេចក្តីក្តៅក្រហាយប្រព្រឹត្តតាមផ្លូវកាយ ដែលកើតឡើងដល់ព្រះខីណាស្រព ដោយអំណាចសម្ផស្សទាំងឡាយ មានក្តៅ និងត្រជាក់ជាដើម មិនទាន់ស្ងប់រម្ងាប់ទេ ពេទ្យជីវកទូលសួរសំដៅដល់ការក្តៅក្រហាយផ្លូវកាយ ។ តែព្រះសាស្តា ទ្រង់ផ្លាស់ប្តូរព្រះធម៌ទេសនា ដោយអំណាចនៃសេចក្តីក្តៅក្រហាយ ដែលប្រព្រឹត្តទៅផ្លូវចិត្ត ព្រោះព្រះអង្គឈ្លាសក្នុងទេសនាវិធី ព្រោះព្រះអង្គជាធម្មរាជា ទើបត្រាស់ថា "ម្នាលជីវក សេចក្តីក្តៅក្រហាយ រមែងមិនមានដល់ព្រះខីណាស្រព" ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងពេទ្យជីវក

# ២. រឿងព្រះមហាកស្សបៈ

ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះមហាកស្សបត្ថេរ ត្រាស់ព្រះធម៌ទេសនានេះថា **ឧយ្យុញ្ជន្តិ** (រមែងចេញ) ជាដើម ។

ធម្មទំនៀមរបស់ព្រះពុទ្ធដែលទ្រង់និងចារិក

សេចក្តីពិស្តារថា សម័យមួយ ព្រះសាស្តាទ្រង់ចាំវស្សានៅក្នុងក្រុងរាជគ្រឹះ ទ្រង់ត្រាស់ឲ្យប្រាប់ភិក្ខុទាំងឡាយថា "កន្លះខែទៀតតថាគតនឹងចេញទៅកាន់ទីចារិក" ។ បានឮថា ការត្រាស់ឲ្យប្រាប់ភិក្ខុទាំងឡាយថា កន្លះខែទៀត តថាគតនឹងចេញទៅកាន់ទីចារិក ដូច្នេះ ដោយទ្រង់បំណងថា ភិក្ខុទាំងឡាយនឹងធ្វើកិច្ចផ្សេងៗ មានការដុតបាត្រ និងជ្រលក់ចីវរជាដើម របស់ខ្លួនហើយ នឹងទៅតាមសប្បាយ នេះជាធម្មទំនៀមរបស់ព្រះពុទ្ធទាំងឡាយ ដែលទ្រង់មានព្រះបំណងនឹងស្តេចត្រាច់ទៅកាន់ទីចារិកជាមួយនឹងពួកភិក្ខុ ។ កាលភិក្ខុទាំងឡាយកំពុងធ្វើកិច្ចផ្សេងៗ មានការដុតបាត្រជាដើមនោះ សូម្បីព្រះមហាកស្សបត្ថេរ ក៏បោកចីវរទាំងឡាយរបស់ខ្លួនដែរ ។

ពួកភិក្ខុថាព្រះថេរៈលះបង់ញាតិ និងឧបដ្ឋាកមិនបាន

ពួកភិក្ខុលើកទោសថា "ព្រោះហេតុអ្វី ទើបព្រះថេរៈបោកចីវរ ក្នុងព្រះនគរនេះ ទាំងខាងក្នុង និងខាងក្រៅ មានមនុស្ស ១៨ កោដិ បណ្តាមនុស្សទាំងនោះ ពួកណាមិនមែនជាញាតិរបស់ព្រះថេរៈទេ ពួកនោះក៏ជាឧបដ្ឋាកដែរ

ពួកណាមិនមែនជាឧបដ្ឋាក ពួកនោះក៏ជាញាតិដែរ ជនទាំងនោះរមែងធ្វើសេចក្ដីគោរព (និង) សក្ការៈចំពោះព្រះថេរៈដោយបច្ច័យទាំង ៤ ព្រះថេរៈនោះ នឹងលះបង់ឧបដ្ឋាកមានប្រមាណប៉ុណ្ណោះ ហើយនឹងទៅទីណាបាន ប្រសិនបើលោកនិមន្តទៅបាននោះ ក៏ទៅមិនហួសអំពីភ្នំឈ្មោះ **មាបមាទៈ** នោះដែរ" ។ បានស្ដាប់មកថា ព្រះសាស្ដាស្ដេចយាងដល់ញកភ្នំណាហើយ ទ្រង់ត្រាស់ប្រាប់ភិក្ខុទាំងឡាយ ដែលព្រះអង្គគួរឲ្យត្រឡប់វិញថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរត្រឡប់ទៅវិញចុះ ហើយកុំប្រមាទ" ញកភ្នំនោះអ្នកស្រុកហៅថា "ញកភ្នំមាបមាទៈ" ពាក្យនោះ ភិក្ខុទាំងឡាយពោលសំដៅយកញកភ្នំមាបមាទៈ នោះឯង ។ សូម្បីព្រះសាស្ដាស្ដេចត្រាច់ទៅកាន់ទីចារិក ក៏ទ្រង់មានព្រះតម្រិះថា "ក្នុងនគរនេះ ទាំងខាងក្នុងទាំងខាងក្រៅ មានមនុស្ស ១៨ កោដិ ដូច្នេះ ត្រូវមានភិក្ខុសម្រាប់និមន្តទៅក្នុងពិធីមង្គល និងអពមង្គលរបស់មនុស្សទាំងឡាយ តថាគតមិនអាចធ្វើវិហារឲ្យទទេដោយគ្មានភិក្ខុបានឡើយ តើតថាគតគួរញុំាងភិក្ខុណាហ្ន៎ ឲ្យត្រឡប់ទៅវិញ ។ គ្រានោះ ព្រះអង្គទ្រង់មានព្រះតម្រិះយ៉ាងនេះថា "ក៏ពួកមនុស្សទាំងនោះ ជាញាតិរបស់មហាកស្សបៈផង ជាឧបដ្ឋាកផង កាលតថាគតឲ្យកស្សបៈត្រឡប់ទៅវិញ រមែងគួរ" ។ ព្រះអង្គទ្រង់ត្រាស់ទៅកាន់ព្រះថេរៈថា "កស្សបៈ តថាគតមិនអាចធ្វើវិហារឲ្យទទេបានទេ សេចក្ដីត្រូវការដោយភិក្ខុ ក្នុងទីធ្វើមង្គល និងអពមង្គលទាំងឡាយ របស់ពួកមនុស្សនឹងមាន អ្នក និងបរិស័ទរបស់ខ្លួន ចូរត្រឡប់វិញចុះ" ។ ព្រះថេរៈទូលថា "ព្រះ

ករុណា ព្រះអង្គ” ហើយនាំបរិស័ទត្រឡប់វិញ ។ ភិក្ខុទាំងឡាយលើកទោសលោកថា “អ្នកមានអាយុទាំងឡាយ អ្នកទាំងឡាយឃើញទេ ពួកយើងទើបតែនិយាយអម្បាញ់មិញនេះឯងមិនមែនឬ ពាក្យដែលពួកយើងនិយាយថា ព្រោះហេតុអ្វី ទើបព្រះមហាកស្សបៈបោកចីវរ លោកមិនទៅជាមួយព្រះសាស្ដាទេ ដូច្នេះ នោះជាការពិតហើយ” ។

ទ្រង់បង្ហាញហេតុដល់ដែលព្រះមហាកស្សបៈត្រឡប់

ព្រះសាស្ដា ទ្រង់ស្ដាប់នូវពាក្យទាំងឡាយ របស់ភិក្ខុទាំងនោះហើយ ទ្រង់ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយពោលអំពីរឿងអ្វី” ភិក្ខុទាំងនោះក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គពោលប្រារព្ធព្រះមហាកស្សបៈ” ដូច្នេះហើយ ក្រាបទូលរឿងរ៉ាវទាំងអស់តាមដែលខ្លួនបានពោលហើយ ។ ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យនោះហើយ ទ្រង់ត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលទោសកស្សបៈថា ជាប់ជំពាក់ក្នុងត្រកូល និងក្នុងបច្ច័យទាំងឡាយ (តែការពិត) កស្សបៈត្រឡប់ទៅវិញដោយធ្វើទុកក្នុងចិត្តថា យើងនឹងធ្វើតាមព្រះពុទ្ធដីកា” ។ ក៏កស្សបៈនោះ ក្នុងកាលមុនបានធ្វើសេចក្ដីប្រាថ្នាថា សូមឲ្យយើងជាមនុស្សកុំជាប់ជំពាក់ក្នុងបច្ច័យ ៤ មានឧបមាដូចជាព្រះច័ន្ទ អាចចូលទៅកាន់ត្រកូលទាំងឡាយបាន កស្សបៈនោះ មិនមានសេចក្ដីជាប់ជំពាក់ក្នុងត្រកូល ឬក្នុងបច្ច័យទាំងឡាយឡើយ តថាគតកាលនឹងពោលវត្តបដិបត្តិដែលប្រៀបដូចព្រះច័ន្ទ និងវត្តបដិបត្តិដែលជាវង្សរបស់ព្រះ

អរិយៈ ក៏បានពោលអាងដល់កស្សបៈជាដើមដែរ" ។

ព្រះសាស្តាទ្រង់ត្រាស់បុព្វចរិយារបស់ព្រះថេរៈ

ភិក្ខុទាំងឡាយ ទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន តើព្រះថេរៈបានធ្វើសេចក្តីប្រាថ្នាយ៉ាងនោះ តាំងអំពីកាលណាមក" ។

ព្រះ. ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចង់ស្តាប់ឬ ។

ពួកភិ. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តាត្រាស់ទៅកាន់ភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ ក្នុងទីបំផុតមួយសែនកប្បអំពីភទ្ទកប្បនេះទៅ ព្រះពុទ្ធទ្រង់ព្រះនាមថា **បទុមុត្តរៈ** ទ្រង់កើតឡើងក្នុងលោក" ដូច្នេះហើយ ទ្រង់ត្រាស់បុព្វចរិយារបស់ព្រះថេរៈទាំងអស់ តាំងពីលោកធ្វើសេចក្តីប្រាថ្នាទុកក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមថា បទុមុត្តរៈ ។

បុព្វចរិយានោះ ព្រះធម្មសង្គាហកាចារ្យ ធ្វើឲ្យពិស្តារហើយក្នុងព្រះបាលីដែលសម្តែងអំពីប្រវត្តិរបស់ព្រះថេរៈនុ៎ះឯង ។ ព្រះសាស្តា លុះទ្រង់ត្រាស់បុព្វចរិយារបស់ព្រះថេរៈឲ្យពិស្តារហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុយ៉ាងនេះឯង ទើបតថាគតពោលវត្តបដិបត្តិ ដែលប្រៀបដូចព្រះច័ន្ទ និងវត្តបដិបត្តិនៃវង្សរបស់ព្រះអរិយៈ និងអាងកស្សបៈបុត្ររបស់តថាគតឲ្យជាយ៉ាងនោះ ជាដើម ។ ការជាប់ជំពាក់ក្នុងបច្ច័យក្តី ត្រកូលក្តី វិហារក្តី បរិវេណក្តី រមែងមិនមានដល់បុត្ររបស់តថាគត ។ បុត្ររបស់តថាគត មិនជាប់ជំពាក់

នឹងអ៊ីៗ ឡើយ ដូចស្តេចហង្សចុះក្នុងកក់ ត្រាច់ទៅក្នុងកក់នោះ ហើយហើរទៅ ដូច្នោះ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងព្រះធម៌ ក៏ត្រាស់ព្រះគាថានេះថា ៖

ឧយ្យុញ្ជន្តិ សតីមន្តោ ន និកេតេ រមន្តិ តេ
ហំសាវ បល្លលំ ហិត្វា ឱកមោកំ ជហន្តិ តេ ។

ព្រះខីណាស្រពទាំងឡាយ មានស្មារតី រមែងខ្វល់-
ខ្វាយ រមែងមិនត្រេកអរ ក្នុងទីនៅអាស្រ័យ លោក
លះបង់ចោលស្រឡះនូវអាល័យទាំងអស់ ដូចហង្ស
លះបង់កក់ហើយហើរទៅ ដូច្នោះ ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បាទព្រះគាថាថា **ឧយ្យុញ្ជន្តិ សតីមន្តោ (បុគ្គលមានសតិរមែងចេញ)** សេចក្តីថា បុគ្គលអ្នកមានស្មារតី គឺថា បុគ្គលអ្នកមានអាសវៈអស់ហើយ រមែងខ្វល់ខ្វាយ រមែងប្រឹងប្រែងក្នុងគុណទាំងឡាយដែលខ្លួនបានសម្រេចហើយ មានឈាន និងវិបស្សនាជាដើម ដោយការនឹក ដោយការចូលសមាបត្តិ ដោយការចេញចាកសមាបត្តិ ដោយការតាំងចិត្តទុកក្នុងសមាបត្តិ និងដោយការពិចារណា ។ បទថា **ន និកេតេ រមន្តិ តេ (លោករមែងមិនត្រេកអរក្នុងទីនៅ)** គឺ ឈ្មោះថា សេចក្តីត្រេកអរក្នុងទីជម្រក រមែងមិនមានដល់ព្រះខីណាស្រពទាំងឡាយ ។ បទថា **ហំសាវ (ដូចហ្វូងហង្ស)**

*នេះជាប្រធាននៃធម៌ទេសនា ។ ក៏សេចក្ដីអធិប្បាយក្នុងបទនេះ ដូច្នេះថា ហង្ស បក្សី កាន់យកចំណីរបស់ខ្លួនក្នុងភក់ ដែលបរិបូណ៌ដោយចំណី ហើយហើរ ទៅ ដោយមិនមានអាល័យនឹងអ្វីៗ សូម្បីតែបន្តិចក្នុងទីនោះថា ទឹករបស់យើង ផ្កាបទុមរបស់យើង ផ្កាឧប្បលរបស់យើង ផ្កាបុណ្ឌរិកៈរបស់យើង ស្មៅរបស់ យើងឡើយ លះបង់ប្រទេសនោះហើយ ហើរទៅកាន់អាកាស យ៉ាងណាមិញ ព្រះខីណាស្រពទាំងឡាយ ក៏ដូច្នោះ សូម្បីនៅក្នុងទីណាមួយក៏ដោយ ក៏មិន ជាប់ជំពាក់នឹងវត្ថុទាំងឡាយ មានត្រកូលជាដើមដែរ ពេលត្រាច់ទៅ ក៏ទៅ តាមសប្បាយ ដោយមិនមានសេចក្ដីអាល័យថា វិហាររបស់យើង បរិវេណ របស់យើង ឧបដ្ឋាករបស់យើងឡើយ ។ បទថា* **ឱកមោកំ** *(សេចក្ដីអាល័យ) គឺ អាល័យ អធិប្បាយថា លះសេចក្ដីជាប់ជំពាក់ទាំងពួង ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ជនទាំងឡាយបានសម្រេចអរិយផលទាំង ឡាយ មានសោតាបត្តិផលជាដើម ។*

ចប់ រឿងព្រះមហាកស្សបត្ថេរ

# ៣. រឿងព្រះពេឡដ្ឋសីសៈ

ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះពេឡដ្ឋសីសៈ ត្រាស់ព្រះធម្មទេសនានេះថា **យេសំ សន្និចយោ នត្ថិ (អ្នកមិនមានការសន្សំ)** ដូច្នេះជាដើម ។

ទ្រង់បញ្ញត្តិសន្និធិការសិក្ខាបទ

បានស្តាប់មក ព្រះពេឡដ្ឋសីសៈនោះ ត្រាច់បិណ្ឌបាតតាមផ្លូវមួយក្នុងស្រុក ធ្វើកត្តកិច្ចហើយ ត្រាច់ទៅតាមផ្លូវដទៃទៀត កាន់យកបាយក្រៀមទៅកាន់វិហាររក្សាទុក ដោយគិតឃើញថា "ការត្រាច់ស្វែងរកអាហារបិណ្ឌបាតរឿយៗ រមែងជាទុក្ខ" ញ៉ាំងកាលឲ្យកន្លងទៅអស់ពីរបីថ្ងៃ ដោយសុខក្នុងឈានហើយ លុះសេចក្តីត្រូវការអាហារកើតឡើងដល់លោកៗ ក៏ឆាន់បាយក្រៀមនោះ ។ ពួកភិក្ខុដឹង ក៏តិះដៀល ហើយក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ ។ ព្រះសាស្តាក៏ទ្រង់បញ្ញត្តិសិក្ខាបទដល់ភិក្ខុទាំងឡាយ ដើម្បីហាមកុំឲ្យភិក្ខុទាំងឡាយធ្វើនូវការសន្សំទុកដាក់អាហារតទៅទៀត ព្រោះមានព្រះថេរៈជាហេតុហើយ ក៏ទ្រង់ប្រកាសថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះមិនមានទោសទេ ព្រោះលោកទុកដាក់អាហារដោយសេចក្តីប្រាថ្នាតិច និងធ្វើក្នុងកាលដែលតថាគតមិនទាន់បញ្ញត្តិសិក្ខាបទ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងព្រះធម៌ បានត្រាស់ព្រះគាថានេះថា ៖

*យេសំ សន្និចយោ នត្ថិ   យេ  បរិញ្ញាតភោជនា*

*សុញ្ញតោ អនិមិត្តោ ច   វិមោក្ខោ យេស គោចរោ*

*អាកាសេវ   សកុន្តានំ   គតិ តេសំ ទុរន្នយា ។*

*ពួកជនណា  មិនមានសេចក្ដីសន្សំ  ពួកជនណាកំណត់*

*ដឹងភោជនហើយ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្ត-*

*វិមោក្ខ និងអប្បណិហិតវិមោក្ខ ជាគោចរ គតិ គឺ ដំណើរ*

*របស់ពួកជននោះៗ គេកម្រដឹងបាន  ដូចដំណើរនៃពួក*

*សត្វស្លាបក្នុងអាកាស ដូច្នោះ ។*

អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា សន្និចយោ (ការសន្សំ) ប្រែថា ការសន្សំ មាន ២ យ៉ាង គឺ សន្សំកម្ម ១ សន្សំបច្ច័យ ១ ក្នុងការសន្សំ ២ យ៉ាងនោះ កម្មដែលជាកុសល និងអកុសល ឈ្មោះថា សន្សំកម្ម ។ បច្ច័យ ៤ ឈ្មោះថា សន្សំបច្ច័យ ។ បណ្ដាការសន្សំ ២ យ៉ាងនោះ ការសន្សំបច្ច័យ រមែងមិនមានដល់ភិក្ខុអ្នកនៅក្នុងវិហារ ដែលទុកដាក់ស្ករអំពៅមួយដុំ ទឹកដោះថ្លាប្រមាណមួយភាគបួន និងអង្ករប្រមាណមួយនាឡិ (តែ) រមែងមានដល់ភិក្ខុអ្នកទុកដាក់ច្រើនជាងនោះ ជនពួកណាមិនមានការសន្សំ ២ យ៉ាងនោះ ជនពួកនោះ ឈ្មោះថា មិនមានការសន្សំ ។*

*បទថា បរិញ្ញាតភោជនា (អ្នកកំណត់ដឹងភោជន) គឺ កំណត់ដឹងភោជន*

ដោយបរិញ្ញា ៣ ។ ការកំណត់ដឹងភោជនមានបបរជាដើម ថាជាបបរជាដើម ឈ្មោះថា **ញាតបរិញ្ញា** (កំណត់ដឹងវត្ថុដែលគេបានដឹង) ចំណែកការកំណត់ដឹងភោជន ដោយអំណាចនៃការសម្គាល់ឃើញថា ជារបស់បដិកូលក្នុងអាហារ ឈ្មោះថា **តីរណបរិញ្ញា** (កំណត់ដឹងដោយការពិចារណា) ។ ញាណជាហេតុដកនូវតម្រេក ដោយអំណាចសេចក្ដីពេញចិត្តក្នុងភោជនាហារចេញ ឈ្មោះថា **បហានបរិញ្ញា** (កំណត់ដឹងដោយការលះបង់) ជនទាំងឡាយណា កំណត់ដឹងភោជនដោយបរិញ្ញា ៣ នេះ ជនពួកនោះ ឈ្មោះថា កំណត់ភោជន ។

ក្នុងបទថា **សុញ្ញតោ អនិមិត្តោ ច (សុញ្ញតវិមោក្ខ និងអនិមិត្តវិមោក្ខ)** នេះ សូម្បីអប្បណិហិតវិមោក្ខ ក៏ព្រះមានព្រះភាគទ្រង់កាន់យកដោយពិត ។ ព្រោះថា បទទាំង ៣ នោះ ជាឈ្មោះនៃព្រះនិព្វាននោះឯង ។ ពិតណាស់ព្រះនិព្វានលោកពោលថា **សុញ្ញតវិមោក្ខ** ព្រោះសូន្យ ព្រោះមិនមានរាគៈ ទោសៈ មោហៈ និងផុតស្រឡះចាករាគៈ ទោសៈ មោហៈនោះ ព្រះនិព្វាននោះ ឈ្មោះថា **អនិមិត្តវិមោក្ខ** ព្រោះមិនមាននិមិត្ត ព្រោះមិនមាននូវនិមិត្តមានរាគៈជាដើម និងផុតស្រឡះចាកនិមិត្តទាំងនោះ ម្យ៉ាងទៀត លោកពោលថា **អប្បណិហិតវិមោក្ខ** ព្រោះថា មិនបានតាំងនៅ ព្រោះមិនមានបណិធិ គឺកិលេសដែលជាទីតាំងនៅនៃរាគៈជាដើម និងរួចផុតចាកបណិធិទាំងនោះ ។ វិមោក្ខទាំង ៣ យ៉ាងនោះ ជាអារម្មណ៍របស់ជនពួកណា ដែលជាអ្នកធ្វើព្រះនិព្វាននោះឲ្យជាអារម្មណ៍ ដោយអំណាចនៃការចូលសមាបត្តិ ដែលសម្បយុត្ត

ជាមួយផលចិត្ត ។

បទថា ***គតិ តេសំ ទុរន្នយា (គតិរបស់... ទៅតាមប្រាថ្នា)*** សេចក្តីថា ដូចជា ផ្លូវទៅនៃហ្វូងបក្សីព្ទដ៏អាកាស ទៅតាមប្រាថ្នា គឺ មិនអាចនឹងដឹងបាន ព្រោះមិនឃើញស្នាមជើង យ៉ាងណា គតិរបស់ជនទាំងឡាយដែលជាអ្នកមិនមានការសន្សំ ២ យ៉ាងនេះ អ្នកកំណត់ដឹងគោជនដោយបរិញ្ញា ៣ និងរបស់បុគ្គលអ្នកមានវិមោក្ខ មានប្រការដូចពោលហើយជាអារម្មណ៍ ក៏រមែងទៅតាមប្រាថ្នា គឺ មិនអាចបញ្ញត្តិ ព្រោះមិនប្រាកដដល់ការទៅថា "ទៅហើយក្នុងចំណែក ៥ នេះ គឺ ភព ៣ កំណើត ៤ គតិ ៥ វិញ្ញាណដ្ឋិតិ ៧ សត្តាវាស ៩ ដោយចំណែកឈ្មោះនេះៗ ដូច្នោះ" ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ។

ចប់ រឿងពេឡដ្ឋសីសត្ថេរ

# ៤. រឿងព្រះអនុរុទ្ធ

ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រះអនុរុទ្ធ ត្រាស់ព្រះធម្មទេសនានេះថា **យស្សាសវា បរិក្ខីណា (អាសវៈទាំងឡាយរបស់បុគ្គលណាអស់ហើយ)** ដូច្នេះជាដើម ។

ទេពធីតាប្រគេនសំពត់ដល់ព្រះអនុរុទ្ធ

សេចក្តីពិស្តារថា ថ្ងៃមួយ ព្រះថេរៈមានចីវរចាស់ហើយ ស្វែងរកចីវរក្នុងទីទាំងឡាយ មានគំនរសំរាមជាដើម ។ ស្ត្រីដែលធ្លាប់ជាភរិយារបស់ព្រះថេរៈតាំងអំពី ៣ ជាតិ មុន បានទៅកើតជាទេពធីតាឈ្មោះ ជាលិនី ក្នុងឋានតាវត្តិង្ស ។ នាងជាលិនីទេពធីតា ឃើញព្រះថេរៈកំពុងស្វែងរកកំណាត់សំពត់ក្នុងទីទាំងឡាយ ក៏បានកាន់យកសំពត់ទិព្វ ៣ ផ្ទាំង មានបណ្តោយ ១៣ ហត្ថ ទទឹង ៤ ហត្ថ មក ហើយគិតថា "ប្រសិនបើយើងប្រគេនលោកដោយអាការយ៉ាងនេះ ប្រាកដជាលោកមិនទទួល" ទើបយកសំពត់នោះទៅដាក់លើគំនរសំរាមមួយកន្លែងខាងមុខព្រះថេរៈ ដែលកំពុងស្វែងរកកំណាត់សំពត់ដោយធ្វើត្រឹមតែជាយសំពត់ប៉ុណ្ណោះឲ្យប្រាកដ ។ ព្រះថេរៈត្រាច់ស្វែងរកសំពត់តាមផ្លូវនោះ ឃើញជាយសំពត់ទាំងនោះហើយ ក៏ចាប់ជាយសំពត់នោះទាញមក ឃើញសំពត់ទិព្វ មានប្រមាណដូចដែលបានពោលហើយ កាន់យកសំពត់នោះដោយគិតថា សំពត់នេះ ជាសំពត់បង្សុកូលយ៉ាងឧក្រិដ្ឋ" ដូច្នេះហើយ ក៏

បៀសចេញទៅ ។

ក្នុងថ្ងៃធ្វើចីវររបស់ព្រះថេរៈនោះ ព្រះសាស្តាមានភិក្ខុ ៥០០ រូប ជាបរិវារ ស្តេចយាងទៅកាន់វិហារប្រថាប់លើអាសនៈ ។ សូម្បីព្រះមហាថេរៈ ៨០ រូប ក៏គង់នៅក្នុងទីនោះដែរ ។ ព្រះមហាកស្សបៈ គង់លើអាសនៈខាងដើម ដើម្បីដេរចីវរ ព្រះសារីបុត្រគង់ត្រង់កណ្តាល ព្រះអានន្ទគង់លើអាសនៈខាងចុង ។ ភិក្ខុសង្ឃមូរបេស ព្រះសាស្តាទ្រង់ដោតគូថម្ជុល ។ ព្រះមហាមោគ្គល្លានរង់ចាំនាំយកនូវវត្ថុឯណា ដែលភិក្ខុសង្ឃត្រូវការមកឲ្យសង្ឃ ។ សូម្បីនាងទេពធីតា ទៅកាន់ស្រុកហើយ បបួលអ្នកស្រុកឲ្យចាត់ចែងភិក្ខា ដោយពាក្យថា "នែអ្នកដ៏ចម្រើនទាំងឡាយ ថ្ងៃនេះ ព្រះសាស្តា ដែលមានព្រះអសីតិមហាសាវកហែហម ទ្រង់ធ្វើចីវរឲ្យព្រះអនុរុទ្ធត្ថេរដែលជាលោកម្ចាស់របស់យើងទាំងឡាយ ទ្រង់ប្រថាប់ក្នុងវិហារជាមួយនឹងភិក្ខុ ៥០០ រូប អ្នកទាំងឡាយចូរកាន់យកយាគូជាដើមទៅវិហារចុះ" ។ ឯព្រះមហាមោគ្គល្លានត្ថេរ បាននាំយកចំណិតនៃព្រីងធំមកក្នុងវេលាចន្លោះភត្ត ។ ភិក្ខុ ៥០០ ឆាន់ចំណិតនៃព្រីងនោះមិនអស់ ។ សក្កទេវរាជ ទ្រង់ធ្វើនូវការប្រស់ព្រំក្នុងទីធ្វើចីវរ ។ ផែនដីក៏ប្រែជាពណ៌ក្រហម ដូចគេជ្រលក់ដោយល័ខ ។ យាគូ របស់គួរទំពា និងភត្តដែលភិក្ខុទាំងឡាយឆាន់សល់ ហើយចាក់ចោល បានជាគំនរធំមួយ ។

ព្រះវីណាស្រពមិននិយាយទាក់ទងនឹងបច្ច័យ

ភិក្ខុទាំងឡាយក៏លើកទោសថា "ប្រយោជន៍អ្វីដល់ភិក្ខុ មានប្រមាណ

ប៉ុណ្ណោះ ដោយយាគូជាដើមដ៏ច្រើនយ៉ាងនេះ ព្រះអនុរុទ្ធគួរកំណត់ចំនួន (ភិក្ខុ) ហើយ គប្បីប្រាប់ញាតិ និងឧបដ្ឋាកថា ពួកអ្នកទាំងឡាយចូរនាំវត្ថុប្រមាណប៉ុណ្ណោះមក មិនមែនឬ ព្រះអនុរុទ្ធប្រហែលជាមានបំណងចង់ឲ្យគេដឹងថា ខ្លួនមានញាតិ និងឧបដ្ឋាកច្រើនហើយមើលទៅ" ។ លំដាប់នោះ ព្រះសាស្ដាត្រាស់សួរភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនិយាយអំពីអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គទាំងឡាយនិយាយអំពីរឿងនេះ" ទើបត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសំគាល់ថា វត្ថុនេះអនុរុទ្ធឲ្យគេនាំមកឬ" ភិក្ខុទាំងឡាយក្រាបទូលថា "ព្រះករុណាព្រះអង្គ" ព្រះសាស្ដាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អនុរុទ្ធបុត្ររបស់តថាគត មិនពោលពាក្យបែបនោះឡើយ ពិតណាស់ ព្រះខីណាស្រពទាំងឡាយ រមែងមិនពោលកថា ដែលបដិសំយុត្តដោយបច្ច័យទេ ក៏បិណ្ឌបាតនេះ កើតឡើងដោយអានុភាពរបស់ទេវតាទេតើ" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យស្សាសវា បរិក្ខីណា អាហារេ ច អនិស្សិតោ
សុញ្ញតោ អនិមិត្តោ ច វិមោក្ខោ យស្ស គោចរោ
អាកាសេវ សកុន្តានំ បទន្តស្ស ទុរន្នយំ ។

ជនណា អស់អាសវៈហើយ ទាំងមិនអាស្រ័យ (តណ្ហា និងទិដ្ឋិ)
ក្នុងអាហារ ជនណា មានសុញ្ញតវិមោក្ខ អនិមិត្តវិមោក្ខ និងអប្ប-

*ណិហិតវិមោក្ខជាគោចរ ដំណើររបស់ជននោះ គេកម្រដឹងបាន*

*ដូចដំណើរនៃពួកសត្វស្លាបឰដ៏អាកាស ដូច្នោះ ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា **យស្សាសវា** (អាសវៈទាំងឡាយរបស់បុគ្គលណា) សេចក្តីថា អាសវៈ ៤ របស់បុគ្គលណាអស់ហើយ ។ បទថា **អាហារេ ច អនិស្សិតោ** (មិនត្រូវអាស្រ័យតណ្ហា ទិដ្ឋិក្នុងអាហារ) សេចក្តីថា ដែលតណ្ហានិស្ស័យ និងទិដ្ឋិនិស្ស័យក្នុងអាហារ មិនអាស្រ័យហើយ ។*

*បទថា **បទន្តស្ស ទុរន្នយំ** (ដំណើររបស់បុគ្គលនោះៗ ដឹងបានលំបាក) សេចក្តីថា ដែលបុគ្គលមិនអាចដឹងស្នាមជើងរបស់បក្សីទាំងឡាយ ត្រាច់ទៅក្នុងអាកាសថា "បក្សីជាន់ក្នុងទីនេះ ហើយហើរទៅ ទង្គិចទីនេះដោយទ្រូងហើយហើរទៅ ទង្គិចទីនេះដោយសីសៈ ទង្គិចទីនេះដោយស្លាបទាំងពីរ យ៉ាងណានរណាៗ ក៏មិនអាចបញ្ញត្តនូវស្នាមរបស់ភិក្ខុបែបនេះ ដោយន័យជាដើមថា ភិក្ខុនេះទៅតាមផ្លូវនរក ឬទៅតាមផ្លូវតិរច្ឆាន" ដូច្នោះដែរ ។*

*ក្នុងកាលចប់ទេសនា ជនជាច្រើន ក៏បានសំរេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ។*

ចប់ រឿងព្រះអនុរុទ្ធ

# ៥. រឿងព្រះមហាកច្ចាយនៈ

*ព្រះសាស្ដា កាលទ្រង់ប្រថាប់នៅវត្តបុព្វារាម ទ្រង់ប្រារព្ធព្រះមហា-កច្ចាយនត្ថេរ ត្រាស់ព្រះធម្មទេសនាដូច្នេះថា* ***យស្សិន្ទ្រិយានិ (ឥន្ទ្រិយទាំងឡាយរបស់ភិក្ខុណា)*** *ជាដើម ។*

ព្រះថេរៈសរសើរការស្ដាប់ធម៌

*សេចក្ដីពិស្ដារថា សម័យមួយ ព្រះសាស្ដាដែលមានព្រះសាវកពួកធំហែហម ទ្រង់ប្រថាប់នៅខាងក្រោមប្រាសាទរបស់មិគារមាតា ក្នុងថ្ងៃមហាបវា-រណា ។ ក្នុងសម័យនោះឯង ព្រះមហាកច្ចាយនត្ថេរ គង់នៅក្នុងអវន្តីជនបទលោកសូម្បីមកអំពីទីឆ្ងាយ ក៏នៅតែសរសើរការស្ដាប់ធម៌ ព្រោះដូច្នេះ ទើបព្រះថេរៈធំៗ ទាំងឡាយ កាលនឹងគង់ ទើបគង់វៀរអាសនៈទុកដើម្បីព្រះមហាកច្ចាយនៈ ។ សក្កទេវរាជ ស្ដេចយាងមកអំពីទេវលោកទាំងពីរ មួយអន្លើដោយទេវបរិស័ទ ទ្រង់បូជាដោយគ្រឿងក្រអូប និងផ្កាកម្រង ដែលជារបស់ទិព្វចំពោះព្រះសាស្ដាហើយ ទ្រង់ប្រថាប់ឈប់រកមើលព្រះមហាកច្ចាយនៈ លុះមិនឃើញព្រះមហាកច្ចាយនៈ ក៏ទ្រង់ត្រិះរិះថា "ព្រោះហេតុអ្វីហ្ន៎ លោកម្ចាស់ដ៏ចម្រើនរបស់យើងមិនប្រាកដក្នុងទីនេះ ប្រសិនបើលោកម្ចាស់ដ៏ចម្រើនរបស់យើង បាននិមន្តមកទីនេះសោត នោះជាការប្រពៃណាស់" ព្រះថេរៈក៏បាននិមន្តមកក្នុងខណៈនោះឯង ហើយបានគង់លើអាសនៈរបស់ខ្លួន ។ សក្កទេវរាជទ្រង់*

ទតឃើញព្រះថេរៈ ក៏ទ្រង់ចាប់ព្រះបាទទាំងពីរហើយ ត្រាស់ថា "លោកម្ចាស់ដ៏ចម្រើនរបស់យើងនិមន្តមកហើយ យើងប្រាថ្នាឲ្យលោកម្ចាស់ដ៏ចម្រើននិមន្តមក" ដូច្នេះហើយ ក៏ទ្រង់ប្របាច់ព្រះបាទរបស់ព្រះថេរៈ ដោយព្រះហស្តទាំងពីររបស់ខ្លួន បូជាគ្រឿងក្រអូប និងផ្កាកម្រងដែលជាទិព្វចំពោះព្រះថេរៈ ថ្វាយបង្គំហើយ ប្រថាប់ឈរក្នុងទីដ៏សមគួរមួយ ។

## ទេវតាស្រឡាញ់ភិក្ខុអ្នកសង្រួមឥន្ទ្រិយ៍

ភិក្ខុទាំងឡាយ លើកទោសសក្កទេវរាជថា "សក្កទេវរាជ ធ្វើសក្ការៈដោយការរើសបុគ្គល ទ្រង់មិនធ្វើសក្ការៈបែបនេះចំពោះព្រះមហាថេរៈដ៏សេស ឃើញព្រះមហាកច្ចាយនៈហើយ ចាប់ព្រះបាទទាំងពីរដោយរហ័ស ត្រាស់ថា លោកម្ចាស់របស់យើងបាននិមន្តមកហើយ ការនិមន្តមកនៃលោកម្ចាស់របស់យើង ជាការប្រពៃណាស់ យើងចង់ឲ្យលោកម្ចាស់និមន្តមក" ដូច្នេះហើយ ទ្រង់ប្របាច់ព្រះបាទទាំងពីរដោយព្រះហស្តទាំងពីរ បូជា ថ្វាយបង្គំហើយ ទ្រង់ប្រថាប់ឈរក្នុងទីដ៏សមគួរ ។ ព្រះសាស្តា លុះទ្រង់ស្តាប់នូវពាក្យរបស់ភិក្ខុទាំងឡាយនោះហើយ ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកសង្រួមឥន្ទ្រិយ៍ទាំងឡាយ ដូចជាមហាកច្ចាយនៈ បុត្ររបស់តថាគតនេះ រមែងជាទីស្រឡាញ់ពេញចិត្តនៃទេវតាទាំងឡាយ" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងព្រះធម៌ ទើបទ្រង់ត្រាស់សម្តែងគាថានេះថា ៖

យស្សិន្ទ្រិយានិ សមថង្គតានិ

អស្សា យថា សារថិនា សុទន្តា
បហីនមានស្ស អនាសវស្ស
ទេវាបិ តស្ស បិហយន្តិ តាទិនោ ។

ឥន្ទ្រិយទាំងឡាយ របស់អ្នកណា ដល់នូវការស្ងប់រម្ងាប់
ដូចសេះ ដែលនាយសារថីហ្វឹកហ្វឺនរាបហើយ សូម្បីទេវតា
និងមនុស្សទាំងឡាយ ក៏ស្រឡាញ់អ្នកនោះឯង ដែលមាន
មានៈលះបង់ហើយ មិនមានអាសវៈ ជាបុគ្គលមានចិត្តនឹង
ធឹងមិនញាប់ញ័រ ។

អធិប្បាយគាថា

សេចក្ដីនៃព្រះគាថានោះ មានដូច្នេះ ៖

ឥន្ទ្រិយ ៦ របស់ភិក្ខុណាដល់នូវស្ងប់ គឺ ភាវៈដែលហ្វឹកហាត់ហើយ បានដល់ ជាឥន្ទ្រិយអស់នូវមានៈ ដូចសេះដែលនាយសារថីហ្វឹកហ្វឺនល្អហើយ ដូច្នោះ (សូម្បីពពួកទេវតា ក៏ស្រឡាញ់) ដល់ភិក្ខុនោះ ដែលឈ្មោះថា មានមានៈបានលះបង់ហើយ ព្រោះលះបង់មានៈទាំង ៩ បានហើយ ឈ្មោះថា ជាអ្នកមិនមានអាសវៈ ព្រោះមិនមានអាសវៈទាំង ៤ ។ បទថា **តាទិនោ** (ជាអ្នកតាំងមាំ) សេចក្ដីថា ទាំងពួកទេវតា ទាំងពួកមនុស្សរមែងរីករាយ គឺរមែងចង់ឃើញ និងចង់ជួបភិក្ខុបែបនោះ ។

ក្នុងវេលាចប់ព្រះធម្មទេសនា ជនជាច្រើន ដែលមកប្រជុំគ្នាក្នុងទីនោះ

*បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។*

ចប់ រឿងព្រះមហាកច្ចាយនត្ថេរ

# ៦. រឿងព្រះសារីបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធ ព្រះសារីបុត្រ ត្រាស់ព្រះធម្មទេសនានេះថា **បឋវីសមោ (ស្មើដោយផែនដី)** ជាដើម ។*

## ព្រះសារីបុត្រត្រូវភិក្ខុមួយរូបប្តឹង

*សេចក្តីពិស្តារថា សម័យមួយ ពេលចេញវស្សាហើយ ព្រះសារីបុត្រ ប្រាថ្នានឹងចៀសចេញទៅកាន់ទីចារិក ទើបចូលទៅលាព្រះមានព្រះភាគ លុះថ្វាយបង្គំលាហើយ ក៏និមន្តទៅជាមួយនឹងបរិវាររបស់ខ្លួន ។ ភិក្ខុទាំងឡាយដទៃ ក៏ជូនដំណើរព្រះថេរៈដែរ ។ ព្រះថេរៈប្រាស្រ័យនឹងភិក្ខុទាំងនោះហើយ ទើបប្រាប់ឲ្យត្រឡប់ទៅវិញ ។ ភិក្ខុមួយរូបមិនប្រាកដឈ្មោះ និងគោត្រ បានគិតថា "ព្រះថេរៈគួរតែប្រាស្រ័យចរចាជាមួយយើងដោយឈ្មោះ និងគោត្របន្តិច ហើយឲ្យយើងត្រឡប់ទៅវិញ" ។ ព្រះថេរៈមិនបានយកចិត្តទុកដាក់ចំពោះលោក ក្នុងចំណោមភិក្ខុសង្ឃជាច្រើន ។ ភិក្ខុនោះ ក៏ចងអាឃាតនឹងព្រះថេរៈថា "ព្រះថេរៈមិនសរសើរយើង មិនប្រាស្រ័យជាមួយនឹងយើងដូចភិក្ខុដទៃ" ។ សូម្បីជាយសង្ឃាដិរបស់ព្រះថេរៈ ក៏បានប៉ះសរីរៈរបស់ភិក្ខុនោះដែរ ។ សូម្បីភិក្ខុនោះ ក៏បានចងអាឃាតនឹងព្រះថេរៈដោយហេតុនោះឯង ។ ភិក្ខុនោះដឹងថា ឥឡូវនេះ ព្រះថេរៈនឹងកន្លងឧបចារៈវិហារ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះសារីបុត្រប្រហារខ្ញុំ*

ព្រះអង្គដូចទំលាយនូវគុម្ពត្រចៀក ហើយមិនទាន់សូមទោសខ្ញុំព្រះអង្គផង ក៏ចៀសចេញទៅកាន់ទីចារិក ដោយសំអាងថា ជាអគ្គសាវករបស់ព្រះអង្គ” ។ ព្រះសាស្តា ក៏ត្រាស់ឲ្យហៅព្រះថេរៈមកវិញ ។

ព្រះថេរៈប្រៀបធៀបខ្លួននៅនឹងរបស់ ៩ យ៉ាង

ក្នុងខណៈនោះឯង ព្រះមហាមោគ្គល្លាន និងព្រះអានន្ទ គិតថា “ព្រះសាស្តាមិនមែនទ្រង់មិនជ្រាបថា បងប្រុសរបស់ពួកយើងមិនបានប្រហារភិក្ខុរូបនោះទេ ប៉ុន្តែព្រះអង្គមានព្រះបំណងនឹងឲ្យបងប្រុសពួកយើងបន្លឺនូវសីហនាទ ដូច្នេះ យើងនឹងឲ្យបរិស័ទប្រជុំគ្នា” ។ ព្រះថេរៈទាំងពីរអង្គនោះ មានកូនសោរនៅក្នុងព្រះហស្ត ក៏បើកទ្វារបរិវេណហើយពោលថា “អ្នកមានអាយុទាំងឡាយចូរចេញមក អ្នកមានអាយុទាំងឡាយចូរចេញមក ឥឡូវនេះ ព្រះសារីបុត្រនឹងបន្លឺសីហនាទនៅចំពោះព្រះភក្ត្រព្រះមានព្រះភាគ” ពោលដូច្នេះហើយ ក៏ឲ្យភិក្ខុសង្ឃជាច្រើនប្រជុំគ្នា ។

ចំណែកព្រះថេរៈ ថ្វាយបង្គំព្រះសាស្តាហើយ គង់ក្នុងទីដ៏សមគួរមួយ លំដាប់នោះ ព្រះសាស្តាត្រាស់សួរព្រះថេរៈថា “ម្នាលសារីបុត្រ តើរឿងនោះយ៉ាងនោះពិតមែនឬ” ព្រះថេរៈមិនទាន់ក្រាបទូលព្រះសាស្តាថា “បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានប្រហារភិក្ខុនេះទេ” តែបានពោលនូវគុណកថារបស់ខ្លួនថា “បពិត្រព្រះអង្គដ៏ចម្រើន សតិដែលប្រព្រឹត្តទៅក្នុងកាយ (កាយគតាសតិ) របស់ភិក្ខុណាមិនមាន គឺ ភិក្ខុណាមិនមានកាយគតាសតិ ភិក្ខុនោះធ្វើ

ឲ្យប៉ះសព្រហ្មចារីណាមួយក្នុងសាសនានេះ មិនទាន់បានសូមទោស ហើយចៀសចេញទៅកាន់ទិស រមែងមានជាពិតប្រាកដ” ដូច្នេះ ហើយប្រកាសនូវភាវៈនៃខ្លួនជាអ្នកមានចិត្តដូចជាដី ទឹក ភ្លើង ខ្យល់ សំពត់ជូតធូលី ក្មេងចណ្ឌាល គោឧសភៈបាក់ស្នែង ការរង្កៀសកាយរបស់ខ្លួនដូចជាសាកសពពស់ជាដើម និងការរក្សានូវកាយរបស់ខ្លួនដូចជាកាជនៈប្រេង ដោយមានន័យយ៉ាងនេះថា “បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលរមែងចោលរបស់ស្អាតខ្លះ មិនស្អាតខ្លះទៅលើផែនដី ផែនដីមិនត្រេកអរ មិនទោមនស្សយ៉ាងណា ចិត្តរបស់ខ្ញុំព្រះអង្គ ក៏ដូច្នោះដែរ” កាលព្រះថេរៈពោលគុណរបស់ខ្លួនដោយ ការឧបមាទៅទីង៩វត្ថុ ៩ យ៉ាងនេះហើយ មហាប្រឹថពីក៏កម្រើកញាប់ញ័រ រហូតដល់ទឹកទ្រផែនដីក្នុងវារៈទាំង ៩ ។ ក៏ក្នុងវេលាដែលព្រះថេរៈនាំឧបមាដោយសំពត់ជូតធូលី ក្មេងចណ្ឌាល និងកាជនៈប្រេងមក ភិក្ខុដែលជាបុថុជ្ជនក៏មិនអាចទប់ទឹកភ្នែកបាន ធម្មសង្វេគក៏បានកើតឡើងដល់ភិក្ខុទីណាស្រេពទាំងឡាយ ។ កាលព្រះថេរៈកំពុងពោលគុណរបស់ខ្លួននោះឯង សេចក្តីក្តៅក្រហាយក៏កើតឡើងក្នុងសរីរៈទាំងមូល របស់ភិក្ខុដែលពោលបង្កាច់ព្រះសារីបុត្រនោះ ។ ក្នុងនោះឯង ភិក្ខុនោះក៏ក្រាបចុះទៀបបាទមូលរបស់ព្រះមានព្រះភាគ ហើយប្រកាសទោសរបស់ខ្លួន ព្រោះការពោលបង្កាច់ព្រះសារីបុត្រដោយពាក្យមិនពិត ។

### ចិត្តរបស់ព្រះសារីបុត្រដូចជាផែនដី

ព្រះសាស្តាត្រាស់ហៅព្រះថេរៈមកហើយ ត្រាស់ថា “ម្នាលសារីបុត្រ

អ្នកចូរអត់ទោសឲ្យមោឃបុរសនេះផង ក្នុងពេលដែលសីសៈរបស់គេមិនទាន់បែកជា ៧ ចំរៀក" ។ ព្រះថេរៈគន់ប្រហោងផ្គងអញ្ជលីក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គព្រមអត់ទោសឲ្យអ្នកដ៏មានអាយុនោះ និងសូមឲ្យអ្នកមានអាយុនោះ អត់ទោសឲ្យខ្ញុំព្រះអង្គផង បើទោសរបស់ខ្ញុំព្រះអង្គមាន" ។ ភិក្ខុទាំងឡាយពោលថា "អ្នកដ៏មានអាយុទាំងឡាយ អ្នកទាំងឡាយចូរមើលព្រះថេរៈដែលជាអ្នកមានគុណមិនថោកថយចុះ លោកមិនបានញុំាំងសេចក្តីក្រោធ ឬការប្រទូសសូម្បីមានប្រមាណតិចតួច ឲ្យកើតឡើងចំពោះភិក្ខុដែលពោលបង្កាច់ដោយមុសាវាទបែបនេះ មិនត្រឹមតែប៉ុណ្ណោះ បានគន់ប្រហោងផ្គងអញ្ជលី សូមឲ្យភិក្ខុនោះអត់ទោសឲ្យទៀតផង" ។

ព្រះសាស្តា ទ្រង់ស្តាប់នូវកថានោះហើយ ត្រាស់សួរភិក្ខុទាំងនោះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនិយាយគ្នាអំពីរឿងអ្វី" ភិក្ខុទាំងឡាយទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គនិយាយអំពីរឿងឈ្មោះនេះ" ក៏ទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ នរណាៗ ក៏មិនអាចញុំាំងសេចក្តីក្រោធ ឬការប្រទូសឲ្យកើតឡើងដល់ភិក្ខុ ដូចជាសារីបុត្របានដែរ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់សារីបុត្រដូចជាផែនដី ដូចជាសសរខឿន និងដូចជាអន្លង់ទឹកដ៏ថ្លា" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

បឋវីសមោ នោ វិរុជ្ឈតិ ឥន្ទខីលូបមោ តាទិ សុព្វតោ
រហទោវ អបេតកទ្ទមោ សំសារា ន ភវន្តិ តាទិនោ ។

ភិក្ខុមានចិត្តដូចផែនដី មិនក្រោធ មានវត្តល្អ មានចិត្តនឹងធឹងដូចសសរគោល មានចិត្តថ្លា ដូចជាអន្លង់ទឹកប្រាសចាកភក់ សង្សារទាំងឡាយរបស់ភិក្ខុបែបនោះរមែងមិនមាន ។

អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះ មានដូច្នេះ ៖

ម្នាលភិក្ខុទាំងឡាយ ជនទាំងឡាយ រមែងចោលរបស់ស្អាត មានគ្រឿងក្រអូប និងផ្កាកម្រងជាដើមខ្លះ រមែងចោលរបស់មិនស្អាត មានមូត្រនិងលាមកជាដើមខ្លះ ទៅលើផែនដី ។ មួយវិញទៀត ក្មេងជាដើមរមែងបន្ទោបង់ឧច្ចារៈខ្លះ បស្សាវៈខ្លះ ទៅលើសសរខឿន ដែលកប់ទុកជិតទ្វារក្រុង តែជនទាំងឡាយដទៃ រមែងធ្វើសក្ការបូជាសសរខឿននោះ ដោយវត្ថុទាំងឡាយមានគ្រឿងក្រអូប និងផ្កាកម្រងជាដើម ព្រោះការធ្វើនោះ សេចក្តីត្រេកអរ និងសេចក្តីមិនត្រេកអរ រមែងមិនកើតឡើងដល់ផែនដី ឬសសរខឿននោះឡើយយ៉ាងណា ភិក្ខុជាខីណាស្រព ឈ្មោះថា មានចិត្តនឹងធឹង ព្រោះមិនញាប់ញ័រដោយលោកធម៌ទាំង ៨ ដែលឈ្មោះថា អ្នកមានវត្តល្អ ព្រោះវត្តទាំងឡាយល្អ ភិក្ខុនោះក៏ដូច្នោះដែរ កាលជនទាំងឡាយធ្វើនូវសក្ការៈបូជាក្តី និងមិនធ្វើនូវសក្ការៈបូជាក្តី រមែងមិនត្រេកអរ មិនទោមនស្ស ថា ជនទាំងនេះធ្វើនូវសក្ការៈបូជាយើងដោយបច្ច័យ ៤ ប៉ុន្តែជនទាំងនេះ មិនធ្វើសក្ការៈបូជាយើង

សោះ ភិក្ខុជាខីណាស្រពនោះ រមែងជាអ្នកមានចិត្តដូចផែនដី និងដូចជាសសរខឿន ដូច្នោះឯង ។ ក៏អន្លង់ទឹកដែលប្រាសចាកកកក់ហើយ ជាអន្លង់ទឹកថ្លាយ៉ាងណា ភិក្ខុជាខីណាស្រពនោះ ក៏ឈ្មោះថា មានកកក់ទៅប្រាសហើយ ដោយកកក់ទាំងឡាយ មានកកក់ គឺ រាគៈជាដើម ព្រោះជាអ្នកមានកិលេសទៅប្រាសហើយ រមែងជាអ្នកមានចិត្តថ្លាផង់ ដូច្នោះ ។

បទថា **តាទិនោ (ជាបុគ្គលនឹងធឹង)** សេចក្តីថា ក៏ឈ្មោះថា សង្សារទាំងឡាយ រមែងមិនមានដល់ភិក្ខុនោះ គឺ បុគ្គលបែបនោះ ដោយអំណាចនៃការត្រាច់រង្គាត់ទៅក្នុងសុគតិ និងទុគ្គតិទាំងឡាយ ។

ក្នុងកាលចប់ព្រះធម្មទេសនា ភិក្ខុ ៩ ពាន់រូប បានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

ចប់ រឿងព្រះសារីបុត្រ

# ៧. រឿងព្រះតិស្សៈអ្នកក្រុងកោសម្ពី

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធសាមណេរ របស់ព្រះតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **សន្តំ តស្ស មនំ ហោតិ (ចិត្តរបស់លោកដែលរួចផុតវិសេសហើយ... ជាចិត្តស្ងប់ហើយ)** ជាដើម ។

ព្រះតិស្សៈបានសម្រេចព្រះអរហត្តមុនអាចារ្យ

បានស្តាប់មកថា កុលបុត្រអ្នកក្រុងកោសម្ពីម្នាក់ បានបួសក្នុងព្រះពុទ្ធសាសនា ឧបសម្បទាហើយប្រាកដនាមថា កោសម្ពីវាសីតិស្សត្ថេរ ។ ព្រះថេរៈនោះចាំវស្សានៅក្នុងក្រុងកោសម្ពី លុះចេញវស្សា ឧបដ្ឋាករបស់លោក បាននាំត្រៃចីវរ ទឹកដោះថ្លា និងស្ករអំពៅ ទៅតំកល់ក្នុងទីជិតព្រះបាទរបស់លោក ។ គ្រានោះ ព្រះថេរៈក៏សួរឧបដ្ឋាកនោះថា ម្នាលឧបាសក នេះជាអ្វី ?

ឧបដ្ឋាក. លោកម្ចាស់ ខ្ញុំព្រះករុណានិមន្ត លោកម្ចាស់ឲ្យចាំវស្សាទីនេះមិនមែនឬ ធម្មតាពួកភិក្ខុអ្នកចាំវស្សានៅក្នុងវិហាររបស់ពួកខ្ញុំ រមែងបានលាភនោះ លោកម្ចាស់និមន្តទទួលយកចុះ ។

ព្រះថេរៈ. ណ្ហើយចុះ ឧបាសក សេចក្តីត្រូវការដោយវត្ថុនេះ របស់អាត្មាមិនមានទេ ។

ឧបដ្ឋាក. លោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី? ។

ព្រះថេរៈ. សូម្បីសាមណេរ ដែលជាកប្បិយការកៈក្នុងសំណាក់របស់

អាត្មា ក៏មិនមានដែរ ឧបាសក ។

ឧបដ្ឋាក. លោកម្ចាស់ដ៏ចម្រើន ប្រសិនបើលោកម្ចាស់មិនមានកប្បិយការកៈ ខ្ញុំព្រះករុណានឹងឲ្យបុត្ររបស់ខ្ញុំបួសជាសាមណេរ ក្នុងសម្នាក់របស់លោកម្ចាស់ ។

ព្រះថេរៈក៏ទទួលដោយតុណ្ហីភាព ។ ឧបាសកនោះ នាំបុត្ររបស់ខ្លួនដែលមានអាយុ ៧ ខួប ទៅកាន់សម្នាក់របស់ព្រះថេរៈហើយ ថ្វាយបង្គំ រួចទូលថា "សូមលោកម្ចាស់បំបួសក្មេងនេះចុះ" ។ គ្រានោះ ព្រះថេរៈកក់សក់របស់ក្មេងនោះឲ្យសើមហើយ ឲ្យតចបញ្ចកកម្មដ្ឋាន ហើយបំបួសក្មេងនោះ ។ ក្នុងវេលាកោរសក់រួចនោះឯង កុមារនោះ ក៏បានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទា ។ ព្រះថេរៈលុះបំបួសកុមារនោះហើយ បានគង់នៅទីនោះអស់កន្លះខែ ក៏គិតថា "យើងនឹងទៅគាល់ព្រះសាស្តា ទើបឲ្យសាមណេរកាន់បន្ទេចកណ្ឌៈ ធ្វើដំណើរទៅដល់វិហារមួយក្នុងរវាងផ្លូវ ។ សាមណេរបានចាត់ចែង រៀបចំសេនាសនៈប្រគេនព្រះឧបជ្ឈាយ៍ ។ កាលសាមណេររវល់តែចាត់ចែង រៀបចំសេនាសនៈប្រគេនព្រះឧបជ្ឈាយ៍ វេលាក៏អស់ទៅ ។ ព្រោះហេតុនោះ ទើបសាមណេរមិនអាចចាត់ចែងសេនាសនៈសម្រាប់ខ្លួនបាន ។

គ្រានោះ ព្រះថេរៈសួរសាមណេរថា "សាមណេរ អ្នកបានចាត់ចែងទីនៅរបស់ខ្លួនហើយឬ?"

សាមណេរ. លោកម្ចាស់ ខ្ញុំព្រះករុណាមិនទាន់មានឱកាសដើម្បីចាត់

បែងទេ ។

## ភ្នែករបស់សាមណេរបែកព្រោះអាចារ្យ

ព្រះថេរៈពោលថា "បើដូច្នេះ ចូរនៅក្នុងទីនៅរបស់ខ្ញុំករុណាចុះ ការនៅក្នុងទីសម្រាប់អាគន្តុកៈ រមែងលំបាក" លុះពោលដូច្នេះហើយ នាំសាមណេរនោះចូលទៅកាន់សេនាសនៈរបស់ខ្លួន ។ ធម្មតាព្រះថេរៈជាបុថុជ្ជន គ្រាន់តែដាក់ខ្នងដល់កន្ទេលប៉ុណ្ណោះ ក៏លង់លក់ភ្លាម ។ សាមណេរគិតថា "ថ្ងៃនេះជាថ្ងៃទី ៣ របស់យើង ដែលជាអ្នកសឹងនៅក្នុងទីប្រក់ទីបាំងជាមួយនឹងព្រះឧបជ្ឈាយ៍ ប្រសិនបើយើងដេកលក់ ភ្ញាក់ឡើងមិនទាន់អរុណរះ ព្រះថេរៈនឹងត្រូវអាបត្តិ (សហសេយ្យាបត្តិ) យើងនឹងអង្គុយតែម្យ៉ាង ញុំាងកាលឲ្យកន្លងទៅ" ។ សាមណេរអង្គុយពែនភ្នែនជិតគ្រែព្រះឧបជ្ឈាយ៍ ញុំាងរាត្រីឲ្យកន្លងទៅ ។ ព្រះថេរៈក្រោកឡើងក្នុងវេលាជិតភ្លឺ គិតថា "គួរឲ្យសាមណេរចេញ" ទើបចាប់ផ្លិតដែលដាក់ក្នុងទីម្ខាងនៃគ្រែ យកចុងផ្លិតវាយកន្ទេលរបស់សាមណេរ លើកផ្លិតឡើងលើហើយ ពោលថា "សាមណេរចូរចេញទៅខាងក្រៅ ផ្លិតបុកភ្នែកសាមណេរបែកក្នុងខណៈនោះឯង" សាមណេរនោះសួរថា "លោកម្ចាស់ លោកម្ចាស់មានការអ្វី" កាលព្រះថេរៈពោលថា "ចូរក្រោកឡើងចេញទៅខាងក្រៅ" ក៏មិនបានពោលថា "លោកម្ចាស់ ភ្នែករបស់ខ្ញុំព្រះករុណាបែកហើយ" បិទភ្នែកដោយដៃម្ខាងដើរចេញទៅខាងក្រៅ ។ ក្នុងវេលាធ្វើវត្តសាមណេរមិនបានអង្គុយស្ងៀម ដោយសំអាងថា ភ្នែករបស់យើងខ្វាក់ឡើយ ។ ទប់

ក្អែកដោយដៃម្ខាង កាន់អំបោសដោយដៃម្ខាង បោសវច្ចកុដិ និងទីសម្រាប់លុបលាងមុខ តម្កល់ទឹកសម្រាប់លុបលាងហើយ បោសបរិវេណ ។ សាមណេរនោះ កាលប្រគេនឈើជម្រះធ្មេញចំពោះព្រះឧបជ្ឈាយ៍ បានប្រគេនដោយដៃម្ខាង ។

## អាចារ្យសូមទោសសិស្ស

គ្រានោះ ព្រះឧបជ្ឈាយ៍ពោលនឹងសាមណេរនោះថា "សាមណេរ អ្នកមិនពេញចិត្តឬ ទើបប្រគេនឈើជម្រះធ្មេញដល់អាចារ្យ ឬឧបជ្ឈាយ៍ដោយដៃម្ខាង" ។

សាមណេរ. លោកម្ចាស់ ខ្ញុំព្រះករុណាក៏បានដឹងថា នុ៎ះមិនមែនជាវត្តដែរ ប៉ុន្តែដៃរបស់ខ្ញុំព្រះករុណាម្ខាងទៀតមិនទំនេរ ។

ព្រះថេរៈ. សាមណេរ មានបញ្ហាអ្វី ។

សាមណេរ ក៏ប្រាប់រឿងរ៉ាវទាំងអស់នោះដល់ព្រះឧបជ្ឈាយ៍ ។ ព្រះថេរៈលុះបានស្តាប់ហើយ ក៏មានចិត្តតក់ស្លុត ពោលថា ឱ! យើងបានធ្វើកម្មធ្ងន់ណាស់ ហើយក៏សូមទោសសាមណេរថា "ម្នាលសប្បុរស អត់ទោសឲ្យខ្ញុំករុណាផង ខ្ញុំករុណាមិនដឹងនូវរឿងនោះ សូមអ្នកជាសប្បុរស ចូរជាទីពឹងដល់ខ្ញុំករុណាផង" ពោលដូច្នេះហើយ អង្គុយច្រហោង ផ្គងអញ្ជលី នៅទីជិតជើងសាមណេរអាយុ ៧ ខួប ។ លំដាប់នោះ សាមណេរប្រាប់ព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនបាននិយាយដើម្បីត្រូវការឲ្យលោកម្ចាស់

សូមទោសខ្ញុំព្រះករុណាទេ ខ្ញុំករុណាមានបំណងចង់តាមរក្សាចិត្តរបស់លោកម្ចាស់ ទើបបាននិយាយយ៉ាងនេះ" ក្នុងសេចក្តីនេះ ទោសរបស់លោកម្ចាស់ក៏មិនមែន ទោសរបស់ខ្ញុំព្រះករុណាក៏មិនមែន វាជាទោសរបស់វដ្តៈប៉ុណ្ណោះ សូមលោកម្ចាស់កុំគិតឡើយ ខ្ញុំករុណាខ្លាចលោកម្ចាស់មានសេចក្តីក្តៅក្រហាយ ទើបមិនប្រាប់លោកម្ចាស់ ព្រះថេរៈសូម្បីសាមណេរលួងលោមឲ្យបានធូរចិត្ត ក៏នៅតែមិនធូរស្រាល រីតតែមានសេចក្តីតក់ស្លុតខ្លាំងឡើងៗ កាន់បង្វេចកណ្ឌៈរបស់សាមណេរទៅកាន់សម្នាក់ព្រះសាស្តា ។ សូម្បីព្រះសាស្តា ក៏ទ្រង់ឃើញព្រះថេរៈនិមន្តមកដែរ ។ ព្រះថេរៈនោះ ចូលទៅថ្វាយបង្គំព្រះសាស្តា ធ្វើសេចក្តីរីករាយជាមួយព្រះអង្គហើយ ត្រូវព្រះអង្គសួរថា "ម្នាលភិក្ខុ អ្នកល្មមអត់ធន់បានឬទេ? អាពាធដ៏ខ្លាំងក្លាណាៗ មិនមានដល់អ្នកទេឬ? បានក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គល្មមអត់ធន់បាន អាពាធណាៗ មិនមានដល់ខ្ញុំព្រះអង្គទេ ម្យ៉ាងទៀត អ្នកដែលមានគុណច្រើនដូចសាមណេរនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ" ព្រះសាស្តាត្រាស់សួរថា "ម្នាលភិក្ខុ តើសាមណេរតូចនេះ បានធ្វើនូវកម្មអ្វី" ព្រះថេរៈបានក្រាបទូលរឿងរ៉ាវតាំងអំពីដើមទូលដល់ព្រះសាស្តា ហើយក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សាមណេរនេះ ខ្ញុំព្រះអង្គសូមឲ្យអត់ទោសឲ្យ បានពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា លោកម្ចាស់ដ៏ចម្រើន ក្នុងសេចក្តីនេះ ជាទោសរបស់លោកម្ចាស់ក៏មិនមែន ជាទោសរបស់ខ្ញុំព្រះករុណាក៏មិនមែន វាជាទោសរបស់វដ្តៈប៉ុណ្ណោះ សូមលោក

ម្ចាស់កុំគិតឡើយ សាមណេរបានញ៉ាំងខ្ញុំព្រះអង្គឲ្យធូរស្រាលចិត្ត ដោយប្រការយ៉ាងនេះ មិនបានញ៉ាំងសេចក្ដីក្រោធ ឬប្រទូសឲ្យកើតឡើងចំពោះខ្ញុំព្រះអង្គឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន អ្នកដែលបរិបូណ៌ដោយគុណបែបនេះ ខ្ញុំព្រះអង្គមិនធ្លាប់ឃើញឡើយ" ។

## ព្រះខីណាស្រពមិនក្រោធ មិនប្រទូសនឹងបុគ្គលណា

លំដាប់នោះ ព្រះសាស្ដាត្រាស់ទៅកាន់ព្រះថេរៈដូច្នេះថា "ម្នាលភិក្ខុ ធម្មតាព្រះខីណាស្រពទាំងឡាយ រមែងមិនក្រោធ មិនប្រទូសចំពោះបុគ្គលណាៗ ឡើយ ជាអ្នកមានឥន្ទ្រិយស្ងប់រម្ងាប់ហើយ មានចិត្តស្ងប់ហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់គាថានេះថា ៖

សន្តំ តស្ស មនំ ហោតិ សន្តា វាចា ច កម្ម ច
សម្មទញ្ញា វិមុត្តស្ស ឧបសន្តស្ស តាទិនោ ។
ចិត្តស្ងប់ វាចាស្ងប់ និងកាយកម្មស្ងប់ រមែងមានដល់
លោកដែលដឹងដោយប្រពៃ ផុតស្រឡះ (ចាកពពួកកិ-
លេស) ជាអ្នកស្ងប់រម្ងាប់ ដូច្នោះ ។

## អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា *សន្តំ* (ស្ងប់ហើយ) សេចក្ដីថា ចិត្តរបស់សមណៈដែលជាព្រះខីណាស្រពនោះ ឈ្មោះថា ស្ងប់ពិត គឺ រម្ងាប់ បានដល់រំលត់ ព្រោះមិនមានមនោទុច្ចរិតទាំងឡាយ មានអភិជ្ឈាជាដើម ម្យ៉ាងទៀត

វាចា ឈ្មោះថា ស្ងប់ហើយ ព្រោះមិនមានវចីទុច្ចរិតទាំងឡាយ មានមុសាវាទជាដើម ចំណែកកាយកម្ម ឈ្មោះថា ស្ងប់ ព្រោះមិនមានកាយទុច្ចរិត មានបាណាតិបាតជាដើម ។ បទថា **សម្មទញ្ញា វិមុត្តស្ស (រួចផុតវិសេសហើយព្រោះដឹងដោយប្រពៃ)** សេចក្ដីថា អ្នករួចផុតស្រឡះហើយដោយវិមុត្តិទាំង ៥ ព្រោះដឹងដោយន័យ ដោយហេតុ ។ បទថា **ឧបសន្តស្ស (អ្នកស្ងប់រម្ងាប់)** សេចក្ដីថា អ្នកស្ងប់រម្ងាប់ហើយ ព្រោះស្ងប់រម្ងាប់កិលេស មានរាគៈជាដើមក្នុងខាងក្នុង ។ បទថា **តាទិនោ (អត់ធន់)** គឺ ជាអ្នកបរិបូណ៌ដោយគុណបែបនោះ ។

ក្នុងកាលចប់ព្រះធម្មទេសនា ព្រះតិស្សៈអ្នកក្រុងកោសម្ពីបានសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទាទាំងឡាយ ព្រះធម្មទេសនា បានជាប្រយោជន៍ដល់មហាជនដ៏សេស ដូច្នេះ ។

ចប់ រឿងព្រះតិស្សត្ថេរអ្នកក្រុងកោសម្ពី

# ៨. រឿងព្រះសារីបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធព្រះសារីបុត្រ ត្រាស់ព្រះធម្មទេសនានេះថា អស្សទ្ធោ (មិនជឿ) ជាដើម ។*

សទ្ធិន្ទ្រិយជាដើម មានអមតៈជាទីបំផុត

*សេចក្តីពិស្តារថា ភិក្ខុដែលនៅព្រៃជាវត្តប្រមាណ ៣០ រូប ថ្ងៃមួយបាន ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីដ៏សមគួរ ។*

*ព្រះសាស្តា ទ្រង់ជ្រាបឧបនិស្ស័យព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ទាំងឡាយរបស់ភិក្ខុទាំងនោះហើយ ត្រាស់ហៅព្រះសារីបុត្រមក ត្រាស់សួរ បញ្ហាប្រារព្ធឥន្ទ្រិយទាំង ៥ យ៉ាងនេះថា "សារីបុត្រ អ្នកជឿថា ឥន្ទ្រិយ គឺ សទ្ធាដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ រមែងឈានចុះកាន់អមតៈ មានអមតៈជាទីបំផុតឬ" ។ ព្រះថេរៈទូលដោះស្រាយបញ្ហាយ៉ាងនេះថា "បពិត្រ ព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជឿតពីព្រះមានព្រះភាគ ក្នុងឥន្ទ្រិយទាំង ៥ នេះ ឯង (ថា) ឥន្ទ្រិយ គឺ សទ្ធា ។ល។ មានអមតៈជាទីបំផុតទេ បពិត្រព្រះអង្គ ដ៏ចម្រើន ឥន្ទ្រិយ គឺ សទ្ធានោះ ដែលជនពួកណាមិនបានដឹងហើយ មិនបាន ស្តាប់ មិនបានឃើញ មិនបានជ្រាប មិនបានធ្វើឲ្យជាក់ច្បាស់ មិនបានពាល់ ត្រូវហើយដោយបញ្ញាទេ ជនពួកនោះ គប្បីជលដោយសេចក្តីជឿតពីជនដទៃ ក្នុងឥន្ទ្រិយទាំង ៥ នោះ (ថា) ឥន្ទ្រិយ គឺ សទ្ធា ។ល។ មានអមតៈជាទីបំផុត*

ឡើយ ។ ភិក្ខុទាំងឡាយ ស្តាប់ពាក្យនោះហើយ សន្ទនាគ្នាថា "ព្រះសារីបុត្រ ដោះស្រាយបញ្ហាដោយការប្រកាន់ខុស សូម្បីក្នុងថ្ងៃនេះ ព្រះថេរៈនៅតែមិនជឿចំពោះព្រះសម្មាសម្ពុទ្ធទៀត" ។ ព្រះសាស្តាទ្រង់ស្តាប់នូវកថានោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយនិយាយអំពីរឿងអ្វី តថាគតសួរសារីបុត្រថា សារីបុត្រ អ្នកជឿថា មានបុគ្គលដែលមិនបានអប់រំនូវឥន្ទ្រិយទាំង ៥ មិនចម្រើននូវសមថៈ និងវិបស្សនាហើយ ធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផលដែរឬ" សារីបុត្រនោះពោលថា "បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនជឿថា បុគ្គលដែលធ្វើឲ្យជាក់ច្បាស់នោះ ឈ្មោះថា មានទេ" សារីបុត្រមិនមែនមិនជឿនូវផលវិបាកនៃទានដែលបុគ្គលឲ្យហើយ ឬកម្មដែលបុគ្គលធ្វើហើយទេ ម្យ៉ាងទៀត សារីបុត្រមិនមែនមិនជឿនូវគុណព្រះរតនត្រៃទាំង ៣ មានព្រះពុទ្ធជាដើមទេ តែសារីបុត្រនោះ មិនមែនជឿ.តពីបុគ្គលដទៃក្នុងធម៌ គឺ ឈាន វិបស្សនា មគ្គ និងផល ដែលខ្លួនបានចំពោះហើយ ព្រោះដូច្នេះសារីបុត្រ ទើបជាបុគ្គលដែលនរណាៗ មិនគួរតិះដៀល" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

អស្សទ្ធោ អកតញ្ញូ ច
សន្ធិច្ឆេទោ ច យោ នរោ
ហតាវកាសោ វន្តាសោ
ស វេ ឧត្តមបោរិសោ ។

នរជនណា មិនជឿអ្នកដទៃផង ស្គាល់ព្រះនិព្វាន
ផងកាត់នូវគ្រឿងតតឹវដ្ដៈផង មានឱកាសកំចាត់បង់
ហើយផង មានសេចក្ដីប្រាថ្នាខ្ជាក់ចោលហើយផង
នរជននោះ ជាឧត្ដមបុរស ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អស្សទ្ធោ** ជាដើម គប្បីជ្រាបការវិគ្រោះដូចតទៅនេះ ៖

**នរៈ** ឈ្មោះថា **អស្សទ្ធោ (មិនជឿងាយ)** ព្រោះអត្ថថា មិនជឿនូវគុណដែលខ្លួនចាក់ធ្លុះហើយ ដោយពាក្យអ្នកដទៃ ។ ឈ្មោះថា **អកតញ្ញូ (មានប្រក្រតីដឹងនិព្វានដែលបច្ច័យធ្វើមិនបាន)** ព្រោះអត្ថថា ដឹងព្រះនិព្វាន ដែលបច្ច័យធ្វើមិនបាន អធិប្បាយថា មានព្រះនិព្វានដែលខ្លួនបានធ្វើឲ្យជាក់ច្បាស់ហើយ ។ ឈ្មោះថា **សន្ធិច្ឆេទោ (កាត់ទី.ត)** ព្រោះអត្ថថា កាត់នូវទី.ត គឺវដ្ដៈ ទី.ត គឺ សង្សារ ។ ឈ្មោះថា **ហតាវកាសោ (មានឱកាសដែលកម្ចាត់ហើយ)** ព្រោះអត្ថថា ឱកាសនៃការកើត ឈ្មោះថា ដែលនរៈកម្ចាត់ហើយ ព្រោះពូជ គឺ កុសលកម្ម និងអកុសលកម្មអស់ហើយ ។ ឈ្មោះថា **វន្ដាសោ (មានសេចក្ដីប្រាថ្នាខ្ជាក់ចោលហើយ)** ព្រោះអត្ថថា សេចក្ដីប្រាថ្នាទាំងពួងឈ្មោះថា ដែលនរៈខ្ជាក់ចោលហើយ ព្រោះកិច្ចដែលខ្លួនគួរធ្វើដោយមគ្គ ៤ បានធ្វើហើយ ។ ក៏នរៈបែបនេះ នរៈនោះឯង ឈ្មោះថា ជាបុគ្គលឧត្ដមក្នុង

បុរស ព្រោះអត្ថថា ដល់នូវភាពជាបុគ្គលឧត្តមក្នុងបុរសទាំងឡាយ ដោយអំណាចនៃលោកុត្តរធម៌ដែលខ្លួនចាក់ធ្លុះហើយ ។

ក្នុងកាលចប់ព្រះគាថា ភិក្ខុប្រមាណ ៣០ រូបដែលនៅព្រៃជាវត្តនោះ បានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ ព្រះធម្មទេសនាមានប្រយោជន៍ដល់មហាជនដ៏សេស ដូច្នេះឯង ។

ចប់ រឿងព្រះសារីបុត្រ

# ៩. រឿងព្រះខទិរវនិយរេវតៈ

*ព្រះសាស្តា កាលប្រថាប់នៅវិហារជេតពន ទ្រង់ប្រារព្ធ ព្រះខទិរវនិយរេវតៈ ត្រាស់ព្រះធម្មទេសនានេះថា* **គាមេ វា** *(ឬជាស្រុកក៏ដោយ) ដូច្នេះជាដើម ។*

## ព្រះសារីបុត្រដឹកនាំបងប្អូនឱ្យបួស

*សេចក្តីពិស្តារថា ព្រះសារីបុត្រលះបង់ទ្រព្យ ៨៧ កោដិ ចេញទៅបួស មិនត្រឹមតែប៉ុណ្ណោះ បានដឹកនាំប្អូនស្រី ៣ នាក់ គឺ នាងចាលា នាងឧបចាលា នាងសីសុបចាលា និងប្អូនប្រុស ពីរនាក់ គឺ នាយចុន្ទៈ នាយឧបសេនៈឲ្យបួសទៀតផង ។ នៅសល់តែរេវតៈម្នាក់ប៉ុណ្ណោះ ។ គ្រានោះនាងព្រាហ្មណី ដែលជាមាតារបស់ព្រះសារីបុត្រនោះ គិតថា ឧបតិស្សបុត្ររបស់យើង លះបង់ទ្រព្យប្រមាណប៉ុណ្ណេះ បួសហើយ ដឹកនាំប្អូនស្រីបីនាក់ ប្អូនប្រុសពីរនាក់ឲ្យបួសទៀត នៅសល់តែរេវតៈម្នាក់ប៉ុណ្ណោះ បើលោកដឹកនាំរេវតៈឲ្យទៅបួសទៀត ទ្រព្យសម្បត្តិរបស់យើងប្រមាណប៉ុណ្ណេះ នឹងវិនាស វង្សត្រកូលនឹងដាច់សូន្យ យើងនឹងចងរេវតៈនេះទុក ដោយការគ្រប់គ្រងផ្ទះចាប់តាំងពីគេនៅក្មេងនេះទៅ ។ ចំណែកព្រះសារីបុត្រ បានផ្តាំភិក្ខុទាំងឡាយទុកថា "ម្នាលអ្នកមានអាយុទាំងឡាយ ប្រសិនបើរេវតៈមកកាន់ទីនេះ ហើយចង់បួស អ្នកទាំងឡាយចូរបំបួសគេភ្លាមទៅ (ព្រោះ) មាតាបិតារបស់ខ្ញុំករុណា*

ជាមនុស្សមិច្ឆាទិដ្ឋិ កិច្ចដែលឲ្យរេវតៈទៅលាអ្នកទាំងពីរនោះ មិនចាំបាច់ទេ ខ្ញុំករុណាជាមាតាបិតារបស់រេវតៈនោះឯង” ។

## មាតាបិតាឲ្យរេវតៈរៀបការ

មាតាបិតារបស់ព្រះសារីបុត្រ ប្រាថ្នាចងរេវតកុមារ ដែលទើបតែមានអាយុ ៧ ឆ្នាំប៉ុណ្ណោះ ដោយចំណង គឺ ផ្ទះ ទើបទៅដណ្ដឹងក្មេងស្រីក្នុងត្រកូលដែលមានជាតិស្មើគ្នា កំណត់ថ្ងៃរៀបការហើយ ប្រដាប់តុបតែងរេវតៈ នាំទៅកាន់ផ្ទះញាតិនៃក្មេងស្រី មួយអន្លើដោយបរិវារជាច្រើន ។ លំដាប់នោះ កាលពួកញាតិរបស់គេទាំងពីរនាក់ធ្វើមង្គល ប្រជុំគ្នាហើយ ពួកញាតិឲ្យគេទាំងពីរជ្រលក់ដៃទៅក្នុងទឹកផ្តិល ហើយពោលនូវមង្គលទាំងឡាយ ប្រាថ្នាសេចក្តីចម្រើនដល់ក្មេងស្រី ទើបពោលថា “សូមចៅបានឃើញធម៌ដែលជីដូនរបស់ចៅបានឃើញហើយចុះ ចៅចូររស់នៅឲ្យបានយឺនយូរដូចជីដូនចុះ” រេវតកុមារគិតថា “អ្វីហ្ន៎ជាធម៌ ដែលជីដូននេះបានឃើញហើយ” ទើបសួរថា “អ្នកណាជាជីដូនរបស់ក្មេងស្រីនេះ” ។ គ្រានោះ ពួកញាតិប្រាប់រេវតៈថា “នែបា អ្នកនេះមានអាយុ ១២០ ឆ្នាំ មានធ្មេញបាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ មានខ្លួនត្រូវប្រជ្រុយកម្ទាត់ហើយ ខ្នងកោងដូចបង្កង់ផ្ទះ ឯងមិនឃើញទេឬ” នុ៎ះហើយជាជីដូនរបស់ក្មេងស្រីនោះ” ។

រេវតៈសួរថា សូម្បីស្ត្រីនេះ នឹងជាយ៉ាងនុ៎ះដែរឬ ?

ពួកញាតិ. នែបា បើនាងរស់នៅរហូត ក៏នឹងជាយ៉ាងនុ៎ះឯង ។

## រេវតៈរកឧបាយចេញបួស

រេវតៈគិតថា "សូម្បីសរីរៈបែបនេះ ក៏នឹងដល់នូវប្រការដ៏ប្លែកបែបនេះ ព្រោះជរា ឧបតិស្សៈ បងប្រុសរបស់យើង ប្រាកដជាបានឃើញនូវហេតុនេះហើយ ទើបលោកចេញទៅបួស ។ យើងគួរតែរត់ទៅបួសក្នុងថ្ងៃនេះឯង" ។ គ្រានោះ ពួកញាតិលើករេវតៈឡើងកាន់យានជាមួយ នឹងក្មេងស្រី ហើយនាំចេញទៅ ។ រេវតៈទៅបានបន្តិច ប្រាប់គេថា "អ្នកទាំងឡាយ សូមបញ្ឈប់យានសិន ព្រោះខ្ញុំត្រូវការបន្ទោបង់ឧច្ចារៈ ខ្ញុំចុះទៅបន្តិច ហើយត្រឡប់មកវិញ" ដូច្នេះហើយ ក៏ចុះពីយាន ធ្វើអាការក្នុងគុម្ពឈើឲ្យយូរបន្តិច ទើបដើរមកកាន់យានវិញ ។ លុះធ្វើដំណើរទៅមុខបានបន្តិច ក៏ប្រាប់គេថា "ឲ្យខ្ញុំសូមចុះទៅបន្ទោបង់ឧច្ចារៈម្តងទៀត" ចុះពីយានហើយ សំដែងអាការក្នុងគុម្ពឈើបន្តិចហើយ ទើបដើរមកកាន់យាន ដូចលើកមុន ។ គ្រានោះ ពួកញាតិរបស់រេវតកុមារ បានសម្គាល់ថា រេវតៈនេះទៅបន្ទោបង់ពិតៗ ទើបមិនបានរក្សាការពារឲ្យមាំទាំ ។ រេវតៈទៅបន្តិច ក៏សុំចុះម្តងទៀតដោយអាងថា ទៅបន្ទោបង់ឧច្ចារៈ ហើយបាននិយាយថា សូមពួកលោកបរយានទៅមុនចុះ ខ្ញុំនឹងដើរទៅតាមក្រោយ និយាយដូច្នេះហើយ ក៏ចុះពីយានដើរសំដៅទៅរកគុម្ពឈើ ។

## រេវតៈបានបព្វជ្ជា

ពួកញាតិរបស់រេវតៈ បានបរយានទៅ ដោយសម្គាល់ថា "រេវតៈនឹងដើរមកតាមក្រោយ" ។ ចំណែករេវតៈ បានរត់គេចចេញអំពីទីនោះ ទៅកាន់

សម្នាក់ភិក្ខុប្រមាណ ៣០ រូប ដែលនៅក្នុងប្រទេសមួយ ថ្វាយបង្គំហើយ ប្រាប់ថា "លោកម្ចាស់ សូមលោកម្ចាស់ទាំងឡាយបំបួសខ្ញុំចុះ" ។

ពួកភិក្ខុ. អ្នកមានអាយុ អ្នកប្រដាប់ដោយគ្រឿងអលង្ការយ៉ាងនេះ ពួកអាត្មាភាពមិនដឹងថា "អ្នកជាព្រះរាជបុត្រ ឬក៏ជាបុត្ររបស់អាមាត្យ នឹងបំបួសអ្នកដូចម្ដេចបាន" ។

រេវតៈ. លោកម្ចាស់ទាំងឡាយ មិនស្គាល់ខ្ញុំទេឬ ។

ពួកភិក្ខុ. មិនស្គាល់ទេ អ្នកមានអាយុ ។

រេវតៈ. ខ្ញុំជាប្អូនប្រុសរបស់ឧបតិស្សៈ ។

ពួកភិក្ខុ. ឈ្មោះថា ឧបតិស្សៈនោះ គឺ នរណា ។

រេវតៈ. លោកម្ចាស់ទាំងឡាយ ហៅបងប្រុសរបស់ខ្ញុំថា សារីបុត្រ ព្រោះដូច្នោះ កាលខ្ញុំហៅថា "ឧបតិស្សៈ" ទើបពួកលោកម្ចាស់មិនស្គាល់ ។

ពួកភិក្ខុ. ក៏អ្នក ជាប្អូនប្រុសរបស់ព្រះសារីបុត្រឬ ?

រេវតៈ. យ៉ាងនោះឯង លោកម្ចាស់ ។

ភិក្ខុទាំងនោះពោលថា "បើដូច្នោះ អ្នកចូរមកចុះ យើងបំបួសឲ្យ ព្រោះបព្វជ្ជាកម្មរបស់អ្នក បងប្រុសរបស់អ្នកបានអនុញ្ញាតឲ្យហើយ" លុះពោលដូច្នេះហើយ ក៏ឲ្យដោះគ្រឿងអាភរណៈរបស់រេវតៈចេញ ធ្វើវិធីបំបួសរេវតៈ លុះបំបួសរេវតៈហើយ ក៏បញ្ជូនដំណឹងទៅប្រគេនព្រះសារីបុត្រ ។ ព្រះថេរៈបានទទួលដំណឹងនោះហើយ ក៏ចូលទៅក្រាបទូលព្រះមានព្រះភាគថា "បពិត្រ

ព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយបញ្ជូនដំណឹងមកខ្ញុំព្រះអង្គថា ពួកភិក្ខុដែលនៅព្រៃ បានបំបួសរេវតៈហើយ ខ្ញុំព្រះអង្គថ្វាយបង្គំលាព្រះអង្គទៅសួរសុខទុក្ខរេវតៈ ហើយត្រឡប់មកវិញ" ។ ព្រះសាស្តា ទ្រង់មិនបានអនុញ្ញាតឲ្យព្រះសារីបុត្រទៅ ដោយព្រះតម្រាស់ថា "សារីបុត្រ អ្នកចូរឈប់សិន" ២-៣ ថ្ងៃ ក្រោយមក ព្រះថេរៈក៏ថ្វាយបង្គំលាព្រះសាស្តាម្តងទៀត ព្រះសាស្តាក៏ទ្រង់មិនអនុញ្ញាតឲ្យទៅ ដោយព្រះតម្រាស់ថា "សារីបុត្រ អ្នកចូរបង្អង់សិន ចាំតថាគតទៅដែរ" ។

## រេវតសាមណេរ សម្រេចព្រះអរហត្ត

ចំណែកសាមណេរគិតថា "ប្រសិនបើយើងនៅទីនេះ ពួកញាតិនឹងប្រើមនុស្សឲ្យមកហៅយើងឲ្យត្រឡប់ទៅវិញ" លុះគិតដូច្នេះហើយ ទើបរៀនកម្មដ្ឋានរហូតដល់ព្រះអរហត្តអំពីភិក្ខុទាំងនោះហើយ កាន់បាត្រ និងចីវរត្រាច់ទៅកាន់ទីចារិក ដល់ព្រៃគគីរមួយកន្លែង ដែលនៅឆ្ងាយអំពីទីដែលខ្លួនបានបួសប្រមាណ ៣០ យោជន៍ ។ ក្នុងរវាង ៣ ខែខាងក្នុងវស្សានោះ ព្រះរេវតៈបានសម្រេចព្រះអរហត្តមួយអន្លើដោយបដិសម្ភិទាទាំងឡាយ ។ សូម្បីព្រះសារីបុត្រ លុះបវារណាចេញវស្សាហើយ ក៏ចូលទៅថ្វាយបង្គំលាព្រះសាស្តាដើម្បីទៅកាន់សម្នាក់ព្រះរេវតៈម្តងទៀត ។ ព្រះសាស្តាត្រាស់ថា "ម្នាលសារីបុត្រ តថាគតទៅដែរ" ព្រះសម្មាសម្ពុទ្ធស្តេចយាងទៅជាមួយនឹងភិក្ខុ ៥០០ រូប ។ ក្នុងកាលដែលព្រះអង្គស្តេចយាងទៅបានបន្តិច ព្រះអានន្ទក៏ឈរត្រង់ផ្លូវបែក

ជាពីរ ក្រាបទូលព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន បណ្តាផ្លូវទៅកាន់សម្នាក់របស់រេវត:មានពីរ ផ្លូវនេះជាផ្លូវវាងមានចម្ងាយប្រមាណ ៦០ យោជន៍ ជាទីនៅរបស់មនុស្ស ផ្លូវនេះជាផ្លូវត្រង់ មានចម្ងាយប្រមាណ ៣០ យោជន៍ ជាផ្លូវដែលអមនុស្សហួងហែង តើព្រះអង្គទ្រង់យាងតាមផ្លូវណា?" ។

ព្រះសាស្តា. អានន្ទ ក៏សីវលី មកជាមួយនឹងពួកយើងដែរឬ ?

ព្រះអានន្ទ. ព្រះករុណា ព្រះអង្គ ។

ព្រះសាស្តា. បើសីវលីមកដែរ អ្នកចូរកាន់យកផ្លូវត្រង់ចុះ ។

ពួកភិក្ខុអាស្រ័យបុណ្យរបស់ព្រះសីវលី

បានឮថា ព្រះសាស្តាមិនបានត្រាស់ថា "តថាគតនឹងញ៉ាំងបបរ និងបាយឲ្យកើតឡើងដល់ពួកអ្នក ពួកអ្នកចូរកាន់យកផ្លូវត្រង់" ទ្រង់ជ្រាបថា "ទីនោះ ជាទីឲ្យផលនៃបុណ្យដល់ជនទាំងនោះៗ" ទើបត្រាស់ថា "បើសីវលីមក អ្នកទាំងឡាយចូរកាន់យកផ្លូវត្រង់ចុះ" ។ កាលព្រះសាស្តា ស្តេចយាងទៅផ្លូវនោះ ពួកទេវតាគិតថា "ពួកយើងនឹងធ្វើសក្ការ:ដល់លោកម្ចាស់សីវលីរបស់ពួកយើង" ញ៉ាំងគ្នានិងគ្នាឲ្យសាងវិហារក្នុងទីមួយយោជន៍ មួយកន្លែងមិនឲ្យលើស ឬក៏មិនតិចជាងមួយយោជន៍ឡើយ ក្រោកឡើងពីព្រលឹម កាន់យកវត្ថុទាំងឡាយមានបបរជាដើមដ៏ជាទិព្វទៅ ដោយតាំងចិត្តថា "លោកម្ចាស់សីវលីរបស់ពួកយើង គង់នៅទីណា" ព្រះថេរ:ឲ្យទេវតាថ្វាយកត្តដែលនាំមកដើម្បីខ្លួន ដល់ភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តាព្រមទាំងបរិវារ

កាលដែលព្រះអង្គ យាងទៅកាន់ផ្លូវដាច់ស្រយាលប្រមាណ ៣០ យោជន៍នោះ អាស្រ័យបុណ្យរបស់ព្រះសីវលី ។ ចំណែកព្រះរេវតត្ថេរដឹងថា "ព្រះសាស្ដាស្ដេចយាងមក ក៏និម្មិតព្រះគន្ធកុដិសម្រាប់ព្រះមានព្រះភាគ និម្មិតផ្ទះកំពូល ៥០០ ទីចង្ក្រម ៥០០ និងទីសម្រាប់សម្រាកពេលថ្ងៃ និងទីសម្រាកពេលយប់ ៥០០ ។ ព្រះសាស្ដា ទ្រង់ប្រថាប់នៅក្នុងសម្នាក់របស់ព្រះរេវតត្ថេរនោះ អស់មួយខែ ។ សូម្បីកាលដែលព្រះអង្គប្រថាប់នៅទីនោះ ក៏ទ្រង់អាស្រ័យបុណ្យរបស់ព្រះសីវលីនោះឯង ។

បណ្ដាភិក្ខុទាំងនោះ មានភិក្ខុចាស់ពីររូប ក្នុងវេលាដែលព្រះសាស្ដាស្ដេចយាងចូលទៅកាន់ព្រៃគគីរ បានគិតយ៉ាងនេះថា "ភិក្ខុនេះធ្វើនវកម្ម (ការកសាង) ប្រមាណប៉ុណ្ណេះ នឹងអាចធ្វើសមណធម៌ដូចម្ដេចបាន ព្រះសាស្ដាទ្រង់ធ្វើកិច្ច គឺ ការយល់មុខ ដោយទ្រង់ព្រះតម្រិះថា ជាប្អូនប្រុសរបស់ព្រះ-សារីបុត្រ ទើបស្ដេចយាងមកកាន់សម្នាក់របស់បុគ្គលដែលប្រកបនវកម្មបែបនេះ" ។

## ព្រះសាស្ដាទ្រង់អធិដ្ឋានឱ្យភិក្ខុភ្លេចបរិក្ខារ

ក្នុងថ្ងៃនោះ ព្រះសាស្ដាក៏ទ្រង់ពិចារណាមើលសត្វលោក ក្នុងវេលាជិតភ្លឺ ទ្រង់ឃើញភិក្ខុទាំងនោះហើយ ទ្រង់បានជ្រាបនូវវារៈចិត្តរបស់ភិក្ខុទាំងនោះ ព្រោះហេតុនោះ ទ្រង់ប្រថាប់នៅក្នុងទីនោះអស់កាលប្រមាណមួយខែហើយ ក្នុងថ្ងៃស្ដេចយាងចេញអំពីសម្នាក់របស់ព្រះរេវតត្ថេរ ទ្រង់បានអធិដ្ឋាន

ឲ្យភិក្ខុទាំងនោះភ្លេចនាឡិប្រេង កំសៀវទឹក និងស្បែកជើងរបស់ខ្លួន ស្ដេចយាងទៅហើយ ក្នុងវេលាស្ដេចយាងចេញដល់ខាងក្រៅឧបចារៈវិហារ ទើបទ្រង់រំសាយឫទ្ធិ ។ គ្រានោះ ភិក្ខុទាំងនោះពោលប្រាប់គ្នាថា "ខ្ញុំករុណាភ្លេចវត្ថុនេះ និងវត្ថុនេះ សូម្បីខ្ញុំករុណាក៏ភ្លេច" ដូច្នេះហើយ ទើបត្រឡប់ទៅវិញទាំងពីររូប មិនបានកំណត់ទីនោះឲ្យបានជាក់ច្បាស់ ក៏ត្រូវបន្លាគគីរមុត និមន្តទៅឃើញកណ្ឌៈរបស់ខ្លួនព្យួរនៅលើដើមគគីរមួយដើម កាន់យកហើយ ក៏ចៀសចេញទៅ ។ សូម្បីព្រះសាស្ដាទ្រង់នាំភិក្ខុសង្ឃត្រឡប់មកវិញ ក៏ទ្រង់អាស្រ័យបុណ្យរបស់ព្រះសីវលិត្ថេរ អស់កាលប្រមាណ ១ ខែទៀត ស្ដេចយាងទៅកាន់បុព្វារាម ។ លំដាប់នោះ ភិក្ខុចាស់ទាំងពីរនោះ លុបលាងមុខពីព្រលឹមហើយនិមន្តទៅ ដោយតាំងចិត្តថា ពួកយើងនឹងឆាន់បបរក្នុងផ្ទះរបស់នាងវិសាខា ដែលជាអ្នកប្រគេនភត្តដល់ភិក្ខុអ្នកទើបមកថ្មី ឆាន់បបរ និងរបស់ដែលគួរទំពា (បង្អែម) ហើយគង់ក្នុងទីដ៏សមគួរ ។

នាងវិសាខាសួរអំពីលំនៅរបស់ព្រះរេវត:

គ្រានោះ នាងវិសាខាសួរភិក្ខុចាស់ទាំងពីររូបនោះថា "លោកម្ចាស់ លោកម្ចាស់ទាំងឡាយបាននិមន្តទៅកាន់លំនៅរបស់ព្រះរេវត:ជាមួយនឹងព្រះមានព្រះភាគដែរឬ?"

ភិក្ខុចាស់. ឧបាសិកា ពួកអាត្មាបាននិមន្តទៅដែរ ។

វិសាខា. លោកម្ចាស់ លំនៅរបស់ព្រះថេរ:គួរជាទីត្រេកអរដែរឬ ។

ភិក្ខុចាស់. ឧបាសិកា លំនៅរបស់ព្រះថេរៈ គួរជាទីត្រេកអរអំពីណា ទីនោះជាព្រៃគគីរ មានបន្ទា.សដូចជាទីនៅនៃពួកប្រេត ។ គ្រានោះ ភិក្ខុកំលោះពីររូបដទៃមកទៀត ។ ឧបាសិកាប្រគេនបបរ និងរបស់គួរទំពាដល់ភិក្ខុកំលោះទាំងពីររូបនោះហើយ ក៏សួរដូច្នោះទៀត ។ ភិក្ខុកំលោះទាំងពីររូបនោះពោលថា ឧបាសិកា ពួកអាត្មាមិនអាចពណ៌នាអំពីលំនៅរបស់ព្រះថេរៈបានទេ ព្រោះដូចជាទេវស្ថានឈ្មោះសុធម្មា ដែលទេវតាតាក់តែងឡើងដោយឫទ្ធិ ដូច្នោះ ។ ឧបាសិកាគិតថា "ភិក្ខុដែលមកដំបូងពោលផ្សេង ភិក្ខុដែលមកនេះពោលផ្សេង ភិក្ខុដែលមកដំបូង ប្រាកដជាភ្លេចអ្វីនៅទីនោះ ហើយត្រឡប់ទៅយក ក្នុងពេលដែលព្រះថេរៈរំសាយឫទ្ធិហើយ ឯភិក្ខុពួកនេះនឹងទៅក្នុងវេលាដែលព្រះថេរៈតាក់តែងលំនៅដោយឫទ្ធិ" ព្រោះភាពនៃខ្លួនជាបណ្ឌិតទើបជ្រាបនូវរឿងនោះ នាងបាននៅឈរដោយសន្និដ្ឋានថា "នឹងទូលសួរព្រះសម្មាសម្ពុទ្ធ ក្នុងកាលដែលព្រះអង្គស្តេចយាងមក" ។ តមកគ្រាមួយ ព្រះសាស្តាដែលមានភិក្ខុសង្ឃហែហម ស្តេចយាងទៅកាន់ផ្ទះនាងវិសាខា ទ្រង់គង់លើអាសនៈដែលគេក្រាលទុកហើយ ។ នាងអង្គាសភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ដោយគោរព ក្នុងវេលាស្រេចភត្តកិច្ច នាងថ្វាយបង្គំព្រះសាស្តា ហើយទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន បណ្តាភិក្ខុដែលនិមន្តទៅជាមួយនឹងព្រះអង្គនោះ ភិក្ខុខ្លះពោលថា ច្រើនដោយព្រៃបន្ទា ភិក្ខុពួកខ្លះពោលថា ជាភូមិគួរឲ្យត្រេកអរ តើលំនៅរបស់ព្រះថេរៈនោះដូចម្តេច ព្រះអង្គ" ព្រះសាស្តាទ្រង់ស្តាប់នូវពាក្យ

នោះហើយ ត្រាស់ថា "ម្នាលឧបាសិកា ព្រះអរហន្តទាំងឡាយនៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី ទីនោះគួរមនោរម្យដោយពិត" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសំដែងធម៌ បានត្រាស់គាថានេះថា ៖

*គាមេ វា យទិ វារញ្ញេ*

*និន្នេ វា យទិ វា ថលេ*

*យត្ថ អរហន្តោ វិហរន្តិ*

*តំ ភូមិរាមណេយ្យកំ ។*

*ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី*

*ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។*

អធិប្បាយគាថា

ក្នុងព្រះគាថានោះ មានសេចក្តីថា ព្រះអរហន្តទាំងឡាយ រមែងមិនបាននូវកាយវិវេកខាងក្នុងស្រុកក៏ពិត តែលោករមែងបាននូវចិត្តវិវេកដោយពិត ព្រោះអារម្មណ៍ទាំងឡាយ សូម្បីប្រៀបដូចជារបស់ទិព្វ ក៏មិនអាចនឹងញ៉ាំងចិត្តរបស់ព្រះអរហន្តទាំងឡាយឲ្យញាប់ញ័របាន ព្រោះដូច្នោះ ទោះជាស្រុកឬទីណាមួយ មានព្រៃជាដើម ព្រះអរហន្តទាំងឡាយរមែងរស់នៅក្នុងទីណា ។ បទថា *តំ ភូមិរាមណេយ្យកំ (ទីនោះជាភូមិស្ថានដែលគួរត្រេកអរ)* សេចក្តីថា ភូមិប្រទេសនោះ ជាទីគួរត្រេកអរដោយពិត ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ

មានសោតាបត្តិផលជាដើម ។

## ពួកភិក្ខុសន្ទនាអំពីរឿងរបស់ព្រះសីវលី

ក្នុងសម័យដទៃ ភិក្ខុទាំងឡាយសន្ទនាគ្នាថា "អ្នកមានអាយុទាំងឡាយ ព្រោះហេតុអ្វីហ្ន៎ ទើបព្រះសីវលីនៅក្នុងផ្ទៃរបស់មាតាអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ព្រោះកម្មអ្វី ទើបឆេះនៅក្នុងនរក? ព្រោះកម្មអ្វី ទើបជាអ្នកមានលាភច្រើន មានយសច្រើនយ៉ាងនោះ" ព្រះសាស្ដាទ្រង់ស្ដាប់ពាក្យនោះហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយសន្ទនាអំពីរឿងអ្វី" ភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើនអំពីកថាឈ្មោះនេះ" ដូច្នេះហើយ កាលនឹងត្រាស់បុព្វកម្មរបស់ព្រះសីវលី ទើបត្រាស់ត្រាស់ ៖

## បុព្វកម្មរបស់ព្រះសីវលី

"ម្នាលភិក្ខុទាំងឡាយ ក្នុងកប្បទី ៩១ អំពីកប្បនេះ ព្រះមានព្រះភាគទ្រង់ព្រះនាមថា **វិបស្សី** ទ្រង់កើតឡើងក្នុងលោក ។ សម័យមួយ ស្ដេចយាងទៅកាន់ជនបទ ហើយត្រឡប់មកកាន់នគររបស់បិតា ព្រះរាជាទ្រង់ចាត់ចែងអាគន្តុកភត្តដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ទ្រង់បញ្ជូនដំណឹងទៅប្រាប់អ្នកនគរថា អ្នកទាំងឡាយ ចូរមកជាសំឡាញ់ក្នុងទានរបស់យើង" ។ ជនទាំងនោះធ្វើយ៉ាងនោះហើយ ក៏គិតគ្នាថា "ពួកយើងនឹងថ្វាយទានឲ្យក្រៃលែងជាងទាន ដែលព្រះរាជាថ្វាយហើយ" ទើបទូលនិមន្តព្រះសាស្ដា ក្នុងថ្ងៃស្អែកឡើងចាត់ចែងទានហើយ ក៏បានបញ្ជូនដំណឹងទៅថ្វាយព្រះរាជា ។ ព្រះរាជា

ស្តេចយាងទៅទតឃើញទានរបស់ជនទាំងនោះហើយ ទ្រង់ព្រះតម្រិះថា "យើងនឹងថ្វាយទានឲ្យក្រៃលែងជាងទាននេះ" ថ្ងៃស្អែកឡើង ទ្រង់និមន្តព្រះសាស្តាដើម្បីទទួលភត្ត ។ ព្រះរាជាមិនអាចយកឈ្នះលើអ្នកនគរបាន សូម្បីអ្នកនគរក៏មិនអាចយកឈ្នះព្រះរាជាបាន ។ ក្នុងលើកទី ៦ អ្នកនគរគិតថា "ថ្ងៃស្អែកនេះ យើងនឹងថ្វាយទានដោយប្រការដែលបុគ្គលណាៗ មិនអាចនិយាយបានថា វត្ថុនេះមិនមាន ក្នុងទាននៃជនទាំងនេះ" ដូច្នេះហើយ ថ្ងៃស្អែកឡើងបានចាត់ចែងវត្ថុទានស្រេចហើយ ពិនិត្យមើលថា "អ្វីហ្ន៎ មិនទាន់មានក្នុងទាននេះ" ក៏បានឃើញ ទឹកឃ្មុំស្រស់មួយមុខ ចំណែកទឹកឃ្មុំផ្អិនមានច្រើន ។ ជនទាំងនោះឲ្យទ្រព្យ ៤ ពាន់កហាបណៈដល់មនុស្សម្នាក់ ដើម្បីទៅរកទិញទឹកឃ្មុំស្រស់ តាមខ្លោងទ្វារនគរទាំង ៤ ។ គ្រានោះ អ្នកជនបទម្នាក់មកសួរសុខទុក្ខមេស្រុក បានឃើញឃ្មុំមួយសំបុកតាមផ្លូវ ក៏ដេញមេឃ្មុំឲ្យរត់ចេញហើយកាច់មែកឈើកាន់យកផ្ទិតទឹកឃ្មុំ ព្រមទាំងកំណាត់មែកឈើ ដើរចូលទៅកាន់ព្រះនគរ ដោយតាំងចិត្តថា "នឹងជូនមេស្រុក" បុរសដែលទៅរកទិញទឹកឃ្មុំនោះ បានឃើញបុរសអ្នកជនបទនោះកាន់ទឹកឃ្មុំ ក៏សួរថា "អ្នកដ៏ចម្រើនទឹកឃ្មុំនេះ អ្នកលក់ឬ?" ។

អ្នកជនបទ. មិនលក់ទេ នាយ ។

បុរស. អ្នកចូរទទួលយកកហាបណៈនេះ ចូរឲ្យ (ទឹកឃ្មុំនេះដល់ខ្ញុំ) ចុះ ។

អ្នកជនបទនោះគិតថា "ទឹកឃ្មុំនេះមានតំលៃមិនដល់មួយបាទផង តែបុរសនេះហ៊ានឲ្យទ្រព្យដល់ទៅមួយកហាបណៈដល់យើង ប្រហែលជាបុរសនេះ មានកហាបណៈច្រើនហើយមើលទៅ យើងគួរតែតម្លើងថ្លៃ" ។ គ្រានោះគេទើបប្រាប់បុរសនោះថា "ខ្ញុំឲ្យមិនបានទេ" ។

បុរស. បើដូច្នោះ ខ្ញុំឲ្យអ្នកពីរកហាបណៈ ។

អ្នកជនបទ. សូម្បីពីរកហាបណៈ ក៏ខ្ញុំឲ្យមិនបាន ។

អ្នកជនបទនោះ តម្លើងថ្លៃដោយអាការយ៉ាងនោះ រហូតដល់បុរសនោះពោលថា "បើដូច្នោះ ខ្ញុំឲ្យមួយពាន់កហាបណៈ អ្នកព្រមទេ" ពោលដូច្នោះហើយ បង្អោនបង្វិចទ្រព្យចូលទៅ ។ ពេលនោះ អ្នកជនបទពោលនឹងបុរសនោះថា "លោកឆ្កួតទេឬ ឬក៏លោកមិនមានកន្លែងទុកដាក់កហាបណៈ? ទឹកឃ្មុំមានតម្លៃមិនដល់មួយបាទផង លោកហ៊ានពោលថា អ្នកចូរទទួលយកកហាបណៈមួយពាន់ ហើយចូរឲ្យ (ទឹកឃ្មុំដល់ខ្ញុំ) នេះលោកមានការអ្វីឬ?" ។

បុរស. ម្នាលអ្នកដ៏ចម្រើន ខ្ញុំដឹង ប៉ុន្តែខ្ញុំមានការងារដែលចាំបាច់ត្រូវការទឹកឃ្មុំខានមិនបាន ព្រោះហេតុនោះ ទើបខ្ញុំពោលយ៉ាងនោះ ។

អ្នកជនបទ. នាយ តើកម្មអ្វី ?

បុរស. ពួកយើងចាត់ចែងមហាទានដើម្បីថ្វាយចំពោះព្រះសម្មាសម្ពុទ្ធវិបស្សីដែលមានសមណៈ ៦ លាន ៨ សែនជាបរិវារ ក្នុងមហាទាននោះ នៅខ្វះតែទឹកឃ្មុំស្រស់មួយមុខប៉ុណ្ណោះ ហេតុនេះទើបខ្ញុំសុំទិញ (ទឹកឃ្មុំ) ដោយអាការ

យ៉ាងនេះ ។

អ្នកជនបទ. បើដូច្នោះ ខ្ញុំមិនត្រូវការតម្លៃទេ បើលោកឲ្យចំណែកបុណ្យក្នុងទាននោះដល់ខ្ញុំៗ នឹងឲ្យទឹកឃ្មុំនេះដល់លោក ។

បុរសនោះ យកសេចក្តីនោះទៅប្រាប់អ្នកនគរ ។ អ្នកនគរដឹងថា សទ្ធាអ្នកជនបទនោះ ជាធម្មជាតមានកំលាំង ក៏ទទួលយល់ព្រមថា សាធុ ប្រពៃហើយៗ សូមឲ្យគេបានចំណែកបុណ្យអំពីអ្នកនគរ ដែលបានថ្វាយទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានចុះ ។ អ្នកនគរទាំងនោះ និមន្តភិក្ខុសង្ឃ មានព្រះពុទ្ធប្រធានឲ្យគង់ហើយ ថ្វាយបបរ និងបង្អែម ហើយញុំាងបុគ្គលឲ្យនាំផ្តិលមាសមួយធំមកហើយ ឲ្យគេគាបទឹកឃ្មុំដាក់ គាប់ជូនពេលនោះ ក្អមដែលពេញដោយទឹកដោះ ដែលមនុស្សនោះនាំមកដើម្បីជាបណ្ណាការនៅមាន ជនទាំងអស់នោះដាក់ទឹកដោះជូរទៅក្នុងថាសលាយនឹងទឹកឃ្មុំនោះ ហើយប្រគេនចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន តាំងអំពីដើមអាសនៈមក ។ ភិក្ខុគ្រប់រូប ឆាន់ទឹកឃ្មុំនោះគ្រប់បរិបូណ៌មិនលើសមិនខ្វះ ។ បុគ្គលមិនគួរគិតថា ទឹកឃ្មុំតិចយ៉ាងនេះ ភិក្ខុច្រើនរូបយ៉ាងហ្នឹង ឆាន់គ្រប់បរិបូណ៌បានយ៉ាងណា ពិតណាស់ ទឹកឃ្មុំនោះគ្រប់ល្មមដល់ភិក្ខុដោយអានុភាពនៃព្រះពុទ្ធ ។ ពុទ្ធវិស័យបុគ្គលមិនគួរគិត ។ ពិតណាស់ ហេតុ ៤ យ៉ាង ព្រះមានព្រះភាគទ្រង់ត្រាស់ថា ជារឿងដែលមិនគួរគិត (អចិន្តេយ្យៈ) បើបុគ្គលណាៗ នៅតែគិតដល់ហេតុទាំងនោះ រមែងជាអ្នកមានទូវចំណែកនៃសេចក្តីឆ្កួត ដោយប្រការដូច្នេះ ។

បុរសនោះ ធ្វើកម្មមានប្រមាណប៉ុណ្ណេះហើយ ក្រោយពីការអស់អាយុ ក៏បដិសន្ធិក្នុងទេវលោក អន្ទោលទៅមកក្នុងទេវលោកនោះអស់កាលដ៏យូរ ចុតិចាកទេវលោកហើយ បដិសន្ធិក្នុងរាជត្រកូល នាក្រុងពារាណសី កាលព្រះរាជបិតាសោយទិវង្គតទៅ ក៏បានជាព្រះរាជា ។ លុះបានជាព្រះរាជាហើយ ទ្រង់ព្រះតម្រិះថា "នឹងដណ្តើមយកនគរមួយ" ទើបនាំកងទ័ពទៅឡោមព័ទ្ធនគរនោះ ហើយទ្រង់បញ្ជូនរាជសាសន៍ទៅសួរអ្នកនគរថា "សុខចិត្តប្រគល់នូវរាជ-សម្បត្តិឲ្យយើង ឬក៏ឲ្យនូវចម្បាំង" អ្នកនគរទាំងនោះបញ្ជូនសារតបទៅថា "មិនឲ្យទាំងរាជសម្បត្តិ មិនឲ្យទាំងចម្បាំង" ដូច្នេះហើយ ក៏ចេញទៅ នាំយកវត្ថុទាំងឡាយ មានឧស និងទឹកជាដើមមកតាមទ្វារតូចៗ ធ្វើកិច្ចគ្រប់យ៉ាងដោយការចេញចូលតាមទ្វារតូចៗ ។ ចំណែកព្រះរាជាក្រៅនេះ ការពារទ្វារធំទាំង ៤ ឡោមព័ទ្ធព្រះនគរអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ក្នុងកាលតមកព្រះមាតារបស់ព្រះរាជានោះ ត្រាស់សួរថា "តើ បុត្ររបស់យើងកំពុងធ្វើអ្វី" ទ្រង់ស្តាប់រឿងនោះថា "ទ្រង់ធ្វើនូវកម្មឈ្មោះនេះ" ក៏ត្រាស់ថា "បុត្ររបស់យើងនេះល្ងង់ ពួកអ្នកចូរទៅ ចូរទូលបុត្ររបស់យើងថា "ចូរបិទទ្វារតូចៗ ហើយឡោមពទ្ធព្រះនគរ" ។ ព្រះរាជាទ្រង់ស្តាប់នូវព្រះសវនីយ៍របស់ព្រះមាតាហើយ ក៏ទ្រង់ធ្វើដូច្នោះ ។ ចំណែកអ្នកនគរ កាលមិនបានចេញទៅខាងក្រៅ ដល់ថ្ងៃទី ៧ ក៏សម្លាប់ព្រះរាជារបស់ខ្លួន យករាជសម្បត្តិថ្វាយព្រះរាជាអង្គនោះ ។ ព្រះរាជាទ្រង់ធ្វើកម្មនោះឯង ក្រោយពីសោយទិវង្គតទៅ ក៏បដិសន្ធិនៅក្នុងអវិចី

ឆេះនៅក្នុងនរករហូតដល់ផែនដីដុះឡើងកម្រាស់មួយយោជន៍ ចុតិចាកអត្តភាព នោះហើយ ទៅបដិសន្ធិក្នុងផ្ទៃនៃស្ត្រីដែលធ្លាប់ជាព្រះមាតាកាលពីជាតិមុននោះឯង ហើយនៅក្នុងផ្ទៃមាតាអស់ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ដេកទទឹងទ្វារកំណើតអស់ ៧ ថ្ងៃ ព្រោះអំពើដែលខ្ទប់ទ្វារតូចៗ ទាំង ៤ ។ ម្នាលភិក្ខុទាំងឡាយ សីវលីឆេះនៅក្នុងនរកអស់កាលប្រមាណប៉ុណ្ណេះ ព្រោះកម្មដែលគេឡោមព័ទ្ធព្រះនគរ ហើយដណ្តើមយកនគរក្នុងកាលនោះ បដិសន្ធិក្នុងផ្ទៃនៃមាតា ហើយដេកនៅក្នុងផ្ទៃអស់កាលប្រមាណប៉ុណ្ណោះ ព្រោះលោក បិទទ្វារតូចៗ ទាំង ៤ ជាអ្នកមានលាភច្រើន មានយសច្រើន ព្រោះលោកថ្វាយទឹកឃ្មុំស្រស់ ដោយប្រការយ៉ាងនេះ" ។

## ពួកភិក្ខុសរសើរបុណ្យរបស់ព្រះរេវតៈ

ក្នុងថ្ងៃស្អែកឡើង ភិក្ខុទាំងឡាយសន្ទនាគ្នាថា "សាមណេរតែមួយអង្គធ្វើបានផ្ទះកំពូល ៥០០ ដើម្បីភិក្ខុ ៥០០ រូប មានលាភ មានបុណ្យ គួរឲ្យសរសើរ" ព្រះសាស្តាស្តេចយាងទៅ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយប្រជុំគ្នានិយាយអំពីរឿងអ្វី" កាលភិក្ខុទាំងនោះក្រាបទូលថា "បពិត្រព្រះអង្គដ៏ចម្រើន សន្ទនាគ្នាអំពីរឿងឈ្មោះនេះ" ទ្រង់ត្រាស់ថា "ភិក្ខុទាំងឡាយ បុត្ររបស់តថាគតមិនមានបុណ្យ មិនមានបាបទេ (ព្រោះ) បុណ្យ និងបាបទាំងពីរនោះ បុត្ររបស់តថាគតលះបង់អស់ហើយ" លុះត្រាស់ដូច្នេះហើយក៏បានត្រាស់ ព្រះគាថាក្នុងព្រាហ្មណវគ្គថា ៖

*បុគ្គលណាក្នុងលោកនេះ កន្លងគ្រឿងជាប់ជំពាក់ ២ យ៉ាង គឺ បុណ្យ និងបាប តថាគតហៅបុគ្គលនោះ ជាអ្នកមិនសោក ប្រាសចាកកិលេសដូចជាធូលី ជាអ្នកបរិសុទ្ធ ថាជាព្រាហ្មណ៍ ។*

ចប់ រឿងព្រះរេវតត្ថេរ

# ១០. រឿងស្ត្រីម្នាក់

ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធស្ត្រីមួយរូប ត្រាស់ព្រះធម្មទេសនានេះថា **រមណីយានិ** (ដែលគួរត្រេកអរ) ជាដើម ។

ស្ត្រីនគរសោភិនីញ៉ាំងចិត្ត ព្រះថេរៈឱ្យរវេរ្វង

បានស្តាប់មក ភិក្ខុអ្នកមានបិណ្ឌបាតជាវត្តមួយរូប រៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្តាហើយ ចូលទៅកាន់ឧទ្យានចាស់មួយធ្វើសមណធម៌ ។ គ្រានោះ ស្ត្រីនគរសោភិនី (ស្ត្រីលំអនគរ) ម្នាក់ ធ្វើការណាត់នឹងបុរសម្នាក់ថា "ខ្ញុំនឹងទៅកាន់ទីឈ្មោះឯណោះ លោកគប្បីទៅកាន់ទីនោះចុះ" ឯបុរសនោះមិនបានទៅកាន់ទីនោះ តាមការណាត់ទេ ។ នាងរង់ចាំមើលផ្លូវបុរសនោះមិនឃើញមក កើតសេចក្តីអផ្សុក ក៏ដើរចូលទៅកាន់ឧទ្យាននោះ ជួបព្រះថេរៈកំពុងគង់ពែនភ្នែន ក្រឡេកមើលខាងនេះ ខាងនោះ មិនឃើញអ្នកដទៃណាៗ ក៏គិតថា "បុគ្គលនេះជាបុរសដែរ យើងនឹងញ៉ាំងចិត្តបុរសនេះឲ្យរវេរ្វង" ឈរនៅខាងមុខព្រះថេរៈនោះ ដោះសំពត់សាដកដែលខ្លួនស្លៀកហើយ (ត្រឡប់) ស្លៀកវិញ ធ្វើដូច្នេះរឿយៗ រំសាយសក់ហើយ ចងទៅវិញរឿយៗ ទះដៃសើចនៅខាងមុខព្រះថេរៈ ។ សេចក្តីសង្វេគកើតឡើងដល់ព្រះថេរៈ បានផ្សាយទៅពាសពេញសរីរៈ ។ លោកគិតថា "នេះជាអ្វីហ្ន៎"

ព្រះសាស្តាទ្រង់សំដែងធម៌ដល់ព្រះថេរៈ

ចំណែកព្រះសាស្តា ទ្រង់ពិចារណាមើលថា តើការប្រព្រឹត្តិនៃភិក្ខុអ្នក

រៀនកម្មដ្ឋានក្នុងសម្នាក់របស់តថាគតហើយ ទៅកាន់ព្រៃដោយតាំងចិត្តថា "នឹងធ្វើសមណធម៌នោះ យ៉ាងណាហ្ន៎" ទ្រង់ឃើញស្ត្រីនោះហើយ ទ្រង់ជ្រាបនូវកិរិយាអនាចាររបស់ស្ត្រីនោះផង សេចក្តីសង្វេគរបស់ព្រះថេរៈផង ទ្រង់គង់ប្រថាប់នៅក្នុងព្រះគន្ធកុដិនោះឯង បានត្រាស់ទៅកាន់ព្រះថេរៈថា "ម្នាលភិក្ខុ ទីដែលមិនត្រេកអរនៃបុគ្គលអ្នកស្វែងរកកាមនោះឯង ជាទីត្រេកអរនៃបុគ្គលអ្នកមានរាគៈប្រាសទៅហើយទាំងឡាយ" ។ លុះត្រាស់យ៉ាងនោះហើយ ទ្រង់ផ្សាយពន្លឺទៅ កាលនឹងទ្រង់សំដែងធម៌ដល់ភិក្ខុនោះ បានត្រាស់ព្រះគាថានេះថា ៖

*រមណីយានិ អរញ្ញានិ យត្ថ ន រមតី ជនោ*
*វីតរាគា រមេស្សន្តិ ន តេ កាមគវេសិនោ ។*

*ជន (អ្នកស្វែងរកកាម) រមែងមិនត្រេកអរក្នុងព្រៃ ដែលគួររីករាយទេ ព្រះខីណាស្រពដែលមានរាគៈទៅប្រាសហើយ ទើបត្រេកអរក្នុងព្រៃនោះ ព្រោះលោកជាអ្នកមិនស្វែងរកកាម ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អរញ្ញានិ** (ព្រៃ) សេចក្តីថា ធម្មតា ព្រៃទាំងឡាយ ដែលប្រដាប់ដោយដងព្រៃ ដ៏ដេរដាសដោយឈើជំទង់ មានផ្ការីក សម្បូណ៌ដោយទឹកស្អាត ប្រាសចាកមន្ទិល ជាទីគួរឲ្យត្រេកអរពិតៗ ។ បទថា **យត្ថ** (ក្នុងព្រៃណា) ជាដើម សេចក្តីថា ជនណាស្វែងរកកាម រមែង

មិនត្រេកអរក្នុងព្រៃទាំងឡាយ ដូចជារុយស្រុកទាំងឡាយ មិនត្រេកអរក្នុងព្រៃឈូកទាំងឡាយ ដែលមានផ្ការីកស្គុះស្គាយ ដូច្នោះ ។ បទថា **វីតរាគា** (ប្រាសចាករាគៈ) ជាដើម សេចក្តីថា បុគ្គលអ្នកមានរាគៈទៅប្រាសហើយទាំងឡាយ គឺ ព្រះខីណាស្រព រមែងត្រេកអរក្នុងព្រៃទាំងឡាយបែបនោះ ដូចសត្វកន្ទង់និងសត្វឃ្មុំទាំងឡាយ តែងតែត្រេកអរក្នុងព្រៃឈូក ដូច្នោះ ។

សួរថា ព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះលោកមានរាគៈទៅប្រាសហើយទាំងនោះ ជាអ្នកមានប្រក្រតីមិនស្វែងរកកាម អធិប្បាយថា ព្រោះលោកទាំងនោះ រមែងជាអ្នកមិនមានប្រក្រតីស្វែងរកកាម (ទើបត្រេកអរក្នុងព្រៃទាំងឡាយ) ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះថេរៈនោះ បានសម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ មកតាមផ្លូវអាកាស សរសើរព្រះធម្មទេសនារបស់ព្រះសាស្តា ថ្វាយបង្គំព្រះបាទទាំងគូរបស់តថាគត បានទៅហើយ ។

ចប់ រឿងស្ត្រីម្នាក់

## ចប់អរហន្តវគ្គវណ្ណនា វគ្គទី ៧

ក្នុងវគ្គនេះរួមមាន ១០ រឿង


| | |
|---|---|
| ១.រឿងពេទ្យជីវក | ២. រឿងព្រះមហាកស្សបៈ |
| ៣.រឿងព្រះពេឡដ្ឋសីសៈ | ៤. រឿងព្រះអនុរុទ្ធ |
| ៥.រឿងព្រះមហាកច្ចាយនៈ | ៦. រឿងព្រះសារីបុត្រ |
| ៧.រឿងព្រះថេរៈអ្នកក្រុងកោសម្ពី | ៨. រឿងព្រះសារីបុត្រ |
| ៩.រឿងព្រះខទិរវនិយរេវតៈ | ១០. រឿងស្ត្រីម្នាក់ |

# ៨. សហស្សវគ្គវណ្ណនា

## ១. រឿងបុរសអ្នកសម្លាប់ចោរឈ្មោះតម្ពទាឋិកៈ

[១៨] *ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធបុរសអ្នកសម្លាប់ចោរឈ្មោះ **តម្ពទាឋិកៈ** បានត្រាស់ព្រះធម្មទេសនានេះថា **សហស្សមបិ ចេ វាចា** (បើវាចាសូម្បីទាំងពាន់) ជាដើម ។*

ពេជ្ឈឃាតពុកមាត់ក្រហម

*ដូចបានស្តាប់មកថា មានចោរ ៥៩៩ នាក់ ធ្វើកម្ម មានការប្លន់អ្នកស្រុកជាដើមចិញ្ចឹមជីវិត ។ គ្រានោះ បុរសម្នាក់មានភ្នែកលឿងក្រឡោត មានពុកមាត់ក្រហម បានទៅកាន់សម្នាក់របស់ចោរទាំងនោះ ពោលថា "ខ្ញុំសូមនៅជាមួយពួកលោកផង" ។ ខណៈនោះ ពួកចោរបង្ហាញបុរសនោះដល់មេចោរ ហើយពោលថា "បុរសនេះប្រាថ្នានឹងនៅក្នុងសម្នាក់របស់ពួកយើង" ។ គ្រានោះ មេចោរពិនិត្យមើលបុរសនោះ ហើយគិតថា "បុរសនេះ សាហាវណាស់ អាចកាត់ដោះរបស់មាតាស៊ី ឬអារបំពង់កយកឈាមបិតាផឹកបាន" ទើបបដិសេធថា "កិច្ច គឺ ការនៅក្នុងសម្នាក់របស់ពួកយើងសម្រាប់បុរសនេះមិនមាន" ។ បុរសនោះ សូម្បីត្រូវមេចោរហាមដូច្នោះ ក៏មិនព្រមទៅ នៅបម្រើកូនចោរម្នាក់ រហូតធ្វើឲ្យចោរនោះពេញចិត្តស្រឡាញ់ ។ ចោរនោះ នាំបុរស*

នោះចូលទៅរកមេចោរ ហើយអង្វរថា “នាយ ជននេះជាមនុស្សល្អ មានឧបការៈដល់ពួកយើង សូមលោកអាណិតគេផង” ។ មេចោរក៏ព្រមទទួល ។ ខាងក្រោយមក ថ្ងៃមួយ ពួកអ្នកនគររួមគ្នាជាមួយពួករាជបុរសចាប់ចោរទាំងនោះបាន នាំទៅកាន់សម្នាក់របស់ពួកអាមាត្យអ្នកវិនិច្ឆ័យក្តី ។ ពួកអាមាត្យបង្គាប់ឲ្យកាត់ក្បាលចោរទាំងនោះដោយកាំបិត ។ លំដាប់នោះ ពួកអ្នកនគរប្រឹក្សាគ្នាថា “បាននរណាហ្ន៎ សម្លាប់ចោរទាំងនេះ” ស្វែងរកទៅ មិនឃើញនរណាៗប្រាថ្នាសម្លាប់ចោរទាំងនោះ ទើបនិយាយនឹងមេចោរថា “បើលោកសម្លាប់ចោរទាំងនេះ នឹងបានទាំងជីវិតទាំងការរាប់អាន លោកចូរសម្លាប់ចោរទាំងនោះ” ។ មេចោរនោះក៏មិនប្រាថ្នានឹងសម្លាប់ ព្រោះពួកចោរនោះ រស់នៅអាស្រ័យនឹងខ្លួន ។ ពួកអ្នកនគរសួរចោរទាំង ៤៩៩ នាក់ ដោយឧបាយនោះ ។ សូម្បីចោរទាំងអស់ក៏មិនប្រាថ្នា ។ ពួកអ្នកនគរសួរនាយតម្ពទាឋិកៈ ដែលមានពុកមាត់ក្រហមនោះក្រោយគេបង្អស់ ។ នាយតម្ពទាឋិកៈនោះក៏ទទួលថា “បាន” ហើយសម្លាប់ចោរទាំងអស់នោះ បានទាំងជីវិត ទាំងការរាប់អាន ។

ពេជ្ឈឃាតចេញចាកតំណែងពេលខ្លួនចាស់

ពួកអ្នកនគរនាំចោរ ៥០០ នាក់ មកពីទិសទក្សិណនៃនគរ ប្រគល់ដល់ពួកអាមាត្យដោយឧបាយនោះ កាលពួកអាមាត្យនោះ បង្គាប់កាត់ក្បាលចោរទាំងនោះ ក៏សួរតាំងពីមេចោរជាដើមទៅ មិនមាននរណាម្នាក់ប្រាថ្នានឹងសម្លាប់ ទើបសួរថា “ក្នុងថ្ងៃមុនបុរសម្នាក់សម្លាប់ចោរ ៥០០ ឥឡូវបុរសនោះនៅទី

ណា” កាលជនទាំងឡាយប្រាប់ថា “ពួកខ្ញុំ ឃើញគាត់នៅឯណោះ ទើបឲ្យហៅមក” ហើយបង្គាប់ថា “លោកចូរសម្លាប់ចោរទាំងនេះ លោកនឹងបានការរាប់អាន” ។ នាយតម្ពទាឋិកៈនោះព្រមថា “ល្អហើយ” ក៏សម្លាប់ចោរទាំងនោះ ។ គ្រានោះ ពួកអ្នកនគរប្រឹក្សាគ្នាថា “បុរសនេះល្អ ពួកយើងនឹងឲ្យគាត់សម្លាប់ចោរជាប្រចាំ” ដូច្នេះហើយ ទើបឲ្យតំណែងនោះដល់គាត់ ។ នាយតម្ពទាឋិកៈនោះសម្លាប់ចោរ មួយដងៗ ៥០០ ដែលគេនាំមកពីទិសបស្ចិមខ្លះ ទិសឧត្តរខ្លះ គាត់សម្លាប់ចោរអស់ ២ ពាន់នាក់ ដែលគេនាំមកអំពីទិសទាំង ៤ ដោយឧបាយយ៉ាងនោះ ។ ចាប់ផ្តើមអំពីនោះមក សម្លាប់មនុស្សដែលគេនាំមក រហូតនៅត្រឹមមួយនាក់ ពីរនាក់ រាល់ៗ ថ្ងៃ អស់ ៥៥ ឆ្នាំ ។ ក្នុងវេលាខ្លួនចាស់ គាត់មិនអាចកាត់ក្បាលចោរដោយការប្រហារតែម្តងបាន ត្រូវកាត់ ២-៣ ដង ធ្វើឲ្យចោរទាំងឡាយលំបាក ។ ពួកអ្នកនគរគិតគ្នាថា “នឹងមានមនុស្សសម្លាប់ចោរដទៃទៀតទេ អ្នកនេះធ្វើចោរ ទាំងឡាយឲ្យលំបាកខ្លាំងណាស់ ត្រូវការគាត់ធ្វើអ្វីទៀត” ទើបដកតំណែងនោះរបស់គាត់ចេញ ។ នាយតម្ពទាឋិកៈនោះ រវល់តែធ្វើចោរឃាតកម្មក្នុង កាលមុន ទើបមិនបានកិច្ច ៤ យ៉ាង គឺ ការស្លៀកសំពត់ថ្មី ការផឹកយាគូដែលលាយដោយទឹកដោះថ្លា ការប្រដាប់ផ្កាម្លិះ ការលាបដោយរបស់ក្រអូប ។ ថ្ងៃដែលត្រូវចេញចាកតំណែងគាត់ពោលថា “លោកទាំងឡាយចូរចំអិនបបរលាយ ដោយទឹកដោះដល់យើង ហើយឲ្យគេកាន់សំពត់ថ្មី កម្រងផ្កាម្លិះ និងគ្រឿងលាបទៅកាន់ស្ទឹង ងូតទឹក

ហើយស្លៀកសំពត់ថ្មី ប្រដាប់ផ្កាម្រិះ មានខ្លួនលាបដោយគ្រឿងក្រអូប ត្រឡប់មកអង្គុយក្នុងផ្ទះ ។ ខណៈនោះ ជនទាំងឡាយដាក់បបរ ដែលលាយដោយទឹកដោះស្រស់ខាងមុខគាត់ហើយ ក៏យកទឹកសម្រាប់លាងដៃមក ។

## នាយតម្ពទាឋិកៈធ្វើបុណ្យចំពោះព្រះសារីបុត្រ

ក្នុងខណៈនោះ ព្រះសារីបុត្តត្ថេរចេញចាកសមាបត្តិ ពិចារណាមើលផ្លូវត្រាច់កិក្ខារបស់ខ្លួនថា "ថ្ងៃនេះ យើងគួរទៅទីណាហ្ន៎" ឃើញយាគូដែលលាយដោយទឹកដោះថ្លា ក្នុងផ្ទះរបស់នាយតម្ពទាឋិកនោះ ទើបពិចារណាថា "បុរសនោះនឹងធ្វើការសង្គ្រោះយើងឬហ្ន៎" ក៏ដឹងថា "គាត់ឃើញយើងហើយនឹងធ្វើការសង្គ្រោះដល់យើង" ក៏កុលបុត្រនេះ គ្រាធ្វើហើយនឹងបានសម្បត្តិធំ ទើបឃ្លុំចីវរប្រដាប់ដោយបាត្រ បង្ហាញខ្លួននៅត្រង់ទ្វារផ្ទះរបស់នាយតម្ពទា-ឋិកៈនោះឯង ។ នាយតម្ពទាឋិកៈនោះ គ្រាន់តែឃើញព្រះថេរៈ ក៏មានចិត្តជ្រះថ្លា គិតថា "យើងធ្វើចោរឃាតកកម្មមកយូរហើយ យើងសម្លាប់មនុស្សជាច្រើន ឥឡូវនេះ ក្នុងផ្ទះរបស់យើងមានយាគូលាយដោយទឹកដោះថ្លា ឯព្រះថេរៈក៏មកឈរត្រង់ទ្វារផ្ទះរបស់យើង យើងថ្វាយទេយ្យធម៌ដល់លោក-ម្ចាស់ក្នុងវេលានេះ ទើបគួរ" ដូច្នេះហើយ ក៏យកយាគូដែលទុកខាងមុខខ្លួនចេញទៅ ចូលទៅជិតព្រះថេរៈ ហើយថ្វាយបង្គំ និមន្តឲ្យគង់ខាងក្នុងផ្ទះ ដាក់យាគូដែលលាយដោយទឹកដោះថ្លាចូលទៅក្នុងបាត្រ និងឈរបក់ព្រះថេរៈ ។ ខណៈនោះ អធ្យាស្រ័យ គឺ ចំណង់ដ៏ខ្លាំងក្លា ដើម្បីផឹកយាគូដែលលាយដោយ

ទឹកដោះថ្លា ក៏កើតឡើងដល់គាត់ ព្រោះខ្លួនមិនធ្លាប់បានអស់កាលដ៏យូរមក ហើយ ។ ព្រះថេរៈដឹងអធ្យាស្រ័យរបស់នាយតម្ពទាឋិកៈនោះ ទើបនិយាយ នឹងគាត់ថា "ឧបាសក លោកចូរផឹកយាគូរបស់ខ្លួនចុះ" ។ នាយតម្ពទាឋិកៈ នោះ ឲ្យផ្ចិតដល់អ្នកដទៃហើយ ខ្លួនក៏ផឹកយាគូ ។ ព្រះថេរៈនិយាយនឹងបុរស អ្នកបក់ផ្ចិតថា "អ្នកចូរទៅ ចូរបក់ឲ្យឧបាសកចុះ" ។ នាយតម្ពទាឋិកៈផឹក យាគូឆ្អែតហើយ មកឈរបក់ឲ្យព្រះថេរៈវិញ បានទទួលបាត្ររបស់ព្រះថេរៈ ក្រោយពីធ្វើភត្តកិច្ចស្រេចហើយ ។ ព្រះថេរៈបានផ្តើមអនុមោទនាដល់គាត់ ។ គាត់មិនអាចធ្វើចិត្តរបស់ខ្លួនឲ្យទៅតាមក្រសែធម៌ទេសនារបស់ព្រះថេរៈបាន ។ ព្រះថេរៈសង្កេតដឹង ទើបសួរថា "ឧបាសក ហេតុអ្វី ទើបលោកមិនអាចធ្វើ ចិត្តឲ្យទៅតាមធម៌ទេសនាបាន" តម្ពទាឋិកៈ "លោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណា ធ្វើកម្មអាក្រក់មកអស់កាលយូរហើយ មនុស្សជាច្រើន ត្រូវខ្ញុំព្រះករុណាសម្លាប់ ខ្ញុំករុណារវល់តែរឭកដល់កម្មរបស់ខ្លួននោះ ទើបមិនអាចធ្វើចិត្ត ឲ្យទៅតាម ព្រះធម៌ទេសនារបស់លោកម្ចាស់បាន" ។

ព្រះថេរៈគិតថា "យើងនឹងលួងបុរសនោះ" ទើបនិយាយថា "ចុះលោក ធ្វើតាមសេចក្តីពេញចិត្តរបស់ខ្លួន ឬត្រូវអ្នកដទៃឲ្យធ្វើ"

តម្ពទាឋិកៈ. លោកម្ចាស់ដ៏ចម្រើន ព្រះរាជាឲ្យខ្ញុំករុណាធ្វើ ។

ព្រះថេរៈ. ឧបាសក បើដូច្នោះ អកុសលនឹងមានដល់លោកដែរឬ ?

ឧបាសកជាមនុស្សជាតុទន់ ត្រូវព្រះថេរៈពោលដូច្នោះ ក៏មានសេចក្តី

សម្គាល់ថា "អកុសលមិនមានដល់យើង" ទើបពោលថា "លោកម្ចាស់ បើដូច្នោះ សូមលោកម្ចាស់ពោលធម៌ចុះ" ។ ឧបាសកនោះ កាលព្រះថេរៈធ្វើអនុមោទនា មានចិត្តមានអារម្មណ៍តែមួយ ស្តាប់ធម៌ ញ៉ាំងខន្តិប្រព្រឹត្តទៅដោយអនុលោម (ដល់អរិយសច្ចៈ) ខាងក្នុងនៃសោតាបត្តិមគ្គឲ្យកើតឡើង ។ ឯព្រះថេរៈធ្វើអនុមោទនាហើយ ក៏ចៀសចេញទៅ ។ នាងយក្ខិនីម្នាក់មកហើយ ដោយក្លែងភេទជាមេគោ វែចត្រង់ទ្រូងឧបាសក ដែលតាមជូនដំណើរព្រះថេរៈហើយត្រឡប់មកវិញ ឲ្យស្លាប់ ។ ឧបាសកនោះធ្វើមរណកាលហើយ ក៏កើតក្នុងតុសិតបុរី ។

## កល្យាណមិត្តជាហេតុឱ្យកើតក្នុងតុសិត

ភិក្ខុទាំងឡាយសន្ទនាក្នុងធម្មសភាថា "បុរសសម្លាប់ ចោរធ្វើកម្មអាក្រក់អស់ ៥៥ ឆ្នាំ រួចផុតអំពីកម្មនោះក៏ក្នុងថ្ងៃនេះ ថ្វាយភិក្ខាដល់ព្រះថេរៈក៏ក្នុងថ្ងៃនេះ ធ្វើមរណកាលក៏ក្នុងថ្ងៃនេះដូចគ្នា តើគាត់កើតក្នុងទីណាហ្ន៎?" ។

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកសន្ទនាគ្នាដោយពាក្យអ្វី" កាលភិក្ខុទាំងឡាយក្រាបទូលថា "ដោយពាក្យឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុរសនោះកើតក្នុងតុសិតបុរី" ។ ភិក្ខុទាំងឡាយទូលសួរថា "ព្រះអង្គ ព្រះអង្គត្រាស់អ្វី បុរសនោះសម្លាប់មនុស្សប្រមាណប៉ុណ្ណោះ អស់កាលប៉ុណ្ណោះ ហើយកើតក្នុងវិមានតុសិត" ។

ព្រះសាស្តាត្រាស់ថា "យ៉ាងនោះឯង ភិក្ខុទាំងឡាយ បុរសនោះបាន កល្យាណមិត្តអ្នកធំ គេស្តាប់ធម៌ទេសនារបស់សារីបុត្រ ញ៉ាំងអនុលោម-ញាណឲ្យកើត ចុតិចាកលោកនេះហើយ កើតក្នុងតុសិតវិមាន" ដូច្នេះហើយ ទ្រង់ត្រាស់ព្រះគាថានេះថា ៖

បុរសអ្នកសម្លាប់ចោរក្នុងនគរ ស្តាប់ពាក្យជាសុភាសិត
ហើយ បានអនុលោមខន្តិ ទៅកាន់ទេវលោកជាន់ត្រៃទិព្វ
រមែងរីករាយចិត្ត ។

ពួកភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាអនុមោទនាកថា មានកម្លាំង បុរសនោះធ្វើអកុសលកម្មជាច្រើន គាត់ញ៉ាំងគុណវិសេសឲ្យកើតដោយអនុ-មោទនាកថា ប៉ុណ្ណោះដូចម្តេចបាន?" ។

ព្រះសាស្តាត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំកាន់យក ប្រមាណនៃធម៌ដែលតថាគតសំដែងហើយថា តិច ឬច្រើន ព្រោះថា សូម្បីវាចា មួយម៉ាត់ ដែលអាស្រ័យប្រយោជន៍ ប្រសើរដោយពិត" កាលនឹងទ្រង់បន្ត អនុសន្ធិដើម្បីសំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

សហស្សមបិ ចេ វាចា    អនត្ថបទសញ្ហិតា
ឯកំ អត្ថបទំ សេយ្យោ    យំ សុត្វា ឧបសម្មតិ

បើវាចាសូម្បីមួយពាន់ម៉ាត់ ជាវាចាប្រកបដោយបទឥត
ប្រយោជន៍ វាចានោះពុំប្រសើរឡើយ អ្នកណាស្តាប់បទ

មានប្រយោជន៍ណាហើយ រមែងស្ងប់រម្ងាប់បាន បទដែលមាន

ប្រយោជន៍នោះ សូម្បីតែមួយបទ ក៏ឈ្មោះថាប្រសើរជាង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សហស្សមបិ (សូម្បីទាំងពាន់)** ជាពាក្យសម្រាប់កំណត់ ។ អធិប្បាយថា "សូម្បីថា វាចាដែលគេកំណត់ហើយយ៉ាងនេះ គឺ ១ ពាន់ ២ ពាន់ តែវាចានោះមិនប្រកបដោយបទមានប្រយោជន៍ គឺប្រកបដោយបទទាំងឡាយដែលមិនមានប្រយោជន៍ ដែលប្រកាសអំពីរឿងពណ៌នាអាកាស ពណ៌នាភ្នំ និងពណ៌នាព្រៃជាដើម មិនសម្តែងនូវនិព្វាន មានច្រើនត្រឹមណា ក៏ជាវាចាអាក្រក់ត្រឹមនោះ ។

បទថា **ឯកំ អត្ថបទំ (បទមានប្រយោជន៍តែមួយបទ)** សេចក្តីថា ឯបុគ្គលស្តាប់បទណា ដែលមានប្រយោជន៍សូម្បីតែមួយបទ នេះថា នេះកាយ នេះកាយគតាសតិ វិជ្ជា ៣ យើងចាក់ធ្លុះហើយ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ យើងបានធ្វើហើយ រមែងស្ងប់រម្ងាប់ ដោយការស្ងប់រម្ងាប់កិលេសមានរាគៈជាដើមបាន បទនោះសម្រេចប្រយោជន៍ ប្រកបដោយនិព្វាន គឺថាសម្តែងខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គៈ និងសតិប្បដ្ឋានសូម្បីមួយបទ គង់ប្រសើរជាងដោយពិត ។

ក្នុងវេលាចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ

មានសោតាបត្តិជាដើម ដូច្នេះឯង ។

ចប់ រឿងបុរសអ្នកសម្លាប់ចោរឈ្មោះតម្ពទាឋិកៈ

# ២. រឿងព្រះទារុចីរិយត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះទារុចីរិយត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***សហស្សមបិ ចេ គាថា (ប្រសិនបើគាថាសូម្បី ទាំងពាន់)*** *ជាដើម ។*

ទារុចីរិយៈសម្គាល់ថាខ្លួនជាព្រះអរហន្ត

*សេចក្តីពិស្តារថា ក្នុងសម័យមួយ មនុស្សជាច្រើននាក់ជិះនាវាទៅកាន់មហាសមុទ្ទ កាលនាវាធ្លាយក្នុងមហាសមុទ្ទ ក៏បានជាចំណីរបស់ពពួកត្រីនិងអណ្តើកទាំងឡាយ ។ បណ្តាមនុស្សទាំងនោះ មានតែបុរសម្នាក់ប៉ុណ្ណោះចាប់បានបន្ទះក្តារមួយ ព្យាយាមហែលរហូតដល់ត្រើយនៃកំពង់ឈ្មោះសុប្បារកៈ ។ បុរសនោះមិនមានសំពត់ស្លៀកដណ្តប់ជាប់ខ្លួនឡើយ ។ គាត់មិនឃើញវត្ថុអ្វីដទៃ ទើបយកសារាយមកវុំធ្វើជាសំពត់ស្លៀកដណ្តប់ រួចហើយកាន់យកអំបែងអំពីទេវស្ថាន (ខ្ទមអ្នកតា) បានដើរទៅកាន់កំពង់សុប្បារកៈ ។ មនុស្សទាំងឡាយឃើញគាត់ហើយ បានឲ្យយាគូ និងភត្តជាដើម ដោយពោលសរសើរថា "បុរសនេះជាព្រះអរហន្តមួយអង្គ" ។ បុរសនោះ កាលមនុស្សទាំងឡាយនាំយកសំពត់មកឲ្យ គិតថា "បើអញស្លៀក ឬដណ្តប់ លាភសក្ការៈរបស់អញនឹងសាបសូន្យ" ទើបមិនទទួលសំពត់ដែលគេនាំយកមកឲ្យ ក៏ស្លៀកដណ្តប់តែសំពត់សំបកឈើប៉ុណ្ណោះ ។ គ្រានោះ គាត់កាលត្រូវមនុស្សជាច្រើន*

ពោលថា ជាព្រះអរហន្ត ក៏មានបរិវិតក្កៈយ៉ាងនេះថា "បុគ្គលណាមួយជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គក្នុងលោក បណ្តាបុគ្គលទាំងនោះ យើងក៏ជាព្រះអរហន្តមួយអង្គដែរ" ។ ខណៈនោះ ទេវតាដែលជាសាលោហិតក្នុងកាលមុនរបស់បុរសនោះ ក៏គិតហើយយ៉ាងនោះ ។

## ប្រវត្តិដើមរបស់នារុចីរិយៈ

ពាក្យថា **អ្នកដែលជាសាលោហិតក្នុងកាលមុន** គឺ អ្នកធ្វើសមណធម៌រួមគ្នាក្នុងកាលមុន ។ បានឮថា ក្នុងកាលមុន កាលសាសនានៃព្រះកស្សបទសពល រោយរៀវទៅ ភិក្ខុ ៧ រូប ឃើញវិការៈប្លែកនៃបព្វជិតទាំងឡាយមានសាមណេរជាដើម មានសេចក្តីសង្វេគកើតឡើងថា "ពួកយើងនឹងធ្វើទីពឹងរបស់ខ្លួន ទាន់វេលាដែលព្រះសាសនាមិនទាន់អន្តរធាន" ថ្វាយបង្គំសុវណ្ណចេតិយហើយ ក៏ចូលទៅកាន់ព្រៃឃើញភ្នំមួយ ពោលថា "អ្នកដែលមានការអាល័យក្នុងជីវិត ចូរត្រឡប់ទៅវិញចុះ អ្នកដែលមិនមានអាល័យចូរឡើងភ្នំនេះ" រួចហើយក៏ចងបង្អោងឡើងទៅលើភ្នំនោះទាំងអស់អង្គ ដល់ហើយ ស្រាយបង្អោងទម្លាក់ ហើយធ្វើសមណធម៌ ។ បណ្តាភិក្ខុទាំងនោះ គ្រាន់តែកន្លងមួយរាត្រីប៉ុណ្ណោះ ព្រះសង្ឃត្ថេរក៏បានសម្រេចព្រះអរហត្ត ។ ព្រះសង្ឃត្ថេរនោះ ទំពាឈើស្ទន់ឈ្មោះនាគលតានាអនោតត្តស្រះ ហើយនាំបិណ្ឌបាតពីឧត្តរកុរុទ្វីបមក បានពោលនឹងភិក្ខុទាំងនោះថា "អ្នកមានអាយុទាំងឡាយ ពួកលោកចូរទំពាឈើស្ទន់នេះ លុបលាងមុខហើយ ចូរឆាន់បិណ្ឌបាតនេះចុះ" ។

ភិក្ខុ. លោកម្ចាស់ ចុះពួកយើងដាក់កតិកាគ្នាថា "ភិក្ខុណាបានសម្រេចព្រះអរហត្តមុន ភិក្ខុទាំងឡាយដ៏សេស នឹងឆាន់បិណ្ឌបាតដែលភិក្ខុនោះនាំមកឬ?"

ព្រះថេរៈ. អ្នកមានអាយុ សេចក្តីនោះមិនមានទេ ។

ភិក្ខុទាំងឡាយពោលថា "បើដូច្នោះ សូម្បីពួកយើងក៏គប្បីញ៉ាំងគុណវិសេសឲ្យកើតដូចលោក ពួកយើងនឹងនាំមកឆាន់ដោយខ្លួនឯង" ដូច្នេះហើយ ក៏មិនប្រាថ្នាដើម្បីឆាន់ ។ ក្នុងថ្ងៃទី ២ ព្រះថេរៈអង្គទី ២ បានសម្រេចជាព្រះអនាគាមី ។ ព្រះថេរៈនោះ នាំបិណ្ឌបាតមកហើយ ក៏និមន្តភិក្ខុក្រៅនេះឲ្យឆាន់ដូចគ្នា ។ ភិក្ខុទាំងនោះពោលយ៉ាងនេះថា "លោកម្ចាស់ ក៏ពួកយើងធ្វើកតិកាគ្នាទុកយ៉ាងនេះថា ពួកយើងនឹងមិនឆាន់បិណ្ឌបាត ដែលមហាថេរៈនាំមក តែនឹងឆាន់បិណ្ឌបាតដែលព្រះអនុថេរៈនាំមកឬ?" ។

ព្រះថេរៈទី ២. អ្នកមានអាយុ សេចក្តីនោះមិនមានទេ ។

ភិក្ខុទាំងនោះពោលថា "បើដូច្នោះ សូម្បីពួកយើងក៏គប្បីញ៉ាំងគុណវិសេសឲ្យកើតដូចលោកម្ចាស់ ហើយអាចដើម្បីឆាន់ ដោយការព្យាយាមនៃបុរសរបស់ខ្លួនបាន" ដូច្នេះហើយ ក៏មិនប្រាថ្នាឆាន់ ។

បណ្តាភិក្ខុទាំងនោះ ភិក្ខុអ្នកសម្រេចព្រះអរហត្ត ក៏បរិនិព្វាន ភិក្ខុអ្នកជាអនាគាមីកើតក្នុងព្រហ្មលោក ភិក្ខុ ៥ រូបក្រៅនេះ មិនអាចញ៉ាំងគុណវិសេសឲ្យកើតបាន ក៏ធ្វើមរណកាលក្នុងថ្ងៃទី ៧ ហើយកើតក្នុងទេវលោក

ក្នុងពុទ្ធុប្បាទកាលនេះ ចុតិចាកទេវលោកនោះហើយ កើតក្នុងផ្ទះនៃត្រកូលនោះៗ ។ បណ្ដាបុគ្គលទាំងនោះ បុគ្គលម្នាក់បានជាព្រះរាជា ព្រះនាមបុក្កុសាតិ ម្នាក់បានជាព្រះកុមារកស្សបៈ ម្នាក់បានជាព្រះទារុចីរិយៈ ម្នាក់បានជាព្រះទព្វមល្លបុត្រ និងម្នាក់ទៀតបានជាបរិព្វាជកឈ្មោះសភិយៈ ។ ក្នុងពាក្យថា ទេវតាជាសាលោហិតក្នុងកាលមុននេះ លោកពោលសំដៅយក ភិក្ខុអ្នកកើតក្នុងព្រហ្មលោកនោះ ។

## ព្រហ្មប្រាប់សេចក្ដីពិតដល់ទារុចីរិយៈ

ព្រហ្មនោះ មានបរិវិតក្កៈយ៉ាងនេះថា "បុរសនេះបានចងបង្អោងឡើងភ្នំ ធ្វើសមណធម៌ជាមួយយើង ឥឡូវនេះ គេប្រកាន់ទិដ្ឋិនេះត្រាច់ទៅ គប្បីវិនាស យើងនឹងធ្វើគេឲ្យសង្វេគ" ។ ខណៈនោះ ព្រហ្មនោះចូលទៅរកបុរសនោះហើយ ពោលយ៉ាងនេះថា "ពាហិយៈ អ្នកមិនមែនជាព្រះអរហន្តទេ អ្នកមិនទាន់សម្រេចព្រះអរហត្តមគ្គឡើយ ទាំងបដិបទារបស់អ្នកដែលជាព្រះអរហន្ត ឬជាអ្នកសម្រេចអរហត្តមគ្គក៏មិនមាន" ។ ពាហិយៈក្រឡេកមើលមហាព្រហ្មដែលឈរនិយាយពួដ៏អាកាសហើយ គិតថា "ឱ! យើងធ្វើកម្មធ្ងន់ណាស់ យើងគិតថា យើងជាព្រះអរហន្ត តែមហាព្រហ្មនេះនិយាយនឹងយើងថា អ្នកមិនមែនជាព្រះអរហន្ត មិនទាន់បានអរហត្តមគ្គឡើយ ព្រះអរហន្តដទៃមានក្នុងលោកឬហ្ន៎?" គ្រានោះ គាត់សួរមហាព្រហ្មនោះថា "លោកជាទេវតា ឥឡូវនេះព្រះអរហន្ត ឬអ្នកសម្រេចអរហត្តមគ្គមានក្នុងលោកឬ?" លំដាប់នោះ ព្រហ្ម

ប្រាប់ដល់ពាហិយៈថា “ពាហិយៈ ក្នុងជនបទ ខាងជើងនៃនគរឈ្មោះសាវត្ថី ឥឡូវនេះ ព្រះសម្ពុទ្ធជាព្រះអរហន្តនោះ ប្រថាប់នៅក្នុងនគរនោះ ពាហិយៈ ក៏ព្រះមានព្រះភាគអង្គនោះ ជាព្រះអរហន្តផង ទ្រង់សម្តែងធម៌ដើម្បីភាពជាព្រះអរហន្តផង ។

## ពាហិយៈទៅគាល់ព្រះសាស្តា

ពាហិយៈស្តាប់ពាក្យរបស់ទេវតាក្នុងចំណែកនៃរាត្រីហើយ មានចិត្តតក់ស្លុតក្នុងខណៈនោះៗ ឯង ចេញចាកកំពង់សុប្បារកៈ បានទៅដល់ក្រុងសាវត្ថី ដោយសម្រាកតែមួយរាត្រីប៉ុណ្ណោះ ។ គាត់បានដើរផ្លូវប្រមាណ ១២០ យោជន៍ ដោយការសម្រាកតែមួយរាត្រីប៉ុណ្ណោះ ឯការទៅ ក៏សម្រេចហើយដោយអានុភាពរបស់ទេវតា ។ អាចារ្យពួកខ្លះពោលថា ទៅដោយអានុភាពរបស់ព្រះពុទ្ធ ដូច្នេះខ្លះ ។ ក៏ក្នុងខណៈនោះ ព្រះសាស្តាស្តេចចូលទៅកាន់ក្រុងសាវត្ថីដើម្បីបិណ្ឌបាត ។ ពាហិយៈនោះ សួរភិក្ខុទាំងឡាយដែលឆាន់អាហារព្រឹក ហើយចង្រ្កមនៅទីវាលស្រឡះ ដើម្បីដោះសេចក្តីខ្ជិលច្រអូសផ្លូវកាយថា “ឥឡូវនេះ ព្រះសាស្តាប្រថាប់នៅក្នុងទីណា” ភិក្ខុទាំងឡាយតបថា “ស្តេចយាងទៅក្រុងសាវត្ថីដើម្បីបិណ្ឌបាត” ហើយសួរបុរសនោះថា “ចុះលោកមកពីទីណា?” ។

ទារុចីរិយៈ. ខ្ញុំមកពីកំពង់ឈ្មោះសុប្បារកៈ ។

ភិក្ខុ. លោកចេញមកតាំងពីពេលណា ?

ទារុចីរិយៈ. ខ្ញុំព្រះករុណា ចេញមកពីរសៀលម្សិលមិញ ។

ភិក្ខុ. លោកមកពីទីឆ្ងាយ ចូរអង្គុយសិន លាងជើងហើយ លាបដោយប្រេងនេះ និងចូរសម្រាកបន្តិចសិនចុះ លោកនឹងឃើញព្រះសាស្តាក្នុងពេលដែលទ្រង់យាងមក ។

ទារុចីរិយៈ. លោកម្ចាស់ ខ្ញុំព្រះករុណាមិនដឹងជីវិតន្តរាយរបស់ព្រះសាស្តា ឬខ្ញុំព្រះករុណាៗ មិនបានឈប់ មិនបានអង្គុយក្នុងទីណា ដើរមកអស់ចម្ងាយផ្លូវ ១២០ យោជន៍ ត្រឹមតែមួយរាត្រីប៉ុណ្ណោះ ខ្ញុំព្រះករុណាលុះតែឃើញព្រះសាស្តាហើយ ទើបនឹងសម្រាក ។

ពាហិយៈនោះ ពោលដូច្នេះហើយ មានកាពតក់ក្រហល់ក៏ចូលទៅក្រុងសាវត្ថី ឃើញព្រះមានព្រះភាគ ស្តេចយាងបិណ្ឌបាតដោយពុទ្ធសិរី ដែលរកប្រៀបមិនបាន ក៏គិតថា "យូរណាស់ហើយ យើងទើបបានឃើញព្រះសមណ-គោតម" ហើយក៏បន្ទន់ខ្លួនដើរទៅ តាំងពីទីដែលខ្លួនឃើញ ហើយថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋានក្នុងចន្លោះផ្លូវ ចាប់ត្រង់ក.ព្រះបាទទាំងពីរយ៉ាងណែនក្រាបទូលយ៉ាងនេះថា "បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ប្រោសខ្ញុំព្រះអង្គ សូមព្រះសុគត ទ្រង់សម្តែងធម៌ដែលប្រព្រឹត្តទៅដើម្បីជាប្រយោជន៍សុខអស់កាលដ៏យូរ ដល់ខ្ញុំព្រះអង្គ" ។

## ទារុចីរិយៈសម្រេចព្រះអរហត្ត តែនៅជាគ្រហស្ថ

លំដាប់នោះ ព្រះសាស្តាទ្រង់ហាមថា "ពាហិយៈ មិនមែនជាកាលទេ

តថាគតកំពុងត្រាច់តាមចន្លោះផ្លូវដើម្បីបិណ្ឌបាត ។ ពាហិយៈស្តាប់ព្រះពុទ្ធ-តម្រាស់នោះហើយ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាច់ទៅក្នុងសង្សារ មិនធ្លាប់បានអាហារ គឺ ពំនូតបាយឬ? ខ្ញុំព្រះអង្គមិនដឹងជីវិត-ន្តរាយរបស់ព្រះអង្គ ឬរបស់ខ្ញុំព្រះអង្គទេ សូមព្រះអង្គសំដែងធម៌ប្រោសដល់ខ្ញុំព្រះអង្គ” ។ សូម្បីលើកទី ២ ព្រះសាស្តាក៏ទ្រង់ហាមដូចគ្នា ។ បានឮថា ព្រះសាស្តាអង្គនោះ ទ្រង់បានបរិវិតក្កៈយ៉ាងនេះថា “តាំងពីកាលដែលពាហិយៈនេះ ឃើញតថាគតហើយ សរីរៈទាំងអស់ (របស់គេ) ត្រូវបីតិជ្រួតជ្រាបហើយ មិនមានចន្លោះ ក៏អ្នកដែលមានបីតិដ៏មានកម្លាំង សូម្បីស្តាប់ធម៌ហើយ ក៏មិនអាចចាក់ធ្លុះសច្ចធម៌បាន ឲ្យគេឋិតនៅក្នុងឧបេក្ខា គឺ ភាពជាកណ្តាលសិនចុះ សូម្បីសេចក្តីក្រវល់ក្រវាយរបស់គេក៏មានកម្លាំង ព្រោះជាអ្នកដើរផ្លូវមកអស់ចម្ងាយ ១២០ យោជន៍ ត្រឹមតែមួយរាត្រីប៉ុណ្ណោះ ចាំសេចក្តីក្រវល់ក្រវាយរបស់គេស្ងប់ម្ងាប់សិន” ព្រោះដូច្នោះ ទើបព្រះសាស្តាត្រាស់ហាមដល់ពីរលើក កាលត្រូវគាត់អង្វរលើកទី ៣ ក៏ប្រថាប់ឈរត្រង់ចន្លោះផ្លូវនោះឯង ទ្រង់សម្តែងធម៌ដោយន័យជាដើមថា “ពាហិយៈ ព្រោះហេតុនោះ អ្នកគប្បីសិក្សាក្នុងសាសនានេះ យ៉ាងនេះថា កាលរូបដែលអ្នកឃើញហើយ ត្រឹមតែជារូបដែលអ្នកឃើញ” ។ ពាហិយៈនោះកំពុងស្តាប់ធម៌របស់ព្រះសាស្តានោះឯង ក៏ញ៉ាំងអាសវៈទាំងអស់ឲ្យអស់ទៅ សម្រេចអរហត្តព្រមទាំងបដិសម្ភិទា ៤ ក៏ក្នុងខណៈនោះៗ ឯង គាត់ទូលសូមបព្វជ្ជាចំពោះព្រះមានព្រះភាគ កាល

ព្រះមានព្រះភាគត្រាស់សួរថា “បាត្រ និងចីវររបស់អ្នកគ្រប់គ្រាន់ហើយឬ?” ក៏ទូលតបថា “មិនទាន់មានទេព្រះអង្គ” ។ ខណៈនោះ ព្រះសាស្ដាត្រាស់នឹងគេថា “បើដូច្នោះ អ្នកចូរស្វែងរកបាត្រ ចីវរចុះ” ហើយក៏ស្ដេចចៀសចេញទៅ ។ បានឮថា ពាហិយៈនោះ ធ្វើសមណធម៌អស់ពីរម៉ឺនឆ្នាំ គិតថា “ធម្មតាភិក្ខុបានបច្ច័យទាំងឡាយដោយខ្លួនឯងហើយ មិនបាច់ខ្វល់ភិក្ខុដទៃ បរិភោគតែឯងប៉ុណ្ណោះទើបគួរ” ដូច្នេះហើយ មិនបានធ្វើការសង្គ្រោះដោយបាត្រ ឬចីវរដល់ភិក្ខុរូបណាមួយឡើយ ។ ព្រោះហេតុនោះ ព្រះសាស្ដាទ្រង់ជ្រាបថា បាត្រចីវរដែលសម្រេចដោយឫទ្ធិនឹងមិនកើតឡើង ទើបមិនបានប្រទានបព្វជ្ជាដោយភាពជាឯហិភិក្ខុដល់គេ ។ កាលពាហិយៈនោះកំពុងស្វែងរកបាត្រ និងចីវរនោះឯង យក្ខិនីមួយរូប ក្លែងភេទជាមេគោមកវែជត្រូវត្រង់ទ្រូងខាងឆ្វេងស្លាប់ទៅ ។

ព្រះសាស្ដា ស្ដេចយាងបិណ្ឌបាតហើយ កាលស្រេចភត្តកិច្ច ស្ដេចយាងទៅជាមួយភិក្ខុជាច្រើន ទ្រង់ឃើញសរីរៈរបស់ព្រះពាហិយៈដួលក្នុងទីគំនរសម្រាម ទើបត្រាស់នឹងភិក្ខុទាំងឡាយថា “ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរឈរជិតទ្វារផ្ទះមួយកន្លែង ឲ្យគេនាំគ្រែមក ហើយនាំសរីរៈនេះចេញអំពីក្រុង ដុតហើយ ធ្វើស្តូបទុក ។ ភិក្ខុទាំងឡាយក៏បានធ្វើដូច្នេះហើយ លុះធ្វើរួចហើយ ទៅកាន់វិហារចូលគាល់ព្រះសាស្ដា ទូលប្រាប់កិច្ចដែលខ្លួនធ្វើហើយ រួចសួរអភិសម្បរាយភព (បរលោក) របស់ពាហិយៈនោះ ។

## ទារុចីរិយៈជាកំពូលក្នុងផ្នែកខិប្បាភិញ្ញា

លំដាប់នោះ ព្រះមានព្រះភាគត្រាស់ប្រាប់អំពីព្រះពាហិយៈបរិនិព្វាន ដល់ភិក្ខុទាំងនោះ ទ្រង់តាំងទុកក្នុងតំណែងជាឯតទគ្គៈថា "ម្នាលភិក្ខុទាំងឡាយ ពាហិយទារុចីរិយៈ ជាកំពូលលើភិក្ខុទាំងឡាយ ដែលជាសាវករបស់តថាគត អ្នកត្រាស់ដឹងរហ័ស" ។ លំដាប់នោះ ភិក្ខុទាំងឡាយទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់ថា ពាហិយៈសម្រេចអរហត្ត លោកសម្រេចព្រះអរហត្តក្នុងកាលណា?" ។

ព្រះសាស្តា. ភិក្ខុទាំងឡាយ ក្នុងកាលគេស្តាប់ធម៌របស់តថាគត ។

ភិក្ខុ. ព្រះអង្គសម្តែងធម៌ដល់គេ ក្នុងកាលណា ។

ព្រះសាស្តា. កាលតថាគតត្រាច់ទៅបិណ្ឌបាត ឈរក្នុងចន្លោះផ្លូវ បានសម្តែងធម៌ដល់គេ ។

ភិក្ខុ. បពិត្រព្រះអង្គ ធម៌ដែលព្រះអង្គប្រថាប់ឈរក្នុងចន្លោះផ្លូវសម្តែងហើយ មានប្រមាណតិចតួច គាត់ញុំាងគុណវិសេសឲ្យកើត ព្រោះធម៌មានប្រមាណប៉ុណ្ណោះដូចម្តេច ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងភិក្ខុទាំងឡាយនោះថា "ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយកុំប្រមាណក្នុងធម៌របស់តថាគតថា តិច ឬច្រើន ព្រោះថា គាថាសូម្បីមួយពាន់ជាអនេក ដែលមិនអាស្រ័យប្រយោជន៍ មិនប្រសើរ ចំណែកបទនៃគាថាសូម្បីមួយបទ ដែលអាស្រ័យប្រយោជន៍ប្រសើរ

ជាង" ដូច្នេះហើយ កាលទ្រង់បន្តអនុសន្ធិសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

សហស្សមបិ ចេ គាថា  អនត្ថបទសញ្ហិតា
ឯកំ គាថាបទំ សេយ្យោ  យំ សុត្វា ឧបសម្មតិ ។

បើគាថា សូម្បីមួយពាន់ ជាគាថាប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្ដាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ឯកំ គាថាបទំ (បទនៃគាថាមួយ) សេចក្ដីថា សូម្បីគាថាមួយ មានសភាពដូច្នេះថា អប្បមាទោ អមតំបទំ ។បេ។ យថា មតា (សេចក្ដីមិនប្រមាទ ជាផ្លូវអមតៈ ។ល។ ដូចមនុស្សស្លាប់ហើយ) ប្រសើរជាង ។ បទដ៏សេសគប្បីជ្រាបតាមន័យមុននោះឯង ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះពាហិយទារុចីរិយត្ថេរ

# ៣. រឿងព្រះនាងកុណ្ឌលកេសីថេរី

ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធនាងកុណ្ឌលកេសី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច គាថា សតំ ភាសេ** (ជនណាគប្បីពោលគាថាទាំងរយ) ជាដើម ។

ធីតាសេដ្ឋីបានចោរជាស្វាមី

បានឮថា ធីតាសេដ្ឋីម្នាក់ក្នុងក្រុងរាជគ្រឹះ មានអាយុ ១៦ ឆ្នាំ មានរូបល្អ គួរមើល ។ ក៏នារីទាំងឡាយដែលឋិតនៅក្នុងវ័យនោះ រមែងមានការចូលចិត្តក្នុងបុរស ឡេះឡោះក្នុងបុរស ។ គ្រានោះ មាតាបិតាឲ្យធីតានោះនៅក្នុងបន្ទប់ដ៏មានសិរី នៃជាន់លើប្រាសាទ ៧ ជាន់ បានឲ្យទាសីម្នាក់ប៉ុណ្ណោះ នៅចាំបម្រើនាង ។ គ្រានោះ ពួករាជបុរសចាប់កុលបុត្រម្នាក់ ដែលធ្វើចោរកម្ម បានចងដើមដៃទៅក្រោយ វាយដោយខ្សែតី មួង ៤ ខ្សែតីៗ ហើយនាំទៅកាន់ទីពិឃាត ។ ធីតាសេដ្ឋីបានឮសំឡេងមហាជន គិតថា "មានរឿងអ្វីហ្ន៎" ក៏ឈរក្រឡេកមើលពីលើផ្ទៃប្រាសាទ ឃើញចោរនោះហើយ មានចិត្តប្រតិព័ទ្ធ ក្តុលក្តួលអួលណែនក្នុងឱរា ហើយក៏ទៅដេកលើគ្រែ មិនព្រមបរិភោគអាហារ ។ លំដាប់នោះ មាតាបិតាសួរនាងថា "មានរឿងអ្វីកូន?" ។

ធីតាសេដ្ឋី. បើខ្ញុំបានបុរសដែលត្រូវគេចាប់នាំទៅ ដែលថាជាចោរនោះ ខ្ញុំនឹងរស់នៅ បើមិនបាន ជីវិតខ្ញុំនឹងមិនមាន ខ្ញុំនឹងស្លាប់ក្នុងទីនេះឯង ។

មាតា. កូនកុំធ្វើយ៉ាងនេះឡើយ កូននឹងបានស្វាមីដទៃដែលស្មើដោយជាតិ និងភោគៈនឹងយើង ។

ធីតាសេដ្ឋី. ខ្ញុំមិនត្រូវការបុរសដទៃ កាលមិនបានបុរសនេះ នឹងស្លាប់ ។

មាតា. កាលមិនអាចអង្វរកូនស្រីឲ្យព្រមបាន ក៏ប្រាប់ដល់បិតា ។ សូម្បីបិតានោះ ក៏មិនអាចធ្វើឲ្យធីតានោះយល់ព្រមបាន ក៏គិតថា "យើងធ្វើយ៉ាងណានឹងបានហ្ន៎" ហើយបញ្ជូនកណ្ឌៈមួយពាន់ដល់រាជបុរស ដែលកំពុងបណ្តើរចោរនោះទៅ ដោយពាក្យថា "លោកចូរទទួលកណ្ឌៈនេះហើយ ចូរឲ្យបុរសនោះដល់ខ្ញុំ" ។ រាជបុរសនោះទទួលពាក្យហើយ ទទួលយកកហាបណៈ ដោះលែងចោរនោះទៅ ហើយសម្លាប់បុរសដទៃ ក្រាបទូលដល់ព្រះរាជាថា "បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គសម្លាប់ចោរហើយ" ។ ចំណែកសេដ្ឋីនោះ ក៏ប្រគល់ធីតាដល់ចោរនោះ ។ នាងគិតថា "យើងនឹងធ្វើឲ្យស្វាមីត្រេកអរ ទើបតាក់តែងដោយគ្រឿងប្រដាប់ទាំងពួង ចាត់ចែងយាគូជាដើម ដល់ចោរនោះដោយខ្លួនឯងផ្ទាល់ ។ ដោយកន្លងទៅ ២-៣ ថ្ងៃ ចោរគិតថា "ក្នុងកាលណាហ្ន៎ យើងនឹងបានសម្លាប់ស្ត្រីនេះ ហើយកាន់យកគ្រឿងប្រដាប់របស់ស្ត្រីនេះលក់ស៊ីចាយក្នុងរោងសុរាមួយកន្លែង" ។ ចោរនោះគិតថា "ឧបាយនេះ មាន ទើបទៅដេកលើគ្រែ មិនបរិភោគអាហារ" ។ ខណៈនោះ នាងចូលទៅរកចោរនោះ ហើយសួរថា "អ្នកបង អ្នកមានរឿងអ្វី?" ។

ចោរ. នាងដ៏ចម្រើន គ្មានរឿងអ្វីទេ ។

ធីតាសេដ្ឋី. មាតាបិតារបស់ខ្ញុំនឹងនឹងអ្នកឬ ។

ចោរ. នាងដ៏ចម្រើន មិនដឹងទេ ។

ធីតាសេដ្ឋី. បើដូច្នោះ រឿងនេះដូចម្តេច ។

ចោរ. ម្នាលនាងដ៏ចម្រើន កាលថ្ងៃដែលគេចាប់ខ្ញុំទៅនោះ ខ្ញុំបានទទួលពលីកម្មចំពោះទេវតាដែលអាស្រ័យនៅក្នុងសម្រាប់ទម្លាក់ចោរ ទើបបានជីវិតរស់ សូម្បីនាងក៏ខ្ញុំបានដោយអានុភាពរបស់ទេវតានោះដែរ ម្នាលនាងដ៏ចម្រើន ខ្ញុំគិតថា "ខ្ញុំនឹងធ្វើពលីកម្មនោះដល់ទេវតា" ។

ធីតាសេដ្ឋី. អ្នកបងកុំគិតឡើយ ខ្ញុំនឹងធ្វើពលីកម្ម ចូរប្រាប់មក តើត្រូវការអ្វីខ្លះ ។

ចោរ. ត្រូវការមធុបាយាសដែលមានទឹកតិច និងផ្កាឈើ មានលាជជាគម្រប់ ៥ ។

ធីតាសេដ្ឋី. ល្អហើយ អ្នកបង ខ្ញុំនឹងចាត់ចែងឲ្យ ។

ធីតាសេដ្ឋីនោះ ចាត់ចែងពលីកម្មគ្រប់យ៉ាង ហើយពោលថា មកចុះអ្នកបង យើងនឹងទៅ ។

ចោរ. ម្នាលនាងដ៏ចម្រើន បើដូច្នោះ នាងចូរឲ្យពពួកញាតិរបស់នាងត្រឡប់ទៅវិញ កាន់យកតែសំពត់ និងគ្រឿងប្រដាប់ដែលមានតម្លៃច្រើន ហើយប្រដាប់តាក់តែងខ្លួន យើងនឹងសើចលេង ដើរទៅយ៉ាងសប្បាយ ។

នាងក៏បានធ្វើយ៉ាងនោះ ។ ខណៈនោះ ក្នុងវេលាដល់ជើងភ្នំ ចោរនោះ

ពោលនឹងនាងថា "ម្នាលនាងដ៏ចម្រើន ខាងមុខអំពីនេះ យើងនឹងទៅតែពីរនាក់ ចូរនាងបញ្ឈប់ជនដ៏សេស ព្រមទាំងយាន លើកភាជនៈពលីកម្មទៅដោយខ្លួនឯង ។ នាងបានធ្វើដូច្នោះហើយ ចោរនាំនាងឡើងកាន់ភ្នំទម្លាក់ចោរ ។

ក៏មនុស្សទាំងឡាយ ឡើងទៅតាមម្ខាងនៃភ្នំនោះ ម្ខាងទៀតជាប្រាំងដាច់ មនុស្សទាំងឡាយឈរលើកំពូលភ្នំហើយ រមែងទម្លាក់ចោរទាំងឡាយតាមម្ខាងនោះ ចោរទាំងឡាយនោះ ក៏ដាច់ជាកំណាត់តូច-ធំ ធ្លាក់ចុះទៅលើផែនដី ព្រោះហេតុដូច្នោះ ទើបគេហៅភ្នំនោះថា "ភ្នំទម្លាក់ចោរ" ។ នាងឈរលើកំពូលភ្នំនោះហើយ ពោលថា "អ្នកបង បងចូរធ្វើពលីកម្មចុះ ។ ចោរនោះបាននៅស្ងៀម កាលនាងសួរទៀតថា "អ្នកបង ហេតុអ្វីទើបនៅស្ងៀម" ទើបប្រាប់នាងថា "ខ្ញុំមិនត្រូវការពលីកម្មទេ តែខ្ញុំបញ្ឆោតនាំនាងមក" ។

ធីតាសេដ្ឋី. ព្រោះហេតុអ្វី អ្នកបង ។

ចោរ. ព្រោះយើងត្រូវការសម្លាប់នាង ហើយកាន់យកគ្រឿងប្រដាប់របស់នាងចេញទៅ ។

នាងត្រូវមរណភ័យគ្របសង្កត់ហើយ ក៏ពោលថា "អ្នកបង ខ្ញុំព្រមទាំងគ្រឿងប្រដាប់របស់ខ្ញុំ ជារបស់អ្នកបងហើយ ហេតុអ្វីទើបពោលយ៉ាងនេះ?" ចោរនោះ សូម្បីនាងអង្វររឿយៗ ថា "សូមកុំធ្វើយ៉ាងនេះ" ក៏នៅតែពោលថា "យើងនឹងសម្លាប់នាងឲ្យបាន" ។ នាងពោលថា "បើដូច្នោះ អ្នកបងនឹងត្រូវការអ្វី? ដោយការស្លាប់របស់ខ្ញុំ អ្នកបងកាន់យកគ្រឿងប្រដាប់ទាំងនេះហើយ

ឲ្យជីវិតដល់ខ្ញុំចុះ ចាប់តាំងពីពេលនេះ អ្នកបងចូរចាំខ្ញុំថា ស្លាប់ហើយ ឬថា ខ្ញុំនឹងជាទាសីរបស់អ្នកបង ខ្ញុំនឹងធ្វើហត្ថកម្ម ហើយបានពោលគាថានេះថា ៖

សង្វារមាសទាំងនេះ សុទ្ធតែសម្រេចហើយដោយ
កែវពិទូរ្យ អ្នកដ៏ចម្រើនចូរកាន់យកទាំងអស់ និង
ចូរប្រកាសថា នាងខ្ញុំជាទាសីចុះ ។

ចោរស្តាប់ពាក្យនោះហើយ ពោលថា "បើខ្ញុំធ្វើដូច្នោះ នាងទៅហើយក៏នឹងប្រាប់ដល់មាតាបិតា ខ្ញុំនឹងសម្លាប់ឲ្យបាន នាងកុំយំសោកធ្វើអ្វី" ហើយពោលគាថានេះថា ៖

នាងកុំខ្សឹកខ្សួលឡើយ ចូរវេចកណ្ឌៈឲ្យឆាប់ ជីវិតរបស់
នាងមិនមានទេ ខ្ញុំនឹងកាន់យកកណ្ឌៈទាំងអស់ ។

## ធីតាសេដ្ឋីប្រាជ្ញចោរឱ្យធ្លាក់ស្លាប់

នាងគិតថា "ឱ! កម្មនេះធ្ងន់ហ្ន៎ ឈ្មោះថា បញ្ញា ធម្មតា មិនបានសាងមកដើម្បីចំអិនស៊ីទេ ដែលពិត គឺ សាងមកដើម្បីពិចារណា យើងនឹងដឹងកិច្ចដែលគួរធ្វើដល់គេ" ។

លំដាប់នោះ នាងពោលនឹងចោរនោះថា "អ្នកបង កាលអ្នកបងត្រូវគេចាប់បណ្តើរទៅព្រោះអ្នកបងជាចោរនោះ ខ្ញុំបានប្រាប់ដល់មាតាបិតា លោកទាំងពីរនោះលះទ្រព្យមួយពាន់ ឲ្យនាំលោកមកនៅក្នុងផ្ទះ តាំងពីពេលនោះមក ខ្ញុំបានបម្រើអ្នក ថ្ងៃនេះ អ្នកចូរឲ្យខ្ញុំ ឃើញអ្នកឲ្យបានច្បាស់ ដើម្បីបាន

ថ្វាយបង្គំ ។ ចោរនោះពោលថា "ល្អហើយនាង នាងចូរមើលខ្ញុំឲ្យបានច្បាស់ ហើយថ្វាយបង្គំចុះ" ហើយក៏ឈរនៅលើកំពូលភ្នំនោះ ។ ខណៈនោះ នាងធ្វើប្រទក្សិណ ៣ ដង ថ្វាយបង្គំចោរនោះក្នុងទី ៤ កន្លែង ហើយពោលថា "អ្នកបង នេះជាការឃើញចុងក្រោយរបស់ខ្ញុំ ឥឡូវនេះ ការដែលអ្នកឃើញខ្ញុំ ឬការដែលខ្ញុំឃើញអ្នក មិនមានទៀតទេ" ហើយស្រវាឱបខាងមុខខាងក្រោយរួចបានឈរពីក្រោយ យកដៃម្ខាងចាប់ចោរដែលជាអ្នកប្រមាទឈរលើកំពូលភ្នំត្រង់.ក យកដៃម្ខាងទៀតចាប់ត្រង់ក្លៀកខាងក្រោយ រុញទម្លាក់ចុះទៅអំពីភ្នំ ។ ចោរនោះត្រូវខ្ទាំងខ្ទប់នឹងផ្ទៃនៃភ្នំ ដាច់ជាកំណាត់តូច-ធំ ធ្លាក់ចុះលើផែនដី ។ ទេវតាដែលអាស្រ័យលើកំពូលភ្នំទម្លាក់ចោរ ឃើញអំពើរបស់ជនទាំងពីរនោះហើយ ក៏ឲ្យសាធុការដល់ស្ត្រីនោះ ហើយពោលគាថានេះថា ៖

**បុរសនោះ ជាបណ្ឌិតក្នុងទីទាំងពួង ក៏មិនមែន សូម្បីស្ត្រី**
**អ្នកមានបញ្ញាយល់ច្បាស់ ក៏ជាបណ្ឌិតបានក្នុងទីនោះៗ ។**

ធីតាសេដ្ឋីនោះ លុះរុញទម្លាក់ចោរទៅក្នុងជ្រោះហើយ គិតថា "បើយើងទៅផ្ទះ មាតាបិតានឹងសួរថា ស្វាមីរបស់នាងទៅណា? បើយើងត្រូវគាត់សួរយ៉ាងនេះ ហើយឆ្លើយថា ខ្ញុំសម្លាប់ហើយ លោកនឹងចាក់យើងដោយលំពែងគឺ មាត់ថា នែនាងក្បាលរឹង យើងឲ្យទ្រព្យមួយពាន់ ឲ្យនាំស្វាមីមក ឥឡូវនេះ នាងសម្លាប់គេហើយ សូម្បីកាលយើងប្រាប់ថា គេប្រាថ្នានឹងសម្លាប់ខ្ញុំដើម្បីត្រូវការគ្រឿងប្រដាប់ លោកក៏នឹងមិនជឿ កុំឡើយដោយផ្ទះរបស់យើង"

ដូច្នេះហើយ ទម្លាក់គ្រឿងប្រដាប់ទុកក្នុងទីនោះៗ ឯង ចូលទៅកាន់ព្រៃ ត្រាច់ទៅដោយលំដាប់ ក៏ដល់អាស្រមរបស់បរិព្វាជកមួយកន្លែង ថ្វាយបង្គំហើយពោលថា “លោកដ៏ចម្រើន សូមលោកទាំងឡាយ ឲ្យបព្វជ្ជាដល់ខ្ញុំក្នុងសម្នាក់របស់ពួកលោកផង ។ លំដាប់នោះ បរិព្វាជកទាំងឡាយឲ្យនាងបានបព្វជ្ជា ។

ធីតាសេដ្ឋីបួសជាបរិព្វាជិកា

ធីតាសេដ្ឋីនោះ ពេលបួសហើយ សួរថា “លោកដ៏ចម្រើន អ្វីជាប្រយោជន៍ដ៏ឧត្តមនៃបព្វជ្ជារបស់ពួកលោក?” ។

បរិព្វាជក. នាងដ៏ចម្រើន បុគ្គលធ្វើបរិកម្មក្នុងកសិណ ១០ ហើយ គប្បីញ៉ាំងឈានឲ្យកើតឡើងខ្លះ គប្បីរៀនវាទៈមួយពាន់ខ្លះ នេះជាប្រយោជន៍ដ៏ឧត្តមនៃបព្វជ្ជារបស់ពួកយើង ។

ធីតាសេដ្ឋី. នាងខ្ញុំមិនអាចញ៉ាំងឈានឲ្យកើតឡើងបានទេ តែនឹងរៀនវាទៈមួយពាន់ លោកម្ចាស់ ។

លំដាប់នោះ បរិព្វាជកទាំងនោះ បានឲ្យនាងរៀនវាទៈ ១.០០០ ហើយពោលថា “សិល្បៈ នាងក៏រៀនហើយ ឥឡូវនេះ នាងចូរត្រាច់ទៅលើផ្ទៃជម្ពូទ្វីប តើនរណាអាចពោលវាទៈនឹងខ្លួនបាន ហើយឲ្យមែកព្រីងដល់នាង បើនរណាៗជាគ្រហស្ថ អាចពោលបញ្ហាជាមួយនឹងនាងបាន នាងចូរធ្វើជាបាទបរិចារិកា (ប្រពន្ធ) របស់អ្នកនោះចុះ, បើជាបព្វជិត នាងចូរបព្វជ្ជាក្នុងសម្នាក់អ្នកនោះចុះ” ។ នាងមានឈ្មោះថា ជម្ពុបរិព្វាជិកា តាមនាម (ឈើ) ចេញចាកទីនោះ

ហើយ ត្រាច់សួរបញ្ហាចំពោះអ្នកដែលខ្លួនឃើញហើយ ។ មនុស្សដែលឈ្មោះថា អាចនឹងពោលបញ្ហាជាមួយនឹងនាង មិនមានឡើយ ។ មនុស្សទាំងឡាយគ្រាន់តែឮថា ជម្ពុបរិព្វាជិកាមកទីនេះ រមែងរត់ចេញ ។ នាងចូលទៅកាន់ស្រុក ឬនិគម ដើម្បីភិក្ខា ធ្វើគំនរខ្សាច់ទុកជិតទ្វារនៃស្រុក ទុកមែកព្រីងលើគំនរខ្សាច់នោះ ពោលថា "អ្នកណាអាចពោលជាមួយនឹងយើង ចូរជាន់មែកព្រីងនេះ" រួចក៏ចូលទៅកាន់ស្រុក ។ នរណាៗ ឈ្មោះថា អាចនឹងចូលទៅកាន់ទីនោះមិនមានឡើយ ។ សូម្បីនាង រមែងកាន់យកមែកព្រីងដទៃ កាលមែកព្រីងចាស់ស្វិតស្រពោន ត្រាច់ទៅដោយទំនងនេះ រហូតដល់ក្រុងសាវត្ថី ដាក់មែកព្រីងជិតទ្វារស្រុក បាននិយាយដោយន័យដែលពោលមកហើយនោះឯង ហើយចូលទៅដើម្បីភិក្ខា ។ ក្មេងជាច្រើនបានទៅឈរចោមរោមមែកព្រីង ។

ក្នុងកាលនោះ ព្រះសារីបុត្តត្ថេរ ត្រាច់ទៅដើម្បីបិណ្ឌបាត ធ្វើភត្តកិច្ចហើយ ចេញទៅអំពីក្រុង ឃើញក្មេងទាំងនោះ ឈរចោមរោមមែកព្រីង ទើបសួរថា "នេះអ្វី" ក្មេងទាំងនោះ ក៏បានប្រាប់រឿងនោះដល់ព្រះថេរៈ ។ ព្រះថេរៈពោលថា "នែ! ក្មេងទាំងឡាយ បើដូច្នោះ ពួកអ្នកចូរជាន់មែកព្រីងនេះ" ។

ពួកក្មេង. ពួកខ្ញុំខ្លាច លោកម្ចាស់ ។

ព្រះថេរៈ. យើងនឹងពោលបញ្ហា ពួកឯងចូរជាន់ចុះ ។

ក្មេងទាំងនោះ ក៏មានសេចក្តីក្លាហាន ដោយពាក្យរបស់ព្រះថេរៈ ក៏ធ្វើដូច្នោះ ស្រែកបាចធូលីឡើង ។ នាងបរិព្វាជិកាមកហើយ ជេរក្មេងទាំងនោះ

ហើយពោលថា "ហេតុអ្វីពួកឯងនាំគ្នាជាន់មែកព្រីងយើង កិច្ចដោយបញ្ហារបស់យើងជាមួយនឹងពួកឯង មិនមានទេ" ។ ពួកក្មេងឆ្លើយថា "ព្រះថេរៈឲ្យពួកខ្ញុំជាន់" ។

នាងបរិព្វាជិកា. លោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ឲ្យពួកក្មេងៗ ជាន់មែកព្រីងរបស់នាងខ្ញុំឬ ។

ព្រះថេរៈ. ម្នាលប្អូនស្រី ពិតមែន ។

នាងបរិព្វាជិកា. បើដូច្នោះ សូមលោកម្ចាស់ពោលបញ្ហាជាមួយនាងខ្ញុំ ។

ព្រះថេរៈ. ល្អហើយ អាត្មានឹងពោល ។

នាងបរិព្វាជិកានោះ បានទៅកាន់សម្នាក់របស់ព្រះថេរៈ ដើម្បីសួរបញ្ហាក្នុងវេលារសៀល ។ អ្នកនគរទាំងអស់ ភ្ញាក់ផ្អើលថា "ពួកយើងនឹងស្តាប់ពាក្យរបស់បណ្ឌិតទាំងពីរ ។ ពួកអ្នកនគរ ទៅជាមួយនាងបរិព្វាជិកានោះឯង ថ្វាយបង្គំព្រះថេរៈហើយ អង្គុយក្នុងទីដ៏សមគួរ ។

នាងបរិព្វាជិកាពោលនឹងព្រះថេរៈថា "លោកម្ចាស់ដ៏ចម្រើន នាងខ្ញុំនឹងសួរបញ្ហាចំពោះលោកម្ចាស់" ។ ព្រះថេរៈពោលថា "សួរមកចុះ ប្អូនស្រី" ។ នាងបានសួរវាទៈមួយពាន់ ។ ព្រះថេរៈ បានដោះស្រាយបញ្ហាដែលនាងសួរហើយៗ ។

លំដាប់នោះ ព្រះថេរៈពោលនឹងនាងថា "បញ្ហារបស់នាងមានតែប៉ុណ្ណោះ

ឬនៅមានបញ្ហាដទៃទៀត? ។

នាងបរិព្វាជិកា. មានប៉ុណ្ណេះឯង លោកម្ចាស់ ។

ព្រះថេរ:. នាងសួរបញ្ហាជាច្រើន ចំណែកអាត្មានឹងសួរបញ្ហាមួយ នាងនឹងឆ្លើយបាន ឬមិនបាន? ។

នាងបរិព្វាជិកា. កាលនាងខ្ញុំដឹងនឹងឆ្លើយ សូមសួរមកចុះ លោកម្ចាស់ ។

ព្រះថេរ:សួរបញ្ហាថា "អ្វី ឈ្មោះថាមួយ" នាងបរិព្វាជិកានោះមិនដឹងថា បញ្ហានេះ គួរឆ្លើយយ៉ាងនេះ ទើបសួរថា "នុ៎ះឈ្មោះថាអ្វី លោកម្ចាស់" ។

ព្រះថេរ:. ឈ្មោះពុទ្ធមន្ត ប្អូនស្រី ។

នាងបរិព្វាជិកា. បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ឲ្យនូវពុទ្ធមន្តនោះដល់នាងខ្ញុំខ្លះ ។

ព្រះថេរ:. បើនាងនឹងបួសដូចអាត្មាៗ នឹងឲ្យ ។

បើដូច្នោះ សូមលោកម្ចាស់ ឲ្យបព្វជ្ជាដល់នាងខ្ញុំចុះ ។

ព្រះថេរ: បានប្រាប់ដល់នាងភិក្ខុនីទាំងឡាយឲ្យបព្វជ្ជា ។

នាង គ្រាបានបព្វជ្ជាឧបសម្បទាហើយ មានឈ្មោះថា កុណ្ឌលកេសី សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ដោយកាលកន្លងទៅ ២-៣ ថ្ងៃប៉ុណ្ណោះ ។

## ឈ្នះកិលេសប្រសើរ

ភិក្ខុទាំងឡាយ សន្ទនាគ្នាក្នុងសាលាធម្មសភាថា "ការស្តាប់ធម៌របស់

នាងកុណ្ឌលកេសីថេរីមិនច្រើនទេ កិច្ចនៃបព្វជិតរបស់នាងក៏បានដល់ទីបំផុត ហើយ បានឮថា នាងធ្វើមហាសង្គ្រាមជាមួយចោរម្នាក់ ឈ្នះហើយទើបមក” ។

ព្រះសាស្ដា ស្ដេចយាងមកហើយ ត្រាស់សួរថា “ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកសន្ទនាគ្នាដោយពាក្យអ្វី” កាលភិក្ខុទាំងឡាយនោះក្រាបទូលថា “ដោយពាក្យឈ្មោះនេះ” ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ កុំប្រមាណដល់ធម៌ដែលតថាគតសម្ដែងហើយថា តិច ឬច្រើន បទដែលមិនជាប្រយោជន៍សូម្បីមួយពាន់ មិនប្រសើរ ចំណែកបទនៃធម៌ សូម្បីតែមួយ រមែងប្រសើរដោយពិត ម្យ៉ាងទៀត កាលបុគ្គលឈ្នះចោរដ៏សេស មិនឈ្មោះថា ជាការឈ្នះទេ ចំណែកបុគ្គលអ្នកឈ្នះចោរ គឺ កិលេសដែលប្រព្រឹត្តទៅខាងក្នុងនោះឯង ទើបឈ្មោះថា ជាការឈ្នះ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងព្រះធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យោ ច គាថា សតំ ភាសេ អនត្ថបទសញ្ហិតា<br>
ឯកំ ធម្មបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។<br>
យោ សហស្សំ សហស្សេន សង្គាមេ មានុសេ ជិនេ<br>
ឯកញ្ច ជេយ្យមត្តានំ ស វេ សង្គាមជុត្តមោ ។

អ្នកណា គប្បីពោលគាថាមួយរយ ជាគាថាប្រកបដោយបទ<br>
ឥតប្រយោជន៍ គាថាដែលអ្នកនោះពោលហើយ ពុំប្រសើរ<br>
ឡើយ អ្នកណាស្ដាប់បទនៃធម៌ហើយ រមែងស្ងប់រម្ងាប់បាន

បទនៃធម៌នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

អ្នកណា គប្បីឈ្នះពួកមនុស្សក្នុងសង្គ្រាម អស់ ១ ពាន់ៗ ដង

គឺ មួយលាន ចំណែកអ្នកណាឈ្នះខ្លួនឯងម្នាក់ឯងបាន អ្នកនោះ

ឈ្មោះថា ជាមនុស្សខ្ពង់ខ្ពស់ជាងអ្នកដែលឈ្នះ ក្នុងសង្គ្រាម

នោះ ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **គាថា សតំ** (គាថាទាំងរយ) សេចក្ដីថា ក៏បុគ្គលណាគប្បីពោលគាថាកំណត់ដោយពាន់ គឺ ជាច្រើន ។ បទថា **អនត្ថ-បទសញ្ហិតា** (មិនប្រកបដោយបទមានប្រយោជន៍) សេចក្ដីថា ប្រកបដោយបទទាំងឡាយដែលមិនមានប្រយោជន៍ ដោយអំណាចនៃការពណ៌នាអាកាសជាដើម ។

បទដែលបដិសំយុត្តដោយធម៌ មានខន្ធជាដើម ដែលសម្រេចប្រយោជន៍ ឈ្មោះថា **ធម្មបទំ** (បទធម៌) ។ បណ្ដាបទធម៌ទាំង ៤ ដែលព្រះសាស្ដាត្រាស់ទុកយ៉ាងនេះថា "ម្នាលបរិព្វាជកទាំងឡាយ បទធម៌ ៤ ទាំងនេះ បទធម៌ ៤ គឺ អ្វីខ្លះ ម្នាលបរិព្វាជកទាំងឡាយ បទធម៌ គឺ អនភិជ្ឈា បទធម៌ គឺ អព្យាបាទ បទធម៌ គឺ សម្មាសតិ បទធម៌ គឺ សម្មាសមាធិ បទធម៌សូម្បីតែមួយបទប្រសើរជាង (គថាទាំងរយ)" ។

បទថា **យោ សហស្សំ សហស្សេន** (អ្នកណាគប្បីឈ្នះមនុស្សមួយ

ពាន់គុណនឹងមួយពាន់) សេចក្ដីថា អ្នកណា មិនថាជាអ្នកច្បាំងក្នុងសង្គ្រាម គប្បីឈ្នះមនុស្សមួយពាន់គុណដោយមួយពាន់ ក្នុងសង្គ្រាមម្ដង បានដល់ ឈ្នះមនុស្សមួយលានក្នុងសង្គ្រាម ហើយនាំជ័យជំនះមក សូម្បីអ្នកនេះ ក៏មិនឈ្មោះថា ជាកំពូលនៃជនទាំងឡាយ អ្នកឈ្នះក្នុងសង្គ្រាម ។

បទថា ឯកញ្ច ជេយ្យមត្តានំ (ឈ្នះខ្លួនឯងតែម្នាក់) សេចក្ដីថា ចំណែកអ្នកណាពិចារណាកម្មដ្ឋាន ដែលប្រព្រឹត្តទៅក្នុងខាងក្នុង ក្នុងទីសម្រាកពេលយប់ និងពេលថ្ងៃ ហើយឈ្នះខ្លួនឯង ដោយការឈ្នះកិលេស មានលោភៈជាដើម របស់ខ្លួនបាន ។

បទថា ស វេ សង្គាមជុត្តមោ (អ្នកនោះឯងជាកំពូលនៃអ្នកឈ្នះក្នុងសង្គ្រាម) សេចក្ដីថា អ្នកនោះឈ្មោះថា ជាកំពូល គឺ ប្រសើរជាងជនទាំងឡាយអ្នកឈ្នះក្នុងសង្គ្រាម បានដល់ ជាអ្នកឆ្នើមក្នុងសង្គ្រាម ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ជនជាច្រើននាក់បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះនាងកុណ្ឌលកេសីថេរី

# ៤. រឿងព្រះអនត្ថបុច្ឆកព្រាហ្មណ៍

*ព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធអនត្ថបុច្ឆក-ព្រាហ្មណ៍ ត្រាស់ព្រះធម្មទេសនានេះថា **អត្តា ហវេ (ខ្លួននោះឯង)** ជាដើម ។*

សេចក្ដីវិនាសរមែងមានដល់អ្នកប្រព្រឹត្តកម្ម ៦ យ៉ាង

*បានឮថា ព្រាហ្មណ៍នោះគិតថា "ព្រះសម្មាសម្ពុទ្ធ ទ្រង់ជ្រាបវត្ថុដែលជាប្រយោជន៍តែម្យ៉ាង ឬក៏ទ្រង់ជ្រាបសូម្បីវត្ថុដែលមិនមែនជាប្រយោជន៍ដែរ យើងនឹងទូលសួរព្រះអង្គ" ដូច្នេះហើយ ទើបគាត់ចូលទៅគាល់ព្រះសាស្តា ទូលសួរថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គទ្រង់ជ្រាបវត្ថុដែលជាប្រយោជន៍ប៉ុណ្ណោះ ប្រហែលទ្រង់មិនជ្រាបវត្ថុដែលមិនមែនជាប្រយោជន៍ទេដឹង" ។*

*ព្រះសាស្តា. ព្រាហ្មណ៍! តថាគតដឹងទាំងវត្ថុជាប្រយោជន៍ ទាំងវត្ថុមិនជាប្រយោជន៍ ។*

*ព្រាហ្មណ៍. បើដូច្នោះ សូមព្រះអង្គត្រាស់ប្រាប់វត្ថុ ដែលមិនមែនជាប្រយោជន៍ ដល់ខ្ញុំព្រះអង្គ ។*

*លំដាប់នោះ ព្រះសាស្តាត្រាស់ព្រះគាថានេះដល់ព្រាហ្មណ៍នោះថា ៖*

*ការដេកដល់ថ្ងៃរះ សេចក្ដីខ្ជិលច្រអូស ការកាច ការដេក*
*អស់កាលដ៏វែង ការដើរផ្លូវឆ្ងាយរបស់បុគ្គលតែម្នាក់ឯង*
*ការប្រព្រឹត្តកន្លងកិរិយារបស់អ្នកដទៃ ម្នាលព្រាហ្មណ៍ អ្នក*

ចូរសេពកម្ម ៦ យ៉ាងនេះចុះ វត្ថុដែលមិនជាប្រយោជន៍

(សេចក្តីវិនាស) នឹងមានដល់អ្នក ។

ព្រាហ្មណ៍ស្តាប់ព្រះពុទ្ធតម្រាស់នោះហើយ បានធ្វើសាធុការថា "ល្អ ហើយៗ" ទ្រង់ជាអាចារ្យនៃគណៈ ទ្រង់ជាធំក្នុងគណៈ មានតែព្រះអង្គប៉ុណ្ណោះ រមែងទ្រង់ជ្រាបទាំងរឿងដែលជាប្រយោជន៍ ទាំងរឿងដែលមិនជាប្រយោជន៍ ។

ព្រះសាស្តា. យ៉ាងហ្នឹងហើយព្រាហ្មណ៍ ដែលឈ្មោះថា អ្នកដឹងវត្ថុ ដែលជាប្រយោជន៍ និងវត្ថុដែលមិនជាប្រយោជន៍ ប្រាកដស្មើដោយតថាគត មិនមានទេ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ពិចារណាមើលអធ្យាស្រ័យរបស់ ព្រាហ្មណ៍នោះហើយ ទើបត្រាស់សួរថា "ព្រាហ្មណ៍អ្នកចិញ្ចឹមជីវិតដោយការ-ងារអ្វី" ។

ព្រាហ្មណ៍. បពិត្រព្រះគោតមដ៏ចម្រើន ដោយការងារ គឺ លេងបាស្កា (ល្បែងក្តាល់) ។

ព្រះសាស្តា. ចុះអ្នកឈ្នះ ឬចាញ់ ។

ឈ្នះខ្លួនឯងជាការឈ្នះដ៏ប្រសើរ

កាលព្រាហ្មណ៍នោះទូលថា "ឈ្នះខ្លះ ចាញ់ខ្លះ" ដូច្នេះហើយ ទើបព្រះ សាស្តាត្រាស់ថា "ម្នាលព្រាហ្មណ៍ ទុំះនៅមានប្រមាណតិច ឈ្មោះថា ការឈ្នះ របស់បុគ្គលអ្នកឈ្នះអ្នកដទៃ មិនប្រសើរ ចំណែកអ្នកណាឈ្នះខ្លួនឯងបាន ដោយការឈ្នះកិលេស ការឈ្នះរបស់អ្នកនោះ ប្រសើរ ព្រោះថា នរណាៗ

មិនអាចធ្វើការឈ្នះនោះឲ្យត្រឡប់ចាញ់បាន" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថាទាំងនេះថា ៖

អត្តា ហវេ ជិតំ សេយ្យោ យា ចាយំ ឥតរា បជា
អត្តទន្តស្ស បោសស្ស និច្ចំ សញ្ញតចារិនោ
នេវ ទេវោ ន គន្ធព្វោ ន មារោ សហ ព្រហ្មុនា
ជិតំ អបជិតំ កយិរា តថារូបស្ស ជន្តុនោ ។

ខ្លួនឯងដែលឈ្នះហើយ ប្រសើរជាង ចំណែកពួកសត្វក្រៅពីនេះ ដែលគេឈ្នះហើយ មិនប្រសើរឡើយ កាលបើបុរសមានខ្លួនទូន្មានហើយ ជាអ្នកប្រព្រឹត្តសង្រួមជានិច្ច ទេវតា គន្ធព្វ មារ ព្រមទាំងព្រហ្ម មិនគប្បីធ្វើនូវជំនះ របស់សត្វមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់វិញបានឡើយ ។

អធិប្បាយគាថា

ក្នុងព្រះគាថានោះ ស័ព្ទថា ហវេ ជានិបាត ។

ស័ព្ទថា ជិតំ ជាលិង្គវិបល្លាស សេចក្តីថា ខ្លួនដែលបុគ្គលឈ្នះហើយ ដោយការឈ្នះកិលេសរបស់ខ្លួន ប្រសើរ ។

បទថា យា ចាយំ ឥតរា បជា សេចក្តីថា ចំណែកពួកសត្វនេះណា គឺ ដ៏សេស គប្បីជាអ្នកដែលគេឈ្នះ ដោយការលេងភ្នាល់ក្តី ដោយការឆបោកទ្រព្យក្តី ដោយការគ្រប់សង្កត់ពលក្នុងសង្គ្រាមក្តី ការឈ្នះដែលបុគ្គលអ្នកឈ្នះ

ពួកសត្វនោះ ឈ្នះហើយ មិនប្រសើរ ។

សួរថា ព្រោះហេតុអ្វី ការឈ្នះនោះប៉ុណ្ណោះ ប្រសើរ ការឈ្នះនេះមិនប្រសើរ?

ឆ្លើយថា ព្រោះកាលបុគ្គលទូន្មានខ្លួនហើយ ។បេ។ របស់សត្វដែលមានសភាពដូច្នោះ ឲ្យត្រឡប់ចាញ់មិនបាន ។

ព្រះសាស្ដាត្រាស់ពាក្យនេះទុកថា "ពិតហើយ ព្រោះហេតុដែលបុគ្គលនេះឯង ឈ្មោះថា ជាអ្នកទូន្មានខ្លួនហើយ ព្រោះជាអ្នកប្រាសចាកកិលេសដូច្នោះ ទេវតាក្ដី គន្ធព្វក្ដី ឬមារ ព្រមទាំងព្រហ្ម សូម្បីព្យាយាមថា យើងនឹងធ្វើការឈ្នះរបស់អ្នកនោះ ឲ្យត្រឡប់ចាញ់វិញ នឹងធ្វើកិលេសទាំងឡាយដែលគេលះបានដោយមគ្គភាវនាឲ្យកើតទៀត ក៏មិនអាចឡើយ ដើម្បីនឹងធ្វើ (ការឈ្នះ) របស់សត្វបែបនោះ គឺ អ្នកសង្រួមហើយ ដោយការសង្រួមផ្លូវកាយជាដើមទាំងនេះឲ្យត្រឡប់ចាញ់ ដូចអ្នកចាញ់ដោយទ្រព្យជាដើម ឲ្យទៅជាពួកដទៃ ឈ្នះអ្នកដែលមនុស្សក្រៅអំពីនេះឈ្នះហើយ គប្បីធ្វើឲ្យត្រឡប់ជាចាញ់ទៀត ដូច្នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយមានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងអនត្ថបុច្ឆកព្រាហ្មណ៍

# ៥. រឿងព្រាហ្មណ៍ជាឪពុកមារបស់ព្រះសារីបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធឪពុកមា របស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា មាសេ មាសេ (រាល់ៗ ខែ) ជាដើម ។*

ព្រះថេរៈនាំឪពុកមានៅគាល់ព្រះសាស្តា

*បានស្តាប់មកថា ព្រះថេរៈទៅកាន់សម្នាក់របស់ព្រាហ្មណ៍ ហើយសួរថា "ព្រាហ្មណ៍ លោកបានធ្វើកុសលអ្វីៗ ខ្លះដែរឬទេ"*

*ព្រាហ្មណ៍. ធ្វើ លោកម្ចាស់ ។*

*ព្រះថេរៈ. ធ្វើកុសលអ្វី ។*

*ព្រាហ្មណ៍. ខ្ញុំព្រះករុណាបានឲ្យទាន ដោយការបរិច្ចាគទ្រព្យមួយពាន់ រាល់ៗ ខែ ។*

*ព្រះថេរៈ. ឲ្យដល់អ្នកណា ។*

*ព្រាហ្មណ៍. ឲ្យដល់ពួកនិគ្រន្ថ លោកម្ចាស់ ។*

*ព្រះថេរៈ. ប្រាថ្នាអ្វី ។*

*ព្រាហ្មណ៍. ព្រហ្មលោក លោកម្ចាស់ ។*

*ព្រះថេរៈ. ក៏នេះ ជាផ្លូវនៃព្រហ្មលោកឬ ។*

ព្រាហ្មណ៍. យ៉ាងនោះហើយ លោកម្ចាស់ ។

ព្រះថេរៈ. អ្នកណា ពោលយ៉ាងនេះ ?

ព្រាហ្មណ៍. ពួកអាចារ្យរបស់ខ្ញុំពោល លោកម្ចាស់ ។

ព្រះថេរៈពោលថា "លោកមិនដឹងផ្លូវនៃព្រហ្មលោកទេ ទាំងពួកអាចារ្យរបស់លោកក៏មិនដឹងដែរ ព្រះសាស្តាមួយអង្គប៉ុណ្ណោះ ទ្រង់ទើបដឹង មកចុះព្រាហ្មណ៍ អាត្មានឹងទូលអារាធនា ឲ្យព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោកដល់លោក" ដូច្នេះហើយ ក៏នាំព្រាហ្មណ៍នោះ ទៅកាន់សម្នាក់របស់ព្រះសាស្តាក្រាបទូលរឿងនោះថា "បពិត្រព្រះអង្គដ៏ចម្រើន ព្រាហ្មណ៍នេះ ពោលយ៉ាងនេះ" ហើយក្រាបទូលថា "សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្មលោក ដល់ព្រាហ្មណ៍នោះ" ។

## ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសដល់ព្រាហ្មណ៍

ព្រះសាស្តាត្រាស់សួរថា "ម្នាលព្រាហ្មណ៍ បានឮថា យ៉ាងនោះឬ?" កាលព្រាហ្មណ៍នោះទូលថា "ព្រះករុណា ព្រះគោតមដ៏ចម្រើន" ទើបត្រាស់ថា "ការក្រឡេកមើលសាវករបស់តថាគត ដោយចិត្តដែលជ្រះថ្លាត្រឹមតែមួយភ្លែត ឬការថ្វាយអាហារវត្ថុត្រឹមតែកិច្ចាមួយវែក ក៏មានផលច្រើនជាងទានដែលអ្នកឲ្យយ៉ាងនោះ សូម្បីអស់មួយរយឆ្នាំ" កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

*មាសេ មាសេ សហស្សេន យោ យជេថ សតំ សមំ*

*ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ*
*សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។*

*អ្នកណា បូជា (លោកិយមហាជន) ដោយទ្រព្យមួយ*
*ពាន់រាល់ ៗ ខែ អស់មួយរយឆ្នាំគត់ ចំណែកអ្នកណា*
*គប្បីបូជាចំពោះបុគ្គល ដែលមានខ្លួនអប់រំហើយតែម្នាក់*
*សូម្បីតែមួយរំពេច ការបូជានោះឯង ប្រសើរជាងការ*
*បូជារបស់អ្នកដែលបូជាអស់មួយរយឆ្នាំនោះ ការបូជា*
*អស់មួយរយឆ្នាំ មិនប្រសើរឡើយ ។*

អធិប្បាយគាថា

*បណ្ដាបទទាំងនោះ បទថា សហស្សេន (ដោយទ្រព្យមួយពាន់) សេចក្ដីថា ដោយការបរិច្ចាគទ្រព្យមួយពាន់ ។ បទថា យោ យជេថ សតំ សមំ (អ្នកណាគប្បីបូជា... អស់ ១០០ ឆ្នាំ) សេចក្ដីថា អ្នកណាកាលបរិច្ចាគទ្រព្យមួយពាន់រាល់ៗ ខែ ឲ្យទានដល់លោកិយមហាជនអស់មួយរយឆ្នាំ ។ បទថា ឯកញ្ច ភាវិតត្តានំ (អ្នកមានខ្លួនអប់រំហើយ តែម្នាក់) សេចក្ដីថា ចំណែកអ្នកណាបូជាលោកដែលមានខ្លួនអប់រំហើយ ដោយអំណាចនៃគុណ មានសីលជាដើម ដោយទីបំផុតយ៉ាងទាប ជាព្រះសោតាបន្ន ដោយទីបំផុតយ៉ាងខ្ពស់ជាព្រះអរហន្ត ដែលមកដល់ទ្វារនៃផ្ទះ ដោយអំណាចការប្រគេនភិក្ខាមួយវែក ដោយអំណាចការប្រគេនអាហារ ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបាន ឬដោយ*

ត្រឹមតែថ្វាយសំពត់សាច់គ្រោតគ្រាត ការបូជារបស់អ្នកនោះឯង ប្រសើរ គឺល្អឯក បានដល់ ខ្ពង់ខ្ពស់ជាងការបូជាដែលបុគ្គលក្រៅអំពីនេះបូជាហើយអស់មួយរយឆ្នាំ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រាហ្មណ៍នោះបានសម្រេចសោតាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះឯង ។

ចប់ រឿងព្រាហ្មណ៍ជាឪពុកមារបស់ព្រះសារីបុត្រ

# ៦. រឿងក្មួយរបស់ព្រះសារីបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅនាវត្តវេឡុវ័ន ទ្រង់ប្រារព្ធក្មួយរបស់ព្រះសារីបុត្តត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* **យោ ច វស្សសតំ ជន្តុ** *(អ្នកណាបម្រើភ្លើងក្នុងព្រៃអស់រយៈនៃឆ្នាំ) ជាដើម ។*

ព្រះថេរៈនាំក្មួយទៅគាល់ព្រះសាស្តា

*បានឮថា ព្រះថេរៈចូលទៅរកក្មួយនោះហើយ សួរថា "ព្រាហ្មណ៍អ្នកធ្វើកុសលដែរឬ" ។*

*ព្រាហ្មណ៍. ករុណាលោកម្ចាស់ ។*

*ព្រះថេរៈ. ធ្វើកុសលអ្វី ។*

*ព្រាហ្មណ៍. សម្លាប់សត្វចិញ្ចឹមមួយហើយ បម្រើភ្លើង រាល់ៗ ខែ ។*

*ព្រះថេរៈ. ធ្វើយ៉ាងនោះ ដើម្បីអ្វី ។*

*ព្រាហ្មណ៍. គេថា នុ៎ះជាផ្លូវនៃព្រហ្មលោក ។*

*ព្រះថេរៈ. អ្នកណាថាយ៉ាងនោះ ។*

*ព្រាហ្មណ៍. ពួកអាចារ្យរបស់ខ្ញុំ លោកម្ចាស់ ។*

*ព្រះថេរៈពោលថា "អ្នកមិនដឹងផ្លូវនៃព្រហ្មលោកឡើយ ទាំងពួកអាចារ្យរបស់អ្នកក៏មិនដឹង មកចុះ យើងនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា" ហើយនាំក្មួយនោះទៅកាន់សម្នាក់ព្រះសាស្តា ទូលរឿងនោះហើយ បានក្រាបទូលថា*

“បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គត្រាស់ប្រាប់ផ្លូវព្រហ្មលោកដល់ព្រាហ្មណ៍នេះ” ។

## ព្រះសាស្ដាទ្រង់សម្ដែងធម៌ប្រោសដល់ព្រាហ្មណ៍

ព្រះសាស្ដាត្រាស់សួរថា “បានឮថា យ៉ាងនោះឬ ព្រាហ្មណ៍” កាលព្រាហ្មណ៍នោះទូលថា “បពិត្រព្រះគោតមដ៏ចម្រើន ពិតមែន” ទើបត្រាស់ថា “ព្រាហ្មណ៍ ការបម្រើភ្លើងរបស់អ្នកបម្រើភ្លើងយ៉ាងនោះ សូម្បីអស់មួយរយឆ្នាំ រមែងមិនស្មើការបូជាសាវករបស់តថាគត ត្រឹមតែមួយខណៈ” កាលទឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

យោ ច វស្សសតំ ជន្តុ អគ្គឹ បរិចរេ វនេ
ឯកញ្ច ភាវិតត្តានំ មុហុត្តមបិ បូជយេ
សាយេវ បូជនា សេយ្យោ យញ្ចេ វស្សសតំ ហុតំ ។

ជនណា បម្រើភ្លើងក្នុងព្រៃ អស់មួយរយឆ្នាំ ចំណែកអ្នកណា
បូជាលោកដែលមានខ្លួនអប់រំហើយតែម្នាក់ សូម្បីមួយរំពេច
ការបូជានោះឯង ប្រសើរជាងការបូជារបស់ជននោះ ការបូជា
អស់មួយរយឆ្នាំ មិនប្រសើរឡើយ ។

### អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា ជន្តុ នេះ ជាឈ្មោះរបស់សត្វ ។ បទថា អគ្គឹ បរិចរេ វនេ (គប្បីបម្រើភ្លើងក្នុងព្រៃ) សេចក្ដីថា សូម្បីចូលទៅកាន់ព្រៃ

ដោយប្រាថ្នាភាពជាអ្នកមិនមានធម៌ជាគ្រឿងយឺតយូរ ហើយបម្រើភ្លើងក្នុងព្រៃនោះ ។

ពាក្យដ៏សេស ដូចពាក្យដែលមានក្នុងន័យមុននោះឯង ។

កាលចប់ព្រះធម៌ទេសនា ព្រាហ្មណ៍បានសម្រេចសោតាបត្តិផល ជនដទៃទៀតជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ ។

ចប់ រឿងព្រាហ្មណ៍ជាក្មួយរបស់ព្រះសារីបុត្រ

# ៧. រឿងសំឡាញ់របស់ព្រះសារីបុត្រ

*ព្រះសាស្តា កាលប្រថាប់នៅវត្តវេឡុវ័ន ទ្រង់ប្រារព្ធព្រាហ្មណ៍ ជាសំឡាញ់របស់ព្រះសារីបុត្រ ត្រាស់ព្រះធម្មទេសនានេះថា យំ កិញ្ចិ យិដ្ឋំ (ការបូជាយញ្ញណាមួយ)* ជាដើម ។

ព្រះថេរៈនាំសំឡាញ់ទៅគាល់ព្រះសាស្តា

*សេចក្តីពិស្តារថា ព្រះថេរៈចូលទៅរកព្រាហ្មណ៍នោះហើយ សួរថា “ព្រាហ្មណ៍ អ្នកធ្វើកុសលខ្លះដែរឬ”* ។

*ព្រាហ្មណ៍. ធ្វើ លោកម្ចាស់* ។

*ព្រះថេរៈ. ធ្វើកុសលអ្វី* ។

*ព្រាហ្មណ៍. បូជាយញ្ញ តាមដែលគេបូជាហើយ* ។

*បានឮថា ក្នុងសម័យនោះ ជនទាំងឡាយរមែងបូជាយញ្ញនោះ ដោយការបរិច្ចាគយ៉ាងច្រើន ។ បន្ទាប់អំពីនេះ ព្រះថេរៈសួរដោយន័យមុននោះឯង ហើយនាំព្រាហ្មណ៍នោះ ទៅកាន់សម្នាក់ព្រះសាស្តា បានទូលរឿងនោះហើយ ក្រាបទូលថា “បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គត្រាស់ប្រាប់ផ្លូវនៃព្រហ្ម-លោកដល់ព្រាហ្មណ៍នេះ”* ។

ព្រះសាស្តាទ្រង់សម្តែងធម៌ប្រោសដល់ព្រាហ្មណ៍

*ព្រះសាស្តាត្រាស់សួរថា “បានឮថា យ៉ាងនោះឬ ព្រាហ្មណ៍” កាល*

ព្រាហ្មណ៍ទូលថា "យ៉ាងនោះពិតមែន" ទើបត្រាស់ថា "ព្រាហ្មណ៍ ទានដែលអ្នកបូជាយញ្ញ តាមដែលគេបូជាហើយ ឲ្យដល់លោកិយមហាជន សូម្បីអស់មួយឆ្នាំ រមែងមិនស្មើសូម្បីត្រឹមតែចំណែកទី ៤ នៃកុសលចេតនាដែលកើតឡើងដល់ជនទាំងឡាយ អ្នកថ្វាយបង្គំសាវកតថាគត ដោយចិត្តដែលជ្រះថ្លា កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបទ្រង់ត្រាស់ព្រះគាថានេះថា ៖

យង្កិញ្ចិ យិដ្ឋំ វ ហុតំ វ លោកេ
សំវច្ឆរំ យជេថ បុញ្ញបេក្ខោ
សព្វំបិ តំ ន ចតុភាគមេតិ
អភិវាទនា ឧជុគតេសុ សេយ្យោ ។

បុគ្គលអ្នកប្រាថ្នាបុណ្យ គប្បីបូជាគ្រឿងសក្ការបូជាធំតូច
ណាមួយ ក្នុងលោកអស់មួយឆ្នាំ ការបូជាទាំងអស់នោះឯង
រមែងមិនដល់នូវចំណែកទី ៤ នៃការអភិវាទន៍ ចំពោះលោក
ទាំងឡាយដែលប្រព្រឹត្តត្រង់ហើយ ប្រសើរជាង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **យង្កិញ្ចិ** (យ៉ាងណាមួយ) នេះ ជាពាក្យសង្គ្រោះការបូជាទាំងអស់មិនមានចំណែកសេសសល់ ។ បទថា **យិដ្ឋំ** (យញ្ញ) បានដល់ ទានដែលគេឲ្យ ដោយអំណាចការធ្វើមង្គលជាដើម ដោយច្រើន ។ បទថា **ហុតំ** (បួងសួង) បានដល់ ទានដើម្បីភ្ញៀវ ដែលគេចាត់ចែងធ្វើ និង

ទានដែលគេជឿកម្ម និងផលនៃកម្ម ហើយធ្វើ ។

ពីរបទថា **សំវច្ឆរំ យជេថ (គប្បីបូជា... មួយឆ្នាំ)** សេចក្ដីថា គប្បីឲ្យទានមានប្រការដូចពោលហើយ ដល់លោកិយមហាជន សូម្បីក្នុងចក្រវាឡទាំងអស់ រហូតមួយឆ្នាំមិនមានចន្លោះ ។ បទថា **បុញ្ញបេក្ខោ (អ្នកប្រាថ្នាបុណ្យ)** បានដល់ អ្នកប្រាថ្នាបុណ្យ ។ បទថា **ឧជុគតេសុ (ឲ្យដល់លោកអ្នកប្រព្រឹត្តត្រង់)** សេចក្ដីថា ក្នុងព្រះសោតាបន្នដោយទីបំផុតយ៉ាងទាប ក្នុងព្រះខីណាស្រពយ៉ាងខ្ពស់បំផុត ។

ពាក្យនេះ ដែលព្រះសាស្ដាត្រាស់ ទុកថា "ទានទាំងអស់នោះ មិនស្មើសូម្បីចំណែកទី ៤ អំពីផលនៃកុសលចេតនារបស់អ្នកបង្អោនសរីរៈថ្វាយបង្គំដោយចិត្តដែលជ្រះថ្លាបែបនោះ" ព្រោះហេតុដូច្នោះ ការអភិវាទចំពោះលោកប្រព្រឹត្តត្រង់ប៉ុណ្ណោះ ប្រសើរបំផុត ។

ក្នុងវេលាចប់ព្រះធម៌ទេសនា ព្រាហ្មណ៍ក៏បានសម្រេចសោតាបត្តិផល ជនដទៃទៀតជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រាហ្មណ៍ជាសំឡាញ់របស់ព្រះសារីបុត្រ

# ៨. រឿងអាយុវឌ្ឍនកុមារ

*ព្រះសាស្តា ទ្រង់អាស្រ័យទីឃលម្ពិកនគរ ប្រថាប់នៅក្នុងកុដិក្នុងព្រៃ ទ្រង់ប្រារព្ធកុមារអ្នកមានអាយុវែង ត្រាស់ព្រះធម្មទេសនា នេះថា **អភិវាទ-នសីលិស្ស** (ដល់បុគ្គលអ្នកក្រាបថ្វាយបង្គំជាប្រក្រតី) ជាដើម ។*

ព្រាហ្មណ៍ជាសំលាញ់ពីរនាក់ចេញបួស

*បានឮថា ព្រាហ្មណ៍ពីរនាក់នៅក្នុងទីឃលម្ពិកនគរ បួសក្នុងលទ្ធិខាងក្រៅ បំពេញតបៈអស់កាល ៤៨ ឆ្នាំ ។ បណ្តាព្រាហ្មណ៍ទាំងពីរនាក់នោះ ព្រាហ្មណ៍ម្នាក់គិតថា "ប្រពៃណីរបស់យើងនឹងសាបសូន្យ យើងនឹងសឹក" ដូច្នេះហើយ ទើបលក់បរិក្ខារតបៈដែលខ្លួនធ្វើទុក ដល់មនុស្សពួកដទៃ បានភរិយាព្រមទាំងគោ ១០០ ក្បាល និងទ្រព្យ ១០០ កហាបណៈ ឲ្យគេតាំងទុកជាគំនរទ្រព្យ ។ គ្រានោះ ភរិយារបស់គាត់បានសម្រាលកូន ។ ចំណែកសំឡាញ់របស់គាត់ទៅកាន់កន្លែងផ្សេងហើយ ក៏ត្រឡប់មកកាន់នគរនោះម្តងទៀត ។ គាត់បានឮថា សំឡាញ់នោះមក ទើបនាំបុត្រ និងភរិយាទៅដើម្បីជួបសំឡាញ់ ពេលទៅដល់ហើយ បានឲ្យបុត្រដល់ភរិយា ហើយខ្លួនឯងក៏ថ្វាយបង្គំមុន ។ សូម្បីភរិយា ឲ្យបុត្រដល់ស្វាមីហើយ ក៏ថ្វាយបង្គំដែរ ។ សំឡាញ់នោះពោលថា "ចូរអ្នកទាំងពីរមានអាយុវែង តែកាលព្រាហ្មណ៍ជាស្វាមី និងភរិយា ឲ្យបុត្រថ្វាយបង្គំហើយ សំឡាញ់នោះបាននៅស្ងៀម ។*

## ព្រាហ្មណ៍សួរហេតុដែលសំឡាញ់មិនឱ្យពរដល់បុត្រ

លំដាប់នោះ គាត់ពោលនឹងសំឡាញ់នោះថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រោះហេតុអ្វី កាលខ្ញុំថ្វាយបង្គំ លោកម្ចាស់ពោលថា ចូរអ្នកមានអាយុវែង ក្នុងវេលាដែលក្មេងនេះថ្វាយបង្គំ មិនពោលពាក្យអ្វីៗ" ។

សំឡាញ់. ព្រាហ្មណ៍ ក្មេងនេះមានអន្តរាយមួយ ។

ព្រាហ្មណ៍. ក្មេងនេះនឹងរស់នៅអស់កាលប៉ុន្មាន លោកម្ចាស់ ?

សំឡាញ់. ៧ ថ្ងៃទៀត ព្រាហ្មណ៍ ។

ព្រាហ្មណ៍. ហេតុជាគ្រឿងការពារ មានដែរឬ លោកម្ចាស់ ?

សំឡាញ់. យើងមិនដឹងហេតុដែលជាគ្រឿងការពារទេ ។

ព្រាហ្មណ៍. ចុះអ្នកណាដឹងបាន លោកម្ចាស់ ?

សំឡាញ់. ព្រះសមណគោតម លោកចូរទៅកាន់សម្នាក់របស់ព្រះសមណគោតមនោះ ហើយសួរចុះ ។

ព្រាហ្មណ៍. ខ្ញុំទៅក្នុងទីនោះ ខ្លាចតែវិនាសតបៈ ។

សំឡាញ់. បើអ្នកមានសេចក្តីស្រឡាញ់ក្នុងបុត្រ អ្នកកុំគិតដល់ការវិនាសនៃតបៈ ចូរទៅសម្នាក់របស់ព្រះសមណគោតមនោះ សួរចុះ ។

ព្រាហ្មណ៍នោះ ទៅកាន់សម្នាក់ព្រះសាស្តាហើយ ក៏ថ្វាយបង្គំដោយខ្លួនឯងមុន ។ ព្រះសាស្តាត្រាស់ថា "ចូរអ្នកមានអាយុវែង" សូម្បីក្នុងកាលដែលបជាបតិ (ប្រពន្ធ) ថ្វាយបង្គំ ក៏ត្រាស់ដូចគ្នា ក្នុងពេលដែលគាត់ឲ្យបុត្រ

ថ្វាយបង្គំ ទ្រង់បានគង់ស្ងៀម ។ គាត់ទូលសួរព្រះសាស្តា ដោយន័យមុននោះឯង ។ សូម្បីព្រះសាស្តា ក៏ទ្រង់ព្យាករដល់គាត់យ៉ាងនោះដូចគ្នា ។

បានឮថា ព្រាហ្មណ៍នោះ មិនចាក់ធ្លុះព្រះសព្វញ្ញុតញ្ញាណ ទើបប្រៀបផ្ទឹមមន្តរបស់ខ្លួននឹងព្រះសព្វញ្ញុតញ្ញាណ តែមិនដឹងឧបាយជាគ្រឿងការពារ ។

ព្រះសាស្តាត្រាស់ប្រាប់ឧបាយជាគ្រឿងការពារ

ព្រាហ្មណ៍ទូលសួរព្រះសាស្តាថា "បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាយជាគ្រឿងការពារមានដែរឬ?" ។

ព្រះសាស្តា. មាន ព្រាហ្មណ៍ ។

ព្រាហ្មណ៍. គប្បីមានដូចម្តេច ?

ព្រះសាស្តា. បើអ្នកអាចធ្វើមណ្ឌបជិតទ្វារផ្ទះរបស់ខ្លួន ហើយឲ្យគេធ្វើតាំងទុកត្រង់កណ្តាលមណ្ឌបនោះ រួចក្រាលអាសនៈទុក ៨ ឬ ១៦ កន្លែងព័ទ្ធជុំវិញតាំងនោះ ឲ្យសាវករបស់តថាគតអង្គុយលើអាសនៈទាំងនោះ ឲ្យធ្វើព្រះបរិត្ត ៧ ថ្ងៃ តជាប់គ្នាមិនដាច់ អន្តរាយនៃក្មេងនោះ គប្បីវិនាសទៅដោយឧបាយយ៉ាងនេះ ។

ព្រាហ្មណ៍. ព្រះគោតមដ៏ចម្រើន ខ្ញុំព្រះអង្គអាចធ្វើមណ្ឌបជាដើមបាន តែនឹងបានសាវករបស់ព្រះអង្គយ៉ាងណា ?

ព្រះសាស្តា. កាលអ្នកធ្វើកិច្ចទាំងនេះហើយ តថាគតនឹងបញ្ជូនសាវករបស់តថាគតទៅ ។

ព្រាហ្មណ៍ទទួលព្រមថា “ប្រពៃហើយ ព្រះគោតមដ៏ចម្រើន” ហើយធ្វើកិច្ចនោះទាំងអស់ជិតទ្វារផ្ទះរបស់ខ្លួន រួចបានទៅកាន់សម្នាក់ព្រះសាស្ដា ។

ព្រះសាស្ដា ទ្រង់បញ្ជូនភិក្ខុទាំងឡាយទៅ ។ ភិក្ខុទាំងនោះទៅគង់ក្នុងមណ្ឌបនោះ ។ ព្រាហ្មណ៍ស្វាមីភរិយា បានឲ្យក្មេងដេកលើតាំង ។ ភិក្ខុទាំងឡាយសូត្រព្រះបរិត្ត ៧ យប់ ៧ ថ្ងៃ តជាប់គ្នា ។ ក្នុងថ្ងៃទី ៧ ព្រះសាស្ដាស្ដេចយាងមកដោយព្រះអង្គឯង ។ កាលព្រះសាស្ដាស្ដេចយាងទៅហើយ ពួកទេវតាក្នុងចក្រវាឡទាំងអស់បានមកប្រជុំគ្នា ។ ក៏ **អវរុទ្ធកយក្ស** ដែលបម្រើព្រះបាទវេស្សវណ្ណអស់ ១២ ឆ្នាំ កាលបានពរពីសម្នាក់ស្ដេចវេស្សវ័ណនោះថា ក្នុងថ្ងៃទី ៧ អំពីថ្ងៃនេះ អ្នកគប្បីចាប់យកក្មេងនេះ ព្រោះដូច្នោះ ទើបយក្សនោះបានមកឈរទីនេះ ។ កាលព្រះសាស្ដា ស្ដេចយាងទៅក្នុងមណ្ឌបនោះ កាលពួកទេវតាអ្នកមានសក្តិធំប្រជុំគ្នា ពួកទេវតាអ្នកមានសក្តិតូច ថយទៅមិនបានឱកាស ចៀសចេញទៅរហូត ១២ យោជន៍ ។ សូម្បីអវរុទ្ធកយក្សក៏បានចៀសចេញទៅ ឈរយ៉ាងនោះដូចគ្នា ។

## ក្មេងផុតពីអន្តរាយត្រឡប់មានអាយុវែង

សូម្បីព្រះសាស្ដា ក៏ទ្រង់ធ្វើព្រះបរិត្តរហូតអស់មួយរាត្រី ។ កាលកន្លងទៅ ៧ ថ្ងៃ អវរុទ្ធកយក្សមិនបានក្មេង ក្នុងថ្ងៃទី ៨ គ្រាន់តែអរុណរះឡើងប៉ុណ្ណោះ ពីរនាក់ស្វាមីភរិយា នាំក្មេងមកឲ្យថ្វាយបង្គំព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា “ចូរអ្នកមានអាយុវែងចុះ” ។

ព្រាហ្មណ៍. ព្រះគោតមដ៏ចម្រើន ក៏ក្មេងនេះនឹងតាំងនៅយូរប៉ុន្មាន ?

ព្រះសាស្ដា. ១២០ ឆ្នាំ ព្រាហ្មណ៍ ។

លំដាប់នោះ ពីរនាក់ស្វាមីភរិយា ដាក់នាមក្មេងនោះថា **អាយុវឌ្ឍនកុមារ** ។ អាយុវឌ្ឍនកុមារនោះ ធំពេញវ័យហើយ មានឧបាសក ៥០០ នាក់ជាបរិវារ ។

## ការក្រាបថ្វាយបង្គំអ្នកដែលមានគុណាធ្វើឱ្យមានអាយុវែង

ក្នុងថ្ងៃមួយ ភិក្ខុទាំងឡាយសន្ទនាគ្នា ក្នុងសាលាធម្មសភាថា "អាវុសោទាំងឡាយ លោកទាំងឡាយចូរមើល បានឮថា អាយុវឌ្ឍនកុមារ គប្បីស្លាប់ក្នុងថ្ងៃទី ៧ ឥឡូវនេះ អាយុវឌ្ឍនកុមារនោះ នឹងបានរស់នៅរហូតអស់ ១២០ ឆ្នាំ ទាំងមានឧបាសក ៥០០ ជាបរិវារ ហេតុជាគ្រឿងចម្រើនអាយុរបស់សត្វទាំងនេះ នឹងមាន" ។

ព្រះសាស្ដាស្ដេចយាងមកហើយ ត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ពួកអ្នកអង្គុយប្រជុំគ្នាដោយរឿងអ្វី" កាលភិក្ខុទាំងឡាយក្រាបទូលថា "ដោយរឿងឈ្មោះនេះ" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អាយុចម្រើនតែម្ដងក៏មិនមែន តែសត្វទាំងនេះ ថ្វាយបង្គំលោកអ្នកដែលមានគុណ រមែងចម្រើនដោយហេតុ ៤ ប្រការ ផុតចាកអន្តរាយ នឹងតាំងនៅរហូតអស់អាយុដោយពិត" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ ទើបត្រាស់ព្រះគាថានេះ ៖

*អភិវាទនសីលិស្ស និច្ចំ វុឌ្ឍាបចាយិនោ*
*ចត្តារោ ធម្មា វឌ្ឍន្តិ អាយុ វណ្ណោ សុខំ ពលំ ។*
*ធម៌ ៤ ប្រការ គឺ អាយុ ១ វណ្ណៈ ១ សុខៈ ១ ពលៈ ១*
*រមែងចម្រើនដល់អ្នកដែលមានសេចក្ដីខ្ជិនកាយ ថ្វាយបង្គំ*
*ជាប្រក្រតី មានសេចក្ដីកោតក្រែងដល់បុគ្គលដែលចម្រើន*
*ជាងខ្លួន អស់កាលជានិច្ច ។*

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា **អភិវាទនសីលិស្ស** (ដល់បុគ្គលដែលក្រាបថ្វាយបង្គំជាប្រក្រតី) គឺ អ្នកថ្វាយបង្គំជាប្រក្រតី បានដល់ អ្នកខ្វល់ខ្វាយក្នុងកិច្ច គឺ ការថ្វាយបង្គំរឿយៗ ។ បទថា **វុឌ្ឍាបចាយិនោ** (កោតក្រែងដល់បុគ្គលដែលចម្រើន) សេចក្ដីថា ដល់គ្រហស្ថអ្នកខ្ជិនលំទោន ឬអ្នកបូជាជានិច្ចដោយការថ្វាយបង្គំ សូម្បីដល់ភិក្ខុកំលោះ ឬសាមណេរដែលបួសក្នុងថ្ងៃនោះ ឬក៏ដល់បព្វជិតអ្នកខ្ជិនលំទោន ឬអ្នកបូជាជានិច្ច ដោយការថ្វាយបង្គំចំពោះលោកអ្នកដែលចាស់ជាងដោយបព្វជ្ជា ឬឧបសម្បទា ឬចំពោះលោកអ្នកដែលចម្រើនដោយគុណ ។ បទថា **ចត្តារោ ធម្មា** (ធម៌ ៤ ប្រការ) សេចក្ដីថា កាលអាយុចម្រើនហើយ អាយុនោះ រមែងចម្រើនអស់កាលត្រឹមណា ធម៌ទាំងឡាយសូម្បីក្រៅពីនេះ ក៏ចម្រើនអស់កាលប៉ុណ្ណោះដូចគ្នា ព្រោះថា អ្នកណាធ្វើបុណ្យនៅក្នុងអាយុ ៥០ ឆ្នាំ អន្តរាយនៃជីវិតរបស់អ្នកនោះ គប្បីកើត

ឡើងក្នុងកាលដែលមានអាយុ ២៥ ឆ្នាំប៉ុណ្ណោះ អន្តរាយនោះ រមែងស្ងប់ទៅបានដោយភាពជាអ្នកថ្វាយបង្គំជាប្រក្រតី ។ អ្នកនោះ រមែងរស់នៅបានរហូតអស់អាយុ ។ សូមរ្បីវណ្ណៈជាដើមរបស់អ្នកនោះ រមែងចម្រើនព្រមជាមួយនឹងអាយុដែរ ។ ន័យសូម្បីក្រៅលែងជាងនេះ ក៏យ៉ាងនេះឯង ។ ក៏ឈ្មោះថា ការចម្រើននៃអាយុ ដែលប្រព្រឹត្តទៅដោយមិនមានអន្តរាយ រមែងមិនមាន ។

ក្នុងវេលាចប់ទេសនា អាយុវឌ្ឍនកុមារ តាំងនៅក្នុងសោតាបត្តិផលព្រមទាំងឧបាសក ៥០០ រូប ។ សូម្បីជនដទៃជាច្រើនទៀត ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងអាយុវឌ្ឍនកុមារ

# ៩. រឿងសន្តិច្ចសាមណេរ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធសន្តិច្ចសាមណេរ ត្រាស់ព្រះធម្មទេសនានេះថា* ***យោ ច វស្សសតំ ជីវេ*** *(គប្បីរស់នៅ ១០០ ឆ្នាំ) ជាដើម ។*

## កុលបុត្រ ៣០ រូបចេញបួស

*បានឮថា កុលបុត្រប្រមាណ ៣០ រូប ក្នុងក្រុងសាវត្ថី ស្តាប់ធម្មកថាហើយ បួសថ្វាយជីវិតក្នុងសាសនារបស់ព្រះសាស្តា ។ ភិក្ខុទាំងនោះ ឧបសម្បទាបាន ៥ វស្សា ចូលទៅគាល់ព្រះសាស្តា ស្តាប់ធុរៈ ២ ប្រការ គឺ គន្ថធុរៈ វិបស្សនាធុរៈ មិនធ្វើសេចក្តីព្យាយាមក្នុងគន្ថធុរៈ ព្រោះជាអ្នកបួសក្នុងវេលាខ្លួនជាមនុស្សចាស់ តែមានបំណងនឹងបំពេញវិបស្សនាធុរៈ ទើបទូលព្រះសាស្តាឲ្យទ្រង់ត្រាស់ប្រាប់កម្មដ្ឋានរហូតដល់ព្រះអរហត្ត ហើយទូលលាព្រះសាស្តាថា "ខ្ញុំព្រះអង្គនឹងទៅកាន់ព្រៃមួយកន្លែង ព្រះអង្គ" ។*

*ព្រះសាស្តាត្រាស់សួរថា "ពួកអ្នកនឹងទៅកាន់ទីណា" កាលភិក្ខុទាំងនោះក្រាបទូលថា "ទីឈ្មោះឯណោះ" ទ្រង់ជ្រាបថា ភ័យនឹងកើតឡើងក្នុងទីនោះដល់ភិក្ខុទាំងនោះ ព្រោះអាស្រ័យមនុស្សស៊ីដែលម្នាក់ តែថា ក្នុងកាលសន្តិច្ចសាមណេរទៅហើយ ភ័យនោះនឹងស្ងប់រម្ងាប់បាន កាលបើដូច្នោះ កិច្ចនៃបព្វជិតរបស់ភិក្ខុទាំងនោះនឹងដល់ភាពបរិបូណ៌ ។*

## ប្រវត្តិរបស់សង្កិច្ចសាមណេរ

សាមណេររបស់ព្រះសារីបុត្រ ឈ្មោះសង្កិច្ចសាមណេរ មានអាយុ ៧ ឆ្នាំ ដោយកំណើត ។ បានឮថា មាតារបស់សង្កិច្ចសាមណេរនោះ ជាធីតារបស់ត្រកូលស្តុកស្តម្ភក្នុងក្រុងសាវត្ថី ។ កាលសាមណេរនោះនៅក្នុងផ្ទៃមាតានោះ បានធ្វើមរណកាលក្នុងខណៈនោះឯង ដោយរោគម្យ៉ាង ។ កាលមាតានោះត្រូវគេដុត សាច់ចំណែកដ៏សេសបានឆេះ វៀរតែសាច់គភ៌ ។ គ្រានោះ អ្នកដុតសពទាំងឡាយយកសាច់គភ៌របស់នាងចុះចាកជើងថ្ករ ចាក់ដោយដែកស្រួចក្នុងទី ២-៣ កន្លែង ចុងដែកស្រួចក៏ប៉ះកន្ទុយភ្នែករបស់ទារកនោះ ។ ពួកអ្នកដុតសព ចាក់សាច់គភ៌យ៉ាងនោះហើយ លើកបោះទៅក្នុងគំនររងើកភ្លើង បិទបាំងដោយរងើកភ្លើងនោះឯង ហើយចៀសចេញទៅ ។ កាលសាច់គភ៌ឆេះអស់ហើយ ទារកក៏បានប្រាកដស្មើដោយរូបមាស លើគំនររងើកភ្លើងដូចជាដេកនៅក្នុងស្រទាប់ផ្កាឈូក ។ ពិតហើយ សត្វអ្នកមានភពជាទីបំផុត កាលមិនទាន់សម្រេចព្រះអរហត្ត សូម្បីសង្កត់ដោយភ្នំព្រះសិនេរុ ហើយអស់ជីវិត រមែងមិនមាន ។ ក្នុងថ្ងៃព្រឹកឡើង ពួកអ្នកដុតសាកសពមក ដោយគិតថា នឹងពន្លត់ភ្លើង ឃើញទារកដេកនៅដូច្នោះ កើតអស្ចារ្យ និងចំឡែកចិត្តគិតថា "រឿងនេះ ដូចម្តេចហ្ន៎? កាលសរីរៈទាំងអស់ត្រូវដុតនៅលើឧសប៉ុណ្ណេះ ទារកមិនបានឆេះ នឹងមានហេតុអ្វីហ្ន៎" ទើបបីក្មេងនោះ នាំយកទៅខាងក្នុងស្រុក ហើយសួរពួកអ្នកទាយនិមិត្ត ។ ពួកអ្នកទាយនិមិត្តទាយថា "បើទារក

នេះនៅគ្រប់គ្រងផ្ទះ ពួកញាតិរហូត ៧ ជួរត្រកូលនឹងមិនលំបាក បើនឹងបួសជាអ្នកដែលមានសមណៈ ៥០០ រូបជាបរិវារ ។ ពួកញាតិសន្មតនាមទារកនោះថា **សង្កិច្ចៈ** ព្រោះកន្ទុយភ្នែករបស់គេត្រូវដោយដែកស្ទូច ។ សម័យក្រោយមក ក្មេងនោះប្រាកដថា "សង្កិច្ចៈ" ។ គ្រានោះ ពួកញាតិចិញ្ចឹមគេទុកដោយប្រឹក្សាគ្នាថា "ក្នុងវេលាដែលគេធំពេញវ័យហើយ ពួកយើងនឹងឲ្យគេបួសក្នុងសម្នាក់ព្រះសារីបុត្រ ដែលជាលោកម្ចាស់របស់ពួកយើង" ។ ក្នុងវេលាដែលខ្លួនមានអាយុ ៧ ឆ្នាំ សង្កិច្ចៈនោះបានឮពាក្យក្មេងៗ និយាយថា "ក្នុងកាលដែលគេនៅក្នុងផ្ទៃ មាតារបស់គេបានធ្វើមរណកាល សរីរៈរបស់មាតាអ្នកនោះ សូម្បីត្រូវភ្លើងឆេះ តែគេមិនឆេះ" ទើបប្រាប់ដល់ពួកញាតិថា "គេថា ខ្ញុំផុតភ័យបែបនោះ ប្រយោជន៍អ្វីដោយផ្ទះសម្រាប់ខ្ញុំ ខ្ញុំនឹងបួស" ។ ញាតិទាំងនោះទទួលថា "ល្អហើយ កូន!" ហើយនាំទៅកាន់សម្នាក់ព្រះសារីបុត្រ បានថ្វាយដោយពាក្យថា "លោកម្ចាស់ សូមលោកម្ចាស់ ឲ្យក្មេងនេះបួសផង" ។ ព្រះថេរៈឲ្យតចបញ្ចកកម្មដ្ឋាន ហើយក៏ឲ្យបួស ។ សាមណេរនោះសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាក្នុងវេលាកោរសក់រួចស្រេច ។ រឿងសង្កិច្ចសាមណេរ មានត្រឹមប៉ុណ្ណេះ ។

## ព្រះសាស្តាត្រាស់ឱ្យពួកភិក្ខុទៅលាព្រះសារីបុត្រ

ព្រះសាស្តាទ្រង់ជ្រាបថា "កាលសាមណេរនេះទៅហើយ ភ័យនោះនឹងរម្ងាប់ កាលបើដូច្នេះ កិច្ចនៃបព្វជិតរបស់ភិក្ខុទាំងនោះ នឹងដល់ភាពបរិបូណ៌"

ដូច្នេះហើយ ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរលាសារីបុត្រដែលជាបងប្រុសរបស់ពួកអ្នក ហើយសឹមទៅ" ។ ពួកភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ថា "ព្រះករុណា ព្រះអង្គ" ហើយទៅកាន់សម្នាក់របស់ព្រះថេរៈ កាលព្រះថេរៈសួរថា "មានកិច្ចអ្វី អ្នកមានអាយុ" ទើបពោលថា "ពួកខ្ញុំរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាហើយ មានបំណងនឹងចូលទៅព្រៃ ទើបទូលលា កាលពួកខ្ញុំទូលលាហើយ ព្រះសាស្ដាត្រាស់នឹងពួកខ្ញុំយ៉ាងនេះថា ពួកអ្នកចូរលាបងប្រុសរបស់ពួកអ្នកហើយ សឹមទៅ" ហេតុនេះ ទើបពួកខ្ញុំមកទីនេះ ។

ព្រះថេរៈគិតថា "ភិក្ខុទាំងនេះនឹងជាអ្នកដែលព្រះសាស្ដាទ្រង់ឃើញហេតុយ៉ាងណាមួយហើយ ទើបទ្រង់បញ្ជូនមកទីនេះ ហេតុនេះដូចម្ដេចហ្ន៎" ដឹងរឿងនោះហើយ ទើបពោលថា "អ្នកមានអាយុ សាមណេររបស់ពួកលោកមានដែរឬ" ។

ពួកភិក្ខុ. មិនមានទេ លោកដ៏មានអាយុ ។

ព្រះថេរៈ. បើមិនមាន ពួកលោកចូរនាំសង្កិច្ចសាមណេរនេះទៅចុះ ។

ពួកភិក្ខុ. កុំបាច់ឡើយ លោកដ៏មានអាយុ ព្រោះអាស្រ័យសាមណេរបលិពោធ (កង្វល់) នឹងមានដល់ពួកខ្ញុំ ប្រយោជន៍អ្វីដោយសាមណេរសម្រាប់ពួកភិក្ខុនៅក្នុងព្រៃ ។

ព្រះថេរៈ. លោកដ៏មានអាយុ ព្រោះអាស្រ័យសាមណេរនេះ កង្វល់នឹងមិនមានដល់ពួកលោក តែព្រោះអាស្រ័យពួកលោក កង្វល់នឹងមានដល់

សាមណេរនេះ សូម្បីព្រះសាស្តា ទ្រង់បញ្ជូនពួកលោកមកសម្នាក់ខ្ញុំ ទ្រង់រង់ចាំឲ្យសាមណេរទៅជាមួយពួកលោក ទើបទ្រង់បញ្ជូនពួកលោកមក ពួកលោកចូរនាំសាមណេរនេះទៅចុះ ។

## ភិក្ខុ ៣០ រូប នៅធ្វើសមណធម៌

ភិក្ខុទាំងនោះទទួលថា "ប្រពៃហើយ លោកដ៏មានអាយុ" រួមជា ៣១ រូបទាំងសាមណេរ លាព្រះថេរៈចេញចាកវិហារ ត្រាច់ចារិកទៅរហូតដល់ស្រុកមួយ ដែលមានត្រកូលមួយពាន់ ក្នុងចម្ងាយផ្លូវ ១២០ យោជន៍ ។ ពួកមនុស្សឃើញភិក្ខុទាំងនោះ មានចិត្តជ្រះថ្លា និមន្តឲ្យឆាន់ដោយគោរពហើយ សួរថា "លោកម្ចាស់ ពួកលោកម្ចាស់ នឹងនិមន្តទៅទីណា" កាលភិក្ខុទាំងនោះប្រាប់ថា "ទៅកាន់ទីដែលសប្បាយ អ្នកមានអាយុ" ក៏ក្រាបចុះទៀបបាទមូល ហើយអង្វរថា "លោកម្ចាស់ បើពួកលោកម្ចាស់នៅចាំវស្សាក្នុងស្រុកនេះ ពួកខ្ញុំនឹងសមាទានសីល រក្សាឧបោសថ" ។ ព្រះថេរៈទាំងឡាយក៏ទទួលនិមន្ត ។ គ្រានោះ ពួកមនុស្សបានចាត់ចែងទីសម្រាកពេលថ្ងៃ និងពេលយប់ ទីចង្ក្រម និងបណ្ណសាលា ដល់នូវសេចក្តីឧស្សាហ៍ថា "ថ្ងៃនេះពួកយើង ស្អែកនេះពួកយើង" បានធ្វើការទំនុកបម្រុងពួកភិក្ខុទាំងនោះ ។

## ពួកភិក្ខុដាក់កតិកាគ្នានៅចាំវស្សា

ក្នុងថ្ងៃចូលវស្សា ព្រះថេរៈទាំងឡាយដាក់កតិកាគ្នាថា "អ្នកមានអាយុ ពួកយើងរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់ ដែលទ្រង់ធរមាននៅ បើរៀរ

ការដល់ព្រមដោយវត្តបដិបត្តិ ពួកយើងមិនអាចញុំាងព្រះពុទ្ធទាំងឡាយ ឲ្យទ្រង់ប្រោសប្រាណបានឡើយ ម្យ៉ាងទៀត ទ្វារអបាយក៏បើកហើយ សម្រាប់ពួកយើងជាប្រាកដ ព្រោះដូច្នោះ វៀរតែវេលាភិក្ខាចារ ក្នុងពេលព្រឹក និងបម្រើព្រះថេរៈក្នុងពេលល្ងាច ក្នុងកាលដ៏សេស ពួកយើងមិនត្រូវនៅកន្លែងមួយពីររូបទេ បើសេចក្ដីមិនសប្បាយនឹងមានដល់ភិក្ខុណា កាលភិក្ខុនោះគោះរគាំង ពួកយើងនឹងទៅកាន់សម្នាក់ភិក្ខុនោះធ្វើថ្នាំ តាំងពីពេលនេះទៅពួកយើងនឹងមិនប្រមាទ ប្រកបព្យាយាមក្នុងកម្មដ្ឋានរឿយៗ” ។

## ទុគ្គតបុរសមកអាស្រ័យនៅជាមួយពួកភិក្ខុ

កាលភិក្ខុទាំងនោះដាក់កតិកាវត្ត ព្រមព្រៀងគ្នាយ៉ាងនេះហើយ ទុគ្គត-បុរសម្នាក់រស់នៅអាស្រ័យធីតា កាលទីនោះកើតទុរភិក្ស ក៏មានបំណងនឹងចិញ្ចឹមជីវិតអាស្រ័យធីតាដទៃទៀត ក៏ធ្វើដំណើរទៅ សូម្បីព្រះថេរៈទាំងឡាយក៏ត្រាច់ទៅបិណ្ឌបាតក្នុងស្រុក កាលត្រឡប់មកវិញ បានទៅស្រង់ទឹកក្នុងស្ទឹងមួយ ហើយគង់ធ្វើកត្តកិច្ចលើពំនូកខ្សាច់ ។ ក្នុងខណៈនោះ បុរសនោះដល់ទីនោះហើយ បានឈរក្នុងទីដ៏សមគួរមួយ ។ លំដាប់នោះ ព្រះថេរៈទាំងឡាយសួរបុរសនោះថា “អ្នកនឹងទៅទីណា” បុរសនោះប្រាប់សេចក្ដីនោះហើយ ព្រះថេរៈទាំងឡាយមានសេចក្ដីករុណាចំពោះបុរសនោះ ទើបពោលថា “ឧបាសកអ្នកឃ្លានខ្លាំងណាស់ ចូរទៅយកស្លឹកឈើមក ពួកអាត្មានឹងឲ្យពំនូតបាយមួយដុំៗ ដល់អ្នក” កាលគេយកស្លឹកឈើមកហើយ ក៏លាយដោយសម្លទឹក និង

សម្ភោគ តាមទំនងដែលនឹងបានរៀងៗ ខ្លួន ហើយបានឲ្យដុំបាយមួយដុំៗ ។ បានឮថា ការឲ្យដោយទំនងនៃការបានដោយរៀងៗ ខ្លួននោះឯង ជាវត្តនៃភិក្ខុអ្នកឲ្យភត្តដល់បុគ្គលអ្នកមកក្នុងវេលាបាន់ មិនឲ្យភត្តដ៏ប្រសើរ គប្បីឲ្យតិចឬច្រើន ដោយទំនងដែលបានដោយខ្លួននោះឯង ព្រោះហេតុនោះ ភិក្ខុទាំងនោះទើបឲ្យយ៉ាងនោះ ។ បុរសនោះបរិភោគហើយ ថ្វាយបង្គំព្រះថេរៈទាំងឡាយ ហើយសួរថា "លោកម្ចាស់ លោកម្ចាស់ទាំងឡាយ មានអ្នកណានិមន្តទុកឬ"

ពួកភិក្ខុ. មិនមានការនិមន្តទេ ឧបាសក ពួកមនុស្សថ្វាយអាហារបែបនេះ រាល់ៗ ថ្ងៃ ។

ទុគ្គតបុរសគិតថា "យើងសូម្បីប្រឹងប្រែងសង្វាតធ្វើការងាររហូតកាលជានិច្ច ក៏មិនអាចបានអាហារបែបនេះ ប្រយោជន៍អ្វីដោយការទៅទីដទៃសម្រាប់យើងៗ នឹងរស់នៅក្នុងសម្នាក់របស់ពួកភិក្ខុនេះឯង" ។ លំដាប់នោះ ទើបពោលនឹងភិក្ខុទាំងនោះថា "ខ្ញុំនឹងធ្វើវត្តបដិបត្តិក្នុងសម្នាក់របស់ពួកលោកម្ចាស់" ។

ពួកភិក្ខុ. ល្អហើយ ឧបាសក ។

ទុគ្គតបុរសគេចពីពួកភិក្ខុ ទៅសួរទុក្ខធីតា

គេបានទៅកាន់ទីលំនៅរបស់ភិក្ខុទាំងនោះ ជាមួយនឹងភិក្ខុទាំងនោះ ធ្វើវត្តបដិបត្តិយ៉ាងល្អ ធ្វើឲ្យពួកភិក្ខុពេញចិត្តយ៉ាងពន់ពេក កន្លងទៅ ២ ខែ ប្រាថ្នានឹងទៅជួបធីតា ក៏គិតថា "បើយើងនឹងប្រាប់លាលោកម្ចាស់ទាំងឡាយៗ នឹងមិនបណ្ដោយយើងៗ នឹងមិនបាច់ប្រាប់ ទៅតែម្ដង" ដូច្នេះហើយ ក៏មិនប្រាប់

ដល់ភិក្ខុទាំងឡាយនោះ បានចៀសចេញទៅ ។ បានឮថា ការដែលគេមិនប្រាប់ពួកភិក្ខុ ចៀសចេញទៅប៉ុណ្ណោះ ជាសេចក្តីក្លាំងក្លាត់យ៉ាងធ្ងន់ ។ ក៏ក្នុងផ្លូវទៅរបស់បុរសនោះ មានដងព្រៃមួយ ។ ថ្ងៃទី ៧ ជាថ្ងៃរបស់ពួកចោរ ៥០០ នាក់ ដែលនៅក្នុងព្រៃនោះ ធ្វើការបន់ស្រន់ទេវតាថា "អ្នកណាចូលមកកាន់ដងព្រៃនេះ ពួកយើងនឹងសម្លាប់អ្នកនោះ ហើយធ្វើពលីកម្មដល់លោកដោយសាច់ និងឈាមរបស់អ្នកនោះ" ។ ព្រោះដូច្នោះ ក្នុងថ្ងៃទី ៧ មេចោរឡើងដើមឈើចាំមើលពួកមនុស្ស ឃើញបុរសនោះដើរមក បានឲ្យសញ្ញាដល់ពួកចោរ ។ មេចោរនោះ ដឹងថា បុរសនោះចូលដល់កណ្តាលព្រៃ ទើបព័ទ្ធចាប់គេចងចំណងយ៉ាងមាំ រួចបង្កាត់ភ្លើងដោយពំនូតភ្លើង ប្រមូលឧសមកដុតជាគំនរភ្លើងធំ សម្រួចឈើអណ្តោតទុក ។ បុរសនោះឃើញកិរិយារបស់ចោរទាំងនោះ ទើបសួរថា "នាយ ក្នុងទីនេះខ្ញុំមិនឃើញជ្រូក និងម្រឹគជាដើមឡើយ ហេតុអ្វី ពួកលោកធ្វើអណ្តោតនេះ" ។

ពួកចោរ. ពួកយើងនឹងសម្លាប់អ្នក ធ្វើពលីកម្មដល់ទេវតាដោយសាច់ និងឈាមរបស់អ្នក ។ បុរសនោះត្រូវមរណភ័យគម្រាម មិនគិតដល់ឧបការៈនៃភិក្ខុទាំងឡាយនោះ កាលនឹងរក្សាជីវិតរបស់ខ្លួនតែម្យ៉ាង ទើបពោលយ៉ាងនេះថា "នាយ ខ្ញុំជាមនុស្សស៊ីដែល ស៊ីកត្តដែលសល់ ឈ្មោះថា ជាមនុស្សស៊ីដែល មនុស្សក្រាឡកណ្តី ក៏ពួកលោកម្ចាស់សុទ្ធតែចេញបួសពីត្រកូលក្សត្រ ភិក្ខុ ៣១ រូប គង់នៅក្នុងទីឯណោះ ពួកលោកចូរសម្លាប់ភិក្ខុទាំងនោះ ហើយ

ធ្វើពលីកម្ម ទេវតារបស់ពួកលោកនឹងត្រេកអរយ៉ាងក្រៃលែង ។

## ពួកចោរនៅចាប់ពួកភិក្ខុដើម្បីធ្វើពលីកម្ម

ពួកចោរស្តាប់ពាក្យនោះហើយ គិតថា “គេនេះនិយាយត្រូវ ប្រយោជន៍អ្វីដោយមនុស្សក្រាឡកណ្តី ពួកយើងនឹងសម្លាប់ពួកក្សត្រធ្វើពលីកម្មវិញ” ដូច្នេះហើយ ទើបពោលថា “មកចុះ ចូរប្រាប់ទីលំនៅរបស់ពួកភិក្ខុទាំងនោះ” ហើយឲ្យទុគ្គតបុរសនោះឯងជាអ្នកនាំផ្លូវ ទៅដល់ទីនោះហើយ មិនឃើញពួកភិក្ខុនៅក្នុងវិហារ ទើបសួរថា “ពួកភិក្ខុទៅណា” គេដឹងកតិកាវត្តរបស់ពួកភិក្ខុទាំងនោះព្រោះនៅបានពីរខែ ទើបពោលយ៉ាងនេះថា “ពួកភិក្ខុគង់នៅក្នុងទីសម្រាកពេលថ្ងៃ និងពេលយប់របស់ខ្លួន ចូរលោកគោះរគាំងនោះ ពួកភិក្ខុនឹងមកប្រជុំគ្នាដោយសំឡេងរគាំង” ។ មេចោរក៏បានគោះរគាំង ។ ពួកភិក្ខុបានឮសំឡេងរគាំង គិតថា “អ្នកណាគោះរគាំងខុសវេលា សេចក្តីមិនសប្បាយនឹងមានដល់អ្នកណា” ដូច្នេះហើយ ទើបមកអង្គុយលើផែនថ្ម ដែលគេតាក់តែងទុកដោយលំដាប់ ត្រង់កណ្តាលវិហារ ។ ព្រះសង្ឃត្ថេរក្រឡេកមើលពួកចោរហើយ សួរថា “ពួកឧបាសក អ្នកណាគោះរគាំងនេះ” មេចោរឆ្លើយថា “គឺខ្ញុំលោកម្ចាស់”។

សង្ឃត្ថេរ. ព្រោះហេតុអ្វី ?

ចោរ. ពួកខ្ញុំបន់ស្រន់ទេវតាប្រចាំព្រៃទុក នឹងចាប់ភិក្ខុមួយរូបទៅ ដើម្បីត្រូវការធ្វើពលីកម្មដល់ទេវតានោះ ។ ព្រះមហាថេរៈ ស្តាប់ពាក្យនោះហើយទើបពោលនឹងពួកភិក្ខុថា “អ្នកមានអាយុ ធម្មតាកិច្ចកើតឡើងដល់ពួកប្អូនៗ

អ្នកជាបងត្រូវតែដោះស្រាយ ខ្ញុំនឹងលះជីវិតរបស់ខ្លួនដើម្បីពួកលោក ទៅជាមួយចោរទាំងនេះ សូមអន្តរាយកុំមានដល់លោកគ្រប់អង្គ ពួកលោកចូរជាអ្នកកុំប្រមាទ ធ្វើសមណធម៌ចុះ" ។ ព្រះអនុថេរៈពោលថា "លោកម្ចាស់ ធម្មតាកិច្ចរបស់បងប្រុស រមែងជាភាររបស់ប្អូនប្រុស ខ្ញុំនឹងទៅ សូមលោកទាំងឡាយចូរជាអ្នកមិនប្រមាទចុះ" ។ ដោយឧបាយនេះ ភិក្ខុសូម្បីទាំង ៣០ រូប ក្រោកឡើងនិយាយជាលំដាប់ថា "ខ្ញុំករុណា ខ្ញុំករុណា" ។ ដោយប្រការដូច្នេះ ភិក្ខុទាំងអស់មិនមែនជាបុត្ររបស់មាតាជាមួយគ្នាឡើយ មិនជាបុត្ររបស់បិតារួមគ្នាឡើយ ទាំងនៅមិនទាន់អស់រាគៈ តែក៏ព្រមលះបង់ជីវិតតាមលំដាប់ដើម្បីប្រយោជន៍ដល់ភិក្ខុដ៏សេស បណ្តាភិក្ខុទាំងនោះ សូម្បីភិក្ខុមួយរូប ឈ្មោះថាអាចពោលថា "លោកទៅចុះ មិនបានមានឡើយ" ។

## សង្កិច្ចសាមណេរព្រមប្រគល់ខ្លួនឱ្យដល់ចោរ

សង្កិច្ចសាមណេរ បានស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបពោលថា "ឈប់ចុះលោកម្ចាស់ ខ្ញុំនឹងលះបង់ជីវិតដើម្បីពួកលោក ទៅខ្លួនឯង" ។

ពួកភិក្ខុ. អ្នកមានអាយុ យើងទាំងអស់សូម្បីនឹងត្រូវសម្លាប់រួមគ្នា ក៏មិនព្រមលះបង់លោកតែមួយរូបឡើយ ។

សាមណេរ. ព្រោះហេតុអ្វី លោកម្ចាស់ ?

ពួកភិក្ខុ. អ្នកមានអាយុ អ្នកជាសាមណេររបស់ព្រះធម្មសេនាបតីសារីបុត្រ បើយើងលះបង់លោក ព្រះថេរៈនឹងតិះដៀលថា ពួកភិក្ខុនាំសាមណេរ

របស់យើងទៅប្រគល់ឲ្យដល់ពួកចោរ យើងមិនអាចនឹងដោះពាក្យតិះដៀលនោះបាន ព្រោះដូច្នោះ យើងមិនលះបង់លោកទេ ។

សាមណេរ. លោកម្ចាស់ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ជូនពួកលោកម្ចាស់ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍របស់ខ្ញុំករុណាក្តី ព្រះឧបជ្ឈាយ៍របស់ខ្ញុំ បញ្ជូនខ្ញុំករុណាមកជាមួយពួកលោកម្ចាស់ក្តី ទ្រង់បានឃើញហេតុនេះឯង ទើបបញ្ជូនមក ឈប់ចុះលោកម្ចាស់ ខ្ញុំករុណានឹងទៅតែឯង ។ សាមណេរនោះ ថ្វាយបង្គំភិក្ខុទាំង ៣០ រូបហើយ ពោលថា "លោកម្ចាស់ បើទោសរបស់ខ្ញុំព្រះករុណាមាន សូមលោកម្ចាស់អត់ទោស" ដូច្នេះហើយ ក៏ចៀសចេញទៅ ។ ការសង្វេគយ៉ាងខ្លាំង បានកើតឡើងដល់ពួកភិក្ខុ ភ្នែកពេញដោយទឹកភ្នែកសាច់បេះដូងក៏បានញ័ររន្ធត់ ។ ព្រះមហាថេរៈពោលនឹងពួកចោរថា "ឧបាសកទាំងឡាយ ក្មេងនេះឃើញពួកលោកបង្កាត់ភ្លើង ចាំងឈើអណ្តោត ក្រាលស្លឹកឈើនឹងខ្លាច លោកទាំងឡាយ ដាក់សាមណេរនេះទុកក្នុងទីដ៏សមគួរមួយហើយសឹមធ្វើកិច្ចទាំងពួងចុះ" ។

ក្នុងវេលាសម្រេចកិច្ច មេចោរហូតដាវដើរចូលទៅរកសាមណេរ ។ សាមណេរគង់ចូលឈាន មេចោរគ្រវីដាវដាក់ចុះត្រង់.កសាមណេរ ។ ដាវក៏ខ្ទូរចូលគ្នា ។ មេចោរនោះសម្គាល់ថា "យើងប្រហារមិនល្អ" ទើបពត់ដាវនោះឲ្យត្រង់ ហើយប្រហារម្តងទៀត ។ ដាវដូចជាស្លឹកត្នោតដែលមូរ បានរមូរដល់គល់ដង ។ ពិតណាស់ បុគ្គលសូម្បីនឹងយកភ្នំសិនេរុសង្កត់សាមណេរ

ក្នុងវេលានោះ ឈ្មោះថា ទីងឲ្យសាមណេរស្លាប់ មិនមានឡើយ នឹងពោល ទៅថ្វីត្រឹមតែការយកដាវសម្លាប់ឲ្យស្លាប់ ។ មេចោរឃើញបាដិហារិយ៍នោះ ហើយ គិតថា "កាលមុនដាវរបស់យើង រមែងកាត់សសរថ្ម ឬដង្គត់ឈើគគីរ ដូចកាត់ដើមចេក ឥឡូវនេះ ដាវរបស់យើងខ្ទមត្ពងហើយមួងទៀត ដូចជាស្លឹក ត្នោតដែលមូរ ដាវនេះ សូម្បីមិនមានចេតនានៅដឹងគុណរបស់សាមណេរនេះ តែយើងមានចេតនា នៅមិនដឹង" ។ មេចោរនោះ ទម្លាក់ដាវចុះលើផែនដី ក្រាបចុះទៀបបាទមូលរបស់សាមណេរនោះដោយទ្រូង កាលសួរថា "លោក ម្ចាស់ ពួកខ្ញុំចូលមកក្នុងព្រៃនេះ ព្រោះហេតុត្រូវការទ្រព្យ បុរសសូម្បីមាន ប្រមាណមួយពាន់ ឃើញពួកខ្ញុំអំពីចម្ងាយប៉ុណ្ណោះ រមែងញ័ររន្ធត់ មិនអាច និយាយ ២-៣ មាត់បាន ចំណែកលោកម្ចាស់ សូម្បីតែការភិតភ័យ ក៏មិន មាន មុខរបស់លោកម្ចាស់ ផូរផង់ដូចមាសក្នុងមាត់បាវ និងដូចផ្កាកណិការ ដែលរីកល្អ ព្រោះហេតុអ្វីហ្ន៎" ទើបពោលគាថានេះថា ៖

"សេចក្តីតក់ស្លុតមិនមានដល់លោក សេចក្តីខ្លាចក៏មិនមាន
វណ្ណៈស្រស់ថ្លាយ៉ាងក្រៃលែង ហេតុអ្វីទើបលោកមិនខ្សឹក-
ខ្សួល ព្រោះភ័យធំបែបនេះ ?

សាមណេរចេញចាកឈាន កាលនឹងសម្តែងធម៌ដល់មេចោរនោះ ទើប ពោលថា "លោកជាមេស្រុក ឈ្មោះថា អត្តភាពរបស់ព្រះខីណាស្រព រមែង ដូចជាភារៈ (របស់ធ្ងន់) ដម្កល់លើសីសៈ ព្រះខីណាស្រពនោះ កាលអត្តភាព

នោះបែបណាយទៅ រមែងត្រេកអរតែម្យ៉ាង រមែងមិនភ័យឡើយ" ដូច្នេះហើយ បានពោលគាថាទាំងនេះថា ៖

"លោកជាមេស្រុក ទុក្ខផ្លូវចិត្ត រមែងមិនមានដល់អ្នកមិនអាឡោះអាល័យ លោកអ្នកស្វែងរកគុណ អស់សំយោជនៈហើយ កន្លងភ័យគ្រប់យ៉ាងបាន តណ្ហាដែលនាំទៅកាន់ភព របស់ព្រះខីណាស្រពនោះអស់ហើយ លោកបានឃើញធម៌ហើយតាមសេចក្តីពិត ឬដោយជាក់ច្បាស់ ការស្លាប់ (របស់លោក) អស់ភ័យហើយ ដូចដាក់ភារៈចុះដូច្នោះ" ។

មេចោរសូមបព្វជ្ជាអំពីសាមណេរ

មេចោរនោះ ស្តាប់ពាក្យរបស់សាមណេរនោះហើយ ក្រឡេកមើលចោរ ៥០០ នាក់ និយាយថា "ពួកលោកនឹងធ្វើយ៉ាងណា ?"

ពួកចោរ. ចុះលោកវិញ ?

មេចោរ. កិច្ចក្នុងផ្ទះរបស់ខ្ញុំមិនមាន ព្រោះឃើញបាដិហារិយ៍បែបនេះ ខ្ញុំនឹងបួសក្នុងសម្នាក់លោកជាម្ចាស់ ។

ពួកចោរ. សូម្បីយើងនឹងធ្វើយ៉ាងនោះដែរ ។

មេចោរ. ប្រពៃហើយ ។

លំដាប់នោះ ចោរទាំង ៥០០ នាក់ ថ្វាយបង្គំសាមណេរ ហើយទើបសូមបព្វជ្ជា ។ សាមណេរនោះ កាត់សក់នឹងជាយសំពត់ដោយមុខដាវរបស់

ចោរទាំងនោះឯង ជ្រលក់ដោយដីក្រហម ឲ្យគ្រងសំពត់កាសាយៈទាំងនោះ ឲ្យតាំងនៅក្នុងសីល ១០ កាលនាំសាមណេរទាំងនោះទៅ គិតថា “បើយើងមិនទាន់ឃើញព្រះថេរៈទាំងឡាយជាមុន ហើយទៅ ព្រះថេរៈទាំងនោះ នឹងមិនអាចធ្វើសមណធម៌បាន ចាប់ផ្ដើមអំពីកាលដែលពួកចោរចាប់យើងទៅ បណ្ដាព្រះថេរៈទាំងនោះ សូម្បីមួយរូប ក៏មិនអាចទប់ទឹកភ្នែកបាន កាលព្រះថេរៈទាំងនោះ នៅគិតថា សាមណេរត្រូវចោរសម្លាប់ស្លាប់ហើយឬនៅហ្ន៎ កម្មដ្ឋាននឹងមិនតាំងមាំបាន ព្រោះដូច្នោះ យើងជួបពួកលោកហើយ សឹមទៅ” ។

## សាមណេរត្រឡប់ទៅជួបពួកភិក្ខុ

សាមណេរនោះ មានសាមណេរ ៥០០ រូបជាបរិវារទៅក្នុងទីនោះ កាលភិក្ខុទាំងនោះត្រឡប់បានការជូរចិត្ត ព្រោះឃើញខ្លួនហើយ ពោលថា “សង្កិច្ចៈ អ្នកសប្បុរស លោកបានជីវិតហើយឬ?” ទើបប្រាប់ថា “ពិតហើយ លោកម្ចាស់ ចោរទាំងនេះប្រាថ្នានឹងសម្លាប់ខ្ញុំ ករុណាឲ្យស្លាប់ក៏មិនអាចសម្លាប់បាន ជ្រះថ្លាក្នុងគុណរបស់ខ្ញុំករុណា ស្ដាប់ធម៌ហើយក៏សូមបួស ខ្ញុំករុណាមកដោយសង្ឃឹមថា ជួបលោកម្ចាស់ហើយ នឹងទៅ សូមលោកម្ចាស់ ចូរជាអ្នកកុំប្រមាទ ធ្វើសមណធម៌ចុះ ខ្ញុំករុណានឹងទៅកាន់សម្នាក់ព្រះសាស្ដាហើយ” ថ្វាយបង្គំភិក្ខុទាំងនោះហើយ នាំសាមណេរក្រៅនេះទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ កាលព្រះឧបជ្ឈាយ៍សួរថា “សង្កិច្ចៈ អ្នកបានអន្តេវាសិកហើយឬ” ទើបប្រាប់ថា “ករុណាលោកម្ចាស់” ដូច្នេះហើយ ក៏ប្រាប់រឿងនោះ ក៏កាលព្រះថេរៈពោលថា “សង្កិច្ចៈ

អ្នកចូរទៅគាល់ព្រះសាស្តា លោកទទួលថា "ករុណា លោកម្ចាស់" ហើយថ្វាយបង្គំព្រះថេរៈ នាំសាមណេរទាំងនោះទៅកាន់សម្នាក់ព្រះសាស្តា សូម្បីកាលព្រះសាស្តាត្រាស់សួរថា "សង្កិច្ចៈ អ្នកបានអន្តេវាសិកហើយឬ" ទើបក្រាបទូលរឿងនោះ ។

## អ្នកមានសីលប្រសើរជាងអ្នកទ្រុស្តសីល

ព្រះសាស្តាត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ បានឮថា យ៉ាងនោះឬ" កាលពួកភិក្ខុក្រាបទូលថា "ពិតយ៉ាងនោះ ព្រះអង្គ" ទើបត្រាស់ថា "ការតាំងនៅក្នុងសីល ហើយរស់នៅសូម្បីមួយថ្ងៃក្នុងកាលឥឡូវនេះ ប្រសើរជាងការដែលពួកលោកធ្វើចោរកម្ម តាំងនៅក្នុងភាពទ្រុស្តសីល រស់នៅសូម្បី ១០០ ឆ្នាំ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ទើបព្រះគាថានេះថា ៖

យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ
ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានដម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា ទុស្សីលោ (ទ្រុស្តសីល) គឺ មិនមានសីល ។

បទថា **សីលវន្តស្ស (របស់អ្នកមានសីល)** សេចក្តីថា ការរស់នៅសូម្បីមួយថ្ងៃ គឺ សូម្បីមួយគ្រារបស់អ្នកមានសីល មានឈាន ដោយឈានពីរប្រការប្រសើរ គឺ ខ្ពង់ខ្ពស់ជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកទ្រុស្តសីល ។

ក្នុងវេលាចប់ទេសនា ភិក្ខុទាំង ៥០០ រូបនោះ សម្រេចព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ធម្មទេសនាបានមានប្រយោជន៍ដល់មហាជនដែលប្រជុំគ្នា ដូច្នេះ ។

## ប្រវត្តិអធិមុត្តកសាមណេរ

សម័យតមក សង្កិច្ចៈបានឧបសម្បទាហើយ មានវស្សា ១០ ទើបទទួលសាមណេរ ។ ក៏សាមណេរនោះ ជាក្មួយរបស់លោកឈ្មោះ អធិមុត្តកសាម-ណេរ ។ គ្រានោះ ព្រះថេរៈហៅសាមណេរនោះមក ក្នុងវេលាមានអាយុគ្រប់បញ្ចូនទៅ ដោយពាក្យថា "យើងនឹងឧបសម្បទាលោក ចូរទៅសួរចំនួនអាយុក្នុងសម្នាក់ពួកញាតិ ហើយចូរមក" ។ អធិមុត្តកសាមណេរនោះ កាលទៅសម្នាក់របស់មាតាបិតា ត្រូវពួកចោរ ៥០០ នាក់ នឹងសម្លាប់ឲ្យស្លាប់ ដើម្បីត្រូវការពលីកម្មក្នុងរវាងផ្លូវ សម្តែងធម៌ដល់ចោរទាំងនោះ ជាអ្នកដែលពួកចោរមានចិត្តជ្រះថ្លា លែងឲ្យទៅដោយពាក្យថា "លោកកុំគប្បីប្រាប់ថា ពួកយើងមាននៅក្នុងទីនេះ ដល់អ្នកណាៗ" ឃើញ មាតាបិតាដើរឃ្លាងផ្លូវមកក៏រក្សាសច្ចៈ មិនប្រាប់ដល់មាតាបិតាទាំងនោះ សូម្បីដើរទៅផ្លូវនោះនុ៎ះឯង ។ កាលមាតាបិតានោះ ត្រូវពួកចោរបៀតបៀន ខ្សឹកខ្សួលនិយាយថា "ប្រហែល

ជាលោកចូលដៃជាមួយពួកចោរ ទើបមិនប្រាប់ដល់យើង” ចោរទាំងនោះបាន ឮសំឡេងហើយ ដឹងថា សាមណេរមិនប្រាប់ដល់មាតាបិតា ក៏មានចិត្តជ្រះថ្លា សូមបព្វជ្ជា ។ សូម្បីអធិមុត្តកសាមណេរនោះ ក៏ញ៉ាំងចោរទាំងអស់នោះឲ្យ បួសហើយ ដូចសង្កិច្ចសាមណេរដែរ នាំមកកាន់សម្នាក់ព្រះឧបជ្ឈាយ៍ ត្រូវ ព្រះឧបជ្ឈាយ៍នោះបញ្ជូនទៅកាន់សម្នាក់ព្រះសាស្តា នាំភិក្ខុទាំងនោះទៅ បាន ក្រាបទូលរឿងនោះដល់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់សួរថា “ម្នាលភិក្ខុ ទាំងឡាយ ឮថាយ៉ាងនោះឬ” កាលពួកភិក្ខុក្រាបទូលថា “ព្រះករុណា ព្រះអង្គ” កាលទ្រង់បន្តអនុសន្ធិសម្តែងធម៌ដោយន័យមុននោះឯង ទើបត្រាស់ ព្រះគាថា នេះថា ៖

បុគ្គលណាទ្រុស្តសីល មានចិត្តមិនតាំងមាំ សូម្បីរស់នៅ ១០០ ឆ្នាំ ការរស់នៅតែមួយថ្ងៃរបស់លោកអ្នកមានសីល មានឈាន ប្រសើរ ជាង (ការរស់នៅរបស់បុគ្គលនោះ) ។

រឿងអធិមុត្តកសាមណេរនេះ ខ្ញុំក៏ពោលទុកហើយ ដោយព្រះគាថានេះ ដូចគ្នា ។

ចប់ រឿងសង្កិច្ចសាមណេរ

# ១០. រឿងព្រះខាណុកោណ្ឌញ្ញៈ

*ព្រះសាស្ដា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះខាណុកោណ្ឌញ្ញត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា* ***យោ ច វស្សសតំ ជីវេ*** *(សូម្បីរស់នៅ ១០០ ឆ្នាំ) ជាដើម ។*

ព្រះថេរៈគង់ចូលឈាន ចោរយកបង្វេចទ្រព្យដាក់លើមិនដឹង

*បានឮថា ព្រះថេរៈនោះរៀនកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដា នៅក្នុងព្រៃសម្រេចព្រះអរហត្តហើយ គិតថា "នឹងទូលព្រះសាស្ដា" កាលមកអំពីទីនោះនឿយហត់ក្នុងរវាងផ្លូវ គេចចេញពីផ្លូវ គង់ចូលឈានលើខ្នងថ្មមួយផ្ទាំង ។ គ្រានោះ ចោរ ៥០០ នាក់ ប្លន់ស្រុកមួយកន្លែង ហើយចងបង្វេចទ្រព្យតាមសមគួរដល់កម្លាំងរបស់ខ្លួន យកសីសៈទូលដើរទៅ ពេលដើរទៅឆ្ងាយ ក៏នឿយហត់ គិតថា "យើងមកឆ្ងាយហើយ នឹងសម្រាកឲ្យបាត់ហត់លើផ្ទាំងថ្មនេះ" ចេញពីផ្លូវទៅកាន់ទីជិតផ្ទាំងថ្មនោះ សូម្បីឃើញព្រះថេរៈហើយ ក៏មានសេចក្ដីសម្គាល់ថា "នេះជាដង្កត់ឈើ" ។ លំដាប់នោះ ចោរម្នាក់ទុកបង្វេចរបស់លើសីសៈព្រះថេរៈ ។ ចោរដទៃៗ ក៏ដាក់បង្វេចទ្រព្យផ្អែកព្រះថេរៈ ។ ដោយប្រការដូច្នេះ ចោរសូម្បីទាំង ៥០០ នាក់ យកបង្វេចទ្រព្យ ៥០០ ដាក់ព័ទ្ធជុំវិញព្រះថេរៈ សូម្បីខ្លួនឯងក៏ដេកលក់ ភ្ញាក់ក្នុងវេលាអរុណរះ ប្រវាយកបង្វេចរៀងៗ ខ្លួន បានឃើញព្រះថេរៈ ក៏បម្រុងនឹងរត់ចេញទៅ ដោយសម្គាល់*

ថា "ជាអមនុស្ស" ។ ខណៈនោះ ព្រះថេរៈពោលនឹងពួកចោរនោះថា "កុំខ្លាចឡើយឧបាសក អាត្មាជាបព្វជិត" ។ ចោរទាំងនោះ ក្រាបចុះទៀបបាទមូលរបស់ព្រះថេរៈ ឲ្យព្រះថេរៈអត់ទោស ដោយពាក្យថា "មេត្តាអត់ទោសផងចុះលោកម្ចាស់ ពួកខ្ញុំបានសម្គាល់ថា ជង្គត់ឈើ" កាលមេចោរប្រាប់ថា "យើងនឹងបួសក្នុងសម្នាក់លោកម្ចាស់" ពួកចោរដ៏សេសក៏ពោលថា "សូម្បីពួកយើងក៏នឹងបួស" មានឆន្ទៈដូចគ្នាទាំងអស់ ក៏សូមបព្វជ្ជានឹងព្រះថេរៈ ។ ព្រះថេរៈឲ្យចោរទាំងអស់នោះបួស ដូចសទ្ធិវិហារិកសាមណេរ ។ ចាប់តាំងអំពីនោះមក ព្រះថេរៈប្រាកដឈ្មោះថា **"ខាណុកោណ្ឌញ្ញៈ"** ។ លោកបានទៅកាន់សម្នាក់ព្រះសាស្តាព្រមជាមួយភិក្ខុទាំងនោះ កាលព្រះសាស្តាត្រាស់សួរថា "កោណ្ឌញ្ញៈអ្នកបានអន្តេវាសិកហើយឬ" ទើបក្រាបទូលរឿងនោះ ។

បុគ្គលមានបញ្ញា ប្រសើរជាងបុគ្គលអត់បញ្ញា

ព្រះសាស្តាត្រាស់សួរថា "ម្នាលភិក្ខុទាំងឡាយ ឮថាយ៉ាងនោះឬ" កាលភិក្ខុទាំងនោះក្រាបទូលថា "ព្រះករុណា ព្រះអង្គ ពួកខ្ញុំព្រះអង្គមិនធ្លាប់ឃើញអានុភាពបែបនោះរបស់អ្នកដទៃឡើយ ព្រោះដូច្នោះ ពួកខ្ញុំព្រះអង្គនឹងបួស" ទើបត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ការរស់នៅសូម្បីមួយថ្ងៃរបស់ពួកអ្នកដែលប្រព្រឹត្តក្នុងបញ្ញាសម្បទាដូចក្នុងកាលឥឡូវនេះ ប្រសើរជាង ការតាំងនៅក្នុងកម្មរបស់អ្នកអត់បញ្ញា សូម្បីរស់នៅ ១០០ ឆ្នាំ" ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

*យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ*
*ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។*

*បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា*
*មានចិត្តមិនបានដម្កល់ខ្ជាប់ ការរស់នៅត្រឹមតែមួយថ្ងៃ*
*របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា*
*ជាប្រក្រតី ប្រសើរជាង ។*

អធិប្បាយគាថា

*បណ្តាបទទាំងនោះ បទថា ទុប្បញ្ញោ (មិនមានបញ្ញា) សេចក្តីថា អ្នកគ្មានបញ្ញា ។ បទថា បញ្ញវន្តស្ស (របស់អ្នកមានបញ្ញា) សេចក្តីថា អ្នកមានបញ្ញា ។ ពាក្យដ៏សេសដូចគ្នានឹងពាក្យមុននោះឯង ។*

*ក្នុងកាលចប់ព្រះធម៌ទេសនា ភិក្ខុទាំង ៥០០ រូប សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ព្រះធម្មទេសនាបានមានប្រយោជន៍ដល់មហាជនដែលមកប្រជុំគ្នា ដូច្នេះឯង ។*

ចប់ រឿងខាណុកោណ្ឌញ្ញត្ថេរ

# ១១. រឿងព្រះសប្បទាសត្ថេរ

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះសប្បទាសត្ថេរ ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** (សូម្បីរស់នៅ ១០០ ឆ្នាំ) ជាដើម ។*

## ព្រះថេរៈឱ្យពស់ខាំខ្លួន

*បានឮថា កុលបុត្រម្នាក់ក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ ក៏បានបព្វជ្ជាឧបសម្បទា ដោយសម័យតមក មានសេចក្តីអផ្សុក ទើបគិតថា "ឈ្មោះថា ភាវៈនៃគ្រហស្ថមិនគួរដល់កុលបុត្រដូចជាយើង សូម្បីតាំងនៅក្នុងបព្វជ្ជាហើយស្លាប់ទៅ ជាការល្អរបស់យើង" ដូច្នេះហើយ ក៏ត្រាច់រកឧបាយដើម្បីសម្លាប់ខ្លួន ។ ក្រោយមក ថ្ងៃមួយភិក្ខុទាំងឡាយស្រង់ទឹកអំពីព្រលឹម ធ្វើភត្តកិច្ចស្រេចហើយទៅកាន់វិហារ បានឃើញពស់ក្នុងរោងភ្លើង ទើបចាប់ពស់នោះទុកក្នុងក្អមមួយ បិទគម្រប ហើយកាន់ចេញទៅក្រៅវិហារ ។ ចំណែកភិក្ខុដែលអផ្សុក ធ្វើភត្តកិច្ចហើយ ដើរមកឃើញភិក្ខុទាំងនោះ ទើបសួរថា "នេះអ្វី? អ្នកមានអាយុ" កាលពួកភិក្ខុប្រាប់ថា "ពស់ អ្នកមានអាយុ" ទើបសួរថា "នឹងធ្វើដូចម្តេចដោយពស់នេះ" ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះថា យើងនឹងបោះចោល ក៏គិតថា "យើងនឹងឲ្យពស់នេះខាំឲ្យស្លាប់" ទើបពោលថា "នាំមកចុះ ខ្ញុំនឹងបោះចោល" ទទួលក្អមអំពីដៃភិក្ខុទាំងនោះហើយ*

អន្ទុយនៅក្នុងទីសមគួរមួយ ក៏ឲ្យពស់នោះខាំខ្លួន ។ ពស់មិនប្រាថ្នានឹងខាំ ។ ភិក្ខុនោះយកដៃដាក់ចូលក្នុងក្អម ហើយកូរខាងនេះខាងនោះ ហែកមាត់ពស់ ហើយស៊កម្រាមដៃចូលទៅ ។ ពស់នៅតែមិនខាំលោក ។ លោកគិតថា "ពស់នេះ មិនមែនពស់មានពិស ជាពស់ផ្ទះ" ទើបបោះពស់នោះចោល ហើយបានទៅកាន់វិហារ ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងលោកថា "អ្នកមានអាយុ លោកចោលពស់ហើយឬ?" ។

ភិក្ខុនឿយណាយ. អ្នកមានអាយុ នោះមិនមែនពស់ (ពិស) ទេ នុ៎ះជាពស់ផ្ទះ ។

ភិក្ខុ. អ្នកមានអាយុ ពស់ពិសដោយពិត វាបើកពពារយ៉ាងធំ បញ្ចេញសំឡេងសុសុ ពួកខ្ញុំករុណាចាប់បានដោយលំបាក ព្រោះហេតុអ្វី ទើបលោកពោលយ៉ាងនេះ ?

ភិក្ខុនឿយណាយ. អ្នកមានអាយុ ខ្ញុំឲ្យវាខាំអវយវៈខ្លះ ស៊កម្រាមទៅក្នុងមាត់ខ្លះ ក៏មិនអាចឲ្យវាខាំបាន ។ ពួកភិក្ខុស្តាប់ពាក្យនោះហើយ បាននៅស្ងៀម ។

ព្រះថេរៈសម្រេចព្រះអរហត្ត មានឈ្មោះថា សប្បទាសៈ

ខាងក្រោយមកថ្ងៃមួយ ជាងកោរសក់កាន់កាំបិតកោរ ២-៣ ទៅកាន់វិហារ ដាក់កាំបិតកោរមួយទុកលើផែនដី យកកាំបិតកោរមួយ កោរសក់របស់ភិក្ខុទាំងឡាយ ។ ភិក្ខុអផ្សុកនោះ កាន់យកកាំបិតកោរដែលគេទុកលើផែនដី

ហើយគិតថា "នឹងកាត់.កដោយកាំបិតកោរនេះឲ្យស្លាប់" ទើបឈរដាក់.កត្រង់ដើមឈើមួយដើម ហើយដាក់កាំបិតកោរត្រង់បំពង់.ក ពិចារណាដល់សីលរបស់ខ្លួន ចាប់តាំងអំពីការឧបសម្បទា បានឃើញសីលគ្មានមន្ទិល ដូចដួងច័ន្ទដែលប្រាសចាកមន្ទិល និងដូចដួងកែវមណីដែលខាត់ល្អហើយ ។ កាលលោកពិចារណាមើលសីលនោះ បីតិកើតឡើងផ្សាយពេញសរីរៈ ។ លោកគ្របសង្កត់បីតិបានហើយ ចម្រើនវិបស្សនាសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ទើបកាន់យកកាំបិតកោរចូលទៅកណ្ដាលវិហារ ។ លំដាប់នោះ ភិក្ខុទាំងឡាយសួរលោកថា "អ្នកមានអាយុ លោកទៅណា" ។

ភិក្ខុអផ្សុក. អ្នកមានអាយុ ខ្ញុំទៅដោយគិតថា "នឹងយកកាំបិតកោរនេះកាត់បំពង់.កឲ្យស្លាប់ ។

ភិក្ខុ. បើដូច្នោះ ព្រោះហេតុអ្វីទើបលោកមិនស្លាប់ ?

ភិក្ខុអផ្សុក. ឥឡូវនេះ ខ្ញុំជាអ្នកមិនគួរនាំសស្ត្រាមកទេ ព្រោះខ្ញុំគិតថានឹងកាត់បំពង់.កដោយកាំបិតកោរនេះ តែកាត់កិលេសចេញអស់ដោយកាំបិតកោរ គឺ ញាណ ។

ពួកភិក្ខុក្រាបទូលដល់ព្រះសាស្ដាថា "ភិក្ខុនេះ ព្យាករណ៍ព្រះអរហត្តដោយពាក្យមិនពិត" ។ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ស្ដាប់ពាក្យភិក្ខុទាំងនោះហើយ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះខីណាស្រព រមែងមិនផ្ដាច់បង់ជីវិតខ្លួន ដោយដៃខ្លួនឯងឡើយ" ។

ភិក្ខុ. បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គត្រាស់នឹងភិក្ខុនេះថា ជាព្រះខីណាស្រព ក៏ភិក្ខុនេះសំបូរដោយឧបនិស្ស័យនៃព្រះអរហត្តយ៉ាងនេះ ហេតុអ្វីទើបអផ្សុក អ្វីជាហេតុនៃឧបនិស្ស័យនៃព្រះអរហត្តរបស់ភិក្ខុនោះ ហេតុអ្វីពស់នោះ ទើបមិនខាំភិក្ខុនោះ ។

ព្រះសាស្តា. ម្នាលភិក្ខុទាំងឡាយ ពស់នោះជាទាសៈរបស់ភិក្ខុនេះក្នុងអត្តភាពទី ៣ អំពីអត្តភាពនេះ វាមិនអាចខាំសរីរៈរបស់ម្ចាស់របស់ខ្លួនទេ ។ ព្រះសាស្តាទ្រង់ប្រាប់ហេតុមួយដល់ភិក្ខុទាំងនោះ ដោយប្រការដូច្នេះមុន ។ តាំងពីនោះមក ភិក្ខុនោះបានឈ្មោះថា **សប្បទាសៈ** ។

បុព្វកម្មរបស់ព្រះសប្បទាសត្ថេរ

ដូចបានស្តាប់មក ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ បុត្ររបស់គហបតីម្នាក់ ស្តាប់ធម៌របស់ព្រះសាស្តាហើយ កើតសេចក្តីសង្វេគ ទើបបព្វជ្ជាបានឧបសម្បទាហើយ សម័យក្រោយមក កាលសេចក្តីធុញទ្រាន់កើតឡើងទើបប្រាប់ដល់ភិក្ខុជាសំឡាញ់មួយរូប ។ ភិក្ខុជាសំឡាញ់នោះ ពោលទោសក្នុងភាពជាគ្រហស្ថដល់លោករឿយៗ ។ ភិក្ខុនោះស្តាប់ពាក្យនោះហើយ ក៏ត្រេកអរក្រៃលែងក្នុងព្រះសាសនា ទើបទៅអង្គុយដុសខាត់សមណបរិក្ខារទាំងឡាយដែលមន្ទិលចាប់ក្នុងវេលាដែលមិនត្រេកអរក្នុងកាលមុន ឲ្យជ្រះមន្ទិលជិតមាត់ស្រះមួយកន្លែង ។ ចំណែកសំឡាញ់របស់ភិក្ខុនោះ អង្គុយក្នុងទីជិតនោះដែរ ។ លំដាប់នោះ ភិក្ខុនោះពោលនឹងសំឡាញ់នោះយ៉ាងនេះថា "អ្នក

មានអាយុ បើខ្ញុំសឹក ប្រាថ្នានឹងប្រគេនបរិក្ខារទាំងនេះដល់លោក ។ សំឡាញ់នោះកើតលោភៈឡើង គិតថា “យើងនឹងត្រូវការអ្វីដោយភិក្ខុនេះនៅបួស ឬសឹកឥឡូវនេះ យើងនឹងញុាំងបរិក្ខារទាំងឡាយឲ្យវិនាស” ។ តាំងពីពេលនោះមកសំឡាញ់នោះពោលពាក្យជាដើមថា “អ្នកមានអាយុ ឥឡូវនេះនឹងប្រយោជន៍អ្វីដោយជីវិតរបស់ពួកយើង ដែលមានដៃកាន់អំបែង ត្រាច់ទៅដើម្បីដុំបាយក្នុងត្រកូលអ្នកដទៃ ទាំងមិនបានធ្វើការសន្ទនាប្រាស្រ័យជាមួយបុត្រ និងភរិយា” ដូច្នេះហើយ ក៏ពោលគុណនៃភាពជាគ្រហស្ថ ។ ភិក្ខុនោះ ស្តាប់ពាក្យរបស់សំឡាញ់នោះហើយ ក៏កើតអផ្សុកទៀត គិតថា “សំឡាញ់នេះ កាលយើងពោលថា “ខ្ញុំអផ្សុក” ក៏ពោលទោសក្នុងភាពជាគ្រហស្ថ” ឥឡូវនេះ ពោលដល់គុណរឿយៗ “តើហេតុអ្វីហ្ន៎” ក៏ដឹងថា ព្រោះសេចក្តីលោភក្នុងសមណបរិក្ខារទាំងនេះ ទើបប្រែចិត្តរបស់ខ្លួនដោយខ្លួនឯង ។ ព្រោះភិក្ខុមួយរូបធ្វើឲ្យខ្លួនអផ្សុកហើយ ក្នុងកាលនៃព្រះពុទ្ធកស្សបៈ ។ ឥឡូវនេះ ការធុញទ្រាន់ទើបកើតឡើងដល់ភិក្ខុនោះ ដោយប្រការដូច្នេះ ។ ក៏សមណធម៌ណា ដែលភិក្ខុនោះបំពេញមកអស់ពីរម៉ឺនឆ្នាំក្នុងកាលនោះ សមណធម៌នោះ បានជាឧបនិស្ស័យនៃព្រះអរហត្តរបស់ភិក្ខុនោះ ក្នុងកាលឥឡូវនេះ ។

ជីវិតរបស់អ្នកប្រារព្ធសេចក្តីព្យាយាមមួយថ្ងៃប្រសើរ

ភិក្ខុទាំងនោះស្តាប់សេចក្តីនេះ អំពីព្រះមានព្រះភាគជាម្ចាស់ហើយ ទើបទូលសួរតទៅទៀតថា “បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ភិក្ខុនេះ ឈរដាក់

កាំបិតកោរត្រង់គល់.កសោះ ក៏សម្រេចព្រះអរហត្ត ព្រះអរហត្តមគ្គកើតឡើង បានដោយខណៈត្រឹមប៉ុណ្ណោះឬ” ព្រះសាស្ដាត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ពិតហើយ កាលភិក្ខុអ្នកប្រារព្ធសេចក្ដីព្យាយាម លើកជើងឡើងដាក់លើផែនដី កាលជើងមិនទាន់ដល់ផែនដីនៅឡើយ ព្រះអរហត្តមគ្គក៏បានកើតឡើង ពិតហើយ ការរស់នៅសូម្បីត្រឹមមួយខណៈរបស់លោកអ្នកប្រារព្ធសេចក្ដីព្យាយាម ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់បុគ្គលអ្នកខ្ជិលច្រអូស ដូច្នេះហើយ កាលទីងទ្រង់បន្តអនុសន្ធិដើម្បីសម្ដែងធម៌ បានត្រាស់ព្រះគាថានេះ ៖

យោ ច វស្សសតំ ជីវេ កុសីតោ ហីនវីរិយោ
ឯកាហំ ជីវិតំ សេយ្យោ វិរិយំ អារភតោ ទឡ្ហំ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ ជាមនុស្សមានចិត្តធ្លុលងប់
ក្នុងអកុសលវិតក្កៈ មានព្យាយាមថោកទាប ការរស់នៅ
សូម្បីតែមួយថ្ងៃ របស់លោកដែលប្រារព្ធសេចក្ដីព្យាយាម
មាំមួន ប្រសើរជាង ។

អធិប្បាយគាថា

បណ្ដាបទទាំងនោះ បទថា កុសីតោ (ខ្ជិលច្រអូស) បានដល់ បុគ្គលអ្នកញ៉ាំងវេលាឲ្យកន្លងទៅ ដោយវិតក្កៈ ៣ មានកាមវិតក្កៈជាដើម ។ បទថា ហីនវីរិយោ (មានសេចក្ដីព្យាយាមថោកទាប) គឺ គ្មានសេចក្ដីព្យាយាម ។ បទថា វិរិយំ អារភតោ ទឡ្ហំ (អ្នកប្រារព្ធសេចក្ដីព្យាយាមមុតមាំ) សេចក្ដីថា

អ្នកប្រារព្ធសេចក្តីព្យាយាមមាំទាំ ដែលអាចញ៉ាំងឈាន ២ ប្រការឲ្យកើត ។ ពាក្យដ៏សេស ដូចគ្នានឹងពាក្យមុននោះឯង ។

ក្នុងកាលចប់ទេសនា ជនជាច្រើនសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

ចប់ រឿងព្រះសប្បទាសត្ថេរ

# ១២. រឿងព្រះនាងបដាចារា

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធ ព្រះនាងបដា-ចារាថេរី ត្រាស់ព្រះធម្មទេសនានេះថា* ***យោ ច វស្សសតំ ជីវេ (ជនណា... គប្បីរស់នៅ ១០០ ឆ្នាំ)*** *ជាដើម ។*

*នាងបដាចាររស់នៅជាមួយអ្នកបម្រើ*

*ដូចបានស្តាប់មក នាងបដាចារានោះ បានជាធីតារបស់សេដ្ឋីអ្នកមានសម្បត្តិ ៤០ កោដិ ក្នុងក្រុងសាវត្ថី មានរូបស្អាត ។ ក្នុងវេលានាងមានអាយុ ១៦ ឆ្នាំ មាតាបិតាកាលនឹងរក្សា បានឲ្យនាងនៅលើផ្ទៃប្រាសាទ ៧ ជាន់ ។ សូម្បីដូច្នោះ នាងក៏នៅតែប្រព្រឹត្តខុសប្រពៃណីនឹងអ្នកបម្រើម្នាក់ ។ គ្រានោះ មាតាបិតារបស់នាងលើកនាងឲ្យដល់បុរសកំលោះម្នាក់ ក្នុងត្រកូលដែលមានជាតិស្មើគ្នា បានកំណត់ថ្ងៃវិវាហៈ ។ កាលថ្ងៃវិវាហៈនោះជិតមកដល់ហើយ ទើបនាងពោលនឹងអ្នកបម្រើនោះថា “បានឮថា មាតាបិតាខ្ញុំ បានលើកខ្ញុំឲ្យដល់ត្រកូលឯណោះ ក្នុងកាលដែលខ្ញុំទៅកាន់ត្រកូលខាងប្តី អ្នកសូម្បីយកបណ្ណាការមកដើម្បីខ្ញុំ ក៏នឹងមិនបានចូលទៅក្នុងទីនោះ បើអ្នកស្រឡាញ់ខ្ញុំ ចូរនាំខ្ញុំចាកចេញទៅដោយផ្លូវណាមួយ ក្នុងកាលឥឡូវនេះ” ។ អ្នកបម្រើនោះទទួលថា “ល្អហើយ នាងដ៏ចម្រើន” ហើយពោលថា “បើដូច្នោះ ក្នុងថ្ងៃស្អែកខ្ញុំនឹងឈរចាំនាងនៅក្នុងទីឈ្មោះឯណោះ នៃទ្វារនគរអំពីព្រឹក នាងគប្បីចេញ*

ទៅដោយឧបាយយ៉ាងណាទីមួយ ហើយមកក្នុងទីនោះ" លុះដល់ថ្ងៃទី ២ ក៏បានឈរនៅក្នុងទីសន្យាគ្នា ។

ចំណែកធីតាសេដ្ឋីនោះ ស្លៀកសំពត់ចាស់ៗ រំសាយសក់ យកកន្ទក់លាបសរីរៈ កាន់ក្អមទឹកចេញអំពីផ្ទះ ដូចជាដើរទៅជាមួយពួកទាសី បានទៅកាន់ទីនោះអំពីព្រលឹម ។ បុរសអ្នកបម្រើនោះនាំនាងទៅឆ្ងាយហើយ សម្រេចការអាស្រ័យនៅក្នុងស្រុកមួយ ភ្ជួរស្រែនៅក្នុងព្រៃ បាននាំឧស និងបន្លែជាដើមមក ។ ឯធីតាសេដ្ឋីនោះវិញ យកក្អមទឹកមក ហើយធ្វើកិច្ចមានការបុកស្រូវ និងដាំបាយជាដើមដោយដៃខ្លួនឯង បានសោយផលនៃសេចក្តីអាក្រក់របស់ខ្លួន ។ គ្រានោះ សត្វកើតក្នុងគភ៌បានតាំងឡើងក្នុងផ្ទៃរបស់នាង ។ នាងមានគភ៌ចាស់ហើយ ទើបអង្វរស្វាមីថា "នរណាៗ អ្នកមានឧបការៈរបស់យើង មិនមានក្នុងទីនេះ ធម្មតាមាតាបិតាជាអ្នកមានចិត្តទន់ភ្លន់ក្នុងបុត្រទាំងឡាយ លោកចូរនាំខ្ញុំទៅកាន់សម្នាក់របស់ពួកលោកចុះ ខ្ញុំនឹងប្រសូតបុត្រក្នុងទីនោះ" ។ ស្វាមីនោះឃាត់ អង្វរថា "នាងដ៏ចម្រើន នាងនិយាយអ្វី? មាតាបិតារបស់នាងឃើញខ្ញុំហើយ គប្បីធ្វើទោសមានប្រការផ្សេងៗ ខ្ញុំមិនអាចទៅក្នុងទីនោះបានឡើយ" ។ នាងសូម្បីអង្វរហើយអង្វរទៀត កាលមិនបានការយល់ព្រម ក្នុងវេលាដែលស្វាមីនោះទៅព្រៃ ទើបប្រាប់មនុស្សដែលនៅជិតខាងថា "បើគាត់មកមិនឃើញខ្ញុំ នឹងសួរថា ខ្ញុំទៅណា? ពួកលោកគប្បីប្រាប់ថា ខ្ញុំទៅកាន់ផ្ទះនៃត្រកូលរបស់ខ្លួន" ដូច្នេះហើយ ក៏បិទទ្វារផ្ទះចេញទៅ ។

ចំណែកស្វាមីនោះមកហើយ មិនឃើញភរិយានោះ ទើបសួរមនុស្ស ដែលស្និទ្ធស្នាល ស្តាប់រឿងនោះហើយ ក៏រត់តាមទៅ ដោយគិតថា "នឹងឲ្យនាងត្រឡប់" ជួបនាងហើយ សូម្បីនឹងអង្វរដោយប្រការផ្សេងៗ ក៏មិនអាចឲ្យនាងត្រឡប់បាន ។ ខណៈនោះ ខ្យល់កម្មជ្ជវាតរបស់នាងក៏កម្រើកហើយក្នុងទីកន្លែងមួយ ។ នាងចូលទៅក្នុងចន្លោះគុម្ពឈើមួយគុម្ព និយាយថា "នាយ ខ្យល់កម្មជ្ជវាតរបស់ខ្ញុំកម្រើកហើយៗ ដេកបំរាស់ទន្ទៀលនៅលើផែនដី ប្រសូតទារកដោយលំបាក ហើយគិតថា "យើងទៅកាន់ផ្ទះនៃត្រកូលដើម្បីប្រយោជន៍ណា ប្រយោជន៍នោះបានសម្រេចហើយ" ទើបត្រឡប់មកផ្ទះវិញជាមួយស្វាមី សម្រេចការនៅជាមួយគ្នាទៀត ។

សម័យក្រោយមក គភ៌របស់នាងតាំងឡើងទៀត ។ កាលនាងមានគភ៌ចាស់ហើយ ទើបអង្វរស្វាមីដោយន័យមុននោះឯង កាលមិនបានការយល់ព្រមទើបបីបុត្រចៀសចេញទៅយ៉ាងនោះឯង សូម្បីត្រូវស្វាមីនោះរត់តាមទៅជួបហើយ ក៏មិនប្រាថ្នានឹងត្រឡប់ ។ គ្រានោះ កាលជនទាំងពីរនោះកំពុងដើរទៅ មហាមេឃដែលមិនមែនជារដូវកាលបានកើតឡើង ។ ផ្ទៃមេឃ បានមានធារទឹកធ្លាក់ចុះមិនដាច់ ផ្លេកបន្ទោរតាំងឡើងភ្លឺបភ្លែតដោយជុំវិញ ដូចជានឹងទម្លាយចុះដោយសំឡេងគ្រហឹម ។ ក្នុងខណៈនោះ ខ្យល់កម្មជ្ជវាតរបស់នាងក៏បានកម្រើក ។ នាងហៅស្វាមីមកពោលថា "នាយ ខ្យល់កម្មជ្ជវាតរបស់ខ្ញុំកម្រើកហើយ ខ្ញុំមិនអាចនឹងទ្រាំបានទេ លោកចូរដឹងស្ថានទីដែលភ្លៀងមិនធ្លាក់ត្រូវខ្ញុំ

ចុះ” ។ ស្វាមីនោះ មានកាំបិតនៅក្នុងដៃ ពិនិត្យមើលខាងនោះខាងនេះ ឃើញគុម្ពឈើដែលដុះនៅលើដំបូកមួយ ប្រារព្ធនឹងកាប់ ។ គ្រានោះ អាសិរពិសមានពិសដ៏ពន្លឹកវារចេញអំពីដំបូក ខាំគេក្នុងខណៈនោះឯង សរីរៈរបស់គេមានពណ៌ខៀវដូចត្រូវអណ្ដាតភ្លើងឆេះ ដែលតាំងឡើងខាងក្នុង ដួលចុះក្នុងទីនោះឯង ។ ចំណែកកិរិយាសោយទុក្ខយ៉ាងខ្លាំង រង់ចាំមើលផ្លូវមករបស់គេក៏មិនបានឃើញគេឡើយ ទើបប្រសូតបុត្រម្នាក់ទៀត ។ ទារកទាំងពីរអត់ធន់នឹងកម្លាំងនៃខ្យល់ និងភ្លៀងមិនបាន ក៏ស្រែកយំទ្រហឹង ។ នាងយកទារកសូម្បីទាំងពីរនាក់នោះទុកត្រង់ចន្លោះពោះ ឈរច្រត់ផែនដីដោយជង្គង់ និងដៃទាំងពីរ ឲ្យរាត្រីកន្លងទៅហើយ ។ សរីរៈទាំងអស់មានពណ៌ដូចជាពណ៌ស្លឹកឈើលឿង ដូចមិនមានឈាម ។ កាលអរុណរះ នាងបីបុត្រម្នាក់ដែលមានពណ៌ដូចដុំសាច់ដោយចង្កេះ កាន់ដៃបុត្រក្រៅនេះ (កូនបង) ពោលថា “មកចុះកូន បិតាកូនទៅតាមផ្លូវនេះ” ដូច្នេះហើយ ក៏ដើរទៅតាមផ្លូវដែលស្វាមីទៅ ឃើញស្វាមីនោះដួលស្លាប់លើដំបូកមានពណ៌ខៀវ ខ្លួនរឡើងរឹង ក៏ស្រែកយំរំពងថា “ព្រោះអាស្រ័យយើង ទើបស្វាមីរបស់យើងស្លាប់ត្រង់ទីនេះ” ដូច្នេះហើយ ក៏ដើរទៅ ។ នាងឃើញស្ទឹងអចិរវតី ពេញប្រៀបដោយទឹកមានប្រ-មាណត្រឹមជង្គង់ មានប្រមាណត្រឹមដោះ ព្រោះភ្លៀងធ្លាក់រហូតមួយយប់ទល់ភ្លឺ មិនអាចចុះទឹកជាមួយនឹងទារកទាំងពីរនាក់បាន ព្រោះខ្លួនមានសភាពទន់ខ្សោយ ទើបដាក់បុត្រច្បងទុកត្រង់ត្រើយខាងអាយ បីបុត្រតូចទៅត្រើយនាយ

ក្រោលកំណាត់ឈើទុកឲ្យបុត្រដេកហើយ គិតថា "ទីងទៅទីនៅរបស់បុត្រក្រៅនេះ មិនអាចលះបុត្រតូចបាន ត្រឡប់ក្រឡេកមើលរឿយៗ ដើរទៅ ។ ក្នុងវេលាដែលនាងដល់កណ្ដាលស្ទឹង ខ្លែងមួយឃើញទារកនោះ ទើបធាបចុះមកអំពីអាកាស ដោយសម្គាល់ថាជាដុំសាច់ ។ នាងឃើញវាធាបចុះដើម្បីត្រូវការបុត្រ ទើបលើកដៃទាំងពីរឡើង ស្រែកសំឡេងខ្លាំង ៣ ដងថា សូសូ ខ្លែងមិនបានឮសំឡេងនោះឡើយ ព្រោះឆ្ងាយគ្នា ទើបធាបយកក្មេងហើរឡើងកាន់វេហាស៍ទៅ ។ សូម្បីបុត្រដែលឈរនៅត្រង់ត្រើយខាងអាយ ឃើញមាតាលើកដៃទាំងពីរឡើង ស្រែកសំឡេងខ្លាំងៗ ត្រង់កណ្ដាលស្ទឹង ទើបលោតចុះក្នុងស្ទឹងដោយរហ័ស ដោយសម្គាល់ថា មាតាហៅយើង ។ ខ្លែងធាបបុត្រតូចរបស់នាងទៅ បុត្រច្បងត្រូវទឹកបន្សាត់ទៅ ដោយប្រការដូច្នេះ ។

### នាងជ្រាបដំណឹងថា មាតាបិតាស្លាប់

នាងដើរស្រែកយំរំពងថា "បុត្ររបស់យើងម្នាក់ត្រូវខ្លែងធាបយកទៅ បុត្រម្នាក់ត្រូវទឹកបន្សាត់ទៅ ស្វាមីក៏ស្លាប់ក្នុងទីស្ងាត់" ជួបបុរសម្នាក់ដើរមកអំពីក្រុងសាវត្ថី ទើបសួរថា "លោកនៅទីណា?"

បុរស. ខ្ញុំនៅក្រុងសាវត្ថី នាង ។

ធីតាសេដ្ឋី. ត្រកូលឈ្មោះឯណោះ មានសភាពបែបនេះ នៅជិតថ្នល់ឯណោះក្នុងក្រុងសាវត្ថីមាន លោកពុក ស្គាល់ទេ ?

បុរស. ខ្ញុំស្គាល់ នាង តែកុំសួរដល់ត្រកូលនោះឡើយ បើនាងចង់ដឹង

ត្រកូលដទៃ ចូរសួរចុះ ។

ធីតាសេដ្ឋី. កិច្ចដោយត្រកូលដទៃរបស់ខ្ញុំមិនមាន ខ្ញុំសួរដល់ត្រកូលនោះប៉ុណ្ណោះ លោកពុក ។

បុរស. នាង ខ្ញុំប្រាប់ក៏មិនគួរ ។

ធីតាសេដ្ឋី. ប្រាប់ខ្ញុំចុះលោកពុក ។

បុរស. ថ្ងៃនេះ នាងឃើញភ្លៀងធ្លាក់ចុះមួយយប់ទល់ភ្លឺទេ ?

ធីតាសេដ្ឋី. ខ្ញុំឃើញ លោកពុក ភ្លៀងនោះធ្លាក់មួយយប់ទល់ភ្លឺដើម្បីខ្ញុំប៉ុណ្ណោះ មិនមែនធ្លាក់ដើម្បីមនុស្សដទៃ តែខ្ញុំនឹងប្រាប់ហេតុដែលភ្លៀងធ្លាក់ដើម្បីខ្ញុំ ដល់លោកពុកខាងក្រោយ មេត្តាប្រាប់ការប្រព្រឹត្តិទៅក្នុងផ្ទះសេដ្ឋីនោះដល់ខ្ញុំមុនសិន ។

បុរស. នាង ថ្ងៃនេះ ក្នុងកណ្តាលយប់ ផ្ទះរលំសង្កត់ជនទាំងបីនាក់ គឺ សេដ្ឋី ១ ភរិយាសេដ្ឋី ១ បុត្រសេដ្ឋី ១ ជនទាំងបីនាក់នោះត្រូវដុតលើជើងថ្ករជាមួយគ្នា នាងអើយ ទុំះផ្សែង នៅប្រាកដនៅឡើយ ។ ក្នុងខណៈនោះនាងមិនដឹងដល់សំពត់ដែលស្លៀកហើយរបូតចុះ ក៏ដល់ភាពជាមនុស្សវិកលចរិត នៅឈរស្រឡាំងកាំង ស្រែកយំខ្សឹកខ្សួលរៀបរាប់ថា ៖

បុត្រ ២ នាក់ស្លាប់ហើយ ស្វាមីរបស់យើងក៏ស្លាប់
ត្រង់ផ្លូវស្ងាត់ មាតាបិតា និងបងប្រុសក៏ត្រូវដុតលើ
ជើងថ្ករជាមួយគ្នា ។

មនុស្សទាំងឡាយឃើញនាងហើយ យល់ថា "ស្ត្រីឆ្កួតៗ" ទើបកាន់យកសម្រាម អាចម៍ដី រោយចុះលើសីសៈ គ្រវែងដោយដុំដី ។ ព្រះសាស្តាប្រថាប់គង់សម្តែងធម៌នៅក្នុងកណ្តាលបរិស័ទ ៤ ក្នុងព្រះជេតពនមហាវិហារ បានទតឃើញនាង ដែលជាអ្នកបំពេញបារមីមកមួយសែនកប្ប សំបូរដោយអភិនីហារកំពុងដើរមក ។

នាងធានតាំងសេចក្តីប្រាថ្នាទុកក្នុងជាតិមុន

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ នាងបដាចារានោះឃើញព្រះថេរីអ្នកទ្រទ្រង់ព្រះវិន័យមួយរូប ដែលព្រះបទុមុត្តរសាស្តាទ្រង់តាំងទុកក្នុងតំណែងឯតទគ្គៈ ដូចសក្កទេវរាជចាប់ត្រង់ដើមដៃ តាំងទុកក្នុងសួននន្ទវ័ន ទើបធ្វើគុណសេចក្តីល្អហើយ តាំងសេចក្តីប្រាថ្នាទុកថា "សូម្បីខ្ញុំគប្បីបានជាកំពូលលើសព្រះថេរីទាំងឡាយខាងអ្នកទ្រទ្រង់ព្រះវិន័យ ក្នុងសម្នាក់ព្រះពុទ្ធជាម្ចាស់ ប្រាកដស្មើដូចព្រះអគ្គ ព្រះបទុមុត្តរៈជាម្ចាស់ទ្រង់ពិចារណាដល់អនាគតង្សញ្ញាណ ទ្រង់ក៏ជ្រាបថា "ការប្រាថ្នានឹងសម្រេច" ទើបទ្រង់ព្យាករណ៍ថាក្នុងអនាគតកាល ស្ត្រីនេះនឹងជាអ្នកប្រសើរលើសព្រះថេរីទាំងឡាយខាងទ្រទ្រង់ព្រះវិន័យ មាននាមថា **បដាចារា** ក្នុងសាសនានៃព្រះពុទ្ធព្រះនាម **គោតម** ។

ព្រះសាស្តា ទ្រង់ឃើញនាងមានសេចក្តីប្រាថ្នាតាំងទុកហើយយ៉ាងនោះជាអ្នកសំបូរដោយអភិនីហារ កំពុងដើរមកអំពីចម្ងាយ ទ្រង់មានព្រះតម្រិះថា "វៀរតថាគតចេញ អ្នកដទៃឈ្មោះថាអាច និងជាទីពឹងរបស់ស្ត្រីនេះបាន មិន

មាន" ទើបទ្រង់ធ្វើឲ្យនាងមានមុខដើរឆ្ពោះមករកវិហារ ។ បរិស័ទឃើញនាងហើយ ទើបពោលថា "លោកទាំងឡាយ កុំឲ្យស្ត្រីឆ្កួតនេះមកទីនេះឡើយ" ។ ព្រះសាស្តាត្រាស់ថា "ពួកអ្នកចូរកុំហាមនាងឡើយ" ក្នុងវេលានាងមកជិត បានត្រាស់ថា "ចូរត្រឡប់បានសតិចុះ ប្អូនស្រី" ។ នាងត្រឡប់ជាមានសតិដោយពុទ្ធានុភាពក្នុងខណៈនោះឯង ។ ក្នុងវេលានោះ នាងក៏កំណត់នូវសំពត់ស្លៀកដែលរបូតបានហើយ ញ៉ាំងហិរិឱត្តប្បៈឲ្យកើតឡើង ទើបអង្គុយច្រហោង ។ លំដាប់នោះ បុរសម្នាក់បានបោះសំពត់ដណ្តប់ទៅឲ្យនាង ។ នាងស្លៀកសំពត់នោះហើយ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ទៀបព្រះបាទទាំងគូរ ដែលមានវណ្ណៈដូចមាស ហើយទូលថា "សូមព្រះអង្គទ្រង់ជាទីពឹងដល់នាងខ្ញុំផង ព្រះអង្គ ព្រោះថា ខ្លែងឆាបបុត្រម្នាក់របស់ខ្ញុំទៅ បុត្រម្នាក់ត្រូវទឹកបន្សាត់ទៅ ស្វាមីស្លាប់ត្រង់ផ្លូវស្ងាត់ ឯមាតាបិតា និងបងប្រុសក៏ត្រូវផ្ទះសង្កត់ស្លាប់ គេដុតលើជើងថ្ករជាមួយគ្នា" ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យរបស់នាងហើយ "ទើបត្រាស់ថា កុំគិតឡើយបដាចារា នាងមកកាន់សម្នាក់របស់បុគ្គលដែលជាទីពឹងពំនាក់របស់នាងហើយ ឥឡូវនេះ បុត្រម្នាក់របស់នាងត្រូវខ្លែងឆាបយកទៅ បុត្រម្នាក់ត្រូវទឹកបន្សាត់ទៅ ស្វាមីត្រូវស្លាប់ត្រង់ផ្លូវស្ងាត់ មាតាបិតា និងបងប្រុសត្រូវផ្ទះរលំសង្កត់ យ៉ាងណា ទឹកភ្នែកដែលហូរចេញរបស់នាង ដែលស្រែកយំក្នុងសង្សារនេះ ក្នុងវេលាដែលបិយ-ជន មានបុត្រជាដើមស្លាប់ គង់ច្រើនជាងទឹកមហាសមុទ្រទាំង ៤ ក៏ដូច្នោះ"

ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា ៖

ទឹកក្នុងសមុទ្រទាំង ៤ មានប្រមាណតិច ទឹកភ្នែករបស់
បុគ្គលដែលទុក្ខពាល់ត្រូវហើយ សោយសោក មិនមែន
តិច ច្រើនជាងទឹកក្នុងមហាសមុទ្រនោះ ហេតុអ្វី ទើបនាង
នៅប្រមាទ ។

កាលព្រះសាស្តា ត្រាស់អនមតគ្គបរិយាយសូត្រយ៉ាងនោះ សេចក្តីសោកក្នុងសរីរៈរបស់នាង ក៏បានដល់ភាពធូរស្រាលខ្លះ ។ លំដាប់នោះ ព្រះសាស្តាទ្រង់ជ្រាបថា នាងមានសេចក្តីសោកធូរស្រាលហើយ ទើបទ្រង់ដាស់តឿនទៀត ហើយត្រាស់ថា "បដាចារា ឈ្មោះថា បិយជន មានបុត្រជាដើម មិនអាចដើម្បីជាទីពឹង ឬជាទីពួនរបស់អ្នកទៅកាន់បរលោកបានទេ ព្រោះដូច្នោះ បុត្រជាដើមទាំងនោះសូម្បីមាន ក៏ឈ្មោះថា រមែងមិនមានមែន ចំណែកបណ្ឌិតជម្រះសីលហើយ គួរជម្រះផ្លូវដែលញ៉ាំងសត្វឲ្យដល់និព្វានរបស់ខ្លួនប៉ុណ្ណោះ" កាលនឹងទ្រង់សម្តែងធម៌ បានត្រាស់ព្រះគាថាទាំងនេះថា ៖

បុត្រទាំងឡាយ មិនមានដើម្បីជាទីពឹង បិតាក៏មិនមាន
សូម្បីផៅពង្សក៏មិនមាន កាលបុគ្គលត្រូវសេចក្តីស្លាប់
គ្របសង្កត់ហើយ ទីពឹងក្នុងញាតិទាំងឡាយ រមែងមិន
មាន បណ្ឌិតជ្រាបដល់ប្រយោជន៍នោះហើយ ក៏សង្រួម
ក្នុងសីល គប្បីជម្រះផ្លូវទៅព្រះនិព្វាន ដោយរហ័ស ។

ក្នុងកាលចប់ព្រះធម៌ទេសនា នាងបដាចារាជុតកិលេសមានប្រមាណប៉ុនលំអងធូលីក្នុងផែនដីដ៏ធំ ហើយតាំងនៅក្នុងសោតាបត្តិផល សូម្បីជនដទៃជាច្រើនទៀត ក៏សម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

## នាងបដាចារាទូលសូមបព្វជ្ជា

ចំណែកនាងបដាចារានោះ ជាព្រះសោតាបន្នហើយ ទូលសូមបព្វជ្ជានឹងព្រះសាស្តា ។ ព្រះសាស្តា ទ្រង់បញ្ជូននាងទៅកាន់សម្នាក់របស់ពួកនាងភិក្ខុនីឲ្យបព្វជ្ជា ។ នាងបានឧបសម្បទ៏ហើយ ប្រាកដឈ្មោះថា "បដាចារា" ព្រោះនាងត្រឡប់ពីការប្រព្រឹត្តបាន ។ ថ្ងៃមួយ នាងកំពុងយកក្អមទឹកចាក់លាងជើង ។ ទឹកនោះហូរទៅបន្តិចហើយក៏ស្ងួត ។ លើកទី ២ ទឹកដែលនាងចាក់ចុះ បានហូរទៅឆ្ងាយជាងនោះ ។ លើកទី ៣ ទឹក ដែលនាងចាក់ចុះបានហូរទៅឆ្ងាយជាងលើកទី ១ និងលើកទី ២ ដោយប្រការដូច្នេះ ។ នាងកាន់យកទឹកនោះឯងជាអារម្មណ៍ កំណត់វ័យទាំង ៣ ហើយគិតថា "សត្វទាំងនេះស្លាប់ក្នុងបឋមវ័យក៏មាន ដូចទឹកដែលយើងចាក់លើកដំបូង ស្លាប់ក្នុងមជ្ឈិម-វ័យក៏មាន ដូចទឹកដែលយើងចាក់លើកទី ២ ហូរទៅឆ្ងាយជាងនោះ ស្លាប់ក្នុងបច្ឆិមវ័យក៏មាន ដូចទឹកដែលយើងចាក់លើកទី ៣ ហូរទៅឆ្ងាយជាងនោះ" ។

ព្រះសាស្តាប្រថាប់ក្នុងព្រះគន្ធកុដិ ទ្រង់បញ្ចេញព្រះរស្មីទៅ ដូចជាទ្រង់ប្រថាប់ឈរត្រាស់នៅចំពោះមុខរបស់នាង ត្រាស់ថា "បដាចារា ប្រការនោះ

ពិតហើយ ព្រោះថា ការរស់នៅមួយថ្ងៃក្តី មួយខណៈក្តី របស់អ្នកឃើញការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកមិនឃើញការកើតឡើង និងការរលត់ទៅនៃបញ្ចក្ខន្ធ” ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

*យោ ច វស្សសតំ ជីវេ អបស្សំ ឧទយព្វយំ*
*ឯកាហំ ជីវិតំ សេយ្យោ បស្សតោ ឧទយព្វយំ ។*

*បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញការកើតឡើង និង*
*ការវិនាសទៅ ការរស់នៅសូម្បីតែមួយថ្ងៃរបស់លោកដែល*
*ឃើញការកើតឡើង និងការវិនាសទៅ ប្រសើរជាង ។*

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អបស្សំ ឧទយព្វយំ (មិនឃើញការកើតឡើង និងការវិនាសទៅ)** សេចក្តីថា មិនឃើញការកើតឡើង និងការវិនាសទៅ ដោយលក្ខណៈ ២៥ នៃបញ្ចក្ខន្ធ ។ បទថា **បស្សតោ ឧទយព្វយំ (របស់អ្នកឃើញការកើត និងការរលត់)** សេចក្តីថា ការរស់នៅសូម្បីមួយថ្ងៃរបស់អ្នកឃើញការកើតឡើង និងការវិនាសទៅនៃបញ្ចក្ខន្ធទាំងនោះ ប្រសើរជាងការរស់នៅរបស់បុគ្គលក្រៅពីនេះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា នាងបដាចារា បានសម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

ចប់ រឿងនាងបដាចារា

# ១៣. រឿងព្រះនាងកិសាគោតមី

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធនាងកិសាគោតមី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** (ក៏នរណា...រស់នៅ ១០០ ឆ្នាំ) ជាដើម ។*

ទ្រព្យរបស់សេដ្ឋីក្លាយជាធ្យូង

*បានឮថា ទ្រព្យ ៤០ កោដិ ក្នុងផ្ទះរបស់សេដ្ឋីមួយរូប នៅក្នុងក្រុងសាវត្ថី បានក្លាយជាធ្យូងអស់ ។ សេដ្ឋីឃើញហេតុនោះ ក៏កើតការសោយសោក ទើបមិនព្រមបរិភោគអាហារ ដេកនៅលើគ្រែតូចមួយ ។ សំឡាញ់ម្នាក់របស់សេដ្ឋីនោះ សួរថា "ហេតុអ្វីទើបសោយសោក សំឡាញ់" ស្តាប់ដំណឹងនោះហើយ ពោលថា "កុំសោយសោកឡើយ សំឡាញ់ ខ្ញុំដឹងឧបាយមួយ ចូរធ្វើតាមឧបាយនោះចុះ" ។*

*សេដ្ឋី. ធ្វើយ៉ាងណា សំឡាញ់ ?*

*សំឡាញ់. ចូរលោកក្រាលកន្ទេលត្រង់រានផ្សាររបស់ខ្លួន ធ្វើធ្យូងឲ្យជាគំនរទុក រួចចូរអង្គុយដូចជានឹងលក់ បណ្តាមនុស្សដែលមកហើយៗ នរណាពោលយ៉ាងនេះថា "ជនដ៏សេសគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ចំណែកលោកអង្គុយលក់ធ្យូង" លោកគប្បីនិយាយនឹងមនុស្សទាំងនោះថា "បើយើងមិនលក់របស់របររបស់ខ្លួន នឹងធ្វើដូចម្តេច" ចំណែកនរណា*

និយាយនឹងលោកយ៉ាងនេះថា "ជនដទៃគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងស្ករ អំពៅជាដើម ចំណែកលោកអង្គុយលក់មាស និងប្រាក់" លោកគប្បីនិយាយនឹងជននោះថា "មាស និងប្រាក់នៅឯណា" ក៏កាលគេនិយាយថា "នេះ" លោកគប្បីនិយាយថា "ចូរនាំមាស និងប្រាក់នោះមកមើល៍" ហើយគប្បីទទួលដោយដៃទាំងពីរ របស់ដែលគេឲ្យដល់ដៃរបស់លោកយ៉ាងនេះ នឹងក្លាយជាមាស និងប្រាក់ ក៏អ្នកនោះ បើជាស្រីក្រមុំ លោកចូរនាំនាងមកដើម្បីបុត្រក្នុងផ្ទះរបស់លោក ប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់នាង គប្បីប្រើប្រាស់មាស និងប្រាក់ដែលនាងឲ្យ បើជាប្រុសកំលោះ លោកគប្បីឲ្យធីតាដែលពេញវ័យហើយក្នុងផ្ទះរបស់លោកដល់គេ ហើយប្រគល់ទ្រព្យ ៤០ កោដិឲ្យដល់គេ ប្រើប្រាស់ទ្រព្យដែលគេឲ្យចុះ ។

សេដ្ឋីនោះពោលថា "ឧបាយល្អ" ទើបធ្វើធ្យូងឲ្យជាគំនរទុកក្នុងរានផ្សាររបស់ខ្លួន អង្គុយធ្វើដូចជានឹងលក់ ។ ពួកមនុស្សឯណានិយាយនឹងសេដ្ឋីនោះយ៉ាងនេះថា "ជនដ៏សេសទាំងឡាយ លក់សំពត់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម លោកអង្គុយលក់ធ្យូង" ក៏ពោលពាក្យតបដល់មនុស្សទាំងនោះថា "ខ្ញុំមិនលក់របស់របររបស់ខ្លួន នឹងធ្វើដូចម្ដេច" ។

ធ្យូងក្លាយជាទ្រព្យដូចដើម

គ្រានោះ ក្មេងស្រីជំទង់ម្នាក់ឈ្មោះ **គោតមី** ប្រាកដឈ្មោះថា **កិសាគោតមី** ព្រោះនាងមានសរីរៈស្គម ជាធីតានៃត្រកូលចាស់មួយ ទៅកាន់ផ្សារ

ដោយកិច្ចឯណាមួយរបស់ខ្លួន ឃើញសេដ្ឋីនោះ ទើបពោលយ៉ាងនេះថា "លោកពុក ជនដ៏សេសគេលក់សំពត់ ប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ម្ដេចក៏លោកពុក អង្គុយលក់មាស និងប្រាក់"

សេដ្ឋី. មាស និងប្រាក់នៅទីណា នាង ?

នាងគោតមី. លោកកំពុងអង្គុយចាប់មាស និងប្រាក់នោះឯងមិនមែនឬ ?

សេដ្ឋី. ចូរនាំមាស និងប្រាក់នោះមកមើល៍ នាង ។

នាងក្បង់ពេញដៃហើយ ដាក់ក្នុងដៃរបស់សេដ្ឋីនោះ ។ ធ្យូងនោះបានក្លាយជាមាស និងប្រាក់ភ្លាម ។

លំដាប់នោះ សេដ្ឋីសួរនាងថា "នាង ផ្ទះនាងនៅឯណា កាលនាងប្រាប់ថា "នៅទីឯណោះ" ដឹងភាពដែលនាងមិនទាន់មានស្វាមីហើយ ទើបរៀបចំទ្រព្យទុកដាក់ ហើយនាំនាងមកដើម្បីបុត្ររបស់ខ្លួន ឲ្យនាងទទួលទ្រព្យ ៤០ កោដិទុក ។ ទ្រព្យទាំងអស់បានក្លាយជាមាស និងប្រាក់ដូចដើម ។

សម័យក្រោយមក នាងបានតាំងគភ៌ ។ ដោយកាលកន្លងទៅ ១០ ខែ នាងក៏បានប្រសូតបុត្រ ។ បុត្រនោះបានស្លាប់ នៅពេលដែលចេះដើរ ។ នាងហាមពួកជនដែលប្រាថ្នានាំបុត្រនោះទៅដុត ព្រោះនាងមិនធ្លាប់ឃើញសេចក្ដីស្លាប់ បីសាកសពបុត្រដែលស្លាប់ហើយដោយចង្កេះ ដោយសង្ឃឹមថា នឹងសួររកថ្នាំដើម្បីបុត្រខ្លួន ត្រាច់សួរទៅតាមលំដាប់ផ្ទះថា "លោកទាំងឡាយដឹង

ថ្នាំដើម្បីបុត្ររបស់ខ្ញុំដែរទេ?" ខណៈនោះ មនុស្សទាំងឡាយពោលនឹងនាងថា "នាងជាស្ត្រីឆ្កួតហើយ នាងត្រាច់សួរថ្នាំដើម្បីបុត្រដែលស្លាប់ដូច្នេះ" ។ នាងសម្គាល់ថា នឹងបានមនុស្សអ្នកដឹងថ្នាំដើម្បីបុត្ររបស់ខ្លួនជាប្រាកដ ទើបចេះតែត្រាច់ទៅ ។ ខណៈនោះ បុរសជាបណ្ឌិតម្នាក់ ឃើញនាងហើយ គិតថា "ធីតារបស់យើងនេះ ទើបនឹងប្រសូតបុត្រដំបូង មិនធ្លាប់ឃើញសេចក្ដីស្លាប់ យើងជាទីពឹងរបស់ស្ត្រីនេះរមែងគួរ ទើបពោលថា "នាង ខ្ញុំមិនដឹងថ្នាំទេ តែខ្ញុំដឹងអ្នកដែលដឹងថ្នាំ" ។

នាងគោតមី. នរណាដឹង លោក ?

បណ្ឌិត. នាង ព្រះសាស្ដាទ្រង់ជ្រាប ចូរទៅទូលសួរព្រះអង្គចុះ ។

នាងពោលថា "ខ្ញុំនឹងទៅ ហើយទូលសួរព្រះអង្គ" ដូច្នេះហើយ ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ឈរនៅក្នុងទីដ៏សមគួរ ទូលសួរថា "ឮថា ព្រះអង្គទ្រង់ជ្រាបថ្នាំដើម្បីបុត្ររបស់នាងខ្ញុំឬ ព្រះអង្គ?"

ព្រះសាស្ដា. អើ តថាគតដឹង ។

នាងគោតមី. បានអ្វី ទើបគួរព្រះអង្គ ?

ព្រះសាស្ដា. បានគ្រាប់ស្ពៃមួយក្ដាប់ គួរ ។

នាងគោតមី. នឹងរកបាន ព្រះអង្គ តែបានក្នុងផ្ទះនរណាទើបគួរ ?

ព្រះសាស្ដា. បុត្រ ឬធីតាណាមួយ ក្នុងផ្ទះរបស់អ្នកណាមិនមានអ្នកស្លាប់ បានក្នុងផ្ទះរបស់អ្នកនោះ ទើបគួរ ។ នាងទូលថា "ព្រះករុណា ព្រះអង្គ"

ហើយថ្វាយបង្គំព្រះសាស្តា បីបុត្រដែលស្លាប់ដោយចង្កេះចូលទៅខាងក្នុងស្រុក ឈរត្រង់ទ្វារផ្ទះដំបូងគេ ពោលថា "គ្រាប់ស្ពៃក្នុងផ្ទះនេះ មានដែរទេ? ឮថា ទុំះជាថ្នាំ ដើម្បីបុត្ររបស់ខ្ញុំ" កាលគេឆ្លើយថា "មាន" ទើបពោលថា "បើដូច្នោះ ចូរឲ្យមកចុះ" កាលមនុស្សទាំងនោះនាំយកគ្រាប់ស្ពៃមកឲ្យ ក៏សួរថា "ក្នុងផ្ទះនេះ បុត្រ ឬធីតាធ្លាប់ស្លាប់មិនមានទេឬ ម៉ែ?" កាលគេឆ្លើយថា "និយាយអ្វីនាង? ព្រោះមនុស្សដែលរស់មានតិច មនុស្សស្លាប់នោះវិញមានច្រើន" ទើបពោលថា "បើដូច្នោះ ចូរទទួលគ្រាប់ស្ពៃរបស់លោកវិញចុះ ទុំះមិនមែនជាថ្នាំដើម្បីបុត្ររបស់ខ្ញុំទេ ហើយបានឲ្យទៅវិញ" នាងដើរសួរដោយទំនងនេះតាំងពីផ្ទះបន្តបន្ទាប់ទៅ ។ នាងមិនបានទទួលគ្រាប់ស្ពៃ សូម្បីក្នុងផ្ទះមួយខ្នង ក្នុងវេលារសៀល គិតថា "ឱ! កម្មធ្ងន់ហ្ន៎ យើងបានសម្គាល់ថា បុត្ររបស់យើងប៉ុណ្ណោះស្លាប់ ក៏ក្នុងស្រុកទាំងអស់ មនុស្សដែលស្លាប់មានច្រើនជាងមនុស្សរស់" កាលនាងគិតដូច្នោះ ទឹកចិត្តដែលទោទន់ព្រោះសេចក្តីស្រឡាញ់ក្នុងបុត្រក៏ដល់នូវភាពរឹងប៉ឹងឡើង ។ នាងទុកបុត្រចោលក្នុងព្រៃ ដើរទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំហើយ បានឈរនៅក្នុងទីគួរមួយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា "នាងបានគ្រាប់ស្ពៃប្រមាណមួយក្តាប់ហើយឬ?"

នាងគោតមី. មិនបានទេព្រះអង្គ ព្រោះក្នុងស្រុកទាំងមូល មនុស្សស្លាប់នោះ ច្រើនជាងមនុស្សដែលរស់ ។

លំដាប់នោះ ព្រះសាស្តាត្រាស់នឹងនាងថា "នាងយល់ថា បុត្ររបស់

ខ្ទួនប៉ុណ្ណោះ ស្លាប់ សេចក្តីស្លាប់នោះ ជាធម៌ទៀងទាត់សម្រាប់សត្វទាំងឡាយ ព្រោះថា មច្ចុរាជ រមែងទាញកន្ត្រាក់សត្វទាំងអស់ អ្នកមានអធ្យាស្រ័យមិនពេញបរិបូណ៌នោះឯង ចុះក្នុងសមុទ្រ គឺ អបាយ ដូចជំនន់ទឹកជំកួចពន្លិចដូច្នោះ" កាលនឹងទ្រង់សំដែងធម៌ ទើបត្រាស់ព្រះគាថានេះថា ៖

**មច្ចុ រមែងនាំជនអ្នកវង្វេងជ្រប់ក្នុងបុត្រ និងសត្វចិញ្ចឹម អ្នកមានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗ ទៅ ដូចទឹកជំនន់ធំដែលកួចយកអ្នកស្រុកកំពុងដេកលក់ទៅ ដូច្នោះ ។**

ក្នុងកាលចប់ព្រះធម៌ទេសនា នាងកិសាគោតមី ក៏បានតាំងនៅក្នុងសោតាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានសម្រេចអរិយផល មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

នាងបួសក្នុងព្រះពុទ្ធសាសនា

ចំណែកនាងកិសាគោតមីនោះ បានទូលសូមបព្វជ្ជានឹងព្រះសាស្តា ។ ព្រះសាស្តាទ្រង់បញ្ជូនទៅកាន់សម្នាក់របស់នាងភិក្ខុនីដើម្បីបានបព្វជ្ជា ។ នាងបានឧបសម្បទាហើយ មាននាមប្រាកដថា **កិសាគោតមីថេរី** ។ ថ្ងៃមួយ នាងដល់វេនក្នុងរោងឧបោសថ អុជ្ជយចាំប្រទីប ឃើញអណ្តាតប្រទីបសន្ធោសន្ធៅឡើង និងរលត់ បានកាន់យកជាអារម្មណ៍ថា សត្វទាំងនេះក៏យ៉ាងនោះដូចគ្នាកើតឡើង និងរលត់ទៅដូចអណ្តាតប្រទីប អ្នកដល់ព្រះនិព្វានទើបមិនប្រាកដយ៉ាងនោះ ។ ព្រះសាស្តា ប្រថាប់ក្នុងព្រះគន្ធកុដិនោះឯង ទ្រង់ផ្សាយព្រះរស្មី

ទៅ ដូចទ្រង់ប្រថាប់ចំពោះមុខនាង ត្រាស់ថា “យ៉ាងនោះឯង គោតមី សត្វទាំងនោះរមែងកើត និងរលត់ដូចអណ្តាតប្រទីប ការដល់ព្រះនិព្វានហើយ រមែងមិនប្រាកដដូច្នោះ ការរស់នៅសូម្បីត្រឹមមួយខណៈ របស់អ្នកឃើញព្រះនិព្វានប្រសើរជាង ការរស់នៅអស់មួយរយឆ្នាំ របស់អ្នកមិនឃើញព្រះនិព្វាននោះ” ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិសម្តែងធម៌ ទើបត្រាស់ព្រះគាថានេះថា៖

យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ
ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន
ការរស់នៅសូម្បីតែមួយថ្ងៃ របស់លោកអ្នកឃើញផ្លូវ
ព្រះនិព្វាន ប្រសើរជាង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អមតំ បទំ** (បទដែលមិនស្លាប់) សេចក្តីថា អមតមហានិព្វាន ដែលជាចំណែកវៀរចាកមរណៈ ។ ពាក្យដ៏សេសក៏មានន័យដូចមុននោះឯង ។

ក្នុងកាលចប់ព្រះធម៌ទេសនា ព្រះនាងកិសាគោតមី គង់កន្លែងដដែលនោះឯង ក៏បានតាំងនៅក្នុងព្រះអរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

ចប់ រឿងនាងកិសាគោតមី

# ១៤. រឿងព្រះនាងពហុបុត្តិកាថេរី

*ព្រះសាស្តា កាលប្រថាប់នៅវត្តជេតពន ទ្រង់ប្រារព្ធព្រះពហុបុត្តិកាថេរី ត្រាស់ព្រះធម្មទេសនានេះថា **យោ ច វស្សសតំ ជីវេ** (ក៏អ្នកណា... រស់នៅ ១០០ ឆ្នាំ) ជាដើម ។*

នាងមានកូនច្រើន

*បានឮថា ក្នុងត្រកូលមួយក្នុងក្រុងសាវត្ថី មានបុត្រ ៧ នាក់ មានធីតា ៧ នាក់ ។ បុត្រ និងធីតាទាំងអស់នោះ ចម្រើនវ័យហើយរស់នៅក្នុងផ្ទះ បានសេចក្តីសុខតាមធម្មតារបស់ខ្លួន ។ សម័យក្រោយមក បិតារបស់ជនទាំងនោះ បានធ្វើមរណកាល ។ មហាឧបាសិកា សូម្បីស្វាមីស្លាប់ទៅហើយ ក៏នៅមិនទាន់បែងចែកទ្រព្យឲ្យដល់បុត្រទាំងឡាយ ។ គ្រានោះ ពួកកូនៗ ពោលនឹងមាតានោះថា "កាលបិតារបស់ខ្ញុំស្លាប់ទៅហើយ ប្រយោជន៍អ្វីអ្នកម៉ែ ដោយគំនរទ្រព្យ ពួកខ្ញុំមិនអាចទំនុកបម្រុងអ្នកម៉ែបានឬ?" នាងស្តាប់ពាក្យរបស់បុត្រទាំងនោះហើយ ក៏នៅស្ងៀម កាលត្រូវបុត្រទាំងនោះនិយាយរឿយៗ ទើបគិតថា "ពួកកូនៗ នឹងទំនុកបម្រុងយើង ប្រយោជន៍អ្វីចំពោះយើង ដោយគំនរទ្រព្យនេះ" ក៏បានបែងទ្រព្យសម្បត្តិពាក់កណ្តាលឲ្យ ។ គ្រានោះ ដោយកាលកន្លង*

ទៅ ២-៣ ថ្ងៃ កិរិយារបស់បុត្រច្បងពោលនឹងម៉ែក្មេកនោះថា "អ្នកម៉ែរបស់ពួកយើងមកតែផ្ទះនេះប៉ុណ្ណោះ ដូចជាឲ្យទ្រព្យពីរចំណែក ថា បុត្រច្បងរបស់យើង ។ សូម្បីកិរិយារបស់បុត្រដ៏សេស ក៏ពោលយ៉ាងនោះដូចគ្នា ។

តាំងអំពីធីតាច្បងក៏ពោលនឹងនាងដូចគ្នា សូម្បីវេលាដែលនាងទៅផ្ទះរបស់ធីតាទាំងនោះ ។ នាងត្រូវប្រមាថអំពីពួកកូនៗ គិតថា "ប្រយោជន៍អ្វីដោយការនៅក្នុងសម្នាក់របស់អ្នកទាំងនេះ យើងនឹងទៅបួសជាភិក្ខុនី ហើយទៅកាន់សម្នាក់របស់នាងភិក្ខុនីសូមបព្វជ្ជា ។ នាងភិក្ខុនីទាំងនោះ ក៏បានឲ្យនាងបព្វជ្ជា ។ នាងបានឧបសម្បទាហើយ ប្រាកដនាមថា **ពហុបុត្តិកាថេរី** ។ នាងគិតថា "យើងបួសក្នុងវេលាខ្លួនចាស់ យើងមិនគួរជាបុគ្គលប្រមាទ ទើបធ្វើវត្តបដិបត្តិដល់នាងភិក្ខុនីទាំងឡាយ គិតថា នឹងធ្វើសមណធម៌រហូតទល់ភ្លឺ" ទើបយកដៃចាប់សសរមួយដើមខាងក្រោមប្រាសាទ ដើរជុំវិញសសរនោះធ្វើសមណធម៌ សូម្បីកាលដើរចង្រ្កម ក៏យកដៃចាប់ដើមឈើ ដោយគិតថា "សីសៈរបស់យើងគង់ប៉ះទង្គិចដើមឈើ ឬអ្វីៗ ក្នុងទីងងឹត" ដូច្នេះហើយ ក៏ដើរជុំវិញដើមឈើនោះ ធ្វើសមណធម៌ នឹកដល់ធម៌ ដោយគិតថា "យើងនឹងធ្វើតាមធម៌ដែលព្រះសាស្តាទ្រង់សម្តែង" តាមរឭកដល់ធម៌ ហើយធ្វើសមណធម៌ ។

លំដាប់នោះ ព្រះសាស្តាប្រថាប់គង់ក្នុងព្រះគន្ធកុដិ ទ្រង់ផ្សាយព្រះរស្មីទៅ ដូចជាទ្រង់ប្រថាប់គង់ចំពោះមុខ កាលត្រាស់ជាមួយនាង ទ្រង់ត្រាស់ថា "ពហុបុត្តិកា ការរស់នៅសូម្បីមួយក្ស័ណរបស់អ្នកឃើញធម៌ដែលតថាគតសម្តែង ប្រសើរជាង ការរស់នៅ ១០០ ឆ្នាំ របស់អ្នកមិនពិចារណា មិនឃើញធម៌ដែលតថាគតសម្តែង កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា ៖

យោ ច វស្សសតំ ជីវេ  អបស្សំ ធម្មមុត្តមំ
ឯកាហំ ជីវិតំ សេយ្យោ  បស្សតោ ធម្មមុត្តមំ ។

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់
ការរស់នៅសូមតែមួយថ្ងៃ របស់លោកអ្នកដែលឃើញ
ធម៌ខ្ពង់ខ្ពស់ ប្រសើរជាង ។

អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ធម្មមុត្តមំ** (ធម៌ដ៏ខ្ពង់ខ្ពស់) បានដល់ លោកុត្តរធម៌ ៩ ប្រការ ។ ក៏លោកុត្តរធម៌នោះ ឈ្មោះថា ធម៌ដ៏ខ្ពង់ខ្ពស់ ។ ការរស់នៅសូម្បីមួយថ្ងៃ គឺ សូម្បីមួយខណៈ របស់អ្នកឃើញ គឺ ចាក់ធ្លុះធម៌នោះ ប្រសើរជាងការរស់នៅ ១០០ ឆ្នាំ របស់អ្នកដែលមិនឃើញធម៌នោះ ។

ក្នុងកាលចប់ព្រះធម៌ទេសនា ពហុបុត្តិកាថេរី ក៏បានតាំងនៅក្នុងព្រះ-អរហត្តព្រមទាំងបដិសម្ភិទាទាំងឡាយ ដូច្នេះឯង ។

ចប់ រឿងព្រះនាងពហុបុត្តិកាថេរី

## ចប់សហស្សវគ្គវណ្ណនា វគ្គទី ៨

ក្នុងវគ្គនេះរួមមាន ១៤ រឿង


១. រឿងបុរសពុកមាត់ក្រហម ២. រឿងព្រះនារុចិរិយៈ

៣. រឿងព្រះនាងកុណ្ឌលកេសី ៤. រឿងអនត្ថបុច្ឆកព្រាហ្មណ៍

៥. រឿងព្រាហ្មណ៍ឪពុកមាព្រះសារីបុត្រ

៦. រឿងព្រាហ្មណ៍ជាក្មួយព្រះសារីបុត្រ

៧. រឿងព្រាហ្មណ៍ជាសំឡាញ់ព្រះសារីបុត្រ

៨. រឿងអាយុវឌ្ឍនកុមារ ៩. រឿងសង្កិច្ចសាមណេរ

១០. រឿងព្រះខាណុកោណ្ឌញ្ញៈ ១១. រឿងព្រះសប្បទាសៈ

១២. រឿងព្រះនាងបដាចារា ១៣. រឿងព្រះនាងកិសាគោតមី

១៤. រឿងព្រះនាងពហុបុត្តិកាថេរី


## ចប់អដ្ឋកថាខុទ្ទកនិកាយ គាថាធម្មបទ ទុតិយភាគ

# រាយនាមសប្បុរសជន
# ចូលរួមកសាងគម្ពីរអដ្ឋកថា

-លោកគ្រូអគ្គបណ្ឌិត .................................... $ 2.000 USA

-ឧបាសក តាំង សុផល ឧបាសិកា ឡុង កេង ព្រមទាំងបុត្ត និងចៅ $ 200 USA

-ឧបាសិកា តាំង ស៊ីថា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-ឧបាសិកា តាំង ដល្វា ព្រមទាំងស្វាមី និងបុត្ត ......... $ 100 USA

-កុមារី តាំង សុមាវតី ........................................ $ 100 USA

-ឧបាសិកា រួច លាង ព្រមទាំងបុត្ត ........................................ $ 100 AUS


នត្ថិ សន្តិ បរំ សុខំ
ព្រះរាជាណាចក្រកម្ពុជា